## រដ្ឋម៉ាសាឈូសិត

# ព័ត៌មានសម្រាប់ អ្នកបោះឆ្នោត

## សំណួរនៅលើសន្លឹកឆ្នោតឆ្នាំ 2026

# ការបោះឆ្នោតថ្នាក់រដ្ឋ

### ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2026

VoteInMA.com

*បោះពុម្ពដោយ*

**William Francis Galvin**

**រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ**

# រដ្ឋម៉ាសាឈូសិត

## រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ វិមានរដ្ឋ

## ទីក្រុងបូស្តុន រដ្ឋម៉ាសាឈូសិត 02133

William Francis Galvin
រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ

ជូនចំពោះអ្នកបោះឆ្នោតជាទីគោរព៖

នៅថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2026 លោកអ្នកនឹងមានឱកាសបង្ហាញឆន្ទៈរបស់ខ្លួនតាមរយៈការបោះឆ្នោត។ ប្រសិនបើលោកអ្នកមានបំណងបោះឆ្នោតមុនថ្ងៃបោះឆ្នោត លោកអ្នកអាចបោះឆ្នោតមុនកំណត់ ឬបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍បាន។ ការបោះឆ្នោតមុនកំណត់នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី 17 ដល់ថ្ងៃទី 30 ខែតុលា។ នៅថ្ងៃបោះឆ្នោត មណ្ឌលបោះឆ្នោតទាំងអស់នឹងបើកដំណើរការចាប់ពីម៉ោង 7:00 ព្រឹក រហូតដល់ម៉ោង 8:00 យប់។

ប្រសិនបើលោកអ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោត ឬបានផ្លាស់ប្តូរទីលំនៅចាប់តាំងពីការបោះឆ្នោតលើកមុនមក សូមចូលទៅកាន់ **www.VoteInMA.com** ដើម្បីចុះឈ្មោះ ពិនិត្យព័ត៌មានចុះឈ្មោះ និងធ្វើបច្ចុប្បន្នភាពអាសយដ្ឋានរបស់អ្នក។ លោកអ្នកត្រូវតែចុះឈ្មោះបោះឆ្នោតឱ្យបានត្រឹម **ថ្ងៃសៅរ៍ ទី 24 ខែតុលា** ដើម្បីចូលរួមក្នុងការបោះឆ្នោតនេះ។

នៅឆ្នាំនេះ នឹងមានសំណួរអំពីសន្លឹកឆ្នោតថ្នាក់រដ្ឋដែលមានអានុភាពចងកាតព្វកិច្ចចំនួន**ប្រាំបួន** ជាចំនួនច្រើនបំផុតមិនធ្លាប់មានដែលគេស្នើឱ្យអ្នកបោះឆ្នោតនៅរដ្ឋម៉ាសាឈូសិតពិចារណា។ សៀវភៅព័ត៌មានផ្លូវការសម្រាប់អ្នកបោះឆ្នោតឆ្នាំ 2026 នេះ មានព័ត៌មានអំពីសំណួរទាំងប្រាំបួននោះ រួមមានសេចក្តីសង្ខេបអំពីសំណើនីមួយៗ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង ឬច្បាប់ដែលមានស្រាប់ សេចក្តីពន្យល់អំពីផលប៉ះពាល់នៃការបោះឆ្នោត “យល់ព្រម” ឬ “មិនយល់ព្រម” ព្រមទាំងទឡ្ហីករណ៍សង្ខេបគាំទ្រនិងជំទាស់ចំពោះសំណួរនីមួយៗ។

ព័ត៌មាននៅក្នុងសៀវភៅនេះ នឹងជួយលោកអ្នកក្នុងការសម្រេចចិត្តគ្រប់ជ្រុងជ្រោយ មុនពេលលោកអ្នកបោះឆ្នោត។ ដោយសារសន្លឹកឆ្នោតនៅឆ្នាំនេះមានខ្លឹមសារច្រើនជាងធម្មតា លោកអ្នកអាចកត់ចំណាំ និងយកសៀវភៅនេះទៅជាមួយ ពេលលោកអ្នកទៅមណ្ឌលបោះឆ្នោត។

ជម្រើសដែលលោកអ្នកជ្រើសយកក្នុងការបោះឆ្នោតនេះ នឹងកំណត់ទិសដៅនៃការគ្រប់គ្រងរដ្ឋាភិបាលរបស់រដ្ឋ ក៏ដូចជាសហគមន៍មូលដ្ឋានរបស់យើងផងដែរ។ ខ្ញុំសូមអំពាវនាវឱ្យលោកអ្នកចូលរួមក្នុងដំណើរការនេះ ពីព្រោះសន្លឹកឆ្នោតរបស់លោកអ្នកមានសារៈសំខាន់ណាស់។

ដោយសេចក្តីគោរពដ៏ស្មោះស្ម័គ្រ !

William Francis Galvin
រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ

# តារាងមាតិកា


ជម្រើសបោះឆ្នោតឆ្នាំ 2026 របស់លោកអ្នក ..... 4

មុខតំណែងនៅលើសន្លឹកឆ្នោតឆ្នាំ 2026 ..... 5

សំណួរនៅលើសន្លឹកឆ្នោតឆ្នាំ 2026 ..... 5

ច្បាប់ស្តីពីឯកសារសាធារណៈ ..... 6

ការចរចាជាសមូហភាពសម្រាប់បុគ្គលិក CPCS ..... 8

ការបោះឆ្នោតបឋមប្រចាំរដ្ឋ ..... 10

ការចុះឈ្មោះនៅថ្ងៃបោះឆ្នោត ..... 12

ការកំណត់ និងការបង្វិលសងចំណូលពន្ធរបស់រដ្ឋ ..... 14

មូលនិធិអភិរក្សធនធានធម្មជាតិ ..... 16

លំនៅឋានគ្រួសារទោល ..... 18

ការហាមឃាត់ការលក់រាយកញ្ឆាសម្រាប់មនុស្សពេញវ័យប្រើប្រាស់កម្សាន្ត ..... 20

ការគ្រប់គ្រងអាវុធជាតិផ្ទុះ ..... 22

របាយការណ៍របស់ស្ថាប័ននីតិប្បញ្ញត្តិ ..... 24

អត្ថបទទាំងស្រុង ..... 36

ការបម្រើការងាររបស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ ..... 86


---

¡Atención! Si desea recibir este folleto en Español, llame al 617-727-2828 o al 1-800-462-VOTE (8683).

請注意！如果您希望索取本手冊的中文譯本，請致電 617-727-2828 或 1-800-462-8683 。

Chú ý! Nếu bạn muốn nhận tập sách này bằng tiếng Việt, vui lòng gọi 617-727-2828 hoặc 1-800-462-VOTE (8683)

សូមយកចិត្តទុកដាក់! ប្រសិនបើអ្នកចង់បានឯកសារនេះជាភាសាខ្មែរ សូមអ្នកទូរសព្ទទៅលេខ 617-727-2828 ឬ 1-800-462-VOTE (8683)។

# ជម្រើសបោះឆ្នោតឆ្នាំ 2026 របស់លោកអ្នក

អ្នកបោះឆ្នោតនៅរដ្ឋម៉ាសាឈូសិត អាចជ្រើសរើសវិធីបោះឆ្នោតដែលងាយស្រួលបំផុតសម្រាប់ខ្លួនឯង។

ប្រសិនបើលោកអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ លោកអ្នកអាចបោះឆ្នោតតាមវិធីដូចខាងក្រោម៖

- នៅទីតាំងបោះឆ្នោតរបស់លោកអ្នក នៅថ្ងៃទី **3 ខែវិច្ឆិកា ឆ្នាំ 2026**
- នៅទីតាំងបោះឆ្នោតមុនកំណត់ក្នុងទីក្រុង ឬតំបន់មូលដ្ឋានរបស់លោកអ្នក ចាប់ពីថ្ងៃទី **17 ដល់ 30 ខែតុលា**
- តាមសំបុត្រប្រៃសណីយ៍។

លោកអ្នកអាចជ្រើសរើសវិធីបោះឆ្នោតណាមួយក្នុងចំណោមជម្រើសខាងលើ។ មុនពេលសម្រេចចិត្ត សូមអានព័ត៌មានខាងក្រោម ដើម្បីស្វែងយល់បន្ថែមអំពីនីតិវិធីបោះឆ្នោត។

## ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត

លោកអ្នកមានមណ្ឌលបោះឆ្នោតដែលបានកំណត់ ដោយផ្អែកលើអាសយដ្ឋានរបស់លោកអ្នក។ ប្រសិនបើលោកអ្នកមិនប្រាកដថា មណ្ឌលបោះឆ្នោតរបស់លោកអ្នកស្ថិតនៅទីណានោះទេ លោកអ្នកអាចចូលទៅកាន់គេហទំព័រ **www.VoteInMA.com** ដើម្បីស្វែងរកមណ្ឌលបោះឆ្នោតរបស់លោកអ្នក។

មណ្ឌលបោះឆ្នោតនៅរដ្ឋម៉ាសាឈូសិត បើកដំណើរការចាប់ពីម៉ោង **7:00** ព្រឹក រហូតដល់ម៉ោង **8:00** យប់។ ប្រសិនបើលោកអ្នកដែលមានសិទ្ធិបោះឆ្នោត លោកអ្នកអាចបោះឆ្នោតបាន ដរាបណាលោកអ្នកស្ថិតនៅក្នុងជួររង់ចាំនៅមណ្ឌលបោះឆ្នោតរបស់ខ្លួន ត្រឹមម៉ោង 8:00 យប់។

## ការបោះឆ្នោតមុនកំណត់

ការបោះឆ្នោតមុនកំណត់ដោយផ្ទាល់ នឹងចាប់ផ្តើមនៅថ្ងៃសៅរ៍ ទី **17 ខែតុលា** និងបញ្ចប់នៅថ្ងៃសុក្រ ទី **30 ខែតុលា**។

រយៈពេលនៃការបោះឆ្នោតមុនកំណត់នេះ រាប់បញ្ចូលទាំងចុងសប្តាហ៍ចំនួនពីរ ហើយទីក្រុងនិងតំបន់មូលដ្ឋាននីមួយៗ ត្រូវកំណត់ម៉ោងសម្រាប់ការបោះឆ្នោតមុនកំណត់មួយចំនួននៅចុងសប្តាហ៍ទាំងពីរនោះ។

ទីក្រុងនិងតំបន់មូលដ្ឋាននីមួយៗ នឹងមានទីតាំងបោះឆ្នោតមុនកំណត់យ៉ាងតិចមួយកន្លែង។ ប្រសិនបើទីក្រុងនិងតំបន់មូលដ្ឋានរបស់លោកអ្នកមានទីតាំងបោះឆ្នោតមុនកំណត់ច្រើនជាងមួយកន្លែង លោកអ្នកអាចទៅបោះឆ្នោតនៅទីតាំងណាមួយក៏បាន។

ទីតាំងនិងកាលវិភាគនៃការបោះឆ្នោតមុនកំណត់ ត្រូវបានកំណត់ដោយមន្ត្រីមូលដ្ឋានក្នុងសហគមន៍របស់លោកអ្នក។ កាលវិភាគទាំងនេះនឹងត្រូវផ្សព្វផ្សាយនៅលើគេហទំព័រ **www.VoteInMA.com** មិនឱ្យយឺតជាងថ្ងៃទី 10 ខែតុលា ឆ្នាំ 2026 ឡើយ។

សូមពិនិត្យមើលកាលវិភាគរបស់សហគមន៍លោកអ្នកជាមុនសិន មុនពេលរៀបចំផែនការទៅបោះឆ្នោត។ នៅថ្ងៃសុក្រ សហគមន៍ជាច្រើនមានកំណត់ម៉ោងបោះឆ្នោតតិចតួច ឬពុំមានម៉ោងបោះឆ្នោតឡើយ។

## ការបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍

ច្បាប់របស់រដ្ឋ អនុញ្ញាតឱ្យលោកអ្នកបោះឆ្នោតតាមប្រៃសណីយ៍ ដោយមិនចាំបាច់បញ្ជាក់មូលហេតុណាមួយឡើយ។ ដើម្បីស្នើសុំសន្លឹកឆ្នោតបោះតាមប្រៃសណីយ៍ លោកអ្នកត្រូវដាក់ពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍ ទៅការិយាល័យរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់លោកអ្នក។

កាលពីដើមឆ្នាំនេះ អ្នកបោះឆ្នោតទាំងអស់ដែលបានចុះឈ្មោះរួច បានទទួលពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍ផ្លូវការសម្រាប់ឆ្នាំ 2026 តាមប្រៃសណីយ៍។ លោកអ្នកអាចប្រើពាក្យសុំនោះ ដើម្បីស្នើសុំសន្លឹកឆ្នោតរបស់លោកអ្នក ឬដាក់ពាក្យតាមអនឡាញនៅលើគេហទំព័រ **www.VoteInMA.com**។ ពាក្យស្នើសុំដែលអាចបោះពុម្ពចេញបាន ក៏មានផ្តល់ជូនផងដែរ។

យើងខ្ញុំសូមណែនាំឱ្យលោកអ្នកដាក់ពាក្យសុំឱ្យបានត្រឹម៖

- ថ្ងៃទី 13 ខែតុលា ប្រសិនបើលោកអ្នកផ្ញើពាក្យសុំតាមប្រៃសណីយ៍។
- ថ្ងៃទី 20 ខែតុលា ប្រសិនបើលោកអ្នកដាក់ពាក្យសុំតាមអនឡាញ។

ពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍របស់លោកអ្នកនឹងត្រូវបានទទួលយក ដរាបណាពាក្យស្នើសុំនោះទៅដល់ការិយាល័យរៀបចំការបោះឆ្នោតមូលដ្ឋានរបស់លោកអ្នកត្រឹមម៉ោង **5:00 ល្ងាច ថ្ងៃអង្គារ ទី 27 ខែតុលា ឆ្នាំ 2026** ប៉ុន្តែលោកអ្នកគួរតែដាក់ពាក្យសុំឱ្យបានមុនកាលកំណត់ ប្រសិនបើលោកអ្នកមានគម្រោងផ្ញើសន្លឹកឆ្នោតត្រឡប់មកវិញតាមប្រៃសណីយ៍។

លោកអ្នកអាចផ្ញើសន្លឹកឆ្នោតត្រឡប់មកវិញតាមវិធីដូចខាងក្រោម៖

- តាមសំបុត្រប្រៃសណីយ៍។
- តាមប្រអប់ទម្លាក់សន្លឹកឆ្នោតដែលមានសុវត្ថិភាព នៅក្នុងទីក្រុងឬតំបន់មូលដ្ឋានរបស់លោកអ្នក។
- ដោយយកទៅប្រគល់ផ្ទាល់នៅទីតាំងបោះឆ្នោតមុនកំណត់ នៅក្នុងទីក្រុង ឬតំបន់មូលដ្ឋានរបស់លោកអ្នក។
- ដោយយកទៅប្រគល់ផ្ទាល់នៅការិយាល័យរៀបចំការបោះឆ្នោតមូលដ្ឋានរបស់លោកអ្នក។

ប្រសិនបើលោកអ្នកមិនបានផ្ញើសន្លឹកឆ្នោតរបស់លោកអ្នកតាមប្រៃសណីយ៍ក្នុងរយៈពេលមួយសប្តាហ៍មុនថ្ងៃបោះឆ្នោតទេនោះ សូមណែនាំដោយទទូចឱ្យលោកអ្នកយកសន្លឹកឆ្នោតទៅដាក់ក្នុងប្រអប់ទម្លាក់សន្លឹកឆ្នោត ឬប្រគល់ដោយផ្ទាល់ ដើម្បីធានាថាអាចរាប់សន្លឹកឆ្នោតរបស់លោកអ្នកបាន!

### តើលោកអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយឬនៅ?

ដើម្បីជ្រើសរើសវិធីបោះឆ្នោតណាមួយក្នុងចំណោមជម្រើសទាំងនេះ ជំហានដំបូងលោកអ្នកត្រូវតែចុះឈ្មោះបោះឆ្នោតជាមុនសិន។

សូមចូលទៅកាន់គេហទំព័រ **www.VoteInMA.com** ដើម្បីពិនិត្យថាព័ត៌មានរបស់លោកអ្នកត្រូវបានធ្វើបច្ចុប្បន្នភាព ជាពិសេសប្រសិនបើលោកអ្នកបានផ្លាស់ប្តូរទីលំនៅចាប់តាំងពីការបោះឆ្នោតលើកមុនមក។

ប្រសិនបើលោកអ្នកមានបណ្ណបើកបររបស់រដ្ឋម៉ាសាឈូសិត លោកអ្នកអាចចុះឈ្មោះបោះឆ្នោត ឬធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់លោកអ្នកនៅលើគេហទំព័រដដែលនេះបាន។

ប្រសិនបើលោកអ្នកមិនមានបណ្ណបើកបររបស់រដ្ឋម៉ាសាឈូសិតទេ លោកអ្នកអាចចុះឈ្មោះបោះឆ្នោតដោយប្រើទម្រង់ក្រដាស តាមរយៈការផ្ញើតាមប្រៃសណីយ៍ ឬប្រគល់ដោយផ្ទាល់នៅការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានរបស់លោកអ្នក ឬនៅទីតាំងបោះឆ្នោតមុនកំណត់។

លោកអ្នកត្រូវតែបានចុះឈ្មោះបោះឆ្នោតត្រឹម **ថ្ងៃសៅរ៍ ទី 24 ខែតុលា ឆ្នាំ 2026 ដើម្បីអាចបោះឆ្នោតនៅក្នុងការបោះឆ្នោតនេះបាន។**

**លោកអ្នកអាចចុះឈ្មោះ៖**

- តាមអនឡាញ រហូតដល់ម៉ោង 11:59 យប់ ថ្ងៃទី 24 ខែតុលា។
- តាមប្រៃសណីយ៍ ដោយប្រើទម្រង់មានត្រាប្រៃសណីយ៍បញ្ជាក់កាលបរិច្ឆេទ ត្រឹមថ្ងៃទី 24 ខែតុលា។
- ដោយផ្ទាល់ ត្រឹមម៉ោង 5:00 ល្ងាច ថ្ងៃទី 24 ខែតុលា។

# មុខតំណែងនៅលើសន្លឹកឆ្នោតឆ្នាំ 2026

**សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក**

**អភិបាលរដ្ឋ និងអភិបាលរងរដ្ឋ**

**អគ្គរដ្ឋអាជ្ញា**

**លេខាធិការរដ្ឋ**

**ហេរញ្ញិក**

**សវនករ**

**តំណាងរាស្ត្ររដ្ឋម៉ាសាឈូសិត**

**សមាជិកក្រុមប្រឹក្**

**សមាជិកព្រឹទ្ធសភាប្រចាំរដ្ឋម៉ាសាឈូសិត**

**តំណាងរាស្ត្ររដ្ឋម៉ាសាឈូសិត**

**រដ្ឋអាជ្ញាប្រចាំតំបន់**

**ប្រធានការិយាល័យចុះបញ្ជីគ្រួសារនិងមរតក**

**ហិរញ្ញិកខោនធី**
(សម្រាប់ខោនធី Bristol, Norfolk និង Plymouth ប៉ុណ្ណោះ)

**សមាជិកក្រុមប្រឹក្សាភិបាលប្រចាំខោនធី**
(សម្រាប់ខោនធី Barnstable, Bristol, Dukes, Norfolk និង Plymouth ប៉ុណ្ណោះ)
ឬ ក្រុមប្រឹក្សាភិបាលនៃខោនធី Franklin
(សម្រាប់ខោនធី Franklin ប៉ុណ្ណោះ)។

**មន្ត្រីនគរបាលប្រចាំខោនធី**
(សម្រាប់ខោនធី Franklin ប៉ុណ្ណោះ)

# សំណួរនៅលើសន្លឹកឆ្នោតឆ្នាំ 2026

សៀវភៅនេះមានព័ត៌មានអំពីសំណួរទូទាំងរដ្ឋចំនួនប្រាំបួនសំណួរ ដែលនឹងមាននៅលើសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតថ្នាក់រដ្ឋ ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026 របស់លោកអ្នក។

**សំណួរទី 1-8** នៅលើសន្លឹកឆ្នោតរបស់លោកអ្នក គឺជាច្បាប់ដែលស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ។ អ្នកបោះឆ្នោតត្រូវបានស្នើឱ្យបោះឆ្នោតថា តើពួកគេយល់ព្រមចំពោះច្បាប់ដែលបានស្នើឡើងនេះដែរឬអត់។ ប្រសិនបើអនុម័តដោយអ្នកបោះឆ្នោត សំណើទាំងនេះនឹងក្លាយជាច្បាប់។

សម្រាប់**សំណួរទី 1-8** នៅលើសន្លឹកឆ្នោតរបស់លោកអ្នក សៀវភៅនេះមានព័ត៌មានដូចខាងក្រោម៖

- សេចក្តីសង្ខេបច្បាប់ដែលបានស្នើឡើង រៀបចំដោយអគ្គរដ្ឋអាជ្ញា។
- សេចក្តីថ្លែងការណ៍សង្ខេបដែលពិពណ៌នាអំពីផលប៉ះពាល់នៃការបោះឆ្នោត “យល់ព្រម” និងការបោះឆ្នោត “មិនយល់ព្រម” រៀបចំដោយអគ្គរដ្ឋអាជ្ញា និងរដ្ឋមន្ត្រីកិច្ចការរដ្ឋម៉ាសាឈូសិត។
- សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ដែលរៀបចំដោយរដ្ឋមន្ត្រីក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។
- ទឡ្ហីករណ៍គាំទ្រនិងជំទាស់ចំពោះច្បាប់ដែលបានស្នើឡើងនីមួយៗ រៀបចំដោយអ្នកគាំទ្រ និងអ្នកជំទាស់ចំពោះសំណួរនីមួយៗ។
- របាយការណ៍ភាគច្រើន និង/ឬរបាយការណ៍មតិភាគតិច ដែលរៀបចំដោយគណៈកម្មាធិការពិសេសនៃសភារដ្ឋម៉ាសាឈូសិត។
- អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើងនីមួយៗ។

**សំណួរទី 9** នៅលើសន្លឹកឆ្នោតរបស់លោកអ្នក គឺជាការធ្វើប្រជាមតិចំពោះច្បាប់ដែលមានមានស្រាប់។ អ្នកបោះឆ្នោតត្រូវបានសួរថាតើពួកគេយល់ព្រមលើច្បាប់ដែលមានស្រាប់នេះដែរឬអត់។ ប្រសិនបើសំឡេងភាគច្រើនបោះឆ្នោត “យល់ព្រម” ច្បាប់នេះនឹងបន្តមានសុពលភាព។ ប្រសិនបើសំឡេងភាគច្រើនបោះឆ្នោត “មិនយល់ព្រម” ច្បាប់នេះនឹងត្រូវបានលុបចោល។

សម្រាប់**សំណួរទី 9** នៅលើសន្លឹកឆ្នោតរបស់លោកអ្នក សៀវភៅនេះមានព័ត៌មានដូចខាងក្រោម៖

- សេចក្តីសង្ខេបច្បាប់ដែលមានស្រាប់ រៀបចំដោយអគ្គរដ្ឋអាជ្ញា។
- សេចក្តីថ្លែងការណ៍សង្ខេបដែលពិពណ៌នាអំពីផលប៉ះពាល់នៃការបោះឆ្នោត “យល់ព្រម” និងការបោះឆ្នោត “មិនយល់ព្រម” រៀបចំដោយអគ្គរដ្ឋអាជ្ញា និងរដ្ឋមន្ត្រីកិច្ចការរដ្ឋម៉ាសាឈូសិត។
- សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ដែលរៀបចំដោយរដ្ឋមន្ត្រីក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។
- ទឡ្ហីករណ៍គាំទ្រនិងជំទាស់ចំពោះច្បាប់ដែលមានស្រាប់ រៀបចំដោយអ្នកគាំទ្រ និងអ្នកជំទាស់ចំពោះសំណួរនេះ។
- អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់។

របាយការណ៍សំឡេងភាគច្រើន និងរបាយការណ៍សំឡេងភាគតិចរបស់ស្ថាប័ននីតិប្បញ្ញត្តិ អាចអានបាននៅទំព័រទី 24 ដល់ 35។

អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើងនីមួយៗ អាចអានបាននៅទំព័រទី 36 ដល់ 44។

អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ អាចអានបាននៅទំព័រទី 45 ដល់ 85។

សូមអានបន្ត ដើម្បីស្វែងយល់អំពីសំណួរនីមួយៗដែលលោកអ្នកនឹងឃើញនៅលើសន្លឹកឆ្នោតរបស់លោកអ្នក។

# 1

## សំណួរទី 1៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

# *ច្បាប់ស្តីពីឯកសារសាធារណៈ*

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមនេះដែលមិនត្រូវបានព្រឹទ្ធសភា ឬរដ្ឋសភាបោះឆ្នោតអនុម័ត មុនថ្ងៃទី 6 ខែឧសភា ឆ្នាំ 2026 ដែរឬទេ ?*

---

**សង្ខេប ▶**

តាមច្បាប់តម្រូវ សេចក្តីសង្ខេបនានាត្រូវបានរៀបចំដោយ អគ្គរដ្ឋអាជ្ញារដ្ឋ។

ច្បាប់ដែលបានស្នើនេះ នឹងធ្វើឱ្យឯកសារកំណត់ត្រាភាគច្រើនដែលរក្សាទុកដោយអង្គនីតិប្បញ្ញត្តិ និងការិយាល័យអភិបាលរដ្ឋ ក្លាយជាកំណត់ត្រាសាធារណៈ ស្ថិតក្រោមច្បាប់ស្តីពីកំណត់ត្រាសាធារណៈរបស់រដ្ឋម៉ាសាឈូសិត។ ច្បាប់ដែលបានស្នើនេះ នឹងលើកលែងចំពោះឯកសារនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍគោលនយោបាយសាធារណៈ និងការប្រាស្រ័យទាក់ទងគ្នារវាងសមាជិកអង្គនីតិបញ្ញត្តិ និងប្រជាពលរដ្ឋនៅក្នុងមណ្ឌលរបស់ពួកគេ  ប្រសិនបើការប្រាស្រ័យទាក់ទងទាំងនោះពាក់ព័ន្ធយ៉ាងសមស្របទៅនឹងសំណើរបស់ប្រជាពលរដ្ឋក្នុងការស្នើសុំជំនួយដើម្បីទទួលបានអត្ថប្រយោជន៍ ឬសេវាកម្មដែលផ្តល់ដោយរដ្ឋាភិបាល ឬការប្រាស្រ័យទាក់ទងជាមួយទីភ្នាក់ងាររដ្ឋាភិបាល។

---

**ឥទ្ធិពលនៃការបោះឆ្នោតរបស់លោកអ្នក ▶**

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលពិពណ៌នាអំពីឥទ្ធិពលនៃការបោះឆ្នោត “យល់ព្រម” ឬ “មិនយល់ព្រម” ត្រូវបានរៀបចំរួមគ្នាដោយអគ្គរដ្ឋអាជ្ញារដ្ឋ និងរដ្ឋមន្ត្រីកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងធ្វើឱ្យឯកសារភាគច្រើនដែលគ្រប់គ្រងដោយអង្គនីតិប្បញ្ញត្តិ និងការិយាល័យអភិបាលរដ្ឋ ក្លាយជាឯកសារសាធារណៈក្រោមច្បាប់ស្តីពីឯកសារសាធារណៈរដ្ឋម៉ាសាឈូសិត។

***ការបោះឆ្នោតជំទាស់*** នឹងធ្វើឱ្យគ្មានការផ្លាស់ប្តូរណាមួយទៅលើច្បាប់ស្តីពីឯកសារសាធារណៈរដ្ឋម៉ាសាឈូសិតនោះឡើយ។

---

**សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ▶**

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។

ច្បាប់ដែលបានស្នើនេះ ពុំមានផលប៉ះពាល់ផ្នែកសារពើពន្ធគួរឱ្យកត់សម្គាល់ណាមួយលើហិរញ្ញវត្ថុរបស់រដ្ឋ និងរដ្ឋបាលក្រុងនោះឡើយ។

---

**ទឡ្ហីករណ៍ ▶**

តាមច្បាប់តម្រូវ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកជំទាស់ទៅនឹងសំណួរនីមួយៗ ហើយបង្ហាញពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិត មិនគាំទ្រមតិយោបល់ទាំងនេះទេ ហើយក៏មិនបញ្ជាក់ ឬធានាអំពីភាពត្រឹមត្រូវ ឬពិតប្រាកដនៃសេចក្តីថ្លែងការណ៍ណាមួយដែលមាននៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះបុគ្គល និងអង្គភាពដែលបានរៀបចំទឡ្ហីករណ៍នីមួយៗ ព្រមទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់អ្នកដទៃអំពីទឡ្ហីករណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***គាំទ្រ៖***

រដ្ឋម៉ាសាឈូសិត សក្តិសមនឹងទទួលបានរដ្ឋាភិបាលបើកចំហមួយ។ ក្រុមអង្គការវាយតម្លៃរដ្ឋាភិបាលល្អ បានចាត់ចំណាត់ថ្នាក់រដ្ឋរបស់យើងថាជារដ្ឋដែលមានតម្លាភាពតិចតួចបំផុតក្នុងប្រទេស។ យើងជារដ្ឋមួយក្នុងចំណោមរដ្ឋតែពីរប៉ុណ្ណោះ ដែលទាំងការិយាល័យអភិបាលរដ្ឋ និងស្ថាប័ននីតិប្បញ្ញត្តិ អះអាងថាមានការលើកលែងទូទៅទាំងស្រុងពីច្បាប់ស្តីពីឯកសារសាធារណៈ។ ទីក្រុង តំបន់មូលដ្ឋាន និងទីភ្នាក់ងាររដ្ឋទាំងអស់ ត្រូវគោរពតាមច្បាប់នេះ ប៉ុន្តែក្រុមអ្នកនយោបាយនៅ Beacon Hill បែរជាផ្តល់ការលើកលែងសម្រាប់ខ្លួនឯងទៅវិញ។

សំណួរទី 1 នឹងដាក់ឱ្យស្ថាប័ននីតិប្បញ្ញត្តិ និងការិយាល័យអភិបាលរដ្ឋឱ្យស្ថិតក្រោមច្បាប់ស្តីពីឯកសារសាធារណៈដូចគ្នានឹងស្ថាប័នដទៃទៀតដែរ។ ច្បាប់នេះការពារឯកជនភាពរបស់ប្រជាពលរដ្ឋក្នុងមណ្ឌល ហើយរដ្ឋមន្ត្រីក្រសួងរដ្ឋបាលនិងហិរញ្ញវត្ថុ បានបញ្ជាក់ថា ពុំមានការចំណាយបន្ថែមសម្រាប់អ្នកបង់ពន្ធឡើយ។

នៅឆ្នាំ 2024 អ្នកបោះឆ្នោតចំនួន 72% បានបោះឆ្នោត “យល់ព្រម” លើការធ្វើសវនកម្មស្ថាប័ននីតិប្បញ្ញត្តិ។ Beacon Hill នៅតែជំទាស់នឹងលទ្ធផលនៃការបោះឆ្នោតនោះ ប៉ុន្តែសំណួរទី 1 នឹងផ្តល់ឱ្យលោកអ្នក និងអ្នកបង់ពន្ធគ្រប់រូប នូវសិទ្ធិទទួលបានឯកសារសាធារណៈដោយផ្ទាល់។

លោកអ្នកមានសិទ្ធិដឹងថា រដ្ឋាភិបាលរបស់លោកអ្នកកំពុងប្រើប្រាស់ប្រាក់ពន្ធដែលលោកអ្នកបានខិតខំរកដោយលំបាកនោះ ទៅលើអ្វីខ្លះ។ សូមបោះឆ្នោត “យល់ព្រម” ចំពោះសំណួរទី 1។

**រៀបរៀងដោយ៖**

**Diana DiZoglio**
**គណៈកម្មាធិការដើម្បីតម្លាភាពនិងប្រជាធិបតេយ្យ (Committee for Transparency and Democracy)**
**16 Rosewood Ave.**
**Ayer, MA 01432**
**978-984-7747**
**www.dianaforma.com/ballot**

## សំណួរទី 1៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

**ទឡ្ហីករណ៍ (គ)** ▶ ***ជំទាស់៖***

*ចាប់ពីពេលបោះពុម្ពសៀវភៅនេះមក មិនមានក្រុមដែលបានរៀបចំជាផ្លូវការណាមួយ ដែលជំរុញឱ្យបោះឆ្នោត "មិនយល់ព្រម" លើសំណួរទី 1 នោះទេ។ ព័ត៌មានខាងក្រោមនេះ ត្រូវបានប្រមូលចងក្រងដោយការិយាល័យរដ្ឋមន្ត្រីកិច្ចការរដ្ឋ ដោយផ្អែកមួយផ្នែកលើទឡ្ហីករណ៍ ដែលបានបង្ហាញនៅក្នុង របាយការណ៍សំឡេងភាគច្រើនរបស់សភារដ្ឋ។ ទឡ្ហីករណ៍ខាងក្រោមនេះ មិនមែនជាការបង្ហាញពីទស្សនៈរបស់ការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋឡើយ។*

ច្បាប់ដែលបានស្នើឡើងនេះ មានការលើកលែងដែលមានវិសាលភាពទូលំទូលាយពេក និងមិនមាននិយមន័យច្បាស់លាស់គ្រប់គ្រាន់ទេ។ ច្បាប់នេះនឹងលើកលែងការលាតត្រដាងជាសាធារណៈចំពោះឯកសារពាក់ព័ន្ធនឹងការកសាងគោលនយោបាយសាធារណៈ ប៉ុន្តែការលើកលែងនេះមានប្រសិទ្ធភាពតែក្នុងអំឡុងពេលកសាងគោលនយោបាយប៉ុណ្ណោះ។ ឯកសារទាំងនេះនឹងបើកទូលាយជាសាធារណៈ បន្ទាប់ពីតាក់តែងគោលនយោបាយរួចរាល់។ ការលើកលែងមានកម្រិតនិងបណ្តោះអាសន្ននេះ នឹងរារាំងដល់ទំនាក់ទំនងបើកចំហរបស់សមាជិកសភា បង្កក្តីបារម្ភធ្ងន់ធ្ងរផ្នែករដ្ឋធម្មនុញ្ញ ជាពិសេសទាក់ទងនឹងការការពារសិទ្ធិពាក់ព័ន្ធនឹងការថ្លែងមតិ និងការពិភាក្សារបស់ស្ថាប័ននីតិប្បញ្ញត្តិ។

ការការពារមានដែនកំណត់ចំពោះការទំនាក់ទំនងរបស់ម្ចាស់ឆ្នោតក្នុងមណ្ឌល បង្កហានិភ័យធ្ងន់ធ្ងរដល់ឯកជនភាព។ ច្បាប់នេះនឹងធ្វើឱ្យទំនាក់ទំនងទូទៅផ្សេងទៀតរបស់ម្ចាស់ឆ្នោតក្នុងមណ្ឌល ប្រឈមនឹងការលាតត្រដាងជាសាធារណៈ ដូចជា អ៊ីមែល និងលិខិតពីប្រជាពលរដ្ឋដែលសម្តែងទស្សនៈនយោបាយផ្ទាល់ខ្លួន ចែករំលែកបញ្ហារសើបនៅក្នុងមូលដ្ឋាន ឬរិះគន់សមាជិកសភា ដោយគ្រាន់តែលើកលែងចំពោះការឆ្លើយឆ្លងពាក់ព័ន្ធនឹងអត្ថប្រយោជន៍ ឬទំនាក់ទំនងជាមួយទីភ្នាក់ងាររដ្ឋប៉ុណ្ណោះ។ កង្វះការការពារឯកជនភាពគ្រប់ជ្រុងជ្រោយនេះ នឹងជះឥទ្ធិពលអវិជ្ជមានដល់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការសាធារណៈ និងអាចធ្វើឱ្យប្រជាពលរដ្ឋស្ទាក់ស្ទើរក្នុងការទាក់ទងទៅតំណាងដែលពួកគេបានបោះឆ្នោតជ្រើសរើស។

ជាចុងក្រោយ វិធានការនេះបង្កើតក្របខ័ណ្ឌខ្វះចន្លោះ ដែលមិនអាចផ្តល់ទំនួលខុសត្រូវពិតប្រាកដបាន ហើយថែមទាំងប៉ះពាល់ដល់ឯកជនភាពរបស់ម្ចាស់ឆ្នោតក្នុងមណ្ឌលទៀតផង។

**រៀបរៀងដោយ៖**
**"ប្រសិនបើរដ្ឋមន្ត្រីមិនទទួលបានទឡ្ហីករណ៍ណាមួយពីអ្នកគាំទ្រចម្បង ឬអ្នកជំទាស់ចម្បងចំពោះវិធានការណ៍ណាមួយក្នុងអំឡុងពេលដែលកំណត់ដោយមាត្រានេះទេ រដ្ឋមន្ត្រីត្រូវរៀបចំទឡ្ហីករណ៍នោះ។"**
**– M.G.L. c. 54 § 54.**

# 2

## សំណួរទី 2៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

# *ការចរចាជាសមូហភាពសម្រាប់បុគ្គលិក CPCS*

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមនេះដែលមិនត្រូវបានព្រឹទ្ធសភា ឬរដ្ឋសភាបោះឆ្នោតអនុម័ត មុនថ្ងៃទី 6 ខែឧសភា ឆ្នាំ 2026 ដែរឬទេ ?*

---

**សង្ខេប ▶**
តាមច្បាប់តម្រូវ សេចក្តីសង្ខេបនានាត្រូវបានរៀបចំដោយអគ្គរដ្ឋអាជ្ញារដ្ឋ។

ច្បាប់ដែលបានស្នើឡើងនេះ នឹងបញ្ជាក់ច្បាស់ថា និយោជិតគណៈកម្មាធិការការពារក្តីសាធារណៈ (Committee for Public Counsel Services, CPCS) ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការចរចាជាសមូហភាពជាមួយនិយោជករបស់ពួកគេបាន។ ច្បាប់នេះក៏នឹងតម្រូវឱ្យ CPCS ស្នើសុំកញ្ចប់ថវិកាសមស្របចាំបាច់ពីអភិបាលរដ្ឋ ដើម្បីផ្តល់មូលនិធិដល់កិច្ចព្រមព្រៀងនោះផងដែរ បន្ទាប់ពីបានចុះហត្ថលេខាអនុវត្តកិច្ចព្រមព្រៀងចរចាជាសមូហភាពរួច។

---

**ឥទ្ធិពលនៃការបោះឆ្នោតរបស់លោកអ្នក ▶**
តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលពិពណ៌នាអំពីឥទ្ធិពលនៃការបោះឆ្នោត "យល់ព្រម" ឬ "មិនយល់ព្រម" ត្រូវបានរៀបចំរួមគ្នាដោយអគ្គរដ្ឋអាជ្ញារដ្ឋ និងរដ្ឋមន្ត្រីកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងបញ្ជាក់ថាបុគ្គលិករបស់គណៈកម្មាធិការសេវាការពារច្បាប់សាធារណៈ (Committee for Public Counsel Services) អាចបង្កើតសហជីពដើម្បីចរចាជាសមូហភាពជាមួយនិយោជករបស់ពួកគេបាន។

***ការបោះឆ្នោតជំទាស់*** នឹងធ្វើឱ្យគ្មានការផ្លាស់ប្តូរណាមួយទៅលើច្បាប់ដែលគ្រប់គ្រងទំនាក់ទំនងការងារសម្រាប់បុគ្គលិករបស់គណៈកម្មាធិការសេវាការពារច្បាប់សាធារណៈនោះឡើយ។

---

**សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ▶**
តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។

ច្បាប់ដែលបានស្នើនេះ អាចនឹងមានផលប៉ះពាល់លើថវិការដ្ឋ។ CPCS ទទួលបានថវិកាមួយផ្នែកពីការបែងចែកកញ្ចប់ថវិការដ្ឋ។ ផលប៉ះពាល់ផ្នែកសារពើពន្ធនៃច្បាប់ដែលបានស្នើនេះ ពិបាកប៉ាន់ស្មានដោយសារតែភាពមិនច្បាស់លាស់ទាក់ទងនឹងលទ្ធផលនៃការចរចាជាសមូហភាពណាមួយដោយបុគ្គលិករបស់ CPCS។

---

**ទឡ្ហីករណ៍ ▶**
តាមច្បាប់តម្រូវ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកជំទាស់ទៅនឹងសំណួរនីមួយៗ ហើយបង្ហាញពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិត មិនគាំទ្រមតិយោបល់ទាំងនេះទេ ហើយក៏មិនបញ្ជាក់ ឬធានាអំពីភាពត្រឹមត្រូវ ឬពិតប្រាកដនៃសេចក្តីថ្លែងការណ៍ណាមួយដែលមាននៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះបុគ្គល និងអង្គភាពដែលបានរៀបចំទឡ្ហីករណ៍នីមួយៗ ព្រមទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់អ្នកដទៃអំពីទឡ្ហីករណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***គាំទ្រ៖***

ការបោះឆ្នោត "យល់ព្រម" នឹងផ្តល់សិទ្ធិដល់និយោជិតរបស់គណៈកម្មាធិការសេវាប្រឹក្សាច្បាប់សាធារណៈរដ្ឋម៉ាសាឈូសិត (Massachusetts Committee for Public Counsel Services, CPCS) ក្នុងការរៀបចំបង្កើតសហជីព និងចរចាសមូហភាពជាមួយនិយោជករបស់ពួកគេ ប្រសិនបើពួកគេជ្រើសរើសធ្វើដូច្នេះ។

និយោជិតរបស់ CPCS ផ្តល់ការគាំទ្រដ៏សំខាន់ដល់សិទ្ធិតាមរដ្ឋធម្មនុញ្ញ និងជួយធានាថា ប្រជាពលរដ្ឋរដ្ឋម៉ាសាឈូសិតដែលមិនមានលទ្ធភាពបង់ថ្លៃមេធាវី អាចទទួលបានតំណាងផ្លូវច្បាប់។ ទោះជាយ៉ាងណាក៏ដោយ ខុសពីនិយោជិតរដ្ឋផ្សេងទៀត បច្ចុប្បន្ននេះនិយោជិតរបស់ CPCS មិនមានសិទ្ធិសម្រេចថាពួកគេចង់រៀបចំបង្កើតសហជីព និងចរចាសមូហភាពអំពីប្រាក់ឈ្នួល អត្ថប្រយោជន៍ និងលក្ខខណ្ឌការងារដែរឬអត់នោះទេ។

សំណួរនៅលើសន្លឹកឆ្នោតនេះ នឹងអនុញ្ញាតឱ្យនិយោជិតរបស់ CPCS បង្កើតសហជីពបាន ប្រសិនបើពួកគេសម្រេចធ្វើដូច្នេះ។ វាគ្រាន់តែផ្តល់សិទ្ធិឱ្យនិយោជិតរបស់ CPCS ធ្វើការជ្រើសរើសនេះដោយខ្លួនឯងប៉ុណ្ណោះ។

សូមបោះឆ្នោត "យល់ព្រម" ដើម្បីផ្តល់សិទ្ធិឱ្យនិយោជិតរបស់ CPCS មានសិទ្ធិជ្រើសរើស។

**រៀបរៀងដោយ៖**
**Tom McKeever**
**សហជីពការងារសម្រាប់សិទ្ធិបុគ្គលិកសេវាប្រឹក្សាច្បាប់សាធារណៈ (Labor Unions for Public Counsel Workers Rights)**
**PO Box 9536**
**c/o North Side Ventures**
**Lowell, MA 01853**
**617-241-3300**

**ទឡ្ហីករណ៍ (ត)** ▶ ***ជំទាស់៖***

*ចាប់ពីពេលបោះពុម្ពសៀវភៅនេះមក មិនមានក្រុមដែលបានរៀបចំជាផ្លូវការណាមួយ ដែលជំរុញឱ្យបោះឆ្នោត "មិនយល់ព្រម" លើសំណួរទី 2 នោះទេ។ ព័ត៌មានខាងក្រោមនេះ ត្រូវបានប្រមូលចងក្រងដោយការិយាល័យរដ្ឋមន្ត្រីកិច្ចការរដ្ឋ ដោយផ្អែកមួយផ្អែកលើទឡ្ហីករណ៍ ដែលបានបង្ហាញនៅក្នុង របាយការណ៍សំឡេងភាគច្រើនរបស់សភារដ្ឋ។ ទឡ្ហីករណ៍ខាងក្រោមនេះ មិនមែនជាការបង្ហាញពីទស្សនៈរបស់ការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋឡើយ។*

ការអនុញ្ញាតឱ្យនិយោជិតរបស់គណៈកម្មាធិការសេវាប្រឹក្សាច្បាប់សាធារណៈ (CPCS) ធ្វើការចរចាជាសមូហភាព អាចបង្កើតហានិភ័យធ្ងន់ធ្ងរផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុសម្រាប់ស្ថាប័នតុលាការ។ CPCS ដំណើរការជាទីភ្នាក់ងារឯករាជ្យមួយនៃអំណាចតុលាការ ដែលមានភារកិច្ចផ្តល់ការការពារតាមរដ្ឋធម្មនុញ្ញដល់អតិថិជនដែលគ្មានលទ្ធភាពជួលមេធាវី។ ការដាក់បញ្ចូលការចរចាជាសមូហភាពទៅក្នុងក្របខ័ណ្ឌនេះ អាចរំខានដល់ក្របខ័ណ្ឌគ្រប់គ្រង និងត្រួតពិនិត្យដែលមានស្រាប់ បង្កើតភាពមិនច្បាស់លាស់ក្នុងខ្សែច្រវាក់អំណាច និងបណ្តាលឱ្យមានអប្រសិទ្ធភាពក្នុងប្រតិបត្តិការ។

ការផ្លាស់ប្តូរគោលនយោបាយទំនាក់ទំនងការងារទំហំបែបនេះ អាចនាំឱ្យមានផលវិបាកមិនរំពឹងទុកចំពោះការផ្តល់សេវាផ្លូវច្បាប់ ជាពិសេសប្រសិនបើការផ្លាស់ប្តូរនេះកម្រិតសមត្ថភាពរបស់ទីភ្នាក់ងារក្នុងការឆ្លើយតបដោយភាពបត់បែនទៅនឹងការប្រែប្រួលនៃបន្ទុកសំណុំរឿង តម្រូវការបុគ្គលិក និងការទាមទាររបស់តុលាការ។

**រៀបរៀងដោយ៖**
**"ប្រសិនបើរដ្ឋមន្ត្រីមិនទទួលបានទឡ្ហីករណ៍ណាមួយពីអ្នកគាំទ្រចម្បង ឬអ្នកជំទាស់ចម្បងចំពោះវិធានការណ៍ណាមួយក្នុងអំឡុងពេលដែលកំណត់ដោយមាត្រានេះទេ រដ្ឋមន្ត្រីត្រូវរៀបចំទឡ្ហីករណ៍នោះ។"**
**– M.G.L. c. 54 § 54.**

3

## សំណួរទី 3៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

# *ការបោះឆ្នោតបឋមប្រចាំរដ្ឋ*

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមនេះដែលមិនត្រូវបានព្រឹទ្ធសភា ឬរដ្ឋសភាបោះឆ្នោតអនុម័ត មុនថ្ងៃទី 6 ខែឧសភា ឆ្នាំ 2026 ដែរឬទេ ?*

**សង្ខេប ▶**

តាមច្បាប់តម្រូវ សេចក្តីសង្ខេបនានាត្រូវបានរៀបចំដោយអគ្គរដ្ឋអាជ្ញារដ្ឋ។

ច្បាប់ដែលបានស្នើនេះ នឹងលុបចោលការបោះឆ្នោតបឋមរបស់គណបក្សនយោបាយសម្រាប់ការបោះឆ្នោតថ្នាក់រដ្ឋ ហើយជំនួសមកវិញដោយការបង្កើតប្រព័ន្ធមួយដែលមានការបោះឆ្នោតបឋមរួមគ្នាតែមួយសម្រាប់គ្រប់គណបក្សទាំងអស់ ដោយនៅក្នុងនោះ បេក្ខជនទាំងអស់ ទោះបីជាមកពីគណបក្សណាក៏ដោយ នឹងត្រូវមានឈ្មោះនៅលើសន្លឹកឆ្នោតតែមួយ ហើយអ្នកបោះឆ្នោតអាចបោះឆ្នោតជូនបេក្ខជនណាម្នាក់នៅលើសន្លឹកឆ្នោតនោះបាន។ បេក្ខជនពីររូបដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេនៅក្នុងការបោះឆ្នោតបឋម នឹងមានឈ្មោះលើសន្លឹកឆ្នោតនៃការបោះឆ្នោតសកល។

ច្បាប់ដែលបានស្នើនេះ នឹងតម្រូវឱ្យបេក្ខជនសម្រាប់តំណែងអភិបាលរដ្ឋ និងអភិបាលរងរដ្ឋ ឈរឈ្មោះ និងចុះបញ្ជីឈ្មោះរួមគ្នានៅលើសន្លឹកឆ្នោតក្នុងការបោះឆ្នោតបឋម។

ច្បាប់ដែលបានស្នើនេះ នឹងផ្តល់ឋានៈគណបក្សនយោបាយដល់ក្រុមណាមួយ ដែលមានបេក្ខជនឈរឈ្មោះសម្រាប់តំណែងណាមួយទូទាំងរដ្ឋ ទទួលបានសំឡេងឆ្នោតយ៉ាងហោច 3% នៃសន្លឹកឆ្នោតដែលបានបោះនៅក្នុងការបោះឆ្នោតបឋមរបស់រដ្ឋ។

**ឥទ្ធិពលនៃការបោះឆ្នោតរបស់លោកអ្នក ▶**

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលពិពណ៌នាអំពីឥទ្ធិពលនៃការបោះឆ្នោត "យល់ព្រម" ឬ "មិនយល់ព្រម" ត្រូវបានរៀបចំរួមគ្នាដោយអគ្គរដ្ឋអាជ្ញារដ្ឋ និងរដ្ឋមន្ត្រីកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងលុបចោលការបោះឆ្នោតបឋមដាច់ដោយឡែកតាមគណបក្សសម្រាប់ការបោះឆ្នោតប្រចាំរដ្ឋ ហើយតម្រូវឱ្យមានការបោះឆ្នោតបឋមតែមួយគត់ ដែលបេក្ខជនទាំងអស់មានឈ្មោះនៅលើសន្លឹកឆ្នោតតែមួយ ដោយអ្នកបោះឆ្នោតអាចបោះឆ្នោតឱ្យបេក្ខជនណាក៏បាន ហើយបេក្ខជនពីររូបដែលទទួលបានសំឡេងគាំទ្រខ្ពស់ជាងគេ នឹងត្រូវឡើងទៅកាន់ការបោះឆ្នោតសកល។

***ការបោះឆ្នោតជំទាស់*** នឹងធ្វើឱ្យគ្មានការផ្លាស់ប្តូរណាមួយទៅលើច្បាប់គ្រប់គ្រងការបោះឆ្នោតបឋមនោះឡើយ។

**សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ▶**

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។

ច្បាប់ដែលបានស្នើនេះ ពុំមានផលប៉ះពាល់ផ្នែកសារពើពន្ធគួរឱ្យកត់សម្គាល់ណាមួយលើហិរញ្ញវត្ថុរបស់រដ្ឋ និងរដ្ឋបាលក្រុងនោះឡើយ។

**ទឡ្ហីករណ៍ ▶**

តាមច្បាប់តម្រូវ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកជំទាស់ទៅនឹងសំណួរនីមួយៗ ហើយបង្ហាញពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិត មិនគាំទ្រមតិយោបល់ទាំងនេះទេ ហើយក៏មិនបញ្ជាក់ ឬធានាអំពីភាពត្រឹមត្រូវ ឬពិតប្រាកដនៃសេចក្តីថ្លែងការណ៍ណាមួយដែលមាននៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះបុគ្គល និងអង្គភាពដែលបានរៀបចំទឡ្ហីករណ៍នីមួយៗ ព្រមទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់អ្នកដទៃអំពីទឡ្ហីករណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***គាំទ្រ៖***

មន្ត្រីជាប់ឆ្នោតនៅរដ្ឋម៉ាសាឈូសិត គួរតែធ្វើការដើម្បីពួកយើង មិនមែនដើម្បីក្រុមអ្នកមានអំណាចឥទ្ធិពលខាងក្នុងនោះទេ។ ប៉ុន្តែរយៈពេលជាច្រើនឆ្នាំមកហើយ ក្រុមអ្នកមានឥទ្ធិពលខាងក្នុងតែងតែមានប្រៀប។ ការបោះឆ្នោតជាច្រើនត្រូវបានសម្រេចរួចទៅហើយ មុនពេលពួកយើងជាប្រជាពលរដ្ឋភាគច្រើនបានទៅបោះឆ្នោត។ បេក្ខជនអាចត្រូវបានរារាំងមិនឱ្យឈរឈ្មោះ តាមរយៈសន្និបាតរបស់គណបក្ស។ បច្ចុប្បន្នសមាជិកសភាពីរភាគបីកំពុងឈរឈ្មោះដោយគ្មានគូប្រកួត។ ពួកគេអាចមើលស្រាលអ្នកបោះឆ្នោត និងមិនយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗដូចជា លំនៅឋានតម្លៃសមរម្យ ថ្លៃថាមពល ការអប់រំមានគុណភាពប្រសើរជាងមុន និងសវនកម្មដែលប្រជាពលរដ្ឋ 72% បានទាមទារ។

ការបោះឆ្នោតបឋមបើកចំហសម្រាប់បេក្ខជនគ្រប់គណបក្ស នឹងនាំមកនូវគណនេយ្យភាព និងតម្លាភាពក្នុងនយោបាយរដ្ឋម៉ាសាឈូសិត ដោយធ្វើឱ្យការបោះឆ្នោតមានភាពប្រកួតប្រជែងកាន់តែខ្លាំង និងបង្ខំឱ្យអ្នកនយោបាយស្តាប់ប្រជាពលរដ្ឋ។ បេក្ខជនទាំងអស់នឹងមានឈ្មោះនៅលើសន្លឹកឆ្នោតបឋមរបស់លោកអ្នក ហើយបេក្ខជនពីរនាក់ដែលទទួលបានសំឡេងគាំទ្រច្រើនជាងគេ នឹងឈានទៅការបោះឆ្នោតក្នុងខែវិច្ឆិកា ដែលពួកគេត្រូវការសំឡេងភាគច្រើនដើម្បីឈ្នះ។ ក្រុមអ្នកមានឥទ្ធិពលខាងក្នុងនឹងមានការគ្រប់គ្រងតិចជាងមុន ហើយយើងនឹងមានបេក្ខជនថ្មីៗចូលរួមឈរឈ្មោះជ្រើសតាំង។

ការប្រកួតប្រជែងកាន់តែច្រើន មានន័យថាគណនេយ្យភាពកាន់តែខ្ពស់។ សមាជិកសភាដែលដឹងថាអ្នកបោះឆ្នោតអាចជំនួសពួកគេបាន នឹងស្តាប់ប្រជាពលរដ្ឋ និងផ្តល់លទ្ធផលជាក់ស្តែង។

សូមបោះឆ្នោត "យល់ព្រម" លើសំណួរទី 3 ដើម្បីលើកកម្ពស់គណនេយ្យភាព និងការប្រកួតប្រជែង។

**រៀបរៀងដោយ៖**
**Danielle Allen**
**សម្ព័ន្ធដើម្បីប្រជាធិបតេយ្យប្រកបដោយសុចរិតភាព (Coalition for Healthy Democracy)**
**124 Washington St., Suite 101**
**Foxborough, MA 02035**
**617-987-4192**

## សំណួរទី 3៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

**ទឡ្ហីករណ៍ (គ)** ▶ ***ជំទាស់៖***

***សូមបោះឆ្នោត "មិនយល់ព្រម" លើសំណួរទី 3***

ប្រព័ន្ធបោះឆ្នោតជ្រើសយកបេក្ខជនកំពូលពីររូប ដូចដែលអនុវត្តនៅរដ្ឋកាលីហ្វ័រញ៉ា និងរដ្ឋវ៉ាស៊ីនតោន បានផ្តល់ផលប្រយោជន៍ដល់បេក្ខជនមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងមានមូលនិធិផ្ទាល់ខ្លួន ដែលអាចចំណាយថវិកាផ្សព្វផ្សាយឃោសនាលើសបេក្ខជនផ្សេងទៀត ព្រមទាំងគណៈកម្មាធិការសកម្មភាពនយោបាយសាជីវកម្ម (PAC) ដែលព្យាយាមប្រើប្រាស់ថវិកាដើម្បីទិញមុខតំណែង ខណៈដែលបេក្ខជនមកពីមូលដ្ឋាន និងក្រុមដែលធ្លាប់ត្រូវបានមើលរំលង និងមានតំណាងតិចតួចជាប្រវត្តិសាស្ត្រ ដូចជា បេក្ខជនមិនមែនជនស្បែកស និងស្ត្រី ត្រូវបានរុញច្រានឱ្យនៅក្រៅការប្រកួត។ បេក្ខជនពីគណបក្សទីបី និងបេក្ខជនឯករាជ្យ នឹងត្រូវបានផាត់ចេញពីការបោះឆ្នោតទូទៅ ហើយបេក្ខជនមកពីវណ្ណៈកម្មករ ក៏នឹងបាត់បង់ការគាំទ្រពីស្ថាប័ន និងលទ្ធភាពទទួលបានធនធានរបស់គណបក្សផងដែរ។

សំណើនេះនឹងកម្រិតជម្រើសរបស់អ្នកបោះឆ្នោត ដោយអនុញ្ញាតឱ្យមានតែបេក្ខជនពីររូបប៉ុណ្ណោះឈានទៅការបោះឆ្នោតក្នុងខែវិច្ឆិកា ទោះបីជាពួកគេទាំងពីរស្ថិតក្នុងគណបក្សតែមួយក៏ដោយ ដែលនាំឱ្យកាត់បន្ថយការប្រកួតប្រជែង បន្ថយការចូលរួមរបស់អ្នកបោះឆ្នោត បង្កើនវិសមភាពធ្ងន់ធ្ងរ និងបង្រួមការជជែកពិភាក្សាលើគោលនយោបាយ។

អ្នកបោះឆ្នោតនៅរដ្ឋម៉ាសាឈូសិត សមនឹងទទួលបានជម្រើសពិតប្រាកដ មិនមែនប្រព័ន្ធដែលលម្អៀងទៅរកអំណាចទឹកប្រាក់ និងប្រជាប្រិយភាពជាជាងការគាំទ្រពីសហគមន៍នោះទេ។ សូមបោះឆ្នោត "មិនយល់ព្រម"។

**រៀបរៀងដោយ៖**

**Vanessa A. Snow**
**អង្គការសិទ្ធិអ្នកបោះឆ្នោតរដ្ឋម៉ាសាឈូសិត (Voter Rights MA)**
**P.O. Box 317**
**Roslindale, MA 02131**
**617-383-4336**
**www.voterrightsma.com**

# 4

## សំណួរទី 4៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

# *ការចុះឈ្មោះនៅថ្ងៃបោះឆ្នោត*

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមនេះដែលមិនត្រូវបានព្រឹទ្ធសភា ឬរដ្ឋសភាបោះឆ្នោតអនុម័ត មុនថ្ងៃទី 6 ខែឧសភា ឆ្នាំ 2026 ដែរឬទេ ?*

**សង្ខេប** ▶
តាមច្បាប់តម្រូវ សេចក្តីសង្ខេបនានាត្រូវបានរៀបចំដោយអគ្គរដ្ឋអាជ្ញារដ្ឋ។

ច្បាប់ដែលបានស្នើនេះ នឹងអនុញ្ញាតឱ្យបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ អាចចុះឈ្មោះបោះឆ្នោត ឬធ្វើបច្ចុប្បន្នភាពអាសយដ្ឋានចុះឈ្មោះបោះឆ្នោតរបស់ពួកគេនៅថ្ងៃបោះឆ្នោតបាន។

បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការបោះឆ្នោត អាចចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោតបាន ដោយគ្រាន់តែទៅកាន់ការិយាល័យបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតដែលពួកគេរស់នៅក្នុងអំឡុងម៉ោងបោះឆ្នោត រួចបង្ហាញភស្តុតាងបញ្ជាក់ទីលំនៅ និងចុះហត្ថលេខាលើលិខិតសច្ចាប្រណិធានជាលាយលក្ខណ៍អក្សរ។ ភស្តុតាងបញ្ជាក់ទីលំនៅអាចជាអត្តសញ្ញាណប័ណ្ណមានរូបថតត្រឹមត្រូវ ឬជាឯកសារផ្លូវការនានាដែលបង្ហាញពីឈ្មោះរបស់បុគ្គលនោះ និងអាសយដ្ឋានដែលបុគ្គលនោះកំពុងរស់នៅ ដូចជា វិក្កយបត្រសេវាសាធារណៈបច្ចុប្បន្ន របាយការណ៍គណនីធនាគារ មូលប្បទានបត្រពីរដ្ឋាភិបាល កិច្ចសន្យាជួលលំនៅឋាន វិក្កយបត្រទូរសព្ទចល័ត មូលប្បទានប័ណ្ណប្រាក់បៀវត្សរ៍ វិក្កយបត្របង់ថ្លៃសិក្សាបច្ចុប្បន្ន ឬឯកសារផ្សេងទៀតដែលចេញដោយគ្រឹះស្ថានឧត្តមសិក្សា ឬឯកសារនិងលិខិតឆ្លើយឆ្លងផ្លូវការផ្សេងទៀតពីរដ្ឋាភិបាល។ លិខិតសច្ចាប្រណិធានជាលាយលក្ខណ៍អក្សរនោះ នឹងតម្រូវឱ្យបុគ្គលម្នាក់ៗបញ្ជាក់អះអាងថា ខ្លួនគឺជាពលរដ្ឋសហរដ្ឋអាមេរិក មានអាយុយ៉ាងហោចណាស់ 18 ឆ្នាំ មិនត្រូវបានហាមឃាត់មិនឱ្យបោះឆ្នោតតាមផ្លូវច្បាប់ និងមិនធ្លាប់បានបោះឆ្នោត ហើយនឹងមិនទៅបោះឆ្នោតនៅក្នុងការបោះឆ្នោតដដែលនេះនៅទីតាំងផ្សេងទៀតនោះទេ។ លិខិតសច្ចាប្រណិធាននេះ ក៏នឹងតម្រូវឱ្យបុគ្គលនោះទទួលស្គាល់ផងដែរថា ការផ្តល់ព័ត៌មានមិនពិត គឺជាបទឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមិនលើសពី 5 ឆ្នាំ ឬពិន័យជាប្រាក់មិនលើសពី 10,000 ដុល្លារ ឬត្រូវអនុវត្តទណ្ឌកម្មទាំងពីរនេះរួមគ្នា។

ប្រសិនបើបុគ្គលណាម្នាក់មិនបានបង្ហាញភស្តុតាងបញ្ជាក់ទីលំនៅទេ ពួកគេនឹងត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន ដែលសន្លឹកឆ្នោតនោះនឹងត្រូវយកមករាប់ លុះត្រាតែបុគ្គលនោះត្រឡប់មកផ្តល់ព័ត៌មានចាំបាច់មុនពេលបិទការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតថ្នាក់ក្រុង ក្នុងរយៈពេលពីរថ្ងៃបន្ទាប់ពីការបោះឆ្នោតបឋមរបស់រដ្ឋ ឬក្នុងរយៈពេលប្រាំមួយថ្ងៃបន្ទាប់ពីការបោះឆ្នោតថ្នាក់រដ្ឋប៉ុណ្ណោះ។

បុគ្គលទាំងឡាយដែលចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោតផ្ទាល់ នឹងត្រូវចាត់ទុកថាបានចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតនាពេលអនាគត ព្រមទាំងសម្រាប់ការបោះឆ្នោតដែលប្រព្រឹត្តទៅនៅថ្ងៃនោះផងដែរ។

បុគ្គលទាំងឡាយណាដែលបានចុះឈ្មោះបោះឆ្នោតរួចរាល់ហើយ នឹងមិនអាចផ្លាស់ប្តូរការចូលរួមជាមួយគណបក្សនយោបាយរបស់ពួកគេនៅថ្ងៃបោះឆ្នោតបានឡើយ។

ច្បាប់ដែលបានស្នើនេះ នឹងចូលជាធរមាននៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2028។

---

**ឥទ្ធិពលនៃការបោះឆ្នោតរបស់លោកអ្នក** ▶
តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលពិពណ៌នាអំពីឥទ្ធិពលនៃការបោះឆ្នោត "យល់ព្រម" ឬ "មិនយល់ព្រម" ត្រូវបានរៀបចំរួមគ្នាដោយអគ្គរដ្ឋអាជ្ញារដ្ឋ និងរដ្ឋមន្ត្រីកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងអនុញ្ញាតឱ្យពលរដ្ឋដែលមានសិទ្ធិអាចចុះឈ្មោះបោះឆ្នោត ឬធ្វើបច្ចុប្បន្នភាពអាសយដ្ឋានចុះឈ្មោះបោះឆ្នោតរបស់ពួកគេនៅមណ្ឌលបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត។

***ការបោះឆ្នោតជំទាស់*** នឹងធ្វើឱ្យគ្មានការផ្លាស់ប្តូរណាមួយទៅលើច្បាប់គ្រប់គ្រងការចុះឈ្មោះបោះឆ្នោតនោះឡើយ។

---

**សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ** ▶
តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។

ច្បាប់ដែលបានស្នើនេះ ពុំមានផលប៉ះពាល់ផ្នែកសារពើពន្ធគួរឱ្យកត់សម្គាល់ណាមួយលើហិរញ្ញវត្ថុរបស់រដ្ឋ និងរដ្ឋបាលក្រុងនោះឡើយ។

**ទឡ្ហីករណ៍ ▶**

តាមច្បាប់តម្រូវ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកជំទាស់ទៅនឹងសំណួរនីមួយៗ ហើយបង្ហាញពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិត មិនគាំទ្រមតិយោបល់ទាំងនេះទេ ហើយក៏មិនបញ្ជាក់ ឬធានាអំពីភាពត្រឹមត្រូវ ឬពិតប្រាកដនៃសេចក្តីថ្លែងការណ៍ណាមួយដែលមាននៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះបុគ្គល និងអង្គភាពដែលបានរៀបចំទឡ្ហីករណ៍នីមួយៗ ព្រមទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់អ្នកដទៃអំពីទឡ្ហីករណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***គាំទ្រ៖***

ការបោះឆ្នោតគាំទ្រការចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោត នឹងធានាថាប្រជាធិបតេយ្យរបស់យើងពិតជាតំណាងឱ្យប្រជាពលរដ្ឋ មានសុវត្ថិភាព និងទាន់សម័យ។

ច្បាប់នេះនឹងផ្តល់ឱ្យពលរដ្ឋរដ្ឋម៉ាសាឈូសិតដែលមានសិទ្ធិបោះឆ្នោត អាចចុះឈ្មោះបោះឆ្នោត ឬកែប្រែអាសយដ្ឋានរបស់ខ្លួននៅថ្ងៃបោះឆ្នោតបាន ជាឱកាសមួយដែលអ្នកបោះឆ្នោតនៅរដ្ឋផ្សេងៗទាំងអស់ក្នុងតំបន់ New England មានរួចទៅហើយ។

ការអនុញ្ញាតឱ្យអ្នកបោះឆ្នោតចុះឈ្មោះនៅកន្លែងបោះឆ្នោត នឹងផ្តល់ឱកាសឱ្យពលរដ្ឋរាប់ពាន់នាក់បានចូលរួមក្នុងការបោះឆ្នោតជាតិសំខាន់ៗ។ គោលនយោបាយនេះមានប្រយោជន៍ជាពិសេសសម្រាប់អ្នកដែលផ្លាស់ទីលំនៅញឹកញាប់ ដូចជា យុវជន និងអ្នកជួលផ្ទះជាដើម។

សំខាន់ជាងនេះទៅទៀត ការចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោត នឹងជួយពង្រឹងសុវត្ថិភាពការបោះឆ្នោត។ អ្នកចុះឈ្មោះនៅថ្ងៃបោះឆ្នោត ត្រូវតែបង្ហាញឯកសារបញ្ជាក់ទីលំនៅដែលអាចផ្ទៀងផ្ទាត់បាននៅកន្លែងបោះឆ្នោត និងចុះហត្ថលេខាលើលិខិតសច្ចាប្រណិធានដែលមានចែងពីការផ្តន្ទាទោសព្រហ្មទណ្ឌធ្ងន់ធ្ងរ ដើម្បីធានាគណនេយ្យភាព និងទប់ស្កាត់ការក្លែងបន្លំ។ ប្រសិនបើឯកសារមិនគ្រប់គ្រាន់ អ្នកបោះឆ្នោតអាចប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន ដើម្បីការពារសុចរិតភាពនៃដំណើរការបោះឆ្នោត។

ច្បាប់នេះផ្តល់លទ្ធភាពឱ្យអ្នកបោះឆ្នោតចូលរួមបានយ៉ាងទូលំទូលាយ ព្រមជាមួយនឹងវិធានការការពារសុវត្ថិភាពយ៉ាងតឹងរ៉ឹង។ នេះជាកំណែទម្រង់ប្រកបដោយសុភវិនិច្ឆ័យ ដែលធានាថា សំឡេងរបស់ពលរដ្ឋគ្រប់រូបដែលមានសិទ្ធិបោះឆ្នោត នឹងត្រូវបានដឹងឮ។

**រៀបរៀងដោយ៖**

**Norma B. Shulman**
**អង្គការគាំទ្រការចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោត (YES on Election Day Registration)**
**444 Washington St.**
**Brighton, MA 02135**
**www.electiondayvoterregistration.com**

***ជំទាស់៖***

សុខុមាលភាពសាធារណៈ ទាមទារឱ្យការពារការបោះឆ្នោតពីការក្លែងបន្លំ។ ការចុះឈ្មោះបោះឆ្នោតនៅថ្ងៃតែមួយ អាចប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ដោយលុបបំបាត់រយៈពេលកំណត់ទុកមុន ដែលមន្ត្រីរៀបចំការបោះឆ្នោតប្រើប្រាស់ដើម្បីពិនិត្យអត្តសញ្ញាណ ទីលំនៅ សិទ្ធិបោះឆ្នោត ឬការចុះឈ្មោះស្ទួនរបស់អ្នកចុះឈ្មោះ មុននឹងប្រគល់សន្លឹកឆ្នោតជូន។

ផ្ទុយទៅវិញ មន្ត្រីបោះឆ្នោតនឹងត្រូវធ្វើការកំណត់ទាំងនេះនៅកន្លែងបោះឆ្នោត ក្រោមសម្ពាធពេលវេលាធ្ងន់ធ្ងរ និងក្នុងអំឡុងពេលមានការងារមមាញឹកខ្លាំងនៅថ្ងៃបោះឆ្នោត។ កំហុស ការអះអាងមិនពិត ឬឯកសារខុសគ្នា ដែលផុតមិនមានការពិនិត្យ មិនអាចរកឃើញនោះទេ រហូតទាល់តែសន្លឹកឆ្នោតត្រូវបានបោះរួច និងច្របល់បញ្ចូលគ្នាជាមួយសន្លឹកឆ្នោតផ្សេងៗទៀត ហើយនៅពេលនោះ គេមិនអាចកំណត់អត្តសញ្ញាណ ឬដកសន្លឹកឆ្នោតនោះចេញបានតទៅទៀតឡើយ។

សន្តិសុខនៃការបោះឆ្នោត ពឹងផ្អែកលើការផ្ទៀងផ្ទាត់ដែលមានប្រសិទ្ធភាព មុនពេលអនុញ្ញាតឱ្យធ្វើការបោះឆ្នោត។ សំណួរនៅលើសន្លឹកឆ្នោតនេះ នឹងជំនួសការពិនិត្យផ្ទៀងផ្ទាត់ជាមុនដោយការសម្រេចចិត្តយ៉ាងប្រញាប់ប្រញាល់នៅថ្ងៃបោះឆ្នោត ដែលអាចបង្កើតចំណុចខ្សោយដែលអាចជៀសវាងបានក្នុងការគ្រប់គ្រងការបោះឆ្នោត បង្កើនហានិភ័យថាសន្លឹកឆ្នោតមិនស្របច្បាប់អាចមានឥទ្ធិពលលើការប្រកួតប្រជែងដែលមានលទ្ធផលប្រកៀកប្រកិត និងធ្វើឱ្យចុះខ្សោយដល់ទំនុកចិត្តដែលថា សន្លឹកឆ្នោតនីមួយៗត្រូវបានបោះដោយស្របច្បាប់ក្នុងការបោះឆ្នោតរបស់យើង។ សូមបោះឆ្នោត "មិនយល់ព្រម"។

**រៀបរៀងដោយ៖**

**Amy Carnevale**
**គណបក្សសាធារណរដ្ឋ រដ្ឋម៉ាសាឈូសិត (Massachusetts Republican Party)**
**85 Merrimac St., Suite 505**
**Boston, MA 02114**
**www.massgop.com**

# 5

## សំណួរទី 5៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

# *ការកំណត់ និងការបង្វិលសងចំណូលពន្ធរបស់រដ្ឋ*

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមនេះដែលមិនត្រូវបានព្រឹទ្ធសភា ឬរដ្ឋសភាបោះឆ្នោតអនុម័ត មុនថ្ងៃទី 6 ខែឧសភា ឆ្នាំ 2026 ដែរឬទេ ?*

---

**សង្ខេប** ▶

តាមច្បាប់តម្រូវ សេចក្តីសង្ខេបនានាត្រូវបានរៀបចំដោយអគ្គរដ្ឋអាជ្ញារដ្ឋ។

ច្បាប់ដែលបានស្នើនេះ នឹងផ្លាស់ប្តូរដែនកំណត់នៃចំនួនចំណូលដែលរដ្ឋអាចប្រមូលបានក្នុងឆ្នាំនីមួយៗ។ សំណើនេះនឹងកំណត់កម្រិតចំណូលរដ្ឋក្នុងឆ្នាំនីមួយៗ ត្រឹមចំនួនចំណូលសុទ្ធរបស់រដ្ឋកាលពីឆ្នាំមុន ដោយកើនឡើងតាមអត្រាមួយដែលស្មើនឹងកំណើនមធ្យមនៃប្រាក់ឈ្នួល និងប្រាក់បៀវត្សរ៍នៅក្នុងរដ្ឋម៉ាសាឈូសិត ក្នុងរយៈពេលបីឆ្នាំចុងក្រោយបំផុត។ ប្រសិនបើចំណូលដែលរដ្ឋប្រមូលបានក្នុងឆ្នាំនីមួយៗមានចំនួនលើសពីដែនកំណត់ នោះចំនួនដែលលើសនឹងត្រូវបង្វិលសងទៅអ្នកបង់ពន្ធវិញនៅឆ្នាំបន្ទាប់។ ច្បាប់ដែលបានស្នើឡើងនេះ នឹងរួមបញ្ចូលរាល់ចំណូលទាំងអស់ដែលបានមកពីការហូតពន្ធបន្ថែមលើប្រាក់ចំណូលដែលលើសពី 1 លានដុល្លារ នៅពេលគណនាដែនកំណត់ចំណូល និងនៅពេលកំណត់ថាតើចំណូលរដ្ឋមានចំនួនលើសពីដែនកំណត់ដែរឬទេ។

បញ្ញត្តិទាំងអស់នៃច្បាប់ដែលបានស្នើឡើងនេះ នឹងចូលជាធរមានចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2027 តទៅ។

ច្បាប់ដែលបានស្នើឡើងនេះចែងថា ប្រសិនបើផ្នែកណាមួយនៃច្បាប់នេះត្រូវបានប្រកាសថាមិនមានសុពលភាព ផ្នែកផ្សេងទៀតនឹងនៅតែមានសុពលភាពអនុវត្តដដែល។

---

**ឥទ្ធិពលនៃការបោះឆ្នោតរបស់លោកអ្នក** ▶

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលពិពណ៌នាអំពីឥទ្ធិពលនៃការបោះឆ្នោត "យល់ព្រម" ឬ "មិនយល់ព្រម" ត្រូវបានរៀបចំរួមគ្នាដោយអគ្គរដ្ឋអាជ្ញារដ្ឋ និងរដ្ឋមន្ត្រីកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងផ្លាស់ប្តូរការកំណត់លើការប្រមូលចំណូលពន្ធរបស់រដ្ឋ ដោយគណនាផ្អែកតាមចំណូលពន្ធដែលប្រមូលបានកាលពីឆ្នាំមុន បូកនឹងកំណើនប្រាក់ឈ្នួល និងប្រាក់បៀវត្សរ៍ជាមធ្យម ហើយនឹងផ្តល់នូវការបង្វិលសងចំណូលដែលលើសពីកម្រិតកំណត់នោះវិញ។

***ការបោះឆ្នោតជំទាស់*** នឹងធ្វើឱ្យគ្មានការផ្លាស់ប្តូរណាមួយទៅលើច្បាប់ទាក់ទងនឹងការប្រមូលចំណូលពន្ធរដ្ឋនោះឡើយ។

---

**សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ** ▶

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។

ច្បាប់ដែលបានស្នើនេះ នឹងដាក់កំហិតកាន់តែតឹងរ៉ឹងលើកំណើនចំណូលប្រចាំឆ្នាំដែលអាចអនុញ្ញាតបាន សម្រាប់យកទៅរៀបចំកញ្ចប់ថវិកា។ ជាលទ្ធផល សំណើច្បាប់នេះ នឹងកាត់បន្ថយចំនួនទឹកប្រាក់ដែលអាចរកបានសម្រាប់គាំទ្រដល់ថវិការដ្ឋ ដែលរួមមានទាំងជំនួយមូលដ្ឋានសម្រាប់សាលារៀន និងកញ្ចប់ថវិការបស់រដ្ឋបាលក្រុងផង។ សំណើច្បាប់នេះ ក៏នឹងកាត់បន្ថយចំនួនទឹកប្រាក់ដែលអាចរកបាន ដើម្បីកសាងមូលនិធិស្ថិរភាពរបស់រដ្ឋ ឬហៅថា "មូលនិធិសម្រាប់គ្រាមានអាសន្ន" ដែលជាប្រាក់បម្រុងទុកសម្រាប់ជួយរដ្ឋម៉ាសាឈូសិត គ្រប់គ្រងស្ថានភាពធ្លាក់ចុះផ្នែកសេដ្ឋកិច្ច ឬគ្រាអាសន្ននានា ដោយមិនចាំបាច់ដំឡើងពន្ធ ឬកាត់បន្ថយការចំណាយធំៗនោះឡើយ។ ផ្អែកតាមលក្ខខណ្ឌនៅថ្ងៃអនាគត សំណើច្បាប់នេះអាចនឹងផ្លាស់ប្តូរភាពញឹកញាប់នៃការបង្វិលសងប្រាក់ពន្ធជាកាតព្វកិច្ចផ្លូវច្បាប់ជូនដល់អ្នកជាប់ពន្ធ។

---

**ទឡ្ហីករណ៍** ▶

តាមច្បាប់តម្រូវ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកជំទាស់ទៅនឹងសំណួរនីមួយៗ ហើយបង្ហាញពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិត មិនគាំទ្រមតិយោបល់ទាំងនេះទេ ហើយក៏មិនបញ្ជាក់ ឬធានាអំពីភាពត្រឹមត្រូវ ឬពិតប្រាកដនៃសេចក្តីថ្លែងការណ៍ណាមួយដែលមាននៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះបុគ្គល និងអង្គភាពដែលបានរៀបចំទឡ្ហីករណ៍នីមួយៗ ព្រមទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់អ្នកដទៃអំពីទឡ្ហីករណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***គាំទ្រ៖***

ការបោះឆ្នោត "**យល់ព្រម**" នឹងដាក់កម្រិតសមស្របលើកំណើនចំណូលរបស់រដ្ឋ និងធានាថា អ្នកបង់ពន្ធនឹងទទួលបានការសងប្រាក់វិញ នៅពេលរដ្ឋម៉ាសាឈូសិតប្រមូលចំណូលបានលើសពីអ្វីដែលរដ្ឋត្រូវការ។

សំណើនេះនឹងធ្វើទំនើបកម្មច្បាប់ដែលមានស្រាប់របស់រដ្ឋ ដើម្បីបង្កើតវិធានការវិន័យហិរញ្ញវត្ថុកាន់តែរឹងមាំ លើកកម្ពស់គណនេយ្យភាព ការពារការដំឡើងពន្ធនាពេលអនាគត និងធានាថា កំណើននៃការចំណាយរបស់រដ្ឋ គឺស្របតាមអ្វីដែលអ្នកបង់ពន្ធអាចលៃលកបាន។ សំណើនេះនឹង <u>មិន</u> កាត់បន្ថយការចំណាយរបស់រដ្ឋលើសេវាសំខាន់ៗ ដូចជា ការអប់រំ ការដឹកជញ្ជូន ឬការថែទាំសុខភាពនោះទេ។

គ្រួសារជាច្រើននៅរដ្ឋម៉ាសាឈូសិត កំពុងប្រឈមនឹងការកើនឡើងនៃថ្លៃលំនៅឋាន គ្រឿងឧបភោគបរិភោគ និងការថែទាំកុមារ។ នៅពេលរដ្ឋប្រមូលចំណូលបានលើសពីតម្រូវការ អ្នកបង់ពន្ធសមនឹងទទួលបានប្រាក់នោះត្រឡប់មកវិញ ជាជាងបណ្តោយឱ្យដាក់បញ្ចូលថវិកាទៅក្នុងថវិការដ្ឋដែលកំពុងកើនឡើងលឿនជាងអត្រាអតិផរណា។

ខណៈដែលរដ្ឋម៉ាសាឈូសិតនៅតែបន្តបាត់បង់ប្រជាពលរដ្ឋទៅកាន់រដ្ឋដែលមានការចំណាយលើការរស់នៅទាបជាង សំណួរនៅលើសន្លឹកឆ្នោតនេះផ្តល់អាទិភាពដល់អ្នកបង់ពន្ធ។ ការបោះឆ្នោត "**យល់ព្រម**" មានន័យថា លោកអ្នកនឹងអាចរក្សាទុកប្រាក់ដែលលោកអ្នកខិតខំរកបានដោយខ្លួនឯងកាន់តែច្រើន ហើយធ្វើឱ្យរដ្ឋម៉ាសាឈូសិតក្លាយជាកន្លែងដែលមានតម្លៃសមរម្យជាងមុនសម្រាប់ការរស់នៅ ការធ្វើការ និងការចិញ្ចឹមគ្រួសារ។

**រៀបរៀងដោយ៖**
**សម្ព័ន្ធអ្នកបង់ពន្ធដើម្បីរដ្ឋម៉ាសាឈូសិតដែលមានតម្លៃរស់នៅសមរម្យ (Taxpayers for an Affordable Massachusetts)**
**P.O. Box 9536**
**Lowell, MA 01853**
**www.affordablema.org**

**ទឡ្ហីករណ៍ (ត)** ▶ ***ជំទាស់៖***

សូមបោះឆ្នោត "**មិនយល់ព្រម**" លើសំណួរទី 5 ដើម្បីការពារសាលារៀនរដ្ឋ សេវាថែទាំសុខភាព និងសុវត្ថិភាពសាធារណៈ។

សំណួរទី 5 នឹងដាក់កម្រិតតឹងរ៉ឹងលើចំណូល និងការវិនិយោគរបស់រដ្ឋ ដែលនឹងបង្ខំឱ្យមាន**ការកាត់បន្ថយថវិកាម្តងហើយម្តងទៀត**។ ថ្លៃថែទាំសុខភាពនឹងកើនឡើង ហើយទីក្រុង និងតំបន់មូលដ្ឋាននានា នឹងត្រូវ**បង្កើនពន្ធលើអចលនទ្រព្យ ឬបញ្ឈប់គ្រូបង្រៀន និងអ្នកពន្លត់អគ្គិភ័យ**។

សំណួរទី 5 នឹងកាត់បន្ថយមូលនិធិបម្រុងគ្រាមានអាសន្ន (Rainy Day) របស់រដ្ឋ ដែលនឹងបង្ខំឱ្យមាន**ការកាត់បន្ថយថវិកាច្រើនសន្ធឹកសន្ធាប់ចំពោះសាលារៀន សេវាថែទាំសុខភាព លំនៅឋានតម្លៃសមរម្យ និងសុវត្ថិភាពសាធារណៈ**ក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ច ជាពេលដែលការចំណាយដើម្បីបង្កើតការងារ និងគាំទ្រប្រជាពលរដ្ឋមានសារៈសំខាន់បំផុត។

សំណួរទី 5 នឹងរួមបញ្ចូលចំណូលពី "ពន្ធលើមហាសេដ្ឋី" ដែលផ្តល់ថវិកាសម្រាប់សាលារៀន និងការដឹកជញ្ជូនទៅក្នុងរូបមន្តស្មុគស្មាញ និងមិនអាចព្យាករណ៍បាន ដែលកំណត់កម្រិតចំណូលរបស់រដ្ឋ។ **ក្រុមមហាសេដ្ឋីនឹងទទួលបានការបង្វិលសងពន្ធជាញឹកញាប់** ខណៈដែលពួកយើងទាំងអស់គ្នានឹងត្រូវទទួលបន្ទុកចំណាយនោះ។

សំណួរទី 5 ថែមទាំងអាចគំរាមកំហែងដល់ចំណាត់ថ្នាក់ឥណទានរបស់រដ្ឋម៉ាសាឈូសិត **ដែលនឹងធ្វើឱ្យថ្លៃជួសជុលស្ពាន និងសាលារៀនកាន់តែខ្ពស់ឡើង**។

មហាសេដ្ឋីប្រាក់លានដែលផ្តល់ការគាំទ្រដល់សំណួរទី 5 មិនចាំបាច់ពឹងផ្អែកលើសេវាសាធារណៈទាំងនេះសម្រាប់ខ្លួនឯងនោះទេ។ **សូមបោះឆ្នោត "មិនយល់ព្រម" លើសំណួរទី 5**។

**រៀបរៀងដោយ៖**
**Colette Berard គ្រូប្រវត្តិវិទ្យា**
**សាលា Andover Public Schools**
**អង្គការការពារអនាគតរបស់រដ្ឋម៉ាសាឈូសិត (Protect Massachusetts' Future)**
**P.O. Box 15**
**Boston, MA 02137**
**617-857-7793**
**www.protectmassachusettsfuture.com**

# 6

## សំណួរទី 6៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

# មូលនិធិអភិរក្សធនធានធម្មជាតិ

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមនេះដែលមិនត្រូវបានព្រឹទ្ធសភា ឬរដ្ឋសភាបោះឆ្នោតអនុម័ត មុនថ្ងៃទី 6 ខែឧសភា ឆ្នាំ 2026 ដែរឬទេ ?*

**សង្ខេប** ▶
តាមច្បាប់តម្រូវ សេចក្តីសង្ខេបនានាត្រូវបានរៀបចំដោយអគ្គរដ្ឋអាជ្ញារដ្ឋ។

ច្បាប់ដែលបានស្នើនេះ នឹងបង្កើតមូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នា (Nature for All Fund) នឹងទទួលបាន 50% នៃពន្ធរដ្ឋដែលប្រមូលបានពីការលក់និងប្រើប្រាស់សម្ភារៈកីឡា យានយន្តកម្សាន្ត និងទីលានវាយកូនហ្គោល សម្រាប់ឆ្នាំដំបូងនៃប្រតិបត្តិការរបស់ខ្លួន អាស្រ័យលើការបែងចែកថវិកាពីស្ថាប័ននីតិប្បញ្ញត្តិ។ បន្ទាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2028 តទៅ មូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នានេះ នឹងចាប់ផ្តើមទទួលបាន 100% នៃពន្ធរដ្ឋដែលប្រមូលបានលើការលក់ និងប្រើប្រាស់សម្ភារកីឡា យានយន្តកម្សាន្ត និងទីលានវាយកូនហ្គោល អាស្រ័យលើការបែងចែកថវិកាពីស្ថាប័ននីតិប្បញ្ញត្តិ។ ចំណូលពន្ធពីការលក់ដែលទទួលបានដោយមូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នានេះ នឹងមិនរាប់បញ្ចូលនូវចំណូលពន្ធពីការលក់ដែលផ្ទេរទៅមូលនិធិរួមចំណែកថ្នាក់រដ្ឋនិងថ្នាក់មូលដ្ឋាននៃអាជ្ញាធរដឹកជញ្ជូនឈូងសមុទ្ររដ្ឋម៉ាសាឈូសិត (Massachusetts Bay Transportation Authority State and Local Contribution Fund) និងមូលនិធិក្នុងភារៈគ្រប់គ្រងសម្រាប់ការធ្វើទំនើបកម្ម និងការសាងសង់សាលារៀនឡើងវិញ (School Modernization and Reconstruction Trust Fund) នោះឡើយ។ ច្បាប់ដែលបានស្នើឡើងនេះ នឹងអនុញ្ញាតឱ្យការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថានរបស់រដ្ឋ (Executive Office of Energy and Environmental Affairs) អាចប្រើប្រាស់ថវិកានៅក្នុងមូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នា សម្រាប់ការអភិរក្សធនធានធម្មជាតិបាន។

ច្បាប់ដែលបានស្នើឡើងនេះ នឹងអនុញ្ញាតឱ្យមានការបរិច្ចាគពីសាធារណជននិងឯកជន ដល់មូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នា។ ច្បាប់ដែលបានស្នើនេះ នឹងរារាំងប្រធានគណនេយ្យរដ្ឋមិនឱ្យផ្ទេរថវិកានៅសល់ក្នុងមូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នា នៅដំណាច់ឆ្នាំសារពើពន្ធឡើយ។ ច្បាប់នេះក៏នឹងអនុញ្ញាតឱ្យស្ថាប័នរដ្ឋ រដ្ឋបាលក្រុង អង្គការសប្បុរសធម៌សាធារណៈដែលពាក់ព័ន្ធនឹងការអភិរក្សធនធានធម្មជាតិ រដ្ឋាភិបាលកុលសម្ព័ន្ធ និងអង្គភាពសាធារណៈថ្នាក់តំបន់ផ្សេងទៀត អាចទទួលបានថវិកាពីមូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នានេះផងដែរ។

ការអភិរក្សធនធានធម្មជាតិ នឹងរួមបញ្ចូលទាំងការអភិរក្ស ឬ ការស្តារដីធ្លីឡើងវិញ ដើម្បីការពារទឹកពិសា ស្ទឹង ទន្លេ បឹងបួរ ឆ្នេរសមុទ្រ កសិដ្ឋាន ព្រៃឈើ ការតភ្ជាប់គ្នារវាងទីវាលលំហ ព្រមទាំងដីធ្លីនិងធនធានធម្មជាតិដែលមានសារៈសំខាន់ខាងផ្នែកវប្បធម៌ជនជាតិដើមភាគតិច។ ការអភិរក្សធនធានធម្មជាតិ ក៏នឹងរួមបញ្ចូលទាំងការបង្កើត ការកែលម្អ និងការគ្រប់គ្រងឧទ្យាន ផ្លូវដើរកម្សាន្ត លំហបៃតង ឬលទ្ធភាពទទួលបានការកម្សាន្តក្រៅផ្ទះផងដែរ។

ច្បាប់ដែលបានស្នើនេះ នឹងបង្កើតក្រុមប្រឹក្សាធម្មជាតិសម្រាប់ទាំងអស់គ្នា (Nature for All Board) ដែលមានសមាជិកចំនួន 15 រូប រួមមាន មន្ត្រីរដ្ឋចំនួន 5 រូប និងសមាជិកសាធារណជនចំនួន 10 រូបដែលតែងតាំងដោយអភិបាលរដ្ឋ។ ច្បាប់ដែលបានស្នើនេះ នឹងតម្រូវឱ្យសមាជិកសាធារណជនទាំង 10 រូប រួមបញ្ចូលទាំងតំណាងសហគមន៍ជួបការលំបាក និងជនជាតិដើមភាគតិច ព្រមទាំងយ៉ាងហោចណាស់មានបុគ្គលម្នាក់ដែលមានជំនាញ ឬបទពិសោធក្នុងការអភិរក្សធនធានធម្មជាតិ។ ច្បាប់ដែលបានស្នើនេះ នឹងអនុញ្ញាតឱ្យការិយាល័យប្រតិបត្តិកិច្ចការថាមពល និងបរិស្ថានរបស់រដ្ឋ អាចប្រើប្រាស់ថវិកានៅក្នុងមូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នា ដើម្បីជួលបុគ្គលិកគ្រប់គ្រងមូលនិធិនេះបាន។ ច្បាប់ដែលបានស្នើនេះ ក៏នឹងតម្រូវឱ្យក្រុមប្រឹក្សាធម្មជាតិសម្រាប់ទាំងអស់គ្នា បង្កើតវិធានស្តីពីរបៀបប្រើប្រាស់ថវិកានៅក្នុងមូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នាផងដែរ ដោយរួមបញ្ចូលទាំងវិធានពាក់ព័ន្ធនឹងការអនុលោមតាមគោលការណ៍យុត្តិធម៌បរិស្ថាន លទ្ធភាពទទួលបាន និងការស្តារឡើងវិញនូវដីធ្លីនិងធនធានធម្មជាតិដែលមានសារៈសំខាន់ខាងផ្នែកវប្បធម៌ជនជាតិដើមភាគតិច ការលើកកម្ពស់ការអភិវឌ្ឍលំនៅឋានមានតម្លៃសមរម្យ ព្រមទាំងកិច្ចការផ្សេងទៀតទាក់ទងនឹងការចំណាយ និងការបោះផ្សាយសញ្ញាប័ណ្ណ។

ច្បាប់ដែលបានស្នើនេះ នឹងតម្រូវឱ្យការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថានរបស់រដ្ឋ ដាក់ជូនរបាយការណ៍ប្រចាំឆ្នាំទៅកាន់គណៈកម្មាធិការរដ្ឋផ្សេងៗ ទាក់ទងនឹងថវិកាដែលបានចំណាយដើម្បីទិញ ឬកែលម្អដីធ្លីនៅក្នុងបណ្តាក្រុងនិងស្រុកនានា ដែលមានក្រុមប្រជាជនគោលដៅនៃយុត្តិធម៌បរិស្ថាន។

ច្បាប់ដែលបានស្នើនេះ នឹងចូលជាធរមាននៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2027។

**ឥទ្ធិពលនៃការបោះឆ្នោតរបស់លោកអ្នក** ▶
តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលពិពណ៌នាអំពីឥទ្ធិពលនៃការបោះឆ្នោត "យល់ព្រម" ឬ "មិនយល់ព្រម" ត្រូវបានរៀបចំរួមគ្នាដោយអគ្គរដ្ឋអាជ្ញារដ្ឋ និងរដ្ឋមន្ត្រីកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងបង្កើតមូលនិធិមួយដែលអាចប្រើប្រាស់សម្រាប់ការអភិរក្សធនធានធម្មជាតិ ដែលនឹងទទួលបានចំណូលពន្ធរដ្ឋមួយចំនួនដែលប្រមូលបានពីការលក់និងប្រើប្រាស់សម្ភារៈកីឡា យានជំនិះកម្សាន្ត និងការប្រើប្រាស់ទីលានវាយកូនហ្គោល។

***ការបោះឆ្នោតជំទាស់*** នឹងមិនបង្កើតមូលនិធិអភិរក្សធនធានធម្មជាតិនេះ ឬផ្លាស់ប្តូររបៀបចំណាយប្រាក់ពន្ធលើការលក់និងប្រើប្រាស់នោះទេ។

## សំណួរទី 6៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

**សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ** ▶

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។

ច្បាប់ដែលបានស្នើនេះ នឹងមានផលប៉ះពាល់យ៉ាងខ្លាំងលើកញ្ចប់ថវិការដ្ឋ និងមូលដ្ឋាន។ ទោះបីជាការវិភាគសារពើពន្ធពេញលេញមិនអាចគណនាបានក៏ដោយ ក៏គេប៉ាន់ប្រមាណថា គិតជាប្រចាំឆ្នាំ ច្បាប់ដែលបានស្នើនេះនឹងបង្វែរដោយស្វ័យប្រវត្តិនូវចំណូលពន្ធរាប់សិបលានដុល្លារ ដែលបច្ចុប្បន្នកំពុងគាំទ្រដល់កញ្ចប់ថវិកាដំណើរការរបស់រដ្ឋ ទៅកាន់មូលនិធិថ្មីវិញ។ ច្បាប់ដែលបានស្នើនេះ ក៏នឹងមានការចំណាយខ្ពស់លើការអនុវត្តផងដែរ។

---

**ទឡ្ហីករណ៍** ▶ ***គាំទ្រ៖***

តាមច្បាប់តម្រូវ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកជំទាស់ទៅនឹងសំណួរនីមួយៗ ហើយបង្ហាញពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិត មិនគាំទ្រមតិយោបល់ទាំងនេះទេ ហើយក៏មិនបញ្ជាក់ ឬធានាអំពីភាពត្រឹមត្រូវ ឬពិតប្រាកដនៃសេចក្តីថ្លែងការណ៍ណាមួយដែលមាននៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះបុគ្គល និងអង្គភាពដែលបានរៀបចំទឡ្ហីករណ៍នីមួយៗ ព្រមទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់អ្នកដទៃអំពីទឡ្ហីករណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

យើងទាំងអស់គ្នាសុទ្ធតែត្រូវការទឹកស្អាត និងបរិស្ថានធម្មជាតិ។ ការបោះឆ្នោត **"យល់ព្រម"** លើសំណួរទី 6 **គឺការពារទឹក ដី និងសត្វព្រៃនៅរដ្ឋម៉ាសាឈូសិត ដោយមិនបង្កើនពន្ធឡើយ។**

ការបោះឆ្នោត **"យល់ព្រម"** នឹងបែងចែកថវិការហូតដល់ 100 លានដុល្លារក្នុងមួយឆ្នាំ ដើម្បី

- ការពារទឹកស្អាតទទួលទាន
- កាត់បន្ថយការបំពុលក្នុងទន្លេ បឹង និងមហាសមុទ្រ
- អភិរក្សព្រៃឈើ កសិដ្ឋានគ្រួសារ និងជម្រកធម្មជាតិរបស់សត្វព្រៃ
- ការពារទឹកជំនន់ និងការខូចខាតពីខ្យល់ព្យុះ
- បង្កើត និងកែលម្អសួនសាធារណៈ ផ្លូវដើរ តំបន់បៃតង និងទីធ្លាធម្មជាតិសម្រាប់សាធារណជនប្រើប្រាស់។

**សំណួរទី 6 មិនបង្កើនពន្ធ ឬបង្កើតពន្ធថ្មីទេ។** សំណើរនេះបម្រុងទុកប្រាក់ពន្ធលក់លើសម្ភារកីឡាដែលយើងបង់រួចហើយ ទៅលើការពារទឹក និងធម្មជាតិ ហើយតម្រូវឱ្យមាន**ការត្រួតពិនិត្យយ៉ាងតឹងរ៉ឹង និងការរាយការណ៍ប្រចាំឆ្នាំ** ដើម្បីឱ្យយើងអាចដឹងថា ថវិកាត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច។

រដ្ឋម៉ាសាឈូសិត ជាទីជម្រកនៃតំបន់ធម្មជាតិដ៏ស្រស់ស្អាត និងប្រភេទសត្វចម្រុះជាច្រើន ដូចជា បក្សាបក្សី ត្រី និងសត្វដទៃទៀត។ ហេតុនេះហើយបានជា អង្គការអភិរក្សធម្មជាតិក្នុងតំបន់ និងអាជីវកម្មជាង 90 ស្ថាប័ន គាំទ្រ**ការបោះឆ្នោត "យល់ព្រម" លើសំណួរទី 6 ដើម្បីការពារជាអចិន្ត្រៃយ៍នូវទន្លេ បឹងបួរ ព្រៃឈើ កសិដ្ឋាន និងជម្រកសត្វព្រៃរបស់យើង** សម្រាប់ឱ្យមនុស្សជំនាន់ក្រោយបានរីករាយ។

**អង្គការអភិរក្សធម្មជាតិ និងសត្វព្រៃនៅរដ្ឋម៉ាសាឈូសេត (Mass Audubon)**
**208 S. Great Rd.**
**Lincoln, MA 01773**
**617-682-9926**
**www.natureforma.org**

***ជំទាស់៖***

*ចាប់ពីពេលបោះពុម្ពសៀវភៅនេះមក មិនមានក្រុមដែលបានរៀបចំជាផ្លូវការណាមួយ ដែលជំរុញឱ្យបោះឆ្នោត "មិនយល់ព្រម" លើសំណួរទី 6 នោះទេ។ ព័ត៌មានខាងក្រោមនេះ ត្រូវបានប្រមូលចងក្រងដោយការិយាល័យរដ្ឋមន្ត្រីកិច្ចការរដ្ឋ ដោយផ្អែកមួយផ្នែកលើទឡ្ហីករណ៍ ដែលបានបង្ហាញនៅក្នុង របាយការណ៍សំឡេងភាគច្រើនរបស់សភារដ្ឋ។ ទឡ្ហីករណ៍ខាងក្រោមនេះ មិនមែនជាការបង្ហាញពីទស្សនៈរបស់ការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋឡើយ។*

ច្បាប់ដែលបានស្នើឡើងនេះ បង្កើតក្របខណ្ឌហិរញ្ញវត្ថុដែលមិនមានស្ថិរភាព ដោយកំណត់ជាអចិន្ត្រៃយ៍ឱ្យចំណូល ពន្ធលក់របស់រដ្ឋរហូតដល់ 100% ពីការលក់សម្ភារៈកីឡា យានយន្តកម្សាន្ត និងទីលានវាយកូនហ្គោល។ សំណើនេះនឹងពឹងផ្អែកលើប្រភពចំណូលដែលមានស្រាប់របស់រដ្ឋដែលបច្ចុប្បន្នត្រូវបានបែងចែកសម្រាប់កម្មវិធី និងអាទិភាពផ្សេងៗដែលកំពុងដំណើរការ។ ការអនុវត្តវិធានការនេះ នឹងតម្រូវឱ្យមានការបែងចែកថវិកាឡើងវិញ ឬកាត់បន្ថយមូលនិធិដែលបច្ចុប្បន្នកំពុងត្រូវបានប្រើប្រាស់សម្រាប់គំនិតផ្តួចផ្តើមផ្សេងៗរបស់រដ្ឋ ដែលបង្កើតឱ្យមានសំណួរអំពីតម្លៃនៃឱកាស និងការផ្លាស់ប្តូរដែលអាចកើតមានឡើងចំពោះអាទិភាពមូលនិធិហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានដែលមានស្រាប់។

ទោះបីជាអ្នកបោះឆ្នោតយល់ព្រមក៏ដោយ ក៏ថវិកាទាំងនេះអាចនឹងមិនត្រូវបានបែងចែកទៅក្នុង "មូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នា (Nature for All Fund)" នោះទេ ព្រោះសភារដ្ឋនៅតែរក្សាសិទ្ធិអំណាចផ្តាច់មុខលើការសម្រេចចិត្តអំពីការបែងចែកថវិកាដដែល។ ក្របខ័ណ្ឌរដ្ឋធម្មនុញ្ញនេះធានាថា ការសម្រេចចិត្តអំពីការផ្តល់មូលនិធិ នៅតែស្ថិតក្រោមការពិភាក្សាថវិកាប្រចាំឆ្នាំ និងការកំណត់អាទិភាពផ្នែកហិរញ្ញវត្ថុ។

ដូចបានរៀបរៀង ច្បាប់ដែលបានស្នើឡើងនេះ បង្កើតសំណួរនានាពាក់ព័ន្ធនឹង ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ការជំនួស ឬប៉ះពាល់ដល់កម្មវិធីដែលមានស្រាប់ និងការកំណត់លទ្ធភាពបត់បែនក្នុងការគ្រប់គ្រង។

**រៀបរៀងដោយ៖**
**"ប្រសិនបើរដ្ឋមន្ត្រីមិនទទួលបានទឡ្ហីករណ៍ណាមួយពីអ្នកគាំទ្រចម្បង ឬអ្នកជំទាស់ចម្បងចំពោះវិធានការណ៍ណាមួយក្នុងអំឡុងពេលដែលកំណត់ដោយមាត្រានេះទេ រដ្ឋមន្ត្រីត្រូវរៀបចំទឡ្ហីករណ៍នោះ។"**
**– M.G.L. c. 54 § 54.**

7

## សំណួរទី 7៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

# *លំនៅឋានគ្រួសារទោល*

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមនេះដែលមិនត្រូវបានព្រឹទ្ធសភា ឬរដ្ឋសភាបោះឆ្នោតអនុម័ត មុនថ្ងៃទី 6 ខែឧសភា ឆ្នាំ 2026 ដែរឬទេ ?*

**សង្ខេប ▶**

តាមច្បាប់តម្រូវ សេចក្តីសង្ខេបនានាត្រូវបានរៀបចំដោយអគ្គរដ្ឋអាជ្ញារដ្ឋ។

ច្បាប់ដែលបានស្នើឡើងនេះ នឹងអនុញ្ញាតឱ្យសាងសង់លំនៅដ្ឋានគ្រួសារទោល នៅក្នុងតំបន់ដែលត្រូវបានកំណត់សម្រាប់លំនៅឋានបាន ដរាបណាដីដែលត្រូវសាងសង់នោះមានទំហំយ៉ាងហោចណាស់ 5,000 ហ្វីតការ៉េ មានប្រវែងដីយ៉ាងតិច 50 ហ្វីត មានព្រំទល់ជាប់នឹងផ្លូវ ផ្លូវថ្នល់ ឬផ្លូវសាធារណៈដែលផ្ទះនោះបែរមុខទៅរក និងមានប្រព័ន្ធតភ្ជាប់ទៅនឹងបណ្តាញលូនិងសេវាទឹកស្អាតសាធារណៈ។

ច្បាប់ដែលបានស្នើឡើងនេះ នឹងអនុញ្ញាតឱ្យបណ្តាក្រុងនិងស្រុកនានាកំណត់លក្ខខណ្ឌបច្ចេកទេសសមស្របមួយចំនួននៃលំនៅឋានគ្រួសារទោល រួមមាន កម្ពស់ផ្ទះ គម្លាតពីអគារជិតខាង ទីវាលលំហ លក្ខខណ្ឌតម្រូវសម្រាប់ការចតយានយន្ត និងលទ្ធភាពអនុញ្ញាតឱ្យជួលផ្ទះនោះក្នុងរយៈពេលខ្លី។ ច្បាប់ដែលបានស្នើឡើងនេះ ក៏នឹងអនុញ្ញាតឱ្យការិយាល័យប្រតិបត្តិនៃលំនៅឋាននិងសហគមន៍សមស្របសម្រាប់ការរស់នៅ (Executive Office of Housing and Livable Communities) អាចចេញគោលការណ៍ណែនាំ ឬបទបញ្ញត្តិផ្សេងៗ ដើម្បីចាត់ចែងអនុវត្តច្បាប់ដែលបានស្នើឡើងនេះផងដែរ។

**ឥទ្ធិពលនៃការបោះឆ្នោតរបស់លោកអ្នក ▶**

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលពិពណ៌នាអំពីឥទ្ធិពលនៃការបោះឆ្នោត “យល់ព្រម” ឬ “មិនយល់ព្រម” ត្រូវបានរៀបចំរួមគ្នាដោយអគ្គរដ្ឋអាជ្ញារដ្ឋ និងរដ្ឋមន្ត្រីកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងអនុញ្ញាតឱ្យសាងសង់លំនៅឋានគ្រួសារទោលនៅលើផ្ទៃដីទំហំ 5,000 ហ្វីតការ៉េ ឬធំជាងនេះ ក្នុងតំបន់លំនៅឋានដោយអនុលោមតាមបទប្បញ្ញត្តិមូលដ្ឋានសមស្របលើលក្ខណៈមួយចំនួននៃលំនៅឋានទាំងនោះ។

***ការបោះឆ្នោតជំទាស់*** នឹងធ្វើឱ្យគ្មានការផ្លាស់ប្តូរណាមួយទៅលើច្បាប់ទាក់ទងនឹងការសាងសង់លំនៅឋានគ្រួសារទោលនោះឡើយ។

**សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ▶**

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។

ប្រសិនបើច្បាប់ដែលបានស្នើនេះ ធ្វើឱ្យមានកំណើនលំនៅឋាននៅក្នុងសហគមន៍ វាអាចនឹងផ្តល់ចំណូលថ្មីៗជាវិជ្ជមានដល់រដ្ឋបាលក្រុង។ ទោះជាយ៉ាងណាក៏ដោយ ការប៉ាន់ស្មាន ពីទំហំសក្តានុពលនៃកំណើនថ្មីៗពាក់ព័ន្ធនឹងច្បាប់ដែលបានស្នើនេះ ពិតជាពិបាកណាស់។ ដូច្នេះ ច្បាប់ដែលបានស្នើនេះ ពុំមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុជាដុំកំភួនជាក់លាក់ណាមួយលើថវិការដ្ឋ និងរដ្ឋបាលក្រុងនោះឡើយ។

**ទឡ្ហីករណ៍ ▶**

តាមច្បាប់តម្រូវ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកជំទាស់ទៅនឹងសំណួរនីមួយៗ ហើយបង្ហាញពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិត មិនគាំទ្រមតិយោបល់ទាំងនេះទេ ហើយក៏មិនបញ្ជាក់ ឬធានាអំពីភាពត្រឹមត្រូវ ឬពិតប្រាកដនៃសេចក្តីថ្លែងការណ៍ណាមួយដែលមាននៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះបុគ្គល និងអង្គភាពដែលបានរៀបចំទឡ្ហីករណ៍នីមួយៗ ព្រមទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់អ្នកដទៃអំពីទឡ្ហីករណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***គាំទ្រ៖***

រដ្ឋម៉ាសាឈូសិត គឺជារដ្ឋដែលពិបាកបំផុតនៅក្នុងប្រទេសសម្រាប់មនុស្សវ័យក្មេងក្នុងការទិញផ្ទះ។ វណ្ណៈកណ្តាលកំពុងថយចុះ ដោយសារតម្លៃលំនៅឋានបានកើនឡើងទ្វេដងចាប់តាំងពីឆ្នាំ 2014 មក។ មនុស្សវ័យចំណាស់ជាច្រើនកំពុងជាប់នៅក្នុងផ្ទះរបស់ខ្លួន ដោយមិនមានជម្រើសលំនៅឋានសមស្របជាងនៅក្បែរនោះសម្រាប់ផ្លាស់ប្តូរទៅរស់នៅទីនោះឡើយ។

ប្រជាពលរដ្ឋរដ្ឋម៉ាសាឈូសិត ជាពិសេសយុវជន កំពុងចាកចេញពីរដ្ឋដើម្បីស្វែងរកកន្លែងរស់នៅតម្លៃសមរម្យជាងមុន បំបែកគ្រួសារដែលមានសាច់ញាតិច្រើនជំនាន់ និងប៉ះពាល់ដល់សេដ្ឋកិច្ចរបស់យើង។

ការទាមទារឱ្យមានទំហំដីឡូត៍ធំខ្លាំងសម្រាប់ការសាងសង់លំនៅឋានគ្រួសារទោល ធ្វើឱ្យផ្ទះមានតម្លៃថ្លៃ កាត់បន្ថយការសាងសង់លំនៅឋានថ្មីប្រភេទនេះ និងជំរុញឱ្យអ្នកអភិវឌ្ឍន៍សាងសង់ផ្ទះធំៗ (McMansions) ដើម្បីទទួលបានថ្លៃដីខ្ពស់។ មនុស្សគ្រប់រូបដែលត្រូវការលំនៅដ្ឋានគ្រួសារទោលតម្លៃធូរថ្លៃនៅតាមជាយក្រុង ស្ទើរតែគ្មានលទ្ធភាពឈានជើងចូលទីផ្សារបានឡើយ។

ការបោះឆ្នោត “យល់ព្រម” នឹងកាត់បន្ថយតម្រូវការទំហំដីឡូត៍អប្បបរមាត្រឹម 5000 ហ្វីតការ៉េ ដែលជាទំហំសមស្រប និងទូទៅជាងនៅតំបន់ជាយក្រុងទូទាំងប្រទេសនៅតំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដើម្បីឱ្យយើងអាចមានលំនៅឋានតម្លៃសមរម្យជាងមុន សម្រាប់គ្រួសារវ័យក្មេង និងមនុស្សវ័យចំណាស់រស់នៅ។

**រៀបរៀងដោយ៖**
**Wesley Lima**
**សម្ព័ន្ធធ្វើឱ្យផ្ទះដំបូងស្របច្បាប់ (Legalize Starter Homes)**
**P.O. Box 9536**
**Lowell, MA 01853**
**617-506-9464**
**Legalizestarterhomes.com**

# សំណួរទី 7៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

**ទឡ្ហីករណ៍ (ត)** ▶ ***ជំទាស់៖***

សូមបោះឆ្នោត “មិនយល់ព្រម” លើសំណួរទី 7។

រដ្ឋម៉ាសាឈូសិតត្រូវការលំនៅឋានបន្ថែមទៀត ប៉ុន្តែវិធានការលើសន្លឹកឆ្នោតទូទាំងរដ្ឋនេះ មិនមែនជាវិធីសាស្ត្រត្រឹមត្រូវនោះទេ។ វានឹងបដិសេធការរៀបចំផែនការនៅមូលដ្ឋាន ដោយតម្រូវឱ្យទីក្រុងនិងតំបន់មូលដ្ឋានទាំងអស់ អនុញ្ញាតឱ្យសាងសង់លំនៅឋានគ្រួសារទោលនៅលើដីឡូត៍ដែលមានទំហំតូចរហូតដល់ 5000 ហ្វីតការ៉េ ដោយមិនគិតពីសង្កាត់ដែលមានស្រាប់ ហេដ្ឋារចនាសម្ព័ន្ធ ឬលក្ខខណ្ឌបរិស្ថានឡើយ។

មន្ត្រីមូលដ្ឋានមានទំនួលខុសត្រូវដោយផ្ទាល់ចំពោះអ្នកបង់ពន្ធ ហើយសំណើនេះនឹងដកចេញនូវការត្រួតពិនិត្យសំខាន់ៗដែលពួកគេអនុវត្តក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន។ ពួកគេយល់ដឹងពីសហគមន៍របស់ខ្លួនបានល្អបំផុត ហើយធ្វើការជាមួយប្រជាពលរដ្ឋដើម្បីរៀបចំផែនការលំនៅឋាន ដែលក្នុងពេលជាមួយគ្នានោះក៏រក្សាបាននូវតុល្យភាពរវាងសុវត្ថិភាពសាធារណៈ ចរាចរណ៍ សមត្ថភាពប្រព័ន្ធទឹក និងលូ សាលារៀន និងការការពារបរិស្ថានផងដែរ។ សំណើនេះនឹងជំនួសការរៀបចំផែនការមូលដ្ឋានបានហ្មត់ចត់ ដោយដាក់បញ្ចូលវិធានការតែមួយសម្រាប់គ្រប់ទីកន្លែង ដែលមិនគិតពីតម្រូវការផ្ទាល់ខ្លួនរបស់ទីក្រុង និងតំបន់មូលដ្ឋានទាំង 351 នៅរដ្ឋម៉ាសាឈូសិត។

សហគមន៍គួរតែបន្តពង្រីកលំនៅឋានតាមរយៈការរៀបចំផែនការនៅមូលដ្ឋាន និងកិច្ចសហការជាមួយប្រជាពលរដ្ឋ មិនមែនតាមរយៈការបង្ខំដោយបទបញ្ជាទូទាំងរដ្ឋ ដែលដកហូតសិទ្ធិសម្រេចចិត្តរបស់មូលដ្ឋាននោះទេ។

សូមបោះឆ្នោត “មិនយល់ព្រម”។

**រៀបរៀងដោយ៖**
**Adam Chapdelaine**
**សមាគមក្រុង រដ្ឋម៉ាសាឈូសិត (Massachusetts Municipal Association)**
**3 Center Plaza, Suite 610**
**Boston, MA 02108**
**617-426-7272**
**www.mma.org**

# 8

## សំណួរទី 8៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

# *ការហាមឃាត់ការលក់រាយកញ្ឆាសម្រាប់មនុស្សពេញវ័យប្រើប្រាស់កម្សាន្ត*

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមនេះដែលមិនត្រូវបានព្រឹទ្ធសភា ឬរដ្ឋសភាបោះឆ្នោតអនុម័ត មុនថ្ងៃទី 6 ខែឧសភា ឆ្នាំ 2026 ដែរឬទេ ?*

**សង្ខេប ▶**

តាមច្បាប់តម្រូវ សេចក្តីសង្ខេបនានាត្រូវបានរៀបចំដោយអគ្គរដ្ឋអាជ្ញារដ្ឋ។

ច្បាប់ដែលបានស្នើនេះ នឹងផ្លាស់ប្តូរប្រភេទនិងបរិមាណកញ្ឆាដែលអាចកាន់កាប់ដោយស្របច្បាប់នៅក្នុងរដ្ឋម៉ាសាឈូសិត ដោយលុបចោលនូវច្បាប់នានាដែលផ្តល់ភាពស្របច្បាប់ គ្រប់គ្រង និងហូតពន្ធលើការលក់រាយកញ្ឆាសម្រាប់មនុស្សពេញវ័យប្រើប្រាស់កម្សាន្តនៅក្នុងរដ្ឋម៉ាសាឈូសិត។ ច្បាប់ដែលបានស្នើនេះ ក៏នឹងអនុញ្ញាតឱ្យបុគ្គលដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ អាចកាន់កាប់កញ្ឆាក្នុងបរិមាណ 1 អោន ឬតិចជាងនេះ រួមទាំងសារធាតុចម្រាញ់ពីកញ្ឆាមិនលើសពី 5 ក្រាម ព្រមទាំងអាចផ្តល់ជាអំណោយ ឬផ្ទេរទៅឱ្យបុគ្គលម្នាក់ទៀតដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ នូវកញ្ឆាក្នុងបរិមាណ 1 អោន ឬតិចជាងនេះ រួមទាំងសារធាតុចម្រាញ់ពីកញ្ឆាមិនលើសពី 5 ក្រាមផងដែរ។ ច្បាប់ដែលបានស្នើនេះ ក៏នឹងដាក់ពិន័យរដ្ឋប្បវេណីចំនួន 100 ដុល្លារ និងដកហូតយកកញ្ឆា សម្រាប់ការកាន់កាប់កញ្ឆាមានទម្ងន់ចន្លោះពី 1 ទៅ 2 អោនផងដែរ។

ចំពោះបុគ្គលដែលមានអាយុចាប់ពី 21 ឆ្នាំចុះក្រោម ច្បាប់ដែលបានស្នើនេះ នឹងចាត់ទុកការកាន់កាប់កញ្ឆាក្នុងបរិមាណ 2 អោន ឬតិចជាងនេះជាបទល្មើសរដ្ឋប្បវេណី ដែលត្រូវរងការផាកពិន័យជាប្រាក់ចំនួន 100 ដុល្លារ ការដកហូតយកកញ្ឆា ការបញ្ចប់កម្មវិធីយល់ដឹងអំពីគ្រឿងញៀន និងការងារបម្រើសហគមន៍ ព្រមទាំងការជូនដំណឹងដល់ឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេអំពីបទល្មើស និងទណ្ឌកម្មទាំងនេះ។

ច្បាប់ដែលបានស្នើឡើងនេះ នឹងអនុញ្ញាតឱ្យអាជីវកម្មកញ្ឆាសម្រាប់មនុស្សពេញវ័យប្រើប្រាស់កម្សាន្តដែលមានអាជ្ញាប័ណ្ណបច្ចុប្បន្ន អាចដាក់ពាក្យស្នើសុំតាមនីតិវិធីពន្លឿន ដើម្បីក្លាយជាកន្លែងផ្គត់ផ្គង់កញ្ឆាវេជ្ជសាស្ត្រមានអាជ្ញាប័ណ្ណ និងអាចលក់ស្តុកកញ្ឆាសម្រាប់មនុស្សពេញវ័យប្រើប្រាស់កម្សាន្ត ដែលនៅសេសសល់របស់ពួកគេ ទៅឱ្យកន្លែងផ្គត់ផ្គង់កញ្ឆាវេជ្ជសាស្ត្រនានាបាន។ ច្បាប់ដែលបានស្នើឡើងនេះ នឹងរក្សាគណៈកម្មការត្រួតពិនិត្យកញ្ឆា (Cannabis Control Commission) ទុកដដែល ប៉ុន្តែនឹងកែប្រែសមត្ថកិច្ចរបស់គណៈកម្មការនេះ ដើម្បីឱ្យគ្រប់គ្រងតែលើទីផ្សារកញ្ឆាវេជ្ជសាស្ត្រតែប៉ុណ្ណោះ។

ច្បាប់ដែលបានស្នើចែងថា ប្រសិនបើផ្នែកណាមួយរបស់វាត្រូវបានប្រកាសថាមិនត្រឹមត្រូវ ផ្នែកផ្សេងទៀតនឹងនៅជាធរមាន។

ច្បាប់ដែលបានស្នើនេះនឹងចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2028។

**ឥទ្ធិពលនៃការបោះឆ្នោតរបស់លោកអ្នក ▶**

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលពិពណ៌នាអំពីឥទ្ធិពលនៃការបោះឆ្នោត "យល់ព្រម" ឬ "មិនយល់ព្រម" ត្រូវបានរៀបចំរួមគ្នាដោយអគ្គរដ្ឋអាជ្ញារដ្ឋ និងរដ្ឋមន្ត្រីកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងហាមឃាត់ការធ្វើនីត្យានុកូលកម្ម ការកំណត់បទប្បញ្ញត្តិ និងការប្រមូលពន្ធលើការលក់រាយកញ្ឆាសម្រាប់មនុស្សពេញវ័យប្រើប្រាស់កម្សាន្ត ហើយនឹងផ្លាស់ប្តូរទោសទណ្ឌសម្រាប់ការកាន់កាប់កញ្ឆា។

***ការបោះឆ្នោត*** ជំទាស់ នឹងធ្វើឱ្យគ្មានការផ្លាស់ប្តូរណាមួយទៅលើច្បាប់ទាក់ទងនឹងកញ្ឆានោះឡើយ។

**សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ▶**

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។

តាមរយៈការលុបចោលច្បាប់ដែលបានធ្វើនីត្យានុកូលកម្ម និងហូតពន្ធលើការលក់រាយកញ្ឆាសម្រាប់មនុស្សពេញវ័យប្រើប្រាស់កម្សាន្ត ច្បាប់ដែលបានស្នើនេះ នឹងកាត់បន្ថយចំនួនទឹកប្រាក់ដែលរដ្ឋ និងរដ្ឋបាលក្រុងទទួលបានពីការប្រមូលពន្ធលើការលក់ទាំងនោះ។ ក្នុងឆ្នាំសារពើពន្ធ 2025 ការប្រមូលពន្ធលើការលក់រាយកញ្ឆាសម្រាប់មនុស្សពេញវ័យប្រើប្រាស់កម្សាន្ត រកចំណូលបានប្រហែល 280 លានដុល្លារសម្រាប់ថវិការដ្ឋ និងប្រហែល 50 លានដុល្លារសម្រាប់ថវិកាមូលដ្ឋាន។ ថវិការដ្ឋដែលគាំទ្រដោយចំណូលពន្ធ ផ្តល់ថវិកាជំនួយមូលដ្ឋានសម្រាប់សាលារៀន និងរដ្ឋបាលក្រុង។

# សំណួរទី 8៖ ច្បាប់ដែលបានស្នើឡើងដោយញត្តិផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ

**ទឡ្ហីករណ៍ ▶**

តាមច្បាប់តម្រូវ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកជំទាស់ទៅនឹងសំណួរនីមួយៗ ហើយបង្ហាញពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិត មិនគាំទ្រមតិយោបល់ទាំងនេះទេ ហើយក៏មិនបញ្ជាក់ ឬធានាអំពីភាពត្រឹមត្រូវ ឬពិតប្រាកដនៃសេចក្តីថ្លែងការណ៍ណាមួយដែលមាននៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះបុគ្គល និងអង្គភាពដែលបានរៀបចំទឡ្ហីករណ៍នីមួយៗ ព្រមទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់អ្នកដទៃអំពីទឡ្ហីករណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***គាំទ្រ៖***

អ្នកឯកទេសវេជ្ជសាស្ត្រ និងសុខភាពផ្លូវចិត្ត មាតាបិតា និងម្ចាស់អាជីវកម្ម ជំរុញឱ្យបោះឆ្នោត **“យល់ព្រម” លើសំណួរទី 8។**

- សំណួរទី 8 នឹងរក្សាភាពស្របច្បាប់នៃការកាន់កាប់កញ្ឆាសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន រក្សាភាពស្របច្បាប់នៃកញ្ឆាសម្រាប់គោលបំណងវេជ្ជសាស្ត្រ និងបញ្ឈប់ហាងលក់កញ្ឆាពាណិជ្ជកម្ម។
- ចាប់តាំងពីមានការធ្វើពាណិជ្ជកម្មកញ្ឆាដោយស្របច្បាប់មក ឥឡូវនេះកញ្ឆាបានក្លាយជា **គ្រឿងញៀនដែលប្រទះឃើញញឹកញាប់បំផុតក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលឱ្យស្លាប់បាត់បង់ជីវិត**នៅរដ្ឋម៉ាសាឈូសិត។
- **អ្នកប្រើប្រាស់កញ្ឆា 85% បានទទួលស្គាល់ថា ពួកគេបានបើកបរបន្ទាប់ពីប្រើប្រាស់ ហើយ ជាង 50% បានបើកបរនៅក្នុងរយៈពេលមួយម៉ោង ឬតិចជាងនេះបន្ទាប់ពីប្រើប្រាស់**។
- **ម្ចាស់អាជីវកម្មកំពុងប្រឈមនឹងការចំណាយកើនឡើង** ដោយសារអត្រា **របួសនៅកន្លែងធ្វើការកើនឡើង ថ្លៃថែទាំសុខភាពកើនឡើង និងអត្រាបុគ្គលិកចាកចេញកើនឡើង។**
- សម្រាប់**ប្រាក់ពន្ធចំណូលរាល់ 1 ដុល្លារ ដែលទទួលបាន អ្នកបង់ពន្ធត្រូវចំណាយ 4.5 ដុល្លារ** ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការធ្វើឱ្យកញ្ឆាស្របច្បាប់ពីចំណាយសង្គម រួមមាន ការកើនឡើងនៃថ្លៃថែទាំសុខភាព ការបាត់បង់ផលិតភាព និងបទល្មើស (ដូចជា ការបើកបរក្រោមឥទ្ធិពលសារធាតុស្រវឹង ឬគ្រឿងញៀន ជាដើម)។
- ផលិតផលកញ្ឆាចម្រាញ់ និងអាហារកែច្នៃពីកញ្ឆាសម័យទំនើប មានជាប់ពាក់ព័ន្ធទៅនឹងបញ្ហាសុខភាពផ្លូវចិត្ត ដូចជា **អាការៈវង្វេង ស្មារតី (Psychosis) ការថប់បារម្ភធ្ងន់ធ្ងរ និងជំងឺវិកលចរិត (schizophrenia)** ជាពិសេសក្នុងចំណោមមនុស្សវ័យក្មេង។
- ជាលទ្ធផលនៃការលក់កញ្ឆាពាណិជ្ជកម្ម **ការបញ្ជូនទៅបន្ទប់សង្គ្រោះបន្ទាន់ (ER) នៅរដ្ឋម៉ាសាឈូសិត បានកើនឡើងយ៉ាងខ្លាំងសម្រាប់ក្មេងជំទង់ដែលមានបញ្ហាផ្នែកសុខភាពផ្លូវចិត្ត។**

**រៀបរៀងដោយ៖**
**លោកបណ្ឌិត Jeffrey Morgan វេជ្ជបណ្ឌិត (ចូលនិវត្តន៍)**
**វេជ្ជបណ្ឌិតជំនាញមហារីកនិងជាវេជ្ជបណ្ឌិតទូទៅដែលចូលនិវត្តន៍ ព្រមទាំងអតីតគ្រូបង្រៀនផ្នែកវេជ្ជសាស្ត្រ**
**សម្ព័ន្ធដើម្បីប្រជាធិបតេយ្យប្រកបដោយសុខភាពល្អ (Coalition For a Healthy Massachusetts)**
**138 Conant Street**
**Beverly, MA 01915**
**www.HealthierMA.com**

***ជំទាស់៖***

សូមបោះឆ្នោត “មិនយល់ព្រម” លើសំណួរទី 8

សំណួរទី 8 នឹងបង្កើតបញ្ហាធ្ងន់ធ្ងរផ្នែកសុខភាព និងសុវត្ថិភាពសាធារណៈ ដោយលុបចោលច្បាប់ និងបទប្បញ្ញត្តិដែលបច្ចុប្បន្នកំពុងគ្រប់គ្រងការផលិត និងការលក់កញ្ឆានៅរដ្ឋម៉ាសាឈូសិត។

អស់រយៈពេលដប់ឆ្នាំមកហើយ រដ្ឋម៉ាសាឈូសិតបានគ្រប់គ្រងវិស័យកញ្ឆា ដោយធានាថា ផលិតផលនានាត្រូវបានធ្វើតេស្តសុវត្ថិភាព មានការវេចខ្ចប់ និងដាក់ស្លាកត្រឹមត្រូវ ហើយត្រូវបានលក់នៅក្នុងអាជីវកម្មមានអាជ្ញាបណ្ណ ដល់មនុស្សអាយុ 21 ឆ្នាំឡើងទៅ។

សំណួរទី 8 នឹងលុបចោលវឌ្ឍនភាពទាំងនេះ ហើយបង្វែរកញ្ឆាត្រឡប់ទៅកាន់ទីផ្សារខុសច្បាប់វិញ ដែលគ្មានវិធានការការពារសុវត្ថិភាពឡើយ។ អាជ្ញាធរអនុវត្តច្បាប់នឹងបង្ខំចិត្តត្រូវខ្ជះខ្ជាយពេលវេលា និងធនធានលើការចាប់ខ្លួនពាក់ព័ន្ធនឹងកញ្ឆា ជំនួសឱ្យការផ្តោតលើការប្រយុទ្ធប្រឆាំងបទល្មើសធ្ងន់ធ្ងរ។ តាមប្រវត្តិកន្លងមក ការចាប់ខ្លួនពាក់ព័ន្ធនឹងកញ្ឆា បានប៉ះពាល់ក្នុងកម្រិតមិនសមាមាត្រទៅលើសហគមន៍មិនមែនជនស្បែកស។ ការធ្វើឱ្យកញ្ឆាក្លាយជាបទល្មើសឡើងវិញ នឹងធ្វើឱ្យរដ្ឋម៉ាសាឈូសិតមានសុវត្ថិភាពតិចជាងមុន។

សំណួរទី 8 នឹងបង្ខំឱ្យអាជីវកម្មតូចៗរាប់រយត្រូវបិទទ្វារ បាត់បង់ការងាររាប់ពាន់កន្លែង និងលុបបំបាត់ចំណូលពន្ធរដ្ឋរាប់ពាន់លានដុល្លារ។

យើងមិនគួរត្រឡប់ថយក្រោយលើបញ្ហាសុខភាព និងសុវត្ថិភាពសាធារណៈនោះឡើយ។

សូមបោះឆ្នោត “មិនយល់ព្រម” លើសំណួរទី 8។

**រៀបរៀងដោយ៖**
**Ryan Dominguez**
**សម្ព័ន្ធអ្នកពាក់ព័ន្ធវិស័យកញ្ឆារដ្ឋម៉ាសាឈូសិត (Massachusetts Cannabis Coalition)**
**6 Liberty Square PMB 421**
**Boston, MA 02109**
**617-286-6173**
**www.stoptherepealma.com**

# 9

## សំណួរទី 9៖ ការធ្វើប្រជាមតិលើច្បាប់ដែលមានស្រាប់

# *ការគ្រប់គ្រងអាវុធជាតិផ្ទុះ*

*តើអ្នកយល់ព្រមលើច្បាប់សង្ខេបខាងក្រោម ដែលត្រូវបានអនុម័តដោយសភាតំណាងរាស្ត្រនៅថ្ងៃទី 18 ខែកក្កដា ឆ្នាំ 2024 ដោយសំឡេងគាំទ្រ 124 ទល់នឹង 33 ហើយត្រូវបានអនុម័តដោយព្រឹទ្ធសភា នៅថ្ងៃទី 18 ខែកក្កដា ឆ្នាំ 2024 ដោយសំឡេងគាំទ្រ 35 ទល់នឹង 5 ដែរឬទេ?*

**សង្ខេប** ▶

តាមច្បាប់តម្រូវ សេចក្តីសង្ខេបនានាត្រូវបានរៀបចំដោយអគ្គរដ្ឋអាជ្ញាររដ្ឋ។

ច្បាប់នេះធ្វើឱ្យមានការផ្លាស់ប្តូរមួយចំនួនលើច្បាប់របស់រដ្ឋម៉ាសាឈូសិត ដែលគ្រប់គ្រងអាវុធជាតិផ្ទុះ។

ច្បាប់នេះបន្ថែមគណៈគ្រប់គ្រងសាលារៀន និងអ្នកផ្តល់សេវាថែទាំសុខភាពមានអាជ្ញាប័ណ្ណជាភាគីដែលទទួលបានការអនុញ្ញាតឱ្យស្នើសុំតុលាការចេញដីកាបង្គាប់ហានិភ័យធ្ងន់ធ្ងរ ដែលតម្រូវឱ្យបុគ្គលម្នាក់ប្រគល់ ឬលះបង់ចោលនូវអាជ្ញាប័ណ្ណអាវុធជាតិផ្ទុះ លិខិតអនុញ្ញាត និងអាវុធជាតិផ្ទុះរបស់ពួកគេ ប្រសិនបើបុគ្គលនោះបង្កជាគ្រោះថ្នាក់បច្ចុប្បន្នដល់ខ្លួនឯង ឬអ្នកដទៃ។ ច្បាប់នេះក៏បានចែងផងដែរថា នៅពេលចេញដីកាបង្គាប់ការយាយី តុលាការក៏អាចបង្គាប់ឱ្យមានការប្រគល់អាជ្ញាប័ណ្ណអាវុធជាតិផ្ទុះ លិខិតអនុញ្ញាត និងអាវុធជាតិផ្ទុះផងដែរ។

ច្បាប់នេះកំណត់ទណ្ឌកម្មសម្រាប់ការកាន់កាប់ ការបង្កើត និងការផ្ទេរអាវុធជាតិផ្ទុះ "កាំភ្លើងខ្មោច" ដែលមិនអាចតាមដានប្រភពបាន ព្រមទាំងតម្រូវឱ្យអាវុធជាតិផ្ទុះទាំងអស់ លើកលែងតែអាវុធបុរាណ និងវត្ថុបុរាណ រួមទាំងតួនិងស្នូលកាំភ្លើងដែលមិនទាន់បានធ្វើរួចរាល់ ប៉ុន្តែអាចកែច្នៃធ្វើជាផលិតផលសម្រេចបានដោយងាយ ត្រូវតែមានលេខសម្គាល់។ ច្បាប់នេះរួមបញ្ចូលទាំងកាំភ្លើងដែលផលិតដោយឯកជន ដូចជាកាំភ្លើងបោះពុម្ព 3D ស្ថិតក្រោមបទបញ្ញត្តិគ្រប់គ្រងអាវុធជាតិផ្ទុះ ដែលមិនអាចតាមដានប្រភពបាន ឬ "កាំភ្លើងខ្មោច"។

ច្បាប់នេះផ្លាស់ប្តូរលក្ខខណ្ឌតម្រូវសម្រាប់ការផ្តល់អាជ្ញាប័ណ្ណអាវុធជាតិផ្ទុះដើម្បី៖ (1) អនុញ្ញាតឱ្យអាជ្ញាធរផ្តល់អាជ្ញាប័ណ្ណក្នុងតំបន់ ស្នើសុំព័ត៌មានអំពីអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតពីមុនពីរដ្ឋ ព្រមទាំងអាចពិនិត្យមើលពាក្យបណ្តឹងសុំបង្ខំឱ្យសម្រាកព្យាបាលសុខភាពផ្លូវចិត្តដែលតុលាការបានបដិសេធ បន្ថែមលើការបង្ខំឱ្យសម្រាកព្យាបាលពីមុនៗ ដើម្បីជាផ្នែកមួយនៃការពិនិត្យឡើងវិញនូវពាក្យសុំអាជ្ញាប័ណ្ណកាន់កាប់អាវុធជាតិផ្ទុះ បណ្ណសម្គាល់ខ្លួនម្ចាស់អាវុធជាតិផ្ទុះ និងអាជ្ញាប័ណ្ណលក់អាវុធជាតិផ្ទុះ (2) តម្រូវឱ្យបុគ្គលម្នាក់ៗត្រូវមានអាយុ 21 ឆ្នាំ ទើបអាចក្លាយជាម្ចាស់កម្មសិទ្ធិលើកាំភ្លើងវែងប្រភេទពាក់កណ្តាលស្វ័យប្រវត្តិ ឬកាំភ្លើងបាញ់គ្រាប់រាយបាន (3) បន្ថែមលទ្ធភាពនៃការផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ប្រាំមួយខែ សម្រាប់ការប្រព្រឹត្តល្មើសលើកទីពីរ ពីបទមិនបានរាយការណ៍អំពីការបាត់បង់ ឬការលួចអាវុធជាតិផ្ទុះ និង (4) អនុញ្ញាតឱ្យយុវជនអាយុពី 12 ដល់ 15 ឆ្នាំ អាចដាក់ពាក្យសុំលិខិតអនុញ្ញាតប្រើប្រាស់ស្ព្រាយបាញ់ការពារខ្លួន ដោយមានការអនុញ្ញាតពីមាតាបិតា ហើយយុវជនអាយុពី 15 ដល់ 18 ឆ្នាំ អាចដាក់ពាក្យសុំដោយខ្លួនឯងបាន។

ច្បាប់នេះអនុញ្ញាតឱ្យអាជ្ញាធរផ្តល់អាជ្ញាប័ណ្ណអាវុធជាតិផ្ទុះក្នុងតំបន់ អាចផ្ទេរទំនួលខុសត្រូវក្នុងការចុះត្រួតពិនិត្យអាជីវករលក់អាវុធជាតិផ្ទុះទៅឱ្យប៉ូលិសរដ្ឋបាន។ ច្បាប់នេះតម្រូវឱ្យអាជ្ញាធរផ្តល់អាជ្ញាប័ណ្ណក្នុងតំបន់ ត្រូវចូលរួមវគ្គបណ្តុះបណ្តាលទូទាំងរដ្ឋ ទាក់ទងនឹងការចុះត្រួតពិនិត្យទាំងនោះ។ ច្បាប់នេះក៏តម្រូវឱ្យអាជីវករលក់អាវុធជាតិផ្ទុះត្រូវដកហូតយកអាជ្ញាប័ណ្ណណាដែលហួសសុពលភាព ឬត្រូវបានព្យួរទុក ហើយរាយការណ៍អំពីករណីទាំងនោះទៅកាន់រដ្ឋ និងអាជ្ញាធរផ្តល់អាជ្ញាប័ណ្ណក្នុងតំបន់ផងដែរ។

ច្បាប់នេះផ្លាស់ប្តូរនិយមន័យពាក្យ "កាំភ្លើងយន្ត" ដោយរួមបញ្ចូលនូវឧបករណ៍ជំនួយល្បឿនបាញ់ ដងរវៃកេះកែកាំភ្លើង ឧបករណ៍បំប្លែងកាំភ្លើងខ្លីទៅជាស្វ័យប្រវត្តិ និងគន្លឹះស្វ័យប្រវត្តិ ទៅក្នុងចំណោមឧបករណ៍ទាំងឡាយដែលការកាន់កាប់ និងការប្រើប្រាស់របស់វាត្រូវទទួលទណ្ឌកម្ម។ ច្បាប់នេះពង្រីកនិយមន័យពាក្យ "ឧបករណ៍ខ្ទប់សំឡេង" ដោយរួមបញ្ចូលទាំងគ្រឿងបង្គុំទាំងឡាយដែលប្រើប្រាស់សម្រាប់ផលិតឧបករណ៍ខ្ទប់សំឡេងនោះផងដែរ។

ច្បាប់នេះបញ្ជាក់ច្បាស់អំពីរបៀបកំណត់ថា តើអាវុធជាតិផ្ទុះណាមួយជាអាវុធប្រភេទវាយលុក និងបញ្ជាក់ពីកាលៈទេសៈទាំងឡាយដែលបុគ្គលម្នាក់អាចបន្តកាន់កាប់អាវុធប្រភេទវាយលុក និងឧបករណ៍ផ្ទុកគ្រាប់មានសមត្ថភាពខ្ពស់ដែលពួកគេកាន់កាប់រួចហើយ។

ច្បាប់នេះតម្រូវឱ្យក្រុមប្រឹក្សាភិបាលប្រឹក្សាយោបល់ត្រួតពិនិត្យអាវុធជាតិផ្ទុះរបស់រដ្ឋ (Firearm Control Advisory Board) និងរដ្ឋមន្ត្រីសន្តិសុខនិងសុវត្ថិភាពសាធារណៈរបស់រដ្ឋ (Secretary of Public Safety and Security) ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអាវុធប្រភេទវាយលុកដែលត្រូវហាមឃាត់ អាវុធជាតិផ្ទុះដែលត្រូវបានអនុញ្ញាត និងអាវុធជាតិផ្ទុះដែលត្រូវបានអនុញ្ញាតសម្រាប់លក់យកទៅប្រើប្រាស់ក្នុងការបាញ់ស៊ីប។

ច្បាប់នេះបញ្ជាក់ច្បាស់ពីលក្ខខណ្ឌតម្រូវនានាដែលពាក់ព័ន្ធនឹងការកាន់កាប់ និងការដឹកជញ្ជូនអាវុធជាតិផ្ទុះ នៅក្នុងយានយន្ត និងម៉ូតូកង់បី ឬកង់បួនសម្រាប់ផ្លូវលំបាក (All-Terrain Vehicles, ATVs)។ ច្បាប់នេះហាមឃាត់ការកាន់កាប់អាវុធជាតិផ្ទុះនៅក្នុងអគាររដ្ឋាភិបាល ទីតាំងបោះឆ្នោត និងសាលារៀន ដោយមានការលើកលែងចំពោះករណីមួយចំនួន។

ច្បាប់នេះពង្រីកលក្ខខណ្ឌតម្រូវសម្រាប់ការចងក្រងទិន្នន័យ និងការរាយការណ៍ទៅនិងមកពីរដ្ឋ ព្រមទាំងបង្កើត ផ្ទាំងគ្រប់គ្រងទិន្នន័យដែលសាធារណជនអាចចូលប្រើប្រាស់បាននូវទិន្នន័យអាវុធជាតិផ្ទុះសរុបដែលត្រូវបានលាក់អត្តសញ្ញាណ រួមជាមួយនឹងគណៈកម្មការមួយដើម្បីសិក្សាពីទិន្នន័យទាំងនោះ។

ច្បាប់នេះតម្រូវឱ្យប៉ូលិសរដ្ឋផ្តល់ការបណ្តុះបណ្តាល និងការធ្វើតេស្តសម្រាប់អ្នកដាក់ពាក្យសុំថ្មីនូវអាជ្ញាប័ណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់ខ្លួនម្ចាស់អាវុធជាតិផ្ទុះ។

ច្បាប់នេះបង្កើតគណៈកម្មការនីតិប្បញ្ញត្តិពិសេសចំនួនពីរ៖ មួយគឺដើម្បីពិនិត្យមើលការផ្តល់មូលនិធិសម្រាប់សេវាបង្ការអំពើហិង្សា និងមួយទៀតគឺដើម្បីសិក្សាអំពីបច្ចេកវិទ្យាអាវុធជាតិផ្ទុះដែលកំពុងលេចឡើងថ្មីៗ។

ច្បាប់នេះបញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌចំពោះការបាញ់អាវុធ និងការបាញ់ត្រូវចំអគារកំពុងប្រើប្រាស់។

# សំណួរទី 9៖ ការធ្វើប្រជាមតិលើច្បាប់ដែលមានស្រាប់

**ឥទ្ធិពលនៃការបោះឆ្នោតរបស់លោកអ្នក** ▶

តាមច្បាប់តម្រូវ សេចក្ដីថ្លែងការណ៍ដែលពិពណ៌នាអំពីឥទ្ធិពលនៃការបោះឆ្នោត “យល់ព្រម” ឬ “មិនយល់ព្រម” ត្រូវបានរៀបចំរួមគ្នាដោយអគ្គរដ្ឋអាជ្ញារដ្ឋ និងរដ្ឋមន្ត្រីកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងរក្សាទុកច្បាប់ដែលបង្កើនការគ្រប់គ្រងអាវុធជាតិផ្ទុះ រួមទាំងកាំភ្លើងកែច្នៃ កាំភ្លើងយន្ត និងអាវុធប្រភេទវាយប្រហារ។

***ការបោះឆ្នោតជំទាស់*** អាចនឹងលុបចោលច្បាប់នេះ។

---

**សេចក្ដីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ** ▶

តាមច្បាប់តម្រូវ សេចក្ដីថ្លែងការណ៍អំពីផលវិបាកផ្នែកហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយក្រសួងរដ្ឋបាល និងហិរញ្ញវត្ថុ។

ចាប់តាំងពីការអនុម័តច្បាប់សុវត្ថិភាពនេះក្នុងឆ្នាំ 2024 មក រដ្ឋម៉ាសាឈូសិតបានធ្វើការវិនិយោគដ៏ធំ ដើម្បីអនុវត្តច្បាប់នេះ រួមមាន ការបណ្ដុះបណ្ដាលនិយោជិត ការរៀបចំដំណើរការថ្មីសម្រាប់ការផ្ដល់អាជ្ញាបណ្ណកាន់កាប់អាវុធ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ការលុបចោលច្បាប់នេះ នឹងតម្រូវឱ្យរដ្ឋម៉ាសាឈូសិតត្រូវចំណាយធនធានបន្ថែម ដើម្បីផ្អាក ឬបង្វែរការវិនិយោគទាំងនោះទៅប្រើប្រាស់សម្រាប់គោលបំណងផ្សេងវិញ។

---

**ទឡ្ហីករណ៍** ▶

តាមច្បាប់តម្រូវ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកជំទាស់ទៅនឹងសំណួរនីមួយៗ ហើយបង្ហាញពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិត មិនគាំទ្រមតិយោបល់ទាំងនេះទេ ហើយក៏មិនបញ្ជាក់ ឬធានាអំពីភាពត្រឹមត្រូវ ឬពិតប្រាកដនៃសេចក្ដីថ្លែងការណ៍ណាមួយដែលមាននៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះបុគ្គល និងអង្គភាពដែលបានរៀបចំទឡ្ហីករណ៍នីមួយៗ ព្រមទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់អ្នកដទៃអំពីទឡ្ហីករណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***គាំទ្រ៖***

ការបោះឆ្នោត “យល់ព្រម” នឹងរក្សាច្បាប់សុវត្ថិភាពអាវុធជាតិផ្ទុះឆ្នាំ 2024 របស់រដ្ឋម៉ាសាឈូសិត ដែលបានជួយសង្គ្រោះជីវិតមនុស្ស។ ច្បាប់នេះបានធ្វើបច្ចុប្បន្នភាពសំខាន់ៗជាច្រើន រួមមាន ការហាមឃាត់អាវុធដែលមិនមានលេខសម្គាល់ផ្លូវការ (ghost guns) ការហាមឃាត់ឧបករណ៍ដែលអាចបម្លែងអាវុធពាក់កណ្ដាលស្វ័យប្រវត្តិឱ្យក្លាយជាកាំភ្លើងយន្ត ការពង្រីកវិធានការជួយការពារការធ្វើអត្តឃាតដោយអាវុធ និងការបាញ់ប្រហារទ្រង់ទ្រាយធំ ការបង្កើតផ្ទាំងព័ត៌មានទិន្នន័យអំពីអាវុធ ដើម្បីឱ្យយល់កាន់តែច្បាស់អំពីការជួញដូរអាវុធខុសច្បាប់ និងវិធានការផ្សេងៗទៀត។

ដោយសារវិធីសាស្ត្រគ្រប់ជ្រុងជ្រោយរបស់យើងក្នុងការទប់ស្កាត់អំពើហិង្សាដោយអាវុធ រដ្ឋម៉ាសាឈូសិតមានអត្រាមរណភាពដោយអាវុធទាបជាងមធ្យមភាគជាតិ 70%។ ធាតុសំខាន់ៗនៃច្បាប់ឆ្នាំ 2024 កំពុងត្រូវបានអនុវត្តយ៉ាងសកម្ម ហើយកំពុងជួយរក្សាសុវត្ថិភាពសហគមន៍របស់យើងរួចហើយ។

ដើម្បីបន្តកាត់បន្ថយអត្រាអំពើហិង្សាដោយអាវុធឱ្យកាន់តែទាប យើងត្រូវតែរក្សាគោលនយោបាយដ៏រឹងមាំដែលមាននៅក្នុងច្បាប់នេះ។ ការបោះឆ្នោត “យល់ព្រម” នឹងរក្សាច្បាប់នេះ ការពារវឌ្ឍនភាពសំខាន់ៗ និងអនុញ្ញាតឱ្យយើងបន្តការងារលុបបំបាត់អំពើហិង្សាដោយអាវុធតទៅទៀត។ ការលុបចោលច្បាប់នេះ នឹងធ្វើឱ្យមនុស្សគ្រប់រូបនៅរដ្ឋម៉ាសាឈូសិតមានសុវត្ថិភាពតិចជាងមុន។

**រៀបរៀងដោយ៖**
**Ned Notis-McConarty**
**សម្ព័ន្ធបោះឆ្នោតគាំទ្រដើម្បីរដ្ឋម៉ាសាឈូសិតមានសុវត្ថិភាព (Vote Yes for a Safe Massachusetts)**
**PO Box 15**
**Boston, MA 02137**
**508-203-7985**
**www.yesforasafema.com**

***ជំទាស់៖***

ការបោះឆ្នោត “មិនយល់ព្រម” លើសំណួរទី 9 នឹងលុបចោលការកែប្រែច្បាប់អាវុធជាតិផ្ទុះដែលមិនចាំបាច់របស់រដ្ឋ។ មុនពេលច្បាប់ថ្មីនេះចូលជាធរមាន រដ្ឋម៉ាសាឈូសិតមានច្បាប់គ្រប់គ្រងអាវុធជាតិផ្ទុះ ដ៏តឹងរ៉ឹងបំផុតមួយចំនួននៅក្នុងប្រទេសរួចទៅហើយ។ ជំពូក 135 មិនពាក់ព័ន្ធនឹងសុវត្ថិភាពសាធារណៈទេ វាគឺជាសេចក្ដីព្រាងច្បាប់កម្រាស់ 116 ទំព័រ ដែលមានកំហុសធ្ងន់ធ្ងរ ជាការជ្រៀតជ្រែកហួសហេតុនៃប្រព័ន្ធរដ្ឋបាលដែលខ្ជះខ្ជាយប្រាក់ពន្ធដ៏មានតម្លៃ និងដាក់បន្ទុកដល់សហគមន៍មូលដ្ឋាន។ ច្បាប់នេះត្រូវបានអនុម័តដោយគ្មានការរៀបចំផែនការគ្រប់គ្រាន់ ហើយបានតម្រូវឱ្យមានប្រព័ន្ធតាមដានអេឡិចត្រូនិកតាមពេលវេលាជាក់ស្ដែង ដែលមានតម្លៃថ្លៃ ខណៈដែលរដ្ឋមិនទាន់បានផ្ដល់ថវិកា និងមិនដឹងច្បាស់ថាបង្កើតប្រព័ន្ធនេះដោយរបៀបណា។ វាក៏បង្ខំឱ្យនាយកដ្ឋានប៉ូលិសមូលដ្ឋានត្រូវអនុវត្តបទប្បញ្ញត្តិដែលមិនច្បាស់លាស់ជាច្រើន និងមានភាពច្របូកច្របល់ ដោយធ្វើឱ្យមន្ត្រីៗត្រូវចំណាយពេលលើឯកសាររដ្ឋបាលជាច្រើន ជំនួសឱ្យការស៊ើបអង្កេតបទល្មើសហិង្សា។ ទីភ្នាក់ងាររដ្ឋបានជួបប្រទះការលំបាកក្នុងការពន្យល់អំពីច្បាប់នេះ ដោយត្រូវចេញសេចក្ដីបកស្រាយ និងការបញ្ជាក់រាប់សិបលើក សម្រាប់បទប្បញ្ញត្តិដែលចាត់ទុកអ្នកសម្ដែងសិល្បៈប្រវត្តិសាស្ត្រឡើងវិញដែលគ្មានគ្រោះថ្នាក់ និងអ្នកចូលចិត្តប្រមូលវត្ថុបុរាណ ដូចជាឧក្រិដ្ឋជន។ សូមបោះឆ្នោត “មិនយល់ព្រម” លើសំណួរទី 9។ ទាមទារឱ្យមានច្បាប់ប្រកបដោយសុភវិនិច្ឆ័យ និងតម្លាភាព ដែលផ្ដោតលើឧក្រិដ្ឋជនដែលប្រើអំពើហិង្សា មិនមែនលើការកម្រិតសិទ្ធិស៊ីវិលរបស់ប្រជាពលរដ្ឋឡើយ។

**រៀបរៀងដោយ៖**
**Toby Leary**
**សម្ព័ន្ធសិទ្ធិប្រជាពលរដ្ឋ (The Civil Rights Coalition)**
**PO Box 252**
**North Andover, MA 01845**
**978-481-6990**
**TheCivilRightsCoalition.com**

# របាយការណ៍របស់ស្ថាប័ននីតិប្បញ្ញត្តិ

*របាយការណ៍ខាងក្រោមនេះ ត្រូវបានរៀបរៀងឡើងដោយសមាជិកគណៈកម្មាធិការរួមពិសេសរបស់សភាស្តីពីញត្តិផ្តួចផ្តើម។ រដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត អនុញ្ញាតឱ្យសភាបញ្ចូលរបាយការណ៍ទាំងនេះនៅក្នុងសៀវភៅនេះ។* ***សេចក្តីថ្លែងការណ៍ដែលមាននៅក្នុងរបាយការណ៍នេះ មិនតំណាងឱ្យមតិយោបល់របស់ ការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋនោះទេ។***

## សំណួរទី 1៖ របាយការណ៍សំឡេងភាគច្រើន

ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (Special Joint Committee on Initiative Petitions)

មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត អនុញ្ញាតឱ្យអ្នកបោះឆ្នោតអាចស្នើច្បាប់ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញបាន តាមរយៈញត្តិផ្តួចផ្តើម ឬហៅជាទូទៅថា សំណួរនៅលើសន្លឹកឆ្នោត។ បន្ទាប់ពីការប្រមូលហត្ថលេខាគ្រប់គ្រាន់តាមការកំណត់ និងការដាក់ជូនហត្ថលេខាបញ្ជាក់ត្រឹមត្រូវទៅរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋរួចមក ញត្តិនោះនឹងត្រូវដាក់ជូនទៅស្ថាប័ននីតិប្បញ្ញត្តិជាផ្លូវការ ដើម្បីធ្វើការពិចារណា។ បន្ទាប់មក ញត្តិនោះនឹងត្រូវបញ្ជូនទៅកាន់គណៈកម្មាធិការមួយ ដែលក្នុងករណីនេះ គឺគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម។

យោងតាមមាត្រា 48 គណៈកម្មាធិការនេះត្រូវតែរាយការណ៍ជូនស្ថាប័ននីតិប្បញ្ញត្តិអំពីញត្តិនីមួយៗ ឱ្យបានមុនថ្ងៃពុធសប្តាហ៍ទីមួយនៃខែឧសភា។ ខុសពីដំណើរការនីតិប្បញ្ញត្តិស្តង់ដា ស្ថាប័ននីតិប្បញ្ញត្តិអាចអនុម័ត ឬបដិសេធញត្តិផ្តួចផ្តើមទៅតាមទម្រង់ដែលបានដាក់ជូនតែប៉ុណ្ណោះ ដោយមិនធ្វើការកែប្រែណាមួយឡើយ។

គណៈកម្មាធិការនេះបានរៀបចំសវនាការស្តីពីញត្តិផ្តួចផ្តើម 25-14 សេចក្តីព្រាងច្បាប់សភាលេខ 5004 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការកែលម្អលទ្ធភាពទទួលបានឯកសារសាធារណៈ* កាលពីថ្ងៃទី 3 ខែមីនា ឆ្នាំ 2026។ គណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម បានរៀបចំសវនាការសាធារណៈពេញមួយខែមីនា ឆ្នាំ 2026 ដើម្បីប្រមូលសក្ខីកម្ម និងព័ត៌មានជាមូលដ្ឋានក្នុងការពិនិត្យឡើងវិញរបស់ខ្លួន។ គណៈកម្មាធិការនេះបានពិចារណាមតិចូលរួមពីអ្នកជំនាញឯកទេស ភាគីអ្នកគាំទ្រ និងភាគីអ្នកប្រឆាំងនឹងញត្តិផ្តួចផ្តើម ក៏ដូចជាសាធារណជនទូទៅផងដែរ។ កំណត់ត្រាសវនាការទាំងស្រុង និងឯកសារគាំទ្រនានា មានផ្តល់ជូនសាធារណជនតាមតំណភ្ជាប់ malegislature.gov/Events/Hearings/Detail/5590។

កាលពីថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026 ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (ហៅកាត់ថា "គណៈកម្មាធិការ") បានបោះឆ្នោតផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ **កុំចាត់វិធានការ**លើញត្តិផ្តួចផ្តើម 25-14/សេចក្តីព្រាងច្បាប់សភាលេខ 5004 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការកែលម្អលទ្ធភាពទទួលបានឯកសារសាធារណៈ (ហៅកាត់ថា "ញត្តិ")*។

ញត្តិនេះមានបំណងដាក់ការិយាល័យអភិបាលរដ្ឋ និងស្ថាប័ននីតិប្បញ្ញត្តិ ឱ្យស្ថិតនៅក្រោមការអនុវត្តច្បាប់ស្តីពីឯកសារសាធារណៈ ស្របតាមជំពូកទី 4 និងទី 66 នៃច្បាប់ទូទៅរបស់រដ្ឋម៉ាសាឈូសិត។ គណៈកម្មាធិការបានកត់សម្គាល់ថា ទោះបីជាញត្តិនេះនឹងផ្តល់ការលើកលែងថ្មីចំនួនពីរដល់ច្បាប់ស្តីពីឯកសារសាធារណៈ បន្ថែមទៅនឹងអ្វីដែលមានស្រាប់នៅក្នុងជំពូកទី 4 ក៏ដោយ ក៏មានការលើកឡើងនៅក្នុងសវនាការនីតិប្បញ្ញត្តិថា ការលើកលែងបន្ថែមទាំងនោះ អាចនឹងផ្តល់ផលប្រយោជន៍តិចតួចជាងអ្វីដែលអ្នកស្នើញត្តិបានជឿជាក់ថានឹងកើតមាន។ អ្នកស្នើញត្តិបានថ្លែងនៅក្នុងសវនាការថា ពួកគេបានផ្តល់ជូនការលើកលែងថ្មីៗទាំងនេះ ដើម្បីចៀសវាងក្តីបារម្ភផ្នែកច្បាប់ពាក់ព័ន្ធនឹងការលាតត្រដាងការឆ្លើយឆ្លងជាមួយម្ចាស់ឆ្នោត និងឯកសាររៀបចំគោលនយោបាយទៅកាន់សាធារណជន។ ទោះជាយ៉ាងណាក៏ដោយ ការលើកលែងថ្មីសម្រាប់ការប្រាស្រ័យទាក់ទងជាមួយម្ចាស់ឆ្នោតនោះ គឺមានភាពចង្អៀតពេក មិនអាចដោះស្រាយក្តីបារម្ភផ្នែកច្បាប់ទាំងនោះបានឡើយ។ ការលើកលែងថ្មីដែលបានស្នើឡើងពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងជាមួយម្ចាស់ឆ្នោតនេះ គឺគ្របដណ្តប់តែលើសំណើជាក់លាក់ពីសំណាក់ម្ចាស់ឆ្នោតផ្ញើជូនសមាជិកសភា ដើម្បីសុំជំនួយក្នុងការទទួលបានអត្ថប្រយោជន៍ ឬសេវាដែលផ្តល់ដោយរដ្ឋាភិបាល ឬការប្រាស្រ័យទាក់ទងផ្សេងទៀតជាមួយទីភ្នាក់ងាររដ្ឋ ឬសហព័ន្ធតែប៉ុណ្ណោះ។ ការលើកលែងថ្មីនេះ នឹងមិនគ្របដណ្តប់លើការប្រាស្រ័យទាក់ទងពាក់ព័ន្ធនឹងម្ចាស់ឆ្នោតដែលស្វែងរកការទទួលបានសេវាកម្មនានាដែលមិនគ្រប់គ្រងដោយរដ្ឋាភិបាលរដ្ឋ ឬរដ្ឋាភិបាលសហព័ន្ធនោះឡើយ ដូចជា សេវាកម្មដែលផ្តល់ដោយមន្ទីរពេទ្យ ឬអង្គការមិនមែនរដ្ឋាភិបាលជាដើម។ ការលើកលែងដែលបានស្នើឡើងនេះ ក៏នឹងមិនរារាំងដល់ការលាតត្រដាងការប្រាស្រ័យទាក់ទងពីសំណាក់ម្ចាស់ឆ្នោតពាក់ព័ន្ធនឹងការតស៊ូមតិដើម្បីគាំទ្រ ឬជំទាស់នឹងសេចក្តីព្រាងច្បាប់ជាក់លាក់ណាមួយនោះដែរ។ ដែនកំណត់នេះ អាចនឹងរំខានដល់បំណងប្រាថ្នារបស់បុគ្គលម្នាក់ៗក្នុងការប្រាស្រ័យទាក់ទងជាមួយសមាជិកសភា និងរឹតត្បិតសិទ្ធិរបស់ពួកគេក្នុងការដាក់ញត្តិជូនរដ្ឋាភិបាលរបស់ខ្លួន។

ពាក់ព័ន្ធនឹងការលើកលែងដែលបានស្នើឡើងសម្រាប់ឯកសារទាក់ទងនឹងការរៀបចំជំហរគោលនយោបាយ អ្នកស្នើញត្តិបានបញ្ជាក់ច្បាស់នៅក្នុងសវនាការថា ការលើកលែងនេះមានបំណងគ្របដណ្តប់តែលើការប្រាស្រ័យទាក់ទងគ្នាក្នុងអំឡុងពេលរៀបចំគោលនយោបាយតែប៉ុណ្ណោះ ហើយការលើកលែងបែបនេះនឹងត្រូវផុតកំណត់ភ្លាមនៅពេលរៀបចំគោលនយោបាយនោះរួចរាល់។ ការលើកលែងបែបនេះគឺមានកម្រិត និងមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ហើយវានឹងបង្អាក់ដល់ការប្រាស្រ័យទាក់ទងគ្នាដោយចំហពីសំណាក់សមាជិកសភា ក្នុងលក្ខណៈដែលបង្កើតឱ្យមានក្តីបារម្ភផ្នែករដ្ឋធម្មនុញ្ញយ៉ាងខ្លាំង ជាពិសេសជុំវិញកិច្ចការពារលើការថ្លែងមតិ និងការជែកដេញដោលក្នុងស្ថាប័ននីតិប្បញ្ញត្តិ។

ផ្ទុយស្រឡះពីការអះអាងនានារបស់អ្នកស្នើញត្តិ គណៈកម្មាធិការបានកត់សម្គាល់ថា ដំណើរការនីតិប្បញ្ញត្តិនៅក្នុងរដ្ឋម៉ាសាឈូសិត គឺត្រូវបានរៀបចំឡើងឱ្យមានលក្ខណៈបើកចំហសម្រាប់សាធារណជនរួចជាស្រេចទៅហើយ។ រាល់សវនាការទាំងអស់ត្រូវបានប្រព្រឹត្តទៅនៅក្នុងសម័យប្រជុំសាធារណៈដោយចំហ ហើយសក្ខីកម្មនានាត្រូវបានទទួលយកពីសំណាក់សាធារណជនទូទៅ អង្គការតស៊ូមតិ អ្នកជំនាញឯកទេស និងមន្ត្រីរដ្ឋាភិបាល។ សម័យប្រជុំនីតិប្បញ្ញត្តិ សវនាការ និងការប្រជុំគណៈកម្មាធិការ ត្រូវជូនដំណឹងជាសាធារណៈ និងបើកចំហជូនសាធារណជន ហើយកិច្ចប្រជុំជាច្រើនត្រូវបានផ្សាយបន្តផ្ទាល់ និងរក្សាទុកក្នុងបណ្ណសារសម្រាប់ទស្សនានៅពេលក្រោយ។

លើសពីនេះ ស្ថាប័ននីតិប្បញ្ញត្តិរដ្ឋម៉ាសាឈូសិត ក៏បានផ្តល់នូវមធ្យោបាយចម្រុះសម្រាប់ការចូលរួមរបស់សាធារណជនផងដែរ។ សេចក្តីព្រាងច្បាប់ វិសោធនកម្ម និងការបោះឆ្នោតដោយហៅឈ្មោះកត់ត្រា គឺត្រូវបានផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណិតដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចតាមដានសេចក្តីព្រាងច្បាប់ និងពិនិត្យមើលថាតើតំណាងរាស្ត្រជាប់ឆ្នោតរបស់ពួកគេបានបោះឆ្នោតដោយរបៀបណា។ ប្រតិទិនការងាររបស់គណៈកម្មាធិការ របាយការណ៍ លទ្ធផលបោះឆ្នោត និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ក៏ត្រូវផ្សព្វផ្សាយជាសាធារណៈផងដែរ ដែលអនុញ្ញាតឱ្យម្ចាស់ឆ្នោតអាចតាមដានវឌ្ឍនភាពនៃសេចក្តីព្រាងច្បាប់ ឆ្លងកាត់ដំណើរការរបស់គណៈកម្មាធិការ។ យន្តការទាំងនេះរួមគ្នាធានាឱ្យមានតម្លាភាពកាន់តែច្បាស់ទៅលើដំណើរការនីតិប្បញ្ញត្តិ ព្រមទាំងផ្តល់ឱកាសនានាសម្រាប់ការចូលរួមរបស់សាធារណជន។

ជាមួយគ្នានេះ គណៈកម្មាធិការក៏បានសន្និដ្ឋានថា ការផ្លាស់ប្តូរដែលបានស្នើទាំងនេះ អាចនឹងបង្កើតជាបន្ទុកផ្នែករដ្ឋបាលធ្ងន់ធ្ងរដល់រដ្ឋ ទាំងសម្រាប់អនុលោមភាព និងការអនុវត្ត

## សំណួរទី 1៖ របាយការណ៍សំឡេងភាគច្រើន (ត)

ច្បាប់។ អង្គភាពនានារបស់រដ្ឋ ទំនងជាត្រូវបែងចែកធនធានបុគ្គលិកឡើងវិញ បង្កើតនីតិវិធីអនុលោមភាពថ្មីៗ និងអាចកែប្រែប្រព័ន្ធគ្រប់គ្រងឯកសារដែលមានស្រាប់ ដើម្បីបំពេញតាមលក្ខខណ្ឌរបស់ញត្តិនេះ។ តម្រូវការផ្នែកប្រតិបត្តិការទាំងនេះ អាចនឹងបង្វែរធនធានចេញពីមុខងារស្នូលសំខាន់ៗដទៃទៀតរបស់រដ្ឋាភិបាល។

ដើម្បីសម្រេចសេចក្ដីសន្និដ្ឋាននេះ គណៈកម្មាធិការបានពិនិត្យឡើងវិញនូវពាក្យពេចន៍ និងបំណងនៃវិធានការដែលបានស្នើ ព្រមទាំងសក្ខីកម្មនិងភស្តុតាងនានាដែលបានបង្ហាញក្នុងអំឡុងពេលសវនាការសាធារណៈ ដែលមានផ្ដល់ជូននៅលើគេហទំព័ររបស់គណៈកម្មាធិការ។ គណៈកម្មាធិការទទួលស្គាល់សារៈសំខាន់នៃលទ្ធភាពទទួលបានឯកសាររដ្ឋាភិបាលរបស់សាធារណជន ប៉ុន្តែ គណៈកម្មាធិការមានក្ដីបារម្ភខ្លាំងអំពីផលប៉ះពាល់ផ្នែកប្រតិបត្តិការ ច្បាប់ និងហិរញ្ញវត្ថុដែលអាចកើតមានឡើងដោយសារញត្តិនេះ។

ផ្អែកលើសក្ខីកម្មពីសំណាក់អ្នកជំនាញ និងភាគីជំទាស់ គណៈកម្មាធិការជឿជាក់ថា ញត្តិនេះរំលោភលើគោលការណ៍បែងចែកអំណាច ដែលត្រូវបានចែងបង្គាប់ដោយរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាឈូសិត។ តាមច្បាប់ ញត្តិនេះនឹងតម្រូវឱ្យរដ្ឋមន្ត្រីកិច្ចការរដ្ឋ ជាមន្ត្រីម្នាក់នៃអំណាចនីតិប្រតិបត្តិ ត្រូវអនុវត្តច្បាប់នេះប្រឆាំងនឹងព្រឹទ្ធសភា និងរដ្ឋសភានៅក្នុងអំណាចនីតិប្បញ្ញត្តិ។ ការណ៍នេះនឹងរំលោភលើរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាឈូសិត ដោយសារវាផ្ដល់ឱ្យអំណាចនីតិប្រតិបត្តិនូវអំណាចត្រួតពិនិត្យលើអំណាចនីតិប្បញ្ញត្តិ។ ការផ្លាស់ប្ដូរអំណាចដ៏ធំធេងបែបនេះរវាងស្ថាប័នកំពូលៗរបស់រដ្ឋាភិបាលរដ្ឋម៉ាសាឈូសិត អាចធ្វើទៅបានតែតាមរយៈវិសោធនកម្មរដ្ឋធម្មនុញ្ញប៉ុណ្ណោះ មិនមែនតាមរយៈច្បាប់ថ្មីនោះឡើយ។

គណៈកម្មាធិការដឹងច្បាស់ថា សមាជិកស្ថាប័ននីតិប្បញ្ញត្តិមានការប្ដេជ្ញាចិត្តរួមគ្នាក្នុងការបង្កើនលទ្ធភាពចូលរួមរបស់សាធារណជនក្នុងស្ថាប័ននីតិប្បញ្ញត្តិ ហើយយើងទន្ទឹងរង់ចាំជួយជំរុញលទ្ធភាពចូលរួមនេះ តាមរយៈមធ្យោបាយទាំងឡាយណាដែលចៀសវាងបាននូវកំហុសឆ្គងរដ្ឋធម្មនុញ្ញដែលមាននៅក្នុងញត្តិបច្ចុប្បន្ននេះ។

គួរកត់សម្គាល់ថា មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត  ដែលគ្រប់គ្រងដំណើរការញត្តិផ្ដួចផ្ដើម តម្រូវឱ្យអគ្គរដ្ឋអាជ្ញាផ្ដល់ការបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្ដួចផ្ដើមណាដែលបំពេញតាមលក្ខខណ្ឌកំណត់ជាក់លាក់ ដូចមានចែងនៅក្នុងមាត្រា 48 នោះ។ ក្នុងការសម្រេចថាតើត្រូវបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្ដួចផ្ដើមណាមួយដែរឬទេនោះ អគ្គរដ្ឋអាជ្ញាមិនធ្វើការវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញក្នុងវិសាលភាពកាន់តែទូលំទូលាយរបស់ញត្តិនោះឡើយ ពោលគឺការសម្រេចបញ្ជាក់ទទួលស្គាល់របស់គាត់ ត្រូវបានកម្រិតត្រឹមតែលក្ខណវិនិច្ឆ័យចង្អៀតដែលមានចែងនៅក្នុងមាត្រា 48 តែប៉ុណ្ណោះ។ ដូចនេះ ញត្តិនេះត្រូវបានបញ្ជាក់ទទួលស្គាល់ដោយអគ្គរដ្ឋអាជ្ញាក្រោមមាត្រា 48 រួចរាល់ហើយ ប៉ុន្តែរូបគាត់ ឬតុលាការមិនទាន់បានវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញរបស់វានាពេលបច្ចុប្បន្ននេះនៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ ចៅក្រមតុលាការយុត្តិធម៌កំពូល (Supreme Judicial Court) នៅក្នុងមតិផ្ដល់ប្រឹក្សាមួយដែលបានចេញផ្សាយកាលពីថ្ងៃទី 27 ខែមេសា ឆ្នាំ 2026 បានថ្លែងថា ញត្តិផ្ដួចផ្ដើមច្បាប់នេះអាចនឹងបង្កើតឱ្យមានសំណួរផ្នែករដ្ឋធម្មនុញ្ញសំខាន់ៗជាច្រើន (រួមទាំងសំណួរថាតើញត្តិផ្ដួចផ្ដើមច្បាប់នេះរំលោភលើគោលការណ៍បែងចែកអំណាចដែរឬទេ) ហើយក្រុមចៅក្រមបានរក្សាទុកការពិចារណាលើក្ដីបារម្ភផ្នែករដ្ឋធម្មនុញ្ញទាំងនោះសម្រាប់ឱកាសក្រោយ។

ដោយសារអង្គនីតិបញ្ញត្តិមិនអាចធ្វើវិសោធនកម្មសំណើនេះបាន ភាគច្រើននៃគណៈកម្មាធិការបានផ្ដល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំចាត់វិធានការ**លើញត្តិផ្ដួចផ្ដើម 25-14/សេចក្ដីព្រាងច្បាប់សភាលេខ 5004 *ដែលជាញត្តិផ្ដួចផ្ដើមច្បាប់ពាក់ព័ន្ធនឹងការកែលម្អលទ្ធភាពទទួលបានឯកសារសាធារណៈ*។

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
| --- | --- |
| Cindy F. Friedman | Alice Hanlon Peisch |
| Brendan P. Crighton | Kate Hogan |
| Paul R. Feeney | Frank A. Moran |
| | Michael S. Day |
| | David T. Vieira |

## សំណួរទី 1៖ របាយការណ៍សំឡេងភាគតិច

អំពីការកែលម្អលទ្ធភាពទទួលបានឯកសារសាធារណៈ

ស្ថាប័ននីតិប្បញ្ញត្តិ មានការទទួលខុសត្រូវជាសារវន្តក្នុងដំណើរការការងារដោយភាពបើកចំហ និងភាពស្មោះត្រង់ ហើយការអនុម័តលើគំនិតផ្ដួចផ្ដើមនេះគឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការបំពេញកាតព្វកិច្ចនោះ។ រាល់ទីភ្នាក់ងារ និងនាយកដ្ឋានចំណុះអំណាចនីតិប្រតិបត្តិទាំងអស់នៅក្នុងរដ្ឋម៉ាសាឈូសិត ព្រមទាំងអង្គភាពរដ្ឋបាលក្រុងទាំងឡាយ គឺតម្រូវឱ្យអនុលោមតាមច្បាប់ស្ដីពីឯកសារសាធារណៈ ដោយធានាថាប្រជាពលរដ្ឋមានលទ្ធភាពទទួលបានព័ត៌មានអំពីរបៀបដែលរដ្ឋាភិបាលរបស់ពួកគេដំណើរការ។ សាធារណជនមានទំនុកចិត្តប្រគល់អំណាចដ៏សំខាន់ដល់មន្ត្រីជាប់ឆ្នោត ហើយអំណាចនោះត្រូវដើរទន្ទឹមគ្នានឹងការរំពឹងទុកអំពីតម្លាភាព គណនេយ្យភាព និងលទ្ធភាពទទួលបានព័ត៌មាន។ ការពង្រឹងលទ្ធភាពទទួលបានឯកសារសាធារណៈ នឹងធ្វើឱ្យស្ថាប័ននីតិប្បញ្ញត្តិដើរទន្ទឹមគ្នានឹងការអនុវត្តទាំងឡាយដែលអង្គភាពរដ្ឋដទៃទៀតបានប្រកាន់ខ្ជាប់រួចទៅហើយ។ តម្លាភាពមិនមែនជាបន្ទុកនោះទេ វាគឺជាលក្ខណៈស្នូលនៃអភិបាលកិច្ចល្អ ហើយមិនគួរបដិសេធមិនផ្ដល់តម្លាភាពនោះជូនប្រជាពលរដ្ឋឡើយ។

អាស្រ័យហេតុនេះ  ភាគច្រើននៃគណៈកម្មាធិការបានផ្ដល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) អនុម័តញត្តិផ្ដួចផ្ដើម 25-14/សេចក្ដីព្រាងច្បាប់សភាលេខ 5004 *ដែលជាញត្តិទាក់ទងនឹងច្បាប់កែលម្អលទ្ធភាពទទួលបានឯកសារសាធារណៈ*។

សមាជិកព្រឹទ្ធសភា

Ryan C. Fattman

# របាយការណ៍របស់ស្ថាប័ននីតិប្បញ្ញត្តិ (ត)

## សំណួរទី 2៖ របាយការណ៍សំឡេងភាគច្រើន

មតិភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (Special Joint Committee on Initiative Petitions)

មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត អនុញ្ញាតឱ្យអ្នកបោះឆ្នោតអាចស្នើច្បាប់ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញបាន តាមរយៈញត្តិផ្តួចផ្តើម ឬហៅជាទូទៅថា សំណួរនៅលើសន្លឹកឆ្នោត។ បន្ទាប់ពីការប្រមូលហត្ថលេខាគ្រប់គ្រាន់តាមការកំណត់ និងការដាក់ជូនហត្ថលេខាបញ្ជាក់ត្រឹមត្រូវទៅរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋរួចមក ញត្តិនោះនឹងត្រូវដាក់ជូនទៅស្ថាប័ននីតិប្បញ្ញត្តិជាផ្លូវការ ដើម្បីធ្វើការពិចារណា។ បបន្ទាប់មក ញត្តិនោះនឹងត្រូវបញ្ជូនទៅកាន់គណៈកម្មាធិការមួយ ដែលក្នុងករណីនេះ គឺគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម។

យោងតាមមាត្រា 48 គណៈកម្មាធិការនេះត្រូវតែរាយការណ៍ជូនស្ថាប័ននីតិប្បញ្ញត្តិអំពីញត្តិនីមួយៗ ឱ្យបានមុនថ្ងៃពុធសប្តាហ៍ទីមួយនៃខែឧសភា។ ខុសពីដំណើរការនីតិប្បញ្ញត្តិស្តង់ដា ស្ថាប័ននីតិប្បញ្ញត្តិអាចអនុម័ត ឬបដិសេធញត្តិផ្តួចផ្តើមទៅតាមទម្រង់ដែលបានដាក់ជូនតែប៉ុណ្ណោះ ដោយមិនធ្វើការកែប្រែណាមួយឡើយ។

គណៈកម្មាធិការនេះបានរៀបចំសវនាការស្តីពីញត្តិផ្តួចផ្តើម 25-22 សេចក្តីព្រាងច្បាប់សភាលេខ 5009 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងគោលនយោបាយទំនាក់ទំនងការងារសម្រាប់បុគ្គលិកគណៈកម្មាធិការសេវាមេធាវីការពារក្តីសាធារណៈ* កាលពីថ្ងៃទី 16 ខែមីនា ឆ្នាំ 2026។ គណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម បានរៀបចំសវនាការសាធារណៈពេញមួយខែមីនា ឆ្នាំ 2026 ដើម្បីប្រមូលសក្ខីកម្ម និងព័ត៌មានជាមូលដ្ឋានក្នុងការពិនិត្យឡើងវិញរបស់ខ្លួន។ គណៈកម្មាធិការនេះបានពិចារណាមតិយោបល់ពីអ្នកជំនាញឯកទេស និងអ្នកគាំទ្រញត្តិ ក៏ដូចជាសាធារណជនទូទៅផងដែរ។ កំណត់ត្រាសវនាការទាំងស្រុង និងឯកសារគាំទ្រនានា មានផ្តល់ជូនសាធារណជនតាមតំណភ្ជាប់ malegislature.gov/Events/Hearings/Detail/5595.

កាលពីថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026 ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (ហៅកាត់ថា "គណៈកម្មាធិការ") បានបោះឆ្នោតផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-22 សេចក្តីព្រាងច្បាប់សភាលេខ 5009 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងគោលនយោបាយទំនាក់ទំនងការងារសម្រាប់បុគ្គលិកគណៈកម្មាធិការសេវាមេធាវីការពារក្តីសាធារណៈ* (ហៅកាត់ថា "ញត្តិ")។

ដើម្បីសម្រេចសេចក្តីសន្និដ្ឋាននេះ គណៈកម្មាធិការបានធ្វើការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយនូវវិធានការដែលបានស្នើ រួមទាំងការពិនិត្យយ៉ាងល្អិតល្អន់លើពាក្យពេចន៍ រចនាសម្ព័ន្ធ និងគោលបំណងដែលបានបញ្ជាក់។ គណៈកម្មាធិការបានវាយតម្លៃលើសក្ខីកម្ម និងភស្តុតាងឯកសារដែលបានបង្ហាញក្នុងអំឡុងពេលសវនាការសាធារណៈ ព្រមទាំងឯកសារលាយលក្ខណ៍អក្សរដែលគណៈកម្មាធិការបានទទួល។ សក្ខីកម្មទាំងនោះបានឆ្លុះបញ្ចាំងពីទស្សនៈចម្រុះដ៏ទូលំទូលាយពីភាគីពាក់ព័ន្ធដែលមានបទពិសោធផ្ទាល់ក្នុងវិស័យការពារក្តីសាធារណៈ ទំនាក់ទំនងការងារ និងរដ្ឋបាលសាធារណៈ។

អ្នកគាំទ្រញត្តិបានអះអាងថា ការផ្លាស់ប្តូរដែលបានស្នើឡើងនេះ នឹងពង្រឹងតំណាងបុគ្គលិកនៅក្នុងគណៈកម្មាធិការសេវាមេធាវីការពារក្តីសាធារណៈ (CPCS) លើកកម្ពស់សង្គតិភាពនិងភាពយុត្តិធម៌នៅក្នុងគោលនយោបាយកន្លែងធ្វើការ ព្រមទាំងជួយគាំទ្រដល់ការកែលម្អការជ្រើសរើសបុគ្គលិក និងរក្សាទុកមេធាវី ព្រមទាំងបុគ្គលិកផងដែរ។ អ្នកគាំទ្រជាច្រើននាក់បានសង្កត់ធ្ងន់លើបញ្ហាប្រឈមជាបន្តបន្ទាប់ទាក់ទងនឹងបន្ទុកការងារ សំណង និងលក្ខខណ្ឌកន្លែងធ្វើការ ហើយពួកគេបានអះអាងថា ការពង្រីកកិច្ចការពារការងារ និងសិទ្ធិចរចាសមូហភាព នឹងពង្រឹងសមត្ថភាពស្ថាប័នក្នុងការទាក់ទាញ និងរក្សាបុគ្គលិកមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលចុងក្រោយនឹងផ្តល់ផលប្រយោជន៍ដល់កូនក្តីដែល CPCS បានផ្តល់សេវាជូន។

ក្រុមអ្នកជំនាញបានលើកឡើងពីក្តីបារម្ភចំពោះវិសាលភាព និងរចនាសម្ព័ន្ធនៃសេចក្តីស្នើច្បាប់នេះ។ សក្ខីកម្មបានរំលេចអំពីលទ្ធភាពដែលវិធានការនេះអាចនឹងបង្កការរំខានដល់ក្របខណ្ឌគ្រប់គ្រងនិងត្រួតពិនិត្យដែលមានស្រាប់ បង្កើតឱ្យមានភាពមិនច្បាស់លាស់ក្នុងឋានុក្រមនៃសិទ្ធិអំណាច និងបង្កឱ្យមានភាពគ្មានប្រសិទ្ធភាពក្នុងប្រតិបត្តិការ។ សាក្សីមួយចំនួនក៏បានព្រមានផងដែរថា ការផ្លាស់ប្តូរគោលនយោបាយទំនាក់ទំនងការងារក្នុងទំហំបែបនេះ អាចនឹងបង្កើតឱ្យមានផលវិបាកមិនបានគ្រោងទុកចំពោះការផ្តល់សេវាផ្លូវច្បាប់ ជាពិសេសប្រសិនបើការផ្លាស់ប្តូរទាំងនោះរឹតត្បិតសមត្ថភាពស្ថាប័នក្នុងការឆ្លើយតបដោយមានភាពបត់បែនទៅនឹងការប្រែប្រួលនៃចំនួនរឿងក្តី តម្រូវការបុគ្គលិក និងការទាមទាររបស់តុលាការ។

គណៈកម្មាធិការកត់សម្គាល់ថា គណៈកម្មាធិការសេវាមេធាវីការពារក្តីសាធារណៈ (CPCS) ត្រូវបានបង្កើតឡើងដើម្បីធានាថា ជនក្រីក្រនៅក្នុងរដ្ឋម៉ាសាឈូសិតទទួលបានការតំណាងផ្លូវច្បាប់ក្នុងរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីច្បាប់គ្រួសារជាក់លាក់មួយចំនួន ស្របតាមវិសោធនកម្មទីប្រាំមួយនៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក និងមាត្រា XII នៃសេចក្តីប្រកាសស្តីពីសិទ្ធិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាឈូសិត។ មេធាវីការពារក្តីសាធារណៈ និងមេធាវីចាត់តាំង បំពេញមុខងាររដ្ឋធម្មនុញ្ញដ៏មានសារៈសំខាន់បំផុត ហើយតួនាទីរបស់ពួកគេក្នុងការការពារនីតិវិធីត្រឹមត្រូវតាមច្បាប់ និងសមភាពក្នុងការទទួលបានយុត្តិធម៌ គឺជាគ្រឹះដ៏សំខាន់ចំពោះសុចរិតភាពនៃប្រព័ន្ធច្បាប់។

ក្នុងការវាយតម្លៃលើញត្តិនេះ គណៈកម្មាធិការបានពិចារណាយ៉ាងហ្មត់ចត់ចំពោះសក្ខីកម្មរបស់អ្នកជំនាញ អ្នកគាំទ្រ និងសាធារណជនទូទៅ។ ផ្អែកលើបញ្ហានានាដែលត្រូវបានលើកឡើងដោយសក្ខីកម្មនោះ គណៈកម្មាធិការលើកទឹកចិត្តឱ្យបន្តកិច្ចសន្ទនា និងកិច្ចសហការរវាងអ្នកគាំទ្រញត្តិ និងគណៈកម្មាធិការសេវាមេធាវីការពារក្តីសាធារណៈ (CPCS) ដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលបានគូសបញ្ជាក់នៅក្នុងសក្ខីកម្មនោះ។ គណៈកម្មាធិការក៏លើកទឹកចិត្តបន្ថែមទៀតដល់ CPCS ឱ្យបន្តពិនិត្យ និងដោះស្រាយបញ្ហាប្រឈមក្នុងកន្លែងធ្វើការ តាមរបៀបដែលជួយពង្រឹងទាំងសុខុមាលភាពរបស់បុគ្គលិក និងបេសកកម្មស្នូលរបស់ស្ថាប័ន ក្នុងការផ្តល់តំណាងផ្លូវច្បាប់ប្រកបដោយគុណភាពខ្ពស់ដល់កូនក្តីក្រីក្រ។

គួរកត់សម្គាល់ថា មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាឈូសិត ដែលគ្រប់គ្រងដំណើរការញត្តិផ្តួចផ្តើមច្បាប់ តម្រូវឱ្យអគ្គរដ្ឋអាជ្ញា (Attorney General) ផ្តល់ការបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាដែលបំពេញតាមលក្ខខណ្ឌកំណត់ជាក់លាក់ ដូចមានចែងនៅក្នុងមាត្រា 48 នោះ។ ក្នុងការសម្រេចថាតើត្រូវបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាមួយដែរឬទេនោះ អគ្គរដ្ឋអាជ្ញាមិនធ្វើការវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញក្នុងវិសាលភាពកាន់តែទូលំទូលាយរបស់ញត្តិនោះឡើយ ពោលគឺការសម្រេចបញ្ជាក់ទទួលស្គាល់របស់គាត់ ត្រូវបានកម្រិតត្រឹមតែលក្ខណវិនិច្ឆ័យចង្អៀតដែលមានចែងនៅក្នុងមាត្រា 48 តែប៉ុណ្ណោះ។ ដូចនេះ ញត្តិនេះត្រូវបានបញ្ជាក់ទទួលស្គាល់ដោយអគ្គរដ្ឋអាជ្ញាក្រោមមាត្រា 48 រួចរាល់ហើយ ប៉ុន្តែរូបគាត់ ឬតុលាការមិនទាន់បានវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញរបស់វានាពេលបច្ចុប្បន្ននេះនៅឡើយទេ។

អាស្រ័យហេតុនេះ ភាគច្រើននៃគណៈកម្មាធិការបានផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-22 សេចក្តីព្រាងច្បាប់សភាលេខ 5009 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងគោលនយោបាយទំនាក់ទំនងការងារសម្រាប់បុគ្គលិកគណៈកម្មាធិការសេវាមេធាវី*

## សំណួរទី 2៖ របាយការណ៍សំឡេងភាគច្រើន (ត)

*ការពារក្តីសាធារណៈ។*

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
|---|---|
| Cindy F. Friedman | Alice Hanlon Peisch |
| Brendan P. Crighton | Kate Hogan |
| Barry R. Finegold | Frank A. Moran |
| | Michael S. Day |
| | David T. Vieira |

## សំណួរទី 3៖ របាយការណ៍សំឡេងភាគច្រើន

ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (Special Joint Committee on Initiative Petitions)

មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត អនុញ្ញាតឱ្យអ្នកបោះឆ្នោតអាចស្នើច្បាប់ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញបាន តាមរយៈញត្តិផ្តួចផ្តើម ឬហៅជាទូទៅថា សំណួរនៅលើសន្លឹកឆ្នោត។ បន្ទាប់ពីការប្រមូលហត្ថលេខាគ្រប់គ្រាន់តាមការកំណត់ និងការដាក់ជូនហត្ថលេខាបញ្ជាក់ត្រឹមត្រូវទៅរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋរួចមក ញត្តិនោះនឹងត្រូវដាក់ជូនទៅស្ថាប័ននីតិប្បញ្ញត្តិជាផ្លូវការ ដើម្បីធ្វើការពិចារណា។ បន្ទាប់មក ញត្តិនោះនឹងត្រូវបញ្ជូនទៅកាន់គណៈកម្មាធិការមួយ ដែលក្នុងករណីនេះ គឺគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម។

យោងតាមមាត្រា 48 គណៈកម្មាធិការនេះត្រូវតែរាយការណ៍ជូនស្ថាប័ននីតិប្បញ្ញត្តិអំពីញត្តិនីមួយៗ ឱ្យបានមុនថ្ងៃពុធសប្តាហ៍ទីមួយនៃខែឧសភា។ ខុសពីដំណើរការនីតិប្បញ្ញត្តិស្តង់ដា ស្ថាប័ននីតិប្បញ្ញត្តិអាចអនុម័ត ឬបដិសេធញត្តិផ្តួចផ្តើមតាមទម្រង់ដែលបានដាក់ជូនតែប៉ុណ្ណោះ ដោយមិនធ្វើការកែប្រែណាមួយឡើយ។

គណៈកម្មាធិការនេះបានរៀបចំសវនាការស្តីពីញត្តិផ្តួចផ្តើម 25-12 សេចក្តីព្រាងច្បាប់សភាលេខ 5003 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការអនុវត្តការបោះឆ្នោតបឋមថ្នាក់រដ្ឋសម្រាប់គ្រប់គណបក្សនយោបាយ* កាលពីថ្ងៃទី 31 ខែមីនា ឆ្នាំ 2026។ គណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម បានរៀបចំសវនាការជាសាធារណៈពេញមួយខែមីនា ឆ្នាំ 2026 ដើម្បីប្រមូលសក្ខីកម្ម និងព័ត៌មានជាមូលដ្ឋានក្នុងការពិនិត្យឡើងវិញរបស់ខ្លួន។ គណៈកម្មាធិការនេះបានពិចារណាមតិយោបល់ពីអ្នកជំនាញឯកទេស ភាគីអ្នកគាំទ្រ និងភាគីអ្នកប្រឆាំងនឹងញត្តិនេះ ក៏ដូចជាសាធារណជនទូទៅផងដែរ។ កំណត់ត្រាសវនាការទាំងស្រុង និងឯកសារគាំទ្រនានា មានផ្តល់ជូនសាធារណជនតាមតំណភ្ជាប់ malegislature.gov/Events/Hearings/Detail/5632។

កាលពីថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026 ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (ហៅកាត់ថា "គណៈកម្មាធិការ") បានបោះឆ្នោតផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-12/សេចក្តីព្រាងច្បាប់សភាលេខ 5003 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការអនុវត្តការបោះឆ្នោតបឋមថ្នាក់រដ្ឋសម្រាប់គ្រប់គណបក្សនយោបាយ* (ហៅកាត់ថា "ញត្តិ")។

ដើម្បីសម្រេចសេចក្តីសន្និដ្ឋាននេះ គណៈកម្មាធិការបានធ្វើការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយនូវវិធានការដែលបានស្នើ រួមទាំងការវិភាគយ៉ាងលម្អិតលើពាក្យពេចន៍ រចនាសម្ព័ន្ធ និងផលប៉ះពាល់រំពឹងទុករបស់វា។ គណៈកម្មាធិការបានវាយតម្លៃសក្ខីកម្ម និងភស្តុតាងគាំទ្រនានាដែលបានបង្ហាញក្នុងអំឡុងពេលសវនាការសាធារណៈ ព្រមទាំងមតិយោបល់ជាលាយលក្ខណ៍អក្សរបន្ថែមពីសំណាក់មន្ត្រីរៀបចំការបោះឆ្នោត អ្នកជំនាញខាងគោលនយោបាយ អង្គការតស៊ូមតិ និងសាធារណជនទូទៅ។ សក្ខីកម្មនេះបានលើកឡើងអំពីផលប៉ះពាល់ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុនៃការអនុវត្តសំណើនេះ ទាំងនៅថ្នាក់រដ្ឋនិងថ្នាក់ក្រុង ព្រមទាំងក្តីបារម្ភថា ការបោះឆ្នោតបឋមសម្រាប់គ្រប់គណបក្ស អាចបណ្តាលឱ្យមានការបំបែកការថយចុះទំនួលខុសត្រូវរបស់គណបក្ស ការយល់ច្រឡំរបស់អ្នកបោះឆ្នោត និងការបោះឆ្នោតបែបយុទ្ធសាស្ត្រ ដែលជាញឹកញាប់បង្កផលវិបាកដល់បេក្ខជនដែលមានកញ្ចប់ថវិកាតិចតួច ហើយបង្កើតឱ្យមានលទ្ធផលដែលមិនអាចទស្សន៍ទាយទុកជាមុនបាន ឬលទ្ធផលដែលមិនតំណាងឱ្យឆន្ទៈពិតប្រាកដរបស់ពលរដ្ឋ។

ញត្តិនេះនឹងកែទម្រង់វិធីសាស្ត្ររបស់រដ្ឋម៉ាសាឈូសិត ក្នុងការជ្រើសរើសបេក្ខជនសម្រាប់ការបោះឆ្នោតសកល ដោយលុបបំបាត់ការបោះឆ្នោតបឋមតាមបក្សនយោបាយនីមួយៗ ហើយប្តូរមកអនុវត្តការបោះឆ្នោតបឋមថ្នាក់រដ្ឋសម្រាប់ "គ្រប់គណបក្ស" ជំនួសវិញ។ នៅក្រោមប្រព័ន្ធដែលបានស្នើនេះ ឬដែលត្រូវបានហៅផងដែរថាជាការបោះឆ្នោតបឋមយក "បេក្ខជនកំពូលពីររូប" នៅក្នុងយុត្តាធិការផ្សេងទៀតដែលអនុវត្តរចនាសម្ព័ន្ធប្រហាក់ប្រហែលគ្នានេះ បេក្ខជនឈរឈ្មោះសម្រាប់តំណែងជាប់ឆ្នោត ត្រូវប្រកួតប្រជែងនៅក្នុងការបោះឆ្នោតបឋមជាមួយបេក្ខជនដទៃទៀតទាំងអស់សម្រាប់តំណែងនោះ ហើយមានតែបេក្ខជនពីររូបដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេលំដាប់ទីមួយ និងទីពីរនៅក្នុងការបោះឆ្នោតបឋមប៉ុណ្ណោះ ទើបអាចឈានទៅប្រកួតបន្តនៅក្នុងការបោះឆ្នោតសកលបាន។

ប្រព័ន្ធនៃការបោះឆ្នោតបឋមតាមបក្សនយោបាយដែលរៀបចំដោយរដ្ឋម៉ាសាឈូសិត ត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ 1911 ដោយបង្កើតឱ្យមានការតែងតាំងបេក្ខជនដោយផ្ទាល់ពីសំណាក់អ្នកបោះឆ្នោតសម្រាប់តំណែងថ្នាក់រដ្ឋ។ ច្បាប់នេះបានផ្លាស់ប្តូរការអនុវត្តនាសម័យនោះ ដែលគណបក្សនីមួយៗមានអំណាចគ្រប់គ្រងលើវិធីសាស្ត្រតែងតាំងបេក្ខជនធ្វើជាតំណាងឱ្យគណបក្សរបស់ខ្លួននៅក្នុងការបោះឆ្នោតសកល។ ញត្តិដែលបានស្នើនេះ នឹងលុបបំបាត់លទ្ធភាពរបស់អ្នកបោះឆ្នោតក្នុងការជ្រើសរើសបេក្ខជនដែលខ្លួនចង់បានឱ្យធ្វើជាតំណាងឱ្យគណបក្សដែលខ្លួនពេញចិត្តនៅក្នុងការបោះឆ្នោតសកល ហើយផ្ទុយទៅវិញ នឹងតម្រូវឱ្យអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតបឋម បោះឆ្នោតជូនបេក្ខជនតែម្នាក់គត់សម្រាប់តំណែងនោះក្នុងចំណោមបេក្ខជនទាំងអស់ ដោយមិនគិតពីនិន្នាការគណបក្សនយោបាយឡើយ។

ញត្តិនេះស្នើឱ្យមានប្រព័ន្ធថ្មីមួយដើម្បីដោះស្រាយការលុបបំបាត់ការបោះឆ្នោតបឋមតាមបក្សនយោបាយ ដែលតាមរយៈប្រព័ន្ធថ្មីនេះ បេក្ខជនឈរឈ្មោះសម្រាប់តំណែងនានានឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញពីនិន្នាការគណបក្សរបស់ខ្លួននៅលើសន្លឹកឆ្នោតទាំងសម្រាប់ការបោះឆ្នោតបឋម និងការបោះឆ្នោតសកល ដោយផ្អែកលើ

# របាយការណ៍របស់ស្ថាប័ននីតិប្បញ្ញត្តិ (ត)

## សំណួរទី 3៖ របាយការណ៍សំឡេងភាគច្រើន (ត)

ការចុះឈ្មោះបោះឆ្នោតរបស់ពួកគេ ព្រមទាំងអនុញ្ញាតឱ្យបង្ហាញការគាំទ្រជាផ្លូវការដែលទើបបង្កើតថ្មីដោយគណបក្ស ឬដោយការចាត់តាំងនយោបាយ ដែលអាចនឹងមានរៀបរាប់លើសន្លឹកឆ្នោតផងដែរ។

ភាគីអ្នកស្នើញត្តិបានផ្តល់សក្ខីកម្មថា ការគាំទ្រជាផ្លូវការថ្មីនេះ នឹងផ្តល់លទ្ធភាពឱ្យគណបក្សនយោបាយ និងការចាត់តាំងនយោបាយនានា មានសំឡេងបញ្ជាក់ច្បាស់លាស់ក្នុងការជ្រើសរើសបេក្ខជនដែលជាទីពេញចិត្តរបស់គណបក្សពួកគេ។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថា វិធីសាស្ត្របែបនេះបច្ចុប្បន្នមិនទាន់មានអនុវត្តសម្រាប់គណបក្សធំៗទាំងពីរផ្អែកតាមការចុះឈ្មោះបោះឆ្នោតនៅក្នុងរដ្ឋម៉ាសាឈូសិតនោះឡើយ ពោលគឺគណបក្សប្រជាធិបតេយ្យ និងគណបក្សសាធារណរដ្ឋ។ បច្ចុប្បន្ននេះ គណបក្សទាំងនេះប្រើប្រាស់សន្និបាតដើម្បីគាំទ្រជាផ្លូវការដល់បេក្ខជនសម្រាប់តំណែងជាប់ឆ្នោតទូទាំងរដ្ឋ ប៉ុន្តែការគាំទ្រជាផ្លូវការរបស់គណបក្សនេះ បច្ចុប្បន្នមិនលេចឡើងជាសញ្ញាសម្គាល់នៅលើសន្លឹកឆ្នោតនៅក្នុងការបោះឆ្នោតបឋមតាមបក្សនយោបាយនោះឡើយ។ ដោយសារតែបច្ចុប្បន្នមិនទាន់មានវិធីសាស្ត្រ ឬហេដ្ឋារចនាសម្ព័ន្ធសម្រាប់គណបក្សធំៗទាំងពីរ ក្នុងការផ្តល់ការគាំទ្រដល់បេក្ខជនសម្រាប់តំណែងថ្នាក់ក្រោមរដ្ឋ ញត្តិនេះនៅមិនទាន់មានភាពច្បាស់លាស់អំពីរបៀបអនុវត្តដំណើរការ និងរបៀបទទួលបានការគាំទ្រពីគណបក្សនៅឡើយទេ ព្រមទាំងលទ្ធភាពដែលគណបក្សនានាអាចប្រើប្រាស់ដំណើរការឯកជន ឬដំណើរការមិនយុត្តិធម៌ណាមួយដើម្បីកំណត់វិធីសាស្ត្រនៃការគាំទ្រ ដែលអាចជះឥទ្ធិពលខ្លាំងដល់ការបោះឆ្នោត ដែលចំណុចនេះនឹងផ្ទុយស្រឡះពីកំណែទម្រង់ការបោះឆ្នោតបឋមឆ្នាំ 1911 និងគោលដៅដែលបានថ្លែងបញ្ជាក់របស់អ្នកស្នើញត្តិ។

អ្នកស្នើញត្តិបានបង្ហាញជំហរអះអាងថា ញត្តិនេះនឹងបង្កើនការចូលរួមរបស់អ្នកបោះឆ្នោត និងបង្កើនចំនួនមន្ត្រីជាប់ឆ្នោតមកពីគណបក្សទីបី ឬដែលជាអ្នកនយោបាយឯករាជ្យមិនចំណុះឱ្យគណបក្សណាមួយ។ ភស្តុតាងដែលមានស្រាប់មិនបានបង្ហាញថា ការអះអាងទាំងពីរនេះត្រឹមត្រូវនោះឡើយ។ នៅក្នុងការសិក្សាមួយស្តីពីផលប៉ះពាល់នៃការផ្លាស់ប្តូររបស់រដ្ឋកាលីហ្វ័រញ៉ា ទៅជាប្រព័ន្ធបោះឆ្នោតបឋមយក "បេក្ខជនកំពូលពីររូប" ភស្តុតាងបានបង្ហាញថា ចំនួនអ្នកទៅបោះឆ្នោតនៅក្នុងការបោះឆ្នោតបឋមមានការកើនឡើង ប៉ុន្តែផ្ទុយទៅវិញ ការចូលរួមនៅក្នុងការបោះឆ្នោតសកលមានការថយចុះ នៅពេលប្រៀបធៀបដំណើរការទាំងពីរនេះទៅនឹងដំណើរការបោះឆ្នោតបឋមតាមបក្សនយោបាយកាលពីមុន។ ពោលគឺ ដំណើរការនេះបានជះឥទ្ធិពលអវិជ្ជមានបន្ថែមទៅដល់ការកាត់បន្ថយការចូលរួមរបស់អ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតសកលនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។ ជាងនេះទៀត តាមរយៈការពិនិត្យឡើងវិញនូវសមាសភាពស្ថាប័ននីតិប្បញ្ញត្តិ នៃរដ្ឋកាលីហ្វ័រញ៉ា និងរដ្ឋវ៉ាស៊ីនតោន បានបង្ហាញថា គ្មានសមាជិកមកពីគណបក្សទីបី ឬសមាជិកឯករាជ្យមិនចំណុះឱ្យគណបក្សណាមួយ កំពុងបម្រើការជាសមាជិកសកម្មនោះឡើយ ដែលចំនួននេះគឺតិចជាងសមាសភាពសភានាពេលបច្ចុប្បន្នរបស់រដ្ឋម៉ាសាឈូសិត ដែលមិនបានប្រើប្រាស់ប្រព័ន្ធបោះឆ្នោតបឋមយក "បេក្ខជនកំពូលពីររូប" នោះទៅទៀត។ អ្នកស្នើញត្តិបានថ្លែងថា រដ្ឋអាឡាស្កាមានសមាជិកសភាដែលឯករាជ្យមិនចំណុះឱ្យគណបក្ស ប៉ុន្តែរដ្ឋអាឡាស្កាប្រើប្រាស់ប្រព័ន្ធបោះឆ្នោតបឋមយក "បេក្ខជនកំពូលបួនរូប" ផ្សារភ្ជាប់ជាមួយនឹងការបោះឆ្នោតផ្អែកលើចំណាត់ថ្នាក់បេក្ខជនសម្រាប់ការបោះឆ្នោតសកល ដែលជាប្រព័ន្ធរួមបញ្ចូលគ្នាទាំងស្រុងមួយខុសគ្នាស្រឡះពីអ្វីដែលញត្តិនេះបានស្នើឡើង។ ដូចដែលបានព្រាងជាលាយលក្ខណ៍អក្សរ ការអនុវត្តញត្តិនេះអាចនាំឱ្យការបោះឆ្នោតសកលមានតែបេក្ខជនពីររូបមកពីគណបក្សធំតែមួយគត់ សម្រាប់ឱ្យអ្នកបោះឆ្នោតធ្វើការជ្រើសរើស ដូចជា បេក្ខជនមកពីគណបក្សសាធារណរដ្ឋទាំងពីររូប ឬបេក្ខជនមកពីគណបក្សប្រជាធិបតេយ្យទាំងពីររូបជាដើម។ ករណីបែបនេះបានកើតឡើងរួចមកហើយនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ហើយវាត្រូវបានបញ្ជាក់ថាជាកត្តារួមចំណែកមួយ នាំឱ្យមានការថយចុះនៃចំនួនអ្នកទៅបោះឆ្នោតនៅក្នុងការបោះឆ្នោតសកល។

គួរកត់សម្គាល់ថា មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត ដែលគ្រប់គ្រងដំណើរការញត្តិផ្តួចផ្តើម តម្រូវឱ្យអគ្គរដ្ឋអាជ្ញាផ្តល់ការបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាដែលបំពេញតាមលក្ខខណ្ឌកំណត់ជាក់លាក់ ដូចមានចែងនៅក្នុងមាត្រា 48 នោះ។ ក្នុងការសម្រេចថាតើត្រូវបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាមួយដែរឬទេនោះ អគ្គរដ្ឋអាជ្ញាមិនធ្វើការវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញក្នុងវិសាលភាពកាន់តែទូលំទូលាយរបស់ញត្តិនោះឡើយ ពោលគឺការសម្រេចបញ្ជាក់ទទួលស្គាល់របស់គាត់ ត្រូវបានកម្រិតត្រឹមតែលក្ខណវិនិច្ឆ័យចង្អៀតដែលមានចែងនៅក្នុងមាត្រា 48 តែប៉ុណ្ណោះ។ ដូចនេះ ញត្តិនេះត្រូវបានបញ្ជាក់ទទួលស្គាល់ដោយអគ្គរដ្ឋអាជ្ញាក្រោមមាត្រា 48 រួចរាល់ហើយ ប៉ុន្តែរូបគាត់ ឬតុលាការមិនទាន់បានវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញរបស់វានាពេលបច្ចុប្បន្ននេះនៅឡើយទេ។

អាស្រ័យហេតុនេះ ភាគច្រើននៃគណៈកម្មាធិការបានផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ **ចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-12/សេចក្តីព្រាងច្បាប់សភាលេខ 5003 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោតបឋមថ្នាក់រដ្ឋសម្រាប់គ្រប់គណបក្សនយោបាយ។*

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
| --- | --- |
| Cindy F. Friedman | Alice Hanlon Peisch |
| Brendan P. Crighton | Kate Hogan |
| Paul R. Feeney | Frank A. Moran |
| | Michael S. Day |
| | David T. Vieira |

# សំណួរទី 4៖ របាយការណ៍សំឡេងភាគច្រើន

ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្ដីពីញត្តិផ្តួចផ្តើម (Special Joint Committee on Initiative Petitions)

មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត អនុញ្ញាតឱ្យអ្នកបោះឆ្នោតអាចស្នើច្បាប់ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញបាន តាមរយៈញត្តិផ្តួចផ្តើម ឬហៅជាទូទៅថា សំណួរនៅលើសន្លឹកឆ្នោត។ បន្ទាប់ពីការប្រមូលហត្ថលេខាគ្រប់គ្រាន់តាមការកំណត់ និងការដាក់ជូនហត្ថលេខាបញ្ជាក់ត្រឹមត្រូវទៅរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋរួចមក ញត្តិនោះនឹងត្រូវដាក់ជូនទៅស្ថាប័ននីតិប្បញ្ញត្តិជាផ្លូវការ ដើម្បីធ្វើការពិចារណា។ បន្ទាប់មក ញត្តិនោះនឹងត្រូវបញ្ជូនទៅកាន់គណៈកម្មាធិការមួយ ដែលក្នុងករណីនេះ គឺគណៈកម្មាធិការចម្រុះពិសេសស្ដីពីញត្តិផ្តួចផ្តើម។

យោងតាមមាត្រា 48 គណៈកម្មាធិការនេះត្រូវតែរាយការណ៍ជូនស្ថាប័ននីតិប្បញ្ញត្តិអំពីញត្តិនីមួយៗ ឱ្យបានមុនថ្ងៃពុធសប្ដាហ៍ទីមួយនៃខែឧសភា។ ខុសពីដំណើរការនីតិប្បញ្ញត្តិស្តង់ដា ស្ថាប័ននីតិប្បញ្ញត្តិអាចអនុម័ត ឬបដិសេធញត្តិផ្តួចផ្តើមទៅតាមទម្រង់ដែលបានដាក់ជូនតែប៉ុណ្ណោះ ដោយមិនធ្វើការកែប្រែណាមួយឡើយ។

គណៈកម្មាធិការនេះបានរៀបចំសវនាការស្ដីពីញត្តិផ្តួចផ្តើម 25-08 សេចក្ដីព្រាងច្បាប់សភាលេខ 5001 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោត* កាលពីថ្ងៃទី 3 ខែមីនា ឆ្នាំ 2026។ គណៈកម្មាធិការចម្រុះពិសេសស្ដីពីញត្តិផ្តួចផ្តើម បានរៀបចំសវនាការសាធារណៈពេញមួយខែមីនា ឆ្នាំ 2026 ដើម្បីប្រមូលសក្ខីកម្ម និងព័ត៌មានជាមូលដ្ឋានក្នុងការពិនិត្យឡើងវិញរបស់ខ្លួន។ គណៈកម្មាធិការនេះបានពិចារណាមតិយោបល់ពីអ្នកជំនាញឯកទេស អ្នកគាំទ្រ និងអ្នកជំទាស់នឹងញត្តិផ្តួចផ្តើម ក៏ដូចជាសាធារណជនទូទៅផងដែរ។ កំណត់ត្រាសវនាការទាំងស្រុង និងឯកសារគាំទ្រនានា មានផ្ដល់ជូនសាធារណជនតាមតំណភ្ជាប់ malegislature.gov/Events/Hearings/Detail/5603។

កាលពីថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026 ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្ដីពីញត្តិផ្តួចផ្តើម (ហៅកាត់ថា "គណៈកម្មាធិការ") បានបោះឆ្នោតផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-08/សេចក្តីព្រាងច្បាប់សភាលេខ 5001 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោត* (ហៅកាត់ថា "ញត្តិ")។

ដើម្បីសម្រេចសេចក្ដីសន្និដ្ឋាននេះ គណៈកម្មាធិការបានធ្វើការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយនូវវិធានការដែលបានស្នើ រួមទាំងការវិភាគយ៉ាងលម្អិតលើពាក្យពេចន៍ រចនាសម្ព័ន្ធ និងផលប៉ះពាល់រំពឹងទុករបស់វា។ គណៈកម្មាធិការបានវាយតម្លៃសក្ខីកម្ម និងភស្តុតាងគាំទ្រនានាដែលបានបង្ហាញក្នុងអំឡុងពេលសវនាការសាធារណៈ ព្រមទាំងការដាក់ជូនឯកសារគាំទ្រជាលាយលក្ខណ៍អក្សរពីសំណាក់មន្ត្រីរៀបចំការបោះឆ្នោត អ្នកជំនាញខាងគោលនយោបាយ អង្គការតស៊ូមតិ និងសាធារណជនទូទៅ។ បន្ថែមលើនេះ ផលប៉ះពាល់ផ្នែកច្បាប់ ផ្នែករដ្ឋបាល និងផ្នែកសារពើពន្ធដែលអាចកើតមានឡើង ពាក់ព័ន្ធនឹងការអនុវត្តសំណើនេះ ទាំងនៅថ្នាក់រដ្ឋនិងថ្នាក់ក្រុង ត្រូវបានលើកឡើង រួមជាមួយនឹងការកំណត់តម្រូវការបុគ្គលិក និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ដែលអ្នកផ្តល់សក្ខីកម្មជឿជាក់ថាមានភាពចាំបាច់ក្នុងការអនុវត្តការចុះឈ្មោះបោះឆ្នោតក្នុងថ្ងៃតែមួយ។

ញត្តិនេះបានស្នើឱ្យបង្កើតប្រព័ន្ធចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោត អនុញ្ញាតឱ្យអ្នកបោះឆ្នោតដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ អាចចុះឈ្មោះនិងបោះឆ្នោតបានក្នុងថ្ងៃតែមួយ រួមទាំងក្នុងអំឡុងពេលនៃការបោះឆ្នោតមុនកាលកំណត់ និងនៅក្នុងថ្ងៃបោះឆ្នោតផ្ទាល់តែម្តង។ គណៈកម្មាធិការទទួលស្គាល់នូវសារៈសំខាន់នៃការលើកកម្ពស់ការចូលរួមក្នុងកិច្ចការពលរដ្ឋ និងការធានាឱ្យមានលទ្ធភាពចូលរួមយ៉ាងទូលំទូលាយ និងប្រកបដោយសមធម៌នៅក្នុងដំណើរការបោះឆ្នោត។

គណៈកម្មាធិការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងកំពុងអនុវត្ត ក្នុងការពង្រីកលទ្ធភាពទទួលបាន និងការចូលរួមរបស់អ្នកបោះឆ្នោត ប៉ុន្តែបានរកឃើញថា ញត្តិសរសេរឡើងនេះ (ដែលស្ថាប័ននីតិប្បញ្ញត្តិមិនអាចកែប្រែបាន) មិនបានដោះស្រាយឱ្យបានគ្រប់គ្រាន់នូវបញ្ហាប្រឈមផ្នែកដំណើរការ ដូចបានលើកឡើងនៅក្នុងសក្ខីកម្មដែលខ្លួនបានទទួលនោះទេ។

គួរកត់សម្គាល់ថា មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាឈូសិត ដែលគ្រប់គ្រងដំណើរការញត្តិផ្តួចផ្តើមច្បាប់ តម្រូវឱ្យអគ្គរដ្ឋអាជ្ញា (Attorney General) ផ្តល់ការបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាដែលបំពេញតាមលក្ខខណ្ឌកំណត់ជាក់លាក់ ដូចមានចែងនៅក្នុងមាត្រា 48 នោះ។ ក្នុងការសម្រេចថាតើត្រូវបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាមួយដែរឬទេនោះ អគ្គរដ្ឋអាជ្ញាមិនធ្វើការវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញក្នុងវិសាលភាពកាន់តែទូលំទូលាយរបស់ញត្តិនោះឡើយ ពោលគឺការសម្រេចបញ្ជាក់ទទួលស្គាល់របស់គាត់ ត្រូវបានកម្រិតត្រឹមតែលក្ខណវិនិច្ឆ័យចង្អៀតដែលមានចែងនៅក្នុងមាត្រា 48 តែប៉ុណ្ណោះ។ ដូចនេះ ញត្តិនេះត្រូវបានបញ្ជាក់ទទួលស្គាល់ដោយអគ្គរដ្ឋអាជ្ញាក្រោមមាត្រា 48 រួចរាល់ហើយ ប៉ុន្តែរូបគាត់ ឬតុលាការមិនទាន់បានវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញរបស់វានាពេលបច្ចុប្បន្ននេះនៅឡើយទេ។

អាស្រ័យហេតុនេះ ភាគច្រើននៃគណៈកម្មាធិការបានផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-08 ពង្រាងលេខ 5001 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោតនៅថ្ងៃបោះឆ្នោត*។

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
| --- | --- |
| Cindy F. Friedman | Alice Hanlon Peisch |
| Brendan P. Crighton | Kate Hogan |
| Barry R. Finegold | Frank A. Moran |
| | Michael S. Day |
| | David T. Vieira |

## សំណួរទី 5៖ របាយការណ៍សំឡេងភាគច្រើន

***កំណត់សម្គាល់៖*** *របាយការណ៍ដែលពាក់ព័ន្ធនឹងសំណួរទី 5 មានការលើកឡើងជាច្រើនដងអំពី "ញត្តិផ្តួចផ្តើមសម្រាប់ច្បាប់ស្តីពីការកាត់បន្ថយអត្រាពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួនរបស់រដ្ឋ ពី 5% មក 4%"។ ញត្តិផ្តួចផ្តើមនេះ មិនមែនជាសំណួរមួយក្នុងចំណោមសំណួរដែលនឹងបង្ហាញនៅលើសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតរដ្ឋឆ្នាំ 2026 នោះទេ។*

ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (Special Joint Committee on Initiative Petitions)

មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត អនុញ្ញាតឱ្យអ្នកបោះឆ្នោតអាចស្នើច្បាប់ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញបាន តាមរយៈញត្តិផ្តួចផ្តើម ឬហៅជាទូទៅថា សំណួរនៅលើសន្លឹកឆ្នោត។ បន្ទាប់ពីការប្រមូលហត្ថលេខាគ្រប់គ្រាន់តាមការកំណត់ និងការដាក់ជូនហត្ថលេខាបញ្ជាក់ត្រឹមត្រូវទៅរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋរួចមក ញត្តិនោះនឹងត្រូវដាក់ជូនទៅស្ថាប័ននីតិប្បញ្ញត្តិជាផ្លូវការ ដើម្បីធ្វើការពិចារណា។ បន្ទាប់មក ញត្តិនោះនឹងត្រូវបញ្ជូនទៅកាន់គណៈកម្មាធិការមួយ ដែលក្នុងករណីនេះ គឺគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម។

យោងតាមមាត្រា 48 គណៈកម្មាធិការនេះត្រូវតែរាយការណ៍ជូនស្ថាប័ននីតិប្បញ្ញត្តិអំពីញត្តិនីមួយៗ ឱ្យបានមុនថ្ងៃពុធសប្តាហ៍ទីមួយនៃខែឧសភា។ ខុសពីដំណើរការនីតិប្បញ្ញត្តិស្តង់ដា ស្ថាប័ននីតិប្បញ្ញត្តិអាចអនុម័ត ឬបដិសេធញត្តិផ្តួចផ្តើមទៅតាមទម្រង់ដែលបានដាក់ជូនតែប៉ុណ្ណោះ ដោយមិនធ្វើការកែប្រែណាមួយឡើយ។

កាលពីថ្ងៃទី 30 ខែមីនា ឆ្នាំ 2026 គណៈកម្មាធិការបានរៀបចំសវនាការលើញត្តិផ្តួចផ្តើម 25-17 សេចក្តីព្រាងច្បាប់សភាលេខ 5006 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការកំណត់កំណើននៃការប្រមូលពន្ធរបស់រដ្ឋ និងការបង្វិលថវិកាលើសជូនដល់អ្នកបង់ពន្ធវិញ* និងញត្តិផ្តួចផ្តើម 25-18 សេចក្តីព្រាងច្បាប់សភាលេខ 5007 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការកាត់បន្ថយអត្រាពន្ធលើប្រាក់ចំណូលបុគ្គលរបស់រដ្ឋពី 5% មកត្រឹម 4%។ គណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម បានរៀបចំសវនាការសាធារណៈពេញមួយខែមីនា ឆ្នាំ 2026 ដើម្បីប្រមូលសក្ខីកម្ម និងព័ត៌មានជាមូលដ្ឋានក្នុងការពិនិត្យឡើងវិញរបស់ខ្លួន។ គណៈកម្មាធិការនេះបានពិចារណាមតិយោបល់ពីអ្នកជំនាញឯកទេស អ្នកគាំទ្រ និងអ្នកជំទាស់នឹងញត្តិផ្តួចផ្តើម ក៏ដូចជាសាធារណជនទូទៅផងដែរ។ កំណត់ត្រាសវនាការទាំងស្រុង និងឯកសារគាំទ្រនានា មានផ្តល់ជូនសាធារណជនតាមតំណភ្ជាប់* malegislature.gov/Events/Hearings/Detail/5631.

កាលពីថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026 ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (ហៅកាត់ថា "គណៈកម្មាធិការ") បានបោះឆ្នោតគាំទ្រក្នុងការផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-17 សេចក្តីព្រាងច្បាប់សភាលេខ 5006 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការកំណត់កំណើននៃការប្រមូលពន្ធរបស់រដ្ឋ និងការបង្វិលថវិកាលើសជូនដល់អ្នកបង់ពន្ធវិញ* និងញត្តិផ្តួចផ្តើម 25-18 សេចក្តីព្រាងច្បាប់សភាលេខ 5007 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការកាត់បន្ថយអត្រាពន្ធលើប្រាក់ចំណូលបុគ្គលរបស់រដ្ឋពី 5% មកត្រឹម 4%*។

ដើម្បីសម្រេចសេចក្តីសន្និដ្ឋាននេះ គណៈកម្មាធិការបានធ្វើការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយនូវវិធានការដែលបានស្នើ រួមទាំងការវិភាគយ៉ាងលម្អិតលើពាក្យពេចន៍ រចនាសម្ព័ន្ធ និងផលប៉ះពាល់រំពឹងទុករបស់វា។ គណៈកម្មាធិការបានវាយតម្លៃសក្ខីកម្ម និងភស្តុតាងគាំទ្រនានាដែលបានបង្ហាញក្នុងអំឡុងពេលសវនាការសាធារណៈ ព្រមទាំងការដាក់ជូនឯកសារគាំទ្រជាលាយលក្ខណ៍អក្សរពីសំណាក់អ្នកជំនាញខាងគោលនយោបាយនិងសេដ្ឋកិច្ច អង្គការការងារនិងតស៊ូមតិ និងសាធារណជនទូទៅ។ ការពិនិត្យឡើងវិញបានរកឃើញថា ញត្តិផ្តួចផ្តើមទាំងពីរនេះរួមបញ្ចូលគ្នា នឹងធ្វើឱ្យចុះខ្សោយខ្លាំងដល់សមត្ថភាពរបស់រដ្ឋម៉ាសាឈូសិត ក្នុងការឆ្លើយតបទៅនឹងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ច តាមរយៈការកាត់បន្ថយចំណូល ការកម្រិតកញ្ចប់ថវិកាបម្រុង និងការជំរុញឱ្យមានការបង្វិលប្រាក់ពន្ធជូនវិញ បន្ទាប់ពីមានវិបត្តិសេដ្ឋកិច្ច ដែលបង្កហានិភ័យដល់ការផ្តល់ថវិកាសម្រាប់សេវាសំខាន់ៗ ព្រមទាំងផ្តល់ផលប្រយោជន៍មិនសមាមាត្រនេះដល់អ្នកមានប្រាក់ចំណូលខ្ពស់ ធៀបទៅនឹងប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាបនិងមធ្យម។

ប្រសិនបើត្រូវបានអនុវត្ត ញត្តិទាំងពីរនេះនឹងកាត់បន្ថយ ឬកម្រិតចំនួនប្រាក់ចំណូលដែលរដ្ឋាភិបាលទទួលបាននៅក្នុងឆ្នាំសារពើពន្ធនីមួយៗ។ យោងតាមការវិភាគរបស់មូលនិធិអ្នកបង់ពន្ធរដ្ឋម៉ាសាឈូសិត (Massachusetts Taxpayers Foundation) ញត្តិដែលកាត់បន្ថយពន្ធលើប្រាក់ចំណូលពី 5% មកត្រឹម 4% នឹងបណ្តាលឱ្យមានការខាតបង់ចំណូលរដ្ឋតាមការព្យាករចំនួនជាង 5.3 ពាន់លានដុល្លារ ពេញមួយឆ្នាំសារពើពន្ធដំបូង បន្ទាប់ពីការអនុវត្ត។ ការកាត់បន្ថយនេះគឺស្មើនឹង 406.7% នៃជំនួយរដ្ឋបាលរដ្ឋាភិបាលទូទៅឥតលក្ខខណ្ឌ (Unrestricted General Government Aid) សម្រាប់ឆ្នាំសារពើពន្ធ 2026 ដែលជាជំនួយរបស់រដ្ឋផ្តល់ដោយផ្ទាល់ទៅដល់ក្រុងនិងស្រុក ដើម្បីកាត់បន្ថយចំនួននៃការចំណាយមូលដ្ឋានដែលផ្តល់មូលនិធិដោយពន្ធលើអចលនទ្រព្យ ឬស្មើនឹង 73.1% នៃជំនួយអប់រំជំពូក 70 សម្រាប់ឆ្នាំសារពើពន្ធ 2026 ដែលជាជំនួយរបស់រដ្ឋដល់ក្រុង ស្រុក និងមណ្ឌលសិក្សាធិការប្រចាំតំបន់ ដើម្បីរ៉ាប់រងលើចំណាយផ្នែកអប់រំ។ ការកាត់បន្ថយនេះ នឹងមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការរៀបចំថវិការបស់រដ្ឋ និងសមត្ថភាពក្នុងការផ្តល់មូលនិធិ ដល់កម្មវិធីនិងសេវាកម្មនានា ដែលប្រជាពលរដ្ឋនៅក្នុងរដ្ឋម៉ាសាឈូសិតរំពឹងទុក ហើយសមនឹងទទួលបាន។

នៅក្នុងអំឡុងពេលសវនាការ អ្នកស្នើសុំញត្តិបានកត់សម្គាល់អំពីការសន្សំប្រាក់ពន្ធតាមការព្យាករក្រោមការកាត់បន្ថយពន្ធលើប្រាក់ចំណូល ប៉ុន្តែការសន្សំទាំងនេះហុចផលជាចម្បងដល់អ្នកបង់ពន្ធដែលមានប្រាក់ចំណូលជាប់ពន្ធលើសពី 1 លានដុល្លារ។ ឧទាហរណ៍ អ្នកដែលស្ថិតនៅកម្រិតចាប់ផ្តើមនៃការជាប់ពន្ធបន្ថែមចំណែកសមធម៌ (Fair Share) ពោលគឺចំនួនទឹកប្រាក់ដែលគេចាប់ផ្តើមគិតពន្ធលើប្រាក់ចំណូលបន្ថែម 4% នឹងទទួលបានការសន្សំប្រាក់ពន្ធប៉ាន់ស្មានចំនួន 10,744 ដុល្លារក្នុងមួយឆ្នាំ ក្នុងពេលដែលកម្មករធ្វើការពេញម៉ោងដែលរៀបការរួចមានប្រាក់ឈ្នួល 25 ដុល្លារក្នុងមួយម៉ោង នឹងសន្សំបាន 381 ដុល្លារក្នុងមួយឆ្នាំ ហើយប្តីប្រពន្ធធ្វើការពេញម៉ោងដែលមានប្រាក់ចំណូលរួម 80,115 ដុល្លារ នឹងសន្សំបាន 713 ដុល្លារក្នុងមួយឆ្នាំ។ បន្ថែមលើអត្ថប្រយោជន៍ដែលផ្តល់ជូនដល់អ្នករកចំណូលបានលើសពីមួយលានដុល្លារ ការកាត់បន្ថយពន្ធលើប្រាក់ចំណូលនេះ ក៏នឹងកាត់បន្ថយពន្ធលើផលចំណេញមូលធនរយៈពេលខ្លីបច្ចុប្បន្នលើការវិនិយោគពី 8,5% មកត្រឹម 4% ផងដែរ។ អ្នករកចំណូលបានកម្រិតទាបនិងមធ្យម ដែលមិនមានប្រាក់ចំណូលច្រើនពីការវិនិយោគ នឹងទទួលបានផលសន្សំពន្ធលើប្រាក់ចំណូលក្នុងកម្រិតកាន់តែតិចតួច ធៀបនឹងអ្នករកចំណូលបានលើសពីមួយលានដុល្លារ។

ញត្តិពាក់ព័ន្ធនឹងការផ្លាស់ប្តូររូបមន្តគណនាដែនកំណត់នៃកំណើនប្រាក់ចំណូលជំពូក 62F នឹងកែសម្រួលបន្តិចបន្តួចទៅលើច្បាប់មួយដែលធ្លាប់មានប្រសិទ្ធភាពអនុវត្តតែពីរដងគត់ ចាប់តាំងពីត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ 1986 ពោលគឺម្តងក្នុងឆ្នាំ 1987 និងម្តងទៀតក្នុងឆ្នាំ 2022។ ជំពូក 62F ត្រូវបានបង្កើតឡើងដើម្បីដើរតួជាយន្តការត្រួតពិនិត្យលើការចំណាយរបស់រដ្ឋ ដោយធានាថាប្រាក់ចំណូល

## សំណួរទី 5៖ របាយការណ៍សំឡេងភាគច្រើន (ត)

មិនអាចកើនឡើងហួសប្រមាណនោះឡើយ។ ច្បាប់នេះតម្រូវឱ្យក្រសួងចំណូល (Department of Revenue) ចេញឥណទានជូនដល់អ្នកបង់ពន្ធ ប្រសិនបើប្រាក់ចំណូលពន្ធសរុបក្នុងឆ្នាំសារពើពន្ធជាក់លាក់ណាមួយ លើសពីកម្រិតកំណត់ប្រចាំឆ្នាំ ដែលភ្ជាប់ទៅនឹងកំណើនប្រាក់ឈ្នួល និងប្រាក់ខែនៅក្នុងរដ្ឋម៉ាសាឈូសិត។ ញត្តិនេះមានគោលបំណងផ្លាស់ប្តូរការគណនារបស់ជំពូក 62F ដោយដាក់បញ្ចូលប្រាក់ចំណូលដែលប្រមូលបានតាម រយៈការកែសម្រួលចំណែកសមធម៌ (Fair Share) ដែលបច្ចុប្បន្នមិនមែនជាផ្នែកមួយនៃរូបមន្តនេះឡើយ។ វាក៏នឹងយកចំនួនប្រាក់ចំណូលជាក់ស្តែងដែលបានប្រមូលក្នុងឆ្នាំមុន មកធ្វើជាមូលដ្ឋានសម្រាប់គណនាចំណូលអតិបរមាដែលរដ្ឋអាចប្រមូលបាន ជំនួសឱ្យរូបមន្តបច្ចុប្បន្នដែលផ្អែកលើកម្រិតកំណត់ក្នុងឆ្នាំមុន។ កត្តានេះនឹងរំខានដល់ភាពធន់ផ្នែកសេដ្ឋកិច្ចរបស់រដ្ឋក្នុងអំឡុងពេលដែលមានភាពមិនប្រាកដប្រជា ព្រោះថាឆ្នាំដែលសេដ្ឋកិច្ចចុះដុនដាប ទំនងជានឹងបណ្តាលឱ្យប្រាក់ចំណូលធ្លាក់ចុះទាប ហើយការងើបឡើងវិញនៃសេដ្ឋកិច្ចនៅឆ្នាំបន្ទាប់ នឹងកាន់តែមានលទ្ធភាពខ្ពស់ក្នុងការជំរុញឱ្យមានការបង្វិលសងប្រាក់ពន្ធវិញ។ ចំណុចនេះមានន័យថា រដ្ឋនឹងមានលទ្ធភាពតិចជាងមុនក្នុងការផ្តល់ថវិកាឡើងវិញសម្រាប់កម្មវិធីនានាដែលត្រូវបានកាត់បន្ថយ ឬក្នុងការបំពេញបន្ថែមមូលនិធិស្ថិរភាពថវិការបស់រដ្ឋ ("មូលនិធិបម្រុងសម្រាប់គ្រាលំបាក (Rainy Day Fund") ដែលត្រូវបានប្រើប្រាស់ដើម្បីបំពេញបន្ថែមលើការបាត់បង់ប្រាក់ចំណូល និងបន្តផ្តល់ថវិកាគាំទ្រដល់កម្មវិធីនានាក្នុងអំឡុងពេលទិដ្ឋភាពសេដ្ឋកិច្ចធ្លាក់ចុះដុនដាប។

សរុបសេចក្តីមក ញត្តិទាំងនេះនឹងជះឥទ្ធិពលអវិជ្ជមានដល់លទ្ធភាពរបស់រដ្ឋម៉ាសាឈូសិតក្នុងការទប់ទល់នឹងលក្ខខណ្ឌសេដ្ឋកិច្ចប្រែប្រួល ដែលកើតចេញពីដំណាក់កាលវិបត្តិសេដ្ឋកិច្ច ឬអតិផរណាខ្ពស់ ជាដំណាក់កាលដែលចំណាយមានកំណើនលឿនជាងចំណូល។ ក្នុងអំឡុងមហាវិបត្តិសេដ្ឋកិច្ចឆ្នាំ 2008 រដ្ឋម៉ាសាឈូសិតបានងាកមកប្រើប្រាស់មូលនិធិស្ថិរភាពថវិកា (Stabilization Fund) ដើម្បីធានាថា សាលារៀនអាចទទួលបានមូលនិធិ កម្មវិធីនានាមិនត្រូវបានកាត់បន្ថយយ៉ាងគំហុកនៅគ្រប់វិស័យ ហើយបុគ្គលិករបស់រដ្ឋនឹងទទួលបានប្រាក់បៀវត្សរ៍របស់ពួកគេ។ ដោយមានការថយចុះនៃចំណូលដែលបណ្តាលមកពីការកាត់បន្ថយពន្ធលើប្រាក់ចំណូល រដ្ឋនឹងជួបប្រទះការលំបាកខ្លាំងក្នុងការរក្សាកញ្ចប់ថវិកាបម្រុងរឹងមាំមួយនៅក្នុងមូលនិធិស្ថិរភាពថវិកា ដើម្បីឆ្លងកាត់វិបត្តិសេដ្ឋកិច្ច ហើយការគណនាថ្មីនៃដែនកំណត់ប្រាក់ចំណូលជំពូក 62F ទំនងជានឹងបង្កឱ្យមានការបង្វិលសងពន្ធវិញ នៅក្នុងឆ្នាំបន្ទាប់ពីមានវិបត្តិសេដ្ឋកិច្ច។ សរុបមក ញត្តិទាំងនេះមានលទ្ធភាពបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការផ្តល់មូលនិធិសម្រាប់ផ្លូវថ្នល់ ស្ពាន សាលារៀន និងកម្មវិធីបណ្តាញសុវត្ថិភាពសង្គមរបស់យើង ស្របពេលដែលការផ្តល់ប្រាក់សន្សំត្រឡប់ទៅឱ្យប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាបនិងមធ្យម មានកម្រិតតិចតួចបំផុត ហើយបែរជាផ្តល់នូវការសន្សំពន្ធ និងការបង្វិលសងពន្ធយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់អ្នករកចំណូលបានរាប់លានដុល្លារទៅវិញ។

គួរកត់សម្គាល់ថា មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាឈូសិត ដែលគ្រប់គ្រងដំណើរការញត្តិផ្តួចផ្តើមច្បាប់ តម្រូវឱ្យអគ្គរដ្ឋអាជ្ញា (Attorney General) ផ្តល់ការបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាដែលបំពេញតាមលក្ខខណ្ឌកំណត់ជាក់លាក់ ដូចមានចែងនៅក្នុងមាត្រា 48 នោះ។ ក្នុងការសម្រេចថាតើត្រូវបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាមួយដែរឬទេនោះ អគ្គរដ្ឋអាជ្ញាមិនធ្វើការវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញក្នុងវិសាលភាពកាន់តែទូលំទូលាយរបស់ញត្តិនោះឡើយ ពោលគឺការសម្រេចបញ្ជាក់ទទួលស្គាល់របស់គាត់ ត្រូវបានកម្រិតត្រឹមតែលក្ខណវិនិច្ឆ័យចង្អៀតដែលមានចែងនៅក្នុងមាត្រា 48 តែប៉ុណ្ណោះ។ ដូចនេះ ញត្តិនេះត្រូវបានបញ្ជាក់ទទួលស្គាល់ដោយអគ្គរដ្ឋអាជ្ញាក្រោមមាត្រា 48 រួចរាល់ហើយ ប៉ុន្តែរូបគាត់ ឬតុលាការមិនទាន់បានវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញរបស់វានាពេលបច្ចុប្បន្ននេះនៅឡើយទេ។

អាស្រ័យហេតុនេះ ភាគច្រើននៃគណៈកម្មាធិការ ផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-17 សេចក្តីព្រាងច្បាប់សភាលេខ 5006 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការកំណត់កំណើននៃការប្រមូលពន្ធរបស់រដ្ឋ និងការបង្វិលថវិកាលើសជូនដល់អ្នកបង់ពន្ធវិញ* និងញត្តិផ្តួចផ្តើម 25-18 សេចក្តីព្រាងច្បាប់សភាលេខ 5007 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការកាត់បន្ថយអត្រាពន្ធលើប្រាក់ចំណូលបុគ្គលរបស់រដ្ឋពី 5% មកត្រឹម 4%*។

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
|---|---|
| Cindy F. Friedman | Alice Hanlon Peisch |
| Brendan P. Crighton | Kate Hogan |
| Paul R. Feeney | Frank A. Moran |
| Barry R. Finegold | Michael S. Day |
| | David T. Vieira |

## សំណួរទី 5៖ របាយការណ៍សំឡេងភាគតិច

ច្បាប់ពាក់ព័ន្ធនឹងគោលនយោបាយពន្ធដារ

ការកាត់បន្ថយពន្ធលើប្រាក់ចំណូល នឹងអាចដាក់ប្រាក់ជាមធ្យមចំនួន 1,500 ដុល្លារ នៅក្នុងហោប៉ៅរបស់ក្រុមគ្រួសារនៅក្នុងរដ្ឋម៉ាសាឈូសិត ដែលនេះជាការជួយសម្រាលបន្ទុកហិរញ្ញវត្ថុយ៉ាងពិតប្រាកដ និងជួយធ្វើឱ្យការចំណាយលើជីវភាពរស់នៅក្នុងរដ្ឋម៉ាសាឈូសិតនេះកាន់តែមានភាពធូរស្រាលលើគ្រប់ផ្នែកចំណាយសំខាន់ៗរួមមាន ផ្ទះសម្បែង ការថែទាំកុមារ ភ្លើងអគ្គិសនី ប្រេងឥន្ធនៈ និងការថែទាំសុខភាព។ រដ្ឋម៉ាសាឈូសិត ស្ថិតក្នុងចំណោមរដ្ឋដែលមានការចំណាយលើជីវភាពរស់នៅខ្ពស់បំផុត ដោយមានអត្រាចំណាកស្រុកសុទ្ធខ្ពស់បំផុតមួយ។ អ្នកជិតខាង មិត្តភក្តិ និងក្រុមគ្រួសាររបស់យើង កំពុងតែចាកចេញ ហើយនាំយកទៅជាមួយនូវអនាគតសេដ្ឋកិច្ចរបស់រដ្ឋនេះផងដែរ។ រដ្ឋម៉ាសាឈូសិត ស្ថិតនៅចំណាត់ថ្នាក់ចុងក្រោយគេបង្អស់ក្នុងការបង្កើតឱកាសការងារក្នុងវិស័យឯកជន ដែលនេះជាការឆ្លុះបញ្ចាំងឱ្យឃើញពីទិដ្ឋភាពដ៏គួរឱ្យបារម្ភអំពីភាពរស់រវើកផ្នែកសេដ្ឋកិច្ចដែលកំពុងតែធ្លាក់ចុះខ្សោយរបស់រដ្ឋ។ ក្រុមគ្រួសារ និងបុគ្គលម្នាក់ៗមកពីគ្រប់កម្រិតប្រាក់ចំណូល កំពុងតែចាកចេញពីរដ្ឋនេះ ដើម្បីស្វែងរកកន្លែងដែលមានថ្លៃចំណាយលើជីវភាពរស់នៅសមរម្យជាងមុន ដោយសារតែអាទិភាពមិនស្របតាមតម្រូវការជាក់ស្តែងរបស់រដ្ឋ ហើយប្រសិនបើគ្មានការផ្លាស់ប្តូរទិសដៅគោលនយោបាយជាដុំកំភួននោះទេ ផលវិបាកនៃគោលនយោបាយទាំងនេះនឹងមិនអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋបានឡើយ។ រដ្ឋម៉ាសាឈូសិតនេះបានធ្វើមិនដឹងមិនឮចំពោះកំណែទម្រង់ច្បាប់ដែលគេហៅថា "ច្បាប់ស្តីពីសិទ្ធិទទួលបានទីជម្រក (Right-to-Shelter Law)" របស់រដ្ឋ ដែលច្បាប់នេះបានបង្កើតឱ្យមានវិនភាពរាប់ពាន់លានដុល្លារនៅក្នុងកញ្ចប់ថវិការដ្ឋ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងផ្នែកនីតិប្បញ្ញត្តិដើម្បីទប់ស្កាត់ និងគ្រប់គ្រងច្បាប់នេះយ៉ាងណាក៏ដោយ។

## សំណួរទី 5៖ របាយការសំឡេងភាគតិច (ត)

លើសពីនេះទៅទៀត នៅពេលដែលការចំណាយឈានដល់កម្រិតខ្ពស់បំផុត កញ្ចប់ថវិកាជាង 3,300 ដុល្លារត្រូវបាន ចំណាយក្នុងមួយសប្តាហ៍សម្រាប់គ្រួសារនីមួយៗ ដែលក្នុងនោះមានគ្រួសារជាច្រើនមិនមានវត្តមានស្ថិតនៅស្របច្បាប់ឡើយ ហើយក៏មិនអាចទទួលបានការអនុញ្ញាតតាមផ្លូវច្បាប់ក្នុងការចូលរួមចំណែកដល់សេដ្ឋកិច្ចរដ្ឋ តាមរយៈការចូលបម្រើក្នុងកម្លាំងពលកម្មរបស់រដ្ឋនោះដែរ។ ផែនការអាកាសធាតុនិងថាមពលស្អាតរបស់ម៉ាសាឈូសិត ដែលបានអនុម័តនៅក្នុងច្បាប់ស្តីពីដំណោះស្រាយការឡើងកំដៅផែនដី បានធ្វើឱ្យវិបត្តិថ្លៃចំណាយលើជីវភាពរស់នៅកាន់តែធ្ងន់ធ្ងរឡើងបន្ថែមទៀត។ ក្នុងអំឡុងពេលសវនាការសម្រាប់ញត្តិទាំងនេះ សក្ខីកម្មមួយចំនួនបានលើកឡើងថា ការកាត់បន្ថយពន្ធលើចំណូលរបស់រដ្ឋចំនួន 1%  គឺមានកម្រិតតិចតួចបំផុតសម្រាប់ប្រជាពលរដ្ឋនៃរដ្ឋម៉ាសាឈូសិត។ ការផ្តល់ការបន្ធូរបន្ថយពន្ធ មិនមែនគ្រាន់តែជាបញ្ហាគោលនយោបាយសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាការទទួលស្គាល់នូវបញ្ហាប្រឈមប្រចាំថ្ងៃដែលប្រជាពលរដ្ឋកំពុងជួបប្រទះ និងជាការប្តេជ្ញាចិត្តក្នុងការធ្វើឱ្យរដ្ឋម៉ាសាឈូសិត ក្លាយជាទីកន្លែងដែលប្រជាជនមានលទ្ធភាពរស់នៅ ធ្វើការ និងកសាងអនាគតរបស់ពួកគេបាន។ ប្រសិនបើរដ្ឋម៉ាសាឈូសិតសង្ឃឹមចង់បន្តប្រកួតប្រជែងជាមួយនឹងរដ្ឋជិតខាងរបស់ខ្លួន រដ្ឋត្រូវតែដោះស្រាយឱ្យមានប្រសិទ្ធភាពចំពោះសម្ពាធផ្នែកហិរញ្ញវត្ថុដែលប្រជាពលរដ្ឋកំពុងតែប្រឈម។ ប្រជាពលរដ្ឋនៅក្នុងរដ្ឋត្រូវការការសម្រាលបន្ទុក ពីគោលនយោបាយបង្កើនថ្លៃចំណាយហួសពីលទ្ធភាព ដែលស្ថាប័ននីតិប្បញ្ញត្តិ និងអភិបាលរដ្ឋបានអនុម័ត ដែលគោលនយោបាយទាំងនោះកំពុងតែជំរុញឱ្យថ្លៃចំណាយលើផ្ទះសម្បែង និងថាមពលហក់ឡើងកាន់តែខ្ពស់។ ញត្តិផ្តួចផ្តើមទាំងពីរនេះ ផ្តល់នូវគន្លងផ្លូវជាក់ស្តែងឆ្ពោះទៅរកការសម្រាលបន្ទុកទាំងនេះ តាមរយៈការកាត់បន្ថយបន្ទុកពន្ធលើបុគ្គលម្នាក់ៗ និងធានាថារដ្ឋម៉ាសាឈូសិតមិនប្រមូលចំណូលពន្ធហួសពីអ្វីដែលត្រូវការជាក់ស្តែងសម្រាប់ផ្តល់មូលនិធិដល់សេវាសំខាន់ៗនោះឡើយ។

អាស្រ័យហេតុនេះ សំឡេងភាគតិចនៃគណៈកម្មាធិការ ផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) អនុម័តលើញត្តិផ្តួចផ្តើម 25-18 សេចក្តីព្រាងច្បាប់សភាលេខ 5007 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ស្តីពីការកាត់បន្ថយអត្រាពន្ធលើប្រាក់ចំណូលបុគ្គលរបស់រដ្ឋពី 5% មកត្រឹម 4%* និងញត្តិផ្តួចផ្តើម 25-17 សេចក្តីព្រាងច្បាប់សភាលេខ 5006 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ស្តីពីការកម្រិតកំណើននៃការប្រមូលពន្ធរបស់រដ្ឋ និងការបង្វិលថវិកាលើសជូនដល់អ្នកបង់ពន្ធវិញ*។

សមាជិកព្រឹទ្ធសភា

Ryan C. Fattman

## សំណួរទី 6៖ របាយការណ៍សំឡេងភាគច្រើន

ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (Special Joint Committee on Initiative Petitions)

មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត អនុញ្ញាតឱ្យអ្នកបោះឆ្នោតអាចស្នើច្បាប់ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញបាន តាមរយៈញត្តិផ្តួចផ្តើម ឬហៅជាទូទៅថាសំណួរនៅលើសន្លឹកឆ្នោត។ បន្ទាប់ពីការប្រមូលហត្ថលេខាគ្រប់គ្រាន់តាមការកំណត់ និងការដាក់ជូនហត្ថលេខាបញ្ជាក់ត្រឹមត្រូវទៅរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋរួចមក ញត្តិនោះនឹងត្រូវដាក់ជូនទៅស្ថាប័ននីតិប្បញ្ញត្តិជាផ្លូវការ ដើម្បីធ្វើការពិចារណា។ បន្ទាប់មក ញត្តិនោះនឹងត្រូវបញ្ជូនទៅកាន់គណៈកម្មាធិការមួយ ដែលក្នុងករណីនេះ គឺគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម។

យោងតាមមាត្រា 48 គណៈកម្មាធិការនេះត្រូវតែរាយការណ៍ជូនស្ថាប័ននីតិប្បញ្ញត្តិអំពីញត្តិនីមួយៗ ឱ្យបានមុនថ្ងៃពុធសប្តាហ៍ទីមួយនៃខែឧសភា។ ខុសពីដំណើរការនីតិប្បញ្ញត្តិស្តង់ដា ស្ថាប័ននីតិប្បញ្ញត្តិអាចអនុម័ត ឬបដិសេធញត្តិផ្តួចផ្តើមទៅតាមទម្រង់ដែលបានដាក់ជូនតែប៉ុណ្ណោះ ដោយមិនធ្វើការកែប្រែណាមួយឡើយ។

គណៈកម្មាធិការនេះបានរៀបចំសវនាការមួយ ស្តីពីញត្តិផ្តួចផ្តើម 25-15 សេចក្តីព្រាងច្បាប់សភាលេខ 5005 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការការពារទឹក និងធម្មជាតិ* កាលពីថ្ងៃទី 23 ខែមីនា ឆ្នាំ 2026។ គណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម បានរៀបចំសវនាការសាធារណៈពេញមួយខែមីនា ឆ្នាំ 2026 ដើម្បីប្រមូលសក្ខីកម្ម និងព័ត៌មានជាមូលដ្ឋានក្នុងការពិនិត្យឡើងវិញរបស់ខ្លួន។ គណៈកម្មាធិការនេះបានពិចារណាមតិយោបល់ពីអ្នកជំនាញឯកទេស ភាគីអ្នកគាំទ្រ និងភាគីអ្នកប្រឆាំងនឹងញត្តិផ្តួចផ្តើម ក៏ដូចជាសាធារណជនទូទៅផងដែរ។ កំណត់ត្រាសវនាការទាំងស្រុង និងឯកសារគាំទ្រនានា មានផ្តល់ជូនសាធារណជនតាមតំណភ្ជាប់ malegislature.gov/Events/Hearings/Detail/5601.

កាលពីថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026 ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (ហៅកាត់ថា "គណៈកម្មាធិការ") បានបោះឆ្នោតគាំទ្រក្នុងការផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំទាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-15 សេចក្តីព្រាងច្បាប់សភាលេខ 5005 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការការពារទឹកនិងធម្មជាតិ* (ហៅកាត់ថា "ញត្តិ")។

ដើម្បីសម្រេចសេចក្តីសន្និដ្ឋាននេះ គណៈកម្មាធិការបានធ្វើការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើវិធានការដែលបានស្នើ រួមទាំងការវិភាគយ៉ាងលម្អិតលើពាក្យពេចន៍ រចនាសម្ព័ន្ធ និងផលវិពាកទុក ព្រមទាំងសក្ខីកម្មនិងភស្តុតាងឯកសារដែលបានបង្ហាញក្នុងអំឡុងពេលសវនាការសាធារណៈ។ គណៈកម្មាធិការក៏បានពិចារណាផងដែរលើឯកសារដែលបានដាក់ជូនជាលាយលក្ខណ៍អក្សរដោយអ្នកជំនាញគោលនយោបាយបរិស្ថាន តំណាងទីភ្នាក់ងាររដ្ឋ មន្ត្រីសាលាក្រុង អ្នកតស៊ូមតិខាងការអភិរក្ស និងសាធារណជនទូទៅ។ លើសពីនេះទៅទៀត គណៈកម្មាធិការបានវាយតម្លៃលើផលប៉ះពាល់ជាសក្តានុពលផ្នែកច្បាប់ បរិស្ថាន រដ្ឋបាល និងសេដ្ឋកិច្ចរបស់ញត្តិផ្តួចផ្តើមនេះ រួមទាំងទំនាក់ទំនងរបស់វាជាមួយនឹងអំណាចច្បាប់ជាធរមាន ដែលគ្រប់គ្រងការអភិរក្សដីធ្លី ការគ្រប់គ្រងធនធានទឹក និងការរៀបចំផែនការដើមទុន។

សមាជិកគណៈកម្មាធិការភាគច្រើនបានលើកឡើងពីក្តីបារម្ភចំពោះរចនាសម្ព័ន្ធវិសាលភាព និងផលប៉ះពាល់ជាសក្តានុពលនៃញត្តិនេះដូចដែលបានព្រាង។ ពិតមែនតែអ្នកគាំទ្រវិធានការនេះអះអាងថា វាត្រូវបានបង្កើតឡើងដោយមិនប៉ះពាល់ដល់តុល្យភាពហិរញ្ញវត្ថុ និងមិនមែនជាការដំឡើងពន្ធក៏ដោយ ក៏គណៈកម្មាធិការកត់សម្គាល់ថា សំណើច្បាប់នេះនឹងពឹងផ្អែកលើប្រភពចំណូលរដ្ឋដែលមានស្រាប់ ដែលបច្ចុប្បន្នត្រូវបានបែងចែកទៅឱ្យកម្មវិធី និងអាទិភាពបន្តបន្ទាប់ផ្សេងៗទៀត។ ជាលទ្ធផល ការអនុវត្តវិធានការនេះនឹងតម្រូវឱ្យមានការបែងចែកឡើងវិញ ឬការកាត់បន្ថយមូលនិធិដែលបច្ចុប្បន្នកំពុងត្រូវបានប្រើប្រាស់សម្រាប់គំនិតផ្តួចផ្តើមផ្សេងៗទៀតរបស់រដ្ឋ រួមទាំងការវិនិយោគដែលគ្រប់គ្រងដោយទីភ្នាក់ងារនានា ដូចជានាយកដ្ឋានអភិរក្ស និងកម្សាន្ត (Department of Conservation and Recreation) ជាដើម។ នេះចោទជាសំណួរអំពីតម្លៃឱកាស និងលទ្ធភាពនៃការបង្អាក់ដល់ការផ្តល់អាទិភាពថវិកាដែលមានស្រាប់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន។

# របាយការណ៍របស់ស្ថាប័ននីតិប្បញ្ញត្តិ (ត)

## សំណួរទី 6៖ របាយការណ៍សំឡេងភាគច្រើន (ត)

គណៈកម្មាធិការក៏បានកត់សម្គាល់ផងដែរអំពីការដាក់បញ្ចូលឃ្លា "អាស្រ័យលើការបែងចែងកញ្ចប់ថវិកា (subject to appropriations" នៅក្នុងញត្តិនេះ។ យោងតាមមាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត ញត្តិផ្តួចផ្តើមមិនអាចបែងចែកកញ្ចប់ថវិកាដោយផ្ទាល់បានឡើយ។ អាស្រ័យហេតុនេះ ទោះបីជាត្រូវបានអនុម័តដោយអ្នកបោះឆ្នោតក៏ដោយ វិធានការនេះនឹងមិនមានអនុភាពកំណត់ការចំណាយថវិកាឡើយ ប៉ុន្តែផ្ទុយទៅវិញ វិធានការនេះនឹងអនុវត្តស្របតាមដំណើរការថវិកាដែលមានស្រាប់របស់រដ្ឋម៉ាសាឈូសិត ដែលក្នុងនោះស្ថាប័ននីតិប្បញ្ញត្តិរក្សាសិទ្ធិអំណាចផ្តាច់មុខក្នុងការសម្រេចចិត្តបែងចែកកញ្ចប់ថវិកា។ ក្របខណ្ឌរដ្ឋធម្មនុញ្ញនេះធានាថា ការសម្រេចចិត្តលើការផ្តល់មូលនិធិនៅតែបន្តស្ថិតក្រោមការពិភាក្សាអនុម័តកញ្ចប់ថវិកាប្រចាំឆ្នាំ និងការកំណត់អាទិភាពផ្នែកសារពើពន្ធ។ ហេតុដូច្នេះហើយ ការអនុម័តញត្តិនេះនឹងមិនធានាឱ្យមានមូលនិធិបន្ថែម ហើយក៏មិនផ្លាស់ប្តូរជាសារវន្តនូវស្ថានភាពបច្ចុប្បន្ននោះដែរ។

គណៈកម្មាធិការទទួលស្គាល់សារៈសំខាន់នៃការការពារធនធានទឹក ការអភិរក្សប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងការគាំទ្រដល់និរន្តរភាពបរិស្ថានរយៈពេលវែងនៅទូទាំងរដ្ឋម៉ាសាឈូសិត។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីការពិចារណាដោយហ្មត់ចត់ សមាជិកគណៈកម្មាធិការភាគច្រើនបានសន្និដ្ឋានថា ញត្តិដែលបានព្រាងនេះ បង្កើតជាសំណួរនានាទាក់ទងនឹងផលប៉ះពាល់ផ្នែកសារពើពន្ធ ការបង្អាក់ដល់កម្មវិធី និងការរឹតត្បិតលើភាពបត់បែនផ្នែករដ្ឋបាល។

គួរកត់សម្គាល់ថា មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាឈូសិត ដែលគ្រប់គ្រងដំណើរការញត្តិផ្តួចផ្តើម តម្រូវឱ្យអគ្គរដ្ឋអាជ្ញា (Attorney General) ផ្តល់ការបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាដែលបំពេញតាមលក្ខខណ្ឌកំណត់ជាក់លាក់ ដូចមានចែងនៅក្នុងមាត្រា 48 នោះ។ ក្នុងការសម្រេចថាតើត្រូវបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាមួយដែរឬទេនោះ អគ្គរដ្ឋអាជ្ញាមិនធ្វើការវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញក្នុងវិសាលភាពកាន់តែទូលំទូលាយរបស់ញត្តិនោះឡើយ ពោលគឺការសម្រេចបញ្ជាក់ទទួលស្គាល់របស់គាត់ ត្រូវបានកម្រិតត្រឹមតែលក្ខណវិនិច្ឆ័យចង្អៀតដែលមានចែងនៅក្នុងមាត្រា 48 តែប៉ុណ្ណោះ។ ដូចនេះ ញត្តិនេះត្រូវបានបញ្ជាក់ទទួលស្គាល់ដោយអគ្គរដ្ឋអាជ្ញាក្រោមមាត្រា 48 រួចរាល់ហើយ ប៉ុន្តែរូបគាត់ ឬតុលាការមិនទាន់បានវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញរបស់វានាពេលបច្ចុប្បន្ននេះនៅឡើយទេ។

អាស្រ័យហេតុនេះ  ភាគច្រើននៃគណៈកម្មាធិការបានផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-15 សេចក្តីព្រាងច្បាប់សភាលេខ 5005 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការការពារទឹកនិងធម្មជាតិ*។

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
|---|---|
| Cindy F. Friedman | Alice Hanlon Peisch |
| Brendan P. Crighton | Kate Hogan |
| Barry R. Finegold | Frank A. Moran |
| | Michael S. Day |
| | David T. Vieira |

## សំណួរទី 7៖ របាយការណ៍សំឡេងភាគច្រើន

ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (Special Joint Committee on Initiative Petitions)

មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត អនុញ្ញាតឱ្យអ្នកបោះឆ្នោតអាចស្នើច្បាប់ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញបាន តាមរយៈញត្តិផ្តួចផ្តើម ឬហៅជាទូទៅថា សំណួរនៅលើសន្លឹកឆ្នោត។ បន្ទាប់ពីការប្រមូលហត្ថលេខាគ្រប់គ្រាន់តាមការកំណត់ និងការដាក់ជូនហត្ថលេខាបញ្ជាក់ត្រឹមត្រូវទៅរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋរួចមក ញត្តិនោះនឹងត្រូវដាក់ជូនទៅស្ថាប័ននីតិប្បញ្ញត្តិជាផ្លូវការ ដើម្បីធ្វើការពិចារណា។ បន្ទាប់មក ញត្តិនោះនឹងត្រូវបញ្ជូនទៅកាន់គណៈកម្មាធិការមួយ ដែលក្នុងករណីនេះ គឺគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម។

យោងតាមមាត្រា 48 គណៈកម្មាធិការនេះត្រូវតែរាយការណ៍ជូនស្ថាប័ននីតិប្បញ្ញត្តិអំពីញត្តិនីមួយៗ ឱ្យបានមុនថ្ងៃពុធសប្តាហ៍ទីមួយនៃខែឧសភា។ ខុសពីដំណើរការនីតិប្បញ្ញត្តិស្តង់ដា ស្ថាប័ននីតិប្បញ្ញត្តិអាចអនុម័ត ឬបដិសេធញត្តិផ្តួចផ្តើមទៅតាមទម្រង់ដែលបានដាក់ជូនតែប៉ុណ្ណោះ ដោយមិនធ្វើការកែប្រែណាមួយឡើយ។

គណៈកម្មាធិការនេះបានរៀបចំសវនាការស្តីពីញត្តិផ្តួចផ្តើម 25-03 សេចក្តីព្រាងច្បាប់សភាលេខ 5000 *ដែលជាញត្តិផ្តួចផ្តើមច្បាប់អនុញ្ញាតឱ្យមានលំនៅដ្ឋានគ្រួសារទោលនៅលើដីឡូត៍តូចៗក្នុងតំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់* កាលពីថ្ងៃទី 16 ខែមីនា ឆ្នាំ 2026។ គណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម បានរៀបចំសវនាការសាធារណៈពេញមួយខែមីនា ឆ្នាំ 2026 ដើម្បីប្រមូលសក្ខីកម្ម និងព័ត៌មានជាមូលដ្ឋានក្នុងការពិនិត្យឡើងវិញរបស់ខ្លួន។ គណៈកម្មាធិការនេះបានពិចារណាមតិយោបល់ពីអ្នកជំនាញឯកទេស អ្នកគាំទ្រ និងអ្នកជំទាស់នឹងញត្តិផ្តួចផ្តើម ក៏ដូចជាសាធារណជនទូទៅផងដែរ។ កំណត់ត្រាសវនាការទាំងស្រុង និងឯកសារគាំទ្រនានា មានផ្តល់ជូនសាធារណជនតាមតំណភ្ជាប់ malegislature.gov/Events/Hearings/Detail/5597.

កាលពីថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026 ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (ហៅកាត់ថា "គណៈកម្មាធិការ") បានបោះឆ្នោតគាំទ្រក្នុងការផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-03 សេចក្តីព្រាងច្បាប់សភាលេខ 5000 *ដែលជាញត្តិផ្តួចផ្តើមច្បាប់អនុញ្ញាតឱ្យមានលំនៅឋានគ្រួសារទោលនៅលើដីឡូត៍តូចៗក្នុងតំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់* (ហៅកាត់ថា "ញត្តិ")។

ដើម្បីសម្រេចសេចក្តីសន្និដ្ឋាននេះ គណៈកម្មាធិការបានធ្វើការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយនូវវិធានការដែលបានស្នើ រួមទាំងការវិភាគយ៉ាងលម្អិតលើពាក្យពេចន៍រចនាសម្ព័ន្ធ និងផលប៉ះពាល់រំពឹងទុករបស់វា។ គណៈកម្មាធិការបានវាយតម្លៃលើសក្ខីកម្ម និងភស្តុតាងឯកសារដែលបានបង្ហាញក្នុងអំឡុងពេលសវនាការសាធារណៈ រួមទាំងមតិចូលរួមពីអ្នកជំនាញឯកទេសក្នុងវិស័យគោលនយោបាយលំនៅឋាន អភិបាលកិច្ចក្រុង ការរៀបចំផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេចក្តីថ្លែងការណ៍ពីអ្នកគាំទ្រ អ្នកជំទាស់ និងសាធារណជនទូទៅ។ លើសពីនេះទៅទៀត គណៈកម្មាធិការបានពិចារណាលើផលប៉ះពាល់ជាសក្តានុពលផ្នែក

# របាយការណ៍របស់ស្ថាប័ននីតិប្បញ្ញត្តិ (ត)

## សំណួរទី 7៖ របាយការណ៍សំឡេងភាគច្រើន (ត)

ច្បាប់ រដ្ឋបាល និងសារពើពន្ធនៃសេចក្តីស្នើច្បាប់នេះ សម្រាប់ទាំងរដ្ឋម៉ាសាឈូសិត និងក្រុងរបស់ខ្លួន។

ញត្តិផ្តួចផ្តើមនេះស្វែងរកការអនុញ្ញាតជាសិទ្ធិស្វ័យប្រវត្តិក្នុងការសាងសង់លំនៅដ្ឋានគ្រួសារទោលនៅលើដីឡូត៍ទំហំ 5,000 ហ្វីតការ៉េ នៅក្នុងតំបន់ដែលកំណត់ថាមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដោយមិនគិតពីលក្ខខណ្ឌកំណត់តំបន់មូលដ្ឋានដែលមានស្រាប់នោះឡើយ។ គោលបំណងដែលបានចែងក្នុងញត្តិនេះ គឺបង្កើនការសាងសង់លំនៅឋានខ្នាតតូច ពង្រីកការផ្គត់ផ្គង់ដីធ្លីដែលអាចសាងសង់បាន និងកែលម្អលទ្ធភាពទទួលបានលំនៅឋានសមរម្យនៅទូទាំងរដ្ឋម៉ាសាឈូសិត។ អ្នកជំទាស់បានចោទសួរថាតើគោលដៅរបស់ញត្តិនេះអាចសម្រេចទៅរួចដែរឬទេ ដោយពិនិត្យលើខ្លឹមសារពាក្យពេចន៍ជាក់លាក់នៃញត្តិនេះ។ ឧទាហរណ៍ ពួកគេបានកត់សម្គាល់អំពីភាពមិនច្បាស់លាស់ជុំវិញទំហំសំណង់ និងកង្វះការណែនាំអំពីការអនុវត្ត (រួមទាំងរបៀបកំណត់ហេដ្ឋារចនាសម្ព័ន្ធ "គ្រប់គ្រាន់") ដែលកត្តាទាំងនេះអាចបណ្តាលឱ្យមានការអនុវត្តមិនស្មើភាពគ្នានៅតាមយុត្តាធិការនានា។ គណៈកម្មាធិការទទួលស្គាល់ពីភាពបន្ទាន់នៃបញ្ហាប្រឈមផ្នែកលំនៅឋានរបស់រដ្ឋម៉ាសាឈូសិត និងសារៈសំខាន់នៃការជំរុញគោលនយោបាយនានាដែលលើកកម្ពស់ការអភិវឌ្ឍឱកាសកម្មសិទ្ធិលំនៅឋានដ៏សម្បូរបែប ងាយស្រួលប្រើប្រាស់ និងមានតម្លៃសមរម្យ។

ទោះបីជាគណៈកម្មាធិការគាំទ្រគោលដៅចម្បងនៃការពង្រីកឱកាសលំនៅឋាន និងទទួលស្គាល់តម្រូវការសម្រាប់ការឆ្លើយតបដ៏ម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពលើបញ្ហាកង្វះខាតលំនៅឋានរបស់រដ្ឋម៉ាសាឈូសិតក៏ដោយ ក៏គណៈកម្មាធិការមិនអាចគាំទ្រញត្តិនេះទេ ផ្អែកលើសក្ខីកម្មដែលបានទទួល និងដោយសារស្ថាប័ននីតិប្បញ្ញត្តិមិនអាចកែប្រែតាមផ្លូវច្បាប់នូវខ្លឹមសារសំណួរលើសន្លឹកឆ្នោតដូចបានព្រាងដោយអ្នកគាំទ្រនោះឡើយ។

គួរកត់សម្គាល់ថា មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាឈូសិត ដែលគ្រប់គ្រងដំណើរការញត្តិផ្តួចផ្តើមច្បាប់ តម្រូវឱ្យអគ្គរដ្ឋអាជ្ញា (Attorney General) ផ្តល់ការបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាដែលបំពេញតាមលក្ខខណ្ឌកំណត់ជាក់លាក់ ដូចមានចែងនៅក្នុងមាត្រា 48 នោះ។ ក្នុងការសម្រេចថាតើត្រូវបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្តួចផ្តើមណាមួយដែរឬទេនោះ អគ្គរដ្ឋអាជ្ញាមិនធ្វើការវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញក្នុងវិសាលភាពកាន់តែទូលំទូលាយរបស់ញត្តិនោះឡើយ ពោលគឺការសម្រេចបញ្ជាក់ទទួលស្គាល់របស់គាត់ ត្រូវបានកម្រិតត្រឹមតែលក្ខណៈវិនិច្ឆ័យចង្អៀតដែលមានចែងនៅក្នុងមាត្រា 48 តែប៉ុណ្ណោះ។ ដូចនេះ ញត្តិនេះត្រូវបានបញ្ជាក់ទទួលស្គាល់ដោយអគ្គរដ្ឋអាជ្ញាក្រោមមាត្រា 48 រួចរាល់ហើយ ប៉ុន្តែរូបគាត់ ឬតុលាការមិនទាន់បានវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញរបស់វានាពេលបច្ចុប្បន្ននេះនៅឡើយទេ។

អាស្រ័យហេតុនេះ ភាគច្រើននៃគណៈកម្មាធិការផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-03 សេចក្តីព្រាងច្បាប់សភាលេខ 5000 *ដែលជាញត្តិផ្តួចផ្តើមច្បាប់អនុញ្ញាតឱ្យមានលំនៅដ្ឋានគ្រួសារទោលនៅលើដីឡូត៍តូចៗ ក្នុងតំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់*។

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
|---|---|
| Cindy F. Friedman | Alice Hanlon Peisch |
| Brendan P. Crighton | Kate Hogan |
| Paul R. Feeney | Frank A. Moran |
| Barry R. Finegold | Michael S. Day |
| | David T. Vieira |

## សំណួរទី 8៖ Majority Report

ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (Special Joint Committee on Initiative Petitions)

មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត អនុញ្ញាតឱ្យអ្នកបោះឆ្នោតអាចស្នើច្បាប់ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញបាន តាមរយៈញត្តិផ្តួចផ្តើម ឬហៅជាទូទៅថា សំណួរលើសន្លឹកឆ្នោត។ បន្ទាប់ពីការប្រមូលហត្ថលេខាគ្រប់គ្រាន់តាមការកំណត់ និងការដាក់ជូនហត្ថលេខាបញ្ជាក់ត្រឹមត្រូវទៅរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋរួចមក ញត្តិនោះនឹងត្រូវដាក់ជូនទៅស្ថាប័ននីតិប្បញ្ញត្តិជាផ្លូវការ ដើម្បីពិចារណា។ បន្ទាប់មកញត្តិនោះនឹងត្រូវបញ្ជូនទៅកាន់គណៈកម្មាធិការមួយ ដែលក្នុងករណីនេះ គឺគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម។

យោងតាមមាត្រា 48 គណៈកម្មាធិការនេះត្រូវតែរាយការណ៍ជូនស្ថាប័ននីតិប្បញ្ញត្តិអំពីញត្តិនីមួយៗ ឱ្យបានមុនថ្ងៃពុធសប្តាហ៍ទីមួយនៃខែឧសភា។ ខុសពីដំណើរការនីតិប្បញ្ញត្តិស្តង់ដា ស្ថាប័ននីតិប្បញ្ញត្តិអាចនឹងអនុម័ត ឬបដិសេធញត្តិផ្តួចផ្តើមតាមទម្រង់ដែលបានដាក់ជូនតែប៉ុណ្ណោះ ដោយមិនធ្វើការកែប្រែណាមួយឡើយ។

គណៈកម្មាធិការនេះបានរៀបចំសវនាការស្តីពីញត្តិផ្តួចផ្តើម 25-10 សេចក្តីព្រាងច្បាប់សភាលេខ 5002 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងកញ្ឆា* កាលពីថ្ងៃទី 23 ខែមីនា ឆ្នាំ 2026។ គណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម បានរៀបចំសវនាការសាធារណៈពេញមួយខែមីនា ឆ្នាំ 2026 ដើម្បីប្រមូលសក្ខីកម្ម និងព័ត៌មានជាមូលដ្ឋានក្នុងការពិនិត្យឡើងវិញរបស់ខ្លួន។ គណៈកម្មាធិការនេះបានពិចារណាលើមតិចូលរួមពីសំណាក់អ្នកជំនាញឯកទេស ភាគីអ្នកគាំទ្រ និងភាគីអ្នកប្រឆាំងនឹងញត្តិ ក៏ដូចជាសាធារណជនទូទៅផងដែរ។ កំណត់ត្រាសវនាការទាំងស្រុង និងឯកសារគាំទ្រនានា មានផ្តល់ជូនសាធារណជនតាមតំណភ្ជាប់ malegislature.gov/Events/Hearings/Detail/5602។

កាលពីថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026 ភាគច្រើននៃគណៈកម្មាធិការចម្រុះពិសេសស្តីពីញត្តិផ្តួចផ្តើម (ហៅកាត់ថា "គណៈកម្មាធិការ") បានបោះឆ្នោតផ្តល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ (General Court) **កុំចាត់វិធានការ** លើញត្តិផ្តួចផ្តើម 25-10/សេចក្តីព្រាងច្បាប់សភាលេខ 5002 *ដែលជាញត្តិផ្តួចផ្តើមច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងកញ្ឆា* (ហៅកាត់ថា "ញត្តិ")។

ដើម្បីសម្រេចសេចក្តីសន្និដ្ឋាននេះ គណៈកម្មាធិការបានធ្វើការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើវិធានការដែលបានស្នើ រួមទាំងការវិភាគយ៉ាងលម្អិតលើពាក្យពេចន៍ រចនាសម្ព័ន្ធ និងផលរំពឹងទុក ព្រមទាំងក្របខណ្ឌច្បាប់ដែលសេចក្តីព្រាងនេះមានបំណងកែប្រែផងដែរ។ គណៈកម្មាធិការក៏បានវាយតម្លៃផងដែរលើសក្ខីកម្ម និងភស្តុតាងជាឯកសារនានាដែលបានបង្ហាញក្នុងអំឡុងពេលសវនាការសាធារណៈ រួមជាមួយនឹងមតិយោបល់ជាលាយលក្ខណ៍អក្សរពីសំណាក់អ្នកជំនាញឯកទេស អ្នកជំនាញសុខភាពសាធារណៈ តំណាងវិស័យឧស្សាហកម្ម មន្ត្រីសាលាក្រុង តួអង្គអនុវត្តច្បាប់ និងសាធារណជនទូទៅ។ បន្ថែមលើនេះ គណៈកម្មាធិការបានពិចារណាលើផលប៉ះពាល់ជាសក្តានុពលផ្នែកច្បាប់ សុខភាព សង្គម និងសេដ្ឋកិច្ចនៃសំណើនេះ រួមទាំងទំនាក់ទំនងនៃផលប៉ះពាល់ទាំងនោះទៅនឹងច្បាប់ដែលមានស្រាប់ និង

## សំណួរទី 8៖ របាយការណ៍សំឡេងភាគច្រើន (ត)

រចនាសម្ព័ន្ធបទបញ្ញត្តិនានាផងដែរ។

បន្ទាប់ពីការពិនិត្យឡើងវិញនេះ ភាគច្រើននៃគណៈកម្មាធិការបានលើកឡើងពីក្ដីបារម្ភសំខាន់ៗពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ វិសាលភាព និងផលប៉ះពាល់រំពឹងទុកនៃញត្តិផ្ដួចផ្ដើមនេះ។ សំណើនេះស្វែងរកការកែប្រែគំនិតផ្ដួចផ្ដើមបោះឆ្នោតឆ្នាំ 2016 ដែលអនុម័តដោយអ្នកបោះឆ្នោតរដ្ឋម៉ាសាឈូសិត ដោយគំនិតផ្ដួចផ្ដើមនោះបានធ្វើនីត្យានុកូលកម្ម គ្រប់គ្រង និងកំណត់ការយកពន្ធលើការលក់កញ្ឆាវាយសម្រាប់មនុស្សពេញវ័យប្រើប្រាស់កម្សាន្តនៅរដ្ឋម៉ាសាឈូសិត។ គណៈកម្មាធិការបានកត់សម្គាល់ថា ក្របខណ្ឌមានស្រាប់នេះ តំណាងឱ្យប្រព័ន្ធបទបញ្ញត្តិទូលំទូលាយមួយ ដែលត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដើម្បីរក្សាតុល្យភាពរវាងការការពារសុខភាពសាធារណៈ លទ្ធភាពទទួលបានរបស់អ្នកប្រើប្រាស់ និងទីផ្សារស្របច្បាប់ជាប់កាតព្វកិច្ចពន្ធសម្រាប់ផលិតផលកញ្ឆា។

ញត្តិនេះនាំមកនូវការផ្លាស់ប្ដូរសំខាន់ៗទៅលើរចនាសម្ព័ន្ធបទបញ្ញត្តិគ្រប់គ្រងកញ្ឆាដែលមានស្រាប់របស់រដ្ឋម៉ាឈូសិត។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការបានរកឃើញថា សំណើនេះនៅខ្វះខាតព័ត៌មានលម្អិតគ្រប់គ្រាន់ ពាក់ព័ន្ធនឹងយន្តការអនុវត្ត និងការធានាអនុវត្តច្បាប់ រួមទាំងរបៀបកែប្រែ ផ្ទេរ និងលុបចោលអំណាចបទបញ្ញត្តិដែលមានស្រាប់។ កង្វះភាពច្បាស់លាស់នេះ បង្កើតឱ្យមានភាពមិនប្រាកដប្រជាផ្នែកច្បាប់ ទាក់ទងនឹងការបន្តអនុវត្តច្បាប់និងបទបញ្ញត្តិនាពេលបច្ចុប្បន្ន ក៏ដូចជាតួនាទីរបស់ទីភ្នាក់ងាររដ្ឋនានាដែលមានភារកិច្ចទទួលខុសត្រូវលើការត្រួតពិនិត្យឧស្សាហកម្មកញ្ឆានេះ។

គណៈកម្មាធិការក៏មានក្ដីបារម្ភបន្ថែមទៀតដែរថា ការផ្លាស់ប្ដូរដែលបានស្នើឡើងទាំងនេះ នឹងលុបបំបាត់ ឬកែប្រែជាសារវន្តនូវវិធានការការពារសុវត្ថិភាព និងសុខភាពសាធារណៈដែលមានស្រាប់។ វិធានការទាំងនេះរួមមាន បទបញ្ញត្តិទាំងឡាយដែលបានតាក់តែងឡើងដើម្បីកម្រិតលទ្ធភាពទទួលបានផលិតផលកញ្ឆារបស់យុវជន កាត់បន្ថយហានិភ័យនៃការបើកបរក្រោមឥទ្ធិពលសារធាតុញៀន និងធានាឱ្យមានការធ្វើតេស្តផលិតផល ការបិទស្លាកសញ្ញា ព្រមទាំងស្ដង់ដាអនុភាពនៃសារធាតុ។ សក្ខីកម្មដែលបានបង្ហាញជូនគណៈកម្មាធិការ បានគូសបញ្ជាក់ពីក្ដីបារម្ភថា ការធ្វើឱ្យចុះខ្សោយ ឬការលុបបំបាត់វិធានការធានាសុវត្ថិភាពទាំងនេះ អាចនឹងបង្កើនហានិភ័យដល់សុខភាពសាធារណៈ និងបន្ថយបង្អាក់ដល់កិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់ដោយការទទួលខុសត្រូវនៅក្នុងទីផ្សារស្របច្បាប់។

បន្ថែមលើនេះ ញត្តិនេះនឹងមានផលប៉ះពាល់ខ្លាំងដល់ការផ្ដល់អាជ្ញាប័ណ្ណ ការយកពន្ធ និងរចនាសម្ព័ន្ធទូទៅរបស់ទីផ្សារកញ្ឆាស្ថិតក្រោមបទបញ្ញត្តិ។ គណៈកម្មាធិការបានស្ដាប់ភស្តុតាងដែលបង្ហាញថា ការផ្លាស់ប្ដូរភ្លាមៗចំពោះប្រព័ន្ធបច្ចុប្បន្ន អាចបង្កការរំខានដល់អាជីវកម្មមានអាជ្ញាប័ណ្ណដែលកំពុងដំណើរការដោយអនុលោមតាមច្បាប់ជាធរមាន បង្កើតឱ្យមានភាពមិនប្រាកដប្រជាក្នុងបរិយាកាសវិនិយោគ និងជះឥទ្ធិពលដល់ស្ថិរភាពរបស់ប្រតិបត្តិករទាំងខ្នាតធំ និងខ្នាតតូចនៅក្នុងឧស្សាហកម្មនេះ។ សក្ខីកម្មក៏បានលើកឡើងផងដែរអំពីក្ដីបារម្ភចំពោះសំណើនេះ ពាក់ព័ន្ធនឹងផលប៉ះពាល់ធ្ងន់ធ្ងរដល់ចរន្តចំណូលរបស់រដ្ឋនិងមូលដ្ឋាន ដែលទទួលបានពីការយកពន្ធលើកញ្ឆា និងកម្រៃសេវាអាជ្ញាប័ណ្ណ ដែលបច្ចុប្បន្នចំណូលទាំងនោះកំពុងជួយគាំទ្រដល់កម្មវិធីសាធារណៈ និងគំនិតផ្ដួចផ្ដើមក្នុងតំបន់ជាច្រើន ព្រមទាំងគាំទ្រដល់រចនាសម្ព័ន្ធបទបញ្ញត្តិផងដែរ។

ជាចុងក្រោយ គណៈកម្មាធិការកត់សម្គាល់ថា ការផ្លាស់ប្ដូរពីទីផ្សារប្រើប្រាស់សម្រាប់មនុស្សពេញវ័យដែលមានការគ្រប់គ្រង និងការយកពន្ធត្រឹមត្រូវ ទៅជាក្របខណ្ឌច្បាប់ជំនួសផ្សេងទៀត ដូចដែលបានគ្រោងទុកនៅក្នុងញត្តិនេះ នឹងតម្រូវឱ្យមានការរៀបចំផែនការរដ្ឋបាលគ្រប់ជ្រុងជ្រោយ ការរៀបចំរចនាសម្ព័ន្ធបទបញ្ញត្តិឡើងវិញ និងការបកស្រាយបំភ្លឺផ្នែកនីតិប្បញ្ញត្តិ ដើម្បីចៀសវាងបង្កការរំខានដល់មុខងារអនុវត្តច្បាប់និងត្រួតពិនិត្យ។ ហេតុដូច្នេះ ភាគច្រើននៃគណៈកម្មាធិការបានរកឃើញថា នៅក្នុងសេចក្ដីព្រាង សំណើនេះមិនទាន់ដោះស្រាយឱ្យបានគ្រប់គ្រាន់នូវការគិតគូរផ្នែកប្រតិបត្តិការ ហិរញ្ញវត្ថុ និងសុវត្ថិភាពសាធារណៈទាំងនេះនៅឡើយទេ។

គួរកត់សម្គាល់ថា មាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត ដែលគ្រប់គ្រងដំណើរការញត្តិផ្ដួចផ្ដើម តម្រូវឱ្យអគ្គរដ្ឋអាជ្ញាផ្ដល់ការបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្ដួចផ្ដើមណាដែលបំពេញតាមលក្ខខណ្ឌកំណត់ជាក់លាក់ ដូចមានចែងនៅក្នុងមាត្រា 48 នោះ។ ក្នុងការសម្រេចថាតើត្រូវបញ្ជាក់ទទួលស្គាល់បឋមលើញត្តិផ្ដួចផ្ដើមណាមួយដែរឬទេនោះ អគ្គរដ្ឋអាជ្ញាមិនធ្វើការវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញក្នុងវិសាលភាពកាន់តែទូលំទូលាយរបស់ញត្តិនោះឡើយ ពោលគឺការសម្រេចបញ្ជាក់ទទួលស្គាល់របស់គាត់ ត្រូវបានកម្រិតត្រឹមតែលក្ខណវិនិច្ឆ័យចង្អៀត ដូចមានចែងនៅក្នុងមាត្រា 48 តែប៉ុណ្ណោះ។ ដូចនេះ ញត្តិនេះត្រូវបានបញ្ជាក់ទទួលស្គាល់ដោយអគ្គរដ្ឋអាជ្ញាក្រោមមាត្រា 48 រួចរាល់ហើយ ប៉ុន្តែរូបគាត់ ឬតុលាការមិនទាន់បានវាយតម្លៃលើភាពស្របតាមរដ្ឋធម្មនុញ្ញរបស់វានាពេលបច្ចុប្បន្ននេះនៅឡើយទេ។

អាស្រ័យហេតុនេះ ភាគច្រើននៃគណៈកម្មាធិការបានផ្ដល់អនុសាសន៍ឱ្យសភានីតិបញ្ញត្តិរដ្ឋ **កុំចាត់វិធានការ** លើញត្តិផ្ដួចផ្ដើម 25-10/សេចក្ដីព្រាងច្បាប់សភាលេខ 5002 *ដែលជាញត្តិផ្ដួចផ្ដើមច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងកញ្ឆា*។

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
|---|---|
| Cindy F. Friedman | Alice Hanlon Peisch |
| Brendan P. Crighton | Kate Hogan |
| Paul R. Feeney | Frank A. Moran |
| Barry R. Finegold | Michael S. Day |
| | David T. Vieira |

# អត្ថបទទាំងស្រុង

## សំណួរទី 1៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង

ច្បាប់ស្តីពីការកែលម្អលទ្ធភាពទទួលបានឯកសារសាធារណៈ

អនុម័តដោយប្រជាជន និងតាមអំណាចរបស់ប្រជាជន ដូចតទៅ៖

មាត្រា 1៖ កថាខណ្ឌទីមួយ ឃ្លាទី 26 មាត្រា 7 ជំពូក 4 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយបញ្ចូលនូវឃ្លា “or by the general court, or by the office of the governor of the commonwealth (ឬដោយសភានីតិប្បញ្ញត្តិរដ្ឋ ឬដោយខុទ្ទកាល័យអភិបាលរដ្ឋអភិបាលរដ្ឋម៉ាសាឈូសិត)” បន្ទាប់ពីពាក្យ “ជំពូក 32”។

មាត្រា 2៖ ឃ្លាទី 26 ដែលបានរៀបរាប់ខាងលើ នៃមាត្រា 7 ជំពូក 4 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយបញ្ចូលកថាខណ្ឌរងថ្មីៗ បន្ទាប់ពីកថាខណ្ឌរង (v) ដូចតទៅ៖-

(w) ការប្រាស្រ័យទាក់ទងគ្នារវាងសមាជិកសភានីតិប្បញ្ញត្តិរដ្ឋ ឬបុគ្គលិក ភ្នាក់ងារ ឬតំណាងរបស់សមាជិករូបនោះ ជាមួយម្ចាស់ឆ្នោតណាម្នាក់របស់សមាជិករូបនោះ ដោយគ្រាន់តែថា ការប្រាស្រ័យទាក់ទងនោះពាក់ព័ន្ធសមស្របទៅនឹងការស្នើសុំជំនួយរបស់ម្ចាស់ឆ្នោតដើម្បីទទួលបានអត្ថប្រយោជន៍ ឬសេវាកម្មដែលផ្តល់ដោយរដ្ឋាភិបាល ឬក្នុងទំនាក់ទំនងផ្សេងទៀតជាមួយទីភ្នាក់ងាររដ្ឋ ឬសហព័ន្ធ។

(x) ការប្រាស្រ័យទាក់ទងគ្នា អនុស្សរណៈ សេចក្តីព្រាង ឬឯកសារផ្សេងទៀតដែលពាក់ព័ន្ធនឹងការបង្កើតជំហរគោលនយោបាយរបស់សមាជិកសភានីតិប្បញ្ញត្តិរដ្ឋ ឬអភិបាលរដ្ឋម៉ាសាឈូសិត។

មាត្រា 3៖ ប្រយោគទីបីនៃកថាខណ្ឌទីមួយ មាត្រា 6A ជំពូក 66 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលប្រយោគទីបីនោះ ហើយជំនួសមកវិញនូវខ្លឹមសារដូចតទៅ៖-

សម្រាប់គោលបំណងនៃជំពូកនេះ ពាក្យ “ទីភ្នាក់ងារ” ត្រូវមានន័យថាជាអង្គភាពណាមួយ ក្រៅពីរដ្ឋបាលក្រុង ដែលបានកំណត់ក្នុងឃ្លាទី 26 មាត្រា 7 នៃជំពូក 4 ថាជាអ្នកកាន់កាប់ “ឯកសារសាធារណៈ” ដូចមានកំណត់និយមន័យនៅទីនោះ រាប់បញ្ចូលទាំងសភានីតិប្បញ្ញត្តិរដ្ឋ និងខុទ្ទកាល័យអភិបាលរដ្ឋម៉ាសាឈូសិត។

មាត្រា 4៖ មាត្រា 18 ជំពូក 66 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលមាត្រា 18 នោះ ហើយជំនួសមកវិញនូវខ្លឹមសារដូចតទៅ៖-

មាត្រា 18៖ សេចក្តីប្រកាស លិខិតបញ្ជាក់ និងឯកសារផ្សេងទៀតដែលដាក់ជូនដោយអ្នកទាមទារទៅខុទ្ទការិយាល័យរដ្ឋមន្ត្រីសេវាអតីតយុទ្ធជន ឬកំណត់ត្រាដែលរក្សាទុកដោយរដ្ឋមន្ត្រីសម្រាប់ជាឯកសារយោងដោយមន្ត្រីនៃការិយាល័យរបស់ពួកគេ មិនត្រូវចាត់ទុកជាកំណត់ត្រាសាធារណៈ សម្រាប់គោលបំណងនៃជំពូកនេះឡើយ។

មាត្រា 5៖ ច្បាប់នេះត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2027។

## សំណួរទី 2៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង

ច្បាប់ស្តីពីគោលនយោបាយទំនាក់ទំនងការងារសម្រាប់បុគ្គលិកគណៈកម្មាធិការសេវាមេធាវីការពារក្តីសាធារណៈ

អនុម័តដោយប្រជាជន និងតាមអំណាចរបស់ប្រជាជន ដូចតទៅ៖

មាត្រា 1៖ មាត្រា 1 ជំពូក 150E នៃច្បាប់ទូទៅ ដូចមានចែងនៅក្នុងការបោះពុម្ពផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្មដោយបន្ថែមនៅចុងបញ្ចប់នៃកថាខណ្ឌទីប្រាំពីរ ដែលមានចំណងជើងថា “និយោជក” ឬ “និយោជកសាធារណៈ” នូវប្រយោគដូចតទៅ៖ “ក្នុងករណីបុគ្គលិករបស់គណៈកម្មាធិការសេវាមេធាវីការពារក្តីសាធារណៈ ពាក្យថា និយោជក ត្រូវសំដៅលើគណៈកម្មាធិការសេវាមេធាវីការពារក្តីសាធារណៈ ឬតំណាងដែលខ្លួនបានចាត់តាំង។”

មាត្រា 2៖ មាត្រា 7 ជំពូក 150E នៃច្បាប់ទូទៅ ដែលមានចែងខាងលេ់ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ “or (ឬ)” នៅពីមុខឃ្លា “the state lottery commission (គណៈកម្មការឆ្នោតឡូតូរដ្ឋ)” ក្នុងជួរទី 16 និងបន្ថែមពាក្យបន្ទាប់ពីឃ្លានោះដូចខាងក្រោម៖ “or the committee for public counsel services (ឬគណៈកម្មាធិការសេវាមេធាវីការពារក្តីសាធារណៈ)។”

មាត្រា 3៖ មាត្រា 7 ជំពូក 150E នៃច្បាប់ទូទៅ ដែលមានចែងខាងលើ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ “និង” នៅពីមុខពាក្យ “គណៈកម្មការឆ្នោតឡូតូរដ្ឋ” ដែលមានក្នុងជួរទី 34 និងបញ្ចូលបន្ទាប់ពីពាក្យ “គណៈកម្មការ” ក្នុងជួរទី 35 នូវពាក្យដូចតទៅ៖ “and committee for public counsel services (និងកម្មាធិការសេវាមេធាវីការពារក្តីសាធារណៈ)។”

## សំណួរទី 3៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង

ច្បាប់ស្តីពីការអនុវត្តការបោះឆ្នោតបឋមថ្នាក់រដ្ឋសម្រាប់គ្រប់គណបក្សទាំងអស់

អនុម័តដោយប្រជាជន និងតាមអំណាចរបស់ប្រជាជន ដូចតទៅ៖

មាត្រា 1៖ មាត្រា 1 ជំពូក 50 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយកែប្រែនិយមន័យនៃពាក្យ “គណបក្សនយោបាយ” នៅក្នុងនោះ តាមរយៈការបញ្ចូលឃ្លា “the latest state primary held prior to (ការបោះឆ្នោតបឋមថ្នាក់រដ្ឋចុងក្រោយបំផុតដែលបានធ្វើឡើងមុន)” បន្ទាប់ពីឃ្លា “to a party which at (ទៅគណបក្សមួយដែលនៅ)” ក្នុងប្រយោគទីមួយនៃនិយមន័យនោះ និងដោយលុបចោលប្រយោគទីពីរនៃនិយមន័យនោះទាំងស្រុង។

មាត្រា 2៖ ជំពូក 50 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយបញ្ចូលបន្ទាប់ពីមាត្រា 2 នូវមាត្រា 2A ដូចតទៅ៖

មាត្រា 2A៖ នៅក្នុងការបោះឆ្នោតបឋមថ្នាក់រដ្ឋដែលប្រព្រឹត្តទៅអនុលោមតាមមាត្រា 41 ដល់ 53A (រួមទាំងពីរមាត្រានេះផង) នៃជំពូក 53 បុគ្គលពីររូបដែលទទួលបានសំឡេងឆ្នោតគាំទ្រខ្ពស់ជាងគេសម្រាប់តំណែងមួយ ត្រូវចាត់ទុកថាបានតែងតាំងឱ្យឈរឈ្មោះបោះឆ្នោតសម្រាប់តំណែងនោះ ហើយមានតែឈ្មោះបុគ្គលពីររូបនោះគត់នឹងត្រូវបានបោះពុម្ពលើសន្លឹកឆ្នោតសម្រាប់តំណែងនោះ នៅក្នុងការបោះឆ្នោតថ្នាក់រដ្ឋនាពេលខាងមុខ។

## សំណួរទី 3៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង (ត)

មាត្រា 3៖ មាត្រា 2 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយបញ្ចូលឃ្លា "Except as provided in section two-A of chapter fifty (លើកលែងតែមានចែងក្នុងមាត្រា 2A នៃជំពូក 50)" នៅដើមប្រយោគទីពីរនៃផ្នែកនោះ។

មាត្រា 4៖ មាត្រា 6 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលប្រយោគពីរដំបូងនៃកថាខណ្ឌទីមួយ និងលុបចោលកថាខណ្ឌទីពីរនិងទីបីនៃមាត្រា 6 នោះទាំងស្រុង។

មាត្រា 5៖ មាត្រា 8 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលប្រយោគបីដំបូងនៃកថាខណ្ឌទីមួយ និងប្រយោគទីមួយនិងទីបួននៃកថាខណ្ឌទីពីរនៃមាត្រា 8 នោះ។

មាត្រា 6៖ មាត្រា 10 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលប្រយោគបួនដំបូងចេញពីកថាខណ្ឌទីមួយនៃមាត្រា 10 នោះ ហើយជំនួសមកវិញនូវខ្លឹមសារដូចតទៅ៖

រាល់វិញ្ញាបនបត្របញ្ជាក់ការតែងតាំង និងឯកសារតែងតាំងរបស់បេក្ខជនសម្រាប់តំណែងនានា ដែលការបោះឆ្នោតបឋមថ្នាក់រដ្ឋត្រូវបានរៀបចំឡើងអនុលោមតាមមាត្រា 41 ត្រូវដាក់ជូនស្របតាមមាត្រា 46។

មាត្រា 7៖ មាត្រា 14 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយបញ្ចូលបន្ទាប់ពីពាក្យ "otherwise (បើមិនដូច្នោះទេ)" នៅក្នុងប្រយោគទីមួយនៃផ្នែកនោះ នូវខ្លឹមសារដូចតទៅ៖ "shall first be filled by the candidate who received the next highest number of votes for such office in the applicable state primary, and if there is no such candidate (ជាដំបូងត្រូវបំពេញបន្ថែមដោយបេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រខ្ពស់ជាងគេបន្ទាប់ សម្រាប់តំណែងនោះ នៅក្នុងការបោះឆ្នោតបឋមថ្នាក់រដ្ឋដែលពាក់ព័ន្ធ ហើយប្រសិនបើគ្មានបេក្ខជនបែបនោះទេ)"

មាត្រា 8៖ មាត្រា 33 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលមាត្រា 33 នោះ ហើយជំនួសមកវិញនូវខ្លឹមសារដូចតទៅ៖-

មាត្រា 33៖ យ៉ាងហោចណាស់ត្រូវផ្តល់ច្បាប់ចម្លងនៃសន្លឹកឆ្នោតដូចគ្នាបេះបិទចំនួនបីច្បាប់ សម្រាប់មណ្ឌលបោះឆ្នោតនីមួយៗ ដើម្បីធ្វើជាសន្លឹកឆ្នោតគំរូ។

មាត្រា 9៖ មាត្រា 34 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពីប្រយោគទីមួយនូវឃ្លា "Official ballot of the (here shall follow the party name) [សន្លឹកឆ្នោតផ្លូវការរបស់ (នៅទីនេះត្រូវដាក់តាមឈ្មោះគណបក្ស)]" ហើយជំនួសមកវិញនូវឃ្លា "Official primary ballot (សន្លឹកឆ្នោតបឋមផ្លូវការ)" និងដោយបញ្ចូលបន្ទាប់ពីកថាខណ្ឌទីមួយនូវខ្លឹមសារដូចតទៅ៖-

នៅជាប់នឹងឈ្មោះបេក្ខជនម្នាក់ៗ ត្រូវបោះពុម្ពបញ្ជាក់ពីគណបក្សនយោបាយ ឬការចាត់តាំងដែលបង្ហាញនៅលើឯកសារតែងតាំងរបស់ពួកគេ ដូចមានចែងក្នុងមាត្រា 45 ហើយផ្អែកលើការស្នើសុំរួមគ្នាពីគណៈកម្មាធិការទូទៅ ឬគណៈកម្មាធិការប្រតិបត្តិដែលតំណាងឱ្យគណបក្សនយោបាយ ឬការចាត់តាំង និងបេក្ខជននោះ ត្រូវបោះពុម្ពពាក្យថា ""Endorsed by the [name of political party or designation] (គាំទ្រដោយ [ឈ្មោះគណបក្សនយោបាយ ឬការចាត់តាំង])"។ នៅក្នុងករណីក្រោយនេះ លិខិតស្នើសុំត្រូវតែដាក់ជូនរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ មិនតិចជាងដប់ប្រាំថ្ងៃមុនកាលបរិច្ឆេទចុងក្រោយដែលសន្លឹកឆ្នោតត្រូវបានបោះពុម្ពឡើយ។

មាត្រា 10៖ មាត្រា 37 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្ម ដោយលុបចោលប្រយោគទីមួយទាំងស្រុងពីកថាខណ្ឌទីមួយ ព្រមទាំងលុបចោលឃ្លា "Except as provided by section thirty-seven A (លើកលែងតែករណីដែលមានចែងក្នុងមាត្រា 37A)" និងឃ្លា ", and, if the party enrolment of such voter is shown on the voting list, the name of the party in which he is enrolled (ហើយប្រសិនបើការចុះឈ្មោះគណបក្សរបស់អ្នកបោះឆ្នោតត្រូវបានបង្ហាញនៅក្នុងបញ្ជីបោះឆ្នោត ឈ្មោះគណបក្សដែលគាត់បានចុះឈ្មោះ)" ពីប្រយោគទីពីរនៃកថាខណ្ឌនោះ លុបចោលប្រយោគទីបីទាំងស្រុងនៃកថាខណ្ឌនោះនូវឃ្លា "of the political party so requested (របស់គណបក្សនយោបាយដែលបានស្នើសុំ)" ពីប្រយោគទីបួននៃកថាខណ្ឌនោះ និងលុបចោលប្រយោគទីប្រាំទាំងស្រុង ហើយលុបចោលប្រយោគទីពីរនិងទីបីទាំងស្រុងពីកថាខណ្ឌទីពីរនៃផ្នែកនោះ។

មាត្រា 11៖ មាត្រា 41 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលឃ្លា "of political parties (របស់គណបក្សនយោបាយ)" ពីប្រយោគទីមួយនៃផ្នែកនោះ។

មាត្រា 12៖ មាត្រា 44 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលប្រយោគចុងក្រោយនៃផ្នែកនោះ ហើយជំនួសមកវិញនូវខ្លឹមសារដូចតទៅ៖-

ចំពោះករណីតំណែងអភិបាលរដ្ឋ និងអភិបាលរងរដ្ឋ ទាល់តែមានឯកសារតែងតាំងដែលមានឈ្មោះនិងអាសយដ្ឋានរបស់បេក្ខជនសម្រាប់តំណែងទាំងពីរប៉ុណ្ណោះ ទើបចាត់ទុកថាមានសុពលភាព។

មាត្រា 13៖ មាត្រា 45 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មតាមរយៈបញ្ញត្តិនោះ ដោយលុបចោលឃ្លា "the political party whose nomination he seeks (គណបក្សនយោបាយដែលខ្លួនស្វែងរកការតែងតាំង)" នៅក្នុងប្រយោគទីមួយ ហើយជំនួសមកវិញនូវឃ្លា "the political party or designation that he represents, if any, as determined by his voter registration (គណបក្សនយោបាយ ឬការចាត់តាំងដែលខ្លួនតំណាង ប្រសិនបើមាន ដូចដែលបានកំណត់ដោយការចុះឈ្មោះបោះឆ្នោតរបស់ខ្លួន)" និងដោយលុបចោលកថាខណ្ឌទីបួននៃផ្នែកនោះ ហើយជំនួសមកវិញនូវខ្លឹមសារដូចតទៅ៖-

គ្មានឯកសារតែងតាំងប្រើប្រាស់សម្រាប់ការតែងតាំងបេក្ខជន ដើម្បីបោះឆ្នោតក្នុងការបោះឆ្នោតបឋមថ្នាក់រដ្ឋ មាននូវឈ្មោះបេក្ខជនលើសពីមួយរូបឡើយ លើកលែងតែឯកសារតែងតាំងសម្រាប់បេក្ខជនអភិបាលរដ្ឋ និងអភិបាលរងរដ្ឋ ដែលត្រូវមានឈ្មោះបេក្ខជនមួយរូបសម្រាប់តំណែងនីមួយៗ។ ឯកសារតែងតាំងនោះសម្រាប់បេក្ខជនអភិបាលរដ្ឋ និងអភិបាលរងរដ្ឋ ត្រូវមានកន្លែងសម្រាប់ឈ្មោះនិងអាសយដ្ឋានរបស់សមាជិកនៃគណៈកម្មាធិការអ្នកបោះឆ្នោតដែលបានចុះឈ្មោះចំនួនប្រាំរូប ដែលនឹងត្រូវជំនួសមុខតំណែងនៅទំនេរណាមួយ ដោយសារមរណភាព ការដកខ្លួនចេញ ការមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬការដកសិទ្ធិរបស់បេក្ខជនណាម្នាក់។

មាត្រា 14៖ មាត្រា 46 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលឃ្លា "and who are not enrolled in any other party than that whose nomination the candidate seeks (ហើយដែលមិនបានចុះឈ្មោះចូលក្នុងគណបក្សណាផ្សេងក្រៅពីគណបក្សដែលបេក្ខជនស្វែងរកការតែងតាំង)" ចេញពីប្រយោគទីប្រាំនៃផ្នែកនោះ។

មាត្រា 15៖ មាត្រា 53 ជំពូក 53 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលមាត្រា 53 នោះ ហើយជំនួសមកវិញនូវខ្លឹមសារដូចតទៅ៖-

មាត្រា 53៖ ក្នុងករណីមានសំឡេងឆ្នោតស្មើគ្នា ដែលចំនួនបុគ្គលទទួលបានសំឡេងឆ្នោតស្មើគ្នានោះ លើសពីចំនួននៃការតែងតាំងដែលមាន រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋត្រូវកោះហៅបេក្ខជនដែលទទួលបានសំឡេងឆ្នោតស្មើគ្នាទាំងនោះ ឱ្យមកជួបខ្លួនជាបន្ទាន់ តាមពេលវេលានិងទីកន្លែងដែលបានកំណត់។ រដ្ឋមន្ត្រីក្រសួង

## សំណួរទី 3៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង (ត)

កិច្ចការរដ្ឋត្រូវកាត់សេចក្តីលើសំឡេងស្មើគ្នានោះដោយការចាប់ឆ្នោត តាមពេលវេលា និងទីកន្លែងនោះ។

មាត្រា 16៖ មាត្រា 33 ជំពូក 54 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលឃ្លា "and elections and of voting for candidates of more than one political party at a primary (និងការបោះឆ្នោត រួមទាំងការបោះឆ្នោតឱ្យបេក្ខជនមកពីគណបក្សនយោបាយច្រើនជាងមួយនៅក្នុងការបោះឆ្នោតបឋម)" ពីកថាខណ្ឌទីមួយ លុបចោលប្រយោគចុងក្រោយនៃកថាខណ្ឌទីពីរ និងលុបចោលឃ្លា "or of voting for candidates of more than one political party at a primary (ឬការបោះឆ្នោតឱ្យបេក្ខជនមកពីគណបក្សនយោបាយច្រើនជាងមួយនៅក្នុងការបោះឆ្នោតបឋម)" ពីកថាខណ្ឌទីបីនៃផ្នែកនោះ

មាត្រា 17៖ មាត្រា 43A ជំពូក 54 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលឃ្លា "at a state election (នៅក្នុងការបោះឆ្នោតរដ្ឋ)" ពីប្រយោគទីមួយនៃផ្នែកនោះ។

មាត្រា 18៖ ច្បាប់នេះត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2028។

មាត្រា 19៖ បទប្បញ្ញត្តិនៃច្បាប់នេះ អាចមានសុពលភាពដោយអន្លើ ហើយប្រសិនបើមានឃ្លា ប្រយោគ កថាខណ្ឌ ឬមាត្រាណាមួយនៃបញ្ញត្តិនោះ ឬការអនុវត្តញត្តិនេះត្រូវបានកាត់សេចក្តីដោយតុលាការមានសមត្ថកិច្ចណាមួយថាជានិរាករណ៍ សេចក្តីសម្រេចនោះមិនត្រូវជះឥទ្ធិពល ប៉ះពាល់ ឬធ្វើឱ្យមានអសុពលភាពដល់ផ្នែកដែលនៅសល់នោះឡើយ ប៉ុន្តែត្រូវកម្រិតឥទ្ធិពលត្រឹមតែឃ្លា ប្រយោគ កថាខណ្ឌ មាត្រា ឬការអនុវត្តច្បាប់ដែលត្រូវបានកាត់សេចក្តីជានិរាករណ៍នោះតែប៉ុណ្ណោះ ហើយឃ្លា ប្រយោគ កថាខណ្ឌ មាត្រា ឬការអនុវត្តបែបនោះ ត្រូវតែកែទម្រង់ និងបកស្រាយក្នុងន័យដើម្បីឱ្យមានសុពលភាពក្នុងកម្រិតអតិបរមាដែលអាចអនុញ្ញាតបាន។

## សំណួរទី 4៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង

ច្បាប់ស្តីពីការចុះឈ្មោះនៅថ្ងៃបោះឆ្នោត

អនុម័តដោយប្រជាជន និងតាមអំណាចរបស់ប្រជាជន ដូចតទៅ៖

មាត្រា 1៖ មាត្រា 1 ជំពូក 51 នៃច្បាប់ទូទៅ ដូចមានចែងនៅក្នុងការបោះពុម្ពផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្មដោយ លុបចោលប្រយោគចុងក្រោយ ហើយជំនួសមកវិញនូវប្រយោគដូចតទៅ៖- បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការបោះឆ្នោតជ្រើសរើសមន្ត្រីថ្នាក់ជាតិ ឬថ្នាក់រដ្ឋ ប៉ុន្តែមិនទាន់បានចុះឈ្មោះស្របតាមបទប្បញ្ញត្តិមាត្រា 26 នៃជំពូកនេះ ត្រូវមានសិទ្ធិចុះឈ្មោះបោះឆ្នោតក្រោមមាត្រា 34A។

មាត្រា 2៖ មាត្រា 1F ជំពូក 51 នៃច្បាប់ទូទៅ ត្រូវបានលុបចោលតាមរយៈច្បាប់នេះ។

មាត្រា 3៖ ជំពូក 25 ដូចមានចែងខាងលើ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលមាត្រា 3 ដូចបានចែង ហើយជំនួសមកវិញនូវមាត្រាដូចតទៅ៖

មាត្រា 3៖ សម្រាប់ការបោះឆ្នោត និងការបោះឆ្នោតបឋមទាំងអស់ បុគ្គលម្នាក់ត្រូវចុះឈ្មោះ និងអាចបោះឆ្នោតនៅមណ្ឌលបោះឆ្នោតមូលដ្ឋានដែលពួកគេរស់នៅបាន។ ទោះជាយ៉ាងណាក៏ដោយ អ្នកបោះឆ្នោតដែលបានចុះឈ្មោះក្នុងទីក្រុងឬស្រុកណាមួយ ដែលផ្លាស់ប្តូរទីលំនៅទៅកាន់មណ្ឌលបោះឆ្នោតមូលដ្ឋានផ្សេងទៀតនៅក្នុងទីក្រុង ឬស្រុកដដែលនោះ ឬទៅកាន់ទីក្រុង ឬទីប្រជុំជនផ្សេងទៀត អាចចុះឈ្មោះបោះឆ្នោតនៅអាសយដ្ឋានថ្មីរបស់ពួកគេបាន ដោយធ្វើលិខិតស្នើសុំជាលាយលក្ខណ៍អក្សរជូនទៅលេខាធិការក្រុងឬស្រុក មិនឱ្យហួសពីពេលបិទការចុះឈ្មោះឡើយ ឬស្របតាមបទប្បញ្ញត្តិនៃមាត្រា 34A នៃជំពូកនេះ។ និវាសនជនថ្មីនៃទីក្រុងឬស្រុក ក៏អាចចុះឈ្មោះនៅអាសយដ្ឋានថ្មីបានដែរ តាមរយៈការដាក់លិខិតស្នើសុំជាលាយលក្ខណ៍អក្សរស្រដៀងគ្នានេះជូនទៅលេខាធិការក្រុងឬស្រុក មិនឱ្យហួសពីពេលបិទការចុះឈ្មោះ ឬស្របតាមបទប្បញ្ញត្តិនៃមាត្រា 34A។ លេខាធិការក្រុងឬស្រុក ត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកបោះឆ្នោតម្នាក់ៗដែលបានធ្វើលិខិតស្នើសុំជាលាយលក្ខណ៍អក្សរនោះថា បានទទួលលិខិតស្នើសុំរួចរាល់ ហើយពួកគេអាចបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតមូលដ្ឋានដែលពួកគេបានផ្លាស់ទីលំនៅទៅនោះបាន ដោយផ្អែកលើបទប្បញ្ញត្តិនៃមាត្រាពាក់ព័ន្ធនឹងការបិទការចុះឈ្មោះ ឬស្របតាមបទប្បញ្ញត្តិនៃមាត្រា 34A។

មាត្រា 4៖ មាត្រា 26 នៃជំពូក 51 ដូចមានចែងខាងលើ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលប្រយោគចុងក្រោយ។

មាត្រា 5៖ ជំពូក 51 ខាងលើ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលមាត្រា 34 ដូចមានចែងនៅក្នុងការបោះពុម្ពផ្លូវការឆ្នាំ 2022 ហើយជំនួសមកវិញនូវមាត្រាដូចតទៅ៖ —

មាត្រា 34៖ លើកលែងតែមានចែងផ្សេងទៀតនៅក្នុងមាត្រា 34A ពុំនោះទេ បន្ទាប់ពីម៉ោង 5:00 ល្ងាច នៅថ្ងៃបញ្ឈប់ការចុះឈ្មោះ មន្ត្រីចុះឈ្មោះមិនត្រូវចុះឈ្មោះបុគ្គលណាម្នាក់ដើម្បីបោះឆ្នោតនៅក្នុងការបោះឆ្នោតបន្ទាប់ឡើយ លើកលែងតែពួកគេត្រូវផ្តល់ ឬចាត់ចែងឱ្យផ្តល់ជូនដល់បុគ្គលម្នាក់ៗដែលកំពុងរង់ចាំក្នុងជួរនៅវេលាម៉ោង 5:00 ល្ងាច ក្នុងគោលបំណងចុះឈ្មោះ នូវបណ្ណ ឬសន្លឹកបណ្ណសម្គាល់អត្តសញ្ញាណដែលមានឈ្មោះរបស់បុគ្គលនោះ ហើយត្រូវអនុញ្ញាតឱ្យបុគ្គលនោះចុះឈ្មោះ មុនពេលការចុះឈ្មោះត្រូវបានបញ្ឈប់។

មាត្រា 6៖ ជំពូក 51 ខាងលើ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយបញ្ចូលបន្ទាប់ពីមាត្រា 34 នូវមាត្រាដូចតទៅ៖ —

មាត្រា 34A៖ (a) បុគ្គលដែលមានសិទ្ធិបោះឆ្នោត អាចចុះឈ្មោះនៅថ្ងៃបោះឆ្នោតបាន ដោយបង្ហាញខ្លួនដោយផ្ទាល់នៅការិយាល័យបោះឆ្នោតសមស្របសម្រាប់មណ្ឌលបោះឆ្នោតមូលដ្ឋានដែលពួកគេរស់នៅ ក្នុងអំឡុងម៉ោងដែលការិយាល័យបោះឆ្នោតបើកដំណើរការ ដោយបំពេញពាក្យសុំចុះឈ្មោះក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ បង្ហាញភស្តុតាងបញ្ជាក់ពីទីលំនៅទៅកាន់មន្ត្រីរៀបចំការបោះឆ្នោតសមស្រប និងធ្វើសច្ចាប្រណិធានជាលាយលក្ខណ៍អក្សរដែលមានខ្លឹមសារដូចតទៅ៖ ខ្ញុំសូមបញ្ជាក់ថា៖ ខ្ញុំជាពលរដ្ឋសហរដ្ឋអាមេរិក មានអាយុយ៉ាងហោចណាស់ 18 ឆ្នាំ មិនស្ថិតក្រោមអាណាព្យាបាលដែលហាមឃាត់មិនឱ្យខ្ញុំចុះឈ្មោះ និង/ឬបោះឆ្នោត ឬត្រូវបានហាមឃាត់មិនឱ្យបោះឆ្នោតតាមរូបភាពផ្សេងទៀតឡើយ មិនត្រូវបានដកហូតសិទ្ធិជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍តាមផ្លូវច្បាប់ ដោយសារតែការអនុវត្តអំពើពុករលួយពាក់ព័ន្ធនឹងការបោះឆ្នោតមិនធ្លាប់បានបោះឆ្នោត ហើយនឹងមិនទៅបោះឆ្នោតនៅក្នុងការបោះឆ្នោតនេះនៅទីតាំងណាមួយផ្សេងទៀតនៅក្នុងរដ្ឋម៉ាសាឈូសិត ឬនៅកន្លែងផ្សេងទៀតឡើយ ព្រមទាំងបានអាន និងយល់ច្បាស់អំពីសេចក្តីថ្លែងការណ៍នេះ។ ខ្ញុំក៏យល់ច្បាស់ដែរថា ការផ្តល់ព័ត៌មានមិនពិត គឺជាបទឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមិនលើសពី 5 ឆ្នាំ ឬពិន័យ

## សំណួរទី 4៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង (ត)

ជាប្រាក់មិនលើសពី 10,000 ដុល្លារ ឬត្រូវអនុវត្តទណ្ឌកម្មទាំងពីរនេះរួមគ្នា។

(b) សម្រាប់គោលបំណងនៃមាត្រានេះ ពាក្យ “ភស្តុតាងបញ្ជាក់ទីលំនៅ” ត្រូវសំដៅលើជាឯកសារណាមួយដូចខាងក្រោម ដរាបណាឯកសារនោះមានឈ្មោះរបស់អ្នកដាក់ពាក្យ និងអាសយដ្ឋានដែលពួកគេកំពុងចុះឈ្មោះ៖

(i) អត្តសញ្ញាណប័ណ្ណដែលមានរូបថតត្រឹមត្រូវ រួមមានជាអាទិ៍ បណ្ណបើកបររដ្ឋម៉ាសាឈូសិត ឬប័ណ្ណសម្គាល់អត្តសញ្ញាណផ្សេងទៀតដែលចេញដោយរដ្ឋ ឬ

(ii) ឯកសារផ្សេងទៀតដែលបង្ហាញពីឈ្មោះនិងអាសយដ្ឋានដែលអ្នកដាក់ពាក្យរក្សាទុកជាទីលំនៅ និងស្វែងរកការចុះឈ្មោះ រួមមានជាអាទិ៍ ច្បាប់ចម្លងនៃវិក្កយបត្រសេវាសាធារណៈបច្ចុប្បន្ន របាយការណ៍គណនីធនាគារ មូលប្បទានបត្រពីរដ្ឋាភិបាល កិច្ចសន្យាជួលលំនៅឋាន វិក្កយបត្រទូរសព្ទចល័ត មូលប្បទានប័ណ្ណប្រាក់បៀវត្សរ៍ ឯកសារឬលិខិតឆ្លើយឆ្លងផ្លូវការផ្សេងទៀតពីរដ្ឋាភិបាល វិក្កយបត្របង់ថ្លៃសិក្សាបច្ចុប្បន្ន ឬឯកសារផ្សេងទៀតពីគ្រឹះស្ថានឧត្តមសិក្សាដែលបញ្ជាក់ពីអាសយដ្ឋានបច្ចុប្បន្នរបស់និស្សិត។

(c) នៅពេលបំពេញបានតាមលក្ខខណ្ឌអត្តសញ្ញាណនៃកថាខណ្ឌ (a) ការបង្ហាញភស្តុតាងបញ្ជាក់ទីលំនៅ និងការធ្វើសច្ចាប្រណិធានគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការចុះឈ្មោះ ស្មៀនចែកសន្លឹកឆ្នោត ឬតំណាងដែលខ្លួនបានចាត់តាំង ត្រូវអនុញ្ញាតឱ្យអ្នកដាក់ពាក្យបោះឆ្នោតនៅក្នុងការបោះឆ្នោតនោះ។ បុគ្គលណាក៏ដោយដែលចុះឈ្មោះនៅថ្ងៃបោះឆ្នោតស្របតាមមាត្រានេះ ត្រូវទទួលបានការចុះឈ្មោះដើម្បីបោះឆ្នោតនៅក្នុងការបោះឆ្នោតបឋម និងការបោះឆ្នោតជាបន្តបន្ទាប់ទាំងអស់ លើកលែងតែមានការដកសិទ្ធិ។

(d) អ្នកចុះឈ្មោះដែលខកខានមិនបានបង្ហាញឯកសារសម្គាល់អត្តសញ្ញាណសមស្រប ត្រូវអនុញ្ញាតឱ្យបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន អនុលោមតាមបទប្បញ្ញត្តិមាត្រា 76C នៃជំពូក 54 ប៉ុន្តែត្រូវតម្រូវឱ្យត្រឡប់មកវិញមុនពេលបិទការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតថ្នាក់ក្រុង ក្នុងរយៈពេលពីរថ្ងៃធ្វើការបន្ទាប់ពីការបោះឆ្នោតបឋមថ្នាក់រដ្ឋ ឬក្នុងរយៈពេលប្រាំមួយថ្ងៃបន្ទាប់ពីការបោះឆ្នោតថ្នាក់រដ្ឋ ដើម្បីបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណគ្រប់គ្រាន់ជូនមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋាន ដើម្បីឱ្យមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានកំណត់ថាតើអ្នកចុះឈ្មោះនោះមានលក្ខណសម្បត្តិគ្រប់គ្រាន់បោះឆ្នោតនៅក្នុងការបោះឆ្នោតនោះដែរឬទេ និងដើម្បីសម្រេចថាតើត្រូវរាប់សន្លឹកឆ្នោតបណ្ដោះអាសន្ននោះឬយ៉ាងណា។

(e) មិនតិចជាងប្រាំពីរថ្ងៃមុនការបោះឆ្នោតណាមួយ មន្ត្រីចុះឈ្មោះសម្រាប់ទីក្រុង ឬស្រុកនីមួយៗ ត្រូវប្រកាសផ្សាយពីទីតាំងបោះឆ្នោតទាំងអស់ ព្រមទាំងកាលបរិច្ឆេទ និងម៉ោងដំណើរការបោះឆ្នោត។ ការជូនដំណឹងត្រូវតែបិទផ្សាយជាសាធារណៈនៅការិយាល័យរបស់មន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋាន ឬនៅលើបញ្ជរព្រឹត្តិបត្រព័ត៌មានផ្លូវការចម្បងរបស់ទីក្រុងឬស្រុកនីមួយៗ នៅអគារសាធារណៈផ្សេងទៀតដែលចាត់ទុកថាចាំបាច់ លើគេហទំព័ររបស់ទីក្រុងឬស្រុក ប្រសិនបើមាន និងនៅលើគេហទំព័ររបស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

(f) រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋត្រូវផ្តល់លទ្ធភាពជូនមន្ត្រីរៀបចំការបោះឆ្នោតនៅតាមទីតាំងបោះឆ្នោតនីមួយៗ តាមដែលអាចធ្វើទៅបាន ក្នុងការចូលប្រើប្រាស់បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានចុះឈ្មោះទូទាំងរដ្ឋ ដូចមាននៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតគោលដែលបានចែងក្នុងមាត្រា 47C។

(g) មន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋាន អាចកែតម្រូវព័ត៌មានដែលផ្តល់ដោយអ្នកចុះឈ្មោះបាន ក្នុងកម្រិតដែលចាំបាច់ដើម្បីរក្សាភាពត្រឹមត្រូវនៃកំណត់ត្រារបស់ពួកគេ។ ប្រសិនបើលិខិតសច្ចាប្រណិធានមិនពេញលេញ ឬប្រសិនបើព័ត៌មានដែលបានចែងក្នុងលិខិតសច្ចាប្រណិធាននោះបង្ហាញថា អ្នកចុះឈ្មោះគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការចុះឈ្មោះជាអ្នកបោះឆ្នោតទេនោះ មន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានត្រូវចាត់វិធានការស្របតាមបទប្បញ្ញត្តិនៃមាត្រា 47។

(h) ក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបានបន្ទាប់ពីការបោះឆ្នោត ប៉ុន្តែមិនឱ្យលើសពីសាមសិបថ្ងៃបន្ទាប់ពីការបោះឆ្នោតឡើយ មន្ត្រីចុះឈ្មោះត្រូវបញ្ចូលឈ្មោះ អាសយដ្ឋាន និងកាលបរិច្ឆេទចូលជាធរមាននៃការចុះឈ្មោះរបស់អ្នកចុះឈ្មោះ ទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតប្រចាំឆ្នាំ។

(i) មាត្រានេះមិនត្រូវអនុវត្តចំពោះបុគ្គលដែលស្វែងរកការចុះឈ្មោះបោះឆ្នោតក្នុងស្រុកណាមួយ សម្រាប់គោលបំណងបោះឆ្នោតក្នុងអង្គប្រជុំប្រចាំឆ្នាំរបស់ស្រុក ឬអង្គប្រជុំវិសាមញ្ញរបស់ស្រុកឡើយ។

(j) អ្នកបោះឆ្នោតមិនត្រូវផ្លាស់ប្តូរការចុះឈ្មោះគណបក្ស នៅក្នុងការបោះឆ្នោតបឋមនៅក្រោមមាត្រានេះឡើយ។

(k) រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋត្រូវអនុម័តបទប្បញ្ញត្តិដើម្បីអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃជំពូកនេះ។

(l) នៅពេលទទួលបានព័ត៌មាន ឬការចោទប្រកាន់គួរឱ្យទុកចិត្តអំពីការចុះឈ្មោះបោះឆ្នោតខុសច្បាប់ ឬព័ត៌មាន ឬការចោទប្រកាន់គួរឱ្យទុកចិត្តអំពីការបោះឆ្នោតច្រើនដងដោយខុសច្បាប់ ត្រូវតែមានការស៊ើបអង្កេតលើអង្គសេចក្តីនៃព័ត៌មាន ឬការចោទប្រកាន់នោះ ដោយអគ្គរដ្ឋអាជ្ញា ឬដោយរដ្ឋអាជ្ញាប្រចាំតំបន់ដែលមានយុត្តាធិការលើរដ្ឋបាលក្រុងដែលការចុះឈ្មោះខុសច្បាប់ ឬការបោះឆ្នោតច្រើនដងខុសច្បាប់រងការចោទប្រកាន់នោះបានកើតឡើង។ គ្មានខ្លឹមសារណាមួយនៅក្នុងកថាខណ្ឌនេះ ត្រូវបកស្រាយថាជាការដកចេញនូវការអនុវត្តច្បាប់នៃមាត្រានេះតាមរយៈមធ្យោបាយណាមួយដែលច្បាប់បានចែងនោះឡើយ។

(m) ការរំលោភលើផ្នែកនេះ ត្រូវផ្តន្ទាទោសនៅក្រោមមាត្រា 8 មាត្រា 26 និងមាត្រា 27 នៃជំពូក 56។

មាត្រា 7៖ ច្បាប់នេះត្រូវចូលជាធរមាននៅថ្ងៃ 1 ខែមករា ឆ្នាំ 2028។

## សំណួរទី 5៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង

ច្បាប់ស្ដីពីការកំណត់កំណើននៃការប្រមូលពន្ធរបស់រដ្ឋ និងការបង្វិលសងប្រាក់ពន្ធលើសទៅឱ្យអ្នកជាប់ពន្ធវិញ

អនុម័តដោយប្រជាជន និងតាមអំណាចរបស់ប្រជាជន ដូចតទៅ៖

មាត្រា 1៖ មាត្រា 2 ជំពូក 62F នៃច្បាប់ទូទៅ ដូចមានចែងនៅក្នុងការបោះពុម្ពផ្លូវការឆ្នាំ 2024 ត្រូវបានធ្វើវិសោធនកម្មដោយជំនួសនិយមន័យនៃពាក្យ “ចំណូលពន្ធរដ្ឋអតិបរមាដែលបានគណនា” និងពាក្យ “ចំណូលពន្ធរដ្ឋ” ដោយនិយមន័យខាងក្រោម៖ —

“ចំណូលពន្ធរដ្ឋអតិបរមាដែលបានគណនា” មានន័យថា ចំនួនទឹកប្រាក់សម្រាប់ឆ្នាំសារពើពន្ធណាមួយដែលចាប់ផ្ដើមបន្ទាប់ពីថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2027 ដោយគណនាចេញពីផលគុណចំណូលពន្ធរដ្ឋសុទ្ធ (Net State Tax Revenues) នៃឆ្នាំសារពើពន្ធដែលទើបតែកន្លងផុតទៅ ជាមួយនឹងកត្តាកំណើនពន្ធរដ្ឋដែលអាចអនុញ្ញាត (Allowable State Tax Growth Factor) នៃឆ្នាំសារពើពន្ធបច្ចុប្បន្ននាពេលនោះ ដូចមានចែងក្នុងនិយមន័យនៃបញ្ញត្តិនេះ។

“ចំណូលពន្ធរដ្ឋ” មានន័យថា ចំណូលរបស់រដ្ឋម៉ាសាឈូសិតពីគ្រប់ប្រភេទពន្ធ ពន្ធបន្ថែម ចំណូលទទួលបាន ប្រាក់ពិន័យ និងការទាមទារជាទឹកប្រាក់ផ្សេងទៀត ព្រមទាំងការប្រាក់ពាក់ព័ន្ធនឹងចំណូលទាំងនោះ រួមមានជាអាទិ៍ ពន្ធ និងពន្ធបន្ថែមលើប្រាក់ចំណូលបុគ្គល (រួមទាំងចំណូលពន្ធបន្ថែមលើប្រាក់ចំណូលដែលប្រមូលបាន និងបានដាក់បញ្ចូលទៅក្នុងមូលនិធិអប់រំ និងដឹកជញ្ជូន អនុលោមតាមមាត្រា 2BBBBBB ជំពូក 29 នៃច្បាប់ទូទៅ សម្រាប់គោលបំណងនៃការគណនាណាមួយក្រោមជំពូកនេះ ចាប់ផ្ដើមបន្ទាប់ពីថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2027) រដ្ឋាករ និងពន្ធលើការលក់រាយនិងការប្រើប្រាស់ ចំណីអាហារ ប្រេងឥន្ធនៈយានយន្ត អាជីវកម្មនិងសាជីវកម្ម សេវាសាធារណៈ ភេសជ្ជៈមានជាតិអាល់កុល ថ្នាំជក់ មរតក អចលនទ្រព្យ ការផ្ទេរកម្មសិទ្ធិ ការស្នាក់នៅតាមបន្ទប់ និងការភ្នាល់ល្បែងប្រណាំង ប៉ុន្តែមិនរាប់បញ្ចូលសំណងរបស់សហព័ន្ធ ចំណូលដែលបានមកពីការបោះផ្សាយសញ្ញាបណ្ណ ផលចំណេញលើការវិនិយោគ ថ្លៃសិក្សា កម្រៃសេវា ការគិតថ្លៃសេវាកម្ម និងចំណូលនាយកដ្ឋានផ្សេងទៀត និងចំណូលទាក់ទងដោយផ្ទាល់ទៅនឹងពន្ធបន្ថែមដែលបានដកយក អនុលោមតាមមាត្រាប៉ែតសិបប្រាំបី ជំពូកប្រាំមួយរយប៉ែតសិបបួន នៃច្បាប់ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំ។

មាត្រា 2៖ មាត្រា 2BBBBBB ជំពូក 29 នៃច្បាប់ទូទៅ ដូចមានចែងនៅក្នុងការបោះពុម្ពផ្លូវការឆ្នាំ 2024 ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលកថាខណ្ឌរង (d) ដែលមានប្រសិទ្ធភាពសម្រាប់គោលបំណងនៃការគណនាណាមួយក្រោមជំពូក 62F នៃច្បាប់ទូទៅ ដូចមានចែងនៅក្នុងការបោះពុម្ពផ្លូវការឆ្នាំ 2024 សម្រាប់ឆ្នាំសារពើពន្ធណាមួយ ចាប់ផ្ដើមបន្ទាប់ពីថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2027។

មាត្រា 3៖ បទប្បញ្ញត្តិនៃច្បាប់នេះ អាចមានសុពលភាពដោយអន្លើ ហើយប្រសិនបើមានឃ្លា ប្រយោគ កថាខណ្ឌ ឬមាត្រាណាមួយនៃញត្តិនេះ ឬការអនុវត្តញត្តិនេះ ត្រូវបានកាត់សេចក្ដីដោយតុលាការមានសមត្ថកិច្ចណាមួយថាជានិរាករណ៍ សេចក្ដីសម្រេចនោះមិនត្រូវជះឥទ្ធិពល ប៉ះពាល់ ឬធ្វើឱ្យមានអសុពលភាពដល់ផ្នែកដែលនៅសល់នោះឡើយ ប៉ុន្តែត្រូវកម្រិតឥទ្ធិពលត្រឹមតែឃ្លា ប្រយោគ កថាខណ្ឌ មាត្រា ឬការអនុវត្តច្បាប់ដែលត្រូវបានកាត់សេចក្ដីជានិរាករណ៍នោះតែប៉ុណ្ណោះ។

## សំណួរទី 6៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង

ច្បាប់ស្ដីពីការការពារទឹក និងធម្មជាតិ

អនុម័តដោយប្រជាជន និងតាមអំណាចរបស់ប្រជាជន ដូចតទៅ៖

មាត្រា 1៖ ជំពូក 29 នៃច្បាប់ទូទៅ ដូចមានចែងក្នុងការបោះពុម្ពផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្មដោយបន្ថែមមាត្រា ដូចខាងក្រោម៖

មាត្រា 2EEEEEE៖ (a) ត្រូវតែបង្កើតនិងរៀបចំមូលនិធិដាច់ដោយឡែកមួយនៅលើសៀវភៅបញ្ជីរបស់រដ្ឋម៉ាសាឈូសិត ហៅថា មូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នា។ ត្រូវផ្ទេរចូលមូលនិធិនូវទឹកប្រាក់តម្លៃស្មើនឹង 50% នៃថវិកាទាំងអស់ដែលរដ្ឋម៉ាសាឈូសិតទទួលបានពីចំណូលពន្ធលើការលក់និងប្រើប្រាស់សម្ភារៈកីឡា យានយន្តកម្សាន្ត និងទីលានវាយកូនហ្គោល ដូចបានចាត់ថ្នាក់ក្រោមច្បាប់ចាត់ថ្នាក់ឧស្សាហកម្មអាមេរិកខាងជើង (North American Industry Classification Codes) កំណែឆ្នាំ 2022 អនុលោមតាមជំពូក 64H និង 64I។ ចំនួនទឹកប្រាក់ដែលផ្ទេរចូលមូលនិធិនៅក្រោមកថាខណ្ឌនេះ ត្រូវតែជាទឹកប្រាក់សុទ្ធ បន្ទាប់ពីដកទឹកប្រាក់ចំណូលពន្ធលើការលក់បម្រុងទុក ដែលបានផ្ទេរចូលអនុលោមតាមមាត្រា 35T និង 35BB នៃជំពូក 10។ មូលនិធិអាចទទួលយកអំណោយ មូលនិធិជំនួយ និងការបរិច្ចាគសាធារណៈ និងឯកជន ដើម្បីបម្រើដល់គោលបំណងនៃមាត្រានេះ ព្រមទាំងថវិកាផ្សេងទៀតដែលបានបញ្ចូល ឬផ្ទេរពីប្រភពណាមួយផ្សេងទៀត អនុលោមតាមច្បាប់រដ្ឋ។ មូលនិធិនេះមិនត្រូវស្ថិតនៅក្រោមមាត្រា 5C នៃជំពូកនេះឡើយ។

(b) សម្រាប់គោលបំណងនៃមាត្រានេះ ឃ្លា “ការអភិរក្សធនធានធម្មជាតិ” ត្រូវមានន័យថា៖ (i) ការអភិរក្ស ឬការស្ដារដីធ្លីឡើងវិញ ដើម្បីការពារទឹកស្អាត និងគុណភាពទឹកស្ទឹង ទន្លេ បឹងបួ និងឆ្នេរសមុទ្រ។ (ii) ការអភិរក្ស ឬការស្ដារឡើងវិញនូវកសិដ្ឋាន ព្រៃឈើ និងដីធ្លីផ្សេងទៀត ដើម្បីជំរុញគោលដៅនិងផែនការទូទាំងរដ្ឋក្នុងតំបន់ជីវៈចម្រុះ អាកាសធាតុ ដីធម្មជាតិ និងដីកសិកម្ម ភាពធន់ និងយុត្តិធម៌បរិស្ថាន។ (iii) ការបង្កើតនិងកែលម្អសួនឧទ្យាន លំហបៃតង ផ្លូវដើរកម្សាន្ត និងលទ្ធភាពទទួលបានការកម្សាន្តក្រៅផ្ទះ ជាពិសេសនៅក្នុងសហគមន៍ដែលលទ្ធភាពទទួលបានធនធានទាំងនេះនៅមានកម្រិត។ (iv) ការអភិរក្សក្បាលដី ដើម្បីបង្កើតការតភ្ជាប់ត្រួវរវាងទីវាលលំហ។ (v) ការអភិរក្ស និងការស្ដារឡើងវិញនូវដីធ្លី និងធនធានធម្មជាតិដែលមានសារៈសំខាន់ខាងផ្នែកវប្បធម៌ជនជាតិដើមភាគតិច និង (vi) ការផ្ដល់ការគ្រប់គ្រងថែរក្សាជាប្រចាំ លទ្ធភាពទទួលបានការកម្សាន្តក្រៅផ្ទះ និងការគ្រប់គ្រងធនធានទាំងនោះ។

(c) ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន ត្រូវចាត់ចែងការចំណាយពីមូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នា សម្រាប់គោលបំណងអភិរក្សធនធានធម្មជាតិ។

(d) ត្រូវមានក្រុមប្រឹក្សាមួយដែលមានសមាជិក 15 រូប ហៅថា ក្រុមប្រឹក្សាធម្មជាតិសម្រាប់ទាំងអស់គ្នា ដែលមានសមាសភាព រដ្ឋមន្ត្រីកិច្ចការថាមពលនិងបរិស្ថាន ប្រធាននាយកដ្ឋានជលផលនិងល្បែងកម្សាន្ត ប្រធាននាយកដ្ឋានអភិរក្ស និងកម្សាន្ត រដ្ឋមន្ត្រីលំនៅឋាននិងសហគមន៍រស់នៅដោយសមរម្យ និងប្រធានផ្នែកអាកាសធាតុ ព្រមទាំងសាធារណជនចំនួន 10 រូប ដែលត្រូវតែងតាំងដោយអភិបាលរដ្ឋ។ សាធារណជនទាំង 10 រូបនោះ ត្រូវរួមបញ្ចូលទាំងតំណាងសហគមន៍ជួបការលំបាក និងជនជាតិដើមភាគតិច និងបុគ្គលមួយរូប ឬច្រើនរូបដែលមានជំនាញ ឬបទពិសោធក្នុងការអភិរក្សធនធានធម្មជាតិ។ ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន

## សំណួរទី 6៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង (ត)

អាចចាត់ចែងការចំណាយពីមូលនិធិ ដើម្បីជួលបុគ្គលិកដែលចាំបាច់ក្នុងការគ្រប់គ្រង និងចាត់ចែងការចំណាយពីមូលនិធិនេះ។ ក្រុមប្រឹក្សាត្រូវប្រកាសឱ្យប្រើបទប្បញ្ញត្តិសម្រាប់ការចំណាយពីមូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នា ដោយការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន រួមមានជាអាទិ៍៖ (i) តម្រូវការសម្រាប់ការអភិរក្សធនធានធម្មជាតិដែលគាំទ្រ និងស្របតាមគោលការណ៍យុត្តិធម៌បរិស្ថាន ដូចមានចែងនៅក្នុងមាត្រា 62 នៃជំពូក 30។ (ii) តម្រូវការសម្រាប់លទ្ធភាពទទួលបាន និងការស្តារឡើងវិញនូវដីធ្លី និងធនធានធម្មជាតិដែលមានសារៈសំខាន់ខាងផ្នែកវប្បធម៌ជនជាតិដើមភាគតិច (iii) សេចក្តីណែនាំដើម្បីលើកកម្ពស់ការអភិរក្សធនធានធម្មជាតិទន្ទឹមគ្នានឹងការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ (iv) សេចក្តីណែនាំដែលបង្ការមិនឱ្យប្រើប្រាស់ការចំណាយទាំងនេះទៅជំនួសការចំណាយផ្សេងទៀត ឬបណ្តាលឱ្យមានការកាត់បន្ថយចំណាយក្រោមពិដានថវិកាសញ្ញាបណ្ណលើកម្មវិធីអភិវឌ្ឍមូលធនដែលមានស្រាប់ និង (vi) សេចក្តីណែនាំសម្រាប់វិសាលភាព និងការផ្តល់អាទិភាពនៃសញ្ញាបណ្ណកាតព្វកិច្ចជាក់លាក់ ដែលបានបោះផ្សាយដើម្បីគាំទ្រដល់ការអភិរក្សធនធានធម្មជាតិ។

(e) ទីភ្នាក់ងាររដ្ឋ រដ្ឋបាលក្រុង ឬក្រុមរដ្ឋបាលក្រុង រដ្ឋបាលថ្នាក់តំបន់ អង្គភាពសាធារណៈថ្នាក់តំបន់ផ្សេងទៀត រួមមានជាអាទិ៍ ទីភ្នាក់ងារផែនការថ្នាក់តំបន់ តំបន់អភិវឌ្ឍសេដ្ឋកិច្ច និងតំបន់គ្រប់គ្រងទឹក អង្គការសប្បុរសធម៌សាធារណៈដែលមានគោលបំណងពាក់ព័ន្ធនឹងការអភិរក្សធនធានធម្មជាតិ និងរដ្ឋបាលកុលសម្ព័ន្ធ ត្រូវតែជាអ្នកទទួលការចំណាយទាំងនេះដោយស្របច្បាប់។

(f) ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន ត្រូវដាក់ជូនជារៀងរាល់ឆ្នាំទៅកាន់ក្រុមប្រឹក្សា ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថានដែលបានបង្កើតឡើងក្នុងមាត្រា 62L នៃជំពូក 30 គណៈកម្មាធិការរដ្ឋសភានិងព្រឹទ្ធសភាទទួលបន្ទុកវិធីសាស្ត្រនិងមធ្យោបាយថវិកា និងគណៈកម្មាធិការចម្រុះស្តីពីបរិស្ថាននិងធនធានធម្មជាតិ នូវរបាយការណ៍អំពីសមាមាត្រនៃថវិកាដែលបានចំណាយពីមូលនិធិធម្មជាតិសម្រាប់ទាំងអស់គ្នា ដែលត្រូវបានបម្រុងទុកសម្រាប់ការទិញ ឬការកែលម្អដីធ្លីនៅក្នុងទីក្រុង ឬទីប្រជុំជនដែលមានប្រជាជនយុត្តិធម៌បរិស្ថាន ដូចមានចែងក្នុងមាត្រា 62 នៃជំពូក 30។

(g) រាល់បទប្បញ្ញត្តិទាំងអស់នៃមាត្រានេះ ត្រូវអនុលោមតាមការអនុម័តផ្តល់ កញ្ចប់ថវិកាដោយអង្គនីតិប្បញ្ញត្តិ។

មាត្រា 2៖ កថាខណ្ឌ 2EEEEEE(a) ជំពូក 29 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មនៅក្នុងប្រយោគទីពីរ ដោយលុបចោលពាក្យ “50% of (50% នៃ)”។

មាត្រា 3៖ មាត្រា 1 ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2027។

មាត្រា 4៖ មាត្រា 2 ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2028។

## សំណួរទី 7៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង

ច្បាប់ស្តីពីការអនុញ្ញាតឱ្យមានលំនៅឋានគ្រួសារទោលនៅលើដីឡូត៍តូចៗក្នុងតំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់

អនុម័តដោយប្រជាជន និងតាមអំណាចរបស់ប្រជាជន ដូចតទៅ៖

មាត្រា 1៖ មាត្រា 3 ជំពូក 40A នៃច្បាប់ទូទៅរបស់រដ្ឋម៉ាសាឈូសិត ដូចមានចែងស្រាប់ ត្រូវបានធ្វើវិសោធនកម្មដោយបន្ថែមកថាខណ្ឌដូចតទៅ៖

គ្មានបទបញ្ជា ឬលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំដែនដីណា ត្រូវហាមឃាត់ រឹតត្បិតដោយគ្មានហេតុផល ឬតម្រូវឱ្យមានលិខិតអនុញ្ញាតពិសេស ឬការអនុម័តផ្នែករៀបចំដែនដីតាមឆន្ទានុសិទ្ធិផ្សេងទៀត សម្រាប់ការប្រើប្រាស់ដីធ្លី ឬសំណង់សម្រាប់ជាលំនៅឋានគ្រួសារទោល នៅក្នុងតំបន់រៀបចំដែនដីដែលអនុញ្ញាតឱ្យមានការប្រើប្រាស់សម្រាប់ជាលំនៅឋានឡើយ ក្នុងលក្ខខណ្ឌដែលលំនៅឋានគ្រួសារទោលនោះត្រូវបានរួមបញ្ចូលទាំងស្រុងក្នុងដីឡូត៍ដែលមានទំហំស្មើ ឬធំជាង 5,000 ហ្វីតការ៉េ និងមានប្រវែងមុខដីជាប់ផ្លូវស្មើ ឬធំជាង 50 ហ្វីត ព្រមទាំងមានលទ្ធភាពតភ្ជាប់ទៅនឹងសេវាប្រព័ន្ធលូសាធារណៈ និងសេវាទឹកស្អាតសាធារណៈ ហើយការប្រើប្រាស់ដីធ្លី ឬសំណង់សម្រាប់លំនៅឋានគ្រួសារទោលនោះនៅក្រោមកថាខណ្ឌនេះ អាចនឹងត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិសមស្រប រួមមានជាអាទិ៍ បទប្បញ្ញត្តិស្តីពីគម្លាតសុវត្ថិភាពនៃទំហំសំណង់ ទំហំនិងកម្ពស់នៃសំណង់ ហើយអាចស្ថិតនៅក្រោមការរឹតត្បិត និងការហាមឃាត់ចំពោះការជួលក្នុងរយៈពេលខ្លី។ ការិយាល័យប្រតិបត្តិនៃលំនៅឋាននិងសហគមន៍សមស្របសម្រាប់ការរស់នៅ (Executive Office of Housing and Livable Communities) អាចចេញសេចក្តីណែនាំ ឬប្រកាសឱ្យប្រើបទប្បញ្ញត្តិដើម្បីគ្រប់គ្រងកថាខណ្ឌនេះ។

មាត្រា 2៖ ច្បាប់នេះត្រូវចូលជាធរមាន ដូចមានចែងក្នុងមាត្រា 48 នៃវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាឈូសិត ដែលបានធ្វើវិសោធនកម្មជាបន្តបន្ទាប់។

## សំណួរទី 8៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង

ច្បាប់ស្តីពីការស្តារឡើងវិញនូវគោលនយោបាយកញ្ឆាសមស្រប

អនុម័តដោយប្រជាជន និងតាមអំណាចរបស់ប្រជាជន ដូចតទៅ៖

មាត្រា 1៖ គោលបំណងនៃច្បាប់នេះ គឺដើម្បីកែប្រែលក្ខខណ្ឌសម្រាប់ការកាន់កាប់ ការចែកចាយ និងការប្រើប្រាស់កញ្ឆាដោយស្របច្បាប់ តាមរយៈ៖ (a) ការបន្តកម្មវិធីប្រើប្រាស់កញ្ឆាក្នុងគោលបំណងវេជ្ជសាស្ត្រ (b) ការធានាថាការកាន់កាប់ធម្មតានូវកញ្ឆាក្នុងទម្ងន់ 1 អោនស៍ ឬតិចជាងនេះ ដោយបុគ្គលអាយុចាប់ពី 21 ឆ្នាំឡើងទៅ មិនត្រូវរងពិន័យរដ្ឋប្បវេណី ឬព្រហ្មទណ្ឌឡើយ ហើយការកាន់កាប់កញ្ឆាលើសពី 1 អោនស៍ ដល់បរិមាណមិនលើសពី 2 អោនស៍ ត្រូវផ្តន្ទាទោសត្រឹមតែការផាកពិន័យរដ្ឋប្បវេណីប៉ុណ្ណោះ និង (c) ការលុបចោលជំពូក 94G និង 64N នៃច្បាប់ទូទៅ ដែលគ្រប់គ្រងលើការកាន់កាប់ ការប្រើប្រាស់ ការចែកចាយ ការដាំដុះ និងការប្រមូលពន្ធលើកញ្ឆាដែលមិនមានវេជ្ជបញ្ជា។ តាមលទ្ធភាពដែលអាចធ្វើបាន លក្ខខណ្ឌរបស់ច្បាប់នេះត្រូវតែបកស្រាយស្របតាមគោលបំណងនិងឆន្ទៈដែលមានចែងក្នុងមាត្រានេះ។

មាត្រា 2៖ ច្បាប់នេះអាចហៅថាជា “ច្បាប់ស្តីពីការស្តារឡើងវិញនូវគោលនយោបាយកញ្ឆាសមស្រប។”

មាត្រា 3៖ ជំពូក 64N នៃច្បាប់ទូទៅ ត្រូវបានលុបចោលតាមរយៈច្បាប់នេះ។

មាត្រា 4៖ ជំពូក 94C នៃច្បាប់ទូទៅ ដូចមានចែងក្នុងការបោះពុម្ពផ្សាយឆ្នាំ 2024 ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលមាត្រា 32L និងជំនួសមកវិញនូវមាត្រាដូចខាងក្រោម៖

មាត្រា 32L៖ ការកាន់កាប់កញ្ឆា ការផាកពិន័យរដ្ឋប្បវេណី និងការរឹបអូស រួមទាំងការហាមឃាត់លើទណ្ឌកម្ម ឬការដកសិទ្ធិផ្សេងៗ

(a) ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសផ្សេងទៀតណាមួយផ្ទុយពីនេះក៏ដោយ លើកលែងតែមានចែងផ្សេងទៀតក្នុងជំពូកនេះ ពុំនោះទេ បុគ្គលអាយុចាប់ពី 21 ឆ្នាំឡើងទៅ មិនត្រូវបានចាប់ខ្លួន កាត់ទោស ពិន័យ ទទួលទណ្ឌកម្ម ឬដកហូតសិទ្ធិក្រោមច្បាប់នៃរដ្ឋម៉ាសាឈូសិតដោយប្រការណាមួយ ឬបដិសេធសិទ្ធិឬឯកសិទ្ធិណាមួយឡើយ ហើយមិនត្រូវទទួលរងនូវការរឹបអូស ឬដកហូតយកទ្រព្យសម្បត្តិសម្រាប់៖

(1) ការកាន់កាប់កញ្ឆាទម្ងន់ 1 អោនស៍ ឬតិចជាងនេះ លើកលែងតែចំពោះកញ្ឆាក្នុងទម្រង់ជាសារធាតុចម្រាញ់ដែលមិនលើសពី 5 ក្រាម ឬ

(2) ការផ្តល់ឱ្យ ឬការផ្ទេរកញ្ឆាផ្សេងទៀតដោយមិនយកកម្រៃក្នុងទម្ងន់រហូតដល់ 1 អោនស៍ លើកលែងចំពោះកញ្ឆាក្នុងទម្រង់ជាសារធាតុចម្រាញ់ដែលមិនលើសពី 5 ក្រាម ទៅឱ្យបុគ្គលអាយុចាប់ពី 21 ឆ្នាំឡើងទៅ ដរាបណាការផ្ទេរនោះមិនត្រូវបានផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយជាសាធារណៈ។

(b) ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយផ្ទុយពីនេះក៏ដោយ ការកាន់កាប់កញ្ឆាទម្ងន់ចន្លោះលើសពី 1 អោនស៍ រហូតដល់ 2 អោនស៍ ឬតិចជាងនេះ សម្រាប់អ្នកប្រព្រឹត្តល្មើសអាយុចាប់ពី 21 ឆ្នាំឡើងទៅ ត្រូវចាត់ទុកត្រឹមតែជាបទល្មើសរដ្ឋប្បវេណីប៉ុណ្ណោះ ដោយតម្រូវឱ្យអ្នកប្រព្រឹត្តល្មើសទទួលពិន័យរដ្ឋប្បវេណីចំនួនមួយរយដុល្លារ និងរឹបអូសកញ្ឆានោះ ប៉ុន្តែមិនត្រូវរងការផ្តន្ទាទោស ឬការដកសិទ្ធិផ្នែកព្រហ្មទណ្ឌ ឬផ្នែករដ្ឋប្បវេណីទម្រង់ផ្សេងទៀតឡើយ។

(c) ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយផ្ទុយពីនេះក៏ដោយ ការកាន់កាប់កញ្ឆាទម្ងន់ 2 អោនស៍ ឬតិចជាងនេះ សម្រាប់អ្នកប្រព្រឹត្តល្មើសអាយុក្រោម 21 ឆ្នាំ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិស្តីពីការរឹបអូស និងការផាកពិន័យរដ្ឋប្បវេណីដូចគ្នានឹងកថាខណ្ឌ (b) ដែរ ក្នុងលក្ខខណ្ឌដែលបុគ្គលនោះឆ្លងកាត់កម្មវិធីយល់ដឹងអំពីគ្រឿងញៀន ស្របតាមលក្ខណវិនិច្ឆ័យមានចែងក្នុងមាត្រា 32M នៃជំពូកនេះ។ មាតាបិតា ឬអាណាព្យាបាលស្របច្បាប់របស់អ្នកប្រព្រឹត្តល្មើសណាម្នាក់ដែលមានអាយុក្រោម 18 ឆ្នាំ ត្រូវតែទទួលបានការជូនដំណឹងស្របតាម មាត្រា 32N នៃជំពូកនេះ អំពីបទល្មើស និងលទ្ធភាពទទួលបានកម្មវិធីយល់ដឹងអំពីគ្រឿងញៀន ក៏ដូចជាជម្រើសសេវាបម្រើសហគមន៍។ ប្រសិនបើអ្នកប្រព្រឹត្តល្មើសអាយុក្រោម 18 ឆ្នាំ មិនបានឆ្លងកាត់កម្មវិធីយល់ដឹងអំពីគ្រឿងញៀន និងសេវាបម្រើសហគមន៍ដែលចាំបាច់ត្រូវបំពេញក្នុងរយៈពេល 1 ឆ្នាំគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើសទេនោះ ការផាកពិន័យរដ្ឋប្បវេណីអាចនឹងត្រូវដំឡើងរហូតដល់មួយពាន់ដុល្លារ អនុលោមតាមមាត្រា 32N នៃជំពូកនេះ ហើយអ្នកប្រព្រឹត្តល្មើស រួមទាំងមាតាបិតារបស់ខ្លួន ត្រូវទទួលខុសត្រូវរួមគ្នា និងដោយឡែកពីគ្នាក្នុងការបង់ចំនួនទឹកប្រាក់នោះ។

(d) លើកលែងតែមានការចែងជាក់លាក់នៅក្នុងជំពូកនេះ មាត្រា 24I នៃជំពូក 90 និងជំពូក 387 នៃច្បាប់ឆ្នាំ 2008 ពុំនោះទេ ទាំងរដ្ឋម៉ាសាឈូសិត និងមូលដ្ឋានរដ្ឋបាលដែនដីក្រោមឱវាទណាមួយ ឬទីភ្នាក់ងារ អាជ្ញាធរ ឬស្ថាប័នពាក់ព័ន្ធរៀងៗខ្លួន មិនអាចដាក់ពិន័យ ទណ្ឌកម្ម ឬដកសិទ្ធិក្នុងទម្រង់ណាមួយផ្សេងទៀតលើអ្នកប្រព្រឹត្តល្មើសចំពោះការកាន់កាប់កញ្ឆាទម្ងន់ 2 អោនស៍ ឬតិចជាងនេះឡើយ។ ឧទាហរណ៍ជាអាទិ៍ ការកាន់កាប់កញ្ឆាទម្ងន់ 2 អោនស៍ ឬតិចជាងនេះ មិនអាចយកជាមូលដ្ឋានដើម្បីបដិសេធមិនផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់សិស្ស លំនៅឋានសាធារណៈ ឬជំនួយហិរញ្ញវត្ថុសាធារណៈទម្រង់ណាមួយ រួមទាំងអត្ថប្រយោជន៍ពេលអត់ការងារធ្វើ ដល់អ្នកប្រព្រឹត្តល្មើស ឬបដិសេធសិទ្ធិបើកបរយានយន្ត ឬដកសិទ្ធិអ្នកប្រព្រឹត្តល្មើសពីការធ្វើជាឪពុកម្តាយចិញ្ចឹម ឬឪពុកម្តាយសុំកូនឡើយ។ ព័ត៌មានពាក់ព័ន្ធនឹងបទល្មើសនៃការកាន់កាប់កញ្ឆាទម្ងន់ 2 អោនស៍ ឬតិចជាងនេះ មិនត្រូវចាត់ទុកជា “កំណត់ត្រាព័ត៌មានអ្នកប្រព្រឹត្តល្មើសព្រហ្មទណ្ឌ” “ព័ត៌មានវាយតម្លៃ” ឬ “ព័ត៌មានស៊ើបការណ៍” ដូចមានកំណត់និយមន័យពាក្យទាំងនោះក្នុងមាត្រា 167 នៃជំពូក 6 នៃច្បាប់ទូទៅឡើយ ហើយមិនត្រូវកត់ត្រាទុកក្នុងប្រព័ន្ធកំណត់ត្រាព័ត៌មានអ្នកប្រព្រឹត្តល្មើសព្រហ្មទណ្ឌ (Criminal Offender Record Information) ឡើយ។

(e) តាមន័យប្រើប្រាស់ក្នុងបញ្ញត្តិនេះ ឃ្លា “ការកាន់កាប់កញ្ឆាទម្ងន់ 2 អោនស៍ ឬតិចជាងនេះ” រួមបញ្ចូលទាំងការកាន់កាប់កញ្ឆា ឬសារធាតុ Tetrahydrocannabinol ទម្ងន់ 2 អោនស៍ ឬតិចជាងនេះ និងការមានសារធាតុ Cannabinoids ឬផលបំប្លែងសារធាតុ Cannabinoid នៅក្នុងទឹកនោម ឈាម ទឹកមាត់ ញើស សក់ ក្រចកដៃ ក្រចកជើង ឬជាលិកា ឬវត្ថុរាវផ្សេងទៀតនៃរាងកាយមនុស្ស។ គ្មានខ្លឹមសារណាមួយក្នុងបញ្ញត្តិនេះ ត្រូវបកស្រាយថាជាការលុបចោល ឬកែប្រែច្បាប់ ដីកា ឬបទបញ្ជាផ្ទៃក្នុង បទប្បញ្ញត្តិ ការអនុវត្តការងារបុគ្គលិក ឬគោលនយោបាយដែលមានស្រាប់ ពាក់ព័ន្ធនឹងការបើកបរយានយន្ត ឬសកម្មភាពផ្សេងទៀតដែលធ្វើឡើងក្រោមឥទ្ធិពលកញ្ឆា ឬសារធាតុ Tetrahydrocannabinol ច្បាប់ពាក់ព័ន្ធនឹងការកាន់កាប់ដោយខុសច្បាប់នូវទម្រង់កញ្ឆាមានវេជ្ជបញ្ជា ឬសារធាតុ Tetrahydrocannabinol ដូចជាថ្នាំ Marinol ការកាន់កាប់កញ្ឆា ឬសារធាតុ Tetrahydrocannabinol លើសពី 2 អោនស៍ ឬការលក់ ការផលិត ឬការជួញដូរកញ្ឆា ឬសារធាតុ Tetrahydrocannabinol នោះឡើយ។ គ្មានខ្លឹមសារណាមួយក្នុងបញ្ញត្តិនេះ ហាមឃាត់មូលដ្ឋានរដ្ឋបាលដែនដីក្រោមឱវាទណាមួយនៃរដ្ឋម៉ាសាឈូសិតក្នុងការអនុម័តដីកា ឬបទបញ្ជាផ្ទៃក្នុង នៅក្នុងការកំណត់ ឬហាមឃាត់ការប្រើប្រាស់កញ្ឆា ឬសារធាតុ Tetrahydrocannabinol នៅទីសាធារណៈ និងដាក់ពិន័យបន្ថែមសម្រាប់ការប្រើប្រាស់កញ្ឆា ឬសារធាតុ Tetrahydrocannabinol ជាសាធារណៈនោះឡើយ។

(f) ការប្រើប្រាស់កញ្ឆា មិនអាចដកសិទ្ធិបុគ្គលម្នាក់ពីនីតិវិធីវេជ្ជសាស្ត្រ ឬការព្យាបាលដែលចាំបាច់ណាមួយឡើយ រួមទាំងការប្តូរសរីរាង្គ និងជាលិកាផងដែរ។

(g) មាត្រានេះមិនអនុវត្តចំពោះការលក់ ការចែកចាយ ឬការផ្គត់ផ្គង់កញ្ឆាប្រើប្រាស់

## សំណួរទី 8៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង (ត)

សម្រាប់វិស័យវេជ្ជសាស្ត្រ អនុលោមតាមជំពូក 94I ឡើយ។

(h) សម្រាប់គោលបំណងនៃមាត្រានេះ "សារធាតុចម្រាញ់ពីកញ្ឆា" មានន័យថា សារធាតុទទួលបានពីកញ្ឆា ដែលផលិតឡើងដោយការចម្រាញ់ ឬការបង្កាប់សារធាតុ Cannabinoids ពីរុក្ខជាតិកញ្ឆា តាមរយៈការប្រើប្រាស់៖ (i) សារធាតុរំលាយ (ii) កាបូនឌីអុកស៊ីត ឬ (iii) កម្ដៅ ស្បែចម្រោះ ម៉ាស៊ីនសង្កត់ ឬការបិតចម្រាញ់។

មាត្រា 5៖ មាត្រា 32M នៃជំពូក 94C ដូចមានចែង ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលរាល់ការយោងទៅលើពាក្យ "ដប់ប្រាំបី" នៅក្នុងមាត្រានោះ ហើយជំនួសមកវិញនូវពាក្យ៖ - 21

មាត្រា 6៖ ជំពូក 94G នៃច្បាប់ទូទៅ ត្រូវបានលុបចោលតាមរយៈច្បាប់នេះ។

មាត្រា 7៖ ជំពូក 94I នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយការដាក់បញ្ចូលបន្ទាប់ពីមាត្រា 1 នូវមាត្រាដូចខាងក្រោម៖-

មាត្រា 1A៖ គណៈកម្មការគ្រប់គ្រងកញ្ឆា៖

(a) គណៈកម្មការត្រូវមានរាល់អំណាចដែលចាំបាច់ ឬផ្ដល់ភាពងាយស្រួល ដើម្បីអនុវត្ត និងសម្រេចបាននូវគោលបំណងរបស់ខ្លួន រួមមានអំណាចជាអាទិ៍ក្នុងការ៖

(i) តែងតាំងមន្ត្រី និងជួលបុគ្គលិក។

(ii) បង្កើត និងកែប្រែផែនការរៀបចំស្ថាប័នដែលខ្លួនយល់ថាសមស្រប។

(iii) អនុវត្តរាល់លិខិតូបករណ៍គតិយុត្តដែលចាំបាច់ ឬផ្ដល់ភាពងាយស្រួល សម្រាប់សម្រេចបាននូវគោលបំណងនៃជំពូកនេះ។

(iv) ចុះកិច្ចព្រមព្រៀង ឬធ្វើប្រតិបត្តិការផ្សេងទៀតជាមួយបុគ្គល រួមមានជាអាទិ៍ អង្គភាពសាធារណៈ ឬអាជ្ញាធរ ឬស្ថាប័នរដ្ឋាភិបាលផ្សេងទៀត ដែលពាក់ព័ន្ធនឹងអំណាច និងភារកិច្ចរបស់ខ្លួនក្រោមជំពូកនេះ។

(v) តំណាងឱ្យខ្លួនឯង នៅចំពោះមុខក្រុមប្រឹក្សា គណៈកម្មការ នាយកដ្ឋាន ឬទីភ្នាក់ងារផ្សេងទៀតនៃរដ្ឋបាលក្រុង រដ្ឋ ឬរដ្ឋាភិបាលសហព័ន្ធ។

(vi) ដាក់ពាក្យសុំ និងទទួលយកជំនួយឧបត្ថម្ភ មូលនិធិជំនួយ កម្ចី ប្រាក់បុរេប្រទាន និងវិភាគទានជាប្រាក់ ទ្រព្យសម្បត្តិ កម្លាំងពលកម្ម ឬវត្ថុមានតម្លៃផ្សេងទៀតពីប្រភពណាមួយ ដើម្បីរក្សាទុក ប្រើប្រាស់ និងចែកចាយសម្រាប់គោលបំណងរបស់ខ្លួន។

(vii) ផ្ដល់ និងបង់ប្រាក់សម្រាប់សេវាប្រឹក្សាយោបល់ និងជំនួយបច្ចេកទេស ស្របតាមការវិនិច្ឆ័យចាំបាច់របស់ខ្លួន ដើម្បីអនុវត្តជំពូកនេះ និងកំណត់កម្រិតប្រាក់កម្រៃសម្រាប់បុគ្គលដែលផ្ដល់សេវាឬជំនួយទាំងនោះ។

(viii) រៀបចំ បោះពុម្ពផ្សាយ និងចែកចាយការសិក្សាស្រាវជ្រាវ របាយការណ៍ ព្រឹត្តិបត្រ និងឯកសារផ្សេងទៀតដែលគណៈកម្មការយល់ថាសមស្រប ដោយគិតថ្លៃ ឬមិនគិតថ្លៃ តាមការកំណត់របស់គណៈកម្មការ។

(ix) តម្រូវឱ្យអ្នកដាក់ពាក្យសុំអាជ្ញាបណ្ណក្រោមជំពូកនេះ ដាក់ពាក្យសុំអាជ្ញាបណ្ណនោះ និងអនុម័ត ឬបដិសេធរាល់ពាក្យសុំ ឬប្រតិបត្តិការ ព្រឹត្តិការណ៍ និងដំណើរការផ្សេងទៀត ដូចមានចែងក្នុងជំពូកនេះ។

(x) កំណត់ថាអ្នកដាក់ពាក្យសុំរូបណាដែលគួរទទួលបានអាជ្ញាបណ្ណ។

(xi) បដិសេធពាក្យសុំ ឬកំណត់កម្រិត ដាក់លក្ខខណ្ឌ រឹតត្បិត ដកហូត ឬព្យួរអាជ្ញាបណ្ណ។

(xii) បង្កើតដំណើរការចុះបញ្ជី ដោយផ្អែកលើលទ្ធផលនៃភាពសមស្រប ឬការអនុម័តអាជ្ញាបណ្ណ។

(xiii) ផាកពិន័យបុគ្គលដែលបានទទួលអាជ្ញាបណ្ណ បានចុះបញ្ជី រកឃើញថាមានភាពសមស្រប ឬទទួលបានការអនុម័តផ្ដល់អាជ្ញាបណ្ណ ចំពោះបុព្វហេតុណាមួយដែលគណៈកម្មការយល់ឃើញថាត្រឹមត្រូវ។

(xiv) ប្រមូលអង្គហេតុ និងព័ត៌មានពាក់ព័ន្ធនឹងភារកិច្ចរបស់គណៈកម្មការក្នុងការចេញ ព្យួរ ឬដកហូតអាជ្ញាបណ្ណ ការចុះបញ្ជី លទ្ធផលនៃភាពសមស្រប ឬការអនុម័តអាជ្ញាបណ្ណសម្រាប់៖ (A) ការរំលោភលើជំពូកនេះ ឬបទប្បញ្ញត្តិណាមួយដែលបានអនុម័តដោយគណៈកម្មការ (B) ការរំលោភដោយចេតនាលើសេចក្ដីបង្គាប់របស់គណៈកម្មការ ជូនចំពោះអ្នកទទួលអាជ្ញាបណ្ណ ឬបុគ្គលដែលតម្រូវឱ្យចុះបញ្ជី (C) ការផ្ដន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ ឬ (D) បទល្មើសផ្សេងទៀតដែលនឹងដកសិទ្ធិអ្នកទទួលអាជ្ញាបណ្ណនោះពីការកាន់អាជ្ញាបណ្ណ។

(xv) ធ្វើការស៊ើបអង្កេតលើលក្ខណសម្បត្តិនៃអ្នកស្នើសុំការងារទាំងអស់នៅគណៈកម្មការ និងអ្នកស្នើសុំអាជ្ញាបណ្ណទាំងអស់។

(xvi) ទទួលពីប៉ូលិសរដ្ឋ នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ឬទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀត រួមមានជាអាទិ៍ ការិយាល័យស៊ើបអង្កេតសហព័ន្ធ (Federal Bureau of Investigation) និងសេវាចំណូលផ្ទៃក្នុង (Internal Revenue Service) នូវកំណត់ត្រា ព័ត៌មានអ្នកល្មើសច្បាប់ព្រហ្មទណ្ឌ ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតព្រហ្មទណ្ឌ និងប្រវត្តិសារតារតាមតម្រូវការចាំបាច់ សម្រាប់គោលបំណងវាយតម្លៃអ្នកទទួលអាជ្ញាបណ្ណ អ្នកដាក់ពាក្យសុំអាជ្ញាបណ្ណ និងទីភ្នាក់ងារមន្ទីរពិសោធន៍។

(xvii) មានវត្តមានតាមរយៈមន្ត្រីអធិការកិច្ច និងទីភ្នាក់ងាររបស់ខ្លួន ពេលណាដែលចាំបាច់ នៅមជ្ឈមណ្ឌលព្យាបាលវេជ្ជសាស្ត្រដោយប្រើកញ្ឆាណាមួយ សម្រាប់គោលបំណងអនុវត្តទំនួលខុសត្រូវត្រួតពិនិត្យរបស់ខ្លួន។

(xviii) ពិនិត្យ និងមានសិទ្ធិចូលប្រើប្រាស់រាល់ឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់ក្នុងមជ្ឈមណ្ឌលព្យាបាលវេជ្ជសាស្ត្រដោយប្រើកញ្ឆា។

(xix) រឹបអូស និងដកហូតចេញពីទីតាំងមជ្ឈមណ្ឌលព្យាបាលវេជ្ជសាស្ត្រដោយប្រើកញ្ឆា និងឃាត់ទុកនូវកញ្ឆា ឧបករណ៍ សម្ភារៈផ្គត់ផ្គង់ ឯកសារ និងកំណត់ត្រាណាមួយដែលទទួលបាន ឬកាន់កាប់ដោយរំលោភលើជំពូកនេះ សម្រាប់គោលបំណងពិនិត្យនិងធ្វើអធិការកិច្ច។

(xx) ករណីមានមូលហេតុច្បាស់លាស់ អាចទាមទារសិទ្ធិចូលប្រើប្រាស់ និងពិនិត្យរាល់ឯកសារ សៀវភៅ និងកំណត់ត្រាដែលគួជិតស្និទ្ធរបស់អ្នកទទួលអាជ្ញាបណ្ណ ដែលគណៈកម្មការសង្ស័យថាមានពាក់ព័ន្ធនឹងការផ្ដល់ហិរញ្ញប្បទាន ការដំណើរការ ឬការគ្រប់គ្រងរបស់អ្នកទទួលអាជ្ញាបណ្ណ។ ទោះយ៉ាងណាក៏ដោយ ការពិនិត្យ ការធ្វើអធិការកិច្ច ការថតចម្លង និងការធ្វើសវនកម្ម អាចប្រព្រឹត្តទៅបាននៅទីតាំងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬនៅកន្លែងផ្សេងទៀតតាមដែលអាចធ្វើទៅបាន និងក្រោមវត្តមានរបស់ភាគីពាក់ព័ន្ធ ឬទីភ្នាក់ងារខ្លួន។

(xxi) តម្រូវឱ្យរក្សាទុកសៀវភៅ និងកំណត់ត្រាហិរញ្ញវត្ថុ ឬកំណត់ត្រាផ្សេងទៀត ឬរបាយការណ៍របស់អ្នកទទួលអាជ្ញាបណ្ណ ជាទម្រង់ដែលគណៈកម្មការយល់ថាសមរម្យ។

(xxii) កំណត់ថ្លៃសេវា និងប្រាក់ពិន័យ ដូចបានអនុញ្ញាតដោយជំពូកនេះ និងការផាកពិន័យ ក៏ដូចជាដាក់ទណ្ឌកម្មសម្រាប់ការរំលោភលើជំពូកនេះ ឬបទប្បញ្ញត្តិណាមួយដែលបានប្រកាសឱ្យប្រើដោយគណៈកម្មការ។

(xxiii) ប្រមូលថ្លៃសេវាក្រោមជំពូកនេះ។

(xxiv) រៀបចំដំណើរការកាត់សេចក្ដី និងប្រកាសឱ្យប្រើបទប្បញ្ញត្តិស្របតាមជំពូក 30A។

## សំណួរទី 8៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើឡើង (ត)

(xxv) បញ្ជូនសំណុំរឿងសម្រាប់ការចោទប្រកាន់តាមផ្លូវព្រហ្មទណ្ឌ ទៅកាន់អាជ្ញាធរសហព័ន្ធ រដ្ឋ ឬមូលដ្ឋានដែលមានសមត្ថកិច្ច។

(xxvi) គ្រប់គ្រងរក្សាគេហទំព័រអ៊ីនធឺណិតផ្លូវការសម្រាប់គណៈកម្មការ។

(xxvii) តាមដានរាល់សកម្មភាពរបស់សហព័ន្ធពាក់ព័ន្ធនឹងកញ្ឆា និង

(xxviii) អនុម័ត ធ្វើវិសោធនកម្ម ឬលុបចោលបទប្បញ្ញត្តិសម្រាប់ការដាក់ឱ្យអនុវត្ត ការគ្រប់គ្រង និងការអនុវត្តច្បាប់នៃជំពូកនេះ។

(b) គណៈកម្មការត្រូវអនុលោមតាមជំពូក 30A ក្នុងការអនុម័តបទប្បញ្ញត្តិដែលស្របនឹងជំពូកនេះ សម្រាប់ការគ្រប់គ្រង ការបញ្ជាក់ និងការអនុវត្តច្បាប់ដែលគ្រប់គ្រង និងផ្តល់អាជ្ញាបណ្ណដល់កម្មវិធីប្រើប្រាស់កញ្ឆាសម្រាប់ផ្នែកវេជ្ជសាស្ត្រ។ បទប្បញ្ញត្តិទាំងនោះត្រូវរួមបញ្ចូល៖ (i) ការផ្តល់អាជ្ញាបណ្ណ និងការត្រួតពិនិត្យមន្ទីរពិសោធន៍ធ្វើតេស្តឯករាជ្យ និងបង្កើតពិធីសារធ្វើតេស្តសម្រាប់ការយកគំរូ ការធ្វើតេស្ត និងការវិភាគលើកញ្ឆា កញ្ឆាសម្រេច និងផលិតផលកញ្ឆាប្រើប្រាស់ផ្នែកវេជ្ជសាស្ត្រដោយមានការពិគ្រោះយោបល់ជាមួយក្រសួងសុខភាពសាធារណៈ និងក្រសួងធនធានកសិកម្ម។

(c) គណៈកម្មការត្រូវគ្រប់គ្រងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណនៅក្នុងជំពូកនេះ។

(d) ក្នុងឆ្នាំសារពើពន្ធនីមួយៗ គណៈកម្មការត្រូវដាក់ផែនការហិរញ្ញវត្ថុប្រចាំឆ្នាំជូនទៅរដ្ឋមន្ត្រីរដ្ឋបាលនិងហិរញ្ញវត្ថុ និងធ្វើបច្ចុប្បន្នភាពលើផែនការនោះ ស្របតាមការណែនាំដែលចេញដោយរដ្ឋមន្ត្រីខាងលើ។

(e) គណៈកម្មការត្រូវបើកសវនាការជាសាធារណៈមុនការអនុម័ត ការធ្វើវិសោធនកម្ម ឬការលុបចោលបទប្បញ្ញត្តិណាមួយ។ ដំណើរការកាត់សេចក្តី ត្រូវធ្វើឡើងដោយអនុលោមតាមជំពូក 30A នៃច្បាប់ទូទៅ និងតាមវិធានស្តង់ដានៃនីតិវិធីកាត់សេចក្តីដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា 9 ជំពូក 30A នៃច្បាប់ទូទៅ។

(f) គណៈកម្មការត្រូវដាក់របាយការណ៍លម្អិត និងពេញលេញប្រចាំឆ្នាំអំពីសកម្មភាពរបស់គណៈកម្មការ រួមទាំងការពិនិត្យឡើងវិញលើការដាក់ឱ្យអនុវត្ត និងការអនុវត្តច្បាប់នៃជំពូកនេះ ព្រមទាំងរចនាសម្ព័ន្ធអភិបាលកិច្ចដែលបានបង្កើតឡើងនៅក្នុងជំពូកនេះ មិនឱ្យលើសពី 90 ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ ជូនទៅអភិបាលរដ្ឋ អគ្គរដ្ឋអាជ្ញា អគ្គហេរញ្ញិកនិងបេឡា លេខាធិការនៃរដ្ឋសភានិងព្រឹទ្ធសភា ប្រធានគណៈកម្មាធិការចម្រុះស្តីពីគោលនយោបាយកញ្ឆា និងប្រធានគណៈកម្មាធិការរដ្ឋសភានិងព្រឹទ្ធសភាស្តីពីថវិកានិងហិរញ្ញវត្ថុ។

(g) គណៈកម្មការ និងក្រសួងសុខភាពសាធារណៈ ត្រូវសហការគ្នាដើម្បីធានាថាការផលិត និងការចែកចាយកញ្ឆាប្រើប្រាស់ផ្នែកវេជ្ជសាស្ត្រ ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៅក្នុងរដ្ឋម៉ាសាឈូសិត ដើម្បីជំរុញគោលបំណងនៃច្បាប់នេះ។

(h) គណៈកម្មការត្រូវប្រកាសឱ្យប្រើគោលការណ៍ណែនាំប្រឹក្សា និងឧត្តមានុវត្តន៍ស្តីពីការដាំដុះកញ្ឆានៅក្នុងលំនៅឋានចម្បងរបស់បុគ្គលម្នាក់ អនុលោមតាមមាត្រា 2 នៃជំពូកនេះ។

មាត្រា 8៖ ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយផ្ទុយពីនេះក៏ដោយ គណៈកម្មការគ្រប់គ្រងកញ្ឆាត្រូវចាត់វិធានការដើម្បីពន្លឿន និងសម្រួលដំណើរការសម្រាប់អ្នកទទួលអាជ្ញាបណ្ណក្រោមជំពូក 94G រួមទាំងគ្រឹះស្ថានផលិតកញ្ឆា ក្នុងការដាក់ពាក្យសុំ និងទទួលអាជ្ញាបណ្ណដើម្បីចូលរួមក្នុងកម្មវិធីប្រើប្រាស់កញ្ឆាផ្នែកវេជ្ជសាស្ត្រដែលត្រូវបានគ្រប់គ្រងអនុលោមតាមជំពូក 94I និងសម្រាប់អ្នកទទួលអាជ្ញាបណ្ណក្រោមជំពូក 94G ក្នុងការលក់ ការផ្គត់ផ្គង់កញ្ឆាដែលមានស្រាប់ ទៅឱ្យមជ្ឈមណ្ឌលព្យាបាលវេជ្ជសាស្ត្រដោយប្រើកញ្ឆា ដែលទទួលបានអាជ្ញាបណ្ណអនុលោមតាមជំពូក 94I។

មាត្រា 9៖ សុពលភាពដោយអន្លើ

បទប្បញ្ញត្តិនៃច្បាប់នេះ អាចមានសុពលភាពដោយអន្លើ ហើយប្រសិនបើមានឃ្លា ប្រយោគ កថាខណ្ឌ ឬមាត្រាណាមួយនៃបញ្ញត្តិនេះ ឬការអនុវត្តបញ្ញត្តិនេះ ត្រូវបានកាត់សេចក្តីដោយតុលាការមានសមត្ថកិច្ចណាមួយថាជានិរាករណ៍ សេចក្តីសម្រេចនោះមិនត្រូវជះឥទ្ធិពល ប៉ះពាល់ ឬធ្វើឱ្យមានអសុពលភាពដល់ផ្នែកដែលនៅសល់នោះឡើយ ប៉ុន្តែត្រូវកម្រិតឥទ្ធិពលត្រឹមតែឃ្លា ប្រយោគ កថាខណ្ឌ មាត្រា ឬការអនុវត្តច្បាប់ដែលត្រូវបានកាត់សេចក្តីជានិរាករណ៍នោះតែប៉ុណ្ណោះ។

មាត្រា 10៖ កាលបរិច្ឆេទចូលជាធរមាន

ច្បាប់នេះត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2028។

# សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់

ច្បាប់ស្តីពីការធ្វើទំនើបកម្មច្បាប់គ្រប់គ្រងអាវុធ

បានអនុម័តជាច្បាប់ដោយព្រឹទ្ធសភានិងរដ្ឋសភាក្នុងសម័យប្រជុំនៃសភានីតិបញ្ញត្តិរដ្ឋ (General Court) និងដោយអំណាចនៃស្ថាប័នទាំងនេះ ដូចតទៅ៖

មាត្រា 1 មាត្រា 172M ក្នុងជំពូក 6 នៃច្បាប់ទូទៅ (General Laws) ដែលបានចែងនៅក្នុងការបោះពុម្ពផ្សាយជាផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្មនៅក្នុងបន្ទាត់ទី 6 និងទី 7 ដោយលុបចោលពាក្យថា៖ "និងការប៉ះពាល់អាវុធ កាំភ្លើងគ្រាប់ប្រាយ ឬកាំភ្លើងវែងគ្រប់ប្រភេទដោយគ្មានការត្រួតពិនិត្យ" ហើយជំនួសមកវិញនូវពាក្យដូចតទៅនេះ៖ "ការប៉ះពាល់អាវុធ" ដូចបានកំណត់នៅក្នុងមាត្រា 121 នៃជំពូក 140 ដែលបានពោល។

មាត្រា 2 មាត្រា 18¾ ក្នុងជំពូក 6A នៃច្បាប់ទូទៅ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មក្នុងបន្ទាត់ទី 88 និងទី 89 ដោយលុបចោលពាក្យថា៖ "និង (v) ប្រសិទ្ធភាពនៃមាត្រា 128B ក្នុងជំពូក 140" ហើយជំនួសមកវិញនូវពាក្យដូចតទៅនេះ៖ "(v) ប្រសិទ្ធភាពនៃមាត្រា 128B ក្នុងជំពូក 140 និង (vi) ការវិភាគថាតើលេខអាជ្ញាបណ្ណដែលបានប្រើប្រាស់សម្រាប់ការទិញ ឬការផ្ទេរកាំភ្លើងដែលបានប្រើប្រាស់ក្នុងបទល្មើស ឬការប៉ុនប៉ងធ្វើអត្តឃាត ឬការធ្វើអត្តឃាតបានសម្រេច មានពាក់ព័ន្ធនឹងការទិញ ឬការផ្ទេរកាំភ្លើងផ្សេងទៀតណាមួយនៅក្នុងរដ្ឋម៉ាសាឈូសិត ឬនៅក្នុងយុត្តាធិការផ្សេងទៀតណាមួយក្នុងអំឡុងពេល 12 ខែ មុនពេល ឬក្រោយពេលលក់កាំភ្លើងដែលបានដកហូតមកវិញនោះ ព្រមទាំងចំនួនសរុបនៃកាំភ្លើងបែបនោះដែលបានទិញនិងផ្ទេរដោយម្ចាស់អាជ្ញាបណ្ណនោះ ហើយថាតើកាំភ្លើងណាមួយក្នុងចំណោមនោះ ត្រូវបានយកទៅប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសដែរឬទេ។"

មាត្រា 3 មាត្រា 5J ក្នុងជំពូក 18 នៃច្បាប់ទូទៅ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មក្នុងបន្ទាត់ទី 10 និងទី 11 ទាំងស្រុង ដោយការលុបចោលពាក្យថា៖ "និងអាជីវករលក់គ្រាប់រំសេវដែលទទួលបានអាជ្ញាបណ្ណដោយអនុលោមតាមមាត្រា 122B ក្នុងជំពូក 140 ដូចដែលបានពោល"។

មាត្រា 4 មាត្រា 2LLL ក្នុងជំពូកជំពូក 29 នៃច្បាប់ទូទៅ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មក្នុងបន្ទាត់ទី 8 និងទី 9 ដោយលុបចោលពាក្យថា៖ "កម្រៃសេវាដែលបានកំណត់ក្រោមមាត្រា 122, 122B, 129B, 131, 131A, 131F, និង 131H" ហើយជំនួសមកវិញនូវពាក្យដូចតទៅនេះ៖ "កម្រៃសេវាដែលបានកំណត់ក្រោមមាត្រា 121F, 131A និង 131F"។

មាត្រា 5 ជំពូក 29 ដែលបានពោល ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយការបញ្ចូលទៅខាងក្រោយមាត្រា 2DDDDDD នូវមាត្រាដូចតទៅនេះ៖-

មាត្រា 2EEEEEE ដើម្បីលើកកម្ពស់សេវាកម្មបង្ការ និងអន្តរាគមន៍លើអំពើហិង្សា ត្រូវបង្កើត និងកត់ត្រាទុកក្នុងបញ្ជីគណនេយ្យរបស់រដ្ឋម៉ាសាឈូសិត នូវមូលនិធិដាច់ដោយឡែកមួយ ហៅថា មូលនិធិបរធនបាលកិច្ចវិនិយោគឡើងវិញរបស់សហព័ន្ធសម្រាប់ការបង្ការអំពើហិង្សា (Violence Prevention Federal Reinvestment Trust Fund)។ ត្រូវបញ្ចូលទៅក្នុងឥណទានមូលនិធិនេះនូវប្រាក់ចំណូលដែលស្មើនឹងចំនួននៃការចូលរួមផ្នែកហិរញ្ញវត្ថុរបស់សហព័ន្ធដែលមូលនិធិទូទៅ (General Fund) ទទួលបានសម្រាប់ការចំណាយលើសេវាកម្មបង្ការ និងអន្តរាគមន៍លើអំពើហិង្សា ព្រមទាំងការទូទាត់សងវិញ ជំនួយឥតសំណងបុព្វលាភ អំណោយ ការប្រាក់ ឬការបរិច្ចាគផ្សេងទៀតពីប្រភពទទួលបានផ្សេងទៀត ដែលបានកំណត់ជាក់លាក់ថាត្រូវបញ្ចូលទៅក្នុងមូលនិធិនេះ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសេវាមនុស្សជាតិ គឺជាបរធនបាលនៃមូលនិធិនេះ។

ដើម្បីសម្របសម្រួលដល់ភាពខុសគ្នាផ្នែកពេលវេលារវាងការទទួលបានប្រាក់ចំណូល និងការចំណាយពាក់ព័ន្ធ មូលនិធិនេះអាចទទួលបន្ទុកចំណាយបាន ហើយអគ្គធិការហិរញ្ញវត្ថុត្រូវបញ្ជាក់ទទួលស្គាល់ចំនួនទឹកប្រាក់ទូទាត់ ដែលមិនត្រូវឱ្យលើសពីការប៉ាន់ស្មានប្រាក់ចំណូលចុងក្រោយបង្អស់ដែលបញ្ជាក់ទទួលស្គាល់ដោយប្រធាននាយកដ្ឋានសុខាភិបាលរដ្ឋម៉ាសាឈូសិត និងដែលបានរាយការណ៍ក្នុងប្រព័ន្ធគណនេយ្យរបស់រដ្ឋឡើយ។ ចំនួនទឹកប្រាក់ដែលបានបញ្ចូលទៅក្នុងមូលនិធិនេះត្រូវស្ថិតក្រោមការបែងចែកថវិកាបន្ថែមទៀត ហើយសាច់ប្រាក់នៅសេសសល់ក្នុងមូលនិធិនេះនាដំណាច់ឆ្នាំសារពើពន្ធ មិនត្រូវបង្វែរត្រឡប់ចូលទៅក្នុងមូលនិធិទូទៅវិញឡើយ ហើយត្រូវមានសម្រាប់ការចំណាយនៅក្នុងឆ្នាំសារពើពន្ធបន្ទាប់។

រដ្ឋមន្ត្រីត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំនៅត្រឹម ឬមុនថ្ងៃទី 1 ខែសីហា ជូនដល់ប្រធានគណៈកម្មាធិការថវិកានិងហិរញ្ញវត្ថុ (Ways and Means) របស់រដ្ឋសភានិងព្រឹទ្ធសភា ហើយប្រធានភាគីព្រឹទ្ធសភានិងរដ្ឋសភានៃគណៈកម្មាធិការចម្រុះទទួលបន្ទុកប្រព័ន្ធតុលាការ និងគណៈកម្មាធិការចម្រុះទទួលបន្ទុកសន្តិសុខសាធារណៈនិងសន្តិសុខមាតុភូមិ អំពីសកម្មភាពចំណូល-ចំណាយនៅក្នុងមូលនិធិបរធនបាលកិច្ចនេះ។

មាត្រា 6 មាត្រា 10B ក្នុងជំពូក 66 នៃច្បាប់ទូទៅ ដូចមានចែងនៅក្នុងការបោះពុម្ពផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្មនៅក្នុងបន្ទាត់ទី 7 និងទី 8 ដោយលុបចោលពាក្យដូចខាងក្រោម៖ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត។"

មាត្រា 7 មាត្រា 10B ក្នុងជំពូក 66 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតនៅក្នុងបន្ទាត់ទី 14 ដោយបញ្ចូលនៅខាងក្រោយពាក្យ "សំណើ" នូវពាក្យដូចតទៅ៖  "ទោះជាយ៉ាងណាក៏ដោយ គ្មានបទប្បញ្ញត្តិណាមួយក្នុងមាត្រានេះ ត្រូវហាមឃាត់ការបញ្ជូនទិន្នន័យនិងព័ត៌មានផ្សេងទៀតទៅកាន់នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ និងការប្រើប្រាស់ទិន្នន័យទាំងនោះអនុលោមតាមមាត្រា 121E នៃជំពូក 140 ឡើយ"។

មាត្រា 8 មាត្រា 26 ក្នុងជំពូក 90B នៃច្បាប់ទូទៅ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មនៅក្នុងបន្ទាត់ទី 6 និងទី 66 ដោយការលុបចោលពាក្យថា៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 9 មាត្រា 26 នៃជំពូក 90B ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតនៅក្នុងបន្ទាត់ទី 68 និងទី 69 ដោយលុបចេញនូវពាក្យ៖ "អាវុធ កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយទាំងនេះ មិនត្រូវបញ្ចូលគ្រាប់ឡើយ ហើយត្រូវស្ថិតក្នុងប្រអប់បិទជិត"  ហើយជំនួសដោយពាក្យដូចខាងក្រោម៖ "បុគ្គលនោះមានអាជ្ញាបណ្ណកាន់កាប់អាវុធចាំបាច់ ឬបណ្ណសម្គាល់អាវុធដែលចេញជូនស្របតាមមាត្រា 129B ឬ 131 នៃជំពូក 140 ហើយកាន់អាវុធនោះអនុលោមតាមមាត្រា 131C នៃជំពូក 140។" ការរំលោភបំពានណាមួយលើកថាខណ្ឌនេះ ត្រូវផ្តន្ទាទោសស្របតាមមាត្រា 131C នៃជំពូក 140។

មាត្រា 10 មាត្រា 35 ក្នុងជំពូក 123 នៃច្បាប់ទូទៅ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មក្នុងបន្ទាត់ទី 122 ដោយលុបចោលពាក្យថា៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

មាត្រា 11 មាត្រា 36A នៃជំពូក 123 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចេញនូវកថាខណ្ឌទីពីរ ហើយបញ្ចូលជំនួសដោយកថាខណ្ឌខាងក្រោម៖-

ទោះបីមានបទប្បញ្ញត្តិណាមួយក្នុងមាត្រានេះក៏ដោយ តុលាការត្រូវបញ្ជូនព័ត៌មានដែលមាននៅក្នុងកំណត់ត្រារបស់តុលាការ ទៅកាន់នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ អនុលោមតាមមាត្រា 35 និងមាត្រា 36C ហើយនាយកដ្ឋាននោះត្រូវផ្តល់ព័ត៌មានទាំងនោះទៅឱ្យ៖ (i) អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ដូចបានកំណត់ក្នុងមាត្រា 121 នៃជំពូក 140។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានដែលបានចែករំលែកក្រោមអនុប្រយោគនេះ ត្រូវជាព័ត៌មានដែលតម្រូវ ឬអនុញ្ញាតឱ្យយកមកពិចារណាស្របតាមច្បាប់រដ្ឋ ឬច្បាប់សហព័ន្ធ ដើម្បីអនុវត្តការត្រួតពិនិត្យសាវតារសម្រាប់ការលក់ ឬការផ្តល់អាជ្ញាបណ្ណអាវុធ។ (ii) ការិយាល័យស៊ើបអង្កេតសហព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានដែលបានចែករំលែកក្រោមអនុប្រយោគនេះ ត្រូវជាព័ត៌មានដែលតម្រូវ ឬអនុញ្ញាតស្របតាមច្បាប់សហព័ន្ធឱ្យបញ្ចូលក្នុងប្រព័ន្ធជាតិត្រួតពិនិត្យប្រវត្តិឧក្រិដ្ឋកម្ម (National Instant Criminal Background Check System) ដែលត្រូវបានរក្សាទុកសម្រាប់អនុវត្តការត្រួតពិនិត្យសាវតារសម្រាប់ការលក់ ឬការផ្តល់អាជ្ញាបណ្ណអាវុធ ហើយម្យ៉ាងទៀត តុលាការមិនត្រូវបញ្ជូនព័ត៌មាន គ្រាន់តែដោយសារបុគ្គលម្នាក់ស្វែងរកការព្យាបាលដោយស្ម័គ្រចិត្ត ឬត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដោយមិនស្ម័គ្រចិត្តសម្រាប់ការវាយតម្លៃ ឬការពិនិត្យសុខភាពនោះឡើយ។ ព័ត៌មានដែលត្រូវបានបញ្ជូនទៅនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌអនុលោមតាមមាត្រានេះ និងមាត្រា 35 ព្រមទាំងមាត្រា 36C ខាងលើ មិនត្រូវចាត់ទុកថាជាកំណត់ត្រាសាធារណៈឡើយ អនុលោមតាមមាត្រា 10 នៃជំពូក 66 និងអនុប្រយោគទី 26 នៃមាត្រា 7 ក្នុងជំពូក 4។ ប្រសិនបើព័ត៌មានដែលត្រូវបញ្ជូនស្របតាមអនុប្រយោគ (i) នៃកថាខណ្ឌនេះ ពាក់ព័ន្ធនឹងបុគ្គលម្នាក់ដែលបច្ចុប្បន្ននេះមានអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតដែលចេញស្របតាមមាត្រា 122, 122B, 129B, 131 ឬ 131F នៃជំពូក 140 នោះ ព័ត៌មានទាំងនោះត្រូវបានចែកចាយដោយស្វ័យប្រវត្តិទៅកាន់អាជ្ញាធរផ្តល់អាជ្ញាបណ្ណពាក់ព័ន្ធតាមរយៈប្រព័ន្ធព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ នៅពេលមានព័ត៌មាននោះសម្រាប់ការបញ្ជូនទៅសម្រាកព្យាបាលទាំងបង្ខំនីមួយៗដែលត្រូវបានបង្គាប់។

មាត្រា 12 មាត្រា36C នៃជំពូក 123 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយការដាក់បន្ថែមនូវកថាខណ្ឌដូចខាងក្រោម៖ -

(e) អង្គភាពអនុវត្តច្បាប់ណាមួយដែលដាក់ពាក្យសុំ ឬពាក់ព័ន្ធនឹងការឃាត់ខ្លួន និងការដាក់ពាក្យសុំឱ្យបញ្ជូនបុគ្គលម្នាក់ទៅសម្រាកព្យាបាលតាមមាត្រា 12 កថាខណ្ឌ (a) ឬ (b) ត្រូវបញ្ជូនលេខកំណត់ហេតុឧបទ្ទវហេតុ ឬលេខរបាយការណ៍ ព្រមទាំងឈ្មោះនិងព័ត៌មានអត្តសញ្ញាណរបស់បុគ្គលនោះ រួមទាំងលេខសន្តិសុខសង្គម និងថ្ងៃខែឆ្នាំកំណើត ទៅនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីផ្តល់ព័ត៌មានដល់អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ដូចបានកំណត់ក្នុងមាត្រា 121 នៃជំពូក 140 រួមជាមួយនឹងព័ត៌មានចាំបាច់ ឬអនុញ្ញាតឱ្យយកមកពិចារណាស្របតាមច្បាប់រដ្ឋ ឬច្បាប់សហព័ន្ធ ដើម្បីអនុវត្តការត្រួតពិនិត្យសាវតារក្នុងការលក់ ឬការផ្តល់អាជ្ញាបណ្ណអាវុធ។ ឯកសារទាំងឡាយដែលបានផ្តល់ជូនទៅក្រសួងសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌអនុលោមតាមកថាខណ្ឌនេះ មិនត្រូវរួមបញ្ចូលនូវព័ត៌មានណាមួយ ឬការរៀបរាប់អំពីការធ្វើរោគវិនិច្ឆ័យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រ ផែនការព្យាបាលឱសថព្យាបាលសុខភាពផ្លូវចិត្ត អ្នកផ្តល់សេវាថែទាំសុខភាពផ្លូវចិត្ត ឬព័ត៌មានផ្សេងទៀតដែលមានលក្ខណៈពិនិត្យព្យាបាលរបស់បុគ្គលនោះឡើយ។ គ្មានបុគ្គលណាម្នាក់ត្រូវបានចាត់ទុកថាជាបុគ្គលដែលត្រូវហាមឃាត់មិនឱ្យទទួលអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាត ស្របតាមមាត្រា 122, 122B, 129B, 131 ឬ 131F នៃជំពូក 140 ខាងលើ ដោយសារតែមូលហេតុនៃការឃាត់ខ្លួន និងការដាក់ពាក្យសុំបញ្ជូនទៅសម្រាកព្យាបាលស្របតាមកថាខណ្ឌ (a) ឬ (b) នៃមាត្រា 12 ខាងលើឡើយ លើកលែងតែក្នុងករណីដែលអាជ្ញាធរផ្តល់អាជ្ញាបណ្ណកំណត់ថា បុគ្គលនោះមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតនោះ ឬមិនសមស្របសម្រាប់ទទួលវា ស្របតាមមាត្រា 121F នៃជំពូក 140។ ទោះជាយ៉ាងណាក៏ដោយ នៅពេលកំណត់អំពីភាពសមស្របរបស់បុគ្គលសម្រាប់ទទួលអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតកាន់អាវុធ អាជ្ញាធរផ្តល់អាជ្ញាបណ្ណត្រូវធ្វើការស្នើសុំព័ត៌មានបន្ថែមពីអង្គភាពអនុវត្តច្បាប់ដែលបានបញ្ជូនរបាយការណ៍អំពីការឃាត់ខ្លួន និងការស្នើសុំបញ្ជូនទៅសម្រាកព្យាបាល និងទៅតុលាការដែលបានបង្គាប់ ឬបដិសេធការបញ្ជូនទៅសម្រាកព្យាបាលទាំងបង្ខំ ពាក់ព័ន្ធនឹងកាលៈទេសៈនៃការឃាត់ខ្លួន និងការស្នើសុំបញ្ជូនទៅសម្រាកព្យាបាលនោះ ព្រមទាំងមូលហេតុនៃការបង្គាប់ ឬការបដិសេធនោះ។ បុគ្គលណាម្នាក់ដែលត្រូវបានបដិសេធមិនផ្តល់អាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតស្របតាមអនុមាត្រានេះ ដោយគ្មានដីកាបង្គាប់ឱ្យបញ្ជូនទៅសម្រាកព្យាបាលទាំងបង្ខំពីតុលាការ អនុលោមតាមកថាខណ្ឌ (e) នៃមាត្រា 12 នោះ បន្ទាប់ពីរយៈពេល 5 ឆ្នាំ គិតចាប់ពីថ្ងៃបដិសេធ បុគ្គលនោះអាចដាក់ពាក្យបណ្តឹងសុំការសង្គ្រោះស្របតាមកថាខណ្ឌ (b) ទៅកាន់តុលាការដែលបានបដិសេធការដាក់ឱ្យស្ថិតក្រោមការបង្ខាំង ដោយស្នើឱ្យតុលាការស្តារឡើងវិញនូវសមត្ថភាពរបស់បុគ្គលនោះក្នុងការកាន់កាប់អាវុធ។ នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ មិនត្រូវបង្ហាញរបាយការណ៍ ឬព័ត៌មានណាមួយដែលបានទទួលស្របតាមកថាខណ្ឌនេះ ទោះក្នុងហេតុផលណាក៏ដោយ លើកលែងតែការផ្តល់ជូនអាជ្ញាធរផ្តល់អាជ្ញាបណ្ណ នូវព័ត៌មានដែលចាំបាច់ ឬអនុញ្ញាតឱ្យយកមកពិចារណាស្របតាមច្បាប់រដ្ឋ ឬច្បាប់សហព័ន្ធ ដើម្បីអនុវត្តការត្រួតពិនិត្យសាវតារសម្រាប់ការលក់ ឬការផ្តល់អាជ្ញាបណ្ណអាវុធនោះឡើយ។ អាជ្ញាធរផ្តល់អាជ្ញាបណ្ណមិនត្រូវបង្ហាញរបាយការណ៍ ឬព័ត៌មានណាមួយដែលបានទទួលស្របតាមកថាខណ្ឌនេះ ទោះដោយហេតុផល ឬគោលបំណងណាមួយផ្សេងក្រៅពីអ្វីដែលចាំបាច់ដើម្បីអនុវត្តទំនួលខុសត្រូវរបស់អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ក្នុងការចេញ ឬដកហូតអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាត ស្របតាមជំពូក 140 នោះឡើយ។ គ្មានបទប្បញ្ញត្តិណាមួយក្នុងកថាខណ្ឌនេះ រាងរាំងអ្នកដាក់ពាក្យសុំ ឬអ្នកកាន់លិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ ពីការប្តឹងឧទ្ធរណ៍ចំពោះការបដិសេធ ការដកហូត ឬការផ្អាកលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ ស្របតាមមាត្រា 121F នៃជំពូក 140 ខាងលើឡើយ។

មាត្រា 13 ជំពូក 131 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មលុបចោលមាត្រា 62 ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 62 បុគ្គលណាម្នាក់ដែលមានបរិមាណអាល់កុលក្នុងឈាមចាប់ពី 0.08 ភាគរយធៀបនឹងទម្ងន់ ឬស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងដែលបណ្តាលឱ្យស្រវឹង ឬកញ្ឆា ឬថ្នាំញៀន ឬសារធាតុបន្ថយប្រព័ន្ធប្រសាទ ឬសារធាតុជំរុញប្រព័ន្ធប្រសាទ ដែលទាំងអស់នេះត្រូវបានកំណត់និយមន័យក្នុងមាត្រា 1 នៃជំពូក 94C ឬបុគ្គល

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ណាដែលហិត ឬស្រូបចំហាយសារធាតុណាមួយដែលមានលក្ខណៈបញ្ចេញចំហាយពុលដោយចេតនា ដែលជាការបំពានលើមាត្រា 18 នៃជំពូក 270 នោះ មិនត្រូវបរបាញ់សត្វ ឬកាន់កាប់អាវុធ ធ្នូនិងព្រួញ ឬអាវុធផ្សេងទៀត ក្នុងពេលកំពុងចូលរួមបរបាញ់សត្វ ឬបាញ់ស៊ីបឡើយ។ ការល្មើសនឹងមាត្រានេះ ត្រូវផ្តន្ទាទោសដោយការពិន័យជាប្រាក់មិនលើសពីចំនួន 5,000 ដុល្លារ ឬដាក់ពន្ធនាគារនៅក្នុងមណ្ឌលកែប្រែមិនលើសពីរយៈពេល 2 ឆ្នាំកន្លះ ឬទាំងពិន័យជាប្រាក់ ទាំងដាក់ពន្ធនាគារ។

មាត្រា 14 មាត្រា 90 នៃជំពូក 131 ដែលមានចែងនៅក្នុងការបោះពុម្ពផ្សាយជាផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលលេខ “62” នៅក្នុងបន្ទាត់ទី 7។

មាត្រា 15 មាត្រា 121 ក្នុងជំពូក 140 នៃច្បាប់ទូទៅ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយបញ្ចូលទៅខាងក្រោយនិយមន័យនៃពាក្យ “គ្រាប់រំសេវ” នូវនិយមន័យដូចតទៅនេះ៖-

“អាវុធបុរាណ” សំដៅលើអាវុធណាមួយ ឬវត្ថុចម្លងដូចគ្នាបេះបិទនៃអាវុធនោះ ដែលត្រូវបានផលិតនៅក្នុងឆ្នាំ ឬមុនឆ្នាំ 1899 ប្រសិនបើអាវុធបែបនោះ៖ (i) មិនត្រូវបានរចនាឡើង ឬកែច្នៃឡើងវិញដើម្បីប្រើគ្រាប់រំសេវរួមសំបកប្រភេទផ្ទុះគែម ឬគ្រាប់រំសេវប្រភេទបាញ់ចំកណ្តាលបែបធម្មតាឡើយ ឬ (ii) ប្រើប្រាស់គ្រាប់រំសេវរួមសំបកប្រភេទផ្ទុះគែម ឬគ្រាប់រំសេវប្រភេទបាញ់កណ្តាលបែបធម្មតា ដែលមិនមានការផលិតបន្តទៀតឡើយនៅក្នុងសហរដ្ឋអាមេរិក និងដែលមិនអាចស្វែងរកបានដោយងាយនៅក្នុងបណ្តាញពាណិជ្ជកម្មលក់ដូរធម្មតា។ ប៉ុន្តែ “អាវុធបុរាណ” ត្រូវរាប់បញ្ចូលទាំងអាវុធប្រភេទកាំភ្លើងវែងញាត់គ្រាប់តាមចុងកាណុង កាំភ្លើងគ្រាប់ប្រាយ ឬកាំភ្លើងខ្លី ដែលរចនាឡើងដើម្បីប្រើប្រាស់រំសេវខ្មៅ ឬសារធាតុជំនួសរំសេវខ្មៅ ហើយមិនអាចប្រើប្រាស់គ្រាប់រំសេវរួមសំបក លើកលែងតែក្នុងករណីដែលអាវុធនោះ៖ (a) រួមបញ្ចូលគ្រោង ឬតួកាំភ្លើង (b) ត្រូវបានបំប្លែងទៅជាអាវុធញាត់គ្រាប់ពីចុងកាណុង ឬ (c) ជាអាវុធញាត់គ្រាប់តាមកាណុងដែលអាចងាយបំប្លែងដើម្បីបាញ់គ្រាប់រំសេវមានសំបក ដោយជំនួសកាណុងកាំភ្លើង ឬគន្លឹះអាមេ ឬដុំបិទបាតកាណុង ឬការផ្សំបញ្ចូលគ្នានៃផ្នែកទាំងនេះ។

មាត្រា 16 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយដកចេញនូវនិយមន័យ “អាវុធវាយប្រហារ” ហើយបញ្ចូលជំនួសដោយនិយមន័យចំនួន 5 ដូចខាងក្រោម៖-

“កាំភ្លើងប្រភេទវាយប្រហារ” សំដៅលើអាវុធណាមួយដែលជា៖

(a) កាំភ្លើងវែងប្រភេទពាក់កណ្តាលស្វ័យប្រវត្តិ បាញ់ផ្ទុះកណ្តាល មានសមត្ថភាពប្រើប្រាស់បង់គ្រាប់អាចដោះចេញបាន ហើយរួមបញ្ចូលលក្ខណៈពិសេសយ៉ាងហោចណាស់ចំនួន 2 ដូចតទៅនេះ៖ (i) ស្នូកកាំភ្លើងស្វ័យបត់ ឬស្វ័យចល័ត (ii) ស្នូកកាំភ្លើងមានប្រហោងមេដៃ ឬដងកាំភ្លើងខ្លី (iii) ដងកាន់ខាងមុខ ឬដងកាន់ដៃទីពីរ ឬដងកាន់លយចេញមកក្រៅ អាចកាន់បានដោយដៃម្ខាងទៀតដែលមិនមែនជាដៃកេះកៃ (iv) កាណុងមានធ្មេញវីសដែលរចនាឡើងដើម្បីបំពាក់ឧបករណ៍បំបាត់ពន្លឺចាំង ឬឧបករណ៍កាត់បន្ថយកម្លាំងធាក់ ឬលក្ខណៈពិសេសប្រហាក់ប្រហែលនេះ ឬ (v) សំបកការពារព័ទ្ធជុំវិញកាណុងទាំងមូល ឬមួយផ្នែករចនាឡើងដើម្បីការពារដៃរបស់អ្នកកាន់កុំឱ្យក្តៅ ដោយមិនរាប់បញ្ចូលនូវស្លាយកាំភ្លើងគ្របពីលើកាណុងនោះឡើយ។

(b) កាំភ្លើងខ្លីប្រភេទពាក់កណ្តាលស្វ័យប្រវត្តិ មានសមត្ថភាពប្រើប្រាស់បង់គ្រាប់អាចដកចេញបាន ហើយរួមបញ្ចូលលក្ខណៈពិសេសយ៉ាងហោចណាស់ចំនួន 2 ដូចតទៅនេះ៖ (i) សមត្ថភាពប្រើប្រាស់បង់គ្រាប់ដែលភ្ជាប់ទៅនឹងកាំភ្លើងខ្លី នៅខាងក្រៅដងកាំភ្លើងខ្លី (ii) ដងកាន់ដៃទីពីរ ឬដងកាន់លយចេញមកក្រៅ អាចកាន់ដោយដៃម្ខាងទៀតដែលមិនកេះកៃ។ (iii) កាណុងកាំភ្លើងមានធ្មេញវីស អាចបំពាក់ឧបករណ៍បំបាត់ពន្លឺចាំង ដងកាន់ខាងមុខ ឬឧបករណ៍ខ្ទប់សំឡេង ឬ (iv) សំបកការពារព័ទ្ធជុំវិញកាណុងទាំងមូល ឬមួយផ្នែក រចនាឡើងដើម្បីការពារដៃរបស់អ្នកកាន់កុំឱ្យក្តៅ ដោយមិនរាប់បញ្ចូលនូវស្លាយកាំភ្លើងគ្របពីលើកាណុងនោះឡើយ។

(c) កាំភ្លើងគ្រាប់ប្រាយពាក់កណ្តាលស្វ័យប្រវត្តិដែលរួមបញ្ចូលលក្ខណៈពិសេសយ៉ាងហោចណាស់ចំនួន 2 ដូចតទៅនេះ៖ (i) ស្នូកកាំភ្លើងស្វ័យបត់ ឬស្វ័យចល័ត (ii) ស្នូកកាំភ្លើងមានប្រហោងមេដៃ ឬដងកាំភ្លើងខ្លី (iii) ដងកាន់លយចេញមកក្រៅសម្រាប់ដៃម្ខាងទៀតដែលមិនកេះកៃ ឬ (iv) សមត្ថភាពប្រើប្រាស់បង់គ្រាប់អាចដោះចេញបាន។

(d) កាំភ្លើងណាមួយដែលត្រូវបានចុះក្នុងបញ្ជីឈ្មោះអាវុធប្រភេទវាយប្រហារ ដោយអនុលោមតាមមាត្រា 128A។

(e) កាំភ្លើងណាមួយដូចតទៅនេះ ឬកាំភ្លើងចម្លង ឬកាំភ្លើងធ្វើតាមអាវុធទាំងនេះ ទោះជាទំហំមុខកាត់កាណុងណាក៏ដោយ ដែលស្គាល់ថាជា៖ (i) Avtomat Kalashnikov ឬ AK គ្រប់ម៉ូដែលទាំងអស់។ (ii) កាំភ្លើងម៉ាក UZI និង Galil របស់ក្រុមហ៊ុន Action Arms នៃឧស្សាហកម្មយោធាអ៊ីស្រាអែល។ (iii) Beretta AR70 (SC-70)។ (iv) Colt AR-15។ (v) Fabrique National FN/FAL, FN/LAR និង FNC។ (vi) SWD M-10, M-11, M-11/9 និង M-12។ (vii) Steyr AUG។ (viii) INTRATEC TEC-9, TEC-DC9 និងTEC-22។ និង (ix) កាំភ្លើងខ្លីដែលប្រើស៊ីឡាំងវិល រួមមានជាអាទិ៍ កាំភ្លើង Street Sweeper និង Striker 12 ជាដើម។

(f) កាំភ្លើងចម្លង ឬកាំភ្លើងធ្វើតាមគំរូកាំភ្លើងណាមួយដែលស្របតាមស្តង់ដា ឬត្រូវបានបញ្ជាក់ក្នុងអនុប្រយោគ (d) និង (e) ខាងលើ ដោយចែងថា សម្រាប់គោលបំណងនៃកថាខណ្ឌនេះ ពាក្យ “កាំភ្លើងចម្លង ឬកាំភ្លើងធ្វើតាម” មានន័យថាកាំភ្លើងមួយ៖ (A) ដែលត្រូវបានផលិត ឬត្រូវបានកែច្នៃរចនាសម្ព័ន្ធជាបន្តបន្ទាប់ឱ្យមានសមត្ថភាពប្រើប្រាស់បង់គ្រាប់អាចដោះចេញបាន និង (B) (i) ដែលមានគ្រឿងបង្កុំមុខងារខាងក្នុង មានរចនាសម្ព័ន្ធ និងមានបំណែកស្រដៀងគ្នាខ្លាំងទៅនឹងកាំភ្លើងដែលត្រូវបានចែងក្នុងអនុប្រយោគ (d) និង (e)។ ឬ (ii) ដែលមានតួកាំភ្លើងដូចគ្នា ឬអាចផ្លាស់ប្តូរប្រើជំនួសគ្នាបានជាមួយតួកាំភ្លើងដែលត្រូវបានចែងក្នុងអនុប្រយោគ (d) និង (e)។ ដោយមានចែងបន្ថែមថា កាំភ្លើងមិនត្រូវចាត់ទុកថាជាកាំភ្លើងចម្លង ឬកាំភ្លើងធ្វើតាមប្រភេទកាំភ្លើងដែលត្រូវបានកំណត់ក្នុងអនុប្រយោគ (d) និង (e) ឡើយ ប្រសិនបើកាំភ្លើងនោះត្រូវបានលក់ កាន់កាប់ និងចុះបញ្ជីមុនថ្ងៃទី 20 ខែកក្កដា ឆ្នាំ 2016 រួចហើយ។

(g) អាវុធប្រភេទវាយប្រហារ មិនត្រូវរួមបញ្ចូល៖ (i) អាវុធណាមួយដែលដំណើរការដោយដៃតាមរយៈគន្លឹះអាមេ ប្រព័ន្ធបូម ដងគន្លាស់ ឬស្លាយរំកិលគ្រាប់ (ii) អាវុធណាមួយដែលត្រូវបានធ្វើឱ្យលែងដំណើរការជាអចិន្ត្រៃយ៍ ឬត្រូវបានធ្វើឱ្យមិនអាចចាត់ទុកជាប្រភេទអាវុធវាយប្រហារបែបពាក់កណ្តាលស្វ័យប្រវត្តិ តាមវិធីផ្សេងទៀត

# អត្ថបទទាំងស្រុង (ត)

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ជាអចិន្ត្រៃយ៍ (iii) អាវុធដែលជាវត្ថុបុរាណ ឬជាវត្ថុអនុស្សាវរីយ៍ជាប្រវត្តិសាស្ត្រ ឧបករណ៍ប្រើប្រាស់ក្នុងឆាកល្ខោន/ភាពយន្ត ឬអាវុធផ្សេងទៀតដែលមិនមានសមត្ថភាពបាញ់គ្រាប់ចេញបាន ហើយដែលមិនមានបំណងប្រើប្រាស់ជាអាវុធដំណើរការផ្ទុះពិតប្រាកដ និងមិនអាចងាយស្រួលកែច្នៃដោយការផ្សំគ្រឿងបន្លាស់ដែលមានស្រាប់ឱ្យទៅជាអាវុធវាយប្រហារបានឡើយ (iv) អាវុធណាមួយ ឬអាវុធចម្លង ឬកាំភ្លើងធ្វើតាមគំរូអាវុធដែលមានចែងនៅក្នុងឧបសម្ព័ន្ធ A នៃក្រមច្បាប់សហរដ្ឋអាមេរិក ក្រម 18 មាត្រា 922 ដូចដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធនោះកាលពីថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 1994 ដែលអាវុធទាំងនោះត្រូវបានផលិតឡើងនៅពីថ្ងៃទី 1 ខែតុលា ឆ្នាំ 1993 ឬ (v) កាំភ្លើងបាញ់គ្រាប់វាយពាក់កណ្ដាលស្វ័យប្រវត្តិដែលមិនអាចផ្ទុកគ្រាប់លើសពី 5 គ្រាប់ នៅក្នុងបង់គ្រាប់ដែលជាប់នឹងកាំភ្លើង ឬដែលអាចដោះចេញបាន។

“ការដំឡើង” មានន័យថា ការផ្គុំបញ្ចូលគ្នានូវគ្រឿងបង្គុំផ្សេងៗនៃកាំភ្លើង ប៉ុន្តែពាក្យ “ដំឡើង” មិនរាប់បញ្ចូលការផ្គុំឡើងវិញ ការជួសជុល ឬការបំពាក់កាណុងពិសេសស្វ័យកាំភ្លើង ឬកែបាញ់ទៅលើអាវុធនោះទេ។

“ការបំប្លែងទៅជាស្វ័យប្រវត្តិ” សំដៅលើការកែប្រែណាមួយដែលធ្វើឡើងចំពោះអាវុធរួមទាំងតាមរយៈការប្រើប្រាស់គ្រឿងបង្គុំស្វ័យប្រវត្តិដែលអនុញ្ញាតឱ្យអាវុធនោះបាញ់ចេញលើសពី 1 គ្រាប់បាន ដោយការកេះកៃបាញ់ជាប់តែមួយដង ឬដែលកែប្រែ ឬបង្កើនអត្រាបាញ់ឱ្យមានលក្ខណៈស្រដៀងនឹងការបាញ់ដោយស្វ័យប្រវត្តិ។

“គ្រឿងបង្គុំស្វ័យប្រវត្តិ” គឺជាឧបករណ៍ គ្រឿងបង្គុំ ឬការរួមបញ្ចូលគ្នានូវគ្រឿងបង្គុំណាមួយ មានសមត្ថភាពអាចភ្ជាប់ទៅនឹងកាំភ្លើង ធ្វើឱ្យអាចបាញ់ចេញគ្រាប់លើសពី 1 គ្រាប់ជាស្វ័យប្រវត្តិ ដោយចុចកៃជាប់តែម្តង ឬបង្កើនល្បឿនបាញ់របស់អាវុធដើម្បីយកគ្រាប់តាមការបាញ់ស្វ័យប្រវត្តិ។

“អ្នកប្រមូលអាវុធដោយសុចរិត” សំដៅដល់បុគ្គលដែលទទួលបានអាជ្ញាបណ្ណជាអ្នកប្រមូលកាំភ្លើង ស្របតាមក្រម 18 U.S.C. មាត្រា 923(b)។

មាត្រា 17 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយដាក់បន្ថែមបន្ទាប់ពីកថាខណ្ឌទី 3 នូវ៖ -

“កាំភ្លើងលាក់បន្លំ” សំដៅដល់អាវុធដែលត្រូវបានដាក់ក្នុងប្រអប់ផ្ទុកអាវុធសម្រាប់បន្លំភ្នែក ឬជាអាវុធដែលមិនមែនជាកាំភ្លើងឆក់ មានសមត្ថភាពបាញ់គ្រាប់ចេញបាន ហើយត្រូវបានផលិតឡើងដោយមានរូបរាងមិនដូចជាអាវុធ ឬមិនអាចសម្គាល់ដឹងភ្លាមៗថាជាអាវុធ រួមមានជាអាទិ៍ កាំភ្លើងកែច្នៃដោយខ្លួនឯង កាំភ្លើងលាក់គន្លឹះអាមេកាំភ្លើងបត់ និងអាវុធផ្សេងទៀតដែលមានរូបរាងដូចច្រវាក់កូនសោ ប៊ិច ដំបងច្រត់កាបូបលុយ ពិល ដែកកេះជក់បារី ឬកញ្ចប់បារី កាំភ្លើងបាញ់សញ្ញាអាសន្ន កាំភ្លើងខ្យល់បាញ់គ្រាប់សំណ និងកញ្ចប់ឧបករណ៍កែច្នៃកាំភ្លើងប្រើគ្រាប់សំណមូល។

“អាវុធជាវត្ថុអនុស្សាវរីយ៍ ឬវត្ថុបូរាណ” សំដៅដល់អាវុធដែលជាទីចាប់អារម្មណ៍ពិសេសសម្រាប់អ្នកប្រមូល ដោយសារវត្ថុទាំងនេះមានលក្ខណសម្បត្តិជាក់លាក់មួយចំនួន ដែលជាទូទៅមិនពាក់ព័ន្ធទៅនឹងអាវុធសម្រាប់ប្រើប្រាស់ក្នុងកីឡា ឬជាអាវុធសម្រាប់ប្រើប្រាស់ក្នុងគោលបំណងវាយប្រហារ ឬការពារខ្លួនឡើយ។

មាត្រា 18 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលនិយមន័យពាក្យ “ឧបករណ៍អាវុធបញ្ឆោត” ហើយជំនួសមកវិញនូវនិយមន័យដូចខាងក្រោម៖-

“ឧបករណ៍អាវុធបញ្ឆោត” គឺជាឧបករណ៍ណាមួយដែលមានបំណងបង្ហាញឱ្យឃើញពីវត្តមាននៃអាវុធ ដែលបានយកទៅប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសហិង្សា ហើយដែលបង្កជាការគំរាមកំហែងជាក់ស្តែងភ្លាមៗដល់អាយុជីវិត ឬបង្កគ្រោះថ្នាក់រាងកាយធ្ងន់ធ្ងរដល់បុគ្គលម្នាក់ដែលមានស្មារតីនិងការយល់ដឹងជាមធ្យម។

មាត្រា 19 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលនិយមន័យពាក្យ “ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ” ហើយបញ្ចូលជំនួសដោយនិយមន័យដូចខាងក្រោម៖-

“ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ” គឺជាដីកាបង្គាប់ដោយតុលាការដែលបញ្ជាឱ្យ៖ (i) ព្យួរជាបណ្តោះអាសន្ន និងប្រគល់ជូនវិញជាបន្ទាន់នូវរាល់អាជ្ញាបណ្ណកាន់កាប់អាវុធ ឬកាតសម្គាល់អាវុធណាមួយ ដែលចុងចម្លើយអាចមានកាន់កាប់ (ii) ចុងចម្លើយត្រូវប្រគល់រាល់អាវុធ ឬគ្រាប់រំសេវទាំងអស់ ដែលចុងចម្លើយកំពុងគ្រប់គ្រងមានកម្មសិទ្ធិ ឬកាន់កាប់នៅពេលនោះ និង (iii) ចុងចម្លើយត្រូវបាត់បង់សិទ្ធិក្នុងការទទួលបានអាជ្ញាបណ្ណកាន់កាប់ថ្មី ឬបណ្ណសម្គាល់អាវុធថ្មី ក្នុងអំឡុងពេលនៃដីកានេះ។ ទោះជាយ៉ាងណាក៏ដោយ ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរនេះ ត្រូវមានសុពលភាពរហូតដល់ 1 ឆ្នាំ ចាប់ពីថ្ងៃចេញដីកា ហើយអាចត្រូវបានបន្តសុពលភាពឡើងវិញទៅតាមការស្នើសុំ។

មាត្រា 20 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយការដកចេញនូវនិយមន័យ “អាវុធ” “ជាងធ្វើអាវុធ” និង “អាវុធចម្លង” ហើយបញ្ចូលជំនួស ដោយនិយមន័យចំនួន 5 ដូចខាងក្រោម៖-

“ឧបករណ៍បញ្ចូនគ្រាប់” គឺជាបង់គ្រាប់ ខ្សែក្រវាត់គ្រាប់ បន្ទះកិបគ្រាប់ បង់មូល ឬឧបករណ៍ប្រហាក់ប្រហែលគ្នាណាមួយ ដែលផ្ទុកគ្រាប់រំសេវសម្រាប់អាវុធ មិនថាជាប្រភេទភ្ជាប់ជាប់ ឬអាចដោះចេញបានពីអាវុធឡើយ។

“អាវុធ” គឺកាំភ្លើងឆក់ កាំភ្លើងខ្លី កាំភ្លើងខ្លីបង់បង្វិល កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយកាំភ្លើងគ្រាប់ប្រាយកាត់កាណុង កាំភ្លើងដែលមានសមត្ថភាពផ្ទុកគ្រាប់បានច្រើនកាំភ្លើងវាយប្រហារ និងកាំភ្លើងយន្ត មិនថាមានផ្ទុកគ្រាប់ ឬមិនមានផ្ទុកគ្រាប់នោះទេដែលត្រូវបានរចនាឡើង ឬអាចកែច្នៃបានដោយងាយស្រួលដើម្បីបាញ់ក្បាលគ្រាប់ឬគ្រាប់រំសេវចេញ។ ពាក្យនេះក៏រាប់បញ្ចូលទាំងតួដងកាំភ្លើង ឬប្រអប់ទទួលគ្រាប់នៃអាវុធទាំងនោះ ឬតួកាំភ្លើង និងប្រអប់ទទួលគ្រាប់ដែលមិនទាន់ផលិតរួចរាល់នៃអាវុធនោះផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ពាក្យ “អាវុធ” នេះ មិនត្រូវរាប់បញ្ចូលអាវុធបុរាណ ឬអាវុធដែលលែងដំណើរការជាអចិន្ត្រៃយ៍នោះឡើយ។

“តួដងកាំភ្លើង” គឺជាផ្នែកមួយនៃកាំភ្លើងខ្លី ឬកាំភ្លើងខ្លីបង់បង្វិល ដែលមានប្រអប់ផ្ទុកឬមានរចនាសម្ព័ន្ធសម្រាប់គ្រឿងបង្គុំដែលរចនាឡើងដើម្បីទប់ក្បាលញញួរកៃ ម្ជុលសៀតកៃ គន្លឹះអាមេ ឬសមាសធាតុផ្តល់ថាមពលចម្លងស្រដៀងគ្នានេះ មុនពេលចាប់ផ្តើមដំណើរការបាញ់ ទោះបីជាត្រូវការកន្លាស់ ឬឧបករណ៍ភ្ជាប់ផ្សេងទៀតដើម្បីភ្ជាប់គ្រឿងទាំងនោះទៅនឹងប្រអប់ផ្ទុកឬរចនាសម្ព័ន្ធនោះក៏ដោយ។ គ្រឿងទាំងនេះណាមួយ ដែលត្រូវបានសម្គាល់ដោយលេខស៊េរីរបស់អ្នកនាំចូល ឬរបស់ក្រុមហ៊ុនផលិត ត្រូវសន្មតថាជាតួដងកាំភ្លើងនៃអាវុធនោះ លើកលែងតែមានការសម្រេចជាផ្លូវការដោយការិយាល័យគ្រប់គ្រងគ្រឿងស្រវឹង ថ្នាំជក់ អាវុធ និងគ្រឿងផ្ទុះ (ATF) នៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ឬមានភស្តុតាងគួរឱ្យទុកចិត្តផ្សេងទៀតដែលផ្ទុយពីនេះ។

# សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

"ជាងកាំភ្លើង" គឺជាបុគ្គលណាម្នាក់ដែលប្រកបអាជីវកម្មជួសជុល កែប្រែ សម្អាត ខាត់រំលីង ឆ្លាក់ក្បាច់ បំពាក់ថ្នាំការពារច្រែះ ឬធ្វើប្រតិបត្តិការមេកានិចណាមួយនៅលើអាវុធ។

"អាវុធចម្លង" គឺជាអាវុធណាមួយដែលត្រូវបានរចនា ផលិត ឬកែប្រែក្នុងលក្ខណៈដែលធ្វើឱ្យវាមិនអាចបាញ់ក្បាលគ្រាប់ ឬគ្រាប់រំសេវចេញបាន។

មាត្រា 21 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយលុបចោលនិយមន័យពាក្យ "ឧបករណ៍បញ្ចូនគ្រាប់សមត្ថភាពផ្ទុកខ្ពស់" ហើយបញ្ចូលជំនួសនិយមន័យដូចខាងក្រោម៖-

"ឧបករណ៍បញ្ចូនគ្រាប់សមត្ថភាពផ្ទុកខ្ពស់" (i) គឺជាបង់កាំភ្លើងដែលជាប់នឹងកាំភ្លើង ឬអាចដោះចេញបាន ខ្សែក្រវាត់គ្រាប់ បង់មូល បន្ទះសៀតគ្រាប់ ឬឧបករណ៍ប្រហាក់ប្រហែលគ្នាណាមួយដែលមានសមត្ថភាពផ្ទុក ឬដែលអាចកែច្នៃបានដោយងាយដើម្បីផ្ទុកគ្រាប់លើសពី 10 គ្រាប់ ឬគ្រាប់ប្រាយលើសពី 5 គ្រាប់ ឬ (ii) គឺជាគ្រឿងបង្គុំ ឬបណ្តុំគ្រឿងបង្គុំណាមួយ ដែលអាចយកទៅដំឡើងជាឧបករណ៍បញ្ចូនគ្រាប់បាន ប្រសិនបើគ្រឿងបង្គុំទាំងនោះស្ថិតនៅក្រោមការកាន់កាប់ ឬការគ្រប់គ្រងរបស់បុគ្គលតែម្នាក់។ ទោះជាយ៉ាងណាក៏ដោយ ពាក្យ "ឧបករណ៍បញ្ចូនគ្រាប់សមត្ថភាពផ្ទុកខ្ពស់" មិនត្រូវរាប់បញ្ចូល៖ (a) ឧបករណ៍ណាមួយដែលត្រូវបានកែប្រែជាអចិន្ត្រៃយ៍ ដើម្បីកុំឱ្យវាអាចផ្ទុកគ្រាប់លើសពី 10 គ្រាប់ ឬគ្រាប់ប្រាយលើសពី 5 គ្រាប់ឡើយ (b) ឧបករណ៍រាងបំពង់ទីបដែលបំពាក់ជាប់នឹងកាំភ្លើង រចនាឡើងដើម្បីផ្ទុក និងមានសមត្ថភាពដំណើរការតែជាមួយគ្រាប់គែមមុខកាត់កាណុងទំហំ .22 ប៉ុណ្ណោះ ឬ (c) បង់កាំភ្លើងរាងបំពង់ទីបដែលមាននៅក្នុងអាវុធដំណើរការដោយដងកន្លាស់ ឬនៅលើកាំភ្លើងគ្រាប់ប្រាយប្រើប្រព័ន្ធបូម។

មាត្រា 22 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយលុបចោលនិយមន័យឃ្លា "អាវុធដែលមានសមត្ថភាពខ្ពស់" ហើយបញ្ចូលជំនួសដោយនិយមន័យដូចខាងក្រោម៖-

"អាវុធសមត្ថភាពផ្ទុកគ្រាប់ខ្ពស់" គឺជាអាវុធណាមួយដែល៖ (i) ជាប្រភេទពាក់កណ្តាលស្វ័យប្រវត្តិ ដែលបំពាក់ឧបករណ៍បញ្ចូនគ្រាប់សមត្ថភាពផ្ទុកខ្ពស់ជាប់នឹងអាវុធ (ii) ជាប្រភេទពាក់កណ្តាលស្វ័យប្រវត្តិ និងអាចប្រើប្រាស់ជាមួយ ឬអាចកែច្នៃបានដោយងាយដើម្បីប្រើប្រាស់ជាមួយឧបករណ៍បញ្ចូនគ្រាប់សមត្ថភាពផ្ទុកខ្ពស់ដែលអាចដោះចេញបាន ក្នុងករណីដែលវត្ថុទាំងពីរនេះស្ថិតនៅក្រោមការកាន់កាប់របស់បុគ្គលតែម្នាក់ ឬស្ថិតក្រោមការគ្រប់គ្រងរបស់ពួកគេនៅក្នុងយានយន្ត (iii) ប្រើប្រាស់បង់វិលដែលមានសមត្ថភាពផ្ទុកគ្រាប់រំសេវបានលើសពី 10 គ្រាប់ ឬគ្រាប់ប្រាយលើសពី 5 គ្រាប់ ឬ (iv) ជាអាវុធប្រភេទវាយប្រហារ។ ទោះជាយ៉ាងណាក៏ដោយ ឃ្លា "អាវុធសមត្ថភាពផ្ទុកគ្រាប់ខ្ពស់" ត្រូវសម្គាល់ជាប្រភេទបន្ទាប់បន្សំ ហើយត្រូវអនុវត្តបន្ថែមលើការកំណត់ប្រភេទចម្បងរបស់អាវុធនោះ និងមិនត្រូវរាប់បញ្ចូលអាវុធណាមួយដែល៖ (a) ដំណើរការដោយគន្លឹះអាមេប្រព័ន្ធបូម ដងកន្លាស់ ឬប្រព័ន្ធស្លាយ (b) ជាអាវុធបាញ់បានម្តងមួយគ្រាប់ (c) ត្រូវបានកែប្រែក្នុងលក្ខណៈមួយដែលធ្វើឱ្យវាលែងដំណើរការជាអចិន្ត្រៃយ៍ ឬត្រូវបានធ្វើឱ្យមិនអាចកំណត់ជាប្រភេទអាវុធមានសមត្ថភាពផ្ទុកគ្រាប់ខ្ពស់ជាអចិន្ត្រៃយ៍តាមវិធីផ្សេងទៀតជា ឬ (d) ជាវត្ថុបុរាណ ឬជាវត្ថុសម័យមុន ឧបករណ៍ប្រើប្រាស់ក្នុងឆាកល្ខោន/ភាពយន្ត ឬអាវុធផ្សេងទៀតដែលមិនមានសមត្ថភាពបាញ់គ្រាប់ចេញបាន ហើយដែលមិនមានបំណងប្រើប្រាស់ជាអាវុធដំណើរការពិតប្រាកដ និងមិនអាចកែច្នៃបានដោយងាយតាមរយៈការផ្សំគ្រឿងបង្គុំដែលមានបញ្ចូលគ្នា ទៅជាអាវុធមានសមត្ថភាពផ្ទុកគ្រាប់ខ្ពស់អាចដំណើរការបាន។

មាត្រា 23 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយការបញ្ចូលបន្ថែមនៅបន្ទាត់ទី 119 ខាងក្រោយពាក្យ "ពួកគេ" នូវពាក្យដូចខាងក្រោម៖ "ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីដែលមិនមានប្រធាន ឬមន្ត្រីបែបនោះទេ ស្នងការប៉ូលិសរដ្ឋ ឬបុគ្គលដែលត្រូវបានចាត់តាំងរបស់ពួកគេ ត្រូវដើរតួជាអាជ្ញាធរផ្តល់អាជ្ញាបណ្ណ។"

មាត្រា 24 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយលុបចោលនិយមន័យពាក្យ "កាំភ្លើងយន្ត" ហើយបញ្ចូលជំនួសដោយនិយមន័យចំនួន 4 ដូចខាងក្រោម៖-

"កាំភ្លើងយន្ត" គឺជាអាវុធ ទោះបីជាមានផ្ទុកគ្រាប់ ឬមិនមានផ្ទុកគ្រាប់ក៏ដោយ ដែលអាចបាញ់ចេញដោយស្វ័យប្រវត្តិនូវគ្រាប់លើសពី 1 គ្រាប់ ដោយការសង្កត់កៃជាប់តែម្តង ទោះបីជាវាត្រូវបានផលិតឡើងក្នុងទម្រង់បែបនោះពីដំបូង ឬត្រូវបានកែប្រែដោយការកែច្នៃឱ្យមានលក្ខណៈជាស្វ័យប្រវត្តិក៏ដោយ រួមទាំងតាមរយៈការប្រើប្រាស់គ្រឿងបង្គុំស្វ័យប្រវត្តិ ឬអាវុធណាមួយ ទោះបីជាមានផ្ទុកគ្រាប់ ឬមិនមានផ្ទុកគ្រាប់ក៏ដោយ ដែលត្រូវបានកែប្រែដោយការកែច្នៃជាស្វ័យប្រវត្តិ ដើម្បីផ្លាស់ប្តូរ ឬបង្កើនល្បឿនបាញ់របស់វា ដើម្បីធ្វើតម្រាប់តាមល្បឿនបាញ់របស់អាវុធស្វ័យប្រវត្តិ។ ទោះជាយ៉ាងណាក៏ដោយ ពាក្យ "កាំភ្លើងយន្ត" នេះ ត្រូវរាប់បញ្ចូលទាំងកាំភ្លើងយន្តធុនស្រាលផងដែរ។

"ការផលិត" គឺជាការផលិត ការធ្វើ ការបង្កើត ការបង្កើតផល ឬការកសាងអាវុធឡើង ដោយកម្លាំងដៃ ឬដោយគ្រឿងចក្រ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ពាក្យ "ការផលិត" នេះ មិនត្រូវរាប់បញ្ចូលទាំងការដំឡើងអាវុធឡើងវិញ ការជួសជុលអាវុធ ឬការធ្វើ ឬការបំពាក់បន្ថែមនូវកាណុងកាំភ្លើងពិសេស ស្វ័យកាំភ្លើង ឬយន្តការកៃកាំភ្លើងទៅនឹងអាវុធនោះឡើយ។

"អនិវាសនជន" គឺជាបុគ្គលដែលស្ថិតនៅក្នុងរដ្ឋម៉ាសាឈូសិតនេះជាបណ្តោះអាសន្ន ប៉ុន្តែរស់នៅស្របច្បាប់នៅក្នុងរដ្ឋផ្សេងទៀត ឬនៅក្នុងដែនដីណាមួយនៃសហរដ្ឋអាមេរិក។

"បង្កប់ជាប់ជាអចិន្ត្រៃយ៍" ត្រូវបានប្រើប្រាស់ក្នុងលក្ខណៈមួយដែលមិនអាចដកចេញបានដោយងាយឬភ្លាមៗ ដោយមិនធ្វើឱ្យខូចខាតដល់ផ្នែកដែលប្រើប្រាស់ការបង្កប់នោះឡើយ។

មាត្រា 25 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយលុបចោលនិយមន័យពាក្យ "ពាក្យបណ្តឹង" និង "ដើមបណ្តឹង" ហើយបញ្ចូលជំនួសនូវនិយមន័យចំនួន 3 ខាងក្រោម៖-

"ពាក្យស្នើសុំ" ដូចដែលបានប្រើនៅក្នុងមាត្រា 131R ដល់មាត្រា 131Y ទាំងស្រុង គឺជាសំណើដែលត្រូវបានដាក់ជូនតុលាការដោយដើមបណ្តឹង ដើម្បីចេញ ឬបន្តជាថ្មីនូវដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ។

"ដើមបណ្តឹង" ដូចដែលបានប្រើនៅក្នុងមាត្រា 131R ដល់មាត្រា 131Y ទាំងស្រុង គឺជាបុគ្គលម្នាក់ៗដែលដាក់ពាក្យស្នើសុំ ហើយជា៖ (i) សមាជិកគ្រួសារ ឬសមាជិកក្នុងលំនៅឋានរួមរបស់ចុងចម្លើយ (ii) អាជ្ញាធរផ្តល់អាជ្ញាបណ្ណរបស់សាលាក្រុងដែល

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ចុងចម្លើយរស់នៅ (iii) អង្គភាព ឬមន្ត្រីអនុវត្តច្បាប់ ដូចដែលមានចែងក្នុងមាត្រា 1 នៃជំពូក 6E ដែលមានទំនាក់ទំនងទៅវិញទៅមកជាមួយចុងចម្លើយក្នុងសមត្ថកិច្ចផ្លូវការរយៈពេល 30 ថ្ងៃកន្លងមកនេះ (iv) អ្នកផ្តល់សេវាថែទាំសុខភាព ដែលបានផ្តល់សេវាថែទាំសុខភាពដល់ចុងចម្លើយក្នុងរយៈពេល 6 ខែមុន ប៉ុន្តែ សម្រាប់គោលបំណងអនុប្រយោគនេះ ឃ្លា "អ្នកផ្តល់សេវាថែទាំសុខភាព" ត្រូវរាប់បញ្ចូលទាំង៖ គ្រូពេទ្យមានអាជ្ញាបណ្ណ ជំនួយការគ្រូពេទ្យមានអាជ្ញាបណ្ណ គិលានុបដ្ឋាកចុះបញ្ជី គិលានុបដ្ឋាកអនុវត្តមានអាជ្ញាបណ្ណ គិលានុបដ្ឋាកជំនាញមានវិញ្ញាបនបត្រ គិលានុបដ្ឋាកជំនាញពិនិត្យព្យាបាលមានវិញ្ញាបនបត្រ គិលានុបដ្ឋាកជំនាញពិនិត្យព្យាបាលផ្នែកចិត្តសាស្ត្រមានវិញ្ញាបនបត្រ គ្រូពេទ្យចិត្តសាស្ត្រមានអាជ្ញាបណ្ណ អ្នកចិត្តវិទ្យាមានអាជ្ញាបណ្ណ អ្នកប្រឹក្សាសុខភាពផ្លូវចិត្តមានអាជ្ញាបណ្ណ អ្នកព្យាបាលអាពាហ៍ពិពាហ៍និងគ្រួសារមានអាជ្ញាបណ្ណ អ្នកប្រឹក្សាគ្រឿងស្រវឹងនិងគ្រឿងញៀនមានអាជ្ញាបណ្ណ បុគ្គលិកសង្គមកិច្ចគ្លីនិកឯករាជ្យមានអាជ្ញាបណ្ណ ឬបុគ្គលិកសង្គមកិច្ចមានវិញ្ញាបនបត្រនិងអាជ្ញាបណ្ណ ឬ (v) នាយក ឬនាយករងសាលាបឋមសិក្សា ឬមធ្យមសិក្សា ឬនាយកមហាវិទ្យាល័យ ឬសាកលវិទ្យាល័យដែលចុងចម្លើយកំពុងសិក្សា។

"អាវុធផលិតជាឯកជន" គឺជាអាវុធដែលត្រូវបានផលិត ឬដំឡើងដោយបុគ្គលម្នាក់ដែលមិនមែនជាក្រុមហ៊ុនផលិតមានអាជ្ញាបណ្ណត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ ពាក្យ "អាវុធផលិតជាឯកជន" នេះ មិនត្រូវរាប់បញ្ចូលទាំងអាវុធដែលផលិត ឬដំឡើងដោយបុគ្គលដែលមានអាជ្ញាបណ្ណស្របតាមមាត្រា 122 ក្នុងដំណើរការសកម្មភាពអាជីវកម្មរបស់ពួកគេនោះឡើយ។

មាត្រា 26 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលនិយមន័យពាក្យ "ចុងចម្លើយ" ហើយបញ្ចូលជំនួសដោយនិយមន័យចំនួន 3 ដូចខាងក្រោម៖-

"ឧបករណ៍ជំរុញការកេះកៃបាញ់រហ័ស" គឺជា៖ (i) ឧបករណ៍បញ្ជាដោយដៃដំណើរការដោយថាមពល ឬឧបករណ៍អេឡិចត្រូនិកណាមួយ ដែលរចនាឡើងដើម្បីបង្កើនល្បឿនបាញ់របស់អាវុធពាក់កណ្តាលស្វ័យប្រវត្តិ នៅពេលដែលវាត្រូវបានបំពាក់ភ្ជាប់ជាមួយ ឬ (ii) ឧបករណ៍ គ្រឿងបង្គុំ ឬបណ្តុំគ្រឿងបង្គុំផ្សេងទៀតណាមួយដែលរចនាឡើងដើម្បីបង្កើនល្បឿនបាញ់របស់អាវុធពាក់កណ្តាលស្វ័យប្រវត្តិឱ្យលឿនជាងល្បឿនបាញ់ស្តង់ដាររបស់វា នៅពេលដែលមិនមានបំពាក់ឧបករណ៍ គ្រឿងបង្គុំ ឬបណ្តុំគ្រឿងបង្គុំបែបនោះ។ ទោះជាយ៉ាងណាក៏ដោយ ករណីនេះមិនត្រូវរាប់បញ្ចូលទាំងការលៃតម្រូវ ឬការប្រើប្រាស់ឧបករណ៍ដើម្បីលៃតម្រូវទម្ងន់កេះកៃរបស់អាវុធ ឬការលៃតម្រូវ ឬការផ្លាស់ប្តូរវីស៊ីរបង់កាំភ្លើងនៅក្នុងអាវុធនោះឡើយ។

"តួកាំភ្លើង" គឺជាផ្នែកនៃកាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយ ដែលមានប្រអប់ផ្ទុក ឬមានរចនាសម្ព័ន្ធសម្រាប់គ្រឿងបង្គុំ ចម្បងដែលបានរចនាឡើងដើម្បីបិទ ឬភ្ជិតកន្ទុយកាណុង មុនពេលចាប់ផ្តើមបាញ់ ទោះបីជាត្រូវការកន្លាស់ ឬឧបករណ៍ភ្ជាប់ផ្សេងទៀត ដើម្បីភ្ជាប់គ្រឿងទាំងនោះទៅនឹងប្រអប់ផ្ទុក ឬរចនាសម្ព័ន្ធនោះក៏ដោយ។ គ្រឿងបង្គុំទាំងនេះណាមួយដែលសម្គាល់ដោយលេខស៊េរីរបស់អ្នកនាំចូល ឬរបស់ក្រុមហ៊ុនផលិត ត្រូវសន្មតថាជាតួកាំភ្លើងនៃអាវុធនោះ លើកលែងតែមានការសម្រេចជាផ្លូវការដោយការិយាល័យគ្រប់គ្រងគ្រឿងស្រវឹង ថ្នាំជក់ អាវុធ និងគ្រឿងផ្ទុះ (ATF) នៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ឬមានភស្តុតាងគួរឱ្យទុកចិត្តផ្សេងទៀតដែលផ្ទុយពីនេះ។

"ចុងចម្លើយ" ដូចដែលបានប្រើប្រាស់នៅក្នុងមាត្រា 131R ដល់មាត្រា 131Y ទាំងស្រុង គឺជាបុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណថាជាចុងចម្លើយនៅក្នុងពាក្យបណ្តឹងមួយ ដែលជាកម្មវត្ថុស្នើសុំចេញដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរប្រឆាំងនឹងខ្លួន។

មាត្រា 27 មាត្រា 121 នៃជំពូក 140 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" នៅត្រង់បន្ទាត់ទី 136, 139, 140 និង 147 រាល់ពេលដែលពាក្យនេះលេចឡើង ហើយជំនួសមកវិញនូវពាក្យ៖ "អាវុធ" ដូចខាងក្រោម នៅត្រង់គ្រប់កន្លែងទាំងនោះ។

មាត្រា 28 មាត្រា 121 នៃជំពូក 140 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយដាក់បញ្ចូលនិយមន័យពាក្យ "កាំភ្លើងគ្រាប់ប្រាយកាត់កាណុង" បន្ទាប់ពីនិយមន័យចំនួនពីរដូចខាងក្រោម៖-

"ការរក្សាទុកដោយសុវត្ថិភាពក្នុងប្រអប់ចាក់សោ" គឺជាការរក្សាទុកដោយសុវត្ថិភាពក្នុងប្រអប់ផ្ទុកណាមួយ ដែលអាចបើកសោបានតែដោយការប្រើសោ កូដសម្ងាត់ ឬមធ្យោបាយប្រហាក់ប្រហែលគ្នាតែប៉ុណ្ណោះ រួមទាំងនៅក្នុងយានយន្តដែលគ្មានមនុស្សជិះ ឃ្លុបក្រោយនៃរថយន្តដែលបានចាក់សោជិត និងមិនអាចចូលទៅយកបានពីកាប៊ីនអ្នកដំណើរ ប្រអប់កណ្តាលក្នុងរថយន្តដែលបានចាក់សោជិត ឬប្រអប់តាប្លូរថយន្តដែលបានចាក់សោជិត ហើយសម្រាប់គោលបំណងនៃភ្នាក់ងារដឹកជញ្ជូនសាធារណៈ ក្នុងដំណើរការដឹកជញ្ជូនអាវុធជាលក្ខណៈធម្មតានិងទូទៅ គឺការចាក់សោរាំងខ្ទប់មិនឱ្យចូលទៅកាន់តំបន់ណាមួយដែលមានផ្ទុកអាវុធ។

"ស្ប្រ៉ាយការពារខ្លួន" គឺជាស្ប្រ៉ាយគីមីបង្ហូរទឹកភ្នែក ស្ប្រ៉ាយម្ទេស ឬឧបករណ៍ ឬសម្ភារៈណាមួយដែលមានផ្ទុក បាញ់ចេញ ឬបញ្ចេញនូវសារធាតុរាវ ឧស្ម័ន ម្សៅ ឬសារធាតុផ្សេងទៀត ដែលរចនាឡើងដើម្បីធ្វើឱ្យបាត់បង់សមត្ថភាព។

មាត្រា 29 មាត្រា 121 នៃជំពូក 140 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយដាក់បញ្ចូលបន្ទាប់ពីនិយមន័យពាក្យ "ពាក់កណ្តាលស្វ័យប្រវត្តិ" នូវនិយមន័យដូចខាងក្រោម៖ -

"ការវាយលេខស៊េរី" គឺជាដំណើរការនៃការឆ្លាក់ ការចាក់ពុម្ព ឬការបង្កប់ភ្ជាប់ជាអចិន្ត្រៃយ៍នូវលេខស៊េរីតែមួយគត់ឱ្យឃើញច្បាស់លាស់នៅលើគ្រោងឬ តួកាំភ្លើង។ លេខស៊េរីនោះត្រូវតែដាក់ក្នុងលក្ខណៈមួយដែលមិនងាយរងការលុបបំបាត់ ការកែប្រែ ឬការដកចេញបានឡើយ ហើយត្រូវឆ្លាក់ ចាក់ពុម្ព ឬបង្កប់ជាអចិន្ត្រៃយ៍ក្នុងជម្រៅមិនតិចជាង 0.003 អ៊ីញឡើយ ហើយមានទំហំអក្សរពុម្ពមិនតូចជាង 1/16 អ៊ីញឡើយ។ បន្ថែមលើនេះ ការវាយលេខស៊េរីលើអាវុធ គ្រោង និងតួកាំភ្លើងដែលផលិតឡើងពីសារធាតុអលោហៈ ត្រូវធ្វើឡើងដោយការប្រើប្រាស់បន្ទះលោហៈដែលបង្កប់ភ្ជាប់ជាអចិន្ត្រៃយ៍ទៅក្នុងសាច់សារធាតុនៃគ្រោង ឬតួកាំភ្លើងនោះ។

មាត្រា 30 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយលុបចោលនិយមន័យពាក្យ "ឧបករណ៍បង្វិលកៃ" ហើយបញ្ចូលជំនួសដោយនិយមន័យចំនួន 5 ដូចខាងក្រោម៖-

"ឧបករណ៍កែកៃអាវុធ" គឺជាការកែប្រែណាមួយដែលធ្វើឱ្យកៃអាវុធដំណើរការបាញ់ម្តងហើយម្តងទៀត រួមមានជាអាទិ៍ ឧបករណ៍បង្វិលកៃ កៃគូ និងឧបករណ៍ពន្លឿនកៃនោះឡើយ។

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

“អាវុធមិនអាចរកឃើញ” (i) គឺជាអាវុធណាមួយ ដែលបន្ទាប់ពីការដោះដងកាន់ស្វ័យកាំភ្លើង និងបង់គ្រាប់ចេញ គឺមិនអាចរកឃើញបានដោយម៉ាស៊ីនស្កែនលោហៈឆ្លងកាត់ ដែលបានក្រិត និងដំណើរការដើម្បីស្វែងរកគំរូសន្តិសុខ ដូចមានចែងនៅក្នុងក្រម 18 U.S.C. មាត្រា 922(p)(2)(C) ឡើយ ឬ (ii)គ្រឿងបង្គុំចម្បងរបស់អាវុធដូចមានចែងនៅក្នុងក្រម 18 U.S.C. មាត្រា 922(p)(2)(B) ដែលមិនបង្កើតជាទម្រង់រូបភាពដែលបង្ហាញបានត្រឹមត្រូវពីទម្រង់រូបរាងរបស់គ្រឿងបង្គុំនោះ នៅពេលពិនិត្យដោយឧបករណ៍ស្កែនរកដែលប្រើប្រាស់ជាទូទៅនៅតាមអគារសាធារណៈដែលមានការការពារសន្តិសុខ និងតាមស្ថានីយដឹកជញ្ជូន។

“គ្រោង ឬតួកាំភ្លើងមិនទាន់ផលិតរួច” គឺជាវត្ថុដែលបានមកពីការដំ ការចាក់ពុម្ព ការបោះពុម្ព ការរុញបញ្ចេញ តួបង្គុំកែច្នៃដោយម៉ាស៊ីន ឬវត្ថុប្រហាក់ប្រហែលគ្នាណាមួយដែល៖ (i) បានឈានដល់ដំណាក់កាលមួយនៅក្នុងការផលិត ដែលវាអាចត្រូវបានធ្វើចប់រួចរាល់ ឬដំឡើងបានដោយងាយ ដើម្បីដំណើរការជាគ្រោង ឬតួកាំភ្លើង ឬ (ii) ត្រូវបានដាក់លក់លើទីផ្សារ ឬលក់ជូនសាធារណជន ដើម្បីក្លាយជា ឬប្រើប្រាស់ជាគ្រោង ឬតួកាំភ្លើងដែលដំណើរការបានពិតប្រាកដមួយ នៅពេលបានធ្វើចប់រួចរាល់ ឬដំឡើងរួច។ ទោះជាយ៉ាងណាក៏ដោយ ពាក្យ “គ្រោង ឬតួកាំភ្លើងមិនទាន់ផលិតរួច” នេះ មិនត្រូវរាប់បញ្ចូលទាំងគ្រឿងបង្គុំដែលបានរចនាឡើង និងមានបំណងប្រើប្រាស់ក្នុងអាវុធបុរាណនោះឡើយ។

“អាវុធមិនអាចតាមដានបាន” គឺជាអាវុធដែលមិនត្រូវបានវាយលេខស៊េរី ឬជាអាវុធដែលលេខស៊េរី ឬលេខសម្គាល់ផ្សេងទៀតរបស់វាត្រូវបានដកចេញ កោសលុប កែប្រែ លុបបំបាត់ ឬធ្វើឱ្យខូចទ្រង់ទ្រាយក្នុងលក្ខណៈណាមួយ។

“លេខស៊េរីមានសុពលភាព” គឺជាលេខសម្គាល់ដែលត្រូវបាន៖ (i) ដាក់នៅលើអាវុធដោយអ្នកទទួលបានអាជ្ញាបណ្ណពីសហព័ន្ធ ដែលមានសិទ្ធិអំណាចក្នុងការវាយលេខស៊េរីលើអាវុធ ឬអនុលោមតាមច្បាប់របស់រដ្ឋណាមួយ ឬស្របតាមក្រម 26 (26 U.S.C.) មាត្រា 5842 និងបទប្បញ្ញត្តិដែលបានប្រកាសឱ្យប្រើប្រាស់ក្រោមច្បាប់នោះ ឬ (ii) ជាលេខស៊េរីដែលត្រូវបានចេញឱ្យដោយប្រធានការិយាល័យគ្រប់គ្រងគ្រឿងស្រវឹង ថ្នាំជក់ អាវុធ និងគ្រឿងផ្ទុះ (ATF) នៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក ឬក្រសួងសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ។

មាត្រា 31 មាត្រា 121 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយលុបចោលបន្ទាត់ទី175 ដល់ 192 ទាំងស្រុង។

មាត្រា 32 ជំពូក 140 នេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយការបញ្ចូលបន្ទាប់ពីមាត្រា 121A នូវមាត្រាចំនួន 5 ដូចតទៅនេះ៖-

មាត្រា 121B (a)(1) នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវអភិវឌ្ឍនិងគ្រប់គ្រងប្រព័ន្ធចុះបញ្ជីអាវុធតាមប្រព័ន្ធអេឡិចត្រូនិកតាមពេលវេលាជាក់ស្តែង។ រាល់អាវុធទាំងអស់ដែលត្រូវបានកាន់កាប់ ផលិត ឬដំឡើងនៅក្នុងរដ្ឋម៉ាសាឈូសិតត្រូវតែចុះបញ្ជីឱ្យបានត្រឹមត្រូវស្របតាមមាត្រានេះ។ ការចុះបញ្ជីអាវុធ ត្រូវធ្វើឡើងឱ្យបានរួចរាល់តាមរយៈប្រព័ន្ធចុះបញ្ជីអាវុធតាមប្រព័ន្ធអេឡិចត្រូនិកតាមពេលវេលាជាក់ស្តែង ដែលត្រូវបានអភិវឌ្ឍ និងគ្រប់គ្រងដោយនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ហើយត្រូវរួមបញ្ចូលជាអាទិ៍នូវព័ត៌មានដូចខាងក្រោម៖ (i) ឈ្មោះ អាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងរបស់អ្នកចុះបញ្ជី (ii) ប្រភេទអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាត លេខអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាត និងកាលបរិច្ឆេទផុតកំណត់របស់អ្នកចុះបញ្ជី ឬឯកសារបញ្ជាក់ពីការលើកលែងស្របតាមមាត្រា 129C, (iii) ប្រភេទអាវុធ (iv) កាលបរិច្ឆេទទទួលបានអាវុធនោះ (v) ឈ្មោះ និងអាសយដ្ឋាននៃប្រភពដែលទទួលបានអាវុធនោះ រួមទាំងឈ្មោះ ព្រមទាំងអាសយដ្ឋានរបស់អ្នកចុះបញ្ជីមុន (ប្រសិនបើមាន) (vi) ថាអាវុធនោះជាអាវុធផលិតជាឯកជន ឬយ៉ាងណា និង (vii) សេចក្តីថ្លែងការណ៍ចុះហត្ថលេខាដោយអ្នកចុះបញ្ជីក្រោមទោសទណ្ឌនៃការផ្តល់សក្ខីកម្មក្លែងក្លាយ ថាពួកគេទទួលបានអាជ្ញាបណ្ណលិខិតអនុញ្ញាត ឬការលើកលែងដោយត្រឹមត្រូវក្រោមច្បាប់រដ្ឋម៉ាសាឈូសិតនេះ ហើយមិនត្រូវបានហាមឃាត់មិនឱ្យធ្វើជាម្ចាស់ ឬកាន់កាប់អាវុធតាមរូបភាពណាមួយផ្សេងទៀតឡើយ។

(2) ការចុះបញ្ជីអាវុធ ត្រូវធ្វើឡើងឱ្យបានរួចរាល់នៅពេលនាំចូល ទិញ ទទួលបាន ផលិត ឬដំឡើងអាវុធ។ ទោះជាយ៉ាងណាក៏ដោយអាវុធអាចនឹងត្រូវ៖ (i) ចុះបញ្ជីក្នុងរយៈពេល 60 ថ្ងៃ ប្រសិនបើត្រូវបាននាំចូលដោយនិវាសនជនថ្មីនៃរដ្ឋម៉ាសាឈូសិតនេះ (ii) ចុះបញ្ជីក្នុងរយៈពេល 7 ថ្ងៃ ប្រសិនបើត្រូវបាននាំចូលដោយអ្នកចែកចាយមានអាជ្ញាបណ្ណ ជាងធ្វើអាវុធ បុគ្គលចែកចាយ ឬក្រុមហ៊ុនផលិត (iii) ចុះបញ្ជីក្នុងរយៈពេល 60 ថ្ងៃ ប្រសិនបើទទួលបានដោយអ្នកស្នងមរតក ឬអ្នកទទួលមរតកសាសន៍ តាមរយៈការបែងចែកទ្រព្យសម្បត្តិមរតក ឬ (iv) ចុះបញ្ជីក្នុងរយៈពេល 7 ថ្ងៃ ប្រសិនបើត្រូវបានផលិត ឬដំឡើងជាអាវុធផលិតជាឯកជន។

(b) រាល់ការជួញដូរអាវុធទាំងអស់នៅក្នុងរដ្ឋនេះ រួមមានជាអាទិ៍ រាល់ការទិញ ការលក់ ការជួល ការជួលតាមកិច្ចសន្យា ការខ្ចី ឬការផ្ទេរកម្មសិទ្ធិតាមរូបភាពផ្សេងទៀត ត្រូវតែរាយការណ៍ទៅកាន់ប្រព័ន្ធចុះបញ្ជីអាវុធតាមប្រព័ន្ធអេឡិចត្រូនិក។ រាល់ការជួញដូរអាវុធទាំងអស់ ត្រូវតែរាយការណ៍ដោយភាគីទាំងអស់នៃការជួញដូរ តាមរយៈប្រព័ន្ធចុះបញ្ជីអាវុធតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងរយៈពេល 7 ថ្ងៃ គិតចាប់ពីថ្ងៃលក់ ជួលរយៈពេលវែង ខ្ចី ឬផ្ទេរកម្មសិទ្ធិតាមរូបភាពផ្សេងទៀតនោះ។ ទោះជាយ៉ាងណាក៏ដោយ មិនតម្រូវឱ្យមានការរាយការណ៍ចំពោះការឱ្យខ្ចីអាវុធទៅឱ្យបុគ្គលដែលទទួលបានអាជ្ញាបណ្ណត្រឹមត្រូវ ឬបុគ្គលដែលត្រូវបានលើកលែងរយៈពេលតិចជាង 7 ថ្ងៃឡើយ។

(c) រាល់ការបាត់បង់ ឬការលួចអាវុធណាមួយ ត្រូវតែរាយការណ៍ដោយម្ចាស់អាវុធនោះតាមរយៈប្រព័ន្ធចុះបញ្ជីអាវុធតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងរយៈពេល 7 ថ្ងៃ ជូនទៅអាជ្ញាធរផ្តល់អាជ្ញាបណ្ណ ឬក្រសួងប៉ូលិសរដ្ឋ ដែលជាកន្លែងចុះបញ្ជីអាវុធ និងជូនទៅក្រសួងសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ។ របាយការណ៍បែបនោះ ត្រូវរួមបញ្ចូលជាអាទិ៍នូវបរិយាយពេញលេញអំពីអាវុធ រួមទាំងម៉ាក ម៉ូដែល លេខស៊េរី និងទំហំមុខកាត់កាណុង ព្រមទាំងបញ្ជាក់ថាតើវាជាអាវុធមានសមត្ថភាពផ្ទុកគ្រាប់ខ្ពស់ ឬយ៉ាងណា។ ប្រព័ន្ធចុះបញ្ជីអាវុធតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តល់ការជូនដំណឹងជាស្វ័យប្រវត្តិ និងភ្លាមៗទៅអាជ្ញាធរផ្តល់អាជ្ញាបណ្ណនៅក្នុងប្រជុំជន ឬទីក្រុងដែលម្ចាស់អាវុធនោះរស់នៅ និងជាកន្លែងដែលអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតត្រូវបានចេញជូន។

(d) មាត្រានេះមិនត្រូវអនុវត្តចំពោះអាវុធទាំងឡាយណាដែល៖ (i) កំពុងត្រូវបានប្រគល់ជូនអាជ្ញាធរអនុវត្តច្បាប់ក្នុងគោលបំណងតែមួយគត់គឺដើម្បីកម្ទេចចោល (ii) ស្ថិតក្រោមការកាន់កាប់ដោយភ្នាក់ងារដឹកជញ្ជូនសាធារណៈ និងនិយោជិត ឬតំណាងដែលទទួលបានការអនុញ្ញាតត្រឹមត្រូវរបស់ពួកគេ ក្នុងពេលកំពុងបំពេញការងារដឹកជញ្ជូនអាវុធជាទំនិញធម្មតានិងទូទៅ សម្រាប់អតិថិជនដែលមាន

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

អាជ្ញាបណ្ណអនុញ្ញាតឱ្យមានការដឹកជញ្ជូនបែបនោះ (iii) ស្ថិតក្រោមការកាន់កាប់ដោយបុគ្គលទាំងឡាយដែលកំពុងធ្វើដំណើរឆ្លងកាត់រដ្ឋម៉ាសាឈូសិតនេះដោយស្របច្បាប់ ដោយស្ថិតក្រោមការថែទាំ និងការគ្រប់គ្រងរបស់ម្ចាស់អាវុធដែលជាអនិវាសនជន។ ទោះជាយ៉ាងណាក៏ដោយ អាវុធទាំងនោះត្រូវតែរក្សាទុកឱ្យបានត្រឹមត្រូវស្របតាមមាត្រា 131C និងមាត្រា 131L, (iv) ជាទ្រព្យសម្បត្តិរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ឬ (v) ត្រូវបានផលិតឡើងដោយក្រុមហ៊ុនផលិតទទួលបានអាជ្ញាបណ្ណពីសហព័ន្ធ ដែលមិនមែនសម្រាប់លក់នៅក្នុងរដ្ឋម៉ាសាឈូសិតឡើយ។

(e) បុគ្គលណាក៏ដោយដែលខកខានមិនបានចុះបញ្ជីអាវុធ ដោយល្មើសនឹងកថាខណ្ឌ (a) ឬខកខានមិនបានរាយការណ៍អំពីប្រតិបត្តិការ ការបាត់បង់ ឬការលួច ដោយល្មើសនឹងកថាខណ្ឌ (b) ឬ (c) ត្រូវផ្តន្ទាទោសដូចខាងក្រោម៖ (i) ពិន័យជាប្រាក់មិនលើសពី 1,000 ដុល្លារ សម្រាប់បទល្មើសលើកដំបូង (ii) ពិន័យជាប្រាក់មិនលើសពី 7,500 ដុល្លារ ឬផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ 6 ខែ ឬទាំងពិន័យជាប្រាក់ ទាំងដាក់ពន្ធនាគារ សម្រាប់បទល្មើសលើកទីពីរ ឬ (iii) ពិន័យជាប្រាក់មិនលើសពី 10,000 ដុល្លារ ឬផ្តន្ទាទោសដាក់ពន្ធនាគារមិនតិចជាង 1 ឆ្នាំ និងមិនលើសពី 5 ឆ្នាំ ឬទាំងពិន័យជាប្រាក់ ទាំងជាប់ពន្ធនាគារ សម្រាប់បទល្មើសលើកទីបី ឬបទល្មើសជាបន្តបន្ទាប់។ ការខកខានមិនបានរាយការណ៍ ក៏ត្រូវជាមូលហេតុនៃការព្យួរ ឬការដកហូតជាអចិន្ត្រៃយ៍នូវអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតរបស់បុគ្គលនោះផងដែរ។

(f) ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ត្រូវប្រកាសឱ្យប្រើប្រាស់បទប្បញ្ញត្តិសម្រាប់ការអនុវត្តមាត្រានេះ ដែលត្រូវរួមបញ្ចូលទាំងព័ត៌មានចាំបាច់សម្រាប់ការចុះបញ្ជី និងការរាយការណ៍អំពីអាវុធ ការជូនដំណឹងជាសាធារណៈ និងយុទ្ធនាការផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងអំពីមាត្រានេះ។

មាត្រា 121C (a) រាល់អាវុធទាំងអស់ត្រូវតែមានលេខស៊េរីដែលអនុលោមតាមលក្ខខណ្ឌនៃមាត្រានេះ។ ដើម្បីបំពេញតាមតម្រូវការវាយលេខស៊េរី រាល់អាវុធទាំងអស់ត្រូវតែឆ្លាក់ ចាក់ពុម្ព ឬបង្កប់ភ្ជាប់ជាអចិន្ត្រៃយ៍នូវលេខស៊េរីតែមួយគត់ឱ្យបានច្បាស់នៅលើគ្រោង ឬតួកាំភ្លើង។ លេខស៊េរីនោះត្រូវតែដាក់ក្នុងលក្ខណៈមួយដែលមិនងាយរងការលុបបំបាត់ ការកែប្រែ ឬការដកចេញបានឡើយ ហើយត្រូវឆ្លាក់ចាក់ពុម្ព ឬបង្កប់ភ្ជាប់ជាអចិន្ត្រៃយ៍ក្នុងជម្រៅមិនតិចជាង 0.003 អ៊ីញ និងមានទំហំអក្សរពុម្ពមិនតូចជាង1/16 អ៊ីញឡើយ។ បន្ថែមលើនេះ ការវាយលេខស៊េរីលើអាវុធគ្រោង និងតួកាំភ្លើងដែលផលិតឡើងពីសារធាតុអលោហៈ ត្រូវធ្វើឡើងដោយការប្រើប្រាស់បន្ទះលោហៈដែលត្រូវបានបង្កប់ភ្ជាប់ជាអចិន្ត្រៃយ៍ទៅក្នុងសារធាតុនៃគ្រោង ឬតួកាំភ្លើងនោះ។

(b) គ្មានបុគ្គលណាម្នាក់ត្រូវកាន់កាប់ ផលិត ឬដំឡើង បញ្ជាឱ្យផលិតឬដំឡើង ទិញ ដាក់លក់ លក់ ឬផ្ទេរកម្មសិទ្ធិ ឬនាំចូលតាមរូបភាពផ្សេងទៀតដោយចេតនា នូវអាវុធមិនអាចតាមដានបាននៅក្នុងរដ្ឋម៉ាសាឈូសិតឡើយ។ ទោះយ៉ាងណាក៏ដោយ អាវុធដែលកាន់កាប់ដោយស្របច្បាប់ ត្រូវបាននាំចូល ឬទទួលបានដោយ៖ (i) និវាសនជនថ្មីដែលផ្លាស់ប្តូរទីលំនៅចូលមកក្នុងរដ្ឋនេះ ឬទទួលបានដោយអ្នកស្នងមរតក ឬអ្នកទទួលមរតកសាសន៍ តាមរយៈការបែងចែកទ្រព្យសម្បត្តិមរតក ត្រូវតែវាយលេខស៊េរីឱ្យបានរួចរាល់ក្នុងរយៈពេល 60 ថ្ងៃ គិតចាប់ពីថ្ងៃនាំចូល ឬទទួលបាន និង (ii) ឈ្មួញអាវុធមានអាជ្ញាបណ្ណ ជាងធ្វើកាំភ្លើង អ្នកចែកចាយ ឬក្រុមហ៊ុនផលិត ត្រូវតែវាយលេខស៊េរីឱ្យបានរួចរាល់ក្នុងរយៈពេល 7 ថ្ងៃ គិតចាប់ពីថ្ងៃនាំចូល ឬទទួលបាន។

(c) គ្មានបុគ្គលណាម្នាក់ផលិត ឬដំឡើងអាវុធផលិតជាឯកជន ដោយគ្មាន៖ (i) ការទទួលបានលេខស៊េរីតែមួយគត់ពីនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ មុនពេលផលិត ឬដំឡើង (ii) ការវាយលេខស៊េរីលើអាវុធនោះដោយប្រើប្រាស់លេខស៊េរីដែលទទួលបានក្នុងអំឡុងពេលផលិត ឬដំឡើង និង (iii) ការចុះបញ្ជីអាវុធនោះនៅនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ស្របតាមមាត្រា 121B ក្នុងរយៈពេល 7 ថ្ងៃ គិតចាប់ពីថ្ងៃផលិត ឬដំឡើងអាវុធនោះរួចរាល់ឡើយ។

(d) គ្មានបុគ្គលណាម្នាក់អាចផលិត ឬដំឡើងអាវុធផលិតជាឯកជន ដែលមិនអនុលោមតាមរាល់បទប្បញ្ញត្តិសន្តិសុខនិងសុវត្ថិភាពពាក់ព័ន្ធរបស់រដ្ឋនិងសហព័ន្ធនោះឡើយ។

(e) នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ ព្រហ្មទណ្ឌ ត្រូវអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធស្នើសុំលេខស៊េរី ដើម្បីទទួល កត់ត្រា និងដំណើរការសំណើសុំលេខស៊េរីតែមួយគត់តាមប្រព័ន្ធអេឡិចត្រូនិក អនុលោមតាមមាត្រានេះ។ ប្រព័ន្ធស្នើសុំលេខស៊េរី ត្រូវតែធ្វើសមាហរណកម្មជាមួយនឹងប្រព័ន្ធចុះបញ្ជីអាវុធតាមប្រព័ន្ធអេឡិចត្រូនិក ដែលគ្រប់គ្រងដោយនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ស្របតាមមាត្រា 121B ហើយត្រូវតែមានអាចចុះបញ្ជីអាវុធទាំងអស់ និងរាយការណ៍អំពីប្រតិបត្តិការអាវុធ ស្របតាមមាត្រា 121B ខាងលើ ព្រមទាំងធានាថា រាល់ទិន្នន័យអំពីអាវុធផលិតជាឯកជន ត្រូវមានជាស្រេចសម្រាប់ការប្រមូលទិន្នន័យ ស្របតាមមាត្រា 121E និងសម្រាប់គោលបំណងតាមដានរកប្រភពស្របតាមមាត្រា 131Q។

(f) សំណើសុំលេខស៊េរីតែមួយគត់តាមរយៈប្រព័ន្ធស្នើសុំលេខស៊េរី ត្រូវរួមបញ្ចូលនូវព័ត៌មានអំពីបុគ្គលដែលស្នើសុំលេខស៊េរីតែមួយគត់នោះ សេចក្តីបញ្ជាក់ទៅលើសំណើសម្រាប់អាវុធផលិតជាឯកជន ប្រភេទនៃអាវុធដែលត្រូវវាយលេខស៊េរី ព្រមទាំងមធ្យោបាយនិងវិធីក្នុងការផលិតអាវុធនោះ ប្រសិនបើជាអាវុធផលិតជាឯកជន។

(g) លក្ខខណ្ឌនៃមាត្រានេះ មិនត្រូវអនុវត្តចំពោះអាវុធទាំងឡាយណាដែល៖ (i) កំពុងត្រូវបានប្រគល់ជូនអាជ្ញាធរអនុវត្តច្បាប់ក្នុងគោលបំណងកម្ទេចចោលតែប៉ុណ្ណោះ (ii) ស្ថិតក្រោមការកាន់កាប់ដោយភ្នាក់ងារដឹកជញ្ជូនសាធារណៈ និងនិយោជិត ឬតំណាងទទួលបានការអនុញ្ញាតត្រឹមត្រូវពីពួកគេ ក្នុងពេលកំពុងបំពេញការងារដឹកជញ្ជូនអាវុធជាទំនិញធម្មតានិងទូទៅ សម្រាប់អតិថិជនដែលមានអាជ្ញាបណ្ណអនុញ្ញាតឱ្យមានការដឹកជញ្ជូនបែបនោះ (iii) ស្ថិតក្រោមការកាន់កាប់ដោយបុគ្គលទាំងឡាយដែលកំពុងធ្វើដំណើរឆ្លងកាត់រដ្ឋម៉ាសាឈូសិតនេះដោយស្របច្បាប់ ស្ថិតក្រោមការថែទាំ និងការគ្រប់គ្រងរបស់ម្ចាស់អាវុធដែលជាអនិវាសនជន ប៉ុន្តែអាវុធទាំងនោះត្រូវតែរក្សាទុកឱ្យបានត្រឹមត្រូវស្របតាមមាត្រា 131C និងមាត្រា 131L, (iv) ជាទ្រព្យសម្បត្តិរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក (v) ផលិតឡើងដោយក្រុមហ៊ុនផលិតដែលទទួលបានអាជ្ញាបណ្ណពីសហព័ន្ធ មិនមែនសម្រាប់លក់នៅក្នុងរដ្ឋម៉ាសាឈូសិតឡើយ ឬ (vi) ផលិតមុនថ្ងៃទី 22 ខែតុលា ឆ្នាំ 1968។

(h) ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវប្រកាសឱ្យប្រើប្រាស់នូវវិធាននិងបទប្បញ្ញត្តិសម្រាប់ការអនុវត្តមាត្រានេះ រួមទាំងលក្ខខណ្ឌបច្ចេកទេសសម្រាប់ការវាយលេខស៊េរីលើអាវុធ នីតិវិធីសម្រាប់ការស្នើសុំលេខស៊េរី និងនីតិវិធីសម្រាប់ការជូនដំណឹងជាសាធារណៈ ព្រមទាំងយុទ្ធនាការផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងអំពីមាត្រានេះ។

# អត្ថបទទាំងស្រុង (ត)

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

មាត្រា 121D (a) គ្មានបុគ្គលណាម្នាក់ប្រើប្រាស់ម៉ាស៊ីនបោះពុម្ព 3D ឬម៉ាស៊ីនក្រឡឹងបញ្ជាដោយកុំព្យូទ័រ ដើម្បីផលិត ឬដំឡើងអាវុធណាមួយនៅក្នុងរដ្ឋម៉ាសាឈូសិត ដោយគ្មានអាជ្ញាបណ្ណដែលមានសុពលភាពក្នុងការកាន់កាប់អាវុធស្របតាមមាត្រា 131 ឡើយ។

(b) គ្មានបុគ្គលណាម្នាក់លក់ ដាក់លក់ ឬផ្ទេរកម្មសិទ្ធិម៉ាស៊ីនបោះពុម្ព 3D ឬម៉ាស៊ីនក្រឡឹងបញ្ជាដោយកុំព្យូទ័រ ដែលមានមុខងារចម្បង ឬមុខងារសម្រាប់ផលិត ឬដំឡើងអាវុធ ទៅឱ្យបុគ្គលណាម្នាក់នៅក្នុងរដ្ឋម៉ាសាឈូសិតឡើយ។ ម៉ាស៊ីនបោះពុម្ព 3D ឬម៉ាស៊ីនក្រឡឹង បញ្ជាដោយកុំព្យូទ័រ ត្រូវបានចាត់ទុកថាមានមុខងារចម្បង ឬមុខងារសម្រាប់ការផលិត ឬការដំឡើងអាវុធ ប្រសិនបើម៉ាស៊ីនបោះពុម្ព ឬម៉ាស៊ីននោះត្រូវបានផ្សព្វផ្សាយពាណិជ្ជកម្ម ធ្វើទីផ្សារ ឬជំរុញការលក់ ដើម្បីផលិត ឬដំឡើងអាវុធ ដោយមិនគិតថាតើម៉ាស៊ីនបោះពុម្ព ឬម៉ាស៊ីននោះ ត្រូវបានពិពណ៌នា ឬចាត់ថ្នាក់តាមរូបភាពផ្សេងទៀតថាមានមុខងារដទៃ ឬជាម៉ាស៊ីនបោះពុម្ព ឬម៉ាស៊ីនសម្រាប់ប្រើប្រាស់ទូទៅនោះឡើយ។

(c) មាត្រានេះ មិនត្រូវអនុវត្តចំពោះម៉ាស៊ីនបោះពុម្ព 3D ឬម៉ាស៊ីនក្រឡឹងបញ្ជាដោយកុំព្យូទ័រទាំងឡាយណាដែល៖ (i) ស្ថិតក្រោមការកាន់កាប់ដោយមន្ទីរពិសោធន៍កោសល្យវិច័យ (ii) កំពុងត្រូវបានប្រគល់ជូនអាជ្ញាធរអនុវត្តច្បាប់ក្នុងគោលបំណងកម្ទេចចោលតែប៉ុណ្ណោះ (iii) ស្ថិតក្រោមការកាន់កាប់ដោយភ្នាក់ងារដឹកជញ្ជូនសាធារណៈ និងនិយោជិត ឬតំណាងទទួលបានការអនុញ្ញាតត្រឹមត្រូវរបស់ពួកគេក្នុងពេលកំពុងបំពេញការងារដឹកជញ្ជូនអាវុធជាទំនិញធម្មតា និងទូទៅ សម្រាប់អតិថិជនដែលមានអាជ្ញាបណ្ណអនុញ្ញាតឱ្យមានការដឹកជញ្ជូនបែបនោះ (iv) ស្ថិតក្រោមការកាន់កាប់ដោយ ឬត្រូវបានលក់ទៅឱ្យក្រុមហ៊ុនផលិតអាវុធដែលទទួលបានអាជ្ញាបណ្ណពីសហព័ន្ធ ឬ (v) ជាទ្រព្យសម្បត្តិរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

(d) ការល្មើសនឹងមាត្រានេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមិនលើសពី 1 ឆ្នាំ ឬពិន័យជាប្រាក់មិនលើសពី 5,000 ដុល្លារ ក្នុងអាវុធមួយដើម និងក្នុងមួយករណីល្មើស ឬទាំងទោសពិន័យជាប្រាក់ទាំងទោសដាក់ពន្ធនាគារ។

មាត្រា 121E (a) នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដោយសហការជាមួយការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ និងការិយាល័យប្រតិបត្តិសេវាបច្ចេកវិទ្យានិងសន្តិសុខ ត្រូវប្រមូល ចងក្រង និងបោះពុម្ពផ្សាយទិន្នន័យ និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការប្រើប្រាស់អាវុធនៅក្នុងរដ្ឋម៉ាសាឈូសិតនេះ។

(b) ភ្នាក់ងាររដ្ឋ និងភ្នាក់ងារមូលដ្ឋាន រួមមានជាអាទិ៍ ក្រសួងប៉ូលិសរដ្ឋ អាជ្ញាធរផ្តល់អាជ្ញាបណ្ណ និងភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌដទៃទៀត ដូចមានចែងក្នុងមាត្រា 167 នៃជំពូក 6 ត្រូវតែផ្តល់លទ្ធភាពទទួលបានព័ត៌មានទាន់ពេលវេលា ដែលស្នើសុំដោយនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ស្របតាមមាត្រានេះ។

(c) នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវផ្តល់លទ្ធភាពឱ្យសាធារណជនទូទៅអាចចូលមើលទិន្នន័យមិនបញ្ជាក់អត្តសញ្ញាណបុគ្គល ដោយការបោះពុម្ពផ្សាយនៅលើផ្ទាំងគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធអនឡាញ ដែលបានធ្វើបច្ចុប្បន្នភាពយ៉ាងហោចណាស់រៀងរាល់មួយត្រីមាសម្តង។ ផ្ទាំងគ្រប់គ្រងទិន្នន័យនេះ ត្រូវរួមបញ្ចូលជាអាទិ៍នូវព័ត៌មានដូចជា៖

(1) ទិន្នន័យសរុបដូចខាងក្រោមនេះ ស្តីពីការចេញអាជ្ញាបណ្ណនិងប័ណ្ណអាវុធស្របតាមមាត្រា 129B មាត្រា 131 និងមាត្រា 131F៖

(i) អាយុ ភេទ ពូជសាសន៍ ជាតិពន្ធុ និងក្រុងរស់នៅរបស់អ្នកស្នើសុំអាជ្ញាបណ្ណកាន់កាប់អាវុធ

(ii) អាយុ ភេទ ពូជសាសន៍ ជាតិពន្ធុ និងក្រុងរស់នៅរបស់បុគ្គលទាំងឡាយណាដែលពាក្យស្នើសុំអាជ្ញាបណ្ណកាន់កាប់អាវុធរបស់ពួកគេត្រូវបានបដិសេធ

(iii) អាយុ ភេទ ពូជសាសន៍ ជាតិពន្ធុ និងក្រុងរស់នៅរបស់អ្នកស្នើសុំបណ្ណសម្គាល់អាវុធ និង

(iv) អាយុ ភេទ ពូជសាសន៍ ជាតិពន្ធុ និងក្រុងរស់នៅរបស់បុគ្គលទាំងឡាយណាដែលពាក្យស្នើសុំប័ណ្ណសម្គាល់អាវុធរបស់ពួកគេត្រូវបានបដិសេធ។

(2) ទិន្នន័យសរុបដូចខាងក្រោមអំពីអំពើហិង្សាពាក់ព័ន្ធនឹងអាវុធ រួមមានជាអាទិ៍ បទល្មើសពាក់ព័ន្ធនឹងអាវុធ និងការប៉ុនប៉ងធ្វើអត្តឃាត ឬការធ្វើអត្តឃាតបានសម្រេចដោយប្រើអាវុធ៖

(i) ប្រភេទអំពើហិង្សាពាក់ព័ន្ធនឹងអាវុធ ឧទាហរណ៍ដូចជា ការប៉ុនប៉ងធ្វើអត្តឃាត ឬការធ្វើអត្តឃាតបានសម្រេច មនុស្សឃាត ការបាញ់ប្រហារដោយចៃដន្យ ឬបទល្មើសដទៃទៀតពាក់ព័ន្ធនឹងអាវុធ

(ii) អាយុ ភេទ ពូជសាសន៍ និងជាតិពន្ធុរបស់អ្នកប្រើប្រាស់អាវុធ

(iii) អាយុ ភេទ ពូជសាសន៍ និងជាតិពន្ធុរបស់ជនរងគ្រោះណាម្នាក់ដោយសារអំពើហិង្សាពាក់ព័ន្ធនឹងអាវុធ

(iv) ទីតាំងភូមិសាស្ត្រនៃអំពើហិង្សាពាក់ព័ន្ធនឹងអាវុធ

(v) ស្ថានភាពអាជ្ញាបណ្ណរបស់អ្នកប្រើប្រាស់អាវុធ

(vi) បញ្ជាក់ថាតើអ្នកប្រើប្រាស់អាវុធនោះ នៅពេលកើតហេតុ ត្រូវគេចាត់ទុកថាជាបុគ្គលដែលត្រូវបានហាមឃាត់ ដូចមានចែងនៅក្នុងមាត្រា 121F ដែរឬទេ

(vii) បញ្ជាក់ថាតើអ្នកប្រើប្រាស់អាវុធនោះ ត្រូវបានចាប់ខ្លួនដោយសារហេតុការណ៍នោះដែរឬទេ

(viii) លទ្ធផលនៃការចាត់ចែងការចោទប្រកាន់តាមផ្លូវតុលាការណាមួយ

(ix) បញ្ជាក់ថាតើអាវុធនោះត្រូវបានប្រើប្រាស់ដោយមានការពាក់ព័ន្ធនឹងសកម្មភាពក្រុមក្មេងទំនើងដែលបានស្គាល់ ជម្លោះក្នុងគ្រួសារ ឬការអន្តរាគមន៍ពីប៉ូលិស ឬយ៉ាងណា

(x) ម៉ាក ម៉ូដែល ក្រុមហ៊ុនផលិត និងរដ្ឋ ឬប្រទេសប្រភពដើមរបស់អាវុធដែលពាក់ព័ន្ធនោះ

(xi) ប្រភពដើម ប្រភពទទួលបាន និងទីផ្សារលក់បន្តនៃអាវុធដែលពាក់ព័ន្ធនោះ រួមទាំងការបញ្ជាក់ថាតើវាត្រូវបានទិញពីឈ្មួញមានអាជ្ញាបណ្ណ ឬពីអ្នកលក់ឯកជន ឬយ៉ាងណា

(xii) បញ្ជាក់ថាតើអាវុធដែលពាក់ព័ន្ធនោះ ត្រូវបានបាត់បង់ ត្រូវបានលួច ឬទទួលបានដោយខុសច្បាប់តាមរូបភាពផ្សេងទៀតដែរឬទេ និង

(xiii) បញ្ជាក់ថាតើអាវុធដែលពាក់ព័ន្ធនោះ ជាអាវុធមិនអាចតាមដានរកប្រភព ឬជា

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

អាវុធផលិតជាឯកជនដែរឬទេ រួមទាំងការបញ្ជាក់អំពីរបៀបដែលវាត្រូវបានផលិតឡើងផងដែរ។

(d) នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដោយសហការសម្របសម្រួលជាមួយការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ និងការិយាល័យប្រតិបត្តិសេវាបច្ចេកវិទ្យានិងសន្តិសុខ ត្រូវប្រកាសឱ្យប្រើវិធាននិងបទប្បញ្ញត្តិនានា ដើម្បីធានាបាននូវការប្រមូល ការផ្លាស់ប្តូរ និងការបោះពុម្ពផ្សាយព័ត៌មានស្តីពីការផ្តល់អាជ្ញាបណ្ណអាវុធឱ្យបានទាន់ពេលវេលាស្របតាមមាត្រានេះ។

មាត្រា 121F (a) ក្នុងរយៈពេល 40 ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតអាវុធដែលបានបំពេញរួចរាល់ណាមួយ ដែលត្រូវបានចេញក្រោមមាត្រា 121, 122B, 122D, 129B, 131 ឬ 131F ឬការបន្តសុពលភាពនៃឯកសារទាំងនោះ អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ត្រូវអនុម័តលើពាក្យស្នើសុំ និងចេញលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ ឬ បដិសេធពាក្យស្នើសុំ និងជូនដំណឹងទៅអ្នកស្នើសុំជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការបដិសេធបែបនោះជាលាយលក្ខណ៍អក្សរ។ ទោះជាយ៉ាងណាក៏ដោយ មិនត្រូវមានលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណណាមួយត្រូវបានចេញឡើយ លុះត្រាតែស្នងការប៉ូលិសរដ្ឋបានបញ្ជាក់ទទួលស្គាល់ថា ព័ត៌មានដែលមានស្រាប់បានបង្ហាញថា ការចេញលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណនោះ មិនរំលោភបំពានលើច្បាប់រដ្ឋ ឬច្បាប់សហព័ន្ធឡើយ។

(b) នៅពេលទទួលពាក្យស្នើសុំ អាជ្ញាធរផ្តល់អាជ្ញាបណ្ណត្រូវផ្តល់ជូនអ្នកស្នើសុំនូវបង្កាន់ដៃទទួលមួយ ដែលរួមមាន៖ (i) ឈ្មោះនិងអាសយដ្ឋានរបស់អ្នកស្នើសុំ លេខលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណបច្ចុប្បន្ន និងកាលបរិច្ឆេទផុតកំណត់ (ប្រសិនបើមាន) (ii) កាលបរិច្ឆេទដែលអាជ្ញាធរផ្តល់អាជ្ញាបណ្ណបានទទួលពាក្យស្នើសុំ (iii) ឈ្មោះ អាសយដ្ឋាន និងលេខទូរសព្ទរបស់អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ឬតំណាងរបស់ខ្លួនដែលបានទទួលពាក្យស្នើសុំនោះ (iv) ប្រភេទនៃពាក្យស្នើសុំ និង (v) បញ្ជាក់ថាតើពាក្យស្នើសុំនោះ គឺសម្រាប់លិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណថ្មី ឬសម្រាប់ការបន្តសុពលភាពនៃឯកសារដដែលនោះ ឬយ៉ាងណា។

(c) ក្នុងរយៈពេល 7 ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំដែលបានបំពេញរួចរាល់ អាជ្ញាធរផ្តល់អាជ្ញាបណ្ណត្រូវបញ្ជូនពាក្យស្នើសុំចំនួន 1 ច្បាប់ និងទម្រង់ផ្តិតស្នាមម្រាមដៃរបស់អ្នកស្នើសុំចំនួន 1 ច្បាប់ ទៅកាន់ស្នងការប៉ូលិសរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ការផ្តិតស្នាមម្រាមដៃមិនតម្រូវឱ្យមាននៅក្នុងការចេញឯកសារបន្តសុពលភាពឡើយ ប្រសិនបើស្នាមម្រាមដៃរបស់អ្នកស្នើសុំមានរក្សាទុកក្នុងសំណុំឯកសាររបស់ក្រសួងប៉ូលិសរដ្ឋរួចហើយនោះ។

(d) ស្នងការប៉ូលិសរដ្ឋ ក្នុងរយៈពេល 30 ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំ និងស្នាមម្រាមដៃ ត្រូវផ្តល់យោបល់ណែនាំជាលាយលក្ខណ៍អក្សរជូនទៅអាជ្ញាធរផ្តល់អាជ្ញាបណ្ណអំពីប្រវត្តិរូបទោសទណ្ឌណាមួយរបស់អ្នកស្នើសុំដែលនាំឱ្យបាត់បង់លក្ខណសម្បត្តិ ដែលកើតមានឡើងនៅក្នុង ឬក្រៅរដ្ឋម៉ាសាឈូសិតនេះ និងបញ្ជាក់ថាតើមានមូលហេតុគួរឱ្យជឿជាក់ថា អ្នកស្នើសុំបានបាត់បង់លក្ខណសម្បត្តិក្នុងការកាន់កាប់លិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណដែលបានស្នើសុំនោះដែរឬទេ។ ប្រសិនបើព័ត៌មានស្នងការប៉ូលិសរដ្ឋមាន មិនបានបង្ហាញថាការចេញលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណនោះ នឹងរំលោភបំពានលើច្បាប់រដ្ឋ ឬច្បាប់សហព័ន្ធទេនោះ ស្នងការប៉ូលិសរដ្ឋត្រូវបញ្ជាក់ទទួលស្គាល់នូវអង្គហេតុនោះដល់អាជ្ញាធរផ្តល់អាជ្ញាបណ្ណក្នុងអំឡុងពេល 30 ថ្ងៃដែលបានកំណត់ខាងលើ។ ក្នុងការស្វែងរកប្រវត្តិណាមួយដែលនាំឱ្យបាត់បង់លក្ខណសម្បត្តិរបស់អ្នកស្នើសុំ ស្នងការប៉ូលិសរដ្ឋត្រូវ៖ (i) ប្រើប្រាស់ ឬបង្គាប់ឱ្យប្រើប្រាស់សំណុំឯកសារដែលរក្សាទុកដោយនាយកដ្ឋានដាក់ទោសសាកល្បង ព្រមទាំងប្រព័ន្ធព័ត៌មាន និងសំណុំឯកសារស្តីពីដីកាបង្គាប់ឱ្យចាប់ខ្លួន ដីកាការពារ និងយុត្តិធម៌ព្រហ្មទណ្ឌនៅទូទាំងរដ្ឋ និងទូទាំងប្រទេស រួមមានជាអាទិ៍ ប្រព័ន្ធត្រួតពិនិត្យប្រវត្តិរូបទោសទណ្ឌបន្ទាន់ថ្នាក់ជាតិ (National Instant Criminal Background Check System / NICS) និង (ii) សាកសួរទៅប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្ត អំពីការបញ្ជាក់ថាអ្នកស្នើសុំបានបាត់បង់លក្ខណសម្បត្តិក្នុងការទទួលបានលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ។

(e) អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ត្រូវធ្វើការសាកសួរព័ត៌មានពាក់ព័ន្ធនឹងអ្នកស្នើសុំទៅកាន់៖ (i) ប្រធាននាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ អំពីលក្ខខណ្ឌបាត់បង់លក្ខណសម្បត្តិណាមួយ ព័ត៌មានអំពីលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណមុនៗ ប្រវត្តិនៃការបង្ខាំងខ្លួនណាមួយ និងពាក្យស្នើសុំឱ្យសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ស្របតាមមាត្រា 12 នៃជំពូក 123 និងកំណត់ត្រានៃការទិញ ការលក់ ការជួល ការជួលរយៈពេលវែង និងការផ្ទេរកម្មសិទ្ធិអាវុធ ឬគ្រាប់រំសេវដែលពាក់ព័ន្ធនឹងអ្នកស្នើសុំ (ii) ប្រធាននាយកដ្ឋានដាក់ទោសសាកល្បង អំពីប្រវត្តិរូបណាមួយដែលមានរក្សាទុកនៅក្នុងនាយកដ្ឋានដាក់ទោសសាកល្បង ឬនៅក្នុងប្រព័ន្ធរក្សាទុកកំណត់ត្រាអំពីអំពើហិង្សាក្នុងគ្រួសារនៅទូទាំងរដ្ឋ ដែលពាក់ព័ន្ធនឹងអ្នកស្នើសុំ និង (iii) ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្ត អំពីការបញ្ជាក់ថាតើអ្នកស្នើសុំគឺជាបុគ្គលដែលសមស្របក្នុងការកាន់កាប់អាវុធដែរឬទេ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ផ្តល់ប្រវត្តិនៃការបង្ខាំងខ្លួន និងពាក្យស្នើសុំឱ្យសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ស្របតាមមាត្រា 12 នៃជំពូក 123 ដែលបានរៀបរាប់អាជ្ញាធរផ្តល់អាជ្ញាបណ្ណត្រូវធ្វើការសាកសួរព័ត៌មានទៅកាន់ភ្នាក់ងារអនុវត្តច្បាប់ដែលបានដាក់ជូនកំណត់ត្រាទាក់ទិននឹងកាលៈទេសៈនៃការបង្ខាំងខ្លួន និងពាក្យស្នើសុំឱ្យសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យនោះ ហើយត្រូវពិចារណាលើកាលៈទេសៈទាំងនោះ នៅពេលសម្រេចសេចក្តីអំពីភាពសមស្របរបស់អ្នកស្នើសុំដើម្បីទទួលបានអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាត។ លើសពីនេះទៀត អ្នកស្នើសុំអាចដាក់ជូនដើម្បីឱ្យអាជ្ញាធរផ្តល់អាជ្ញាបណ្ណពិចារណា នូវលិខិតអះអាងរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណ គិលានុបដ្ឋាកកម្រិតខ្ពស់ដែលបានចុះបញ្ជី ឬអ្នកចិត្តសាស្ត្រពិនិត្យព្យាបាល ដែលបញ្ជាក់អះអាងថា គ្រូពេទ្យ គិលានុបដ្ឋាកជាន់ខ្ពស់ដែលបានចុះបញ្ជី ឬអ្នកចិត្តសាស្ត្រពិនិត្យព្យាបាលរូបនោះ មានការយល់ដឹងច្បាស់លាស់អំពីជំងឺផ្លូវចិត្តរបស់អ្នកស្នើសុំ ហើយតាមទស្សនៈរបស់គ្រូពេទ្យ គិលានុបដ្ឋាកជាន់ខ្ពស់ដែលបានចុះបញ្ជី ឬអ្នកចិត្តសាស្ត្រពិនិត្យព្យាបាលនោះ អ្នកស្នើសុំមិនរងការប៉ះពាល់ដោយជំងឺផ្លូវចិត្ត ក្នុងលក្ខណៈមួយដែលគួរតែរារាំងអ្នកស្នើសុំមិនឱ្យកាន់កាប់អាវុធនោះឡើយ។ នាយក ឬស្នងការដែលអាជ្ញាធរផ្តល់អាជ្ញាបណ្ណធ្វើការសាកសួរ ត្រូវផ្តល់កិច្ចសហប្រតិបត្តិការឱ្យបានឆាប់រហ័ស និងពេញលេញក្នុងការស៊ើបអង្កេតណាមួយចំពោះអ្នកដាក់ពាក្យស្នើសុំ សម្រាប់គោលបំណងនោះ។ រាល់ព័ត៌មានដែលថាបុគ្គលម្នាក់មានប្រវត្តិនៃការបង្ខាំងខ្លួន និងការដាក់ពាក្យសុំចូលសម្រាកក្នុងមន្ទីរពេទ្យ ដោយអនុលោមតាមមាត្រា 12 នៃជំពូក 123 ដែលបានរៀបរាប់ខាងលើ ត្រូវយកមកប្រើប្រាស់សម្រាប់គោលបំណងតែមួយគត់ គឺផ្តល់ព័ត៌មានដែលចាំបាច់ ឬអនុញ្ញាតឱ្យពិចារណាក្រោមច្បាប់រដ្ឋ ឬច្បាប់សហព័ន្ធ ដល់អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ដើម្បីអនុវត្តការត្រួតពិនិត្យសាវតារ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

សម្រាប់ការលក់ ឬការផ្តល់អាជ្ញាបណ្ណអាវុធ ហើយមិនត្រូវលាតត្រដាងទៅឱ្យភាគីដទៃទៀតសម្រាប់គោលបំណងផ្សេងឡើយ។

(f) ជនណាក៏ដោយដែលដាក់ពាក្យសុំលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណណាមួយ អនុលោមតាមមាត្រា 122, 122B, 122D, 129B, 131 ឬ 131F ដោយដឹងខ្លួនជាមុនថាមានផ្ទុកព័ត៌មានមិនពិត ឬជនណាដែលចេញលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណបែបនេះដោយដឹងខ្លួនជាមុនថាបំពានលើជំពូកនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនតិចជាង 500 ដុល្លារ និងមិនលើសពី 1,000 ដុល្លារ ឬផ្តន្ទាទោសដាក់ពន្ធនាគារមិនតិចជាង 6 ខែ និងមិនលើសពី 2 ឆ្នាំ នៅក្នុងមណ្ឌលកែប្រែ ឬត្រូវទទួលរងទាំងការពិន័យជាប្រាក់ ទាំងការដាក់ពន្ធនាគារ។

(g) ពាក្យសុំអាជ្ញាបណ្ណ ឬបណ្ណសម្គាល់អាវុធណាមួយ អនុលោមតាមមាត្រា 122, 122B, 122D, 129B, 131 ឬ 131F ត្រូវធ្វើឡើងតាមទម្រង់ស្តង់ដាផ្តល់ដោយប្រធាននាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដែលតម្រូវឱ្យអ្នកដាក់ពាក្យ ឬឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជន ត្រូវប្រកាសអះអាងស្ថិតក្រោមទោសទណ្ឌនៃការផ្តល់សក្ខីកម្មក្លែងក្លាយថា អ្នកដាក់ពាក្យមិនត្រូវបានបាត់បង់លក្ខណសម្បត្តិលើមូលដ្ឋានណាមួយដែលបានរៀបរាប់លម្អិតនៅក្នុងមាត្រានេះ ក្នុងការទទួលបានលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណបែបនេះឡើយ។

(h) អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ត្រូវកត់ត្រាទុកក្នុងសៀវភៅ ទម្រង់បែបបទ ឬឯកសារអេឡិចត្រូនិកដែលរក្សាទុកសម្រាប់គោលបំណងនោះនៅនឹងទីតាំងផ្ទាល់ និងនៅលើប្រព័ន្ធចុះបញ្ជីអាវុធអេឡិចត្រូនិកដែលបង្កើតឡើងដោយនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ អនុលោមតាមមាត្រា 121B នូវរាល់ចំណុចខាងក្រោមទាំងអស់ នៅពេលបង្កើត ឬទទួលបាន៖ (i) ពាក្យសុំអាជ្ញាបណ្ណ លិខិតអនុញ្ញាត និងបណ្ណសម្គាល់ បង្កាន់ដៃ កម្រៃសេវា លិខិតអះអាងការផ្ទេរទីតាំងអាជ្ញាបណ្ណ និងវិញ្ញាបនបត្របណ្ដុះបណ្ដាល (ii) អាជ្ញាបណ្ណ លិខិតអនុញ្ញាត និងបណ្ណសម្គាល់ដែលបានចេញរួច ព្រមទាំងការបដិសេធ ការដកហូត និងការផ្អាកជាបណ្តោះអាសន្ននូវឯកសារទាំងនោះ (iii) សេចក្តីសម្រេចរបស់គណៈកម្មាធិការត្រួតពិនិត្យការផ្តល់អាជ្ញាបណ្ណអាវុធ (Firearm Licensing Review Board) និង (iv) ការផ្ទេរអាវុធ រួមទាំងការប្រគល់-ទទួល ការដកហូត ការប្រគល់ជូនវិញ ការបាត់បង់ ឬការលួច ឬការកំទេចចោល។ នាយកដ្ឋានត្រូវធានាឱ្យមានការជូនដំណឹងដោយស្វ័យប្រវត្តិទៅអាជ្ញាធរផ្តល់អាជ្ញាបណ្ណ អំពីវត្តមាននៃលក្ខខណ្ឌបាត់បង់លក្ខណសម្បត្តិណាមួយដែលបានរកឃើញ ឬកើតឡើងបន្ទាប់ពីការចេញលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណដែលបានរៀបរាប់ខាងលើ និងសេចក្តីជូនដំណឹងអំពីការហួសសុពលភាពរបស់ឯកសារទាំងនោះ ក្នុងរយៈពេលមិនលើសពី 5 ថ្ងៃ បន្ទាប់ពីការហួសសុពលភាព ដោយរួមបញ្ចូលទាំងកាលបរិច្ឆេទហួសសុពលភាពនៃលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ ព្រមទាំងឈ្មោះនិងអាសយដ្ឋានរបស់ម្ចាស់អាជ្ញាបណ្ណផងដែរ។

(i) លិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណណាមួយដែលបានចេញក្រោមមាត្រា 122D, 129B, 131 ឬ 131F ត្រូវតែចេញតាមទម្រង់ស្តង់ដាផ្តល់ដោយនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដែលមានទំហំ និងរូបរាងសមមូលទៅនឹងបណ្ណបើកបរយានយន្តដែលចេញដោយការិយាល័យចុះបញ្ជីយានយន្ត អនុលោមតាមមាត្រា 8 នៃជំពូក 90 ហើយត្រូវមានសញ្ញាសម្គាល់ច្បាស់លាស់នូវឈ្មោះលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណនោះ។ ឯកសារនោះត្រូវមានលេខលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ ឈ្មោះ អាសយដ្ឋាន រូបថត ស្នាមម្រាមដៃ ទីកន្លែងនិងថ្ងៃខែឆ្នាំកំណើត កម្ពស់ ទម្ងន់ ពណ៌សក់ ពណ៌ភ្នែក និងហត្ថលេខារបស់អ្នកទទួលបានអាជ្ញាបណ្ណ ឬម្ចាស់លិខិតអនុញ្ញាត ឬម្ចាស់បណ្ណសម្គាល់ ហើយត្រូវមានលេខទូរសព្ទទាន់ហេតុការណ៍សង្គ្រោះវិបត្តិ និងបង្ការការធ្វើអត្តឃាត 988 ដោយប្រើទំហំ និងទម្រង់អក្សរងាយស្រួលអាន។

(j) អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ត្រូវបដិសេធរាល់ពាក្យសុំលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណដែលត្រូវផ្តល់ជូនតាមមាត្រា 122, 122B, 122D, 129B, 131 ឬ 131F ឬការបន្តសុពលភាពនៃឯកសារទាំងនោះ ចំពោះបុគ្គលណាដែលអាជ្ញាធរផ្តល់អាជ្ញាបណ្ណកំណត់ថាជាបុគ្គលត្រូវហាមឃាត់។ បុគ្គលត្រូវហាមឃាត់ គឺជាបុគ្គលណាដែល៖

(i) ធ្លាប់ត្រូវបានផ្តន្ទាទោស ឬត្រូវបានកាត់ទោសនៅក្នុងតុលាការរដ្ឋម៉ាសាឈូសិត ឬនៅក្នុងយុត្តាធិការរដ្ឋផ្សេងទៀត ឬយុត្តាធិការសហព័ន្ធ ជាជនល្មើសវ័យក្មេង ឬជាកុមារប្រព្រឹត្តល្មើសច្បាប់ ឬទាំងពីរករណី ដូចដែលបានកំណត់និយមន័យក្នុងមាត្រា 52 នៃជំពូក 119 ចំពោះការប្រព្រឹត្តនូវ៖ (A) បទឧក្រិដ្ឋ (B) បទល្មើសមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី 2 ឆ្នាំ (C) បទឧក្រិដ្ឋកម្មហិង្សា ដូចដែលបានកំណត់ក្នុងមាត្រា 122 (D) ការល្មើសនឹងច្បាប់ណាមួយពាក់ព័ន្ធនឹងការប្រើប្រាស់ ការកាន់កាប់ ការមានជាកម្មសិទ្ធិ ឬការផ្ទេរអាវុធ ឬគ្រាប់រំសេវ ដែលអាចត្រូវប្រឈមនឹងទោសដាក់ពន្ធនាគារ (E) ការល្មើសនឹងច្បាប់ណាមួយរបស់រដ្ឋម៉ាសាឈូសិតដែលគ្រប់គ្រងលើការប្រើប្រាស់ ការកាន់កាប់ ឬការលក់សារធាតុដែលត្រូវត្រួតពិនិត្យ ដូចដែលបានកំណត់ក្នុងមាត្រា 1 នៃជំពូក 94C ឬការល្មើសនឹងច្បាប់ណាមួយដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាខ្លាំងនៃរដ្ឋផ្សេងទៀត ឬនៃយុត្តាធិការសហព័ន្ធ ឬ (F) បទល្មើសមជ្ឈិមនៃអំពើហិង្សាក្នុងគ្រួសារ ដូចបានកំណត់នៅក្នុងក្រម 18 U.S.C. មាត្រា 921(a)(33)។ ទោះជាយ៉ាងណាក៏ដោយ ការប្រព្រឹត្តបទល្មើសដែលបានរៀបរាប់ក្នុងអនុប្រយោគ (B), (D) ឬ (E) ត្រូវធ្វើឱ្យអ្នកដាក់ពាក្យស្នើសុំបាត់បង់លក្ខណសម្បត្តិទទួលបានបណ្ណសម្គាល់អាវុធតាមមាត្រា 129B ត្រឹមតែរយៈពេល 5 ឆ្នាំប៉ុណ្ណោះ បន្ទាប់ពីអ្នកដាក់ពាក្យត្រូវបានផ្តន្ទាទោស ឬត្រូវបានកាត់ទោស ឬត្រូវបានដោះលែងឱ្យមានសេរីភាពពីការឃុំឃាំង ការដាក់រទោសសាកល្បង ឬការដោះលែងដោយមានលក្ខខណ្ឌសម្រាប់ការផ្តន្ទាទោស ឬការកាត់ទោសនោះ ដោយគិតករណីណាកើតឡើងក្រោយគេ។

(ii) ជាបុគ្គលដែលត្រូវបាន ឬធ្លាប់ត្រូវបាន៖ (A) បញ្ជូនឱ្យទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬគ្រឹះស្ថានជំងឺផ្លូវចិត្ត ឬការប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀនខុសច្បាប់ លើកលែងតែការបញ្ជូនទៅព្យាបាលដោយអនុលោមតាមមាត្រា 35 ឬ 36C នៃជំពូក 123 វៀរលែងតែក្រោយរយៈពេល 5 ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការឃុំខ្លួនព្យាបាលនោះ អ្នកដាក់ពាក្យស្នើសុំបានដាក់ជូនមកជាមួយពាក្យសុំលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណនោះនូវលិខិតអះអាងរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណ ឬគ្រូពេទ្យពិនិត្យព្យាបាលចិត្តសាស្ត្រដែលបញ្ជាក់ពីការយល់ដឹងច្បាស់លាស់អំពីជំងឺផ្លូវចិត្ត ឬការប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀនខុសច្បាប់របស់អ្នកដាក់ពាក្យ ហើយយោងតាមទស្សនៈរបស់គ្រូពេទ្យ ឬគ្រូពេទ្យពិនិត្យព្យាបាលចិត្តសាស្ត្រនោះ អ្នកដាក់ពាក្យមិនមែនកំពុងរងទុក្ខពីជំងឺផ្លូវចិត្ត ឬការប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀនខុសច្បាប់ ក្នុងកម្រិតដែលអាចរារាំងអ្នកដាក់ពាក្យមិនឱ្យកាន់កាប់អាវុធដែលមានអាជ្ញាបណ្ណនោះឡើយ។ (B) បញ្ជូនឱ្យទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬគ្រឹះស្ថានជំងឺផ្លូវចិត្តតាមដីកាបង្គាប់របស់តុលាការ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

វៀរលែងតែអ្នកដាក់ពាក្យស្នើសុំត្រូវបានអនុញ្ញាតតាមសេចក្តីសម្រេចលើបណ្តឹងស្នើសុំសង្គ្រោះ រួចផុតពីដីកាបង្គាប់របស់តុលាការនោះ ដោយអនុលោមតាមមាត្រា 36C នៃជំពូក 123 ដែលបានពោល និងបានដាក់ជូននូវច្បាប់ចម្លងនៃដីកាសម្រេចរបស់តុលាការនោះ មកជាមួយពាក្យសុំលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ។ (C) ស្ថិតក្រោមដីកាបង្គាប់របស់តុលាការមរតកសាសន៍និងអាណាព្យាបាលដែលតែងតាំងអ្នកអាណាព្យាបាល ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់បុគ្គលដែលបាត់បង់សមត្ថភាព ដោយហេតុថាអ្នកដាក់ពាក្យខ្វះសមត្ថភាពផ្លូវចិត្តក្នុងការធ្វើកិច្ចសន្យា ឬចាត់ចែងកិច្ចការងាររបស់ខ្លួន វៀរលែងតែអ្នកដាក់ពាក្យស្នើសុំត្រូវបានអនុញ្ញាតតាមសេចក្តីសម្រេចលើបណ្តឹងស្នើសុំសង្គ្រោះ រួចផុតពីដីកាបង្គាប់របស់តុលាការមរតកសាសន៍និងអាណាព្យាបាលនោះ ដោយអនុលោមតាមមាត្រា 56C នៃជំពូក 215 និងបានដាក់ជូននូវច្បាប់ចម្លងនៃដីកាបង្គាប់នោះ មកជាមួយពាក្យសុំលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ ឬ (D) រកឃើញថាជាបុគ្គលដែលមានវិបត្តិពីការប្រើប្រាស់គ្រឿងស្រវឹង ឬវិបត្តិពីការប្រើប្រាស់សារធាតុញៀនខុសច្បាប់ ឬទាំងពីរករណី និងត្រូវបានបញ្ជូនឱ្យទៅសម្រាកព្យាបាលដោយអនុលោមតាមមាត្រា 35 នៃជំពូក 123 ដែលបានពោល វៀរលែងតែអ្នកដាក់ពាក្យស្នើសុំត្រូវបានអនុញ្ញាតតាមសេចក្តីសម្រេចលើបណ្តឹងស្នើសុំសង្គ្រោះ រួចផុតពីដីកាបង្គាប់របស់តុលាការនោះ ដោយអនុលោមតាមមាត្រា 35 នៃជំពូក 123 ដែលបានពោល និងបានដាក់ជូននូវច្បាប់ចម្លងនៃដីកាបង្គាប់របស់តុលាការមកជាមួយពាក្យសុំ។

(iii) បច្ចុប្បន្នស្ថិតក្រោម៖ (A) ដីកាបង្គាប់ឱ្យព្យួរជាបណ្តោះអាសន្ន ឬឱ្យប្រគល់ខ្លួនដោយអនុលោមតាម មាត្រា 3B ឬ 3C នៃជំពូក 209A។ (B) ដីកាការពារជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន ដែលបានចេញដោយអនុលោមតាមជំពូក 209A ដែលបានពោល។ (C) ដីកាបង្គាប់ណាមួយដែលបានពណ៌នាក្នុងក្រម 18 U.S.C. មាត្រា(g)(8)។ (D) ដីកាបង្ការការយាយីជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន ដែលបានចេញដោយអនុលោមតាមជំពូក 258E។ (E) ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ ដែលបានចេញដោយអនុលោមតាមមាត្រា 131R ដល់ 131Y។ ឬ (F) ដីកាបង្គាប់ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងដីកាដែលបានរៀបរាប់ក្នុងអនុប្រយោគ (A), (B), (C), (D) ឬ (E) ដែលចេញដោយយុត្តាធិការផ្សេងទៀត។

(iv) បច្ចុប្បន្នកំពុងស្ថិតក្រោមដីកាចាប់ខ្លួនដែលមិនទាន់អនុវត្ត នៅក្នុងយុត្តាធិការរដ្ឋ ឬសហព័ន្ធណាមួយ។

(v) មិនមែនជាប្រជាពលរដ្ឋ ឬជាជនជាតិរបស់សហរដ្ឋអាមេរិក និងមិនមានលំនៅឋានអចិន្ត្រៃយ៍ស្របច្បាប់។

(vi) ត្រូវបានបណ្តេញចេញពីកងកម្លាំងប្រដាប់អាវុធរបស់សហរដ្ឋអាមេរិក ក្រោមស្ថានភាពបាត់បង់កិត្តិយស ឬ

(vii) ជាជនគេចខ្លួនពីសំណាញ់ច្បាប់។

(k) អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ត្រូវបដិសេធរាល់ពាក្យសុំលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ ស្របតាមមាត្រា 122, 122B, 122D, 129B, 131 ឬ 131F ឬការបន្តសុពលភាពនៃឯកសារទាំងនោះ ចំពោះបុគ្គលណាដែលអាជ្ញាធរផ្តល់អាជ្ញាបណ្ណកំណត់ថាជាបុគ្គលដែលមិនសក្តិសមនឹងកាន់លិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ។ ការកំណត់អំពីភាពមិនសក្តិសម ត្រូវផ្អែកលើព័ត៌មានដែលគួរឱ្យទុកចិត្ត អាចបញ្ជាក់បានច្បាស់ និងប្រកបដោយភាពជឿជាក់ថា អ្នកដាក់ពាក្យស្នើសុំបានបង្ហាញ ឬបានចូលរួមក្នុងឥរិយាបថដែលបង្ហាញឱ្យឃើញថា ប្រសិនបើទទួលបានលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ នោះអ្នកដាក់ពាក្យសុំអាចនឹងបង្កជាហានិភ័យដល់សុវត្ថិភាពសាធារណៈ ឬហានិភ័យគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃ។ នៅពេលមានការបដិសេធលើពាក្យសុំ ឬការបន្តសុពលភាពនៃលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ ដោយផ្អែកលើការកំណត់អំពីភាពមិនសក្តិសម អាជ្ញាធរផ្តល់អាជ្ញាបណ្ណត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីហេតុផលជាក់លាក់សម្រាប់ការកំណត់នោះ។

(l) ក្នុងករណីមានពាក្យសុំ ឬការបន្តសុពលភាពនៃបណ្ណសម្គាល់អាវុធក្រោមមាត្រា 129B អាជ្ញាធរផ្តល់អាជ្ញាបណ្ណមិនមានសមត្ថកិច្ចក្នុងការបដិសេធពាក្យសុំដោយផ្អែកលើភាពមិនសក្តិសមនោះឡើយ ប៉ុន្តែអាចដាក់បណ្តឹងតវ៉ាដើម្បីស្នើសុំឱ្យតុលាការតំបន់ដែលមានយុត្តាធិការ បដិសេធពាក្យសុំដែលបានពោល ដោយផ្អែកលើភាពមិនសក្តិសម។ បណ្តឹងតវ៉ាបែបនេះ ត្រូវមានអានុភាពផ្អាកជាបណ្តោះអាសន្ននូវដំណើរការពិនិត្យពាក្យសុំ ហើយត្រូវបង្កើតឡើងដោយផ្អែកលើសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរអំពីហេតុផលនានាដែលគាំទ្រដល់ការរកឃើញភាពមិនសក្តិសម។ នៅពេលដាក់បណ្តឹងតវ៉ារួចរាល់ ច្បាប់ចម្លងបណ្តឹងតវ៉ា និងសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរនោះ ត្រូវផ្តល់ជូនទៅអ្នកដាក់ពាក្យដោយអាជ្ញាធរផ្តល់អាជ្ញាបណ្ណ។ តុលាការត្រូវរៀបចំសវនាការក្នុងរយៈពេល 90 ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានបណ្តឹងតវ៉ាដែលបានដាក់នោះ ដើម្បីកំណត់ថាតើអ្នកដាក់ពាក្យសុំបណ្ណសម្គាល់អាវុធនោះពិតជាមិនសក្តិសមដែរឬទេ និងត្រូវចេញសាលក្រមសម្រេចលើភាពសក្តិសមនោះ។ ការកំណត់អំពីភាពមិនសក្តិសម ត្រូវផ្អែកលើឧត្តរភាពនៃភស្តុតាងថាមានព័ត៌មានដែលគួរឱ្យទុកចិត្ត អាចបញ្ជាក់បានច្បាស់ និងប្រកបដោយភាពជឿជាក់ថាអ្នកដាក់ពាក្យស្នើសុំបានបង្ហាញ ឬបានចូលរួមក្នុងឥរិយាបថដែលបង្ហាញឱ្យឃើញថា ប្រសិនបើទទួលបានលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ នោះអ្នកដាក់ពាក្យសុំអាចនឹងបង្កជាហានិភ័យដល់សុវត្ថិភាពសាធារណៈ ឬហានិភ័យគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃ។ ប្រសិនបើតុលាការចេញសាលក្រមសម្រេចថាអ្នកដាក់ពាក្យសុំមិនសក្តិសម តុលាការត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីហេតុផលជាក់លាក់ចំពោះការសម្រេចនោះ។ ប្រសិនបើតុលាការមិនបានចេញសាលក្រមសម្រេចថាអ្នកដាក់ពាក្យសុំមិនសក្តិសមក្នុងរយៈពេល 90 ថ្ងៃ គិតចាប់ពីថ្ងៃដាក់ពាក្យបណ្តឹងតវ៉ាទេនោះ សាលក្រមសម្រេចថាអ្នកដាក់ពាក្យមានលក្ខណៈសក្តិសមនឹងទទួលបានបណ្ណសម្គាល់អាវុធ ត្រូវតែចេញដោយស្វ័យប្រវត្តិ។

(m) អ្នកដាក់ពាក្យសុំដែលមិនសុខចិត្ត ដោយសារការបដិសេធមិនផ្តល់លិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណ ក្រោមមាត្រា 122, 122B, 122D, 129B, 131 ឬ 131F អាចប្តឹងឧទ្ធរណ៍តវ៉ានឹងការបដិសេធនោះ ដោយអនុលោមតាមកថាខណ្ឌ (v)។

(n) រាល់កម្រៃសេវាពាក្យសុំសម្រាប់អាជ្ញាបណ្ណ បណ្ណសម្គាល់ និងលិខិតអនុញ្ញាតដែលបានចេញក្រោមមាត្រា 122, 122D, 129B ឬ 131 ត្រូវបង់ទៅអាជ្ញាធរផ្តល់អាជ្ញាបណ្ណដែលជាអ្នកចេញឯកសារ ហើយមិនត្រូវគណនាបែងចែកតាមសមាមាត្រពេលវេលា ឬបង្វិលសងវិញឡើយ ក្នុងករណីមានការដកហូត ឬការបដិសេធ។ ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយចែងផ្ទុយពីនេះក៏ដោយ អាជ្ញាធរផ្តល់អាជ្ញាបណ្ណត្រូវដាក់ប្រាក់កម្រៃសេវាទាំងអស់ចូលទៅក្នុងមូលនិធិដែលបាន

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

កំណត់ជាប្រចាំត្រីមាស មិនឱ្យហួសពីថ្ងៃទី 1 ខែមករា ថ្ងៃទី 1 ខែមេសា ថ្ងៃទី 1 ខែកក្កដា និងថ្ងៃទី 1 ខែតុលា នៃឆ្នាំនីមួយៗឡើយ។

(o) វៀរលែងតែមានការចែងផ្សេងពីនេះនៅក្នុងមាត្រានេះ ពុំនោះទេ កម្រៃសេវាសម្រាប់ពាក្យសុំ ឬការបន្តសុពលភាពនេះ

(i) អាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតណាមួយ ត្រូវមានចំនួន 100 ដុល្លារ ដែលក្នុងនោះអាជ្ញាធរផ្តល់អាជ្ញាបណ្ណត្រូវរក្សាទុកចំនួន 25 ដុល្លារនៃប្រាក់កម្រៃសេវានោះ ហើយចំនួន 50 ដុល្លារនៃប្រាក់កម្រៃសេវានោះ ត្រូវដាក់បញ្ចូលទៅក្នុងមូលនិធិទូទៅ។ ទឹកប្រាក់មិនតិចជាង 50,000 ដុល្លារនៃមូលនិធិសរុបដែលបានដាក់បញ្ចូលទៅក្នុងមូលនិធិទូទៅ ត្រូវបែងចែកទៅឱ្យគណៈកម្មាធិការត្រួតពិនិត្យការផ្តល់អាជ្ញាបណ្ណអាវុធ ដែលបង្កើតឡើងក្រោមមាត្រា 130B សម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ បន្ថែមលើនេះ មូលនិធិទាំងឡាយណាដែលគណៈកម្មាធិការខាងលើមិនបានចំណាយសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួនទេនោះ ត្រូវបង្វិលចូលទៅក្នុងមូលនិធិទូទៅវិញ។ ហើយចំនួន 25 ដុល្លារនៃប្រាក់កម្រៃសេវានោះ ត្រូវដាក់បញ្ចូលទៅក្នុងមូលនិធិរ៉ាប់រងការផ្ទៀងផ្ទាត់អត្តសញ្ញាណស្នាមម្រាមដៃអាវុធ (Firearms Fingerprint Identity Verification Trust Fund) ដែលបង្កើតឡើងក្នុងមាត្រា 2LLL នៃជំពូក 29។

(ii) អាជ្ញាបណ្ណកាន់កាប់អាវុធដែលបានចេញក្រោមមាត្រា 131 សម្រាប់មន្ត្រីអនុវត្តច្បាប់ដែលកំពុងបំពេញការងារ និងដែលបានចូលនិវត្តន៍ ឬសម្រាប់អង្គភាពរដ្ឋាភិបាលមូលដ្ឋាន រដ្ឋ ឬសហព័ន្ធដែលធ្វើសកម្មភាពក្នុងនាមមន្ត្រីទាំងនោះ ត្រូវមានចំនួន 25 ដុល្លារ ដែលក្នុងនោះ 50 ភាគរយ ត្រូវរក្សាទុកដោយអាជ្ញាធរផ្តល់អាជ្ញាបណ្ណ និង 50 ភាគរយ ត្រូវដាក់បញ្ចូលទៅក្នុងមូលនិធិទូទៅ និង

(iii) បណ្ណសម្គាល់អាវុធដែលបានចេញក្រោមមាត្រា 129B សម្រាប់បុគ្គលអាយុក្រោម 18 ឆ្នាំ ឬលិខិតអនុញ្ញាតប្រើប្រាស់ស្ព្រាយការពារខ្លួនដែលបានចេញក្រោមមាត្រា 122D ត្រូវមានចំនួន 25 ដុល្លារ ដែលក្នុងនោះ 50 ភាគរយ ត្រូវរក្សាទុកដោយអាជ្ញាធរផ្តល់អាជ្ញាបណ្ណ និង 50 ភាគរយ ត្រូវដាក់បញ្ចូលទៅក្នុងមូលនិធិទូទៅ។

(p) បុគ្គលណាដែលមានអាយុលើសពី 70 ឆ្នាំ និងមន្ត្រីអនុវត្តច្បាប់ណាម្នាក់ ដែលដាក់ពាក្យសុំតាមរយៈស្ថាប័ននិយោជករបស់ខ្លួន ដើម្បីបន្តសុពលភាពអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ ត្រូវទទួលបានការលើកលែងពីកាតព្វកិច្ចក្នុងការបង់ប្រាក់កម្រៃសេវាបន្តសុពលភាព។

(q) បុគ្គលណាម្នាក់ដែលមានអាជ្ញាបណ្ណលក់អាវុធក្រោមមាត្រា 122 មិនតម្រូវឱ្យបង់ប្រាក់កម្រៃសេវាបន្ថែមណាមួយសម្រាប់អាជ្ញាបណ្ណជាងធ្វើ ឬជួសជុលអាវុធឡើយ។

(r) ប្រធាននាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវផ្ញើតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមប្រៃសណីយ៍ថ្នាក់ទីមួយទៅម្ចាស់អាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាត នូវសេចក្តីជូនដំណឹងអំពីការហួសសុពលភាពនៃអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតនោះ ក្នុងរយៈពេលមិនតិចជាង 90 ថ្ងៃ មុនថ្ងៃហួសសុពលភាព ហើយត្រូវភ្ជាប់មកជាមួយ ឬផ្តល់នូវតំណភ្ជាប់គេហទំព័រទៅកាន់ទម្រង់បែបបទសម្រាប់ធ្វើការបន្តសុពលភាពនោះ។ ទម្រង់បែបបទសម្រាប់ធ្វើការបន្តសុពលភាព ត្រូវរួមបញ្ចូលទាំង៖

(i) លិខិតអះអាងដែលត្រូវបំពេញរួចរាល់ និងផ្ញើត្រឡប់មកវិញ ដើម្បីបន្តសុពលភាពអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាត ដែលក្នុងនោះអ្នកដាក់ពាក្យសុំត្រូវផ្ទៀងផ្ទាត់ថា ខ្លួនមិនបានបាត់បង់ ឬត្រូវបានគេលួចយកអាវុធណាមួយឡើយសម្រាប់ការសុំអាជ្ញាបណ្ណ បណ្ណសម្គាល់ និងលិខិតអនុញ្ញាតនីមួយៗ គិតចាប់ពីកាលបរិច្ឆេទនៃការបន្តសុពលភាព ឬការចេញឱ្យប្រើប្រាស់ចុងក្រោយរបស់អ្នកដាក់ពាក្យសុំ និង

(ii) រាល់ព័ត៌មានពាក់ព័ន្ធទាំងអស់អំពីទណ្ឌកម្ម និងការផ្តន្ទាទោសនានាដែលអាចត្រូវបានអនុវត្ត ប្រសិនបើអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតនោះមិនត្រូវបានបន្តសុពលភាព ហើយអ្នកដាក់ពាក្យសុំនៅតែបន្តកាន់កាប់អាវុធណាមួយ។

(s) ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយចែងផ្ទុយពីនេះក៏ដោយ អាជ្ញាបណ្ណកាន់កាប់អាវុធហួសសុពលភាព ដែលបានចេញក្រោមមាត្រា 131 ឬបណ្ណសម្គាល់អាវុធហួសសុពលភាព ដែលបានចេញក្រោមមាត្រា 129B ត្រូវបន្តមានសុពលភាពសម្រាប់គ្រប់គោលបំណងស្របច្បាប់ទាំងអស់ ប្រសិនបើ៖

(i) ម្ចាស់អាជ្ញាបណ្ណ ឬម្ចាស់ប័ណ្ណ បានដាក់ពាក្យសុំបន្តសុពលភាព មុនកាលបរិច្ឆេទហួសសុពលភាពរបស់អាជ្ញាបណ្ណ ឬប័ណ្ណ ហើយឯកសារនោះត្រូវបន្តមានសុពលភាពរហូតដល់ពាក្យសុំបន្តសុពលភាពត្រូវបានអនុម័ត ឬបដិសេធ

(ii) ម្ចាស់អាជ្ញាបណ្ណ ឬម្ចាស់ប័ណ្ណកំពុងស្ថិតក្នុងកាតព្វកិច្ចយោធាសកម្មជាមួយកងកម្លាំងប្រដាប់អាវុធសហរដ្ឋអាមេរិក នៅថ្ងៃហួសសុពលភាពនៃអាជ្ញាបណ្ណ ឬប័ណ្ណនោះ។ អាជ្ញាបណ្ណ ឬប័ណ្ណនោះត្រូវបន្តមានសុពលភាពរហូតដល់ម្ចាស់អាជ្ញាបណ្ណ ឬម្ចាស់ប័ណ្ណរួចផុតពីបញ្ចប់កាតព្វកិច្ចយោធាសកម្ម និងមានរយៈពេលមិនតិចជាង 180 ថ្ងៃ បន្ទាប់ពីរួចផុតកាតព្វកិច្ចយោធាសកម្មរបស់ពួកគេ។ បន្ថែមលើនេះ ប្រសិនបើម្ចាស់អាជ្ញាបណ្ណ ឬម្ចាស់ប័ណ្ណបានដាក់ពាក្យស្នើសុំបន្តសុពលភាពមុនពេលបញ្ចប់រយៈពេលនោះ អាជ្ញាបណ្ណ ឬប័ណ្ណត្រូវបន្តមានសុពលភាពសម្រាប់គ្រប់គោលបំណងស្របច្បាប់ទាំងអស់ រហូតដល់ពាក្យសុំបន្តសុពលភាពត្រូវបានអនុម័ត ឬបដិសេធ ឬ

(iii) រយៈពេលហួសសុពលភាពមិនទាន់លើស 90 ថ្ងៃ ផុតពីកាលបរិច្ឆេទហួសសុពលភាពដែលបានបញ្ជាក់ឡើយ វៀរលែងតែអាជ្ញាបណ្ណកាន់កាប់អាវុធ ឬប័ណ្ណសម្គាល់អាវុធនោះត្រូវបានដកហូត ឬផ្អាកជាបណ្តោះអាសន្ន។

(t) បុគ្គលណាម្នាក់មានអាជ្ញាបណ្ណកាន់កាប់អាវុធដែលបានចេញក្រោមមាត្រា 131 ឬបណ្ណសម្គាល់អាវុធដែលបានចេញក្រោមមាត្រា 129B ដែលអាជ្ញាបណ្ណ ឬប័ណ្ណនីមួយៗនោះអស់សុពលភាពដោយសារមូលហេតុតែមួយគត់គឺការហួសកំណត់ ដោយមិនរាប់បញ្ចូលអាជ្ញាបណ្ណ និងប័ណ្ណដែលបន្តមានសុពលភាពក្រោមកថាខណ្ឌ (s) ឡើយ ហើយបុគ្គលនោះមិនត្រូវបានបាត់បង់សិទ្ធិក្នុងការបន្តសុពលភាពនៅពេលដាក់ពាក្យសុំនោះ ត្រូវទទួលរងការពិន័យជាប្រាក់មិនតិចជាង 100 ដុល្លារ និងមិនលើសពី 5,000 ដុល្លារ ហើយមាត្រា 10 នៃជំពូក 269 មិនត្រូវយកមកអនុវត្តឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការលើកលែងនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើអាជ្ញាបណ្ណ ឬបណ្ណសម្គាល់នោះ៖ (i) ត្រូវបានដកហូត ឬផ្អាកជាបណ្តោះអាសន្ន វៀរលែងតែការដកហូត ឬការផ្អាកជាបណ្តោះអាសន្ននោះ បណ្តាលមកពីការខកខានមិនបានផ្តល់ដំណឹងអំពីការផ្លាស់ប្តូរអាសយដ្ឋាន (ii) កំពុងស្ថិតក្នុងដំណើរការរង់ចាំការដកហូត ឬការផ្អាកជាបណ្តោះអាសន្ន វៀរលែងតែការដកហូត ឬ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ការផ្អាកជាបណ្ដោះអាសន្ននោះ បណ្ដាលមកពីការខកខានមិនបានផ្ដល់ដំណឹងអំពីការផ្លាស់ប្ដូរអាសយដ្ឋាន ឬ (iii) ត្រូវបានបដិសេធពាក្យសុំបន្តសុពលភាព។ មន្ត្រីអនុវត្តច្បាប់ណាម្នាក់ដែលរកឃើញថាបុគ្គលណាមួយកំពុងកាន់កាប់អាវុធ បន្ទាប់ពីអាជ្ញាបណ្ណ ឬប័ណ្ណរបស់បុគ្គលនោះបានហួសសុពលភាព ពោលគឺហួស 90 ថ្ងៃ ផុតពីកាលបរិច្ឆេទហួសសុពលភាពដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ ឬប័ណ្ណ ឬត្រូវបានដកហូត ឬផ្អាកជាបណ្ដោះអាសន្នដោយសារមូលហេតុតែមួយគត់គឺការខកខានមិនបានផ្ដល់ដំណឹងអំពីការផ្លាស់ប្ដូរអាសយដ្ឋាន ត្រូវតែរឹបអូសអាវុធនោះ ព្រមទាំងអាជ្ញាបណ្ណ ឬប័ណ្ណដែលហួសសុពលភាព ឬត្រូវបានផ្អាកជាបណ្ដោះអាសន្នដែលកំពុងស្ថិតក្នុងការកាន់កាប់នាពេលនោះ ហើយមន្ត្រីរូបនោះត្រូវបញ្ជូនអាជ្ញាបណ្ណ ឬប័ណ្ណនោះឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ទៅអាជ្ញាធរផ្ដល់អាជ្ញាបណ្ណដែលបានចេញអាជ្ញាបណ្ណ ឬប័ណ្ណហួសសុពលភាពនោះ។ នៅពេលរឹបអូស មន្ត្រីនោះត្រូវផ្ដល់បញ្ជីសារពើភណ្ឌជាលាយលក្ខណ៍អក្សរ និងបង្កាន់ដៃសម្រាប់រាល់អាវុធទាំងអស់ដែលត្រូវបានរឹបអូស ជូនដល់បុគ្គលដែលត្រូវបានរឹបអូសអាវុធ ហើយមន្ត្រីរូបនោះត្រូវយកចិត្តទុកដាក់ប្រុងប្រយ័ត្នឱ្យបានដិតដល់ក្នុងការចាត់ចែង ការកាន់កាប់ និងការទុកដាក់ក្នុងឃ្លាំងនូវវត្ថុទាំងនេះ។ រាល់អាវុធដែលត្រូវបានរឹបអូស ត្រូវចាត់ទុកជាអាវុធដែលបានប្រគល់ជូន និងត្រូវស្ថិតក្រោមលក្ខខណ្ឌនៃមាត្រា 129D។ ទោះជាយ៉ាងណាក៏ដោយ អាវុធដែលត្រូវបានរឹបអូសនោះ ត្រូវតែប្រគល់ត្រឡប់ទៅឱ្យម្ចាស់វិញ ប្រសិនមានការផ្ដល់ភស្ដុតាងបញ្ជាក់អំពីការផ្ដល់ជូនឡើងវិញនូវអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត ក្នុងរយៈពេល 1 ឆ្នាំ គិតចាប់ពីពេលរឹបអូស។ កថាខណ្ឌនេះមិនត្រូវយកមកអនុវត្តចំពោះអាជ្ញាបណ្ណបណ្ដោះអាសន្នសម្រាប់ការកាន់កាប់អាវុធក្រោមមាត្រា 131F ឡើយ។

(u)(1) អាជ្ញាធរផ្ដល់អាជ្ញាបណ្ណត្រូវដកហូត ឬផ្អាកជាបណ្ដោះអាសន្ននូវអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតណាមួយ ដោយអនុលោមតាមមាត្រា 122, 122B, 122D, 129B, 131 ឬ 131F នៅពេលកើតមានព្រឹត្តិការណ៍ណាមួយដែលធ្វើឱ្យម្ចាស់អាជ្ញាបណ្ណ ម្ចាស់ប័ណ្ណសម្គាល់ ឬម្ចាស់លិខិតអនុញ្ញាត ក្លាយជាបុគ្គលត្រូវហាមឃាត់ ដូចដែលបានកំណត់ក្នុងកថាខណ្ឌ (j)។ អាជ្ញាធរផ្ដល់អាជ្ញាបណ្ណក៏អាចដកហូត ឬផ្អាកជាបណ្ដោះអាសន្នផងដែរ នូវអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតណាមួយ ដែលបានចេញអនុលោមតាមមាត្រា 122, 122B, 122D, 129B 131 ឬ 131F នៅពេលមានការកំណត់ជាបន្តបន្ទាប់អំពីភាពមិនសក្តិសមដូចបានកំណត់ក្នុងកថាខណ្ឌ (k) ឬនៅពេលមានភស្ដុតាងគ្រប់គ្រាន់ដែលបង្ហាញថាម្ចាស់អាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតបានល្មើស ឬបានបណ្ដោយឱ្យមានការល្មើសណាមួយលើជំពូកនេះ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីបណ្ណសម្គាល់អាវុធដែលបានចេញក្រោមមាត្រា 129B អាជ្ញាធរផ្ដល់អាជ្ញាបណ្ណត្រូវដាក់បណ្ដឹងតវ៉ាទៅតុលាការតំបន់ ដើម្បីសុំការផ្អាកជាបណ្ដោះអាសន្ន ឬការដកហូតប័ណ្ណដែលបានរៀបរាប់ខាងលើ ហើយបណ្ដឹងតវ៉ានោះត្រូវមានអានុភាពនាំឱ្យមានការផ្អាកជាបណ្ដោះអាសន្ន ឬការដកហូតបែបនោះ ក្នុងកំឡុងពេលរង់ចាំការសម្រេចតាមផ្លូវតុលាការអំពីភស្ដុតាងគ្រប់គ្រាន់នៃភាពមិនសក្តិសម ដែលតុលាការត្រូវធ្វើឡើងក្នុងរយៈពេល 15 ថ្ងៃ គិតចាប់ពីថ្ងៃដាក់បណ្ដឹងតវ៉ា ដែលបន្ទាប់ពីនោះ នីតិវិធីនិងស្ដង់ដានៃកថាខណ្ឌ (l) ត្រូវយកមកអនុវត្ត។ អាជ្ញាធរផ្ដល់អាជ្ញាបណ្ណអាចដកហូត ឬផ្អាកជាបណ្ដោះអាសន្ននូវអាជ្ញាបណ្ណណាមួយដែលបានចេញក្រោមមាត្រា 122 ឬ 122B លុះត្រាតែមានការជូនដំណឹងត្រឹមត្រូវទៅម្ចាស់អាជ្ញាបណ្ណ និងមានឱកាសសមស្របក្នុងការចូលខ្លួនមកបកស្រាយ។

(2) រាល់ការដកហូត ឬការផ្អាកជាបណ្ដោះអាសន្ននូវបណ្ណសម្គាល់ លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដែលបានចេញក្រោមមាត្រា 122, 122B, 122D, 129B, 131 ឬ 131F ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជាក់ពីហេតុផលនៃការដកហូត ឬការផ្អាកជាបណ្ដោះអាសន្ននោះ។ គ្មានអត្ថិភាពនៃដំណើរការនីតិវិធីណាមួយដែលកំពុងរង់ចាំការដោះស្រាយនៅចំពោះមុខតុលាការ ត្រូវមានអានុភាពទប់ស្កាត់ការដកហូត ឬផ្អាកជាបណ្ដោះអាសន្នបែបនោះឡើយ។ សេចក្ដីជូនដំណឹងអំពីការដកហូត និងការផ្អាកជាបណ្ដោះអាសន្ន ត្រូវបញ្ជូនទៅប្រធាននាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ និងប្រធានគ្រប់គ្រងការដាក់ទោសសាកល្បង ហើយត្រូវបញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ។ លិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណដែលបានដកហូត ឬផ្អាកជាបណ្ដោះអាសន្ន អាចស្ដារសុពលភាពឡើងវិញបាន លុះត្រាតែមានការបញ្ចប់រាល់លក្ខខណ្ឌបាត់បង់សិទ្ធិទាំងអស់។ ប្រសិនបើអាជ្ញាបណ្ណលក់អាវុធដែលបានចេញក្រោមមាត្រា 122 ឬមាត្រា 122B ត្រូវបានដកហូត ម្ចាស់អាជ្ញាបណ្ណត្រូវបាត់បង់សិទ្ធិក្នុងការទទួលបានអាជ្ញាបណ្ណថ្មីក្នុងរយៈពេល 1 ឆ្នាំ បន្ទាប់ពីការផុតកំណត់អាជ្ញាបណ្ណដែលត្រូវបានដកហូតនោះ។

(v)(1) អ្នកដាក់ពាក្យស្នើសុំ ឬម្ចាស់អាជ្ញាបណ្ណណាម្នាក់ ដែលមិនសុខចិត្ត ដោយសារការបដិសេធ ការដកហូត ឬការផ្អាកជាបណ្ដោះអាសន្ននូវអាជ្ញាបណ្ណលក់អាវុធក្រោមមាត្រា 122 ឬមាត្រា 122B អាចប្ដឹងឧទ្ធរណ៍តវ៉ានឹងការបដិសេធ ការដកហូត ឬការផ្អាកជាបណ្ដោះអាសន្ននោះបានតាមរយៈ៖ (i) ការដាក់ពាក្យស្នើសុំទៅស្នងការប៉ូលិសរដ្ឋដើម្បីសុំអាជ្ញាបណ្ណដែលបានរៀបរាប់ខាងលើ ក្នុងរយៈពេល 10 ថ្ងៃ គិតចាប់ពីថ្ងៃមានការបដិសេធ ការដកហូត ឬការផ្អាកជាបណ្ដោះអាសន្ន ដែលស្នងការរូបនោះអាចបង្គាប់ទៅអាជ្ញាធរផ្ដល់អាជ្ញាបណ្ណឱ្យចេញអាជ្ញាបណ្ណខាងលើ ប្រសិនបើបន្ទាប់ពីការបើកសវនាការរួច ស្នងការប៉ូលិសកំណត់ថា គ្មានមូលដ្ឋានសមស្របណាមួយសម្រាប់ការបដិសេធ ការផ្អាក ឬការដកហូតនោះឡើយ ហើយអ្នកដាក់ពាក្យសុំមិនត្រូវបានហាមឃាត់ដោយច្បាប់ពីការកាន់កាប់អាជ្ញាបណ្ណបែបនេះឡើយ ឬ (ii) ការដាក់ពាក្យប្ដឹងឧទ្ធរណ៍ទៅកាន់តុលាការតំបន់ដែលមានយុត្តាធិការដោយអនុលោមតាមកថាខណ្ឌ (2) នៃកថាខណ្ឌនេះ។

(2) អ្នកដាក់ពាក្យសុំ ឬម្ចាស់បណ្ណសម្គាល់ ម្ចាស់លិខិតអនុញ្ញាត ឬម្ចាស់អាជ្ញាបណ្ណណាម្នាក់ដែលមិនសុខចិត្តដោយសារការបដិសេធ ការដកហូត ឬការផ្អាកជាបណ្ដោះអាសន្ននូវលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណដែលបានចេញក្រោមមាត្រា 122, 122B, 122D, 129B, 131 ឬ 131F អាចដាក់បណ្ដឹងតវ៉ាដើម្បីសុំការពិនិត្យឡើងវិញតាមផ្លូវតុលាការ នៅតុលាការតំបន់ដែលមានយុត្តាធិការក្នុងក្រុង ឬស្រុកដែលអ្នកដាក់ពាក្យបានដាក់ពាក្យស្នើសុំ ឬជាកន្លែងដែលលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណនោះត្រូវបានចេញឱ្យប្រើប្រាស់ ក្នុងរយៈពេល 90 ថ្ងៃ បន្ទាប់ពីទទួលបានសេចក្ដីជូនដំណឹងអំពីការបដិសេធ ការដកហូត ឬការផ្អាកជាបណ្ដោះអាសន្ន ឬក្នុងរយៈពេល 90 ថ្ងៃ បន្ទាប់ពីការផុតកាលបរិច្ឆេទកំណត់ដែលអាជ្ញាធរផ្ដល់អាជ្ញាបណ្ណត្រូវឆ្លើយតបទៅកាន់អ្នកដាក់ពាក្យសុំ វៀរលែងតែសវនាការមួយត្រូវបានរៀបចំឡើងរួចរាល់ពីមុនមកដោយអនុលោមតាមមាត្រា 131S ឬ 131T ជំពូក 209A ឬជំពូក 258E។

(3) តុលាការតំបន់អាចបង្គាប់ឱ្យចេញ ឬស្ដារសុពលភាពលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណឡើងវិញបាន នៅពេលរកឃើញថា គ្មានមូលដ្ឋានសមស្របណាមួយសម្រាប់ការបដិសេធ ការផ្អាក ឬការដកហូតលិខិតអនុញ្ញាត បណ្ណសម្គាល់

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ឬអាជ្ញាបណ្ណនោះឡើយ ហើយដើមបណ្តឹងមិនត្រូវបានហាមឃាត់ដោយច្បាប់ពីការកាន់កាប់លិខិតអនុញ្ញាត ប័ណ្ណ ឬអាជ្ញាបណ្ណនោះទេ។

មាត្រា 33 ជំពូក 140 ដែលបានពោល ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 122 ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 122 (a) អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ដោយអនុលោមតាមមាត្រា 121F អាចផ្តល់ ឬបន្តសុពលភាពអាជ្ញាបណ្ណលក់ ជួល ជួលរយៈពេលវែង ទិញ ឬផ្ទេរតាមរូបភាពផ្សេងទៀតនូវអាវុធ និងគ្រាប់រំសេវសម្រាប់អាវុធទាំងនោះ ឬដើម្បីប្រកបអាជីវកម្មជាជាងធ្វើឬជួសជុលអាវុធ ជូនដល់បុគ្គលណាមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ ដែលមិនមែនជាបុគ្គលត្រូវហាមឃាត់ ហើយក៏មិនត្រូវបានចាត់ទុកថាមិនសក្តិសមទទួលបានអាជ្ញាបណ្ណដែលបានរៀបរាប់ខាងលើ ដោយអនុលោមតាមមាត្រា 121F និងជាបុគ្គលដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអ៊ីនធឺណិតសម្រាប់ហាងលក់អាវុធ ដែលជាកាតព្វកិច្ចកំណត់ក្រោមមាត្រា 125។

(b) រាល់អាជ្ញាបណ្ណទាំងអស់ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវឈ្មោះផ្លូវ និងលេខអាគារដែលប្រកបអាជីវកម្មនោះ ហើយអាជ្ញាបណ្ណនោះមិនត្រូវផ្តល់ការការពារដល់ម្ចាស់អាជ្ញាបណ្ណណាដែលប្រកបអាជីវកម្មរបស់ខ្លួននៅទីកន្លែងផ្សេងទៀតឡើយ ព្រមទាំងមិនផ្តល់សិទ្ធិឱ្យម្ចាស់អាជ្ញាបណ្ណនោះកាន់កាប់ ឬនាំយកអាវុធ ឬគ្រាប់រំសេវណាមួយចេញទៅក្រៅទីតាំងអាជីវកម្មដែលមានអាជ្ញាបណ្ណនោះឡើយ។

មាត្រា 34 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 122B ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 122B (a) ក្លឹបកីឡា ឬក្លឹបបាញ់កាំភ្លើងដែលបានចុះបញ្ជីបង្កើតឡើងដោយស្របច្បាប់ណាមួយ ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានអាជ្ញាបណ្ណដើម្បីលក់ ឬផ្គត់ផ្គង់គ្រាប់រំសេវសម្រាប់ការបាញ់កាំភ្លើងដែលមានបទប្បញ្ញត្តិនៅលើទីតាំងរបស់ខ្លួន ដូចជាការបាញ់កូនចានហោះ ការបាញ់ស៊ីបផ្ទាំងគោលដៅ នៅពេលដាក់ពាក្យស្នើសុំទៅអាជ្ញាធរផ្តល់អាជ្ញាបណ្ណ និងដោយអនុលោមតាមមាត្រា 121F។ ទោះជាយ៉ាងណាក៏ដោយ អាជ្ញាបណ្ណក្លឹបបែបនេះ ក្នុងនាមក្លឹបខាងលើ ត្រូវចេញជូន និងត្រូវប្រើប្រាស់ដោយមន្ត្រី ឬសមាជិកដែលទទួលបានការអនុញ្ញាតត្រឹមត្រូវរបស់ក្លឹបនោះ ដែលមានអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ និងជាបុគ្គលដែលមិនត្រូវបាត់បង់សិទ្ធិក្នុងការទទួលបានអាជ្ញាបណ្ណ ឬប័ណ្ណ ក្រោមមាត្រា 121F ដែលបានរៀបរាប់ខាងលើឡើយ។

(b) ក្លឹប ឬគ្រឹះស្ថានណាមួយដែលបានចុះបញ្ជីបង្កើតឡើងក្រោមច្បាប់របស់រដ្ឋម៉ាសាឈូសិត មានទីលានបាញ់កាំភ្លើង ឬបន្ទប់បាញ់កាំភ្លើងនៅនឹងកន្លែងផ្ទាល់ អាចទទួលបានអាជ្ញាបណ្ណពីប៉ូលិសរដ្ឋ បន្ទាប់ពីមានការស៊ើបអង្កេតរួចរាល់ សម្រាប់ការកាន់កាប់ ការរក្សាទុក និងការប្រើប្រាស់អាវុធដែលមានបង់ផ្លុកគ្រាប់ច្រើន និងគ្រាប់រំសេវសម្រាប់អាវុធទាំងនោះ ព្រមទាំងឧបករណ៍បញ្ចូនគ្រាប់សមត្ថភាពខ្ពស់សម្រាប់ប្រើប្រាស់នៅលើទីតាំងរបស់ក្លឹប។ ទោះជាយ៉ាងណាក៏ដោយ ភាគហ៊ុនិកក្លឹបយ៉ាងហោចណាស់ 1 នាក់ ត្រូវតែមានលក្ខណសម្បត្តិគ្រប់គ្រាន់ ហើយសក្តិសមនឹងទទួលបានអាជ្ញាបណ្ណកាន់កាប់អាវុធក្រោមមាត្រា 121F។ បន្ថែមលើនេះ អាវុធធុនធំបែបនេះអាចត្រូវបានប្រើប្រាស់ក្រោមអាជ្ញាបណ្ណក្លឹបបានសម្រាប់តែសមាជិកណាដែលមានអាជ្ញាបណ្ណកាន់កាប់អាវុធមានសុពលភាព ដែលបានចេញដោយអនុលោមតាមមាត្រា 131 តែប៉ុណ្ណោះ ឬដោយបុគ្គលផ្សេងទៀតដែលក្លឹបអនុញ្ញាតក្នុងអំឡុងពេលស្ថិតក្រោមការត្រួតពិនិត្យផ្ទាល់ពីគ្រូបង្ហាត់សុវត្ថិភាពអាវុធដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សា ឬសមាជិកក្លឹបដែលមានអាជ្ញាបណ្ណកាន់កាប់អាវុធមានសុពលភាពតែប៉ុណ្ណោះ។

(c) ក្លឹបត្រូវ៖

(i) មិនអនុញ្ញាតឱ្យមានការបាញ់ប្រហារលើផ្ទាំងគោលដៅដែលបង្ហាញពីរូបរាងកាយមនុស្ស រូបទីងមោង ឬរូបតំណាងមនុស្ស ស្រមោលរូបរាងមនុស្ស ឬរូបភាពមនុស្សណាមួយឡើយ លើកលែងតែត្រូវបានធ្វើឡើងដោយបុគ្គលិកសន្តិសុខសាធារណៈក្នុងការបំពេញភារកិច្ចផ្លូវការរបស់ខ្លួន។

(ii) មិនអនុញ្ញាតឱ្យមានការយកអាវុធដែលមានបង់ផ្លុកគ្រាប់ច្រើនណាមួយចេញពីទីតាំងឡើយ លើកលែងតែត្រូវបានអនុញ្ញាតដោយច្បាប់ក្នុងគោលបំណងដើម្បី៖ (A) ផ្ទេរទៅឱ្យហាងលក់អាវុធមានអាជ្ញាបណ្ណ (B) ដឹកជញ្ជូនទៅកាន់ជាងធ្វើឬជួសជុលអាវុធដែលមានអាជ្ញាបណ្ណ ដើម្បីធ្វើការជួសជុល (C) ដឹកជញ្ជូនទៅបាញ់ស៊ីបផ្ទាំងគោលដៅ ឬបាញ់កូនចានហោះ នៅក្នុងទីតាំងក្លឹបផ្សេងទៀតដែលបានចុះបញ្ជីបង្កើតឡើងក្រោមច្បាប់របស់រដ្ឋម៉ាសាឈូសិត (D) ដឹកជញ្ជូនទៅចូលរួមការពិព័រណ៍ ឬកម្រោងអប់រំ ឬព្រឹត្តិការណ៍នានាដែលឧបត្ថម្ភ ស្ថិតក្រោមការត្រួតពិនិត្យ ឬទទួលបានការអនុម័តពីទីភ្នាក់ងារអនុវត្តច្បាប់សាធារណៈ ឬអង្គភាពដែលត្រូវបានទទួលស្គាល់ថ្នាក់ជាតិ ឬថ្នាក់រដ្ឋ ដែលលើកកម្ពស់ជំនាញ ឬការអប់រំអំពីអាវុធពាក់កណ្តាលស្វ័យប្រវត្តិ (E) បរបាញ់សត្វដោយអនុលោមតាមជំពូក 131 ឬ (F) ប្រគល់អាវុធជូនអាជ្ញាធរដោយអនុលោមតាមមាត្រា 131O។

(iii) រក្សាទុកដោយសុវត្ថិភាពនៅក្នុងប្រអប់ចាក់សោជិត និងត្រូវដោះគ្រាប់ចេញក្នុងអំឡុងពេលនៃការដឹកជញ្ជូនស្របច្បាប់ណាមួយក្រោមមាត្រា 131C នូវរាល់អាវុធដែលមានបង់ផ្លុកគ្រាប់ច្រើន ឬឧបករណ៍បញ្ជូនគ្រាប់សមត្ថភាពខ្ពស់ទាំងអស់ដែលរក្សាទុកនៅក្នុងទីតាំងនៅពេលមិនប្រើប្រាស់។

(iv) ដាក់របាយការណ៍ប្រចាំឆ្នាំជូនទៅស្នងការប៉ូលិសរដ្ឋ និងប្រធាននាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដោយធ្វើបញ្ជីរាយនាមអាវុធដែលមានបង់ផ្លុកគ្រាប់ច្រើន និងឧបករណ៍បញ្ជូនគ្រាប់សមត្ថភាពខ្ពស់ទាំងអស់ដែលជាកម្មសិទ្ធិ ឬត្រូវបានកាន់កាប់ក្រោមអាជ្ញាបណ្ណនេះ និង

(v) អនុញ្ញាតឱ្យស្នងការប៉ូលិសធ្វើការត្រួតពិនិត្យអាវុធទាំងអស់ដែលជាកម្មសិទ្ធិ ឬត្រូវបានកាន់កាប់ដោយក្លឹប តាមការស្នើសុំក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា។

(d) រដ្ឋមន្ត្រីក្រសួងសន្តិសុខនិងសុវត្ថិភាពសាធារណៈ អាចបង្កើតវិធាន និងបទប្បញ្ញត្តិទាំងឡាយណាដែលរដ្ឋមន្ត្រីយល់ឃើញថាចាំបាច់ដើម្បីអនុវត្តបញ្ញត្តិនៃមាត្រានេះ។

(e) បុគ្គលណាក៏ដោយដែលលក់គ្រាប់រំសេវនៅក្នុងរដ្ឋម៉ាសាឈូសិត ដោយគ្មានអាជ្ញាបណ្ណដូចដែលបានចែងក្នុងមាត្រា 122 ឬមាត្រានេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនតិចជាង 500 ដុល្លារ និងមិនលើសពី 1,000 ដុល្លារ ឬផ្តន្ទាទោសដាក់ពន្ធនាគារមិនតិចជាង 6 ខែ និងមិនលើសពី 2 ឆ្នាំ។

មាត្រា 35 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយការដកចេញនូវមាត្រា 122C ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

មាត្រា 122C (a) បុគ្គលណាក៏ដោយដែលលក់ស្ប្រ៉ាយការពារខ្លួន ដោយគ្មានអាជ្ញាបណ្ណដូចបានចែងក្នុងមាត្រា 122 ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនលើសពី 1,000 ដុល្លារ ឬផ្តន្ទាទោសដាក់ពន្ធនាគារនៅក្នុងមណ្ឌលកែប្រែក្នុងរយៈពេលមិនលើសពី 2 ឆ្នាំ។

(b) បុគ្គលណាក៏ដោយដែលមានអាជ្ញាបណ្ណក្រោមមាត្រា 122 ហើយលក់ស្ប្រ៉ាយការពារខ្លួនទៅឱ្យបុគ្គលអាយុក្រោម 18 ឆ្នាំ ប្រសិនបើបុគ្គលអាយុក្រោម 18 ឆ្នាំនោះមិនមានលិខិតអនុញ្ញាតប្រើប្រាស់ស្ប្រ៉ាយការពារខ្លួនទេនោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនលើសពី 300 ដុល្លារ។

(c) បុគ្គលអាយុក្រោម 18 ឆ្នាំ ដែលកាន់កាប់ស្ប្រ៉ាយការពារខ្លួនដោយគ្មានលិខិតអនុញ្ញាតប្រើប្រាស់ស្ប្រ៉ាយការពារខ្លួន ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនលើសពី 300 ដុល្លារ។

មាត្រា 36 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 122D ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 122D (a) បុគ្គលអាយុក្រោម 18 ឆ្នាំ មិនអាចទិញ ឬកាន់កាប់ស្ប្រ៉ាយការពារខ្លួន ដោយគ្មានលិខិតអនុញ្ញាតប្រើប្រាស់ស្ប្រ៉ាយការពារខ្លួន ដែលចេញដោយអាជ្ញាធរផ្តល់អាជ្ញាបណ្ណ អនុលោមតាមមាត្រា 121F បានឡើយ។ លិខិតអនុញ្ញាតប្រើប្រាស់ស្ប្រ៉ាយការពារខ្លួន ត្រូវមានសុពលភាពសម្រាប់ការទិញ និងការកាន់កាប់ស្ប្រ៉ាយការពារខ្លួន រួមទាំងស្ប្រ៉ាយគីមីបង្ហូរទឹកភ្នែក ស្ប្រ៉ាយម្ទេស ឬសារធាតុរាវ ឧស្ម័ន ឬលម្អងម្សៅផ្សេងទៀតដែលត្រូវបានបាញ់ចេញតាមកម្លាំងរុញច្រានក្នុងលក្ខណៈប្រហាក់ប្រហែលគ្នា ដែលរចនាឡើងដើម្បីធ្វើឱ្យបាត់បង់សមត្ថភាពជាបណ្តោះអាសន្ន។

(b) អាជ្ញាធរផ្តល់អាជ្ញាបណ្ណក្នុងតំបន់ អាចចេញលិខិតអនុញ្ញាតប្រើប្រាស់ស្ប្រ៉ាយការពារខ្លួនឱ្យបុគ្គលអាយុយ៉ាងតិច 15 ឆ្នាំ ប៉ុន្តែក្រោម 18 ឆ្នាំបាន ប្រសិនបើបុគ្គលនោះមិនមែនជាបុគ្គលត្រូវហាមឃាត់ ឬមិនសក្តិសម អនុលោមតាមមាត្រា 121F។ លិខិតអនុញ្ញាតប្រើប្រាស់ស្ប្រ៉ាយការពារខ្លួន ត្រូវចេញឱ្យប្រើប្រាស់ក្នុងគោលបំណងតែមួយគត់គឺសម្រាប់ការទិញ និងការកាន់កាប់ស្ប្រ៉ាយការពារខ្លួន ហើយត្រូវបញ្ជាក់ឱ្យបានច្បាស់ថា លិខិតនេះមានសុពលភាពសម្រាប់តែគោលបំណងកំណត់បែបនោះប៉ុណ្ណោះ។ លិខិតអនុញ្ញាតនេះ អាចត្រូវបានចេញឱ្យបុគ្គលអាយុយ៉ាងតិច 12 ឆ្នាំ ប៉ុន្តែក្រោម 15 ឆ្នាំបាន ប្រសិនបើបុគ្គលនោះមិនមែនជាបុគ្គលត្រូវហាមឃាត់ ឬមិនសក្តិសម អនុលោមតាមមាត្រា 121F និងប្រសិនបើអ្នកដាក់ពាក្យសុំបានដាក់ជូនមកជាមួយពាក្យសុំរបស់ខ្លួន នូវលិខិតបញ្ជាក់ពីឪពុកម្តាយ ឬអាណាព្យាបាលរបស់អ្នកដាក់ពាក្យសុំ ដែលផ្តល់ការអនុញ្ញាតឱ្យដាក់ពាក្យសុំលិខិតអនុញ្ញាតនេះ។

(c) លិខិតអនុញ្ញាតប្រើប្រាស់ស្ប្រ៉ាយការពារខ្លួន ត្រូវមានសុពលភាពរយៈពេល 3 ឆ្នាំ ហើយត្រូវអស់សុពលភាពចំថ្ងៃខួបកំណើតរបស់ម្ចាស់លិខិតអនុញ្ញាត ដែលកើតឡើងមិនក្រោម 3 ឆ្នាំ និងមិនលើសពី 4 ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិត។ រាល់លិខិតអនុញ្ញាតទាំងឡាយណាដែលចេញឱ្យអ្នកដាក់ពាក្យសុំដែលកើតនៅថ្ងៃទី 29 ខែកុម្ភៈ ត្រូវអស់សុពលភាពនៅថ្ងៃទី 1 ខែមីនា។

(d) ម្ចាស់លិខិតអនុញ្ញាតត្រូវរាយការណ៍អំពីការផ្លាស់ប្តូរអាសយដ្ឋានណាមួយតាមរយៈប្រព័ន្ធចុះបញ្ជីអាវុធតាមអេឡិចត្រូនិក ដែលគ្រប់គ្រងដោយប្រធាននាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ។ ការជូនដំណឹងបែបនេះ ត្រូវធ្វើឡើងនៅលើផតថល ក្នុងរយៈពេល 30 ថ្ងៃ គិតចាប់ពីថ្ងៃកើតមានករណីនោះ។ ការខកខានមិនបានជូនដំណឹងតាមការកំណត់ ត្រូវចាត់ទុកជាមូលហេតុនៃការដកហូត ឬការផ្អាកជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតនោះ។

មាត្រា 37 ជំពូក 140 ដែលបានពោល ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 123 ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 123 (a) ដូចដែលបានប្រើប្រាស់នៅក្នុងមាត្រានេះ ពាក្យថា “ម្ចាស់អាជ្ញាបណ្ណ” ត្រូវមានន័យថាជាបុគ្គលដែលមានអាជ្ញាបណ្ណលក់អាវុធក្រោមមាត្រា 122។

(b) ម្ចាស់អាជ្ញាបណ្ណត្រូវតែមានទីតាំងអាជីវកម្មដែលមិនមែនជាលំនៅឋានសម្រាប់រស់នៅ ជាកន្លែងត្រូវអនុវត្តរាល់ប្រតិបត្តិការទាំងពួង និងជាកន្លែងត្រូវរក្សាទុករាល់កំណត់ត្រាផ្សេងៗទាំងអស់។

(c) ម្ចាស់អាជ្ញាបណ្ណត្រូវដាក់បង្ហាញអាជ្ញាបណ្ណលក់របស់ខ្លួន ឬច្បាប់ចម្លងអាជ្ញាបណ្ណដែលបញ្ជាក់ដោយអាជ្ញាធរផ្តល់អាជ្ញាបណ្ណ នៅត្រង់ទីតាំងដែលអាចមើលឃើញ និងអានបានដោយងាយ។ ទោះជាយ៉ាងណាក៏ដោយ មិនត្រូវដាក់បង្ហាញអាវុធណាមួយនៅតាមផ្ទាំងបង្អួចខាងក្រៅទីតាំងអាជីវកម្ម ឬនៅទីកន្លែងផ្សេងទៀតដែលអាចមើលឃើញពីខាងក្រៅទីតាំងអាជីវកម្មបានដោយងាយស្រួលនោះឡើយ។

(d) ម្ចាស់អាជ្ញាបណ្ណត្រូវបិទផ្សាយជាសាធារណៈឱ្យឃើញច្បាស់ និងចែកផ្សាយនៅគ្រប់បញ្ជរទិញទំនិញនីមួយៗ នូវសេចក្តីជូនដំណឹងដែលផ្តល់ព័ត៌មានអំពី៖ (i) ការដឹកជញ្ជូន និងការរក្សាទុកអាវុធដោយសុវត្ថិភាព ដែលរៀបចំឡើង និងផ្តល់ឱ្យដោយនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដែលនាយកដ្ឋាននេះត្រូវបង្កើត និងរក្សាទុកនៅលើគេហទំព័ររបស់ខ្លួនសម្រាប់ទាញយក នូវស្លាកសញ្ញាដែលផ្តល់ព័ត៌មានទាំងនេះ និង (ii) ព័ត៌មានស្តីពីការបង្ការអត្តឃាត ដោយអនុលោមតាមកថាខណ្ឌ (e)។

(e) ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ដោយសហការជាមួយនាយកដ្ឋានសុខាភិបាលសាធារណៈ ត្រូវរៀបចំសេចក្តីជូនដំណឹងមួយដែលផ្តល់ព័ត៌មានស្តីពីការបង្ការអត្តឃាត ដែលត្រូវបិទផ្សាយនៅលើគេហទំព័ររបស់ការិយាល័យប្រតិបត្តិ ហើយត្រូវបិទផ្សាយ និងចែកផ្សាយដោយអនុលោមតាមកថាខណ្ឌ (d)។ សេចក្តីជូនដំណឹងនេះត្រូវរួមបញ្ចូលព័ត៌មានជាអាទិ៍៖ (i) ព័ត៌មានអំពីសញ្ញា និងរោគសញ្ញានៃជំងឺបាក់ទឹកចិត្ត (ii) ខ្សែទូរសព្ទបន្ទាន់សម្រាប់បង្ការអត្តឃាតរបស់រដ្ឋនិងសហព័ន្ធ និង (iii) ធនធានសម្រាប់បុគ្គលដែលប្រឈមនឹងហានិភ័យនៃការធ្វើអត្តឃាត។

(f) មុនពេលមានការផ្ទេរណាមួយ ម្ចាស់អាជ្ញាបណ្ណត្រូវផ្ទៀងផ្ទាត់ស្ថានភាពអាជ្ញាបណ្ណ បណ្ណសម្គាល់ លិខិតអនុញ្ញាត ឬឯកសារលើកលែងណាមួយ រួមទាំងការផ្ទៀងផ្ទាត់បញ្ជាក់ថា បុគ្គលដែលបង្ហាញអាជ្ញាបណ្ណ បណ្ណសម្គាល់ លិខិតអនុញ្ញាត ឬឯកសារនោះ គឺជាម្ចាស់កម្មសិទ្ធិស្របច្បាប់នៃឯកសារទាំងនោះ។ មិនត្រូវមានការផ្ទេរអាវុធ ឬគ្រាប់រំសេវណាមួយទៅឱ្យបុគ្គលណាម្នាក់ដែលមិនមានអាជ្ញាបណ្ណ បណ្ណសម្គាល់ លិខិតអនុញ្ញាត ឬឯកសារលើកលែងដែលតម្រូវឱ្យមាន នៅពេលធ្វើប្រតិបត្តិការនោះឡើយ។

(g) នៅពេលទទួលបានអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតដែលហួសសុពលភាព ត្រូវបានផ្អាកជាបណ្តោះអាសន្ន ឬត្រូវបានដកហូត ម្ចាស់អាជ្ញាបណ្ណ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ត្រូវ៖ (i) រាយការណ៍ភ្លាមៗអំពីការប៉ុនប៉ងធ្វើប្រតិបត្តិការនោះទៅកាន់នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដោយប្រើប្រាស់ប្រព័ន្ធចុះបញ្ជីអាវុធអេឡិចត្រូនិករបស់នាយកដ្ឋាន រួមមានជាអាទិ៍ ព័ត៌មានទាំងអស់ដែលបានកត់ត្រាទុកអនុលោមតាមកថាខណ្ឌ (h) (ii) ដកហូតយកបណ្ណសម្គាល់ លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនោះមកកាន់កាប់ និងបញ្ជូនឯកសារនោះភ្លាមៗទៅកាន់អាជ្ញាធរផ្តល់អាជ្ញាបណ្ណប្រចាំទីក្រុង ឬស្រុកដែលម្ចាស់អាជ្ញាបណ្ណប្រកបអាជីវកម្ម (iii) ចេញបង្កាន់ដៃមួយឱ្យម្ចាស់អាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាត តាមទម្រង់បែបបទដែលផ្តល់ដោយប្រធាននាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដែលត្រូវបញ្ជាក់ថា អាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតរបស់ម្ចាស់ឯកសារ បានហួសសុពលភាព ត្រូវបានផ្អាកជាបណ្ដោះអាសន្ន ឬត្រូវបានដកហូត ហើយត្រូវបានដកហូតទុកដោយម្ចាស់អាជ្ញាបណ្ណលក់អាវុធ និងបានបញ្ជូនទៅកាន់អាជ្ញាធរផ្តល់អាជ្ញាបណ្ណរួចហើយ ដែលបង្កាន់ដៃនេះត្រូវមានសុពលភាពរយៈពេល 90 ថ្ងៃ ក្នុងគោលបំណងផ្តល់អភ័យឯកសិទ្ធិពីការចោទប្រកាន់បទព្រហ្មទណ្ឌក្រោមមាត្រា 10 នៃជំពូក 269 និង (iv) ជូនដំណឹងដល់ម្ចាស់អាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាត អំពីកាតព្វកិច្ចរបស់ពួកគេក្នុងការប្រគល់អាវុធរបស់ខ្លួនភ្លាមៗជូនទៅអាជ្ញាធរផ្តល់អាជ្ញាបណ្ណមូលដ្ឋានរបស់ខ្លួន ក្រោមមាត្រា 129D។ ម្ចាស់អាជ្ញាបណ្ណត្រូវទទួលបានអភ័យឯកសិទ្ធិរួចផុតពីទំនួលខុសត្រូវរដ្ឋប្បវេណី និងព្រហ្មទណ្ឌចំពោះអនុលោមភាពដោយសុទ្ធចិត្តតាមបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងនេះ។

(h) ម្ចាស់អាជ្ញាបណ្ណត្រូវរៀបចំ និងរក្សាទុកកំណត់ត្រាប្រតិបត្តិការអាវុធទាំងអស់នៅនឹងកន្លែងផ្ទាល់ ឬតាមប្រព័ន្ធអេឡិចត្រូនិក ហើយកំណត់ត្រាដែលបានរៀបរាប់ខាងលើ ត្រូវបើកទូលាយគ្រប់ពេលវេលាសម្រាប់ការត្រួតពិនិត្យរបស់មន្ត្រីនគរបាល។ មុនពេលមានការផ្ទេរ ឬការប្រគល់អាវុធ ឬគ្រាប់រំសេវណាមួយ ដែលត្រូវបានលក់ ជួល ជួលរយៈពេលវែង ឬផ្ទេរតាមរូបភាពផ្សេងទៀត ត្រូវធ្វើការកត់ត្រាចូលឱ្យបានច្បាស់ និងអាចអានបាន និងរក្សាទុកក្នុងកំណត់ត្រានៅនឹងកន្លែងផ្ទាល់ ឬតាមប្រព័ន្ធអេឡិចត្រូនិក ដោយបញ្ជាក់លម្អិតអំពី៖ (i) បរិយាយពេញលេញអំពីអាវុធ និងគ្រាប់រំសេវដែលបានផ្ទេរ រួមមាន ម៉ាក លេខស៊េរី ប្រភេទអាវុធ និងការកំណត់ចំណាត់ថ្នាក់ជាអាវុធដែលមានបង់ផ្ទុកគ្រាប់ច្រើន ប្រសិនបើមាន (ii) ថាអាវុធ ឬគ្រាប់រំសេវនោះ ត្រូវបានលក់ ជួល ឬជួលរយៈពេលវែង និងកាលបរិច្ឆេទនៃប្រតិបត្តិការនោះ (iii) លេខសម្គាល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬបណ្ណសម្គាល់របស់បុគ្គលដែលទទួលបានអាវុធ ឬគ្រាប់រំសេវនោះ ព្រមទាំងភេទ អាសយដ្ឋានស្នាក់នៅ និងមុខរបររបស់ពួកគេ និង (iv) ឈ្មោះរបស់អ្នកទិញ អ្នកជួល ឬអ្នកជួលរយៈពេលវែងដូចដែលបុគ្គលនោះបានសរសេរដោយផ្ទាល់ដៃនៅក្នុងសៀវភៅកំណត់ត្រាការលក់ និងដូចដែលបានបញ្ជាក់ផ្ទៀងផ្ទាត់ដោយអត្តសញ្ញាណបណ្ណដែលមានសុពលភាពរបស់រដ្ឋឬសហព័ន្ធ។ កថាខណ្ឌនេះមិនត្រូវយកមកអនុវត្តចំពោះជាងធ្វើឬជួសជុលអាវុធ ពាក់ព័ន្ធនឹងការជួសជុល ការកែច្នៃទម្រង់ ឬការថែទាំអាវុធឡើយ លើកលែងតែជាងធ្វើឬជួសជុលអាវុធនោះ បានផលិតអាវុធសម្រាប់អ្នកទិញ ប៉ុន្តែជាងធ្វើឬជួសជុលអាវុធខាងលើ ត្រូវតែរក្សាទុកកំណត់ត្រាការងាររបស់ខ្លួន រួមជាមួយឈ្មោះ និងអាសយដ្ឋានរបស់អតិថិជនពួកគេផងដែរ។

(i) ម្ចាស់អាជ្ញាបណ្ណ ត្រូវរាយការណ៍ភ្លាមៗនៅពេលបានដឹងអំពីការបាត់បង់ ឬការលួចយកអាវុធ ឬគ្រាប់រំសេវណាមួយពីម្ចាស់អាជ្ញាបណ្ណ ឬពីទីតាំងអាជីវកម្មរបស់ម្ចាស់អាជ្ញាបណ្ណ ទៅកាន់នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ តាមរយៈប្រព័ន្ធចុះបញ្ជីអាវុធអេឡិចត្រូនិក ដែលបានបង្កើតឡើងអនុលោមតាមមាត្រា 121B។

(j) ម្ចាស់អាជ្ញាបណ្ណអាចលក់ ឬផ្ទេរអាវុធ និងគ្រាប់រំសេវ នៅក្នុងកិច្ចប្រជុំធម្មតាណាមួយរបស់ក្លឹបអ្នកប្រមូលទិញអាវុធដែលបានចុះបញ្ជីស្របច្បាប់ ឬនៅក្នុងពិព័រណ៍អាវុធដែលដាក់បង្ហាញជូនសាធារណជនទូទៅ។ ទោះជាយ៉ាងណាក៏ដោយ ម្ចាស់អាជ្ញាបណ្ណត្រូវតែអនុលោមតាមរាល់បទប្បញ្ញត្តិផ្សេងទៀតទាំងអស់នៃមាត្រានេះ ហើយការលក់ ឬការផ្ទេរបែបនោះ ត្រូវតែស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិទាំងរបស់សហព័ន្ធនិងរដ្ឋ។

(k) មិនមានម្ចាស់អាជ្ញាបណ្ណណាម្នាក់ត្រូវបំពេញការបញ្ជាទិញអាវុធ ឬគ្រាប់រំសេវណាមួយដែលទទួលបានតាមរយៈប្រៃសណីយ៍ ទូរសារ ទូរសព្ទ អ៊ីនធឺណិត ឬទូរគមនាគមន៍ផ្សេងទៀតឡើយ លើកលែងតែប្រតិបត្តិការនោះរួមបញ្ចូលទាំងការបង្ហាញដោយផ្ទាល់នូវអាជ្ញាបណ្ណ បណ្ណសម្គាល់ លិខិតអនុញ្ញាត ឬឯកសារដែលតម្រូវឱ្យមាន ដូចបានកំណត់នៅក្នុងនេះ មុនពេលមានការលក់ ការប្រគល់ ឬទម្រង់ណាមួយនៃការផ្ទេរ ឬការកាន់កាប់។ ប្រតិបត្តិការរវាងហាងលក់អាវុធដែលទទួលបានអាជ្ញាបណ្ណពីសហព័ន្ធ ត្រូវទទួលបានការលើកលែងពីកថាខណ្ឌនេះ។

(l) ម្ចាស់អាជ្ញាបណ្ណត្រូវធានាថា រាល់អាវុធនិងគ្រាប់រំសេវទាំងអស់ មិនត្រូវមានផ្ទុកគ្រាប់ឡើយនៅពេលប្រគល់ ហើយការប្រគល់នោះត្រូវធ្វើឡើងតែចំពោះបុគ្គលណាដែលមានអាជ្ញាបណ្ណ បណ្ណសម្គាល់ លិខិតអនុញ្ញាត ឬការលើកលែងត្រឹមត្រូវ ក្នុងការកាន់កាប់អាវុធ ឬគ្រាប់រំសេវដែលមាននៅក្នុងការប្រគល់នោះ។

(m) ម្ចាស់អាជ្ញាបណ្ណណាម្នាក់ ឬនិយោជិត ឬភ្នាក់ងារណាមួយរបស់ម្ចាស់អាជ្ញាបណ្ណនោះ ដែលល្មើសនឹងមាត្រានេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនតិចជាង 1,000 ដុល្លារ និងមិនលើសពី 10,000 ដុល្លារ ឬផ្តន្ទាទោសដាក់ពន្ធនាគារមិនតិចជាង 1 ឆ្នាំ និងមិនលើសពី 10 ឆ្នាំ ឬទាំងការពិន័យជាប្រាក់ ទាំងទោសដាក់ពន្ធនាគារ។

(n) អាជ្ញាធរផ្តល់អាជ្ញាបណ្ណក្នុងតំបន់ ត្រូវចូលទៅក្នុងទីតាំងអាជីវកម្មរបស់ម្ចាស់អាជ្ញាបណ្ណណាមួយ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំប្រតិទិន ក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា ហើយត្រូវសាកសួរព័ត៌មាន និងត្រួតពិនិត្យកំណត់ត្រា បញ្ជីសារពើភណ្ឌ គោលនយោបាយ និងនីតិវិធីរបស់ម្ចាស់អាជ្ញាបណ្ណ ក្នុងគោលបំណងអនុវត្តមាត្រានេះ។ ម្ចាស់អាជ្ញាបណ្ណទាំងឡាយណាដែលរកឃើញថាបានល្មើសនឹងមាត្រានេះ ត្រូវប្រឈមនឹងការផ្អាកជាបណ្ដោះអាសន្ន ឬការដកហូតអាជ្ញាបណ្ណលក់របស់ខ្លួន។ ក្រសួងប៉ូលិសរដ្ឋអាចរ៉ាប់រងទំនួលខុសត្រូវលើការផ្តល់អាជ្ញាបណ្ណជំនួសអាជ្ញាធរផ្តល់អាជ្ញាបណ្ណក្នុងតំបន់សម្រាប់ឆ្នាំប្រតិទិននោះបាន ប្រសិនបើមានការដាក់លិខិតស្នើសុំជាលាយលក្ខណ៍អក្សរយ៉ាងហោចណាស់ 6 ខែ មុនពេលការត្រួតពិនិត្យដែលតម្រូវឱ្យមានណាមួយ។ ក្នុងករណីដែលអាជ្ញាធរផ្តល់អាជ្ញាបណ្ណមូលដ្ឋានខកខានមិនបានធ្វើការត្រួតពិនិត្យម្ចាស់អាជ្ញាបណ្ណ ដោយអនុលោមតាមអនុមាត្រានេះទេ ក្រសួងប៉ូលិសរដ្ឋអាចក្លាយជាអាជ្ញាធរត្រួតពិនិត្យជំនួសបាន។ ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ត្រូវប្រកាសឱ្យប្រើប្រាស់វិធាននិងបទប្បញ្ញត្តិទាំងឡាយដើម្បីសម្រេចបាននូវគោលបំណងរបស់កថាខណ្ឌនេះ ដែលមានជាអាទិ៍៖ (i) កាលវិភាគនៃការត្រួតពិនិត្យ នីតិវិធី ស្តង់ដា និងលក្ខខណ្ឌតម្រូវនៃការរាយការណ៍ (ii) នីតិវិធី និងទណ្ឌកម្មសម្រាប់ការល្មើសរបស់ម្ចាស់អាជ្ញាបណ្ណ និងការត្រួតពិនិត្យឡើងវិញ និង (iii) ដំណើរការ និងស្តង់ដាសម្រាប់អាជ្ញាធរផ្តល់អាជ្ញាបណ្ណក្នុងតំបន់ធ្វើការស្នើសុំ ឬការដកហូតទំនួលខុសត្រូវលើការត្រួតពិនិត្យទៅឱ្យ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ក្រសួងប៉ូលិសរដ្ឋ ឬការខកខានមិនបានត្រួតពិនិត្យដូចមានចែកជាកាតព្វកិច្ចនៅក្នុងកថាខណ្ឌនេះ។ គ្មានការចែងណាមួយនៅក្នុងនេះ ត្រូវហាមឃាត់ទីភ្នាក់ងារអនុវត្តច្បាប់ផ្សេងទៀតណាមួយ មិនឱ្យធ្វើការត្រួតពិនិត្យបែបនេះ ដោយអនុលោមតាមដីកាឆែកឆេរដែលមានសុពលភាព ចេញដោយតុលាការមានសមត្ថកិច្ចនោះឡើយ។

(o) ក្រោមមាត្រា 122 គ្មានម្ចាស់អាជ្ញាបណ្ណណាម្នាក់ត្រូវលក់ ជួល ជួលរយៈពេលវែង ឬផ្ទេរតាមរូបភាពផ្សេងទៀតនូវអាវុធណាមួយដែលបានពណ៌នានៅក្នុងកថាខណ្ឌនេះឡើយ លើកលែងតែការផ្ទេរនោះធ្វើឡើងជូនចំពោះអង្គភាពអាជីវកម្មដែលជាអ្នកបោះដុំអាវុធជាចម្បង ហើយផ្អែកតាមលក្ខខណ្ឌរបស់ខ្លួន ការផ្ទេរនោះត្រូវហាមឃាត់អ្នកទិញមិនឱ្យលក់អាវុធនោះបន្តទៅឱ្យហាងលក់អាវុធរាយ ឬអ្នកប្រើប្រាស់នៅក្នុងរដ្ឋម៉ាសាឈូសិតឡើយ។ កថាខណ្ឌនេះត្រូវអនុវត្តចំពោះ៖

(i) អាវុធណាដែលមានគ្រោង កាណុង ស៊ីឡាំង បន្ទះស្លាយ ឬដុំបិទបាតកាណុងដែលផ្សំឡើងពី៖ (A) លោហៈធាតុណាមួយដែលមានចំណុចរលាយទាបជាង 900 អង្សាហ្វារិនហៃ។ (B) លោហៈធាតុណាមួយ ដែលមានកម្លាំងទាញដាច់អតិបរមាតិចជាង 55.000 ផោនក្នុងមួយអ៊ីញការ៉េ។ ឬ (C) លោហៈម្សៅណាមួយដែលមានដង់ស៊ីតេទាបជាង 7.5 ក្រាមក្នុងមួយសង់ទីម៉ែត្រគូប (7.5 g/cm³)។ អនុប្រយោគនេះមិនត្រូវអនុវត្តចំពោះម៉ាកនិងម៉ូដែលណាមួយរបស់អាវុធដែលមានអាវុធគំរូចំនួន 3 ដើមក្នុងស្ថានភាពថ្មី ឆ្លងកាត់ការសាកល្បងដូចខាងក្រោមដោយជោគជ័យទាំងអស់ឡើយ៖ គំរូនីមួយៗនៃអាវុធទាំង 3 ដើមនោះ ត្រូវតែបាញ់ឱ្យបានចំនួន 600 គ្រាប់ ដោយត្រូវឈប់រៀងរាល់ 100 គ្រាប់ម្តង ដើម្បីតឹងវីសធូរណាមួយ និងដើម្បីសម្អាតអាវុធនោះ ប្រសិនបើតម្រូវតាមកាលវិភាគសម្អាតនៅក្នុងសៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់ និងតាមតម្រូវការចាំបាច់ដើម្បីបញ្ចូលគ្រាប់ទៅក្នុងបង់ទទេ ឬបង់វិលឱ្យអស់ចំណុះ មុនពេលបន្តបាញ់។ ចំពោះអាវុធណាដែលត្រូវបានបញ្ចូលគ្រាប់តាមរូបភាពផ្សេងក្រៅពីការប្រើបង់ដោះចេញបាន អ្នកធ្វើតេស្តសាកល្បងក៏ត្រូវផ្អាករយៈពេល 10 នាទី រៀងរាល់ពេលបាញ់បាន 50 គ្រាប់ម្តងផងដែរ។ គ្រាប់រំសេវដែលយកមកប្រើប្រាស់ ត្រូវតែជាប្រភេទដែលត្រូវបានណែនាំដោយក្រុមហ៊ុនផលិតអាវុធនៅក្នុងសៀវភៅណែនាំរបស់អ្នកប្រើប្រាស់ ឬប្រសិនបើគ្មានការណែនាំទេនោះ ត្រូវប្រើប្រាស់គ្រាប់រំសេវស្តង់ដាណាមួយដែលមានទំហំមុខកាត់ត្រឹមត្រូវ និងស្ថិតក្នុងស្ថានភាពថ្មី។ អាវុធមួយដើមត្រូវចាត់ទុកថាបានឆ្លងកាត់ការសាកល្បងនេះ ប្រសិនបើវាបាញ់ 20 គ្រាប់ដំបូងដោយមិនគាំងដំណើរការ ហើយបាញ់គ្រាប់ចំនួន 600 គ្រាប់ដោយមានគាំងដំណើរការមិនលើសពី 6 ដង ព្រមទាំងបញ្ចប់ការសាកល្បងដោយគ្មានប្រេះស្រាំ ឬបាក់បែកផ្នែកដំណើរការណាមួយរបស់អាវុធដែលមិនបង្កើនគ្រោះថ្នាក់របួសស្នាមដល់អ្នកប្រើប្រាស់។ សម្រាប់គោលបំណងនៃអនុប្រយោគនេះ ពាក្យថា "គាំងដំណើរការ" ត្រូវមានន័យថា ការមិនបញ្ចូលគ្រាប់ មិនបញ្ជូនគ្រាប់ចូលប្រអប់បាញ់ មិនបាញ់ មិនដកសំបកគ្រាប់ចេញ ឬមិនបញ្ចេញសំបកគ្រាប់ចេញពីអាវុធ ឬការមិនបញ្ចូលឬបញ្ចេញបង់កាំភ្លើង ឬការមិនដំណើរការផ្សេងទៀតដែលរារាំងមិនឱ្យអាវុធអាចបាញ់គ្រាប់ដែលស្ថិតនៅក្នុងប្រអប់បាញ់ ឬមិនអាចផ្លាស់ទីគ្រាប់ថ្មីឱ្យចូលទៅក្នុងទីតាំងត្រឹមត្រូវ ដើម្បីឱ្យអាវុធអាចបាញ់គ្រាប់ថ្មីនោះបានត្រឹមត្រូវ ដោយមិនត្រូវការអន្តរាគមន៍ដោយដៃ លើសពីអ្វីដែលចាំបាច់សម្រាប់ការបាញ់ជាប្រក្រតី និងការបញ្ចូលគ្រាប់ឡើងវិញតាមកាលកំណត់។ "ការគាំងដំណើរការ" មិនត្រូវរាប់បញ្ចូលការបាញ់មិនផ្ទុះបណ្តាលមកពីខូចសំបកគ្រាប់ដែលក្បាលបញ្ឆេះគ្រាប់នោះមិនផ្ទុះ នៅពេលត្រូវបានវាយទង្គិចយ៉ាងត្រឹមត្រូវដោយយន្តការបាញ់របស់អាវុធ។

(ii) អាវុធដែលងាយនឹងផ្ទុះដោយចៃដន្យ ដែលសម្រាប់គោលបំណងនៃអនុប្រយោគនេះ ត្រូវមានន័យថាជាម៉ាក និងម៉ូដែលអាវុធណាមួយ ដែលមានគំរូអាវុធចំនួន 5 ដើមក្នុងស្ថានភាពថ្មី ឆ្លងកាត់ការសាកល្បងដូចខាងក្រោមទាំងអស់ និងមិនមានអាវុធណាមួយផ្ទុះអាវុធឡើយ ក្នុងអំឡុងពេលសាកល្បងនោះ៖ គំរូអាវុធនីមួយៗក្នុងចំណោមទាំង 5 ដើមនោះត្រូវតែ៖ (A) បញ្ចូលគ្រាប់សាកល្បង (B) កំណត់រៀបចំឱ្យអាវុធស្ថិតក្នុងស្ថានភាពមួយដែលការកេះកៃកាំភ្លើង និងការធ្វើសកម្មភាពណាមួយដែលត្រូវកើតឡើងទន្ទឹមគ្នានឹងការកេះកៃនោះ ជាផ្នែកមួយនៃនីតិវិធីបាញ់នឹងធ្វើឱ្យអាវុធនោះផ្ទុះ និង (C) ត្រូវទម្លាក់ចុះទៅលើផ្ទាំងបេតុងរឹងមាំកម្ពស់ 1 ម៉ែត្រពីទីតាំងនីមួយៗដូចខាងក្រោម៖ (1) ទីតាំងបាញ់ធម្មតា (2) ផ្កាប់ចុះក្រោម (3) ចំដងកាន់កាំភ្លើង (4) ចំមាត់កាណុង (5) ចំចំហៀងណាមួយ និង (6) ចំញញួរកៃ ឬម្ជុលបុកបំផ្ទុះដែលលេចចេញមកក្រៅ ឬប្រសិនបើគ្មានញញួរកៃ ឬម្ជុលបុកបំផ្ទុះលេចចេញមកក្រៅទេនោះ ត្រូវទម្លាក់ឱ្យចំផ្នែកខាងក្រោយបង្អស់នៃអាវុធនោះ។ ប្រសិនបើអាវុធត្រូវបានរចនាឡើងដើម្បីឱ្យញញួរកៃ ឬម្ជុលបុកបំផ្ទុះរបស់វាអាចកំណត់រៀបចំនៅក្នុងទីតាំងផ្សេងៗទៀតបាន គំរូអាវុធនីមួយៗត្រូវតែយកមកធ្វើការសាកល្បងដូចខាងលើ ដោយដាក់ញញួរកៃ ឬម្ជុលបុកបំផ្ទុះនៅក្នុងទីតាំងនីមួយៗបែបនោះ ប៉ុន្តែក្រៅពីនោះ ត្រូវស្ថិតក្នុងស្ថានភាពមួយដែលការកេះកៃ និងការធ្វើសកម្មភាពណាមួយដែលកើតឡើងទន្ទឹមគ្នានឹងការកេះកៃនោះ ជាផ្នែកមួយនៃនីតិវិធីបាញ់ នឹងធ្វើឱ្យអាវុធនោះផ្ទុះឡើង។ ជាជម្រើសផ្សេងទៀត អ្នកធ្វើតេស្តសាកល្បងអាចប្រើប្រាស់គំរូអាវុធបន្ថែមដែលមានម៉ាកនិងម៉ូដែលដូចគ្នា ក្នុងស្ថានភាពស្រដៀងគ្នា សម្រាប់ការសាកល្បងទៅលើការកំណត់រៀបចំទីតាំងញញួរកៃ ឬម្ជុលបុកបំផ្ទុះនីមួយៗទាំងនេះ។

(iii) អាវុធដែលងាយនឹង៖ (A) ផ្ទុះលើសពីមួយគ្រាប់រាល់ពេលកេះកៃម្តង ឬ (B) ផ្ទុះបែកក្នុងអំឡុងពេលបាញ់ និង

(iv) អាវុធណាដែលមានប្រវែងកាណុងខ្លីជាង 3 អ៊ីញ លើកលែងតែមុនពេលធ្វើប្រតិបត្តិការ អ្នកទទួលអាជ្ញាបណ្ណបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកទិញ អ្នកជួល ឬអ្នកទទួលផ្ទេរនាអនាគត អំពីដែនកំណត់នៃភាពត្រឹមត្រូវរបស់ម៉ាកនិងម៉ូដែលនោះ ដោយបង្ហាញលទ្ធផលតេស្តអង្កត់ផ្ចិតមធ្យមនៃក្រុមគ្រាប់បាញ់នៅចម្ងាយ 7 យ៉ាដ លទ្ធផលតេស្តអង្កត់ផ្ចិតមធ្យមនៃក្រុមគ្រាប់បាញ់នៅចម្ងាយ 14 យ៉ាដ និងលទ្ធផលតេស្តអង្កត់ផ្ចិតមធ្យមនៃក្រុមគ្រាប់បាញ់នៅចម្ងាយ 21 យ៉ាដ។ សម្រាប់គោលបំណងនៃអនុប្រយោគនេះ "លទ្ធផលតេស្តអង្កត់ផ្ចិតមធ្យមនៃក្រុមគ្រាប់បាញ់" មានន័យថា មធ្យមភាគនព្វន្តនៃការសាកល្បងចំនួនបីដាច់ដោយឡែកពីគ្នា ដែលការសាកល្បងនីមួយៗត្រូវអនុវត្តចំពោះអាវុធគំរូផ្សេងគ្នាចំនួនមួយដើមដែលស្ថិតក្នុងសភាពថ្មី និងមានម៉ាកនិងម៉ូដែលដូចគ្នានឹងអាវុធដែលកំពុងពិនិត្យនោះ។ អាវុធនីមួយៗត្រូវបាញ់គ្រាប់ចំនួន 5 គ្រាប់ទៅកាន់គោលដៅនៅចម្ងាយកំណត់ ហើយត្រូវវាស់និងកត់ត្រាចម្ងាយរវាងជាលឆ្ងាយបំផុតគិតជាអ៊ីញ រវាងចំណុចកណ្តាលនៃរន្ធគ្រាប់បាញ់ណាមួយនៅលើគោលដៅសាកល្បង។ នីតិវិធីនេះត្រូវធ្វើឡើងវិញចំនួន 2 ដងបន្ថែមចំពោះអាវុធដដែលនេះ។ មធ្យមភាគនព្វន្តនៃលទ្ធផលទាំង 3 ដែលបានកត់ត្រានោះ ត្រូវចាត់ទុកជាលទ្ធផលនៃការសាកល្បងសម្រាប់អាវុធគំរូជាក់លាក់នោះ។ គ្រាប់កាំភ្លើងដែលប្រើប្រាស់ក្នុងការសាកល្បងត្រូវជាប្រភេទដែលក្រុមហ៊ុនផលិតអាវុធបានណែនាំនៅក្នុងសៀវភៅណែនាំការប្រើ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ប្រាស់។ ប្រសិនបើមិនមានការណែនាំទេ ត្រូវប្រើគ្រាប់កាំភ្លើងស្តង់ដាណាមួយដែលមានទំហំមុខកាត់ត្រឹមត្រូវ និងស្ថិតក្នុងសភាពថ្មី។

(p) កថាខណ្ឌ (o) មិនអនុវត្តចំពោះ៖ (i) អាវុធដែលត្រូវបានកាន់កាប់ ឬមានកម្មសិទ្ធិស្របច្បាប់ក្រោមអាជ្ញាបណ្ណដែលចេញតាមជំពូកនេះនៅថ្ងៃ ឬមុនថ្ងៃទី 21 ខែតុលា ឆ្នាំ 1998 (ii) កាំភ្លើងធក់ ឬ (iii) អាវុធដែលត្រូវបានកំណត់ដោយរដ្ឋមន្ត្រីទទួលបន្ទុកសុវត្ថិភាពសាធារណៈ ដោយមានការផ្តល់យោបល់ពីក្រុមប្រឹក្សាយោបល់គ្រប់គ្រងអាវុធ ដែលត្រូវបានបង្កើតឡើងតាមមាត្រា 131½ ថាជាអាវុធដែលបានរចនា និងដាក់លក់សម្រាប់តែការប្រកួតបាញ់គោលដៅជាផ្លូវការ ឬការប្រកួតបាញ់កាំភ្លើងអូឡាំពិកប៉ុណ្ណោះ ហើយត្រូវបានដាក់បញ្ចូលក្នុងបញ្ជីផ្លូវការតាមមាត្រា 131¾។

មាត្រា 38 ជំពូក 140 ដែលបានពោល ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 125 ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 125 (a) អាជ្ញាធរផ្តល់អាជ្ញាបណ្ណ ត្រូវតែចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាល ដូចដែលបានកំណត់ដោយការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ដែលត្រូវរួមបញ្ចូលជាអាទិ៍នូវការណែនាំស្តីពី៖ (i) ច្បាប់បទប្បញ្ញត្តិ និងវិធានបច្ចុប្បន្នដែលពាក់ព័ន្ធនឹងជំពូកនេះ (ii) ទំនួលខុសត្រូវលើការផ្តល់អាជ្ញាបណ្ណ (iii) កាតព្វកិច្ចរក្សាទុកកំណត់ត្រា (iv) ការប្រគល់អាវុធ ការចុះបញ្ជីអាវុធ និងការស្រាវជ្រាវស្វែងរកប្រភពអាវុធ (v) ទំនួលខុសត្រូវ និងតម្រូវការនានាពាក់ព័ន្ធនឹងការត្រួតពិនិត្យប្រចាំឆ្នាំលើគ្រឹះស្ថានដែលទទួលបានអាជ្ញាបណ្ណក្រោមមាត្រា 122 និង (v) ការប្រើប្រាស់មូលដ្ឋានទិន្នន័យអេឡិចត្រូនិក។

(b) បុគ្គលណាម្នាក់ដែលដាក់ពាក្យសុំការចេញអាជ្ញាបណ្ណលក់ ឬការបន្តសុពលភាពអាជ្ញាបណ្ណលក់ក្រោមមាត្រា 122 ត្រូវតែបញ្ចប់វគ្គសិក្សាបណ្តុះបណ្តាលសម្រាប់ហាងលក់អាវុធ ដែលរៀបចំឡើង និងផ្តល់ជូនតាមប្រព័ន្ធអ៊ីនធឺណិតដោយការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ បន្ថែមលើកខណ្ឌទាំងឡាយដែលបានចែងនៅក្នុងជំពូកនេះ។ គ្មានពាក្យសុំការចេញអាជ្ញាបណ្ណលក់ណាមួយ ត្រូវទទួលបានការយល់ព្រម ឬយកមកចាត់ចែងដំណើរការដោយអាជ្ញាធរផ្តល់អាជ្ញាបណ្ណឡើយ បើគ្មានវិញ្ញាបនបត្របញ្ជាក់ការបញ្ចប់វគ្គសិក្សានោះ។

(c) កម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលអនុលោមតាមកថាខណ្ឌ (b) ត្រូវរួមបញ្ចូលទាំង៖ (i) ស្តង់ដាឯកសណ្ឋានសន្តិសុខសម្រាប់ទីតាំងអាជីវកម្ម (ii) ការពិនិត្យសាវតារបុគ្គលិក និងលក្ខខណ្ឌនៃការបណ្តុះបណ្តាល និង (iii) ព័ត៌មានអំពីតម្រូវការ និងលក្ខខណ្ឌនានាដែលមានចែងក្នុងជំពូក 140 និងច្បាប់ផ្សេងៗទៀតដែលការិយាល័យប្រតិបត្តិយល់ឃើញថាពាក់ព័ន្ធ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

(d) ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ត្រូវប្រកាសឱ្យប្រើនូវវិធាន និងបទប្បញ្ញត្តិទាំងឡាយ ដើម្បីអនុវត្តមាត្រានេះ។

មាត្រា 39 មាត្រា 126 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យថា “កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ ឬកាំភ្លើងយន្ត” នៅត្រង់បន្ទាត់ទី 3 និងទី 4 និងបន្ទាត់ទី 6 និងទី 7 រាល់ពេលដែលពាក្យទាំងនោះលេចឡើង។

មាត្រា 40 មាត្រា 128 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលកថាខណ្ឌទីមួយ ហើយបញ្ចូលជំនួសដោយកថាខណ្ឌខាងក្រោម៖-

ជនណាក៏ដោយដែលទទួលបានអាជ្ញាបណ្ណស្របតាមមាត្រា 122 ឬ 122B ហើយបានលក់ ឬផ្តល់អាវុធ ឬគ្រាប់រំសេវ ទៅឱ្យបុគ្គលណាម្នាក់ដែលគ្មានអាជ្ញាបណ្ណអាវុធ ឬលិខិតអនុញ្ញាត ត្រូវដកហូតអាជ្ញាបណ្ណរបស់ខ្លួន ហើយជននោះគ្មានសិទ្ធិស្នើសុំអាជ្ញាបណ្ណបែបនេះឡើងវិញឡើយ ក្នុងរយៈពេល 10 ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការដកហូតនោះ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនតិចជាង 1,000 ដុល្លារ និងមិនលើសពី 10,000 ដុល្លារ ឬផ្តន្ទាទោសដាក់ពន្ធនាគាររដ្ឋមិនលើសពី 10 ឆ្នាំ ឬដាក់ក្នុងមណ្ឌលកែប្រែមិនលើសពី 2½ ឆ្នាំ ឬទាំងទោសពិន័យជាប្រាក់ ទាំងទោសដាក់ពន្ធនាគារ។ ទោះជាយ៉ាងណាក៏ដោយ លិខិតអនុញ្ញាតទិញមានសុពលភាពដែលបានចេញអនុលោមតាមមាត្រា 131A អាចអនុញ្ញាតឱ្យមានការផ្ទេរអាវុធមួយចំនួនទៅឱ្យបុគ្គលអាយុលើសពី 18 ឆ្នាំបាន។ បុគ្គលណាដែលគ្មានអាជ្ញាបណ្ណក្រោមមាត្រា 122 ឬមិនត្រូវបានលើកលែង ដូចមានចែងក្នុងមាត្រា 129C ហើយបានលក់ ជួល ជួលរយៈពេលវែង ឬផ្ទេរអាវុធតាមរូបភាពផ្សេងទៀត ឬប្រកបអាជីវកម្មជាជាងជួសជុលអាវុធ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនតិចជាង 1,000 ដុល្លារ និងមិនលើសពី 10,000 ដុល្លារ ឬផ្តន្ទាទោសដាក់ពន្ធនាគារមិនតិចជាង 1 ឆ្នាំ និងមិនលើសពី 10 ឆ្នាំ ឬទាំងទោសពិន័យជាប្រាក់ ទាំងទោសដាក់ពន្ធនាគារ។ ភស្តុតាងដែលបង្ហាញថាបុគ្គលណាម្នាក់បានលក់ ឬប៉ុនប៉ងលក់កាំភ្លើងយន្ត ត្រូវចាត់ទុកជាភស្តុតាងបង្ហាញច្បាស់ជាបឋមថា បុគ្គលនោះកំពុងប្រកបអាជីវកម្មលក់កាំភ្លើងយន្ត។

មាត្រា 41 ជំពូក 140 ដែលបានពោល ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយការលុបចេញមាត្រា 128A ដែលបានចែងនេះ ហើយបញ្ចូលជំនួសដោយមាត្រាដូចខាងក្រោម៖-

មាត្រា 128A (a) បុគ្គលដែលមានអាជ្ញាបណ្ណកាន់កាប់អាវុធស្របតាមមាត្រា 131 អាចលក់ ឬផ្ទេរអាវុធ និងគ្រាប់រំសេវបាន ហើយបុគ្គលដែលមានបណ្ណសម្គាល់អាវុធស្របតាមមាត្រា 129B អាចលក់ ឬផ្ទេរកាំភ្លើងវែង និងកាំភ្លើងគ្រាប់ប្រាយដែលមិនមែនជាប្រភេទអាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬជាប្រភេទអាវុធពាក់កណ្តាលស្វ័យប្រវត្តិ ព្រមទាំងគ្រាប់រំសេវទៅឱ្យ៖ (i) បុគ្គលមានអាជ្ញាបណ្ណលក់ដែលបានចេញស្របតាមមាត្រា 122។ (ii) អាជីវករលក់អាវុធដែលទទួលអាជ្ញាបណ្ណពីរដ្ឋាភិបាលសហព័ន្ធ។ ឬ (iii) សមាគមប្រវត្តិសាស្ត្រ សារមន្ទីរ ឬវត្ថុរក្សាទុកតាមស្ថាប័ន ដែលមានអាជ្ញាបណ្ណ ឬទទួលស្គាល់ដោយរដ្ឋាភិបាលសហព័ន្ធ រដ្ឋ ឬអាជ្ញាធរមូលដ្ឋាន និងបើកឱ្យសាធារណជនចូលទស្សនា ដោយមិនកំណត់ចំនួនប្រតិបត្តិការផ្ទេរប្រចាំឆ្នាំឡើយ។

(b) បុគ្គលដែលមានអាជ្ញាបណ្ណកាន់កាប់អាវុធស្របតាមមាត្រា 131 អាចលក់ ឬផ្ទេរអាវុធ និងគ្រាប់រំសេវសម្រាប់អាវុធនោះបាន ហើយបុគ្គលដែលមានបណ្ណសម្គាល់អាវុធស្របតាមមាត្រា 129B អាចលក់ ឬផ្ទេរកាំភ្លើងវែង និងកាំភ្លើងគ្រាប់ប្រាយ ដែលមិនមែនជាប្រភេទអាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬជាប្រភេទពាក់កណ្តាលស្វ័យប្រវត្តិ ព្រមទាំងគ្រាប់រំសេវសម្រាប់អាវុធនោះ ទៅឱ្យបុគ្គលដូចខាងក្រោម ប៉ុន្តែការផ្ទេរអាវុធមិនត្រូវឱ្យលើសពី 4 ដងក្នុងមួយឆ្នាំប្រតិទិនឡើយ៖

(i) បុគ្គលដែលមានអាជ្ញាបណ្ណកាន់កាប់អាវុធស្របតាមមាត្រា 131

(ii) បុគ្គលដែលត្រូវបានលើកលែង ប្រសិនបើត្រូវបានអនុញ្ញាតស្របតាមមាត្រា

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

129C និង

(iii) បុគ្គលដែលមានបណ្ណសម្គាល់អាវុធស្របតាមមាត្រា 129B ប៉ុន្តែ ចំពោះការផ្ទេរ និងការទិញអាវុធទាំងឡាយណាដែលមិនមែនជាកាំភ្លើងវែង និងកាំភ្លើងគ្រាប់ប្រាយ ដែលមិនមែនជាប្រភេទអាវុធមានសមត្ថភាពផ្ទុកខ្ពស់ ឬជាប្រភេទពាក់កណ្តាលស្វ័យប្រវត្តិ នោះបុគ្គលជាអ្នកទទួលការផ្ទេរ ត្រូវតែមានលិខិតអនុញ្ញាតទិញដែលមានសុពលភាព ស្របតាមមាត្រា 131A ផងដែរ។

(c) អ្នកស្នងមរតក ឬអ្នកទទួលមរតកសាសន៍ នៅពេលដែលម្ចាស់អាវុធ ឬគ្រាប់រំសេវបានទទួលមរណភាព បុគ្គលនៅក្នុងជួរកងទ័ព មន្ត្រីប៉ូលិស និងមន្ត្រីរក្សាសន្តិភាពផ្សេងទៀត អង្គការអតីតយុទ្ធជន និងសមាគមប្រវត្តិសាស្ត្រ សារមន្ទីរ និងវត្ថុរក្សាទុកតាមស្ថាប័ននានាដែលបើកជូនសាធារណជនទស្សនា អាច៖

(i) លក់ ឬផ្ទេរអាវុធ និងគ្រាប់រំសេវសម្រាប់អាវុធនោះ ទៅឱ្យអាជីវករលក់អាវុធដែលទទួលបានអាជ្ញាបណ្ណ សហព័ន្ធ ឬសមាគមប្រវត្តិសាស្ត្រ សារមន្ទីរ ឬវត្ថុរក្សាតាមស្ថាប័ននានាដែលបើកជូនសាធារណជនទស្សនា មិនថាក្នុងកម្រិតសហព័ន្ធ រដ្ឋ ឬតំបន់ឡើយ និង

(ii) លក់ ឬផ្ទេរអាវុធមិនឱ្យលើសពី 4 ដើម និងគ្រាប់រំសេវសម្រាប់អាវុធនោះក្នុងមួយឆ្នាំប្រតិទិន ទៅឱ្យ៖ (A) បុគ្គលដែលមានអាជ្ញាបណ្ណកាន់កាប់អាវុធស្របតាមមាត្រា 131។ (B) បុគ្គលដែលត្រូវបានលើកលែងស្របតាមមាត្រា 129C ឬ (C) បុគ្គលដែលមានកាតសម្គាល់អាវុធស្របតាមមាត្រា 129B។ ទោះជាយ៉ាងណាក៏ដោយ ការផ្ទេរ និងការទិញអាវុធទាំងឡាយណាដែលមិនមែនជាកាំភ្លើងវែង និងកាំភ្លើងគ្រាប់ប្រាយដែលមិនមែនជាប្រភេទអាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬជាប្រភេទពាក់កណ្តាលស្វ័យប្រវត្តិ នោះបុគ្គលជាអ្នកទទួលការផ្ទេរ ត្រូវតែមានលិខិតអនុញ្ញាតទិញដែលមានសុពលភាព ស្របតាមមាត្រា 131A។

(d) បុគ្គលដែលមានអាជ្ញាបណ្ណកាន់កាប់អាវុធស្របតាមមាត្រា 131 អាចទិញ ឬផ្ទេរអាវុធ និងគ្រាប់រំសេវសម្រាប់អាវុធនោះ ពីអាជីវករដែលទទួលបានអាជ្ញាបណ្ណស្របតាមមាត្រា 122 ឬពីបុគ្គលដែលត្រូវបានអនុញ្ញាតឱ្យលក់ស្របតាមមាត្រានេះ។

(e) បុគ្គលមានបណ្ណសម្គាល់អាវុធស្របតាមមាត្រា 129B ដែលមានអាយុលើសពី 18 ឆ្នាំ អាចទិញ ឬផ្ទេរកាំភ្លើងវែង និងកាំភ្លើងគ្រាប់ប្រាយដែលមិនមែនជាប្រភេទអាវុធមានសមត្ថភាពផ្ទុកខ្ពស់ ឬពាក់កណ្តាលស្វ័យប្រវត្តិ ព្រមទាំងគ្រាប់រំសេវសម្រាប់អាវុធនោះ ពីអាជីវករដែលទទួលបានអាជ្ញាបណ្ណស្របតាមមាត្រា 122 ឬពីបុគ្គលដែលត្រូវបានអនុញ្ញាតឱ្យលក់ស្របតាមមាត្រានេះ។

(f) អ្នកប្រមូលសន្សំអាវុធពិតប្រាកដ អាចទិញអាវុធដែលមិនធ្លាប់បានកាន់កាប់ ឬចុះបញ្ជីពីមុនមកក្នុងរដ្ឋម៉ាសាឈូសិត ពីអាជីវករដែលទទួលបានអាជ្ញាបណ្ណស្របតាមមាត្រា 122 ប្រសិនបើអាវុធនោះជាប្រភេទអាវុធបុរាណ ឬអាវុធវត្ថុអនុស្សាវរីយ៍កម្រ ដូចមានចែងក្នុងមាត្រា 121។

(g) រាល់ការទិញ ការលក់ ឬការផ្ទេរអាវុធទាំងអស់ដែលត្រូវបានអនុញ្ញាតស្របតាមមាត្រានេះ ត្រូវតែធ្វើឡើងតាមរយៈប្រព័ន្ធចុះបញ្ជីអាវុធអេឡិចត្រូនិក យោងតាមមាត្រា 121B នៅមុនពេល ឬនៅពេលលក់។ នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ តម្រូវឱ្យបុគ្គលម្នាក់ៗដែលលក់ ឬផ្ទេរអាវុធស្របតាមមាត្រានេះ ផ្តល់ព័ត៌មានជាទម្រង់អេឡិចត្រូនិក តាមរយៈប្រព័ន្ធចុះបញ្ជីអាវុធអេឡិចត្រូនិក នូវរាល់ព័ត៌មានទាំងឡាយណាដែលត្រូវបានកំណត់ថាចាំបាច់ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកលក់ និងអ្នកទិញ ព្រមទាំងធានាថាការលក់ ឬការផ្ទេរនោះគឺត្រឹមត្រូវស្របតាមមាត្រានេះ។ នៅពេលបំពេញព័ត៌មានចាំបាច់រួចរាល់ ប្រព័ន្ធចុះបញ្ជីអាវុធអេឡិចត្រូនិកត្រូវពិនិត្យព័ត៌មាននោះដោយស្វ័យប្រវត្តិ និងបង្ហាញសារបញ្ជាក់ថាតើអ្នកលក់អាចបន្តដំណើរការលក់ ឬផ្ទេរនោះបានដែរឬទេ ព្រមទាំងត្រូវផ្តល់ការណែនាំបន្ថែមផ្សេងទៀតសម្រាប់អ្នកលក់ ដូចដែលបានកំណត់ថាចាំបាច់ដោយនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ។ ប្រព័ន្ធចុះបញ្ជីអាវុធអេឡិចត្រូនិក ត្រូវរក្សាទុករាល់កំណត់ត្រាការលក់ ឬការផ្ទេរដែលបានអនុវត្តស្របតាមមាត្រានេះ និងត្រូវផ្តល់ការបញ្ជាក់ផ្ទៀងផ្ទាត់អំពីការលក់ ឬការផ្ទេរនោះ ដល់អ្នកលក់ និងអ្នកទិញ។

មាត្រា 42 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 128B ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 128B រាល់និវាសជនរដ្ឋម៉ាសាឈូសិតណាដែលទិញ ឬទទួលបានអាវុធពីប្រភពណាមួយនៅក្នុង ឬក្រៅរដ្ឋម៉ាឈូសិត ក្រៅតែពីទិញពីម្ចាស់អាជ្ញាបណ្ណស្របតាមមាត្រា 122 ឬបុគ្គលដែលមានសិទ្ធិលក់អាវុធស្របតាមមាត្រា 128A និងរាល់អនិវាសជនរដ្ឋម៉ាសាឈូសិតណាដែលទិញ ឬទទួលបានអាវុធពីប្រភពណាមួយនៅក្នុង ឬក្រៅរដ្ឋម៉ាសាឈូសិត ក្រៅតែពីអ្នកទទួលបានអាជ្ញាបណ្ណ ឬបុគ្គលបែបនោះ ហើយបានទទួលអាវុធនោះនៅក្នុងរដ្ឋម៉ាសាឈូសិត ត្រូវតែចុះបញ្ជីអាវុធនោះ និងត្រូវរាយការណ៍ព័ត៌មានចាំបាច់ ស្របតាមមាត្រា 121B និង 121C។ ជនណាដែលល្មើសនឹងបទប្បញ្ញត្តិណាមួយនៃមាត្រានេះ ចំពោះការប្រព្រឹត្តបទល្មើសលើកដំបូង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនតិចជាង 500 ដុល្លារ និងមិនលើសពី 1,000 ដុល្លារ ហើយចំពោះការប្រព្រឹត្តបទល្មើសជាបន្តបន្ទាប់ទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររដ្ឋមិនលើសពី 10 ឆ្នាំ។

មាត្រា 43 មាត្រា 129 នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យថា "ការជួល ឬការជួលប្រើប្រាស់អាវុធកាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ ឬកាំភ្លើងយន្ត ឬក្នុងការដាក់ពាក្យសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតក្នុងទម្រង់ណាមួយ" នៅក្នុងបន្ទាត់ទី 1 ដល់ទី 3 ទាំងស្រុង ហើយបញ្ចូលជំនួសមកវិញនូវពាក្យដូចខាងក្រោម៖- "ឬការជួលអាវុធ ឬក្នុងការដាក់ពាក្យសុំអាជ្ញាបណ្ណ បណ្ណសម្គាល់ ឬលិខិតអនុញ្ញាតក្នុងទម្រង់ណាមួយ"។

មាត្រា 44 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលមាត្រា 129B ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 129B បណ្ណសម្គាល់អាវុធ ត្រូវតែចេញឱ្យប្រើប្រាស់និងកាន់កាប់ ដោយផ្អែកលើលក្ខខណ្ឌ និងការរឹតត្បិតដូចខាងក្រោម៖

(a) និវាសជនស្របច្បាប់ណាដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ រស់នៅក្នុងដែនសមត្ថកិច្ចរបស់អាជ្ញាធរចេញអាជ្ញាបណ្ណ ឬរស់នៅក្នុងតំបន់ដែនសមត្ថកិច្ចផ្តាច់មុខរបស់សហព័ន្ធដែលស្ថិតនៅក្នុងទីក្រុង ឬតំបន់មួយ អាចដាក់ពាក្យសុំបណ្ណសម្គាល់អាវុធ ឬស្នើសុំបន្តសុពលភាពបណ្ណនោះ ទៅអាជ្ញាធរចេញអាជ្ញាបណ្ណបាន ដែលអាជ្ញាធរចេញអាជ្ញាបណ្ណត្រូវចេញបណ្ណនោះស្របតាមមាត្រា 121F ប្រសិនបើពិនិត្យឃើញថា អ្នកស្នើសុំមិនមែនជាបុគ្គលដែលត្រូវបានហាមឃាត់ ហើយក៏មិនត្រូវបានកំណត់ថាជាបុគ្គលមិនសមស្របក្នុងការទទួលបានបណ្ណ ដូចមានចែងក្នុងមាត្រាខាងលើនោះដែរ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលអាយុចាប់ពី 15 ឆ្នាំឡើងទៅ ប៉ុន្តែ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

តិចជាង 18 ឆ្នាំ ក៏អាចដាក់ពាក្យស្នើសុំបណ្ណសម្គាល់អាវុធបានដែរ ហើយនឹងត្រូវចេញបណ្ណនោះឱ្យ លុះត្រាតែអ្នកស្នើសុំបំពេញតាមលក្ខខណ្ឌចាំបាច់នៃមាត្រា 121F ខាងលើ និងបានភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ពីឪពុកម្ដាយ ឬអាណាព្យាបាលដែលផ្ដល់ការអនុញ្ញាតឱ្យអ្នកស្នើសុំដាក់ពាក្យសុំបណ្ណនេះ។ បុគ្គលដែលមានអាយុ 14 ឆ្នាំ អាចដាក់ពាក្យស្នើសុំបណ្ណសម្គាល់អាវុធបាន ប៉ុន្តែពុំត្រូវចេញបណ្ណជូនអ្នកស្នើសុំឡើយ រហូតទាល់តែអ្នកស្នើសុំនោះមានអាយុគ្រប់ 15 ឆ្នាំ ហើយនៅពេលនោះត្រូវតែបំពេញតាមស្តង់ដា និងលក្ខខណ្ឌតម្រូវអនុលោមតាមកថាខណ្ឌនេះ។

(b) គ្មានបណ្ណណាមួយត្រូវចេញឱ្យក្រោមមាត្រានេះឡើយ លុះត្រាតែអ្នកស្នើសុំដាក់ជូនរួមជាមួយពាក្យសុំរបស់ពួកគេនូវវិញ្ញាបនបត្រសុវត្ថិភាពអាវុធជាមូលដ្ឋាន ឬវិញ្ញាបនបត្រផ្សេងទៀតដែលបំពេញតាមលក្ខខណ្ឌចាំបាច់នៃមាត្រា 131P។

(c) បណ្ណសម្គាល់អាវុធត្រូវផ្ដល់សិទ្ធិឱ្យអ្នកកាន់បណ្ណនោះក្នុងការទិញ ផ្ទេរ កាន់កាប់ និងនាំយកតាមខ្លួននូវកាំភ្លើងវែង និងកាំភ្លើងគ្រាប់ប្រាយទាំងឡាយណាដែលមិនមែនជាប្រភេទមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬជាប្រភេទពាក់កណ្តាលស្វ័យប្រវត្តិ ព្រមទាំងគ្រាប់រំសេវសម្រាប់អាវុធទាំងនោះ។ បណ្ណសម្គាល់អាវុធមិនត្រូវផ្ដល់សិទ្ធិឱ្យអ្នកកាន់បណ្ណនោះក្នុងការផ្ទេរ កាន់កាប់ ឬនាំយកតាមខ្លួននូវអាវុធផ្សេងទៀតណាមួយឡើយ រាប់បញ្ចូលទាំងអាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន កាំភ្លើងវែងមានសមត្ថភាពផ្ទុកខ្ពស់ឬពាក់កណ្តាលស្វ័យប្រវត្តិ ឬកាំភ្លើងគ្រាប់ប្រាយមានសមត្ថភាពផ្ទុកខ្ពស់ ឬពាក់កណ្តាលស្វ័យប្រវត្តិ លើកលែងតែស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់ពីម្ចាស់អាជ្ញាបណ្ណកាន់កាប់អាវុធ នៅឯក្លឹបបាញ់កាំភ្លើងដែលបានចុះបញ្ជីស្របច្បាប់ ឬនៅទីលានបាញ់កាំភ្លើងមានអាជ្ញាបណ្ណ។ លើកលែងតែមានចែងផ្សេងនៅក្នុងបទប្បញ្ញត្តិនេះ ពុំនោះទេ បណ្ណសម្គាល់អាវុធមិនត្រូវមានសុពលភាពសម្រាប់ប្រើប្រាស់ កាន់កាប់ មានកម្មសិទ្ធិ ផ្ទេរ ទិញ លក់ ជួលរយៈពេលវែង ជួល ឬដឹកជញ្ជូនអាវុធមានសមត្ថភាពផ្ទុកខ្ពស់ណាមួយឡើយ។

(d) បណ្ណសម្គាល់អាវុធត្រូវមានសុពលភាពមិនលើសពីរយៈពេល 6 ឆ្នាំឡើយ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណ លើកលែងតែត្រូវបានដកហូត ឬផ្អាកជាបណ្ដោះអាសន្ន ហើយត្រូវអស់សុពលភាពចំថ្ងៃខួបកំណើតរបស់ម្ចាស់បណ្ណ ដែលកើតឡើងមិនក្រោម 5 ឆ្នាំ និងមិនលើសពី 6 ឆ្នាំ គិតចាប់ពីថ្ងៃចេញបណ្ណ។ បណ្ណដែលចេញនៅថ្ងៃទី 29 ខែកុម្ភៈ ត្រូវអស់សុពលភាពនៅថ្ងៃទី 1 ខែមីនា។

(e) ម្ចាស់បណ្ណសម្គាល់អាវុធត្រូវរាយការណ៍អំពីការផ្លាស់ប្ដូរអាសយដ្ឋានណាមួយតាមរយៈប្រព័ន្ធចុះបញ្ជីអាវុធតាមអេឡិចត្រូនិក ដែលគ្រប់គ្រងដោយប្រធាននាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ។ ការជូនដំណឹងបែបនេះ ត្រូវធ្វើឡើងនៅលើផតថល ក្នុងរយៈពេល 30 ថ្ងៃ គិតចាប់ពីថ្ងៃកើតមានករណីនោះ។ ការខកខានមិនបានជូនដំណឹងតាមការកំណត់ ត្រូវចាត់ទុកជាមូលហេតុនៃការដកហូត ឬការផ្អាកជាបណ្ដោះអាសន្ននូវបណ្ណសម្គាល់អាវុធនោះ។

(f) ប្រធានការិយាល័យប្រតិបត្តិសន្តិសុខសាធារណៈ ឬបុគ្គលចាត់តាំង អាចប្រកាសឱ្យប្រើប្រាស់បទប្បញ្ញត្តិទាំងឡាយ ដើម្បីអនុវត្តគោលបំណងនៃមាត្រានេះ។

មាត្រា 45 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 129C ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 129C (a) ការកាន់កាប់អាវុធ ឬគ្រាប់រំសេវសម្រាប់គោលបំណងជាក់លាក់ណាមួយ និងក្នុងរយៈពេលកំណត់ ដោយមិនទាន់ទទួលបានការចេញអាជ្ញាបណ្ណលិខិតអនុញ្ញាត ឬបណ្ណសម្គាល់ត្រឹមត្រូវ ស្របតាមមាត្រា 129B, 131, 131A ឬ 131F ត្រូវអនុញ្ញាតចំពោះ៖ (i) បុគ្គលដែលស្ម័គ្រចិត្តប្រគល់អាវុធ ឬគ្រាប់រំសេវនោះជូនទៅស្នងការប៉ូលីសរដ្ឋ យោងតាមមាត្រា 131O។ (ii) និវាសជនរដ្ឋម៉ាសាឈូសិតដែលត្រឡប់មកវិញបន្ទាប់ពីបានអវត្តមានពីរដ្ឋម៉ាសាឈូសិត មិនតិចជាងរយៈពេល 180 ថ្ងៃជាប់ៗគ្នា ឬនិវាសជនថ្មីណាម្នាក់ដែលផ្លាស់ទីលំនៅចូលមកក្នុងរដ្ឋម៉ាសាឈូសិត ប៉ុន្តែសិទ្ធិនេះមានចំពោះតែអាវុធ ឬគ្រាប់រំសេវណាដែលស្ថិតនៅក្នុងការកាន់កាប់របស់ពួកគេជាមុន មុនពេលផ្លាស់ទីលំនៅ ឬត្រឡប់មកវិញនោះតែប៉ុណ្ណោះ និងមានរយៈពេលត្រឹមតែ 60 ថ្ងៃ បន្ទាប់ពីការត្រឡប់មកវិញ ឬការចូលមកក្នុងរដ្ឋម៉ាសាឈូសិតនេះ ឬ (iii) អ្នកស្នងមរតក ឬអ្នកទទួលមរតកសាសន៍ នៅពេលម្ចាស់អាវុធ ឬគ្រាប់រំសេវស្របច្បាប់នោះបានទទួលមរណភាព ក្នុងរយៈពេលមិនលើសពី 60 ថ្ងៃ បន្ទាប់ពីអាវុធ ឬគ្រាប់រំសេវនោះត្រូវបានផ្ទេរមកឱ្យពួកគេកាន់កាប់ ហើយជននោះក៏ត្រូវទទួលបានការអនុញ្ញាតឱ្យលក់ ឬផ្ទេរអាវុធ ឬគ្រាប់រំសេវនោះតាមរូបភាពផ្សេងទៀត ទៅឱ្យបុគ្គលដែលទទួលបានអាជ្ញាបណ្ណត្រឹមត្រូវនៅក្នុងអំឡុងពេលកំណត់នេះ ស្របតាមមាត្រា 128A ផងដែរ។

(b) ការកាន់កាប់អាវុធ ឬគ្រាប់រំសេវ ក្នុងអំឡុងពេលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ពីបុគ្គលដែលមានអាជ្ញាបណ្ណ ឬប័ណ្ណស្របតាមមាត្រា 129B, 131 ឬ 131F និងសម្រាប់តែគោលបំណងជាក់លាក់ណាមួយ និងក្នុងរយៈពេលកំណត់ ដោយមិនទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតត្រឹមត្រូវស្របតាមមាត្រា 129B, 131 ឬ 131F ដែលបានពោលខាងលើ ត្រូវអនុញ្ញាតចំពោះ៖ (i) អតិថិជនក្នុងគោលបំណងបាញ់កាំភ្លើងកម្សាន្តនៅទីលានបាញ់ស៊ីបដែលមានអាជ្ញាបណ្ណត្រឹមត្រូវតាមសួនកម្សាន្ត ផែ ឬទីតាំងស្រដៀងគ្នាផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ អាវុធដែលត្រូវប្រើប្រាស់ក្នុងទម្រង់បែបនេះ ត្រូវតែភ្ជាប់ដោយច្រវាក់ ឬចងភ្ជាប់រឹងមាំទៅនឹងបញ្ជរ ហើយត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់ពីម្ចាស់អាជីវកម្ម ឬបុគ្គលិករបស់ទីតាំងនោះ ដែលជាអ្នកកាន់កាប់អាជ្ញាបណ្ណ ឬបណ្ណដែលចាំបាច់។ (ii) អ្នកថតរូបអាជីព ឬអ្នកនិពន្ធ ក្នុងគោលបំណងពិនិត្យមើលក្នុងអំឡុងពេលនៃការបំពេញវិជ្ជាជីវៈរបស់ខ្លួន ឬក្នុងអំឡុងពេលនៃការថតកម្មវិធីទូរទស្សន៍ ខ្សែភាពយន្ត សម្ដែងលើឆាក ឬការផលិតល្ខោនស្រដៀងគ្នាផ្សេងទៀត។ ប៉ុន្តែ បុគ្គលទាំងនោះត្រូវតែស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងដិតដល់គ្រប់ពេលវេលាពីអ្នកកាន់អាជ្ញាបណ្ណកាន់កាប់អាវុធ ឬក្នុងករណីជាកាំភ្លើងវែង និងកាំភ្លើងគ្រាប់ប្រាយ ដែលមិនមែនជាប្រភេទអាវុធមានសមត្ថភាពផ្ទុកខ្ពស់ឬពាក់កណ្តាលស្វ័យប្រវត្តិ ត្រូវស្ថិតក្រោមការត្រួតពិនិត្យពីអ្នកកាន់បណ្ណសម្គាល់អាវុធ។ ឬ (iii) បុគ្គលណាម្នាក់ដែលស្ថិតនៅចំពោះមុខអ្នកកាន់អាជ្ញាបណ្ណ ឬប័ណ្ណដែលចាំបាច់ ក្នុងគោលបំណងពិនិត្យមើល សាកល្បង ឬទទួលការណែនាំបង្ហាត់បង្ហាញ។

(c) ក្រុមហ៊ុនដឹកជញ្ជូនសាធារណៈ ព្រមទាំងបុគ្គលិកនិងភ្នាក់ងារទទួលសិទ្ធិត្រឹមត្រូវរបស់ពួកគេ អាចកាន់កាប់អាវុធ និងគ្រាប់រំសេវសម្រាប់អាវុធនោះបាន ដោយមិនចាំបាច់មានអាជ្ញាបណ្ណ ឬប័ណ្ណដែលចាំបាច់ស្របតាមមាត្រា 129B, 131 ឬ 131F ឡើយ ក្នុងអំឡុងពេលបំពេញភារកិច្ចដឹកជញ្ជូនជាប្រចាំនិងជាធម្មតានូវអាវុធ និងគ្រាប់រំសេវក្នុងនាមជាទំនិញសម្រាប់អតិថិជនដែលទទួលបានអាជ្ញាបណ្ណត្រឹមត្រូវក្នុងការអនុញ្ញាតឱ្យមានការដឹកជញ្ជូនបែបនេះ ហើយដរាបណាពួកគេអនុវត្តតាមរាល់លក្ខខណ្ឌចាំបាច់ក្នុងការរក្សាទុក និងការដឹកជញ្ជូន ដូចមានចែងក្នុងមាត្រា 131C និង 131L។

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

(d) ទោះបីជាមានចែងក្នុងមាត្រា 131B ក៏ដោយ ធនាគារ ឬស្ថាប័នផ្តល់កម្ចី ព្រមទាំងបុគ្គលិកនិងភ្នាក់ងារទទួលបានសិទ្ធិត្រឹមត្រូវរបស់ពួកគេ អាចកាន់កាប់ និងផ្ទេរអាវុធដែលមិនមែនជាប្រភេទមានសមត្ថភាពផ្ទុកខ្ពស់ និងគ្រាប់រំសេវសម្រាប់អាវុធនោះ ក្នុងនាមជាទ្រព្យធានាសម្រាប់ប្រតិបត្តិការអាជីវកម្មដែលមានការធានា ឬដោយសារតែមិនបានបំពេញកាតព្វកិច្ចនៃប្រតិបត្តិការនោះ ដោយមិនចាំបាច់មានអាជ្ញាបណ្ណ ឬប័ណ្ណដែលចាំបាច់ស្របតាមមាត្រា 129B, 131 ឬ 131F ខាងលើឡើយ។

(e) ស្ថាប័នដទៃទៀត ព្រមទាំងបុគ្គលិកនិងភ្នាក់ងារទទួលបានសិទ្ធិត្រឹមត្រូវរបស់ពួកគេ អាចទិញ ផ្ទេរ និងកាន់កាប់អាវុធដែលមិនមែនជាប្រភេទមានសមត្ថភាពផ្ទុកខ្ពស់ និងគ្រាប់រំសេវសម្រាប់អាវុធនោះ ដូចមានបញ្ជាក់នៅក្នុងកថាខណ្ឌនេះ សម្រាប់គោលបំណងជាក់លាក់ណាមួយ និងក្នុងរយៈពេលកំណត់ ដោយមិនចាំបាច់មានអាជ្ញាបណ្ណ ឬបណ្ណសម្គាល់ ស្របតាមមាត្រា 129D, 131 ឬ 131F ឡើយ ប្រសិនបើពួកគេជា៖ (i) ក្រុមហ៊ុនផលិតអាវុធ ឬអាជីវករលក់អាវុធដុំ ដែលទទួលបានអាជ្ញាបណ្ណសហព័ន្ធ ឬបុគ្គលិក ឬភ្នាក់ងាររបស់ពួកគេ ដែលអាចកាន់កាប់អាវុធ និងគ្រាប់រំសេវសម្រាប់អាវុធនោះ នៅពេលដែលការកាន់កាប់របស់ពួកគេគឺចាំបាច់សម្រាប់ការផលិត ការដាក់បង្ហាញ ការរក្សាទុក ការដឹកជញ្ជូន ការដំឡើង ការត្រួតពិនិត្យ ឬការធ្វើតេស្តសាកល្បង។ (ii) សមាគមប្រវត្តិសាស្ត្រ សារមន្ទីរ និងវត្ថុរក្សាទុកតាមស្ថាប័ននានា ដែលបើកជូនសាធារណជនទស្សនា មិនថាក្នុងកម្រិតសហព័ន្ធ រដ្ឋ ឬតំបន់ឡើយ ដែលអាចកាន់កាប់អាវុធ និងគ្រាប់រំសេវសម្រាប់អាវុធនោះ។ ទោះជាយ៉ាងណាក៏ដោយ អាវុធបែបនេះត្រូវតែដកគ្រាប់ចេញឱ្យអស់ ព្រមទាំងត្រូវបានដាក់ក្នុងកន្លែងសមរម្យ និងរក្សាសុវត្ថិភាពពីការប៉ះពាល់ដោយគ្មានការអនុញ្ញាត ហើយត្រូវតែបំពេញតាមលក្ខខណ្ឌចាំបាច់សម្រាប់ការលក់ដូចមានចែងក្នុងមាត្រា 128A ផងដែរ។ (iii) អង្គការអតីតយុទ្ធជនដែលត្រូវបានបង្កើតឡើងដោយច្បាប់សភាខន់ហ្គ្រេសសហរដ្ឋអាមេរិក បង្កើតឡើងដោយច្បាប់រដ្ឋម៉ាសាឈូសិត ឬត្រូវបានទទួលស្គាល់ជាអង្គការមិនស្វែងរកប្រាក់ចំណេញដែលត្រូវបានលើកលែងពន្ធដោយទីភ្នាក់ងារប្រមូលចំណូលផ្ទៃក្នុង ព្រមទាំងសមាជិករបស់អង្គការនោះ ដែលអាចកាន់កាប់អាវុធ និងគ្រាប់រំសេវបាន។ ប៉ុន្តែ សមាជិកទាំងនោះអាចកាន់កាប់បានតែកាំភ្លើងវែងមានសមត្ថភាពផ្ទុកគ្រាប់ច្រើនដែលគ្មានគ្រាប់ ឬកាំភ្លើងគ្រាប់ប្រាយមានសមត្ថភាពផ្ទុកគ្រាប់ច្រើនដែលគ្មានគ្រាប់ ឬកាំភ្លើងវែងមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬកាំភ្លើងគ្រាប់ប្រាយមានសមត្ថភាពផ្ទុកគ្រាប់ច្រើនដែលបានបញ្ចូលគ្រាប់សំបកទទេ និងមិនមានក្បាលគ្រាប់ណាមួយនៅក្នុងបំពង់កាំភ្លើង ឬប្រអប់បាញ់គ្រាប់នោះឡើយ។ បន្ថែមលើនេះ រាល់ការកាន់កាប់ដោយសមាជិកអង្គការអតីតយុទ្ធជនត្រូវតែកម្រិតត្រឹមតែការបំពេញតួនាទីក្នុងក្បួនព្យុហយាត្រា ឬក្នុងឱកាសពិធីបុណ្យផ្លូវការតែប៉ុណ្ណោះ។

(f) បុគ្គលនៅក្នុងជួរយោធា ឬសេវាកម្មដទៃទៀតរបស់រដ្ឋណាមួយ ឬរបស់សហរដ្ឋអាមេរិក ព្រមទាំងមន្ត្រីប៉ូលិស និងមន្ត្រីរក្សាសន្តិភាពផ្សេងទៀតក្នុងដែនសមត្ថកិច្ចណាមួយ អាចទិញ លក់ ឬផ្ទេរតាមរូបភាពផ្សេងទៀត និងកាន់កាប់អាវុធដែលមិនមែនជាប្រភេទមានសមត្ថភាពផ្ទុកគ្រាប់ច្រើន និងគ្រាប់រំសេវសម្រាប់អាវុធនោះបាន ដោយមិនចាំបាច់មានអាជ្ញាបណ្ណ ឬប័ណ្ណស្របតាមមាត្រា 129D, 131 ឬ 131F ឡើយ ក្នុងអំឡុងពេលបំពេញតួនាទីផ្លូវការរបស់ខ្លួន ឬនៅពេលដែលទទួលបានសិទ្ធិត្រឹមត្រូវក្នុងការកាន់កាប់អាវុធទាំងនោះពីស្ថាប័នសាមីរបស់ពួកគេ ប៉ុន្តែត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការលក់ដូចមានចែងក្នុងមាត្រា 128A។ នៅពេលទិញ បុគ្គលដែលត្រូវបានលើកលែងក្រោមកថាខណ្ឌនេះ ត្រូវតែដាក់ជូនអ្នកលក់នូវភស្តុតាងពេញលេញនិងច្បាស់លាស់អំពីអត្តសញ្ញាណ រួមទាំងលេខស្លាកសញ្ញា លេខស៊េរី បទបញ្ជា ឬការអនុញ្ញាតពីយោធា ឬរដ្ឋាភិបាល ឯកសារបញ្ជាក់អត្តសញ្ញាណយោធា ឬឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការផ្សេងទៀតទៅតាមភាពជាក់ស្តែង។

(g) បុគ្គលម្នាក់អាចផ្តល់អាវុធ និងគ្រាប់រំសេវទៅឱ្យអនីតិជន ឬបុគ្គលអាយុក្រោម 21 ឆ្នាំ សម្រាប់គោលបំណងបរបាញ់ ការណែនាំបង្ហាត់បង្ហាញ ការកម្សាន្ត និងការចូលរួមក្នុងកីឡាបាញ់កាំភ្លើងបាន លុះត្រាតែបុគ្គលដែលផ្តល់អាវុធ និងគ្រាប់រំសេវនោះមានអាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬបណ្ណសម្គាល់ដែលសមស្រប ឬជាមន្ត្រីដែលទទួលបានការតែងតាំងត្រឹមត្រូវ នាយទាហានរង ឬសមាជិកពលទាហាននៃកងទ័ពជើងគោក ជើងទឹក កងម៉ារីន កងទ័ពអាកាស ឬកងឆ្មាំឆ្នេរសមុទ្រសហរដ្ឋអាមេរិក ឬឆ្មាំជាតិ ឬសេវាកម្មយោធារដ្ឋម៉ាសាឈូសិត ឬអង្គភាពបម្រុងនៃកងកម្លាំងទាំងនោះ ក្នុងអំឡុងពេលបំពេញតួនាទីរបស់ខ្លួន។

(h) គ្មានអាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬប័ណ្ណណាមួយនៅក្រោមជំពូកនេះ ត្រូវបានតម្រូវសម្រាប់និវាសជនស្របច្បាប់របស់រដ្ឋម៉ាសាឈូសិត ដែលមានអាយុលើសពី 18 ឆ្នាំ ក្នុងការនាំយកតាមខ្លួន ឬកាន់កាប់នូវ៖ (i) អាវុធដែលត្រូវបានស្គាល់ថាជាឧបករណ៍បំផុះ និងជាទូទៅត្រូវបានប្រើប្រាស់នៅលើផ្លូវយានយន្តជាឧបករណ៍ផ្តល់សញ្ញា និងដាក់សញ្ញាសម្គាល់ ហើយលុះត្រាតែយកតាមខ្លួនខ្លួន ឬកាន់កាប់អាវុធនោះសម្រាប់គោលបំណងបែបនោះតែប៉ុណ្ណោះ ឬ (ii) ឧបករណ៍ណាមួយដែលត្រូវបានប្រើប្រាស់សម្រាប់តែដើម្បីផ្តល់សញ្ញាអាសន្ន ឬការប្រើប្រាស់ក្នុងស្ថានភាពអាសន្ន ដែលត្រូវបានតម្រូវ ឬណែនាំដោយឆ្មាំឆ្នេរសមុទ្រសហរដ្ឋអាមេរិក ឬគណៈកម្មការពាណិជ្ជកម្មអន្តររដ្ឋ ឬសម្រាប់ការបាញ់គ្រាប់កាំភ្លើងបាញ់បេតុង ឬដែកគោលមីន ឬគ្រាប់រំសេវឧស្សាហកម្មស្រដៀងគ្នា។

(i) អនិវាសជនដែលមានអាយុយ៉ាងតិច 18 ឆ្នាំ អាចកាន់កាប់កាំភ្លើងវែង និងកាំភ្លើងគ្រាប់ប្រាយដែលមិនមែនជាប្រភេទអាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬពាក់កណ្តាលស្វ័យប្រវត្តិ ព្រមទាំងគ្រាប់រំសេវសម្រាប់អាវុធនោះបាន ប្រសិនបើអនិវាសជននោះមានលិខិតអនុញ្ញាត បណ្ណសម្គាល់ ឬអាជ្ញាបណ្ណដែលត្រូវបានចេញឱ្យពីរដ្ឋលំនៅឋានរបស់ខ្លួន ដែលមានលក្ខខណ្ឌតម្រូវស្រដៀងគ្នាច្រើនទៅនឹងលក្ខខណ្ឌតម្រូវរបស់រដ្ឋម៉ាសាឈូសិតសម្រាប់ការទទួលបានបណ្ណសម្គាល់អាវុធដូចដែលបានកំណត់ដោយស្នងការប៉ូលីសរដ្ឋ អនុលោមតាមកថាខណ្ឌ (l)។

(j) អនិវាសជនដែលមានអាយុយ៉ាងតិច 18 ឆ្នាំ អាចកាន់កាប់កាំភ្លើងវែង និងកាំភ្លើងគ្រាប់ប្រាយដែលមិនមែនជាប្រភេទអាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬពាក់កណ្តាលស្វ័យប្រវត្តិ ព្រមទាំងគ្រាប់រំសេវសម្រាប់អាវុធនោះបាន ក្នុងករណី៖ (i) ដើម្បីបរបាញ់ក្នុងអំឡុងរដូវបរបាញ់ដោយមានអាជ្ញាបណ្ណបរបាញ់សម្រាប់អនិវាសជន ឬអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតបរបាញ់ដែលត្រូវបានចេញឱ្យដោយស្របច្បាប់ពីរដ្ឋលំនៅឋានរបស់ខ្លួន ដែលមានលក្ខខណ្ឌតម្រូវស្រដៀងគ្នាជាច្រើនទៅនឹងលក្ខខណ្ឌតម្រូវដែលមានចែងក្នុងមាត្រា 11 នៃជំពូក 131 ដូចដែលបានកំណត់ដោយស្នងការប៉ូលិសរដ្ឋ អនុលោមតាមកថាខណ្ឌ (l)។ (ii) ក្នុងអំឡុងពេលស្ថិតនៅក្នុងទីលានបាញ់កាំភ្លើង ឬទីលានហ្វឹកហាត់បាញ់ស៊ីប។ (iii) ក្នុងអំឡុងពេលធ្វើដំណើរនៅក្នុង ឬឆ្លងកាត់រដ្ឋម៉ាសាឈូសិត ប៉ុន្តែ កាំភ្លើងវែង និងកាំភ្លើង

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

គ្រាប់ប្រាយដែលមិនមែនជាប្រភេទអាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬ ពាក់កណ្តាលស្វ័យប្រវត្តិទាំងនោះ ត្រូវតែដកគ្រាប់ចេញឱ្យអស់ និងត្រូវដាក់ក្នុងប្រអប់ដែលមានចាក់សោត្រឹមត្រូវ អនុលោមតាមមាត្រា 131C និង 131L។ ឬ (iv) ក្នុងអំឡុងពេលស្ថិតនៅក្នុងការដាក់បង្ហាញ ឬការតាំងពិព័រណ៍អាវុធ ដែលត្រូវបានរៀបចំឡើងដោយសមាគម ឬក្លឹបអ្នកប្រមូលទិញអាវុធដែលដំណើរការជាប្រចាំ។

(k) អនិវាសជនអាចនាំយកអាវុធជាប់នឹងខ្លួនបាន ក្នុងអំឡុងពេលស្ថិតនៅក្នុងយានយន្តដែលកំពុងធ្វើដំណើរដោយស្របច្បាប់ឆ្លងកាត់រដ្ឋម៉ាសាឈូសិត ប៉ុន្តែអាវុធនោះត្រូវតែស្ថិតនៅក្នុងយានយន្តជានិច្ច ហើយប្រសិនបើអាវុធនោះស្ថិតនៅក្រៅការគ្រប់គ្រងផ្ទាល់របស់ម្ចាស់ ត្រូវតែរក្សាទុកអាវុធនោះនៅក្នុងយានយន្តឱ្យបានត្រឹមត្រូវស្របតាមមាត្រា 131C។

(l) ស្នងការប៉ូលិសរដ្ឋ ត្រូវកំណត់អត្តសញ្ញាណបណ្តារដ្ឋទាំងឡាយណាដែលមានលក្ខខណ្ឌតម្រូវស្រដៀងគ្នាច្រើនទៅនឹងលក្ខខណ្ឌតម្រូវរបស់រដ្ឋម៉ាសាឈូសិត ដើម្បីទទួលបានបណ្ណសម្គាល់អាវុធក្រោមមាត្រា 129C និងអាជ្ញាបណ្ណបរបាញ់ក្រោមមាត្រា 11 នៃជំពូក 131 ហើយត្រូវបោះពុម្ពផ្សាយបញ្ជីឈ្មោះបណ្តារដ្ឋទាំងនោះជារៀងរាល់ឆ្នាំ។

(m) គ្មានចំណុចណាមួយនៅក្នុងមាត្រានេះ ត្រូវជំនួស ឬលុបចោលលក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីអាវុធ និងការវាយលេខសេរីសម្គាល់អាវុធ អនុលោមតាមមាត្រា 121B និង 121C ឡើយ។

មាត្រា 46 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 129D ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 129D (a) នៅពេលមានការដកហូត ការព្យួរទុក ឬការបដិសេធលើពាក្យសុំអាជ្ញាបណ្ណ ឬប័ណ្ណណាមួយដែលបានចេញឱ្យស្របតាមមាត្រា 129B, 131 ឬ 131F បុគ្គលដែលពាក្យសុំរបស់ខ្លួនត្រូវបានដកហូត ព្យួរទុក ឬបដិសេធបែបនោះ ត្រូវប្រគល់ ឬដាក់ជូនទៅអាជ្ញាធរចេញអាជ្ញាបណ្ណដែលបុគ្គលនោះរស់នៅ នូវរាល់អាវុធ ឬគ្រាប់រំសេវទាំងឡាយណាដែលបានចុះបញ្ជីក្រោមឈ្មោះរបស់ខ្លួន ឬដែលខ្លួនកំពុងកាន់កាប់នៅពេលនោះ ដោយគ្មានការពន្យារពេលឡើយ ហើយត្រូវរាយការណ៍អំពីការប្រគល់ ឬការដាក់ជូននោះទៅកាន់ប្រព័ន្ធចុះបញ្ជីអាវុធអេឡិចត្រូនិក អនុលោមតាមមាត្រា 121B។ ទោះបីជាមានការកំណត់កម្រិតលើការផ្ទេរអាវុធជាឯកជននៅក្នុងមាត្រា 128A ក៏ដោយ ក៏បុគ្គលនោះ ឬតំណាងស្របច្បាប់របស់បុគ្គលនោះ ត្រូវមានសិទ្ធិផ្ទេរអាវុធ និងគ្រាប់រំសេវទាំងនោះនៅពេលណាក៏បាន ក្នុងរយៈពេលរហូតដល់ 1 ឆ្នាំ បន្ទាប់ពីការប្រគល់ ឬការដាក់ជូនទៅឱ្យអាជីវករដែលមានអាជ្ញាបណ្ណ ឬទៅឱ្យបុគ្គលដែលត្រូវបានអនុញ្ញាតដោយស្របច្បាប់ក្នុងការទិញ ឬទទួលយកការកាន់កាប់អាវុធ និងគ្រាប់រំសេវទាំងនោះ ហើយនៅពេលទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីអ្នកទិញ ឬអ្នកទទួលការផ្ទេរ និងពីម្ចាស់ដើម អាជ្ញាធរចេញអាជ្ញាបណ្ណត្រូវប្រគល់អាវុធ និងគ្រាប់រំសេវទាំងនោះទៅឱ្យអ្នកទទួលការផ្ទេរ ឬអ្នកទិញ ក្នុងរយៈពេល 10 ថ្ងៃ ហើយអាជ្ញាធរចេញអាជ្ញាបណ្ណត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការទទួល និងការរក្សាទុកអាវុធ ឬគ្រាប់រំសេវបែបនោះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកទិញ ឬអ្នកទទួលការផ្ទេរ ត្រូវតែបញ្ជាក់អះអាងជាលាយលក្ខណ៍អក្សរថា ខ្លួននឹងមិនផ្ទេរអាវុធ ឬគ្រាប់រំសេវទាំងនោះត្រឡប់ទៅឱ្យម្ចាស់ដើមវិញឡើយ ប៉ុន្តែ ការផ្ទេរបែបនោះមិនត្រូវអនុញ្ញាតឡើយ ប្រសិនបើអាវុធនោះអាចជាភស្តុតាងនៅក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌមិនទាន់ដោះស្រាយរួចណាមួយ។ នៅពេលដែលធ្វើការប្រគល់ ឬដាក់ជូនអាវុធ អាជ្ញាធរចេញអាជ្ញាបណ្ណត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលនោះអំពីសិទ្ធិរបស់ពួកគេក្នុងការស្នើសុំផ្ទេរស្របតាមកថាខណ្ឌនេះ។

(b) បន្ទាប់ពីបានទទួលយកការកាន់កាប់អាវុធ ឬគ្រាប់រំសេវដោយមធ្យោបាយណាមួយរួចហើយ អាជ្ញាធរចេញអាជ្ញាបណ្ណ អាចផ្ទេរការកាន់កាប់នោះសម្រាប់គោលបំណងរក្សាទុក ទៅឱ្យអាជីវករលក់អាវុធដែលទទួលបានអាជ្ញាបណ្ណសហព័ន្ធដែលជាអ្នកប្រតិបត្តិការឃ្លាំងមានធានាសុវត្ថិភាព នៅលើទីតាំងដែលមានអាជ្ញាបណ្ណ ដែលត្រូវបានបំពាក់ដោយទូដែកសុវត្ថិភាពសម្រាប់ការរក្សាទុកអាវុធដោយសុវត្ថិភាព និងប្រអប់ដាក់អាវុធ ឬទូរស្រដៀងគ្នាសម្រាប់ការរក្សាទុកគ្រាប់រំសេវដោយសុវត្ថិភាព។ ទោះជាយ៉ាងណាក៏ដោយ អាជ្ញាធរចេញអាជ្ញាបណ្ណមិនត្រូវផ្ទេរការកាន់កាប់អាវុធ ឬគ្រាប់រំសេវណាដែលជាភស្តុតាងនៅក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌមិនទាន់ដោះស្រាយរួចណាមួយ ទៅឱ្យអាជីវករបែបនោះឡើយ។ អាជីវករលក់អាវុធទាំងនោះដែលទទួលយកការកាន់កាប់អាវុធ ឬគ្រាប់រំសេវស្របតាមមាត្រានេះ ត្រូវតែ៖ (i) ពិនិត្យមើលអាវុធ ឬគ្រាប់រំសេវនោះ។ (ii) ចេញបង្កាន់ដៃជូនម្ចាស់អាវុធ ដោយបញ្ជាក់ពីម៉ាក ម៉ូដែល ទំហំមុខកាត់ លេខសេរី និងស្ថានភាពរបស់អាវុធ ឬគ្រាប់រំសេវនីមួយៗដែលបានទទួលនោះ និង (iii) រក្សាទុក ព្រមទាំង ថែទាំរាល់អាវុធនិងគ្រាប់រំសេវទាំងអស់ដែលបានទទួលនោះ ឱ្យស្របតាមបទប្បញ្ញត្តិ វិធាន ឬគោលការណ៍ណែនាំទាំងឡាយណាដែលប្រធានការិយាល័យប្រតិបត្តិសន្តិសុខ និងសុវត្ថិភាពសាធារណៈអាចនឹងបង្កើតឡើងក្រោមមាត្រានេះ។ ម្ចាស់អាវុធត្រូវទទួលខុសត្រូវចំពោះអាជីវករលក់អាវុធបែបនោះ លើការបង់ថ្លៃរក្សាទុកក្នុងកម្រិតសមរម្យ។

(c) អាវុធនិងគ្រាប់រំសេវទាំងឡាយណាដែលមិនត្រូវបានលក់ឬផ្ទេរ ក្នុងរយៈពេល 1 ឆ្នាំ គិតចាប់ពីការប្រគល់ ឬការដាក់ជូនស្របតាមមាត្រានេះ ត្រូវតែដាក់ដេញលក់ថ្លៃជាសាធារណៈដោយស្នងការប៉ូលិសរដ្ឋ ទៅឱ្យបុគ្គលដែលដេញថ្លៃបានខ្ពស់ជាងគេដែលត្រូវបានអនុញ្ញាតស្របតាមច្បាប់ក្នុងការទិញ និងកាន់កាប់អាវុធនិងគ្រាប់រំសេវខាងលើ ហើយថវិកាដែលទទួលបានពីការលក់នេះ ត្រូវតែប្រគល់ចូលទៅក្នុងកញ្ចប់ថវិកាមូលនិធិទូទៅ។

(d) រាល់អាវុធ ឬគ្រាប់រំសេវបែបនោះ ដែលត្រូវបានរក្សាទុកនិងថែទាំដោយអាជីវករមានអាជ្ញាបណ្ណ អាចត្រូវបាននាំយកទៅដាក់ដេញថ្លៃលក់ស្របតាមកថាខណ្ឌ (c) តាមការណែនាំរបស់៖ (i) អាជ្ញាធរចេញអាជ្ញាបណ្ណ នៅពេលផុតកំណត់ 1 ឆ្នាំបន្ទាប់ពីការដាក់ជូន ឬការប្រគល់ជាលើកដំបូងទៅឱ្យអាជ្ញាធរចេញអាជ្ញាបណ្ណបែបនោះ ឬ (ii) អាជីវករដែលកំពុងកាន់កាប់អាវុធនៅពេលនោះ ប្រសិនបើការបង់ថ្លៃរក្សាទុកអាវុធ ឬគ្រាប់រំសេវទាំងនោះបានខកខានមិនបង់រយៈពេល 90 ថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ មិនថាក្នុងករណីណាឡើយ កម្មសិទ្ធិអាវុធត្រូវផ្ទេរទៅឱ្យអាជីវករដែលមានអាជ្ញាបណ្ណ ដើម្បីផ្ទេរកម្មសិទ្ធិបន្តទៅឱ្យអ្នករៀបចំការលក់ឡៃឡុង ហើយមិនថាក្នុងករណីណាមួយឡើយ បន្ទាប់ពីបានកាត់កង និងទូទាត់ថ្លៃរក្សាទុក ព្រមទាំងរាល់ការចំណាយចាំបាច់ទាំងអស់ពាក់ព័ន្ធនឹងការប្រគល់ និងការផ្ទេរបែបនោះរួចរាល់ ប្រសិនបើមាននៅសល់ថវិកាពីការលក់ ត្រូវតែប្រគល់ជូនទៅម្ចាស់អាវុធ ឬគ្រាប់រំសេវនោះវិញភ្លាមៗ ប៉ុន្តែរាល់អាវុធ ឬគ្រាប់រំសេវទាំងឡាយណាដែលត្រូវបានកំណត់អត្តសញ្ញាណស្របតាមមាត្រា 131Q ថាត្រូវបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស និងរាល់អាវុធ ឬគ្រាប់រំសេវទាំងឡាយណាដែលច្បាប់ហាមឃាត់មិនឱ្យ

# អត្ថបទទាំងស្រុង (ត)

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

មានកម្មសិទ្ធិ ឬកាន់កាប់នៅក្នុងរដ្ឋម៉ាសាឈូសិតទេ មិនត្រូវអនុញ្ញាតឱ្យដេញថ្លៃលក់ជាសាធារណៈស្របតាមមាត្រានេះឡើយ ហើយផ្ទុយទៅវិញ ត្រូវតែបំផ្លាញចោលដោយស្នងការប៉ូលិសរដ្ឋ។

(e) លើកលែងតែមានចែងផ្សេងនៅក្នុងជំពូកនេះ ប្រសិនបើអាជ្ញាធរចេញអាជ្ញាបណ្ណមិនអាចស្វែងរក ឬកំណត់អត្តសញ្ញាណម្ចាស់ស្របច្បាប់បានក្នុងកម្រិតសមរម្យក្នុងរយៈពេល 180 ថ្ងៃ គិតចាប់ពីថ្ងៃដែលអាជ្ញាធរចេញអាជ្ញាបណ្ណទទួលបានអាវុធនោះមក អាជ្ញាធរចេញអាជ្ញាបណ្ណអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការដោះដូរ ឬចាត់ចែងអាវុធឬគ្រាប់រំសេវដែលលើសតម្រូវការ ត្រូវបានបរិច្ចាគ ត្រូវបានបោះបង់ចោល ឬជារបស់អេតចាយ ទៅឱ្យក្រុមហ៊ុនចែកចាយ ឬអាជីវករលក់អាវុធមានអាជ្ញាបណ្ណត្រឹមត្រូវ។ ថវិកាដែលទទួលបានពីការលក់ ឬការផ្ទេរនោះ ត្រូវតែប្រគល់ ឬកត់ត្រាបញ្ចូលជាឥណទានទៅឱ្យសាលាក្រុងដែលអាជ្ញាធរចេញអាជ្ញាបណ្ណនោះកំពុងគ្រប់គ្រង ដើម្បីយកទៅទិញអាវុធ ឧបករណ៍ ឬសម្ភារៈផ្គត់ផ្គង់នានា ឬសម្រាប់ប្រើប្រាស់ក្នុងកម្មវិធីកាត់បន្ថយអំពើហិង្សា ឬការការពារការធ្វើអត្តឃាត។ ទោះជាយ៉ាងណាក៏ដោយ គ្មានអាវុធ ឬគ្រាប់រំសេវណាដែលត្រូវបានកំណត់អត្តសញ្ញាណស្របតាមមាត្រា 131Q ថាត្រូវបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសត្រូវចាត់ទុកជាអាវុធលើសតម្រូវការ ត្រូវបានបរិច្ចាគ ត្រូវបានបោះបង់ចោល ឬរបស់អេតចាយ សម្រាប់គោលបំណងនៃមាត្រានេះឡើយ។

(f) អាជ្ញាធរចេញអាជ្ញាបណ្ណ ត្រូវតែរាយការណ៍អំពីការប្រគល់ ការដាក់ជូន ឬការរឹបអូសអាវុធនិងគ្រាប់រំសេវ ស្របតាមមាត្រា 131R ដល់មាត្រា 131Y ទាំងស្រុង ទៅកាន់នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ តាមរយៈប្រព័ន្ធចុះបញ្ជីអាវុធអេឡិចត្រូនិក។ របាយការណ៍នេះ ត្រូវរួមបញ្ចូលនូវព័ត៌មានដូចខាងក្រោម៖ (i) កាលបរិច្ឆេទនៃការប្រគល់ ការដាក់ជូន ឬការរឹបអូស (ii) ម៉ាក ម៉ូដែល លេខស៊េរី និងទំហំមុខកាត់អាវុធដែលបានប្រគល់ បានដាក់ជូន ឬបានរឹបអូស ព្រមទាំងរាល់ព័ត៌មានសម្គាល់ផ្សេងៗសម្រាប់គ្រាប់រំសេវដែលបានប្រគល់ បានដាក់ជូន ឬបានរឹបអូស (iii) មូលហេតុសំអាងនៃការដាក់ជូន ឬការរឹបអូស (iv) អំពីថាអាវុធ ឬគ្រាប់រំសេវនោះត្រូវបានហាមឃាត់ដោយច្បាប់មិនឱ្យមានកម្មសិទ្ធិ ឬកាន់កាប់នៅក្នុងរដ្ឋម៉ាសាឈូសិត (v) ព័ត៌មានថាអាវុធ ឬគ្រាប់រំសេវនោះត្រូវបានចាត់ថ្នាក់ថាត្រូវបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស (vi) ព័ត៌មានស្តីពីការកាន់កាប់ ការរក្សាទុក ការផ្ទេរ ការលក់ និងចំណូលទាំងឡាយណាដែលទទួលបានពីសកម្មភាពទាំងនោះ និង (vii) ការបំផ្លាញចោល ឬការចាត់ចែងតាមរូបភាពផ្សេងទៀតចំពោះអាវុធ ឬគ្រាប់រំសេវនោះ។ នៅពេលដាក់ជូនព័ត៌មាននេះ ប្រព័ន្ធត្រូវរាយការណ៍ដោយស្វ័យប្រវត្តិមកកាន់អាជ្ញាធរចេញអាជ្ញាបណ្ណវិញ អំពីថាអាវុធនោះត្រូវបានចុះបញ្ជីរួចរាល់ ត្រូវបានវាយលេខស៊េរីសម្គាល់ ត្រូវបានរាយការណ៍ថាបាត់បង់ ឬត្រូវបានលួច ឬជាភស្តុតាងសក្តានុពលនៅក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌមិនទាន់ដោះស្រាយរួចរាល់។

(g) ប្រធានការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ អាចប្រកាសឱ្យប្រើវិធាននិងបទប្បញ្ញត្តិទាំងឡាយតាមការចាំបាច់ ដើម្បីអនុវត្តមាត្រានេះ។

មាត្រា 47 មាត្រា 131 នៃជំពូក 140 ដែលបានពោល ត្រូវបាននិរាករតាមរយៈច្បាប់នេះ។

មាត្រា 48 មាត្រា 130½ នៃជំពូក 140 ខាងលើ ដែលមានចែងនៅក្នុងការបោះពុម្ពផ្សាយផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្ម ដោយការលុបចោលពាក្យ "គ្រឿងសព្វាវុធ" នៅត្រង់បន្ទាត់ទី 2 និង 5 រាល់ពេលដែលពាក្យនេះលេចឡើង ហើយជំនួសមកវិញនូវពាក្យ៖ "អាវុធ" នៅក្នុងករណីនីមួយៗដូចខាងក្រោម៖

មាត្រា 49 ជំពូក 140 ដែលបានពោល ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 131 ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 131 ការចេញ និងការកាន់កាប់អាជ្ញាបណ្ណកាន់កាប់អាវុធ ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌ និងការរឹតត្បិតដូចខាងក្រោម៖

(a) អាជ្ញាបណ្ណត្រូវផ្តល់សិទ្ធិឱ្យអ្នកកាន់កាប់អាជ្ញាបណ្ណនោះ ក្នុងការទិញ ជួលរយៈពេលខ្លី ជួលរយៈពេលវែង ខ្ចី កាន់កាប់ និងនាំយកតាមខ្លួននូវអាវុធ រាប់បញ្ចូលទាំងអាវុធដែលមានសមត្ថភាពផ្ទុកគ្រាប់ច្រើន និងគ្រាប់រំសេវសម្រាប់អាវុធទាំងនោះ។ អាជ្ញាបណ្ណនេះមិនត្រូវផ្តល់សិទ្ធិឱ្យអ្នកកាន់កាប់ក្នុងការផ្ទេរ កាន់កាប់ ឬនាំយកតាមខ្លួននូវឧបករណ៍បញ្ចូលគ្រាប់ មានសមត្ថភាពផ្ទុកខ្ពស់ ឬអាវុធប្រភេទវាយប្រហារឡើយ លើកលែងតែការផ្ទេរ ការកាន់កាប់ ឬការនាំយកតាមខ្លួននោះ ត្រូវបានអនុញ្ញាតក្រោមមាត្រា 131M។

(b) គ្មានអាជ្ញាបណ្ណណាមួយត្រូវចេញឱ្យក្រោមមាត្រានេះឡើយ លុះត្រាតែអ្នកស្នើសុំដាក់ជូនជាមួយពាក្យសុំរបស់ពួកគេនូវវិញ្ញាបនបត្រសុវត្ថិភាពអាវុធជាមូលដ្ឋាន ដែលបំពេញតាមលក្ខខណ្ឌចាំបាច់នៃមាត្រា 131P។

(c) អាជ្ញាបណ្ណកាន់កាប់អាវុធ ត្រូវមានសុពលភាពសម្រាប់ការមានជាកម្មសិទ្ធិ ការកាន់កាប់ ការទិញ និងការផ្ទេរកាំភ្លើងវែង និងកាំភ្លើងគ្រាប់ប្រាយដែលមិនមែនជាប្រភេទអាវុធមានសមត្ថភាពផ្ទុកខ្ពស់ ឬពាក់កណ្តាលស្វ័យប្រវត្តិ ស្របទៅតាមសិទ្ធិផ្តល់ជូនដោយបណ្ណសម្គាល់អាវុធ ដែលបានចេញអនុលោមតាមមាត្រា 129B។

(d) និវាសជនស្របច្បាប់ណាដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ រស់នៅក្នុងដែនសមត្ថកិច្ចរបស់អាជ្ញាធរចេញអាជ្ញាបណ្ណ ឬមន្រ្តីអនុវត្តច្បាប់ណាក៏ដោយដែលបម្រើការងារឱ្យអាជ្ញាធរចេញអាជ្ញាបណ្ណ ឬបុគ្គលណាក៏ដោយដែលរស់នៅក្នុងតំបន់ដែនសមត្ថកិច្ចផ្តាច់មុខរបស់សហព័ន្ធដែលស្ថិតនៅក្នុងទីក្រុង ឬតំបន់ អាចដាក់ពាក្យសុំអាជ្ញាបណ្ណកាន់កាប់អាវុធ ឬស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណនេះទៅកាន់អាជ្ញាធរចេញអាជ្ញាបណ្ណបាន ដែលអាជ្ញាធរចេញអាជ្ញាបណ្ណនេះត្រូវចេញអាជ្ញាបណ្ណនោះឱ្យ ដូចមានចែងក្នុងមាត្រា 121F បានតែក្នុងករណីដែលពិនិត្យឃើញថា អ្នកស្នើសុំមិនមែនជាបុគ្គលត្រូវហាមឃាត់ ហើយក៏មិនត្រូវបានកំណត់ថាជាបុគ្គលមិនសមស្របនឹងទទួលបានអាជ្ញាបណ្ណ ដូចមានចែងក្នុងមាត្រា 121F ខាងលើនោះតែប៉ុណ្ណោះ។ លើសពីនេះទៀត ចំពោះពាក្យសុំអាជ្ញាបណ្ណកាន់កាប់អាវុធជាលើកដំបូង អាជ្ញាធរចេញអាជ្ញាបណ្ណត្រូវធ្វើការសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកស្នើសុំ។

(e) អាជ្ញាបណ្ណកាន់កាប់អាវុធត្រូវមានសុពលភាពមិនលើសពីរយៈពេល 6 ឆ្នាំឡើយ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ លើកលែងតែត្រូវបានដកហូត ឬផ្អាកជាបណ្តោះអាសន្ន ហើយត្រូវអស់សុពលភាពចំថ្ងៃខួបកំណើតរបស់ម្ចាស់អាជ្ញាបណ្ណដែលកើតឡើងមិនតិចជាង 5 ឆ្នាំ និងមិនលើសពី 6 ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ។ រាល់អាជ្ញាបណ្ណចេញឱ្យអ្នកដាក់ពាក្យសុំដែលកើតនៅថ្ងៃទី 29 ខែកុម្ភៈ ត្រូវអស់សុពលភាពនៅថ្ងៃទី 1 ខែមីនា។

(f) គ្មានបុគ្គលណាម្នាក់ត្រូវទទួលបានអាជ្ញាបណ្ណនាំយកតាមខ្លួននូវកាំភ្លើងយន្តនៅក្នុងរដ្ឋម៉ាសាឈូសិតឡើយ លើកលែងតែអាជ្ញាធរចេញអាជ្ញាបណ្ណអាចចេញ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

អាជ្ញាបណ្ណកាំភ្លើងយន្តទៅឱ្យ៖ (i) គ្រូបង្វឹកប្រើអាវុធដែលបញ្ជាក់ទទួលស្គាល់ដោយគណៈកម្មាធិការបណ្តុះបណ្តាលប៉ូលិសក្រុង ក្នុងគោលបំណងតែមួយគត់ គឺការណែនាំបង្ហាត់បង្ហាញអំពីអាវុធដល់មន្ត្រីប៉ូលិស ឬ (ii) អ្នកប្រមូលទិញអាវុធពិតប្រាកដ ដូចមានចែងក្នុងមាត្រា 121 នៅពេលដាក់ពាក្យសុំ ឬនៅពេលដាក់ពាក្យសុំបន្តសុពលភាពរបស់អាជ្ញាបណ្ណបែបនោះ។ អនុប្រយោគ (i) និង (ii) នៃកថាខណ្ឌនេះ មិនត្រូវយកមកអនុវត្តចំពោះឧបករណ៍ស្វ័យប្រវត្តិ ឬ គ្រឿងស្វ័យប្រវត្តិឡើយ។

(g) បុគ្គលដែលទទួលបានអាជ្ញាបណ្ណក្រោមមាត្រានេះ ត្រូវរាយការណ៍អំពីការផ្លាស់ប្តូរអាសយដ្ឋានណាមួយតាមរយៈប្រព័ន្ធចុះបញ្ជីអាវុធតាមអេឡិចត្រូនិក ដែលគ្រប់គ្រងដោយប្រធាននាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ។ ការជូនដំណឹងបែបនេះត្រូវធ្វើឡើងនៅលើផតថល ក្នុងរយៈពេល 30 ថ្ងៃ គិតចាប់ពីថ្ងៃមានការផ្លាស់ប្តូរនោះ។  ការខកខានមិនបានជូនដំណឹងឱ្យបានទាន់ពេលវេលា គឺជាមូលហេតុនៃការដកហូត ឬការព្យួរទុកនូវអាជ្ញាបណ្ណខាងលើ។

(h) ប្រធានការិយាល័យប្រតិបត្តិសន្តិសុខសាធារណៈ ឬបុគ្គលទទួលការចាត់តាំងរបស់ខ្លួន អាចប្រកាសឱ្យប្រើប្រាស់បទប្បញ្ញត្តិទាំងឡាយ ដើម្បីអនុវត្តគោលបំណងនៃមាត្រានេះ។

មាត្រា 50 ជំពូក 140 ដែលបានពោល ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលមាត្រា 131½ ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 131½. (a) ត្រូវបង្កើតឱ្យមានគណៈកម្មាធិការប្រឹក្សាយោបល់ត្រួតពិនិត្យអាវុធនៅក្នុងការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ តទៅនេះហៅកាត់ថា គណៈកម្មាធិការ ដែលមានសមាជិក 7 រូប រួមមាន៖ នាយកការិយាល័យកត់ត្រាទិន្នន័យអាវុធនៅក្នុងនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ឬបុគ្គលទទួលការតែងតាំង ដែលត្រូវធ្វើជាប្រធាន, អគ្គរដ្ឋអាជ្ញា ឬបុគ្គលទទួលការតែងតាំង សមាជិក 1 រូបតែងតាំងដោយប្រធានសភាតំណាងរាស្ត្រ ដែលបុគ្គលនោះមិនត្រូវជាសមាជិកសភានីតិបញ្ញត្តិរដ្ឋឡើយ ហើយត្រូវតែជាបុគ្គលដែលបានបង្ហាញឱ្យឃើញនូវចំណេះដឹង ឬជំនាញច្បាស់លាស់ក្នុងផ្នែកសុវត្ថិភាព ច្បាប់ ឬបច្ចេកវិទ្យាអាវុធ, សមាជិក 1 រូបតែងតាំងដោយប្រធានព្រឹទ្ធសភា ដែលបុគ្គលនោះមិនត្រូវជាសមាជិកសភានីតិបញ្ញត្តិរដ្ឋឡើយ ហើយត្រូវតែជាបុគ្គលដែលបានបង្ហាញឱ្យឃើញនូវចំណេះដឹង ឬជំនាញច្បាស់លាស់ក្នុងផ្នែកសុវត្ថិភាព ច្បាប់ ឬបច្ចេកវិទ្យាអាវុធ, សមាជិក 2 រូបតែងតាំងដោយអភិបាលរដ្ឋ ដែលក្នុងនោះសមាជិក 1 រូបត្រូវតែជាសមាជិកនៃសម្ព័ន្ធសកម្មភាពម្ចាស់អាវុធ (Gun Owners Action League, Inc.) ហើយសមាជិក 1 រូបទៀតត្រូវតែជាមេប៉ូលិស ដែលត្រូវបានជ្រើសរើសចេញពីបញ្ជីមេប៉ូលិសចំនួន 4 រូប ផ្តល់ដោយប្រធានសមាគមប៉ូលិសរដ្ឋម៉ាសាឈូសិត (Massachusetts Chiefs of Police Association Incorporated) និងមន្ត្រីទទួលបន្ទុកថែទាំ និងជួសជុលអាវុធនៃក្រសួងប៉ូលិសរដ្ឋ ឬបុគ្គលទទួលការចាត់តាំង។

(b) គណៈកម្មាធិការនេះត្រូវផ្តល់ប្រឹក្សាយោបល់ដល់ការិយាល័យប្រតិបត្តិសន្តិសុខ និង សុវត្ថិភាពសាធារណៈ អំពីបញ្ហានានាពាក់ព័ន្ធនឹងបទប្បញ្ញត្តិត្រួតពិនិត្យអាវុធនៃជំពូកនេះ រួមមានជាអាទិ៍ ការពិគ្រោះយោបល់ជាមួយការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាព សាធារណៈ លើការរៀបចំបញ្ជីឈ្មោះអាវុធ ដូចមានចែងក្នុងមាត្រា 131¾។ គណៈកម្មាធិការនេះក៏ត្រូវផ្តល់ប្រឹក្សាយោបល់ដល់ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈផងដែរ អំពីតម្រូវការបណ្តុះបណ្តាលនិងឯកសារសម្រាប់អាជ្ញាធរចេញអាជ្ញាបណ្ណ និងអ្នកទទួលអាជ្ញាបណ្ណ។ សមាជិកគណៈកម្មាធិការ ត្រូវបំពេញភារកិច្ចដោយមិនទទួលបានប្រាក់កម្រៃឡើយ។ ទោះជាយ៉ាងណាក៏ដោយ សមាជិកត្រូវទទួលបានការទូទាត់សំណងវិញសម្រាប់ការចំណាយជាទូទៅ និងជាទម្លាប់ ដែលកើតឡើងក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន។ ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការនេះ ត្រូវអនុម័តលើវិធាននិងនីតិវិធីប្រតិបត្តិសម្រាប់ការរៀបចំចាត់តាំងអង្គភាព និងសកម្មភាពនានារបស់ខ្លួន។

មាត្រា 51 ជំពូក 140 ដែលបានពោល ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 131¾ ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 131¾. (a) រដ្ឋមន្ត្រីសន្តិសុខនិងសុវត្ថិភាពសាធារណៈ ដោយមានការពិគ្រោះយោបល់ និងការផ្តល់យោបល់ពីគណៈកម្មាធិការប្រឹក្សាយោបល់ត្រួតពិនិត្យអាវុធដែលត្រូវបានបង្កើតឡើងក្នុងមាត្រា 131½ ត្រូវចងក្រង និងបោះពុម្ពផ្សាយនូវបញ្ជីឈ្មោះអាវុធប្រភេទវាយប្រហារដែលត្រូវបានហាមឃាត់ក្រោមមាត្រា 131M និងបញ្ជីឈ្មោះអាវុធដែលត្រូវបានអនុម័តសម្រាប់ការលក់ និងការប្រើប្រាស់នៅក្នុងរដ្ឋម៉ាសាឈូសិត ដោយផ្អែកតាមប៉ារ៉ាម៉ែត្រកំណត់ដូចមានចែងក្នុងមាត្រា 123។ រដ្ឋមន្ត្រីត្រូវពិនិត្យឡើងវិញ ធ្វើបច្ចុប្បន្នភាព និងបោះពុម្ពផ្សាយបញ្ជីឈ្មោះទាំងនោះតាមប្រព័ន្ធអនឡាញ យ៉ាងហោចណាស់ 3 ដងក្នុងមួយឆ្នាំ ហើយត្រូវផ្ញើច្បាប់ចម្លងទៅគ្រប់បុគ្គលទាំងអស់ដែលទទួលបានអាជ្ញាបណ្ណនៅក្នុងរដ្ឋម៉ាសាឈូសិតស្របតាមមាត្រា 122។ អាជ្ញាធរចេញអាជ្ញាបណ្ណ ត្រូវផ្តល់ព័ត៌មានអំពីបញ្ជីឈ្មោះទាំងនេះដល់គ្រប់អ្នកកាន់លិខិតអនុញ្ញាត អ្នកកាន់បណ្ណសម្គាល់ និងអ្នកទទួលបានអាជ្ញាបណ្ណទាំងអស់ នៅពេលចេញជូនជាលើកដំបូង និងនៅរាល់ពេលបន្តសុពលភាព។

(b) ដោយមានការផ្តល់យោបល់ពីគណៈកម្មាធិការប្រឹក្សាយោបល់ត្រួតពិនិត្យអាវុធ រដ្ឋមន្ត្រីក៏ត្រូវចងក្រង និងបោះពុម្ពផ្សាយផងដែរនូវបញ្ជីឈ្មោះអាវុធទាំងឡាយណាដែលត្រូវបានរចនាឡើង និងលក់ជាពិសេសសម្រាប់តែការប្រកួតបាញ់ស៊ីបផ្លូវការ ឬការប្រកួតកីឡាបាញ់កាំភ្លើងអូឡាំពិកតែប៉ុណ្ណោះ។ គណៈកម្មាធិការត្រូវពិនិត្យឡើងវិញ ធ្វើបច្ចុប្បន្នភាព និងបោះពុម្ពផ្សាយបញ្ជីឈ្មោះទាំងនេះ យ៉ាងហោចណាស់ 2 ដងក្នុងមួយឆ្នាំ និងត្រូវរៀបចំបញ្ជីឈ្មោះទាំងនោះឱ្យមានសម្រាប់ការចែកចាយ។

(c) រដ្ឋមន្ត្រីអាចធ្វើវិសោធនកម្មលើបញ្ជីឈ្មោះណាមួយបាន តាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួនរបស់ពួកគេ។ បុគ្គលម្នាក់អាចដាក់ពាក្យស្នើសុំទៅរដ្ឋមន្ត្រី ដើម្បីបញ្ចូលអាវុធណាមួយចូលទៅក្នុងបញ្ជី ឬដកអាវុធណាមួយចេញពីបញ្ជីឈ្មោះបាន ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ។ ញត្តិសុំធ្វើវិសោធនកម្មលើបញ្ជីឈ្មោះត្រូវតែដាក់ជូនជាលាយលក្ខណ៍អក្សរទៅកាន់រដ្ឋមន្ត្រី ទៅតាមទម្រង់និងបែបបទកំណត់ដោយរដ្ឋមន្ត្រី ហើយត្រូវរួមបញ្ចូលនូវមូលហេតុដែលគួរធ្វើវិសោធនកម្មបញ្ជីឈ្មោះនោះ។ ក្នុងរយៈពេល 45 ថ្ងៃក្រោយពេលទទួលបានញត្តិសុំធ្វើវិសោធនកម្មលើបញ្ជីឈ្មោះរដ្ឋមន្ត្រីត្រូវចាត់វិធានការ ដោយការជូនដំណឹងទៅអ្នកដាក់ញត្តិទោះជាញត្តិនោះត្រូវបានបដិសេធ ឬមានការកែប្រែបញ្ជីឈ្មោះនោះក៏ដោយ។ ការ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

បន្ថែមណាមួយចូលទៅក្នុងបញ្ជីឈ្មោះ ត្រូវមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទដែលគណៈកម្មាធិការបានបោះពុម្ពផ្សាយបញ្ជីឈ្មោះនោះតាមប្រព័ន្ធអនឡាញ។

មាត្រា 52 មាត្រា 131A នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយការលុបចោលពាក្យថា “កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយ” នៅក្នុងបន្ទាត់ទី 10។

មាត្រា 53 មាត្រា 131B នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយការលុបចោលពាក្យថា “កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ ឬកាំភ្លើងយន្ត” នៅក្នុងបន្ទាត់ទី 2 និងទី 7។

មាត្រា 54 មាត្រា 131C នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយដាក់បញ្ចូលបន្ទាប់ពីពាក្យ “មាត្រា” នៅក្នុងបន្ទាត់ទី 2 នូវលេខដូចតទៅ៖ “129B”

មាត្រា 55 មាត្រា 131C នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយដាក់បញ្ចូលបន្ទាប់ពីលេខ “131F” នៅក្នុងបន្ទាត់ទី 2 និងទី 7 នូវពាក្យដូចជា៖ “តាមរយៈការលើកលែងក្រោមប្រការ 129C”។

មាត្រា 56 មាត្រា 131C នៃជំពូក 140 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយការលុបចោលពាក្យ “កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយ” នៅត្រង់បន្ទាត់ទី 6, 8 និងទី 9 រាល់ពេលដែលពាក្យទាំងនេះលេចឡើង ហើយជំនួសមកវិញនូវពាក្យ៖ “អាវុធ” នៅត្រង់គ្រប់កន្លែងទាំងនោះ។

មាត្រា 57 មាត្រា 131C នៃជំពូក 140 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចេញពាក្យ៖ “ត្រូវបានដាក់នៅក្នុងឃ្លុបខាងក្រោយដែលចាក់សោនៃយានយន្ត ឬនៅក្នុងប្រអប់ចាក់សោ ឬប្រអប់សុវត្ថិភាពផ្សេងទៀត” នៅក្នុងបន្ទាត់ទី 9 និងទី 10 ហើយជំនួសមកវិញនូវពាក្យ៖ “ត្រូវបានរក្សាសុវត្ថិភាពនៅក្នុងប្រអប់ចាក់សោ ដូចមានចែងក្នុងមាត្រា 121”។

មាត្រា 58 មាត្រា 131C នៃជំពូកទី 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុចចោលពាក្យ “គ្រឿងសព្វាវុធ” ក្នុងបន្ទាត់ទី 19 ហើយបញ្ចូលជំនួសមកវិញនូវពាក្យដូចខាងក្រោម៖ “អាវុធ”។

មាត្រា 59 មាត្រា 131E នៃជំពូក 140 ដែលបានពោល ត្រូវបាននិរាករតាមរយៈច្បាប់នេះ។

មាត្រា 60 មាត្រា 131F នៃជំពូក 140 ដូចបានពោល ដែលមានចែងនៅក្នុងការបោះពុម្ពផ្សាយជាផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ៖ “កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយ” នៅក្នុងបន្ទាត់ទី 1 និងទី 2។

មាត្រា 61 មាត្រា 131F នៃជំពូក 140 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលពាក្យ “ជនបរទេសដែលរស់នៅក្រៅរដ្ឋម៉ាសាឈូសិត” ក្នុងបន្ទាត់ទី 5 និងទី 6 ហើយជំនួសមកវិញនូវពាក្យដូចខាងក្រោម៖ “ពលរដ្ឋ ឬជនជាតិអាមេរិក ឬបុគ្គលដែលរក្សាបាននូវឋានៈជានិវាសនដ្ឋានអចិន្ត្រៃយ៍ស្របច្បាប់”។

មាត្រា 62 មាត្រា 131F នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលលេខ “131” ក្នុងបន្ទាត់ទី 9 ហើយបញ្ចូលជំនួសវិញដោយលេខ៖ “121F”។

មាត្រា 63 មាត្រា 131F នៃជំពូក 140 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ “ហើយឧបករណ៍បញ្ចូលគ្រាប់មានសមត្ថភាពផ្ទុកខ្ពស់សម្រាប់អាវុធនោះ អាចត្រូវបាននាំយកតាមខ្លួនបាន ប្រសិនបើបុគ្គលនោះទទួលបានអាជ្ញាបណ្ណ ស្នងការអាចអនុញ្ញាតឱ្យអ្នកទទួលបានអាជ្ញាបណ្ណកាន់កាប់កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬកាំភ្លើងទាំងពីរប្រភេទនេះបាន” ក្នុងបន្ទាត់ទី 18 ដល់ទី 21 ទាំងស្រុង ហើយជំនួសមកវិញនូវពាក្យដូចខាងក្រោម៖ “អាចយកតាមខ្លួនបាន ប្រសិនបើបុគ្គលនោះទទួលបានអាជ្ញាបណ្ណ”។

មាត្រា 64 មាត្រា 131G នៃជំពូក 140 ដែលបានពោល ត្រូវបាននិរាករតាមរយៈច្បាប់នេះ។

មាត្រា 65 មាត្រា 131H នៃជំពូក 140 ដែលបានពោល ត្រូវបាននិរាករតាមរយៈច្បាប់នេះ។

មាត្រា 66 មាត្រា 131K នៃជំពូក 140 ខាងលើ ដែលបានចែងនៅក្នុងការបោះពុម្ពផ្សាយជាផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ “គ្រឿងសព្វាវុធ” ក្នុងបន្ទាត់ទី 1, 3, 11, 16, 28, 31, 32, 37, 40, 44, និង 45 រាល់ពេលដែលពាក្យនេះលេចឡើង ហើយជំនួសមកវិញនូវពាក្យដូចខាងក្រោម៖ “អាវុធ”។

មាត្រា 67 មាត្រា 131L នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ “កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយ រួមមានជាអាទិ៍ គ្រឿងសព្វាវុធដែលមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬកាំភ្លើងយន្ត” ក្នុងបន្ទាត់ទី 2 និងទី 3។

មាត្រា 68 មាត្រា 131L នៃជំពូក 140 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ “គ្រឿងសព្វាវុធ” ក្នុងបន្ទាត់ទី 3, 6, 8, 10, 22, 39 និង 41 រាល់ពេលដែលពាក្យនេះលេចឡើង ហើយជំនួសមកវិញនូវពាក្យ៖ “អាវុធ” នៅត្រង់គ្រប់កន្លែងទាំងនោះ។

មាត្រា 69 មាត្រា 131L នៃជំពូក 140 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ “កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយដែលមិនមែនជាសព្វាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន” ក្នុងបន្ទាត់ 14 និង 22 រាល់ពេលដែលពាក្យទាំងនេះលេចឡើង ហើយជំនួសមកវិញនូវពាក្យដូចខាងក្រោម៖ “ដែលមិនមែនជាអាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬកាំភ្លើងយន្ត” នៅត្រង់គ្រប់កន្លែងទាំងនោះ។

មាត្រា 70 មាត្រា 131L នៃជំពូក 140 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយដាក់បញ្ចូលបន្ទាប់ពីពាក្យ “សមត្ថភាព” នៅក្នុងបន្ទាត់ទី 17 នូវពាក្យដូចតទៅ៖ “ឬពាក់កណ្តាលស្វ័យប្រវត្តិ”។

មាត្រា 71 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 131M ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 131M (a) គ្មានបុគ្គលណាម្នាក់ត្រូវកាន់កាប់ មានកម្មសិទ្ធិ ដាក់លក់ លក់ ឬផ្ទេរតាមរូបភាពផ្សេងទៀតនៅក្នុងរដ្ឋម៉ាសាឈូសិត ឬនាំចូលមកក្នុងរដ្ឋម៉ាសាឈូសិតនូវអាវុធប្រភេទវាយប្រហារ ឬឧបករណ៍បញ្ចូលគ្រាប់មានសមត្ថភាពផ្ទុកខ្ពស់។

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

(b) កថាខណ្ឌ (a) មិនត្រូវអនុវត្តចំពោះអាវុធប្រភេទវាយប្រហារ កាន់កាប់ដោយស្របច្បាប់ក្នុងរដ្ឋម៉ាសាឈូសិតនៅថ្ងៃទី 1 ខែសីហា ឆ្នាំ 2024 ដោយម្ចាស់អាវុធមានអាជ្ញាបណ្ណកាន់កាប់អាវុធដែលទទួលបានក្រោមមាត្រា 131 ឬដោយអ្នកកាន់អាជ្ញាបណ្ណលក់អាវុធក្រោមមាត្រា 122 នោះឡើយ ប៉ុន្តែអាវុធប្រភេទវាយប្រហារនោះ ត្រូវតែបានចុះបញ្ជីស្របតាមមាត្រា 121B និងត្រូវបានវាយលេខស៊េរីសម្គាល់ស្របតាមមាត្រា 121C។

(c) កថាខណ្ឌ (a) មិនត្រូវអនុវត្តចំពោះឧបករណ៍បញ្ចូលគ្រាប់មានសមត្ថភាពផ្ទុកខ្ពស់ដែលកាន់កាប់ដោយស្របច្បាប់នៅថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 1994 នោះឡើយ លុះត្រាតែការកាន់កាប់នោះស្ថិតនៅក្នុងករណីដូចខាងក្រោម៖ (i) នៅលើអចលនទ្រព្យឯកជនដែលមានកម្មសិទ្ធិ ឬត្រូវបានគ្រប់គ្រងស្របច្បាប់ដោយបុគ្គលដែលកំពុងកាន់កាប់ឧបករណ៍បញ្ចូលគ្រាប់មានសមត្ថភាពផ្ទុកខ្ពស់។ (ii) នៅលើអចលនទ្រព្យឯកជនដែលមិនបើកចំហជាសាធារណៈ ដោយមានការអនុញ្ញាតច្បាស់លាស់ពីម្ចាស់អចលនទ្រព្យ ឬភ្នាក់ងារទទួលសិទ្ធិពីម្ចាស់អចលនទ្រព្យនោះ។ (iii) ក្នុងពេលស្ថិតនៅលើទីតាំងរបស់អាជីវករលក់អាវុធ ឬជាងធ្វើកាំភ្លើងដែលមានអាជ្ញាបណ្ណ ក្នុងគោលបំណងជួសជុលដោយស្របច្បាប់។ (iv) នៅឯទីលានបាញ់កាំភ្លើងមានអាជ្ញាបណ្ណ ឬទីកន្លែងប្រកួតកីឡាបាញ់កាំភ្លើង ឬ (v) ក្នុងពេលកំពុងធ្វើដំណើរទៅនិងមកពីទីតាំងទាំងនេះ ប៉ុន្តែឧបករណ៍បញ្ចូលគ្រាប់មានសមត្ថភាពផ្ទុកខ្ពស់នោះ ត្រូវតែរក្សាទុកដោយមិនមានផ្ទុកគ្រាប់ និងត្រូវបានរក្សាសុវត្ថិភាពនៅក្នុងប្រអប់ចាក់សោ ស្របតាមមាត្រា 131C និង 131L។ បុគ្គលទទួលបានការអនុញ្ញាតក្រោមកថាខណ្ឌនេះក្នុងការកាន់កាប់ឧបករណ៍បញ្ចូលគ្រាប់មានសមត្ថភាពផ្ទុកខ្ពស់ អាចផ្ទេរឧបករណ៍នោះបានតែចំពោះអ្នកស្នងមរតក ឬអ្នកទទួលមរតកសាសន៍ បុគ្គលដែលរស់នៅក្រៅរដ្ឋម៉ាសាឈូសិត ឬអាជីវករមានអាជ្ញាបណ្ណតែប៉ុណ្ណោះ។

(d) ជនណាក៏ដោយដែលល្មើសនឹងមាត្រានេះ ត្រូវផ្តន្ទាទោសចំពោះបទល្មើសលើកដំបូង ដោយពិន័យជាប្រាក់មិនតិចជាង 1,000 ដុល្លារ និងមិនលើសពី 10,000 ដុល្លារ ឬដោយដាក់ពន្ធនាគារមិនតិចជាង 1 ឆ្នាំ និងមិនលើសពី 10 ឆ្នាំ ឬទាំងទោសពិន័យជាប្រាក់ ទាំងទោសដាក់ពន្ធនាគារ ហើយចំពោះបទល្មើសលើកទីពីរ ត្រូវទទួលទោសដោយពិន័យជាប្រាក់មិនតិចជាង 5,000 ដុល្លារ និងមិនលើសពី 15,000 ដុល្លារ ឬដោយដាក់ពន្ធនាគារមិនតិចជាង 5 ឆ្នាំ និងមិនលើសពី 15 ឆ្នាំ ឬទាំងទោសពិន័យជាប្រាក់ ទាំងទោសដាក់ពន្ធនាគារ។

(e) មាត្រានេះមិនត្រូវអនុវត្តចំពោះការផ្ទេរ ឬការកាន់កាប់ដោយ៖ (i) មន្ត្រីអនុវត្តច្បាប់ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬមន្ត្រីអនុវត្តច្បាប់ចូលនិវត្តន៍ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងច្បាប់ស្តីពីសុវត្ថិភាពមន្ត្រីអនុវត្តច្បាប់ឆ្នាំ 2004 ក្រម18 U.S.C. មាត្រា 926B និង 926C រៀងគ្នា ដូចបានធ្វើវិសោធនកម្ម។ (ii) ទីភ្នាក់ងារអនុវត្តច្បាប់សហព័ន្ធ រដ្ឋ ឬតំបន់ ឬ (iii) ក្រុមហ៊ុនផលិតដែលទទួលបានអាជ្ញាបណ្ណសហព័ន្ធ ក្នុងគោលបំណងតែមួយគត់គឺការលក់ ឬការផ្ទេរនៅក្នុងរដ្ឋផ្សេង ឬសម្រាប់ នាំចេញទៅក្រៅប្រទេស។

មាត្រា 72 មាត្រា 131N នៃជំពូកទី 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលប្រយោគទីមួយ ហើយបញ្ចូលជំនួសដោយប្រយោគខាងក្រោម៖-

គ្មានបុគ្គលណាម្នាក់កាន់កាប់ គ្រប់គ្រង លក់ ដាក់លក់ ផ្ទេរ ផលិត ដំឡើង ជួសជុល ឬនាំចូលដោយចេតនានូវអាវុធណាមួយដែលអាចបញ្ចេញ ឬបាញ់គ្រាប់បាន ជាអាវុធលាក់បាំង ឬអាវុធមិនអាចរកឃើញ ដូចមាននិយមន័យក្នុងមាត្រា 121 ឡើយ។

មាត្រា 73 មាត្រា 131O នៃជំពូកទី 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ “គ្រឿងសព្វាវុធ” នៅក្នុងបន្ទាត់ទី 22 ហើយបញ្ចូលជំនួសមកវិញដោយពាក្យដូចខាងក្រោម៖ “អាវុធ”។

មាត្រា 74 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលមាត្រា 131P ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 131P (a) បុគ្គលណាក៏ដោយដែលដាក់ពាក្យសុំការចេញអាជ្ញាបណ្ណ ឬប័ណ្ណ ក្រោមមាត្រា 129B, 131 ឬ 131F ត្រូវតែដាក់ជូនទៅអាជ្ញាធរចេញអាជ្ញាបណ្ណនូវវិញ្ញាបនបត្រសុវត្ថិភាពអាវុធជាមូលដ្ឋាន បន្ថែមលើលក្ខខណ្ឌតម្រូវនានាដែលបានចែងនៅក្នុងជំពូកនេះ។ ទោះជាយ៉ាងណាក៏ដោយ វិញ្ញាបនបត្រប្រគល់ជូនស្របតាមមាត្រា 14 នៃជំពូក 131 ដែលបង្ហាញពីការបញ្ចប់ជាស្ថាពរនូវវគ្គសិក្សាអប់រំសម្រាប់អ្នកបរបាញ់ ត្រូវចាត់ទុកជាឯកសារជំនួសមានសុពលភាពសម្រាប់វិញ្ញាបនបត្រសុវត្ថិភាពអាវុធជាមូលដ្ឋាន ដែលតម្រូវឱ្យមានក្រោមមាត្រានេះ សម្រាប់ការចេញបណ្ណសម្គាល់អាវុធ ស្របតាមមាត្រា 129B។ បុគ្គលទាំងឡាយណាដែលកាន់កាប់បណ្ណសម្គាល់អាវុធ ឬអាជ្ញាបណ្ណកាន់កាប់អាវុធដោយស្របច្បាប់នៅថ្ងៃទី 1 ខែសីហា ឆ្នាំ 2024 ត្រូវទទួលបានការលើកលែងពីមាត្រានេះ នៅពេលដែលបណ្ណសម្គាល់ ឬអាជ្ញាបណ្ណនោះអស់សុពលភាព និងនៅពេលដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណបែបនោះ ដូចបានតម្រូវក្រោមជំពូកនេះ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលទាំងឡាយណាដែលកាន់កាប់បណ្ណសម្គាល់អាវុធ ឬអាជ្ញាបណ្ណកាន់កាប់អាវុធមុនពេលមានការដាក់ឱ្យអនុវត្តវគ្គបណ្តុះបណ្តាលអនុវត្តការបាញ់អាវុធពិត ដូចបានតម្រូវនៅក្នុងមាត្រានេះ ក៏ត្រូវទទួលបានការលើកលែងពីលក្ខខណ្ឌតម្រូវបែបនោះផងដែរ។ គ្មានពាក្យស្នើសុំចេញបណ្ណសម្គាល់អាវុធ ឬអាជ្ញាបណ្ណកាន់កាប់អាវុធណាមួយ ត្រូវបានទទួលយក ឬដំណើរការពិនិត្យដោយអាជ្ញាធរចេញអាជ្ញាបណ្ណឡើយ ប្រសិនបើគ្មានវិញ្ញាបនបត្របែបនោះភ្ជាប់មកជាមួយទេនោះ។ ទោះជាយ៉ាងណាក៏ដោយ មាត្រានេះមិនត្រូវអនុវត្តចំពោះករណីដូចខាងក្រោមឡើយ៖ (i) មន្ត្រី ភ្នាក់ងារ ឬនិយោជិតណាម្នាក់របស់រដ្ឋម៉ាសាឈូសិត ឬរដ្ឋណាមួយនៃសហរដ្ឋអាមេរិក (ii) សមាជិកកងទ័ពណាម្នាក់ ឬសេវាកម្មយោធាផ្សេងទៀតនៃរដ្ឋណាមួយ ឬនៃសហរដ្ឋអាមេរិក ឬ (iii) មន្ត្រីអនុវត្តច្បាប់ ភ្នាក់ងារ ឬនិយោជិតណាម្នាក់របស់ក្រុងណាមួយនៃរដ្ឋម៉ាសាឈូសិតដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ ប៉ុន្តែបុគ្គលដែលបានរៀបរាប់នៅក្នុងអនុប្រយោគ (i) ដល់ (iii) ទាំងស្រុង ត្រូវទទួលបានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងការយកតាមខ្លួន ឬកាន់កាប់អាវុធដែលយកតាមខ្លួនឬកាន់កាប់នោះ ហើយត្រូវតែបំពេញសកម្មភាពនៅក្នុងក្របខណ្ឌនៃតួនាទីភារកិច្ចរបស់ខ្លួន។

(b)(i) ស្នងការប៉ូលិសរដ្ឋ ដោយមានការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការបណ្តុះបណ្តាលប៉ូលិសក្រុង ត្រូវប្រកាសឱ្យប្រើប្រាស់វិធាននិងបទប្បញ្ញត្តិទាំងឡាយដែលគ្រប់គ្រងលើការចេញ និងបង្កើតទម្រង់វិញ្ញាបនបត្រសុវត្ថិភាពអាវុធជាមូលដ្ឋាន ដែលតម្រូវឱ្យមានស្របតាមមាត្រានេះ រាប់បញ្ចូលទាំងលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់កម្មវិធីវគ្គសិក្សា និងខ្លឹមសារនៃការប្រឡងសរសេរណាមួយ។ ស្នងការប៉ូលីសត្រូវចេញវិញ្ញាសាប្រឡងសរសេរ និងកំណត់លក្ខខណ្ឌតម្រូវអប្បបរមាដើម្បីជាប់ការ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ប្រឡងខាងលើ ដែលត្រូវយកទៅប្រើប្រាស់នៅក្នុងគ្រប់វគ្គសិក្សា ឬកម្មវិធីសុវត្ថិភាពអាវុធទាំងអស់ដែលបានតម្រូវក្រោមមាត្រានេះ។

(ii) ស្នងការប៉ូលិសត្រូវបញ្ជាក់ទទួលស្គាល់បុគ្គលជាក់លាក់មួយចំនួនជាគ្រូបង្វឹកសុវត្ថិភាពអាវុធ បញ្ជាក់ទទួលស្គាល់កម្មវិធីវគ្គសិក្សាសុវត្ថិភាព ហើយត្រូវធ្វើបច្ចុប្បន្នភាព និងបង្ហោះផ្សាយជាប្រចាំឆ្នាំនៅលើគេហទំព័ររបស់ក្រសួងប៉ូលិសរដ្ឋនូវបញ្ជីឈ្មោះគ្រូបង្វឹកដែលបានការអនុម័ត។ ការបញ្ជាក់ទទួលស្គាល់ជាគ្រូបង្វឹកសុវត្ថិភាពអាវុធ ត្រូវមានសុពលភាពរយៈពេល 10 ឆ្នាំ លើកលែងតែត្រូវបានដកហូតមុនកាលកំណត់ដោយសារមូលហេតុនៃភាពមិនសមស្រប តាមឆន្ទានុសិទ្ធិរបស់ស្នងការប៉ូលិសខាងលើ។ គ្រូបង្វឹកសុវត្ថិភាពអាវុធ ត្រូវតែជាបុគ្គលណាដែលទទួលការបញ្ជាក់ពីស្ថាប័នទទួលស្គាល់ថ្នាក់ជាតិដែលលើកកម្ពស់សុវត្ថិភាពអាវុធ ឬបុគ្គលផ្សេងទៀតដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់ការបណ្តុះបណ្តាលនៅក្នុងវគ្គសិក្សាសុវត្ថិភាពអាវុធជាមូលដ្ឋាន តាមឆន្ទានុសិទ្ធិស្នងការខាងលើ។ បេក្ខជនដាក់ពាក្យសុំការបញ្ជាក់វិញ្ញាបនបត្រជាគ្រូបង្វឹកក្រោមមាត្រានេះ មិនត្រូវបានលើកលែងពីកាតព្វកិច្ចនៃជំពូកនេះ ឬច្បាប់ ឬបទប្បញ្ញត្តិផ្សេងទៀតរបស់រដ្ឋម៉ាសាឈូសិត ឬសហរដ្ឋអាមេរិកនោះឡើយ។ បន្ទាប់ពីទទួលបានពាក្យសុំដែលដាក់ជូនស្នងការប៉ូលិសរដ្ឋ ស្នងការខាងលើអាចសម្រេចតាមឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការបញ្ជាក់ទទួលស្គាល់បុគ្គលណាម្នាក់ជាគ្រូបង្វឹកសុវត្ថិភាពអាវុធ ដែលដំណើរការវគ្គសិក្សា ឬកម្មវិធីសុវត្ថិភាពអាវុធ ដែលរួម បញ្ចូលនៅក្នុងកម្មវិធីសិក្សារបស់ខ្លួននូវមាតិកាដូចខាងក្រោម៖ (A) ការប្រើប្រាស់ ការកាន់កាប់ និងការរក្សាទុកអាវុធដោយសុវត្ថិភាព (B) វិធីសាស្ត្រការពារ និងធានាសុវត្ថិភាពអាវុធឱ្យផុតពីដៃក្មេង (C) ច្បាប់ជាធរមាននានាពាក់ព័ន្ធនឹងការកាន់កាប់ ការដឹកជញ្ជូន និងការរក្សាទុកអាវុធ (D) ចំណេះដឹងអំពីប្រតិបត្តិការ គ្រោះថ្នាក់ដែលអាចកើតមាន និងសមត្ថភាពជាមូលដ្ឋានក្នុងការធ្វើជាម្ចាស់ និងការប្រើប្រាស់អាវុធ (E) ការអប់រំអំពីការបង្ការរបួសស្នាម ការបង្ការការធ្វើអត្តឃាត និងការកាត់បន្ថយគ្រោះថ្នាក់ (F) ច្បាប់ជាធរមាននានាពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំង (G) យុទ្ធសាស្ត្រដកថយ ឬបញ្ចៀសការប្រឈមមុខដាក់គ្នា និង (H) ការហ្វឹកហាត់បាញ់គ្រាប់ពិត។

(iii) ក្រសួងប៉ូលិសរដ្ឋអាចកំណត់កម្រៃសេវាចំនួន 50 ដុល្លារ សម្រាប់ការចេញវិញ្ញាបនបត្រប្រភេទនេះជាលើកដំបូង ដើម្បីទូទាត់លើការចំណាយសម្រាប់ការបញ្ជាក់ទទួលស្គាល់គ្រូបង្វឹក។ កម្រៃសេវាសម្រាប់ការបន្តសុពលភាពវិញ្ញាបនបត្រ ត្រូវមានចំនួន 10 ដុល្លារ។

(c)(i) គ្រូបង្វឹកសុវត្ថិភាពអាវុធទាំងឡាយណាដែលបានបញ្ជាក់ទទួលស្គាល់ក្រោមមាត្រានេះ អាចចេញវិញ្ញាបនបត្រសុវត្ថិភាពអាវុធជាមូលដ្ឋាន តាមឆន្ទានុសិទ្ធិរបស់ខ្លួន ជូនដល់បុគ្គលទាំងឡាយណាដែលបញ្ចប់ជាស្ថាពរនូវលក្ខខណ្ឌនានានៃវគ្គសិក្សាសុវត្ថិភាពអាវុធជាមូលដ្ឋាន ដែលអនុម័តដោយស្នងការប៉ូលីស។ មិនអនុញ្ញាតឱ្យគ្រូបង្វឹកសុវត្ថិភាពអាវុធណាម្នាក់ ចេញ ឬបង្គាប់ឱ្យចេញវិញ្ញាបនបត្រសុវត្ថិភាពអាវុធជាមូលដ្ឋាន ជូនដល់បុគ្គលណាម្នាក់ដែលមិនបានបំពេញតាមលក្ខខណ្ឌអប្បបរមានៃវគ្គសិក្សាដែលបានកំណត់នោះឡើយ រួមមានជាអាទិ៍ ការបង្ហាញសមត្ថភាពក្នុងការប្រើប្រាស់អាវុធតាមរយៈការចូលរួមក្នុងថ្នាក់ ការបញ្ចប់ជាស្ថាពរនូវការប្រឡងសំណេរដែលបានកំណត់ដោយស្នងការ និងការហ្វឹកហាត់បាញ់គ្រាប់ពិត។

(ii) គ្រូបង្ហាត់សុវត្ថិភាពអាវុធដែលទទួលការបញ្ជាក់ទទួលស្គាល់ក្រោមមាត្រានេះ ត្រូវបញ្ជូនច្បាប់ចម្លងវិញ្ញាបនបត្រវគ្គសិក្សាសុវត្ថិភាពអាវុធជាមូលដ្ឋានដែលបានចេញទៅនាយកដ្ឋានសេវាកម្មព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដែលក្នុងនោះត្រូវរួមបញ្ចូលទាំងការបញ្ជាក់អំពីការបញ្ចប់ជាស្ថាពរនូវវគ្គសិក្សាសុវត្ថិភាពអាវុធជាមូលដ្ឋាន និងសមត្ថភាពក្នុងការធ្វើជាម្ចាស់ និងការប្រើប្រាស់អាវុធរបស់បុគ្គលម្នាក់ៗ។ បន្ទាប់ពីទទួលបាន នាយកដ្ឋានសេវាកម្មព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវបញ្ជូនច្បាប់ចម្លងវិញ្ញាបនបត្របែបនេះទៅឱ្យបេក្ខជន។

(iii) អាជ្ញាធរចេញអាជ្ញាបណ្ណ ត្រូវតម្រូវឱ្យមានការផ្តល់ជូននូវច្បាប់ចម្លងវិញ្ញាបនបត្របែបនេះ ក្នុងពេលជាមួយគ្នានឹងការដាក់ពាក្យសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត ហើយអាចធ្វើការសាកសួរទៅកាន់នាយកដ្ឋានសេវាកម្មព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ពីការចេញវិញ្ញាបនបត្រសុវត្ថិភាពអាវុធជាមូលដ្ឋានជូនដល់បេក្ខជន។

(d) បុគ្គលណាក៏ដោយដែលដាក់ពាក្យសុំចេញអាជ្ញាបណ្ណ ឬប័ណ្ណក្រោមមាត្រា 129B, 131 ឬ 131F ដែលមានចេតនាដាក់ ឬប្រគល់វិញ្ញាបនបត្រសុវត្ថិភាពអាវុធមូលដ្ឋានដែលមានព័ត៌មានមិនពិតទៅឱ្យអាជ្ញាធរចេញអាជ្ញាបណ្ណ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនតិចជាង 1,000 ដុល្លារ មិនលើសពី 5,000 ដុល្លារ ឬដាក់ពន្ធនាគារមិនលើសពី 2 ឆ្នាំនៅក្នុងមណ្ឌលកែប្រែ ឬទាំងទោសពិន័យជាប្រាក់ ទាំងទោសដាក់ពន្ធនាគារ។

(e) គ្រូបង្វឹកសុវត្ថិភាពអាវុធណាដែលមានចេតនាចេញវិញ្ញាបនបត្រសុវត្ថិភាពអាវុធជាមូលដ្ឋានដល់បុគ្គលម្នាក់ដែលមិនបានបញ្ចប់ជាស្ថាពរនូវវគ្គសិក្សាសុវត្ថិភាពអាវុធអនុម័តដោយស្នងការប៉ូលិស ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនតិចជាង 5,000 ដុល្លារ ឬមិនលើសពី 10,000 ដុល្លារ ឬដាក់ពន្ធនាគារមិនលើសពី 2 ឆ្នាំនៅក្នុងមណ្ឌលកែប្រែ ឬទាំងទោសពិន័យជាប្រាក់ ទាំងទោសដាក់ពន្ធនាគារ។

(f) ស្នងការប៉ូលិសរដ្ឋត្រូវផលិត និងផ្សព្វផ្សាយសេចក្តីប្រកាសព័ត៌មានបម្រើសេវាសាធារណៈ ដើម្បីលើកទឹកចិត្ត និងអប់រំដល់សាធារណជនទូទៅអំពី៖ (i) ការរក្សាទុក និងការដឹកជញ្ជូនអាវុធដោយសុវត្ថិភាព ដូចបានចែងនៅក្នុងមាត្រា 131C និង 131L និង (ii) សារៈសំខាន់នៃការអប់រំ និងការហ្វឹកហាត់សុវត្ថិភាពអាវុធ រួមទាំងព័ត៌មានអំពីទីកន្លែង និងថ្នាក់បណ្តុះបណ្តាលដែលបុគ្គលម្នាក់អាចចូលរួមបាន ដើម្បីទទួលបានការអប់រំ និងការហ្វឹកហាត់សុវត្ថិភាពអាវុធ។

(g) ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ដោយសហការជាមួយនាយកដ្ឋានសុខាភិបាលសាធារណៈ ត្រូវរៀបចំឯកសារអប់រំស្តីពីការកាត់បន្ថយគ្រោះថ្នាក់ដែលគ្រូបង្វឹកត្រូវយកមកពិភាក្សា និងចែកជូនដល់សិក្ខាកាមគ្រប់រូបនៅក្នុងវគ្គសិក្សាសុវត្ថិភាពអាវុធ ស្របតាមមាត្រានេះ។ ឯកសារអប់រំទាំងនោះត្រូវលើកកម្ពស់ការបង្ការការធ្វើអត្តឃាត តាមរយៈការអនុវត្តប្រកបដោយសុវត្ថិភាពដោយម្ចាស់អាវុធ ដើម្បីកាត់បន្ថយលទ្ធភាពទទួលបាន មធ្យោបាយបង្កគ្រោះថ្នាក់ដល់អាយុជីវិត។ ឯកសារទាំងនោះត្រូវរួមបញ្ចូលជាអាទិ៍នូវព័ត៌មានពាក់ព័ន្ធនឹង៖ (i) អត្រាកំណើននៃការធ្វើអត្តឃាតដោយប្រើប្រាស់អាវុធ ធៀបទៅនឹងទម្រង់នៃអំពើហិង្សាដោយអាវុធផ្សេងទៀត រួមទាំងទំនោរប្រជាសាស្ត្រ (ii) ហានិភ័យនៃរបួសស្នាម និងការធ្វើអត្តឃាតដែលអាចទាក់ទងនឹងអាវុធនៅក្នុងគ្រួសារ រួមទាំងអត្រារស់រានមានជីវិតពីការប៉ុនប៉ងអត្តឃាតដោយអាវុធ ធៀបទៅនឹងមធ្យោបាយប៉ុនប៉ងអត្តឃាតផ្សេងទៀត (iii) វិធីសាស្ត្រល្អបំផុតសម្រាប់ការកំណត់អត្តសញ្ញាណ និងការកាត់បន្ថយហានិភ័យនៃការធ្វើអត្តឃាតពាក់ព័ន្ធនឹងអាវុធនៅក្នុងគ្រួសារ (iv) ប្រភពធនធានដែលមានស្រាប់ដើម្បីស្វែងយល់បន្ថែមអំពីការអនុវត្តដោយសុវត្ថិភាព

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

និងការបង្ការការធ្វើអត្តឃាត និង (v) ព័ត៌មានបន្ថែមផ្សេងទៀតកំណត់ដោយប្រធានសន្តិសុខនិងសុវត្ថិភាពសាធារណៈ ពាក់ព័ន្ធនឹងមាត្រានេះ។

មាត្រា 75 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 131Q ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 131Q (a) អាវុធប្រើប្រាស់ក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋ រួមទាំងការធ្វើអត្តឃាត ត្រូវស្វែងរកប្រភពដើមដោយអាជ្ញាធរចេញអាជ្ញាបណ្ណប្រចាំទីក្រុង ឬស្រុកដែលបទល្មើសនោះបានកើតឡើង ឬដោយទីភ្នាក់ងារអនុវត្តច្បាប់ដែលដកហូតការកាន់កាប់អាវុធនោះ។ អាជ្ញាធរ ឬទីភ្នាក់ងារខាងលើ ត្រូវរាយការណ៍រាល់ទិន្នន័យស្ថិតិដែលមានទាំងអស់ទៅនាយកដ្ឋានសេវាកម្មព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ។ ទិន្នន័យស្ថិតិត្រូវរាប់បញ្ចូលជាអាទិ៍៖ (i) ម៉ាក ម៉ូដែល លេខស៊េរី និងទំហំមុខកាត់របស់អាវុធដែលបានប្រើប្រាស់ (ii) ប្រភេទបទល្មើសដែលបានប្រព្រឹត្ត (iii) អំពីការចាប់ខ្លួន ឬការផ្តន្ទាទោស (iv) អំពីការរកឃើញភស្តុតាងស្នាមម្រាមដៃនៅលើអាវុធនោះ (v) អំពីការប្រមូលបានភស្តុតាងបាលីស្ទីកពាក់ព័ន្ធនឹងអាវុធពីកន្លែងកើតហេតុ (vi) អំពីថាការប្រើប្រាស់អាវុធខុសច្បាប់នោះ មានការពាក់ព័ន្ធនឹងសកម្មភាពក្រុមបងធំ (vii) អំពីថាអាវុធនោះទទួលបានមកដោយខុសច្បាប់ (viii) អំពីថាអាវុធនោះត្រូវបានបាត់បង់ ឬត្រូវបានគេលួច និង (ix) អំពីថាបុគ្គលដែលប្រើប្រាស់អាវុធនោះ ជាបុគ្គលដែលត្រូវបានហាមឃាត់មិនឱ្យប្រើប្រាស់អាវុធ។

(b) នាយកដ្ឋានសេវាកម្មព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវប្រាកដថា ទិន្នន័យដែលបានរាយការណ៍ស្របតាមមាត្រានេះ នឹងត្រូវបញ្ជូនដោយស្វ័យប្រវត្តិទៅក្នុងប្រព័ន្ធអេឡិចត្រូនិកសហព័ន្ធ ដែលគ្រប់គ្រងដោយការិយាល័យគ្រប់គ្រងគ្រឿងស្រវឹង បារី អាវុធ និងគ្រឿងផ្ទុះ (Bureau of Alcohol, Tobacco, Firearms and Explosives) នៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក និងបញ្ជូនទៅមជ្ឈមណ្ឌលព័ត៌មានរដ្ឋម៉ាសាឈូសិត ឬអង្គភាពប្រឆាំងការជួញដូរនិងបទល្មើសអាវុធនៅក្នុងការិយាល័យស៊ើបអង្កេត និងកិច្ចការសម្ងាត់ នៃក្រសួងប៉ូលីសរដ្ឋ ដែលត្រូវបានបង្កើតឡើងស្របតាមមាត្រា 6 នៃជំពូក 22C។ ស្នងការប៉ូលីសរដ្ឋ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំឱ្យបានមុនថ្ងៃទី 31 ខែធ្នូ នៃឆ្នាំនីមួយៗ ទាក់ទងនឹងបទល្មើសនានាដែលបានប្រព្រឹត្តនៅក្នុងរដ្ឋម៉ាសាឈូសិតដោយប្រើអាវុធ រួមទាំងប្រភេទទិន្នន័យទាំងអស់ដែលមាននៅក្នុងមាត្រានេះ ហើយត្រូវដាក់ជូនច្បាប់ចម្លងនៃរបាយការណ៍នេះទៅគណៈកម្មាធិការចម្រុះទទួលបន្ទុកសន្តិសុខសាធារណៈ និងសន្តិសុខមាតុភូមិ ប្រធានរដ្ឋសភានិងព្រឹទ្ធសភា ព្រមទាំងផ្តល់ជូនដល់អ្នកស្រាវជ្រាវផ្នែកឧក្រិដ្ឋវិទ្យា គោលនយោបាយសាធារណៈ សុខភាពសាធារណៈ និងទីភ្នាក់ងារអនុវត្តច្បាប់ផ្សេងទៀត នៅពេលមានការស្នើសុំ។

(c) សំបកគ្រាប់ពាក់ព័ន្ធនឹងអាវុធដែលបានរាយការណ៍សម្រាប់ការស្វែងរកប្រភពដើមក្រោមកថាខណ្ឌ (a) ត្រូវតែដាក់បញ្ចូលទៅក្នុងបណ្តាញព័ត៌មានទាក់ទងនឹងអាវុធបាលីស្ទីករួមថ្នាក់ជាតិ (National Integrated Ballistics Information Network) ដែលគ្រប់គ្រងដោយការិយាល័យគ្រប់គ្រងគ្រឿងស្រវឹង បារី អាវុធ និងគ្រឿងផ្ទុះនៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។

មាត្រា 76 មាត្រា 131R នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយការលុបចោលពាក្យ "ដែលមានអាជ្ញាបណ្ណកាន់អាវុធ ឬប័ណ្ណសម្គាល់អាវុធ" នៅក្នុងបន្ទាត់ទី 1 និងទី 2។

មាត្រា 77 មាត្រា 131R នៃជំពូក 140 ដូចដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត គ្រឿងសព្វាវុធ" នៅក្នុងបន្ទាត់ទី 11 គ្រប់ពេលដែលពាក្យទាំងនេះលេចឡើង។

មាត្រា 77A មាត្រា 131R នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត គ្រឿងសព្វាវុធ" នៅក្នុងបន្ទាត់ទី 12 និង 13។

មាត្រា 78 មាត្រា 131R នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "បញ្ញត្តិនៃ" នៅក្នុងបន្ទាត់ទី 40។

មាត្រា 79 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលមាត្រា 131S ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 131S (a) តុលាការត្រូវតែបើកសវនាការលើបណ្តឹងតវ៉ាក្នុងរយៈពេល 10 ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ាស្របតាមមាត្រា 131R។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងតវ៉ា តុលាការត្រូវចេញដីកាកោះហៅ ដោយបញ្ជាក់ពីកាលបរិច្ឆេទពេលវេលា និងទីតាំងនៃសវនាការ។ តុលាការត្រូវបង្គាប់ឱ្យមន្ត្រីអនុវត្តច្បាប់បញ្ជូនច្បាប់ចម្លងនៃពាក្យបណ្តឹងតវ៉ា និងដីកាកោះទៅប្រគល់ជូនចុងចម្លើយដោយផ្ទាល់ ឬប្រសិនបើមន្ត្រីអនុវត្តច្បាប់មិនអាចប្រគល់ជូនផ្ទាល់ដៃបានទេ តុលាការអាចបង្គាប់ឱ្យធ្វើការប្រគល់តាមមធ្យោបាយកំណត់ផ្សេងទៀត ដែលគិតថាសមហេតុផលនឹងអាចទៅដល់ដៃចុងចម្លើយ បន្ទាប់ពីសវនាការ។ ការប្រគល់ដីកាត្រូវធ្វើឡើងមិនតិចជាង 7 ថ្ងៃ មុនថ្ងៃសវនាការនោះឡើយ។

(b) ទោះបីជាមានចែងក្នុងកថាខណ្ឌ (a) ក៏ដោយ តុលាការត្រូវតែបើកសវនាការលើពាក្យបណ្តឹងតវ៉ាក្នុងរយៈពេល 2 ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ាដែលធ្វើឡើងស្របតាមមាត្រា 131R ប្រសិនបើចុងចម្លើយបានដាក់លិខិតអះអាងថា អាវុធឬគ្រាប់រំសេវគឺជារបស់ចាំបាច់សម្រាប់បំពេញការងាររបស់ចុងចម្លើយ។

(c)(1) បន្ទាប់ពីសវនាការស្របតាមកថាខណ្ឌ (a) ឬកថាខណ្ឌ (b) ប្រសិនបើតុលាការរកឃើញដោយផ្អែកលើទម្ងន់នៃភស្តុតាងថា ចុងចម្លើយបង្កហានិភ័យក្នុងការបង្ករបួសស្នាមដល់រាងកាយខ្លួនឯង ឬដល់អ្នកដទៃ ដោយសារការមានអាវុធ ឬគ្រាប់រំសេវស្ថិតក្រោមការគ្រប់គ្រង កម្មសិទ្ធិ ឬការកាន់កាប់របស់ចុងចម្លើយ តុលាការត្រូវសម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ានោះ។ ប្រសិនបើចុងចម្លើយមិនចូលខ្លួនក្នុងសវនាការស្របតាមកថាខណ្ឌ (a) ឬកថាខណ្ឌ (b) ទេ តុលាការត្រូវសម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា នៅពេលមានការកំណត់ថា ដើមបណ្តឹងបានបង្ហាញតាមរយៈទម្ងន់នៃភស្តុតាងនោះថា ចុងចម្លើយពិតជាបង្កជាហានិភ័យបែបនោះមែន។

(2) នៅពេលសម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា តុលាការត្រូវចេញដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ ហើយត្រូវបង្គាប់ឱ្យចុងចម្លើយប្រគល់រាល់អាជ្ញាបណ្ណកាន់កាប់អាវុធ បណ្ណសម្គាល់អាវុធ ព្រមទាំងអាវុធនិងគ្រាប់រំសេវទាំងអស់ដែលចុងចម្លើយកំពុងគ្រប់គ្រង ធ្វើជាម្ចាស់ ឬកាន់កាប់នាពេលនោះ ទៅឱ្យអាជ្ញាធរចេញអាជ្ញាបណ្ណក្រុងដែលចុងចម្លើយរស់នៅ។ តុលាការត្រូវកត់ត្រាការរកឃើញជាលាយលក្ខណ៍អក្សរអំពីមូលដ្ឋាននៃដីការបស់ខ្លួន ក្នុងរយៈពេល 24 ម៉ោង បន្ទាប់ពីបានចេញដីកានោះ។ តុលាការអាចកែប្រែ ផ្អាក ឬបញ្ចប់ដីការបស់ខ្លួននៅពេលក្រោយណាមួយបាន ដោយផ្អែកលើបណ្តឹងតវ៉ាពីភាគីណាមួយ ប៉ុន្តែត្រូវផ្តល់ដំណឹង

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ត្រឹមត្រូវជាមុនទៅចុងចម្លើយនិងដើមបណ្តឹង ហើយតុលាការត្រូវបើកសវនាការលើបណ្តឹងតវ៉ានោះ។ ក្នុងករណីដែលអាសយដ្ឋានរបស់ដើមបណ្តឹងត្រូវបានរក្សាជាការសម្ងាត់មិនឱ្យចុងចម្លើយដឹង ដូចមានចែងក្នុងកថាខណ្ឌ (d) នៃមាត្រា 131R ហើយចុងចម្លើយបានដាក់ពាក្យសុំកែប្រែដីការបស់តុលាការ នោះតុលាការត្រូវទទួលខុសត្រូវក្នុងការជូនដំណឹងទៅដើមបណ្តឹង។ ទោះក្នុងកាលៈទេសៈណាក៏ដោយ តុលាការមិនត្រូវទម្លាយអាសយដ្ឋានសម្ងាត់បែបនេះឡើយ។

(3) មិនតិចជាង 30 ថ្ងៃប្រតិទិន មុនពេលដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរអស់សុពលភាព តុលាការត្រូវជូនដំណឹងទៅដើមបណ្តឹងតាមអាសយដ្ឋានដែលដឹងច្បាស់បំផុត អំពីកាលបរិច្ឆេទកំណត់អស់សុពលភាពនៃដីកានោះ និងប្រាប់ថាដើមបណ្តឹងអាចដាក់ពាក្យបណ្តឹងតវ៉ាដើម្បីបន្តសុពលភាពដីកានោះបាន ស្របតាមមាត្រា 131R។

(d)(1) បន្ទាប់ពីសវនាការស្របតាមកថាខណ្ឌ (a) ឬកថាខណ្ឌ (b) ប្រសិនបើតុលាការមានហេតុផលសមស្របនឹងជឿថា ចុងចម្លើយអាចចូលប្រើប្រាស់អាវុធ ឬគ្រាប់រំសេវជាប់នឹងខ្លួន ឬនៅក្នុងទីតាំងជាក់លាក់ណាមួយ ហើយចុងចម្លើយមិនបានប្រគល់អាវុធ ឬគ្រាប់រំសេវណាមួយក្នុងរយៈពេល 24 ម៉ោងបន្ទាប់ពីទទួលបានដីកាបង្គាប់ស្របតាមកថាខណ្ឌ (e) ទេនោះ តុលាការត្រូវតែចេញដីកាស្វែងរកកំណត់អត្តសញ្ញាណទ្រព្យសម្បត្តិ ព្រមទាំងបញ្ជាក់ឈ្មោះ ឬបរិយាយអំពីបុគ្គល ឬទីកន្លែងដែលត្រូវឆែកឆេរ និងបង្គាប់ឱ្យទីភ្នាក់ងារអនុវត្តច្បាប់មានសមត្ថកិច្ចធ្វើការឆែកឆេរលើខ្លួនប្រាណរបស់ចុងចម្លើយ និងទីកន្លែងជាក់លាក់ណាមួយនោះ ហើយដកហូតរាល់អាវុធ ឬគ្រាប់រំសេវរកឃើញទាំងឡាយ ដែលចុងចម្លើយអាចចូលប្រើប្រាស់បាន។

(2) តុលាការអាចចេញដីកាបន្ថែមទៀតដើម្បីរឹបអូសអាវុធ ឬគ្រាប់រំសេវ ប្រសិនបើតុលាការកំណត់ឃើញថាមានហេតុផលសមស្របនឹងជឿថា ចុងចម្លើយបានរក្សាទុកទទួលបាន ឬអាចចូលប្រើប្រាស់អាវុធឬគ្រាប់រំសេវ ក្នុងអំឡុងពេលដែលដីកាបង្គាប់ក្រោមផ្នែកនេះនៅមានសុពលភាពនៅឡើយ។

(3) នៅពេលអនុវត្តដីកាដែលបានចេញស្របតាមកថាខណ្ឌនេះ ឬមាត្រា 131T ទីភ្នាក់ងារអនុវត្តច្បាប់ដែលធ្វើការឆែកឆេរ ត្រូវចេញបង្កាន់ដៃបញ្ជាក់អត្តសញ្ញាណអាវុធ ឬគ្រាប់រំសេវណាមួយដែលត្រូវបានដកហូត។ ទីភ្នាក់ងារអនុវត្តច្បាប់ត្រូវផ្តល់ច្បាប់ចម្លងនៃបង្កាន់ដៃនោះជូនដល់ចុងចម្លើយ។ បន្ទាប់មក អាជ្ញាធរចេញអាជ្ញាបណ្ណត្រូវប្រគល់ដីកានោះត្រឡប់ទៅតុលាការវិញ ព្រមជាមួយនឹងបង្កាន់ដៃដើមក្នុងរយៈពេល 48 ម៉ោង បន្ទាប់ពីការឆែកឆេរ។ ប្រសិនបើទីភ្នាក់ងារអនុវត្តច្បាប់ដែលអនុវត្តដីកា និងអាជ្ញាធរចេញអាជ្ញាបណ្ណប្រចាំក្រុងដែលចុងចម្លើយរស់នៅគឺជាស្ថាប័នផ្សេងគ្នា នោះទីភ្នាក់ងារអនុវត្តច្បាប់ត្រូវបញ្ជូនច្បាប់ចម្លងនៃបង្កាន់ដៃព្រមជាមួយវត្ថុដែលបានដកហូតទាំងអស់ទៅឱ្យអាជ្ញាធរចេញអាជ្ញាបណ្ណ ហើយត្រូវតម្កល់លិខិតបញ្ជាក់មួយច្បាប់ភ្ជាប់ជាមួយដីកានិងបង្កាន់ដៃរបស់ខ្លួនដោយមានទាំងហត្ថលេខាទីភ្នាក់ងារអនុវត្តច្បាប់ និងអាជ្ញាធរចេញអាជ្ញាបណ្ណ ដើម្បីបញ្ជាក់ថាវត្ថុដែលបានដកហូតទាំងនោះត្រូវបានប្រគល់ជូន និងទទួលយកដោយអាជ្ញាធរចេញអាជ្ញាបណ្ណរួចរាល់ហើយ។ អាជ្ញាធរចេញអាជ្ញាបណ្ណត្រូវរក្សាទុកវត្ថុដែលបានដកហូតទាំងនោះ រួមជាមួយវត្ថុទាំងឡាយណាដែលត្រូវបានប្រគល់ជូនស្របតាមកថាខណ្ឌ (f)។

(e) នៅពេលចេញដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ ក្រឡាបញ្ជីតុលាការត្រូវបញ្ជូនច្បាប់ចម្លងដីកានោះដែលមានការបញ្ជាក់ត្រឹមត្រូវចំនួន 2 ច្បាប់ និងច្បាប់ចម្លងពាក្យបណ្តឹងតវ៉ា និងដីកាកោះហៅចំនួន 1 ច្បាប់ ទៅកាន់អាជ្ញាធរចេញអាជ្ញាបណ្ណរបស់ក្រុងដែលចុងចម្លើយរស់នៅ (លើកលែងតែមានការបង្គាប់ផ្សេងពីនេះដោយតុលាការ) ដែលអាជ្ញាធរនោះត្រូវប្រគល់ច្បាប់ចម្លងដីកានិងពាក្យបណ្តឹងតវ៉ានោះដល់ចុងចម្លើយ។ ប្រសិនបើដីកាត្រូវបានចេញស្របតាមកថាខណ្ឌ (d) ឬស្របតាមកថាខណ្ឌ (b) នៃមាត្រា 131T តុលាការត្រូវបញ្ជូនច្បាប់ចម្លងដីកាបង្គាប់ដែលមានការបញ្ជាក់ត្រឹមត្រូវនោះចំនួន 2 ច្បាប់ ច្បាប់ចម្លងពាក្យបណ្តឹងតវ៉ា និងដីកាកោះហៅចំនួន 1 ច្បាប់ ព្រមទាំងច្បាប់ចម្លងដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរចំនួន 1 ច្បាប់ ទៅទីភ្នាក់ងារអនុវត្តច្បាប់សមស្របដើម្បីអនុវត្ត។ អាជ្ញាធរចេញអាជ្ញាបណ្ណ និងទីភ្នាក់ងារអនុវត្តច្បាប់ ត្រូវបង្កើតនីតិវិធីសមស្របនានាដើម្បីធានាថា នៅពេលធ្វើការប្រគល់ដីកាដល់ចុងចម្លើយ ឬនៅពេលអនុវត្តដីកា មន្ត្រីអនុវត្តច្បាប់ត្រូវធ្វើសកម្មភាពតាមដែលអាចធ្វើទៅបានដើម្បី៖ (i) ជូនដំណឹងឱ្យបានពេញលេញដល់ចុងចម្លើយអំពីខ្លឹមសារ និងលក្ខខណ្ឌនានារបស់ដីកា ឬដីកាបង្គាប់ ព្រមទាំងទណ្ឌកម្មនានាដែលអាចកើតមានចំពោះការបំពានណាមួយលើដីកា និង (ii) ផ្តល់ជូនចុងចម្លើយនូវប្រភពព័ត៌មានជំនួយ រួមមានជាអាទិ៍ បញ្ជីសេវាកម្មពាក់ព័ន្ធនឹងការអន្តរាគមន៍ក្នុងគ្រាអាសន្ន សុខភាពផ្លូវចិត្ត វិបត្តិបណ្តាលមកពីការប្រើប្រាស់សារធាតុញៀន និងការផ្តល់ប្រឹក្សា ព្រមទាំងបញ្ជីឈ្មោះអ្នកបកប្រែភាសាតាមការចាំបាច់ ដែលស្ថិតនៅក្នុង ឬក្បែរដែនសមត្ថកិច្ចរបស់តុលាការ។ ដោយមានការពិគ្រោះយោបល់ជាមួយការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ និងនាយកដ្ឋានសុខភាពផ្លូវចិត្ត ប្រធានចៅក្រមតុលាការជំនុំជម្រះត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំនូវសៀវភៅណែនាំស្តីពីប្រភពព័ត៌មានជំនួយ ដែលតម្រូវឱ្យមានក្រោមមាត្រានេះ។

រាល់ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរចេញដោយតុលាការ ត្រូវតែមានសេចក្តីប្រកាសដូចខាងក្រោម៖ ការបំពានលើដីកានេះគឺជាបទល្មើសព្រហ្មទណ្ឌ។

(f) នៅពេលទទួលបានការប្រគល់ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ អាជ្ញាធរចេញអាជ្ញាបណ្ណរបស់ក្រុងដែលចុងចម្លើយរស់នៅ ត្រូវផ្អាកជាបន្ទាន់នូវអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធរបស់ចុងចម្លើយ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ចុងចម្លើយអំពីការផ្អាកនេះ ហើយមិនត្រូវចេញអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធណាមួយដល់ចុងចម្លើយក្នុងអំឡុងពេលដែលដីកានេះមានសុពលភាពឡើយ។

នៅពេលទទួលបានការប្រគល់ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ ចុងចម្លើយត្រូវប្រគល់ជាបន្ទាន់នូវអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធរបស់ខ្លួន ព្រមទាំងអាវុធ ឬគ្រាប់រំសេវទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រង កម្មសិទ្ធិ ឬការកាន់កាប់របស់ខ្លួន ជូនទៅអាជ្ញាធរចេញអាជ្ញាបណ្ណក្នុងតំបន់ដែលជាអ្នកប្រគល់ដីកានោះ ស្របតាមមាត្រា 129D។ ទោះយ៉ាងណាក៏ដោយ គ្មានខ្លឹមសារណាមួយនៅក្នុងមាត្រានេះ ឬនៅក្នុងមាត្រា 129D អនុញ្ញាតឱ្យចុងចម្លើយធ្វើសកម្មភាពដូចខាងក្រោមឡើយ៖ (i) ផ្ទេរអាវុធ ឬគ្រាប់រំសេវណាមួយដែលតម្រូវឱ្យចុងចម្លើយត្រូវប្រគល់ ឬដែលចុងចម្លើយបានប្រគល់រួចហើយ ទៅឱ្យបុគ្គលណាម្នាក់ក្រៅពីអាជីវករមានអាជ្ញាបណ្ណត្រឹមត្រូវ ឬអាជ្ញាធរចេញអាជ្ញាបណ្ណក្នុងតំបន់។ ឬ (ii) រក្សាការគ្រប់គ្រង កម្មសិទ្ធិ ឬការកាន់កាប់អាវុធ ឬគ្រាប់រំសេវណាមួយក្នុងអំឡុងពេលនៃការប្តឹងឧទ្ធរណ៍មិនទាន់ដោះស្រាយដាច់ស្រេចប្រឆាំងនឹងដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ។ យ៉ាងណាក៏ដោយ ទោះបីជាមានការលះបង់សិទ្ធិកាន់កាប់ស្របតាម

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរដែលតម្រូវឱ្យមានការប្រគល់ជាបន្ទាន់នូវអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ និងអាវុធ ឬគ្រាប់រំសេវទាំងអស់ដែលស្ថិតក្រោមការគ្រប់គ្រង ឬការកាន់កាប់របស់ចុងចម្លើយក៏ដោយ ក៏ការណ៍នេះមិនតម្រូវឱ្យមានការលះបង់សិទ្ធិជាកម្មសិទ្ធិជាអចិន្ត្រៃយ៍ឡើយ។ ជាងនេះទៅទៀត ដោយមិនគិតពីមាត្រា 129D ប្រសិនបើអាជ្ញាធរចេញអាជ្ញាបណ្ណមិនអាចកំណត់រកម្ចាស់អាវុធ ឬគ្រាប់រំសេវស្របច្បាប់ដែលត្រូវបានប្រគល់ស្របតាមដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរបានដោយសមហេតុផល ក្នុងរយៈពេល 180 ថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់ ឬថ្ងៃបញ្ចប់ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរនោះទេ អាជ្ញាធរចេញអាជ្ញាបណ្ណអាចធ្វើការដោះដូរ ឬចាត់ចែងអាវុធ ឬគ្រាប់រំសេវដែលលើស ដែតម្រូវឱ្យបរិច្ចាគ ដែលត្រូវបានបោះបង់ចោល ឬដែលខូចខាតមិនអាចប្រើប្រាស់បាន ទៅឱ្យអ្នកចែកចាយ ឬអាជីវករលក់អាវុធដែលមានអាជ្ញាបណ្ណត្រឹមត្រូវ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ហើយថវិកាបានមកពីការលក់ឬផ្ទេរនោះ ត្រូវប្រគល់ជូន ឬបញ្ចូលទៅក្នុងកញ្ចប់ថវិការបស់ក្រុងដែលអាជ្ញាធរចេញអាជ្ញាបណ្ណនោះគ្រប់គ្រង ដើម្បីប្រើប្រាស់សម្រាប់សកម្មភាពកាត់បន្ថយអំពើហិង្សា ឬការបង្ការការធ្វើអត្តឃាត។ ការល្មើសនឹងកថាខណ្ឌនេះ ត្រូវផ្តន្ទាទោសដោយការពិន័យជាប្រាក់មិនលើសពីចំនួន 5,000 ដុល្លារ ឬដាក់ពន្ធនាគារមិនលើសពីរយៈពេល 2½ ឆ្នាំ ឬទាំងពិន័យជាប្រាក់ ទាំងដាក់ពន្ធនាគារបែបនេះ។

(g) នៅពេលទទួលបានអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ ព្រមទាំងអាវុធ ឬគ្រាប់រំសេវណាមួយដែលបានប្រគល់ដោយចុងចម្លើយស្របតាមកថាខណ្ឌ (f) ឬដែលត្រូវបានដកហូតស្របតាមកថាខណ្ឌ (d) អាជ្ញាធរចេញអាជ្ញាបណ្ណដែលទទួលយកការកាន់កាប់អាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ និងអាវុធ ឬគ្រាប់រំសេវនោះ ត្រូវចេញបង្កាន់ដៃមួយដោយបញ្ជាក់អត្តសញ្ញាណអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ និងអាវុធ ឬគ្រាប់រំសេវទាំងអស់ដែលត្រូវបានប្រគល់ ឬត្រូវបានដកហូតនោះ ហើយត្រូវផ្តល់ច្បាប់ចម្លងបង្កាន់ដៃនោះដល់ចុងចម្លើយ។ អាជ្ញាធរចេញអាជ្ញាបណ្ណ ត្រូវដាក់ជូនបង្កាន់ដៃនោះទៅតុលាការក្នុងរយៈពេល 48 ម៉ោង គិតចាប់ពីពេលប្រគល់ ឬ 48 ម៉ោង គិតចាប់ពីទទួលបានវត្ថុដកហូតនោះ។

(h) ប្រសិនបើបុគ្គលណាម្នាក់ក្រៅពីចុងចម្លើយ ទាមទារសិទ្ធិជាម្ចាស់លើអាវុធ ឬគ្រាប់រំសេវណាមួយដែលត្រូវបានតម្រូវឱ្យប្រគល់ ឬដកហូតស្របតាមមាត្រានេះ ហើយត្រូវបានកំណត់ដោយអាជ្ញាធរចេញអាជ្ញាបណ្ណថាជាម្ចាស់ស្របច្បាប់របស់អាវុធ ឬគ្រាប់រំសេវនោះ អាវុធឬគ្រាប់រំសេវនោះត្រូវប្រគល់ជូនបុគ្គលនោះវិញ ប្រសិនបើ៖ (i) អាវុធឬគ្រាប់រំសេវនោះ ត្រូវតែដកចេញពីការគ្រប់គ្រង កម្មសិទ្ធិ ឬការកាន់កាប់របស់ចុងចម្លើយ ហើយម្ចាស់ស្របច្បាប់យល់ព្រមរក្សាទុកអាវុធ ឬគ្រាប់រំសេវនោះក្នុងលក្ខណៈមួយដែលចុងចម្លើយមិនអាចចូលប្រើប្រាស់ ឬគ្រប់គ្រងអាវុធឬគ្រាប់រំសេវនោះបាន។ និង (ii) អាវុធឬគ្រាប់រំសេវនោះ មិនត្រូវកាន់កាប់ដោយខុសច្បាប់ដោយម្ចាស់នោះក្នុងករណីផ្សេងទៀតឡើយ។ ការល្មើសនឹងកថាខណ្ឌនេះ ត្រូវផ្តន្ទាទោសដោយការពិន័យជាប្រាក់មិនលើសពីចំនួន 5,000 ដុល្លារ ឬដាក់ពន្ធនាគារមិនលើសពីរយៈពេល 2½ ឆ្នាំ ឬទាំងទោសពិន័យជាប្រាក់ ទាំងដាក់ពន្ធនាគារ។

(i) នៅពេលផុតកំណត់ ឬការបញ្ចប់នៃដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ អាជ្ញាធរចេញអាជ្ញាបណ្ណដែលរក្សាទុកអាវុធ ឬគ្រាប់រំសេវណាមួយដែលត្រូវបានប្រគល់ ឬត្រូវបានដកហូតស្របតាមមាត្រានេះ ត្រូវប្រគល់ជូនវិញនូវអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ ព្រមទាំងអាវុធ ឬគ្រាប់រំសេវទាំងអស់ដែលចុងចម្លើយបានស្នើសុំ លុះត្រាតែអាជ្ញាធរចេញអាជ្ញាបណ្ណរបស់ក្រុងដែលចុងចម្លើយរស់នៅ បញ្ជាក់ថាលក្ខខណ្ឌរបស់ចុងចម្លើយគឺសមស្របនឹងទទួលបានអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ និងក្នុងការគ្រប់គ្រង ធ្វើជាម្ចាស់ ឬកាន់កាប់អាវុធ ឬគ្រាប់រំសេវក្រោមច្បាប់សហព័ន្ធ និងច្បាប់រដ្ឋ។

យ៉ាងហោចណាស់ 7 ថ្ងៃ មុនពេលផុតកំណត់ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ អាជ្ញាធរចេញអាជ្ញាបណ្ណដែលរក្សាទុកអាវុធឬគ្រាប់រំសេវណាមួយដែលត្រូវបានប្រគល់ ឬត្រូវបានដកហូតស្របតាមប្រការនេះ ត្រូវជូនដំណឹងដល់ដើមបណ្តឹងអំពីការផុតកំណត់នៃដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ និងការប្រគល់ជូនវិញនូវអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ ព្រមទាំងការប្រគល់អាវុធ ឬគ្រាប់រំសេវណាមួយជូនទៅចុងចម្លើយវិញ។

ក្នុងរយៈពេលឆាប់បំផុតតាមដែលអាចធ្វើទៅបានដោយសមហេតុផល បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងពីតុលាការអំពីការបញ្ចប់ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ អាជ្ញាធរចេញអាជ្ញាបណ្ណដែលរក្សាទុកអាវុធ ឬគ្រាប់រំសេវណាមួយដែលត្រូវបានប្រគល់ ឬត្រូវបានដកហូតស្របតាមមាត្រានេះ ត្រូវជូនដំណឹងដល់ដើមបណ្តឹងអំពីការបញ្ចប់ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ និងការប្រគល់ជូនវិញនូវអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ ព្រមទាំងការប្រគល់អាវុធ ឬគ្រាប់រំសេវណាមួយជូនទៅចុងចម្លើយវិញ។

(j) ចុងចម្លើយដែលបានប្រគល់អាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ ព្រមទាំងអាវុធឬគ្រាប់រំសេវទាំងអស់ជូនទៅអាជ្ញាធរចេញអាជ្ញាបណ្ណ ឬបុគ្គលដែលត្រូវបានទីភ្នាក់ងារអនុវត្តច្បាប់ដកហូតអាវុធ ឬគ្រាប់រំសេវណាមួយ ហើយដែលមិនចង់ទទួលយកអាជ្ញាបណ្ណកាន់កាប់អាវុធ បណ្ណសម្គាល់អាវុធ ឬអាវុធ ឬគ្រាប់រំសេវនោះត្រឡប់មកវិញ ឬបុគ្គលដែលលែងមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ធ្វើជាម្ចាស់ ឬកាន់កាប់អាវុធ ឬគ្រាប់រំសេវស្របតាមជំពូកនេះ ឬច្បាប់សហព័ន្ធ អាចលក់ ឬផ្ទេរសិទ្ធិជាម្ចាស់នៃអាវុធ ឬគ្រាប់រំសេវនោះទៅឱ្យអាជីវករលក់អាវុធមានអាជ្ញាបណ្ណត្រឹមត្រូវ ដោយមិនគិតពីដែនកំណត់លើការផ្ទេរអាវុធឯកជននៅក្នុងមាត្រា 127B ឡើយ ប៉ុន្តែ ចុងចម្លើយមិនត្រូវកាន់កាប់អាវុធ ឬគ្រាប់រំសេវនោះដោយផ្ទាល់ដៃឡើយ។ អាជ្ញាធរចេញអាជ្ញាបណ្ណ អាចផ្ទេរការកាន់កាប់អាវុធ ឬគ្រាប់រំសេវនោះទៅឱ្យអាជីវករមានអាជ្ញាបណ្ណ បន្ទាប់ពីអាជីវករនោះបានផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរជូនដល់អាជ្ញាធរចេញអាជ្ញាបណ្ណ អំពីការលក់ឬផ្ទេរសិទ្ធិជាម្ចាស់នៃអាវុធ ឬគ្រាប់រំសេវនោះពីចុងចម្លើយទៅឱ្យអាជីវករ។

(k) ប្រសិនបើអាជ្ញាធរចេញអាជ្ញាបណ្ណមិនអាចកំណត់រកម្ចាស់ស្របច្បាប់នៃអាវុធ ឬគ្រាប់រំសេវណាមួយដែលត្រូវបានប្រគល់ ឬត្រូវបានដកហូតស្របតាមមាត្រានេះបានដោយសមហេតុផល ក្នុងរយៈពេល 180 ថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់ ឬការបញ្ចប់ដីកាបង្គាប់ឱ្យប្រគល់អាវុធ ឬគ្រាប់រំសេវនោះទេ អាជ្ញាធរចេញអាជ្ញាបណ្ណអាចចាត់ចែងអាវុធ ឬគ្រាប់រំសេវនោះស្របតាមមាត្រា 129D។

មាត្រា 80 ជំពូក 140 ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលមាត្រា 131T ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 131T (a)(1) នៅពេលមានការដាក់ពាក្យបណ្តឹងតវ៉ាស្របតាមមាត្រា 131R

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

តុលាការអាចចេញដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរក្នុងគ្រាអាសន្ន ដោយមិនបាច់ជូនដំណឹងដល់ចុងចម្លើយ និងមុនពេលបើកសវនាការដែលបានតម្រូវអនុលោមតាមកថាខណ្ឌ (a) នៃមាត្រា 131S ប្រសិនបើតុលាការរកឃើញមូលហេតុសមស្របនឹងសន្និដ្ឋានថា ចុងចម្លើយបង្កជាហានិភ័យនៃការបង្ករបួសស្នាមដល់រាងកាយខ្លួនឯង ឬអ្នកដទៃ តាមរយៈការកាន់កាប់អាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ ឬមានអាវុធ ឬគ្រាប់រំសេវស្ថិតនៅក្រោមការគ្រប់គ្រង ភាពជាកម្មសិទ្ធិ ឬការកាន់កាប់របស់ចុងចម្លើយ។ នៅពេលចេញដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរក្នុងគ្រាអាសន្នស្របតាមមាត្រានេះ ក្រឡាបញ្ជីតុលាការត្រូវជូនដំណឹងដល់ចុងចម្លើយស្របតាមកថាខណ្ឌ (e) នៃមាត្រា 131S។ ដីកាដែលបានចេញនៅក្រោមកថាខណ្ឌនេះ ត្រូវផុតកំណត់ក្នុងរយៈពេល 10 ថ្ងៃ បន្ទាប់ពីការចេញដីកានោះ លើកលែងតែមានការកំណត់កាលបរិច្ឆេទសវនាការស្របតាមកថាខណ្ឌ (a) ឬ (b) នៃមាត្រា 131S ដែលបានពោលខាងលើ ឬនៅពេលបញ្ចប់សវនាការដែលបានធ្វើឡើងស្របតាមកថាខណ្ឌ (a) ឬ (b) នៃមាត្រា 131S ដែលបានពោលខាងលើ លើកលែងតែតុលាការចេញដីកាជាអចិន្ត្រៃយ៍មួយស្របតាមអនុប្រយោគទី (2) នៃកថាខណ្ឌ (c) ក្នុងមាត្រា 131S ដែលបានពោលខាងលើ។

(2) នៅពេលទទួលបានការប្រគល់ដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរស្របតាមមាត្រានេះ ចុងចម្លើយត្រូវប្រគល់ជាបន្ទាន់នូវអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធរបស់ខ្លួន ព្រមទាំងអាវុធ ឬគ្រាប់រំសេវទាំងអស់ ជូនទៅអាជ្ញាធរចេញអាជ្ញាបណ្ណក្នុងតំបន់ដែលជាអ្នកប្រគល់ដីកានោះ ដូចមានចែងនៅក្នុងកថាខណ្ឌ (f) នៃមាត្រា 131S។

(b)(1) ប្រសិនបើតុលាការមានហេតុផលសមស្របនឹងជឿថា ចុងចម្លើយអាចចូលប្រើប្រាស់អាវុធ ឬគ្រាប់រំសេវជាប់នឹងខ្លួន ឬនៅក្នុងទីតាំងជាក់លាក់ណាមួយ ហើយចុងចម្លើយមិនបានប្រគល់អាវុធ ឬគ្រាប់រំសេវណាមួយក្នុងរយៈពេល 24 ម៉ោង បន្ទាប់ពីទទួលបានដីកាបង្គាប់ស្របតាមកថាខណ្ឌ (e) នៃមាត្រា 131S ទេនោះ តុលាការត្រូវតែចេញដីកាកំណត់អត្តសញ្ញាណទ្រព្យសម្បត្តិ ព្រមទាំងបញ្ជាក់ឈ្មោះ ឬបរិយាយអំពីបុគ្គល ឬទីកន្លែងដែលត្រូវឆែកឆេរ និងបង្គាប់ឱ្យទីភ្នាក់ងារអនុវត្តច្បាប់សមស្របធ្វើការឆែកឆេរលើខ្លួនប្រាណរបស់ចុងចម្លើយ និងទីកន្លែងជាក់លាក់ណាមួយ ហើយដកហូតរាល់អាវុធ ឬគ្រាប់រំសេវរកឃើញទាំងឡាយ ដែលចុងចម្លើយអាចចូលប្រើប្រាស់បាន។

(2) ទីភ្នាក់ងារអនុវត្តច្បាប់ត្រូវធ្វើការឆែកឆេរ និងគ្រប់គ្រងទ្រព្យសម្បត្តិណាមួយដែលត្រូវបានដកហូត ស្របតាមអនុប្រយោគ (3) នៃកថាខណ្ឌ (d) ក្នុងមាត្រា 131S។

(c) នៅពេលដែលតុលាការបិទទ្វារមិនបំពេញការងារ ចៅក្រមតុលាការជំនុំជម្រះអាចអនុញ្ញាតឱ្យចេញដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរក្នុងគ្រាអាសន្នបាន ប្រសិនបើតុលាការរកឃើញមូលហេតុសមស្របនឹងសន្និដ្ឋានថា ចុងចម្លើយបង្កហានិភ័យនៃការបង្ករបួសស្នាមដល់រាងកាយខ្លួនឯង ឬអ្នកដទៃ តាមរយៈការកាន់កាប់នូវអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ ឬដោយសារការមានអាវុធ ឬគ្រាប់រំសេវស្ថិតនៅក្រោមការគ្រប់គ្រង កម្មសិទ្ធិ ឬការកាន់កាប់របស់ចុងចម្លើយ ហើយត្រូវចេញដីកាស្របតាមកថាខណ្ឌ (b) នៅពេលមានហេតុផលគួរឱ្យជឿថាចុងចម្លើយអាចប្រើប្រាស់អាវុធ ឬគ្រាប់រំសេវ នៅជាប់នឹងខ្លួនរបស់ពួកគេ ឬនៅក្នុងទីកន្លែងកំណត់ជាក់លាក់ណាមួយ និងក្នុងករណីដែលចុងចម្លើយខកខានមិនបានប្រគល់អាវុធ ឬគ្រាប់រំសេវណាមួយក្នុងរយៈពេល 24 ម៉ោង បន្ទាប់ពីត្រូវបានប្រគល់ដីកាស្របតាមកថាខណ្ឌ (e) នៃមាត្រា 131S។ តាមឆន្ទានុសិទ្ធិរបស់ចៅក្រម សេចក្ដីសម្រេចការពារបែបនេះអាចត្រូវបានអនុញ្ញាតចេញ និងបញ្ជូនតាមទូរសព្ទទៅអាជ្ញាធរចេញអាជ្ញាបណ្ណរបស់ក្រុងដែលចុងចម្លើយរស់នៅ ដែលអាជ្ញាធរនោះត្រូវកត់ត្រាដីកា ឬដីកាបង្គាប់នោះទៅលើទម្រង់ដីកា ឬដីកាបង្គាប់ដែលត្រូវបានប្រកាសឱ្យប្រើសម្រាប់កិច្ចការបែបនេះដោយប្រធានចៅក្រមនៃតុលាការជំនុំជម្រះ ហើយត្រូវប្រគល់ច្បាប់ចម្លងដីកា ឬដីកាបង្គាប់នោះនៅថ្ងៃធ្វើការបន្ទាប់របស់តុលាការ ជូនទៅក្រឡាបញ្ជីតុលាការ។ ប្រសិនបើសេចក្ដីសម្រេចការពារត្រូវបានអនុញ្ញាតដោយមិនមានការដាក់ពាក្យបណ្ដឹងតវ៉ាស្របតាមមាត្រា 131R ទេនោះ បុគ្គលដែលអាចជាដើមបណ្ដឹងត្រូវតែមកបង្ហាញខ្លួននៅតុលាការនៅថ្ងៃធ្វើការបន្ទាប់របស់តុលាការ ដើម្បីដាក់ពាក្យបណ្ដឹងតវ៉ា។ ដីកា ឬដីកាបង្គាប់ដែលបានចេញនៅក្រោមកថាខណ្ឌនេះ ត្រូវផុតកំណត់នៅពេលបញ្ចប់ថ្ងៃធ្វើការបន្ទាប់របស់តុលាការ បន្ទាប់ពីការចេញដីកានោះ លើកលែងតែបុគ្គលដែលអាចជាដើមបណ្ដឹងដូចបានពោលខាងលើបានដាក់ពាក្យបណ្ដឹងតវ៉ាទៅតុលាការស្របតាមមាត្រា 131R ហើយតុលាការបានចេញដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរក្នុងគ្រាអាសន្នស្របតាមកថាខណ្ឌ (a)។

មាត្រា 81 មាត្រា 131X នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត គ្រឿងសព្វាវុធ" នៅត្រង់បន្ទាត់ទី 2 និងទី 3 និងបន្ទាត់ទី 4 និងទី 5 រាល់ពេលពាក្យទាំងនេះលេចឡើង។

មាត្រា 82 មាត្រា 131X នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយដាក់បញ្ចូលបន្ទាប់ពីពាក្យ "អាជ្ញាបណ្ណ" នៅក្នុងបន្ទាត់ទី 8 នូវពាក្យខាងក្រោម៖ "ដើម្បីកាន់អាវុធ ឬបណ្ណសម្គាល់អាវុធ"។

មាត្រា 83 មាត្រា 131X នៃជំពូកទី 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលពាក្យ "គ្រួសារ ឬសមាជិកគ្រួសារ" ក្នុងបន្ទាត់ទី 12 ហើយបញ្ចូលជំនួសមកវិញដោយពាក្យដូចខាងក្រោម៖ "ដើមបណ្ដឹង"។

មាត្រា 84 មាត្រា 131X នៃជំពូកទី 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយការដកចេញនូវកថាខណ្ឌ (d) ហើយបញ្ចូលជំនួសដោយកថាខណ្ឌចំនួន 4 ដូចខាងក្រោម៖-

(d) ថ្វីបើមានច្បាប់ទូទៅ ឬច្បាប់ពិសេស វិធាន ឬបទបញ្ញត្តិណាមួយដែលចែងផ្ទុយពីនេះក៏ដោយ គ្រប់អ្នកផ្ដល់សេវាថែទាំសុខភាពដែលទទួលបានការអនុញ្ញាតស្របច្បាប់ក្នុងនាមជាដើមបណ្ដឹង នៅពេលដាក់ពាក្យស្នើសុំ ឬពាក្យស្នើសុំបន្តដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ អាចបង្ហាញព័ត៌មានសុខភាពដែលត្រូវបានការពាររបស់ចុងចម្លើយ បានត្រឹមតែកម្រិតណាដែលចាំបាច់សម្រាប់ការស៊ើបអង្កេតពេញលេញ និងការចាត់ចែងលើពាក្យស្នើសុំ ឬពាក្យស្នើសុំបន្តដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរនោះតែប៉ុណ្ណោះ។ នៅពេលបង្ហាញព័ត៌មានសុខភាពដែលត្រូវបានការពារ អ្នកផ្ដល់សេវាថែទាំសុខភាពត្រូវខិតខំប្រឹងប្រែងតាមលទ្ធភាពសមហេតុផលដើម្បីកម្រិតព័ត៌មានសុខភាពដែលត្រូវបានការពារនោះ ឱ្យត្រឹមតែកម្រិតណា ដែលចាំបាច់ដើម្បីសម្រេចបាននូវការដាក់ពាក្យស្នើសុំ ឬពាក្យស្នើសុំបន្តតែប៉ុណ្ណោះ។

(e) នៅពេលទទួលបានពាក្យបណ្ដឹងតវ៉ាដោយអ្នកផ្ដល់សេវាថែទាំសុខភាពណាម្នាក់ និងដោយមានការបង្ហាញពីមូលហេតុត្រឹមត្រូវ តុលាការអាចចេញដីកាផ្សេងៗតាមការចាំបាច់ ដើម្បីទទួលបាននូវរាល់របាយការណ៍ពិនិត្យព្យាបាល ឬកំណត់ត្រា ឬ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការធ្វើរោគវិនិច្ឆ័យ ការព្យាករណ៍រោគ ឬការព្យាបាលរបស់ចុងចម្លើយ ដែលចាំបាច់សម្រាប់ការស៊ើបអង្កេតពេញលេញ និងការចាត់ចែងលើពាក្យស្នើសុំដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរនៅក្រោមមាត្រានេះ។ រាល់របាយការណ៍បែបនោះ និងព័ត៌មានសុខភាពផ្សេងទៀតដែលបានផ្តល់ជូន ត្រូវតែរក្សាទុកជាការសម្ងាត់ និងបិទជិតដោយតុលាការ។

(f) សេចក្តីសម្រេចរបស់អ្នកផ្តល់សេវាថែទាំសុខភាពណាម្នាក់ក្នុងការបង្ហាញ ឬមិនបង្ហាញនូវរបាយការណ៍ពិនិត្យព្យាបាល ឬកំណត់ត្រា ឬឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការធ្វើរោគវិនិច្ឆ័យ ការព្យាករណ៍រោគ ឬការព្យាបាលរបស់អ្នកជំងឺស្របតាមកថាខណ្ឌនេះ នៅពេលដែលធ្វើឡើងដោយសមហេតុផល និងក្នុងស្មារតីសុចរិត មិនត្រូវយកមកធ្វើជាមូលដ្ឋានសម្រាប់ទំនួលខុសត្រូវរដ្ឋប្បវេណី ឬព្រហ្មទណ្ឌណាមួយចំពោះអ្នកផ្តល់សេវាថែទាំសុខភាពនោះឡើយ។ ទោះយ៉ាងណាក៏ដោយ គ្រប់អ្នកផ្តល់សេវាថែទាំសុខភាពដែលទទួលបានការអនុញ្ញាតស្របច្បាប់ក្នុងនាមជាដើមបណ្តឹង មិនត្រូវស្ថិតនៅក្រោមទំនួលខុសត្រូវរដ្ឋប្បវេណី ឬព្រហ្មទណ្ឌចំពោះការខកខានមិនបានដាក់ពាក្យបណ្តឹងតវ៉ាទៅតុលាការ ដើម្បីសុំការចេញ ឬការបន្តដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរនោះឡើយ។

(g) តុលាការកំពូល និងតុលាការឧទ្ធរណ៍ ត្រូវមានដែនសមត្ថកិច្ចទន្ទឹមគ្នាក្នុងការពិនិត្យឡើងវិញនូវរាល់នីតិវិធីដែលបានធ្វើឡើង ការសម្រេចសេចក្តីដែលបានចេញ និងដីកា ឬសាលក្រមដែលបានចូលជាធរមាននៅក្នុងតុលាការ ស្របតាមមាត្រា 131S ឬមាត្រា 131T។ ដោយផ្អែកលើមាត្រា 13 នៃជំពូក 211A តុលាការកំពូល ឬតុលាការឧទ្ធរណ៍ អាចកែប្រែនីតិវិធីដែលបានអនុញ្ញាត ឬតម្រូវឱ្យមានលក្ខខណ្ឌនៃការពិនិត្យឡើងវិញបែបនោះតាមរយៈវិធានរបស់ខ្លួន នៅពេលរកឃើញថា ការពិនិត្យឡើងវិញដោយតុលាការនោះនឹងធ្វើឡើងក្នុងលក្ខណៈកាន់តែសាមញ្ញ ឆាប់រហ័ស និងមានប្រសិទ្ធភាពជាងមុន។

មាត្រា 85 មាត្រា 131Y នៃជំពូក 140 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលអនុប្រយោគ (7) ដល់ (12) ហើយបញ្ចូលជំនួសដោយអនុប្រយោគទាំង 10 ខាងក្រោម៖-

(7) ចំនួនដីកាដែលបានចេញស្របតាមកថាខណ្ឌ (d) នៃមាត្រា 131S ឬមាត្រា 131T។

(8) ចំនួនដីកាដែលបានចេញស្របតាមកថាខណ្ឌ (d) នៃមាត្រា 131S ឬមាត្រា 131T ដែលឈានទៅដល់ការដកហូតអាវុធ ឬគ្រាប់រំសេវ។

(9) ការបំបែកលម្អិតអំពីប្រភេទវត្ថុដែលបានប្រគល់ រួមមានជាអាទិ៍ អាជ្ញាបណ្ណកាន់កាប់អាវុធ ឬប័ណ្ណសម្គាល់អាវុធ អាវុធ ឬគ្រាប់រំសេវ។

(10) ការបំបែកលម្អិតអំពីប្រភេទវត្ថុដែលបានដកហូត រួមមានជាអាទិ៍ អាវុធ ឬគ្រាប់រំសេវ។

(11) ចំនួនពាក្យបណ្តឹងតវ៉ាសុំដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ ឬដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរក្នុងគ្រាអាសន្ន ដែលត្រូវបានចាត់ទុកថាជាការក្លែងបន្លំ។

(12) ចំនួនករណីដែលពាក្យបណ្តឹងតវ៉ាត្រូវបានរកឃើញថាជាការក្លែងបន្លំ និងទណ្ឌកម្មដែលត្រូវបានទទួលនៅក្នុងករណីនីមួយៗ។

(13) ពូជសាសន៍ និងជាតិពន្ធុរបស់ដើមបណ្តឹងនិងចុងចម្លើយ។

(14) ភេទ និងអត្តសញ្ញាណយេនឌ័ររបស់ដើមបណ្តឹងនិងចុងចម្លើយ។

(15) ទិន្នន័យស្តីពីរយៈពេលមានសុពលភាពនៃដីកាការពារហានិភ័យកម្រិតធ្ងន់ធ្ងរ និង

(16) ចំនួនករណីដែលក្នុងនោះដីកាត្រូវបានបញ្ចប់ ឬត្រូវបានកែប្រែក្នុងករណីផ្សេងទៀត មុនកាលបរិច្ឆេទផុតកំណត់ដើមរបស់វា។

មាត្រា 86 មាត្រា 3B នៃជំពូក 209A នៃច្បាប់ទូទៅ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យថា "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត" នៅត្រង់បន្ទាត់ទី 6 និងទី 7 និងបន្ទាត់ទី 20 និងទី 21 រាល់ពេលដែលពាក្យទាំងនោះលេចឡើង។

មាត្រា 87 មាត្រា 3B នៃជំពូក 209A ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" ក្នុងបន្ទាត់ទី 13 ហើយបញ្ចូលជំនួសមកវិញ ដោយពាក្យដូចខាងក្រោម៖ "អាវុធ"។

មាត្រា 88 មាត្រា 3B នៃជំពូក 209A ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" ក្នុងបន្ទាត់ទី 15 ហើយបញ្ចូលជំនួសមកវិញដោយពាក្យដូចខាងក្រោម៖ "អាវុធ"។

មាត្រា 88A មាត្រា 3B នៃជំពូក 209A ដូចបានបង្ហាញខាងដើម ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយការលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត" នៅក្នុងបន្ទាត់ទី 37។

មាត្រា 89 មាត្រា 3C នៃជំពូក 209A ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត" នៅត្រង់បន្ទាត់ទី 6 និងទី 9 រាល់ពេលដែលពាក្យនោះលេចឡើង។

មាត្រា 90 មាត្រា 3C នៃជំពូក 209A ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" នៅក្នុងបន្ទាត់ទី 13 ហើយបញ្ចូលជំនួសមកវិញ ដោយពាក្យដូចខាងក្រោម៖ "អាវុធ"។

មាត្រា 91 មាត្រា 3C នៃជំពូក 209A ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" ក្នុង បន្ទាត់ទី 17 ហើយបញ្ចូលជំនួសមកវិញដោយពាក្យដូចខាងក្រោម៖ "អាវុធ"។

មាត្រា 92 ជំពូក 258E នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយដាក់បញ្ចូលបន្ទាប់ពីមាត្រា 4 នូវមាត្រាចំនួន 3 ដូចខាងក្រោម៖

មាត្រា 4A នៅពេលចេញដីកាបណ្តោះអាសន្ន ឬដីកាក្នុងគ្រាអាសន្ននៅក្រោមមាត្រា 5 ឬ 6 ប្រសិនបើដើមចោទបង្ហាញឱ្យឃើញពីលទ្ធភាពខ្ពស់នៃការកើតមានគ្រោះថ្នាក់ភ្លាមៗពីការយាយី តុលាការត្រូវបង្គាប់ឱ្យផ្អាក និងប្រគល់ជាបន្ទាន់នូវរាល់អាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធណាមួយដែលចុងចម្លើយអាចមាន និងបង្គាប់ឱ្យចុងចម្លើយប្រគល់អាវុធនិងគ្រាប់រំសេវទាំងអស់ដែលចុងចម្លើយកំពុងគ្រប់គ្រង ធ្វើជាម្ចាស់ ឬកាន់កាប់នាពេលនោះ ស្របតាមបទបញ្ញត្តិនៃជំពូកនេះ និងជំពូក 140។ រាល់អាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធដែលចុងចម្លើយអាចមាន ត្រូវតែប្រគល់ជូនមន្ត្រីអនុវត្តច្បាប់សមស្រប ស្របតាមបទបញ្ញត្តិនៃជំពូកនេះ និងជំពូក 140 ហើយមន្ត្រីអនុវត្តច្បាប់ខាងលើ អាចរក្សាទុក ផ្ទេរ ឬចាត់ចែងក្នុងករណីផ្សេងទៀតនូវអាវុធ ឬគ្រាប់រំសេវបែបនោះ ស្របតាមបទបញ្ញត្តិនៃមាត្រា 129D

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ក្នុងជំពូក 140 ដែលបានពោលខាងលើ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌនេះត្រូវកំណត់ថា គ្មានខ្លឹមសារណាមួយនៅក្នុងនេះ អនុញ្ញាតឱ្យផ្ទេរអាវុធ ឬគ្រាប់រំសេវណាមួយដែលចុងចម្លើយបានប្រគល់ ទៅឱ្យបុគ្គលណាម្នាក់ក្រៅពីអាជីវករមានអាជ្ញាបណ្ណឡើយ។ សេចក្តីជូនដំណឹងអំពីការផ្អាក និងការបង្គាប់ឱ្យប្រគល់បែបនេះ ត្រូវភ្ជាប់មកជាមួយនូវច្បាប់ចម្លងដីកាបង្ការការយាយី ដែលបានបញ្ជូនទៅឱ្យចុងចម្លើយស្របតាមមាត្រា 9។ នៅពេលប្រគល់ដីកាពោលខាងលើ មន្ត្រីអនុវត្តច្បាប់ត្រូវដកហូតជាបន្ទាន់នូវរាល់អាវុធ និងគ្រាប់រំសេវ ព្រមទាំងអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធណាមួយដែលស្ថិតនៅក្រោមការគ្រប់គ្រង ឬការកាន់កាប់របស់ចុងចម្លើយដែលបានពោលខាងលើ។ រាល់ការបំពានលើដីកាទាំងនេះ ត្រូវផ្តន្ទាទោសដោយពិន័យជាប្រាក់មិនលើសពី 5,000 ដុល្លារ ឬដាក់ពន្ធនាគារមិនលើសពី 2 ½ ឆ្នាំនៅក្នុងមណ្ឌលកែប្រែ ឬទាំងការពិន័យជាប្រាក់ ទាំងដាក់ពន្ធនាគារ។

គ្រប់ចុងចម្លើយដែលមិនសុខចិត្តនឹងដីកាបង្គាប់ឱ្យប្រគល់ ឬផ្អាកនៅក្រោមមាត្រានេះ អាចដាក់ពាក្យបណ្តឹងតវ៉ាទៅតុលាការដែលបានចេញដីកាផ្អាក ឬបង្គាប់ឱ្យប្រគល់នោះ ដើម្បីសុំការពិនិត្យឡើងវិញលើចំណាត់ការបែបនេះ ហើយពាក្យបណ្តឹងតវ៉ានោះត្រូវតែយកមកជំនុំជម្រះមិនឱ្យហួសពី 10 ថ្ងៃធ្វើការរបស់តុលាការ បន្ទាប់ពីតុលាការបានទទួលសេចក្តីជូនដំណឹងអំពីពាក្យបណ្តឹងតវ៉ានោះ។ ប្រសិនបើអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធដែលបានពោលខាងលើ ត្រូវបានផ្អាកនៅពេលចេញដីកាស្របតាមមាត្រា 5 ឬ 6 ពាក្យបណ្តឹងតវ៉ាខាងលើអាចត្រូវបានយកមកជំនុំជម្រះទន្ទឹមគ្នាជាមួយនឹងសវនាការនៅក្រោមប្រយោគទីពីរនៃកថាខណ្ឌទីពីរក្នុងមាត្រា 5។ នៅពេលមានការដាក់លិខិតអះអាងពីចុងចម្លើយដោយសម្អាងថា អាវុធឬគ្រាប់រំសេវនោះគឺតម្រូវឱ្យមានជាចាំបាច់ក្នុងការបំពេញការងាររបស់ចុងចម្លើយ និងនៅពេលមានការស្នើសុំបើកសវនាការជាបន្ទាន់ តុលាការត្រូវបង្គាប់ឱ្យបើកសវនាការសួរដេញដោលនោះក្នុងរយៈពេល 2 ថ្ងៃធ្វើការ គិតចាប់ពីពេលទទួលបានលិខិតអះអាង និងការស្នើសុំបែបនេះ ប៉ុន្តែត្រូវធ្វើឡើងតែលើបញ្ហានៃការប្រគល់ និងការផ្អាកស្របតាមមាត្រានេះតែប៉ុណ្ណោះ។

មាត្រា 4B នៅពេលមានការបន្ត ឬការកែប្រែដីកាដែលបានចេញស្របតាមមាត្រា 5 ឬនៅពេលមានពាក្យបណ្តឹងតវ៉ាសុំការពិនិត្យឡើងវិញដូចមានរៀបរាប់នៅក្នុងមាត្រា 4A តុលាការត្រូវបង្គាប់ ឬបន្តបង្គាប់ឱ្យមានការផ្អាក និងការប្រគល់ជាបន្ទាន់នូវអាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធរបស់ចុងចម្លើយ ព្រមទាំងការប្រគល់អាវុធ និងគ្រាប់រំសេវទាំងអស់ដែលចុងចម្លើយកំពុងគ្រប់គ្រង ធ្វើជាម្ចាស់ ឬកាន់កាប់នៅពេលនោះផងដែរ ប្រសិនបើតុលាការធ្វើការកំណត់សេចក្តីថា ការប្រគល់អាជ្ញាបណ្ណកាន់កាប់អាវុធ ឬបណ្ណសម្គាល់អាវុធ ឬអាវុធ និងគ្រាប់រំសេវបែបនោះជូនទៅចុងចម្លើយវិញ អាចបង្កជាលទ្ធភាពនៃការយាយីដល់ដើមចោទ។ ដីកាផ្អាក និងបង្គាប់ឱ្យប្រគល់ដែលបានចេញស្របតាមមាត្រានេះ ត្រូវបន្តមានសុពលភាពដរាបណាដីកាបង្ការការយាយីពាក់ព័ន្ធនឹងដីកានោះនៅមានធរមាន ហើយរាល់មន្ត្រីអនុវត្តច្បាប់ដែលទទួលបានការប្រគល់អាវុធ ឬគ្រាប់រំសេវបែបនោះ អាចរក្សាទុក ផ្ទេរ ឬចាត់ចែងក្នុងករណីផ្សេងទៀតនូវអាវុធ ឬគ្រាប់រំសេវទាំងនោះ ស្របតាមបទបញ្ញត្តិនៃមាត្រា 129D ក្នុងជំពូក 140។ ទោះជាយ៉ាងណាក៏ដោយ គ្មានខ្លឹមសារណាមួយនៅក្នុងនេះ អនុញ្ញាតឱ្យផ្ទេរអាវុធ ឬគ្រាប់រំសេវណាមួយដែលត្រូវបានប្រគល់ដោយចុងចម្លើយ ទៅឱ្យបុគ្គលណាម្នាក់ក្រៅពីអាជីវករដែលមានអាជ្ញាបណ្ណត្រឹមត្រូវនោះឡើយ។ រាល់ការបំពានលើដីកាបែបនេះ ត្រូវផ្តន្ទាទោសដោយពិន័យជាប្រាក់មិនលើសពី 5,000 ដុល្លារ ឬដាក់ពន្ធនាគារមិនលើសពី 2 ½ ឆ្នាំនៅក្នុងមណ្ឌលកែប្រែ ឬទាំងការពិន័យជាប្រាក់ ទាំងដាក់ពន្ធនាគារ។

មាត្រា 4C នៅពេលមានដីកាបង្គាប់ឱ្យផ្អាក ឬប្រគល់ដែលបានចេញស្របតាមមាត្រា 4A ឬទី 4B តុលាការត្រូវបញ្ជូនរបាយការណ៍មួយដែលមានឈ្មោះ និងព័ត៌មានសម្គាល់អត្តសញ្ញាណរបស់ចុងចម្លើយ ព្រមទាំងសេចក្តីថ្លែងរៀបរាប់អំពីទង្វើដែលត្រូវបានចោទប្រកាន់របស់ចុងចម្លើយ និងទំនាក់ទំនងជាមួយដើមចោទ ទៅកាន់នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ។ នៅពេលផុតកំណត់ លុបចោល ឬដកហូតដីកានោះវិញ តុលាការត្រូវបញ្ជូនរបាយការណ៍មួយដែលមានឈ្មោះនិងព័ត៌មានសម្គាល់អត្តសញ្ញាណរបស់ចុងចម្លើយ សេចក្តីថ្លែងការណ៍រៀបរាប់អំពីទង្វើ ដែលត្រូវបានចោទប្រកាន់របស់ចុងចម្លើយ និងទំនាក់ទំនងជាមួយដើមចោទ ព្រមទាំងសេចក្តីពន្យល់ដែលបញ្ជាក់ថាដីកានោះលែងមានបច្ចុប្បន្នភាព ឬលែងមានសុពលភាពទៀតហើយ ទៅកាន់នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ដែលនាយកដ្ឋាននោះត្រូវបញ្ជូនរបាយការណ៍នោះបន្តទៅអគ្គរដ្ឋអាជ្ញាសហរដ្ឋអាមេរិក ដោយស្របតាមកថាខណ្ឌ (h) នៃមាត្រា 167A ក្នុងជំពូក 6 ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធត្រួតពិនិត្យប្រវត្តិរូបព្រហ្មទណ្ឌភ្លាមៗថ្នាក់ជាតិ (National Instant Criminal Background Check System) ឬប្រព័ន្ធបន្តអ្នកវេនណាមួយដែលត្រូវបានរក្សាទុកសម្រាប់គោលបំណងធ្វើការត្រួតពិនិត្យសាវតារសម្រាប់ការលក់ ឬការផ្តល់អាជ្ញាបណ្ណអាវុធ។

មាត្រា 93 មាត្រា 15E ក្នុងជំពូក 265 នៃច្បាប់ទូទៅ ដែលបានចែងនៅក្នុងការបោះពុម្ពផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ “គ្រឿងសព្វាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងគ្រាប់ប្រាយកាត់កាណុង ឬកាំភ្លើងយន្ត” នៅក្នុងបន្ទាត់ទី 2 និងទី 3។

មាត្រា 94 មាត្រា 15F នៃជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ “គ្រឿងសព្វាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងគ្រាប់ប្រាយកាត់កាណុង ឬ កាំភ្លើងយន្ត” នៅក្នុងបន្ទាត់ទី 2 និងទី 3។

មាត្រា 95 មាត្រា 17 ក្នុងជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ “កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងវែង កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ” នៅបន្ទាត់ទី 10 និងទី 11 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ “ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140”។

មាត្រា 96 មាត្រា 17 នៃជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលពាក្យ “កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងវែង កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ” នៅក្នុងបន្ទាត់ទី 13 ដល់ទី 14។

មាត្រា 97 មាត្រា 18 ក្នុងជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ “កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងវែង កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ” នៅក្នុងបន្ទាត់ទី 5 និងទី 30 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ “ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140”។

មាត្រា 98 មាត្រា 18A ក្នុងជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ “កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងវែង ឬសព្វាវុធវាយប្រហារ” នៅក្នុងបន្ទាត់ទី 8 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ “ដូចបាន

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

កំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 99 មាត្រា 18B ក្នុងជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140" នៅក្នុងបន្ទាត់ទី 4។

មាត្រា 100 មាត្រា 18B នៃជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយ" នៅក្នុងបន្ទាត់ទី 6 និងទី 7, 18 និងទី 19 និងបន្ទាត់ទី 21 គ្រប់ពេលដែលពាក្យទាំងនេះលេចឡើង។

មាត្រា 101 មាត្រា 18B នៃជំពូក 265 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" នៅត្រង់បន្ទាត់ទី 7 និងទី 22 រាល់ពេលដែលពាក្យនេះលេចឡើង ហើយជំនួសមកវិញនូវពាក្យ៖ "អាវុធ" ដូចខាងក្រោម នៅគ្រប់កន្លែងដែលមានពាក្យទាំងនោះ។

មាត្រា 102 មាត្រា 18B នៃជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលនៅក្នុងបន្ទាត់ទី 14 និងទី 15 នូវពាក្យថា "កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយ រួមមានជាអាទិ៍ គ្រឿងសព្វាវុធមានសមត្ថភាពផ្ទុកគ្រាប់ច្រើន ឬកាំភ្លើងយន្ត"។

មាត្រា 103 មាត្រា 21A ក្នុងជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅបន្ទាត់ទី 14 និងទី 15 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 104 មាត្រា 22 ក្នុងជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅបន្ទាត់ទី 28 និងទី 29 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 105 មាត្រា 24 ក្នុងជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅបន្ទាត់ទី 8 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 106 មាត្រា 24B ក្នុងជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅបន្ទាត់ទី 9 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 107 មាត្រា 26 ក្នុងជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅបន្ទាត់ទី 8 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 108 មាត្រា 26 នៃជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅក្នុងបន្ទាត់ទី 22 និង 23។

មាត្រា 109 មាត្រា 39 ក្នុងជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅបន្ទាត់ទី 8 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 110 មាត្រា 58 នៃជំពូក 265 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" នៅក្នុងបន្ទាត់ទី 2 ហើយបញ្ចូលជំនួសវិញដោយកថាខណ្ឌខាងក្រោម៖ "អាវុធ"។

មាត្រា 111 មាត្រា 14 ក្នុងជំពូក 266 នៃច្បាប់ទូទៅដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅបន្ទាត់ទី 10 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 112 មាត្រា 17 ក្នុងជំពូក 266 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅបន្ទាត់ទី 8 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 113 មាត្រា 18 ក្នុងជំពូក 266 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅបន្ទាត់ទី 8 និងទី 9 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 114 មាត្រា 10 នៃជំពូក 269 នៃច្បាប់ទូទៅ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "ការកាន់កាប់" នៅក្នុងបន្ទាត់ទី 28 បន្ទាប់ពីពាក្យ៖ "ពាក់កណ្ដាលស្វ័យប្រវត្តិ"។

មាត្រា 115 មាត្រា 10 នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយការលុបចោលពាក្យ "ដូចបានកំណត់និយមន័យនៅក្នុង" នៅក្នុងបន្ទាត់ទី 101 ហើយជំនួសមកវិញនូវពាក្យដូចតទៅ៖ "គ្រឿងស្វ័យប្រវត្តិ ឧបករណ៍ជំនួយបាញ់រហ័ស ឧបករណ៍ជំរុញកេះកៃបាញ់រហ័ស ឬឧបករណ៍កែប្រែកេះកៃ ដូចដែលពាក្យទាំងនោះត្រូវបានកំណត់និយមន័យនៅក្នុងនោះ"។

មាត្រា 116 មាត្រា 10 នៃជំពូកទី 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលពាក្យ "កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយណាមួយ" នៅក្នុងបន្ទាត់ទី 134 ហើយបញ្ចូលជំនួសមកវិញដោយពាក្យដូចខាងក្រោម៖ "អាវុធណាមួយ"។

មាត្រា 117 មាត្រា 10 នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "តម្រូវការលេខស៊េរី ដូចមានចែងនៅក្នុងមាត្រាមួយរយម្ភៃប្រាំបួន B ក្នុងជំពូកមួយរយសែសិប" នៅក្នុងបន្ទាត់ទី 135 ដល់ទី 137 រួមគ្នា នូវ ហើយជំនួសមកវិញនូវពាក្យដូចតទៅ៖ "តម្រូវការចុះបញ្ជីដូចមានចែងនៅក្នុងមាត្រា 121B នៃជំពូក 140"។

មាត្រា 118 មាត្រា 10 នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយ"

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

នៅក្នុងបន្ទាត់ទី 140 និងទី 141 និងបន្ទាត់ទី 150 និងទី 151 គ្រប់ពេលដែលពាក្យទាំងនេះលេចឡើង។

[*Editors Note: There is no SECTION 119*]

មាត្រា 120 មាត្រា 10 នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "ឬ កាំភ្លើងយន្ត"។

មាត្រា 121 មាត្រា 10 នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ ឬ កាំភ្លើងយន្ត" នៅក្នុងបន្ទាត់ទី 162។

មាត្រា 122 មាត្រា 10 នៃជំពូក269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយការលុបចោលពាក្យ "មន្ត្រីអនុវត្តច្បាប់" នៅក្នុងបន្ទាត់ទី 170 ហើយជំនួសមកវិញនូវពាក្យដូចតទៅ៖ "មន្ត្រីអនុវត្តច្បាប់ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬមន្ត្រីអនុវត្តច្បាប់និវត្តជនដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានកំណត់និយមន័យនៅក្នុងច្បាប់ស្តីពីសុវត្ថិភាពមន្ត្រីអនុវត្តច្បាប់ឆ្នាំ 2004 (Law Enforcement Officers Safety Act of 2004) ក្រម 18 U.S.C. មាត្រា 926B និងមាត្រា 926C រៀងគ្នា ដូចដែលបានធ្វើវិសោធនកម្ម"។

មាត្រា 123 មាត្រា 10 នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយដាក់បញ្ចូលបន្ទាប់ពីពាក្យ "សាកលវិទ្យាល័យ" នៅក្នុងបន្ទាត់ទី 174 នូវពាក្យ "រួមទាំងមធ្យោបាយដឹកជញ្ជូនសម្រាប់សិស្សឬនិស្សិតនៃស្ថាប័នដែលបានពោល"។

មាត្រា 124 មាត្រា 10 នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយដាក់បញ្ចូលបន្ទាប់ពីមាត្រា (j) នូវកថាខណ្ឌខាងក្រោម៖

(k)(1) បុគ្គលណាដែលកាន់កាប់អាវុធ ទោះបីជាមានផ្ទុកគ្រាប់ ឬមិនមានផ្ទុកគ្រាប់ក៏ដោយ ដូចមានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140 នៅក្នុងតំបន់ហាមឃាត់ ហើយបុគ្គលនោះបានដឹង ឬតាមហេតុផលសមស្របគួរដឹងថាទីកន្លែងនោះជាតំបន់ហាមឃាត់ ត្រូវផ្តន្ទាទោសជាពិន័យជាប្រាក់មិនលើសពី 1,000 ដុល្លារ ឬដាក់ពន្ធនាគារនៅក្នុងមណ្ឌលកែប្រែមិនលើសពី 2 ½ ឆ្នាំ ឬទាំងពិន័យជាប្រាក់ ទាំងដាក់ពន្ធនាគារ។

(2) សម្រាប់គោលបំណងនៃកថាខណ្ឌនេះ "តំបន់ហាមឃាត់" ត្រូវមានន័យថាជាទីតាំងណាមួយដូចតទៅនេះ៖

(i) ទីកន្លែងដែលជាកម្មសិទ្ធិ ជួល ឬស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរដ្ឋ រដ្ឋបាលខោនធី ឬរដ្ឋបាលក្រុង និងត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃការគ្រប់គ្រងរបស់រដ្ឋាភិបាលរដ្ឋ បណ្តឹងនីតិវិធីតុលាការ ឬរដ្ឋបាលតុលាការ ឬសេវាកែប្រែ រួមទាំងនៅក្នុង ឬនៅលើផ្នែកណាមួយនៃអគារ ដីធ្លី ឬបរិវេណចំណតរថយន្តរបស់ទីកន្លែងទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ "តំបន់ហាមឃាត់" មិនត្រូវរួមបញ្ចូលនូវដីសាធារណៈរបស់រដ្ឋណាមួយដែលបើកជូនសាធារណជនសម្រាប់ធ្វើការបរបាញ់ឡើយ ហើយលើសពីនេះ រដ្ឋបាលក្រុងអាចបោះឆ្នោតស្របតាមមាត្រា 4 នៃជំពូក 4 ដើម្បីដកអគាររដ្ឋបាលរបស់ខ្លួនចេញពីការចាត់ទុកថាជា "តំបន់ហាមឃាត់" បាន។ ឬ

(ii) ទីតាំងដែលកំពុងប្រើប្រាស់នៅពេលកាន់កាប់នោះ ដើម្បីរក្សា ទុក ឬរាប់សន្លឹកឆ្នោត ក្នុងអំឡុងម៉ោងដែលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតកំពុងប្រព្រឹត្តទៅ ឬការិយាល័យបោះឆ្នោត ឬទីតាំងបោះឆ្នោតមុនកាលកំណត់ក្នុងអំឡុងពេលបើកឱ្យបោះឆ្នោត ឬនៅក្នុងរង្វង់ចម្ងាយ 150 ហ្វីតពីទ្វារចូលអគារការិយាល័យបោះឆ្នោត ឬទីតាំងបោះឆ្នោតមុនកាលកំណត់បែបនោះ។

(3) មន្ត្រីអនុវត្តច្បាប់អាចធ្វើការចាប់ខ្លួនដោយគ្មានដីកាបង្គាប់ និងឃុំខ្លួនបុគ្គលណាម្នាក់ដែលរកឃើញថាបានបំពានលើកថាខណ្ឌនេះ។

(4) ត្រូវចាត់ទុកជាការការពារចំពោះការបំពានលើកថាខណ្ឌនេះ ប្រសិនបើបុគ្គលដែលមានអាជ្ញាបណ្ណ ឬបណ្ណសម្គាល់ចាំបាច់ដែលបានចេញនៅក្រោមមាត្រា 129B, 131 ឬ 131F នៃជំពូក 140 ដើម្បីកាន់កាប់អាវុធ បានរក្សាទុកអាវុធនោះដោយសុវត្ថិភាពនៅក្នុងយានយន្ត ខណៈពេលស្ថិតនៅក្នុងតំបន់ហាមឃាត់ ស្របតាមមាត្រា 131C និង 131L នៃជំពូក 140។

(5) កថាខណ្ឌនេះមិនត្រូវអនុវត្តចំពោះមន្ត្រីអនុវត្តច្បាប់ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬមន្ត្រីអនុវត្តច្បាប់និវត្តជនដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានកំណត់និយមន័យនៅក្នុងច្បាប់ស្តីពីសុវត្ថិភាពមន្ត្រីអនុវត្តច្បាប់ឆ្នាំ 2004 ក្រម 18 U.S.C. មាត្រា 926B និងមាត្រា 926C រៀងគ្នា ដូចបានធ្វើវិសោធនកម្ម ឬចំពោះឆ្មាំសន្តិសុខដែលត្រូវបានជួលឱ្យបំពេញការងារនៅតំបន់ហាមឃាត់ ក្នុងពេលស្ថិតនៅទីតាំងការងាររបស់ពួកគេ និងក្នុងអំឡុងពេលនៃការបំពេញការងាររបស់ពួកគេឡើយ។ គ្មានខ្លឹមសារណាមួយនៅក្នុងកថាខណ្ឌនេះ ត្រូវកម្រិតដល់សិទ្ធិអំណាចរបស់ក្រុង ខោនធី ឬនាយកដ្ឋាន អង្គភាព គណៈកម្មការ ក្រុមប្រឹក្សាទីភ្នាក់ងារ ឬតុលាការម៉ាសាឈូសិត ក្នុងការអនុម័តគោលនយោបាយរឹតបន្តឹងបន្ថែមទៀតលើការកាន់កាប់អាវុធនៅក្នុងតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេនោះឡើយ។

មាត្រា 125 មាត្រា 10 នៃជំពូក 269 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" នៅត្រង់បន្ទាត់ទី 196 និងទី 226 រាល់ពេលដែលពាក្យនេះលេចឡើង ហើយជំនួសមកវិញនូវពាក្យដូចខាងក្រោម នៅត្រង់គ្រប់កន្លែងទាំងនោះ៖ "អាវុធ"។

មាត្រា 126 មាត្រា 10 នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយការលុបចោលពាក្យ "កាំភ្លើងគ្រាប់ប្រាយកាត់កាណុងមានបញ្ចូលគ្រាប់ ឬកាំភ្លើងយន្តមានបញ្ចូលគ្រាប់" នៅក្នុងបន្ទាត់ទី 240។

មាត្រា 127 កថាខណ្ឌ (o) នៃមាត្រា 10 ក្នុងជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយដកចេញកថាខណ្ឌទីពីរ ហើយបញ្ចូលជំនួសដោយកថាខណ្ឌខាងក្រោម៖-

សម្រាប់គោលបំណងនៃមាត្រានេះ ពាក្យថា "គ្រាប់រំសេវ" និង "អាវុធ" ត្រូវមានន័យដូចគ្នាទៅនឹងនិយមន័យនៃពាក្យទាំងឡាយដែលបានកំណត់នៅក្នុងមាត្រា 121 នៃជំពូក 140។

មាត្រា 128 មាត្រា 10A នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយការលុបចោលពាក្យ "អាវុធ ត្រូវ" នៅក្នុងបន្ទាត់ទី 11 ហើយជំនួសមកវិញនូវពាក្យដូចតទៅ៖ "អាវុធ រួមទាំងបណ្តុំគ្រឿងណាមួយដែលត្រូវបានរចនា ឬកែច្នៃឡើងវិញ និងមានបំណងសម្រាប់ប្រើប្រាស់ក្នុងការដំឡើង ឬការផលិត

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

នូវឧបករណ៍ គ្រឿងភ្ជាប់ អាវុធ ឬឧបករណ៍ប្រើប្រាស់បែបនោះ និងគ្រឿងណាមួយ ដែលមានបំណងសម្រាប់តែប្រើប្រាស់ក្នុងការដំឡើង ឬការផលិតបែបនោះ ត្រូវ..."។

មាត្រា 129 មាត្រា 10A នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "ឬ សម្ភារៈប្រើប្រាស់" នៅក្នុងបន្ទាត់ទី 6 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "សម្ភារៈប្រើប្រាស់ ឬគ្រឿង"។

មាត្រា 130 មាត្រា 10E ក្នុងជំពូក 269 នៃច្បាប់ទូទៅ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬគ្រឿងបង្កុំណាមួយនៃកាំភ្លើងទាំងនោះ" នៅបន្ទាត់ទី 4 និងទី 5 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 131 មាត្រា 10E នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬការផ្សំបញ្ចូលគ្នាណាមួយនៃកាំភ្លើងទាំងនោះ" នៅក្នុងបន្ទាត់ទី 5 ដល់ 6។

មាត្រា 132 មាត្រា 10F នៃជំពូក 269 ខាងលើ ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" នៅត្រង់បន្ទាត់ទី 3 និងទី 31 រាល់ពេលដែលពាក្យនេះលេចឡើង ហើយជំនួសមកវិញនូវពាក្យ៖ "អាវុធ" ដូចខាងក្រោម នៅគ្រប់កន្លែងដែលមានពាក្យទាំងនោះ។

មាត្រា 133 មាត្រា 10H នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយការបញ្ចូលបន្ថែមបន្ទាប់ពីលេខ "140" នៅក្នុងបន្ទាត់ទី 4 នូវពាក្យដូចតទៅ៖ "ក្នុងពេលដែលមានកម្រិតភាគរយនៃជាតិអាល់កុលក្នុងឈាម ធៀបនឹងទម្ងន់ ចាប់ពីចំនួនសូន្យកណ្ដាក់សញ្ញាសូន្យប្រាំបីភាគរយ ឬច្រើនជាងនេះ ឬ"។

មាត្រា 134 ជំពូក 269 ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 10I ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 10I (a) បុគ្គលណាក៏ដោយដែលដឹកជញ្ជូនអាវុធ ដូចមានកំណត់និយមន័យនៅក្នុងមាត្រា 121ជំពូក 140 ចូលមកក្នុងរដ្ឋម៉ាសាឈូសិត ដើម្បីប្រើប្រាស់អាវុធនោះក្នុងការប្រព្រឹត្តសកម្មភាពឧក្រិដ្ឋ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមិនតិចជាង 5 ឆ្នាំ និងមិនលើសពី 10 ឆ្នាំឡើយ។

(b) បុគ្គលណាក៏ដោយដែលដឹកជញ្ជូនអាវុធចូលមកក្នុងរដ្ឋម៉ាសាឈូសិត ដើម្បីចែកចាយ លក់ ឬផ្ទេរការកាន់កាប់អាវុធនោះដោយខុសច្បាប់ ទៅឱ្យបុគ្គលដែលត្រូវបានហាមឃាត់ ដូចមានកំណត់និយមន័យនៅក្នុងមាត្រា 121F នៃជំពូក 140 ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររដ្ឋមិនតិចជាង 10 ឆ្នាំ និងមិនលើសពី 20 ឆ្នាំឡើយ។

(c) បុគ្គលណាក៏ដោយដែលដឹកជញ្ជូនអាវុធចូលមកក្នុងរដ្ឋម៉ាសាឈូសិត ដើម្បីចែកចាយ លក់ ឬផ្ទេរអាវុធនោះដោយខុសច្បាប់ ទៅឱ្យបុគ្គលដែលត្រូវបានហាមឃាត់ ដូចមានកំណត់និយមន័យនៅក្នុងមាត្រា 121F នៃជំពូក 140 ហើយប្រសិនបើជាបន្តបន្ទាប់មក អាវុធនោះត្រូវបានយកទៅប្រើប្រាស់បង្កឱ្យមានមរណភាពដល់បុគ្គលដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររដ្ឋមិនតិចជាង 20 ឆ្នាំឡើយ។

មាត្រា 135 មាត្រា 10K ក្នុងជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬគ្រាប់រំសេវ" នៅក្នុងបន្ទាត់ទី 9 និងទី 10 បន្ទាត់ទី 15 និងទី 16 និងបន្ទាត់ទី 19 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ឬគ្រាប់រំសេវ ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 136 ជំពូក 269 ត្រូវបានធ្វើវិសោធនកម្មដោយការដកចេញនូវមាត្រា 11A ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 11A សម្រាប់គោលបំណងនៃមាត្រា 11A ដល់មាត្រា 11C រួមគ្នា នូវពាក្យថា "អាវុធ" "លេខស៊េរី" និង "អាវុធមិនអាចតាមដានបាន" ត្រូវមាននិយមន័យដូចគ្នាទៅនឹងមាត្រា 121 នៃជំពូក 140។

មាត្រា 137 មាត្រា 11B នៃជំពូកទី 269 ដែលមានក្នុងបច្ចុប្បន្ននេះត្រូវបានធ្វើវិសោធនកម្មដោយការដកចេញនូវប្រយោគទីមួយ ហើយបញ្ចូលជំនួសដោយប្រយោគខាងក្រោម៖-

បុគ្គលណាក៏ដោយដែលនៅក្នុងអំឡុងពេលនៃការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ មានកាន់កាប់ ឬស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួននូវអាវុធដែលមិនអាចស្វែងរកប្រភពបាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមិនតិចជាង 2 ½ ឆ្នាំឡើយ។

មាត្រា 138 ជំពូក 269 ត្រូវបានធ្វើវិសោធនកម្មដោយការដកចេញនូវមាត្រា 11C ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

មាត្រា 11C បុគ្គលណាក៏ដោយដែលធ្វើសកម្មភាពដោយខ្លួនឯងផ្ទាល់ ឬរួមដៃជាមួយបុគ្គលដទៃ ដោយដឹងខ្លួនជាមុនដែលផលិត ដំឡើង នាំចូល លក់ ឬផ្ទេរកម្មសិទ្ធិអាវុធមិនអាចតាមដានបាន ឬដោយដឹងខ្លួនជាមុនបានចូលរួមក្នុងការផលិត ការដំឡើង ការនាំចូល ការលក់ ឬការផ្ទេរអាវុធដែលមិនអាចស្វែងរកប្រភពបាន ឬទិញ ឬទទួលយកអាវុធដោយដឹងជាមុនថាអាវុធនោះមិនអាចស្វែងរកប្រភពបាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមិនតិចជាង 12 ខែ និងមិនលើសពី 2½ ឆ្នាំឡើយ។ ការកាន់កាប់ ឬការគ្រប់គ្រងអាវុធមិនអាចតាមដានបាន ត្រូវចាត់ទុកជាភស្តុតាងបង្ហាញឱ្យឃើញជាបឋមថា បុគ្គលដែលកាន់កាប់ ឬគ្រប់គ្រងបែបនោះ មានពិរុទ្ធភាពពីការបំពានលើមាត្រានេះ ប៉ុន្តែភស្តុតាងបង្ហាញជាបឋមបែបនេះ អាចត្រូវបដិសេធវិញបាន ដោយភស្តុតាងដែលបញ្ជាក់ថា បុគ្គលនោះមិនបានដឹងទាល់តែសោះថាអាវុធនោះមិនអាចស្វែងរកប្រភពបាន ឬដោយភស្តុតាងដែលបញ្ជាក់ថា ពួកគេមិនមានចេតនាទុច្ចរិតចំពោះរឿងនោះឡើយ។ នៅពេលមានការសម្រេចផ្តន្ទាទោសពីការបំពានលើមាត្រានេះ អាវុធដែលបានពោលខាងលើ ត្រូវបញ្ជូនបន្ត ក្រោមអំណាចនៃដីកាបង្គាប់ជាលាយលក្ខណ៍អក្សររបស់តុលាការ ទៅកាន់ស្នងការប៉ូលីសរដ្ឋដែលត្រូវចាត់ចែងឱ្យបំផ្លាញចោលអាវុធនោះចោល។

មាត្រា 139 មាត្រា 11E នៃជំពូក 269 ដែលមានក្នុងពេលបច្ចុប្បន្ននេះ ត្រូវបាននិរាករតាមរយៈច្បាប់នេះ។

មាត្រា 140 មាត្រា 12D នៃជំពូកទី 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មការដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" នៅក្នុងបន្ទាត់ទី 30 ហើយបញ្ចូលជំនួសមកវិញដោយពាក្យដូចខាងក្រោម៖ "អាវុធ"។

មាត្រា 141 ជំពូក 269 ត្រូវបានធ្វើវិសោធនកម្មបន្ថែម ដោយលុបចោលមាត្រា 12E ដែលមានក្នុងបច្ចុប្បន្ននេះ ហើយបញ្ចូលជំនួសដោយមាត្រាខាងក្រោម៖-

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

មាត្រា 12E (a) បុគ្គលណាក៏ដោយដែលបាញ់អាវុធ ដូចមានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140 នៅក្នុងរង្វង់ចម្ងាយ 500 ហ្វីតពីផ្ទះសម្បែង ឬអគារដទៃទៀតដែលកំពុងប្រើប្រាស់ លើកលែងតែមានការយល់ព្រមពីម្ចាស់ ឬអ្នកស្នាក់នៅស្របច្បាប់នៅទីកន្លែងនោះ ពុំនោះសោត ត្រូវផ្តន្ទាទោសដោយពិន័យជាប្រាក់មិនតិចជាង 50 ដុល្លារ និងមិនលើសពី 100 ដុល្លារ ឬជាប់ទោសក្នុងពន្ធនាគារ ឬមណ្ឌលកែប្រែមិនលើសពី 3 ខែ ឬទាំងទោសពិន័យជាប្រាក់ ទាំងជាប់ពន្ធនាគារ។

(b) មាត្រានេះ មិនអនុវត្តចំពោះបុគ្គលដូចខាងក្រោមឡើយ៖ (i) ការការពារអាយុជីវិត និងទ្រព្យសម្បត្តិស្របច្បាប់ (ii) មន្ត្រីអនុវត្តច្បាប់ណាម្នាក់ដែលធ្វើសកម្មភាពក្នុងការបំពេញតួនាទីរបស់ខ្លួន ឬ (iii) ការបាញ់គ្រាប់ទទេក្នុងគោលបំណងសម្តែងល្ខោន កីឡាអត្តពលកម្ម ពិធីបុណ្យផ្លូវការ ក្រុមបាញ់កាំភ្លើង ឬគោលបំណងផ្សេងទៀត ស្របតាមមាត្រា 39 នៃជំពូក 148។

(c) ផ្នែកនេះមិនត្រូវអនុវត្តចំពោះផ្ទះសម្បែង ឬអគារដែលស្ថិតនៅលើអចលនទ្រព្យតែមួយជាមួយ៖ (i) បុគ្គលដែលប្រើប្រាស់ទីលានហ្វឹកហាត់បាញ់ស៊ីប ឬទីលានសាកល្បងក្រោមដី ឬក្នុងអគារ ដោយមានការយល់ព្រមពីម្ចាស់ ឬអ្នកស្នាក់នៅស្របច្បាប់នៅទីកន្លែងនោះ (ii) បុគ្គលដែលប្រើប្រាស់ទីលានបាញ់កូនចានហោះ ទីលានបាញ់ស៊ីប ឬទីលានសាកល្បងខាងក្រៅអគារ ដោយមានការយល់ព្រមពីម្ចាស់ ឬអ្នកស្នាក់នៅស្របច្បាប់នៃដីដែលជាទីលាននោះ ឬ (iii) បុគ្គលប្រើប្រាស់កន្លែងបាញ់កាំភ្លើងកម្សាន្ត ដែលមានអាជ្ញាបណ្ណ និងមានកំណត់និយមន័យនៅក្រោមបទប្បញ្ញត្តិនៃមាត្រា 56A នៃជំពូក 140។ គ្មានខ្លឹមសារណាមួយនៅក្នុងមាត្រានេះ អាចលើកលែងឱ្យបុគ្គលណាម្នាក់ពីការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ សេចក្តីសម្រេច ឬលក្ខន្តិកៈស្តីពីការត្រួតពិនិត្យសំឡេងរំខានជាធរមាន ឬពីបម្រាមនានានៃមាត្រា 58 ក្នុងជំពូក 131 នោះឡើយ។

មាត្រា 142 មាត្រា 12F នៃជំពូក 269 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយការលុបចោលពាក្យ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 131J នៃជំពូក 140 នូវ កាំភ្លើងវែង កាំភ្លើងគ្រាប់ប្រាយណាមួយ" នៅក្នុងបន្ទាត់ទី 11 និងទី 12។

មាត្រា 143 ជំពូក 269 ដែលបានពោល ត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត ដោយការបញ្ចូលទៅខាងក្រោយមាត្រា 12F នូវមាត្រាដូចតទៅនេះ៖-

មាត្រា 12G បុគ្គលណាក៏ដោយដែលបាញ់អាវុធដោយចេតនា ឬដោយខ្វះការប្រុងប្រយ័ត្ន ដូចមានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140 ហើយគ្រាប់កាំភ្លើងនោះបានទៅត្រូវចំផ្ទះសម្បែង ឬអគារដទៃទៀតដែលកំពុងប្រើប្រាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារនៅក្នុងមណ្ឌលកែប្រែមិនលើសពី 2 ½ ឆ្នាំ ឬដាក់ពន្ធនាគាររដ្ឋមិនលើសពី 5 ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនលើសពី 10,000 ដុល្លារ ឬទាំងជាប់ពន្ធនាគារ ទាំងពិន័យជាប្រាក់។ មាត្រានេះមិនត្រូវអនុវត្តចំពោះបុគ្គលដែលធ្វើសកម្មភាពក្នុងការការពារអាយុជីវិត ឬទ្រព្យសម្បត្តិស្របច្បាប់ ឬមន្ត្រីអនុវត្តច្បាប់ណាម្នាក់ដែលធ្វើសកម្មភាពក្នុងការបំពេញតួនាទីរបស់ខ្លួនឡើយ។ មាត្រានេះមិនត្រូវអនុវត្តចំពោះផ្ទះសម្បែង ឬអគារដែលស្ថិតនៅលើអចលនទ្រព្យតែមួយជាមួយ៖ (A) បុគ្គលដែលប្រើប្រាស់ទីលានហ្វឹកហាត់បាញ់ស៊ីប ឬទីលានសាកល្បងក្រោមដី ឬក្នុងអគារ ដោយមានការយល់ព្រមពីម្ចាស់ ឬអ្នកស្នាក់នៅស្របច្បាប់នៅទីកន្លែងនោះ (b) បុគ្គលដែលប្រើប្រាស់ទីលានបាញ់កូនចានហោះ ទីលានហ្វឹកហាត់បាញ់ស៊ីប ឬទីលានសាកល្បងខាងក្រៅអគារ ដោយមានការយល់ព្រមពីម្ចាស់ ឬអ្នកស្នាក់នៅស្របច្បាប់នៃដីដែលជាទីលាននោះ ឬ (c) បុគ្គលប្រើប្រាស់កន្លែងបាញ់កាំភ្លើងកម្សាន្តដែលមានអាជ្ញាបណ្ណ និងមានកំណត់និយមន័យនៅក្រោមបទប្បញ្ញត្តិនៃមាត្រា 56A នៃជំពូក 140។ គ្មានខ្លឹមសារណាមួយនៅក្នុងមាត្រានេះ អាចលើកលែងបុគ្គលណាម្នាក់ពីការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ ឬលក្ខន្តិកៈស្តីពីការត្រួតពិនិត្យសំឡេងរំខានជាធរមាន ឬពីបម្រាមនានានៃមាត្រា 58 ក្នុងជំពូក 131 នោះឡើយ។

មាត្រា 144 មាត្រា 14 នៃជំពូក 269 ដូចបានពោល ដែលមានចែងនៅក្នុងការបោះពុម្ពផ្សាយជាផ្លូវការឆ្នាំ 2022 ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "កាំភ្លើងវែង ឬកាំភ្លើងគ្រាប់ប្រាយ កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅក្នុងបន្ទាត់ទី 15។

មាត្រា 145 មាត្រា 58A ក្នុងជំពូកទី 276 នៃច្បាប់ទូទៅដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ ឬកាំភ្លើងយន្ត" ក្នុងបន្ទាត់ទី 21 ហើយបញ្ចូលជំនួសដោយពាក្យខាងក្រោម៖-

មាត្រា 146 មាត្រា 58A នៃជំពូកទី 276 ដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យ "គ្រឿងសព្វាវុធ" ក្នុងបន្ទាត់ទី 28 ហើយបញ្ចូលជំនួសដោយពាក្យខាងក្រោម៖ "អាវុធ"។

មាត្រា 147 មាត្រា 25 ក្នុងជំពូក 279 នៃច្បាប់ទូទៅដែលមានក្នុងបច្ចុប្បន្ននេះ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលពាក្យថា "កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងវែង កាំភ្លើងយន្ត ឬសព្វាវុធវាយប្រហារ" នៅបន្ទាត់ទី 17 និងទី 18 ហើយបញ្ចូលជំនួសមកវិញនូវពាក្យ៖ "ដូចបានកំណត់និយមន័យនៅក្នុងមាត្រា 121 នៃជំពូក 140"។

មាត្រា 148 (a) ដូចបានប្រើនៅក្នុងមាត្រានេះ ពាក្យខាងក្រោមត្រូវមានអត្ថន័យដូចតទៅ លើកលែងតែមានបរិបទកំណត់ច្បាស់ផ្សេងពីនេះ៖

"ត្រាបោះពុម្ពខ្នាតតូច" មានន័យថាជាបណ្តុំតួអក្សរតូចៗដែលកំណត់អត្តសញ្ញាណម៉ាក ម៉ូដែល ឬលេខស៊េរីរបស់អាវុធ ដោយការឆ្លាក់ ឬការបោះពុម្ពដោយវិធីផ្សេងទៀតនៅ 2 កន្លែង ឬច្រើនជាងនេះ លើផ្ទៃខាងក្នុង ឬនៅលើគ្រឿងបង្កំដំណើរការខាងក្នុងអាវុធ ដែលតួអក្សរទាំងនោះនឹងត្រូវផ្ទេរដោយការបោះពុម្ពជាប់នៅលើសម្បកគ្រាប់នីមួយៗនៅពេលបាញ់អាវុធនោះ។

"អាវុធកំណត់អត្តសញ្ញាណបុគ្គល" មានន័យថាជាអាវុធដែលត្រូវបានផលិតឡើងដោយការបញ្ចូលបច្ចេកវិទ្យារចនាបង្កំ ឬត្រូវបានកែច្នៃដោយប្រើប្រាស់បច្ចេកវិទ្យាបែបនោះ ដើម្បីឱ្យអាវុធនោះ៖ (i) អនុញ្ញាតឱ្យបាញ់បានតែដោយអ្នកប្រើប្រាស់ដែលមានការអនុញ្ញាតប៉ុណ្ណោះ ឬ (ii) បង្ការមិនឱ្យមានការបិទចោលដោយងាយនូវលក្ខណៈសុវត្ថិភាពណាមួយរបស់អាវុធឡើយ។

(b) តាមរយៈខ្លឹមសារនេះ គណៈកម្មការនីតិប្បញ្ញត្តិពិសេសមួយត្រូវបានបង្កើតឡើងស្របតាមមាត្រា 2A ក្នុងជំពូក 4 នៃច្បាប់ទូទៅ ដើម្បីសិក្សា និងស៊ើបអង្កេតលើបច្ចេកវិទ្យាអាវុធដែលកំពុងលេចឡើងថ្មីៗ។

(c) គណៈកម្មការនីតិប្បញ្ញត្តិពិសេសនេះ ត្រូវមានសមាជិកចំនួន 13 រូប រួមមាន៖ ប្រធានគណៈកម្មាធិការចម្រុះទទួលបន្ទុកប្រព័ន្ធតុលាការ ឬអ្នកតំណាងរបស់ពួកគេដែលត្រូវធ្វើជាសហប្រធាន រដ្ឋមន្ត្រីក្រសួងសន្តិសុខនិងសុវត្ថិភាពសាធារណៈ ឬអ្នកតំណាងម្នាក់ ស្នងការប៉ូលិសរដ្ឋ ឬអ្នកតំណាងម្នាក់ សមាជិក 2 រូបតែងតាំង

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ដោយប្រធានរដ្ឋសភា សមាជិក 2 រូបតែងតាំងដោយប្រធានព្រឹទ្ធសភា សមាជិក 1 រូបតែងតាំងដោយមេដឹកនាំសំឡេងភាគតិចនៃរដ្ឋសភា សមាជិក 1 រូបតែងតាំងដោយមេដឹកនាំសំឡេងភាគតិចនៃព្រឹទ្ធសភា សមាជិក 1 រូបតែងតាំងដោយអភិបាលរដ្ឋ ដែលត្រូវតែជាអ្នកជំនាញខាងបច្ចេកវិទ្យាអាវុធដែលកំពុងលេចឡើងថ្មីៗ អគ្គរដ្ឋអាជ្ញា ឬអ្នកតំណាងម្នាក់ និងសមាជិក 1 រូបតែងតាំងដោយមូលនិធិកីឡាបាញ់កាំភ្លើងជាតិ (National Shooting Sports Foundation, Inc.)។

(d) គណៈកម្មការនីតិប្បញ្ញត្តិពិសេសនេះ ត្រូវធ្វើការស៊ើបអង្កេត និងសិក្សាអំពីស្ថានភាព សមិទ្ធិលទ្ធភាព និងការប្រើប្រាស់ជាប្រយោជន៍នៃបច្ចេកវិទ្យាអាវុធដែលកំពុងលេចឡើងថ្មីៗ រួមមានជាអាទិ៍ បច្ចេកវិទ្យាអាវុធកំណត់អត្តសញ្ញាណបុគ្គល និងបច្ចេកវិទ្យាបោះពុម្ពខ្នាតតូចឡើយ។ ការសិក្សានេះ រួមមាន៖ (i) ការពិនិត្យឡើងវិញនូវបច្ចេកវិទ្យាអាវុធកំណត់អត្តសញ្ញាណបុគ្គល និងបច្ចេកវិទ្យាបោះពុម្ពខ្នាតតូចដែលមានស្រាប់ និងដែលកំពុងអភិវឌ្ឍ ព្រមទាំងបញ្ហាផ្លូវច្បាប់ ឬបញ្ហារដ្ឋធម្មនុញ្ញនានាពាក់ព័ន្ធនឹងបច្ចេកវិទ្យាទាំងនោះ (ii) ការស៊ើបអង្កេតលើភាពត្រឹមត្រូវ ប្រសិទ្ធភាព និងការប្រើប្រាស់ជាប្រយោជន៍នៃបច្ចេកវិទ្យាអាវុធកំណត់អត្តសញ្ញាណបុគ្គល និងបច្ចេកវិទ្យាបោះពុម្ពខ្នាតតូច (iii) ការវាយតម្លៃលើលទ្ធភាពរកបាននៅលើទីផ្សារនៃបច្ចេកវិទ្យាអាវុធកំណត់អត្តសញ្ញាណបុគ្គល និងបច្ចេកវិទ្យាបោះពុម្ពខ្នាតតូច ទាំងក្នុងការផលិតអាវុធថ្មីៗ និងការកែច្នៃអាវុធដែលមានស្រាប់ (iv) ការវាយតម្លៃលើសមិទ្ធិលទ្ធភាព និងការប្រើប្រាស់ជាប្រយោជន៍នៃកម្មវិធីលើកទឹកចិត្តផ្នែកពន្ធសម្រាប់បច្ចេកវិទ្យាអាវុធកំណត់អត្តសញ្ញាណបុគ្គល (v) ការវាយតម្លៃលើហានិភ័យនានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់កូដផលិតកម្មអាវុធឌីជីថលសម្រាប់ម៉ាស៊ីនសិក្សា និងបញ្ញាសិប្បនិម្មិតនិង (vi) ការស៊ើបអង្កេតលើការចំណាយ និងផលប៉ះពាល់នានាដែលពាក់ព័ន្ធនឹងការតម្រូវឱ្យប្រើប្រាស់បច្ចេកវិទ្យាអាវុធកំណត់អត្តសញ្ញាណបុគ្គល ឬបច្ចេកវិទ្យាបោះពុម្ពខ្នាតតូចនៅក្នុងរដ្ឋម៉ាសាឈូសិត។

(e) គណៈកម្មការនីតិប្បញ្ញត្តិពិសេសនេះ ត្រូវដាក់ជូនរបាយការណ៍ស្តីពីការសិក្សា និងអនុសាសន៍របស់ខ្លួន រួមជាមួយអនុសាសន៍ផ្នែកនីតិប្បញ្ញត្តិណាមួយ ទៅប្រធានរដ្ឋសភានិងព្រឹទ្ធសភា ឱ្យបានមុន ឬយ៉ាងយូរបំផុតត្រឹមថ្ងៃទី 1 ខែមីនា ឆ្នាំ 2025។

មាត្រា 149 (a) តាមរយៈខ្លឹមសារនេះ គណៈកម្មការនីតិប្បញ្ញត្តិពិសេសមួយត្រូវបានបង្កើតឡើង ស្របតាមមាត្រា 2A ក្នុងជំពូក 4 នៃច្បាប់ទូទៅ ដើម្បីសិក្សាអំពីរចនាសម្ព័ន្ធផ្តល់ហិរញ្ញប្បទានសម្រាប់សេវាបង្ការអំពើហិង្សារបស់រដ្ឋម៉ាសាឈូសិត។

(b) គណៈកម្មការនីតិប្បញ្ញត្តិពិសេសនេះ ត្រូវមានសមាជិកចំនួន 19 រូប រួមមាន៖ ប្រធានគណៈកម្មាធិការចម្រុះទទួលបន្ទុកសុខភាពសាធារណៈ ឬអ្នកតំណាងរបស់ពួកគេ ដែលត្រូវធ្វើជាសហប្រធាន, ប្រធានគណៈកម្មាធិការចម្រុះទទួលបន្ទុកសុវត្ថិភាពសាធារណៈនិងសន្តិសុខមាតុភូមិ ឬអ្នកតំណាងរបស់ពួកគេ, រដ្ឋមន្ត្រីក្រសួងសន្តិសុខនិងសុវត្ថិភាពសាធារណៈ ឬអ្នកតំណាងម្នាក់, រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងសេវាមនុស្សជាតិ ឬអ្នកតំណាងម្នាក់, សមាជិក 1 រូបតែងតាំងដោយប្រធានរដ្ឋសភា ដែលត្រូវមកពីអង្គការមួយដែលបានទទួលមូលនិធិជំនួយតាមរយៈគំនិតផ្តួចផ្តើមយុវជនប្រកបដោយសុវត្ថិភាពនិងជោគជ័យ (Safe and Successful Youth Initiative), សមាជិក 1 រូបតែងតាំងដោយប្រធានព្រឹទ្ធសភា ដែលត្រូវមកពីអង្គការមួយដែលបានទទួលមូលនិធិជំនួយតាមរយៈគំនិតផ្តួចផ្តើមយុវជនប្រកបដោយសុវត្ថិភាពនិងជោគជ័យ, សមាជិក 1 រូបតែងតាំងដោយមេដឹកនាំសំឡេងភាគតិចនៃរដ្ឋសភា, សមាជិក 1 រូបតែងតាំងដោយមេដឹកនាំសំឡេងភាគតិចនៃព្រឹទ្ធសភា, សមាជិក 3 រូបតែងតាំងដោយអភិបាលរដ្ឋ ដោយក្នុងនោះ 1 រូបត្រូវមកពីអង្គការមួយពាក់ព័ន្ធនឹងការអប់រំ ឬការអភិវឌ្ឍកុមារតូច 1 រូប ត្រូវតំណាងឱ្យអង្គការនៅតាមសហគមន៍ដែលផ្តល់សេវាកម្មអន្តរាគមន៍និងបង្ការ ហើយ 1 រូបទៀតត្រូវតំណាងឱ្យអង្គការនៅតាមសហគមន៍ដឹកនាំដោយស្ត្រីដែលផ្តល់សេវាកម្មបង្ការ និងអន្តរាគមន៍លើអំពើហិង្សា, សមាជិក 2 រូបតែងតាំងដោយក្រុមសមាជិកសភានីតិប្បញ្ញត្តិស្បែកខ្មៅនិងឡាទីនប្រចាំរដ្ឋម៉ាសាឈូសិតដែលមិនមែនជាសមាជិកសភានីតិបញ្ញត្តិរដ្ឋ (General Court), សមាជិក 1 រូបតែងតាំងដោយក្រុមសមាជិកសភានីតិប្បញ្ញត្តិអាស៊ី-អាមេរិកប្រចាំរដ្ឋម៉ាសាឈូសិត (Massachusetts Asian-American Legislative Caucus) ដែលមិនមែនជាសមាជិកសភានីតិបញ្ញត្តិរដ្ឋ, សមាជិក 1 រូបតែងតាំងដោយសមាគមប្រធានមន្ទីរអប់រំប្រចាំរដ្ឋម៉ាសាឈូសិត (Massachusetts Association of School Superintendents, Inc.), សមាជិក 1 រូបតែងតាំងដោយសមាគមសុខាភិបាល និងមន្ទីរពេទ្យប្រចាំរដ្ឋម៉ាសាឈូសិត (Massachusetts Health and Hospital Association, Inc.), និងសមាជិក 1 រូប មកពីសមាគមតុមូលធុរកិច្ចម៉ាសាឈូសិត (Massachusetts Business Roundtable)។

(c) គណៈកម្មការនីតិប្បញ្ញត្តិពិសេសនេះត្រូវ៖ (i) ពិនិត្យ និងវាយតម្លៃលើរចនាសម្ព័ន្ធហិរញ្ញប្បទានបច្ចុប្បន្នរបស់រដ្ឋាភិបាល សម្រាប់សេវាកម្មបង្ការអំពើហិង្សានៅក្នុងរដ្ឋម៉ាសាឈូសិត រួមទាំងប្រភពថវិកា ភាពជាដៃគូរវាងរដ្ឋនិងឯកជន គំនិតផ្តួចផ្តើមនិងកម្មវិធីនានាដែលបានប្រើប្រាស់ សេវាកម្មជាក់លាក់ដែលទទួលបានហិរញ្ញប្បទាន ផលប៉ះពាល់នៃសេវាកម្មដែលផ្តល់ជូនដល់ក្រុមគ្រួសារនៅមានជីវិតនៃជនរងគ្រោះដោយអំពើមនុស្សឃាតក្នុងការជំរុញឱ្យមានការជាសះស្បើយផ្នែកផ្លូវចិត្ត និងការបំបែករង្វង់នៃអំពើហិង្សាពីជំនាន់មួយទៅជំនាន់មួយ សហគមន៍ដែលទទួលបានសេវាកម្ម របៀបធ្វើសេចក្តីសម្រេចចិត្តលើហិរញ្ញប្បទាន និងរបៀបជ្រើសរើសកម្មវិធីនិងស្ថាប័នផ្តល់សេវាកម្ម (ii) សិក្សាអំពីសមិទ្ធិលទ្ធភាពនៃមូលនិធិជំនួយទូទាំងរដ្ឋជូនដល់គណៈភិបាលសុខាភិបាលក្រុង នាយកដ្ឋានសុខាភិបាល និងគណៈកម្មការសុខាភិបាលសម្រាប់ការអភិវឌ្ឍ និងការដំណើរការវិធីសាស្ត្រសុខាភិបាលនិងសុវត្ថិភាពសាធារណៈ ដើម្បីបង្ការអំពើហិង្សាដែលកំណត់ជាគោលដៅតាមរយៈកិច្ចសហការដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ដោយប្រមូលផ្តុំអាជ្ញាធរអនុវត្តច្បាប់មូលដ្ឋាន ស្ថាប័នផ្តល់លំនៅឋាន ស្ថាប័នផ្តល់សេវាមនុស្សធម៌ ស្ថាប័នផ្តល់សេវាយុវជន អ្នកអប់រំ ប្រជាពលរដ្ឋ អង្គការនៅតាមសហគមន៍ សម្ព័ន្ធភាព និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីដោះស្រាយបញ្ហាលំនៅឋាន ការថែទាំសុខភាព ការប្រើប្រាស់សារធាតុញៀន និងបញ្ហាសុខភាពផ្លូវចិត្តពាក់ព័ន្ធនឹងការបង្ការ និងអន្តរាគមន៍លើអំពើហិង្សា និង (iii) ផ្តល់អនុសាសន៍ឱ្យមានការផ្លាស់ប្តូរនានា ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព លទ្ធភាពទទួលបានសេវា និងការប្រើប្រាស់ជាប្រយោជន៍ ដោយមានគោលដៅចុងក្រោយក្នុងការបង្កើនប្រសិទ្ធភាពសេវាកម្មបង្ការអំពើហិង្សា និងកាត់បន្ថយផលប៉ះពាល់មិនសមាមាត្រនៃអំពើហិង្សានៅក្នុងសហគមន៍ដែលរងគ្រោះជាប្រវត្តិសាស្ត្រ។

(d) គណៈកម្មការនីតិប្បញ្ញត្តិពិសេសនេះ ត្រូវដាក់ជូនរបាយការណ៍ពីការសិក្សា និងអនុសាសន៍របស់ខ្លួន រួមជាមួយនឹងច្បាប់ណាមួយ ទៅប្រធានរដ្ឋសភានិងព្រឹទ្ធសភា ឱ្យបានមុន ឬយ៉ាងយូរបំផុតត្រឹមថ្ងៃទី 1 ខែមីនា ឆ្នាំ 2025។

មាត្រា 150 (a) តាមរយៈខ្លឹមសារនេះ គណៈកម្មការនីតិប្បញ្ញត្តិពិសេសមួយត្រូវ

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

បានបង្កើតឡើងស្របតាមមាត្រា 2A ក្នុងជំពូក 4 នៃច្បាប់ទូទៅ ដើម្បីសិក្សាអំពីការប្រមូល ការថែរក្សា ការទទួលបាន ការចូលប្រើប្រាស់ និងការចែកចាយទិន្នន័យអាវុធដោយរដ្ឋម៉ាសាឈូសិត។

(b) គណៈកម្មការនីតិប្បញ្ញត្តិពិសេសត្រូវស៊ើបអង្កេត និងផ្តល់អនុសាសន៍សម្រាប់ការកែលម្អចំពោះរបៀបដែលទិន្នន័យអាវុធ៖ (i) ត្រូវបានប្រមូលតាមរយៈការរាយការណ៍អំពីការកាន់កាប់ និងការផ្ទេរអាវុធ និងគ្រឿងបង្កុំអាវុធផ្សេងៗ រួមទាំងការលក់ដោយអាជីវករលក់អាវុធមានអាជ្ញាបណ្ណ ការផ្ទេរដោយអ្នកមិនមែនជាអាជីវករលក់រាយ និងអាវុធដែលបាត់បង់ ឬត្រូវបានគេលួច ព្រមទាំងរបៀបដែលការប្រមូលទិន្នន័យបែបនេះនឹងត្រូវរងផលប៉ះពាល់ដោយលក្ខខណ្ឌត្រូវចុះបញ្ជី រាយការណ៍ និងវាយលេខស៊េរីដែលបានចែងនៅក្នុងច្បាប់នេះ។ (ii) ត្រូវបានរក្សាទុក និងចែកចាយដោយទីភ្នាក់ងាររដ្ឋ រួមទាំងនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ។ (iii) ត្រូវបានចែករំលែករវាងទីភ្នាក់ងារសហព័ន្ធ រដ្ឋ និងតំបន់ រួមទាំងកិច្ចខិតខំប្រឹងប្រែងក្នុងការស្វែងរកប្រភពដើមរបស់អាវុធ និងការតាមដានអាវុធដែលត្រូវបានប្រើប្រាស់ក្នុងការប៉ុនប៉ងធ្វើអត្តឃាត ឬការធ្វើអត្តឃាតបានសម្រេច។ (iv) ត្រូវបានចូលមើល និងប្រើប្រាស់ដោយអាជ្ញាធរផ្តល់អាជ្ញាបណ្ណ ដូចមានចែងក្នុងមាត្រា 121 នៃជំពូកទី 140 នៃច្បាប់ទូទៅ រួមទាំងការពិនិត្យដំណើរការកម្មវិធីសុំអាជ្ញាបណ្ណអាវុធ ការស៊ើបអង្កេតលើបុគ្គលដែលត្រូវបានហាមឃាត់ និងភាពមិនសមស្រប ការទទួលការជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់អ្នកទទួលអាជ្ញាបណ្ណ និងការដកហូតអាវុធដោយអនុលោមតាមដីកាការពារហានិភ័យបន្ទាន់ និង (v) ត្រូវបានរាយការណ៍ដោយទីភ្នាក់ងាររដ្ឋទៅស្ថាប័ននីតិប្បញ្ញត្តិ ឬអ្នកស្រាវជ្រាវ ក្រោមមាត្រា 18 ¾ ក្នុងជំពូក 6A នៃច្បាប់ទូទៅ និងមាត្រា 131Q ក្នុងជំពូក 140 នៃច្បាប់ទូទៅ ឬត្រូវបានអនុញ្ញាតឱ្យសាធារណជនអាចចូលប្រើប្រាស់បានក្រោមមាត្រា 121E នៃជំពូកទី 140 ដដែលនោះ។ គណៈកម្មការពិសេសត្រូវផ្តល់អនុសាសន៍បន្ថែមទៀតលើការពង្រឹង និងការបំភ្លឺឱ្យបានច្បាស់លាស់អំពីលក្ខន្តិក និងលក្ខខណ្ឌ តម្រូវនៃការរាយការណ៍ទិន្នន័យអាវុធដែលមានស្រាប់។

(c) គណៈកម្មការនីតិប្បញ្ញត្តិពិសេសត្រូវមានសមាជិកចំនួន 15 រូប រួមមាន៖ ប្រធានគណៈកម្មាធិការចម្រុះទទួលបន្ទុកសន្តិសុខសាធារណៈនិងសន្តិសុខមាតុភូមិ ឬតំណាងចាត់តាំងរបស់ពួកគេ ដែលត្រូវធ្វើជាសហប្រធាន, រដ្ឋមន្ត្រីក្រសួងសន្តិសុខ និងសុវត្ថិភាពសាធារណៈ ឬតំណាងដែលបានចាត់តាំង, រដ្ឋមន្ត្រីក្រសួងសេវាបច្ចេកវិទ្យានិងសន្តិសុខ ឬតំណាងដែលបានចាត់តាំង, អគ្គរដ្ឋអាជ្ញា ឬតំណាងដែលបានចាត់តាំង, សមាជិក 1 រូបតែងតាំងដោយប្រធានរដ្ឋសភា ដែលត្រូវជាអ្នកជំនាញខាងប្រមូល និងវិភាគទិន្នន័យ, សមាជិក 1 រូបតែងតាំងដោយប្រធានព្រឹទ្ធសភា ដែលត្រូវជាអ្នកជំនាញខាងប្រមូលនិងវិភាគទិន្នន័យ, សមាជិក 1 រូបតែងតាំងដោយមេដឹកនាំសំឡេងភាគតិចនៃរដ្ឋសភា, សមាជិក 1 រូបតែងតាំងដោយមេដឹកនាំសំឡេងភាគតិចនៃព្រឹទ្ធសភា, ស្នងការប៉ូលិសរដ្ឋ ឬតំណាងដែលបានចាត់តាំង, ប្រធានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ឬតំណាងដែលបានចាត់តាំង, សមាជិក 1 រូបតែងតាំងដោយសមាគមរដ្ឋអាជ្ញាប្រចាំមណ្ឌលរបស់រដ្ឋម៉ាសាឈូសិត (Massachusetts District Attorneys Association), និងសមាជិក 3 រូបតែងតាំងដោយអភិបាលរដ្ឋ ដែលក្នុងនោះ 1 រូបត្រូវជាមេប៉ូលិសមកពីសហគមន៍ជនបទ ដែលត្រូវបានជ្រើសរើសចេញពីបញ្ជីបេក្ខជន 3 រូប ផ្តល់ដោយសមាគមមេប៉ូលិសរដ្ឋម៉ាសាឈូសេត (Massachusetts Chiefs of Police Association) 1 រូបត្រូវជាមេប៉ូលិសមកពីសហគមទីក្រុង ឬជាយក្រុង ដែលត្រូវបានជ្រើសរើសចេញពីបញ្ជីបេក្ខជន 3 រូប ផ្តល់ដោយសមាគមមេប៉ូលិសរដ្ឋម៉ាសាឈូសិត និង 1 រូបទៀត ត្រូវជាអ្នកជំនាញខាងប្រមូល និងវិភាគទិន្នន័យ។

(d) គណៈកម្មការនេះត្រូវដាក់ជូនរបាយការណ៍ ព្រមទាំងអនុសាសន៍ផ្នែកនីតិប្បញ្ញត្តិ ឬបទប្បញ្ញត្តិណាមួយ ទៅគណៈកម្មាធិការថវិកា និងមធ្យោបាយហិរញ្ញវត្ថុ នៃរដ្ឋសភានិងព្រឹទ្ធសភា និងទៅប្រធានរដ្ឋសភានិងព្រឹទ្ធសភា ឱ្យបានមុន ឬត្រឹមថ្ងៃទី 1 ខែសីហា ឆ្នាំ 2025។

មាត្រា 151 (a) ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយចែងផ្ទុយពីនេះក៏ដោយ ការិយាល័យប្រតិបត្តិសុខាភិបាលនិងសេវាមនុស្សជាតិ ត្រូវបង្កើតក្រុមការងារមួយ ដើម្បីពិនិត្យឡើងវិញនូវលទ្ធភាពទទួលបានមូលនិធិសហព័ន្ធ ដើម្បីគាំទ្រដល់កម្មវិធីបង្ការអំពើហិង្សាក្នុងសហគមន៍ និងដើម្បីផ្តល់អនុសាសន៍ក្នុងការបង្កើនមូលនិធិសហព័ន្ធជាអតិបរមា ប្រកបដោយសមធម៌ ដែលគាំទ្រដល់ការផ្តល់សេវាបង្ការអំពើហិង្សាក្នុងសហគមន៍នៅទូទាំងរដ្ឋម៉ាសាឈូសិត។ ក្រុមការងារនេះត្រូវមានសមាជិក៖ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសេវាមនុស្សជតិ ឬតំណាងចាត់តាំង ដែលត្រូវធ្វើជាប្រធាន, ប្រធាននាយកដ្ឋានសុខភាពសាធារណៈ ឬតំណាងដែលបានចាត់តាំង, នាយកកម្មវិធីជំនួយវេជ្ជសាស្ត្រ (Medicaid) ឬតំណាងដែលបានចាត់តាំង, និងបុគ្គលចំនួន 9 រូបតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសេវាមនុស្សជាតិ ដែលក្នុងនោះ 2 រូបត្រូវតំណាងឱ្យអង្គការនានាដែលធ្លាប់បានទទួលមូលនិធិជំនួយតាមរយៈគំនិតផ្តួចផ្តើមយុវជនប្រកបដោយសុវត្ថិភាព និងជោគជ័យ (Safe and Successful Youth Initiative) 2 រូបត្រូវតំណាងឱ្យអ្នកទទួលមូលនិធិជំនួយសម្រាប់ការបង្ការអំពើហិង្សាដោយអាវុធតាមរយៈនាយកដ្ឋានសុខភាពសាធារណៈ 2 រូបត្រូវជាបុគ្គលដែលមានបទពិសោធន៍ផ្ទាល់ក្នុងជីវភាពដែលមានផលប៉ះពាល់ពីអំពើហិង្សាក្នុងសហគមន៍ ដែលក្នុងនោះយ៉ាងហោចណាស់ 1 រូបត្រូវតែធ្លាប់បានទទួលសេវាពីកម្មវិធីអន្តរាគមន៍ ឬបង្ការអំពើហិង្សាក្នុងសហគមន៍ 1 រូបតំណាងឱ្យមន្ទីរពេទ្យដែលបច្ចុប្បន្នកំពុងដំណើរការកម្មវិធីបង្ការអំពើហិង្សានៅតាមមន្ទីរពេទ្យក្នុងរដ្ឋនេះ 1 រូបតំណាងឱ្យមន្ទីរពេទ្យនៅក្នុងរដ្ឋនេះដែលបច្ចុប្បន្នមិនទាន់ដំណើរការកម្មវិធីបង្ការអំពើហិង្សានៅតាមមន្ទីរពេទ្យ និង 1 រូបទៀត តំណាងឱ្យគ្លីនិកវិទូថែទាំសុខភាពផ្លូវចិត្តនិងអាកប្បកិរិយា ដែលមានបទពិសោធន៍ក្នុងការផ្តល់ការថែទាំផ្អែកលើការយល់ដឹងពីផលប៉ះទង្គិចផ្លូវចិត្ត។

(b) ក្រុមការងារត្រូវពិចារណាអំពី៖ (i) ថាថវិកាសហព័ន្ធអាចត្រូវបានយកទៅប្រើប្រាស់ប្រកបដោយសមធម៌សម្រាប់កម្មវិធីបង្ការអំពើហិង្សាក្នុងសហគមន៍ ទាំងនៅក្នុងមជ្ឈដ្ឋានពិនិត្យព្យាបាល និងមជ្ឈដ្ឋានមិនមែនពិនិត្យព្យាបាល នៅទូទាំងតំបន់ភូមិសាស្ត្រ (ii) សមត្ថភាពនៃកម្មវិធីបង្ការនិងអន្តរាគមន៍អំពើហិង្សាក្នុងសហគមន៍ដែលមានស្រាប់ ក្នុងការអនុវត្តតាមលក្ខខណ្ឌសហព័ន្ធណាមួយ ដើម្បីឱ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានហិរញ្ញប្បទាន និង (iii) ផលប៉ះពាល់ណាមួយដែលហិរញ្ញប្បទានសហព័ន្ធអាចមានលើគំរូផ្តល់សេវាបង្ការអំពើហិង្សានៅក្នុងរដ្ឋម៉ាសាឈូសិត។

(c) ក្រុមការងារត្រូវដាក់ជូនអនុសាសន៍របស់ខ្លួនទៅអភិបាលរដ្ឋ និងប្រធានរដ្ឋសភា និងព្រឹទ្ធសភា ឱ្យបានមុន ឬត្រឹមថ្ងៃទី 2 ខែធ្នូ ឆ្នាំ 2024។

(d) ប្រសិនបើក្រុមការងារផ្តល់អនុសាសន៍ថា រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងសេវាមនុស្សជាតិ គួរតែបន្តស្វែងរកការធ្វើវិសោធនកម្មលើផែនការកម្មវិធីជំនួយវេជ្ជសាស្ត្រ (Medicaid State Plan) របស់រដ្ឋ និងស្វែងរកការអនុម័តពីសហព័ន្ធដែលចាំបាច់

## សំណួរទី 9៖ អត្ថបទទាំងស្រុងនៃច្បាប់ដែលមានស្រាប់ (ត)

ណាមួយដើម្បីទទួលបានមូលនិធិសហព័ន្ធក្នុងការគាំទ្រដល់ការទទួលបានសេវាបង្ការអំពើហិង្សាក្នុងសហគមន៍ប្រកបដោយសមធម៌ នោះរដ្ឋមន្ត្រីត្រូវបន្តអនុវត្តការធ្វើវិសោធនកម្មបែបនេះ ហើយត្រូវស្វែងរកការអនុម័តពីសហព័ន្ធស្រដៀងគ្នានេះ ដោយអនុលោមតាមអនុសាសន៍ និងការរកឃើញរបស់ក្រុមការងារ។

មាត្រា 152 ទោះបីជាមានច្បាប់ទូទៅ ច្បាប់ពិសេស វិធាន ឬបទប្បញ្ញត្តិណាមួយចែងផ្ទុយពីនេះក៏ដោយ រដ្ឋមន្ត្រីក្រសួងសន្តិសុខនិងសុវត្ថិភាពសាធារណៈ ឬតំណាងដែលបានចាត់តាំង ត្រូវសិក្សានិងរាយការណ៍ជូនស្ថាប័ននីតិប្បញ្ញត្តិអំពីអនុសាសន៍នានាដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃការហ្វឹកហាត់បាញ់អាវុធពិតដែលតម្រូវស្របតាមមាត្រា 131P ក្នុងជំពូក 140 នៃច្បាប់ទូទៅ។ របាយការណ៍ដែលបានលើកឡើងខាងលើនេះ ត្រូវរួមបញ្ចូលជាអាទិ៍នូវអនុសាសន៍ណាមួយដើម្បីធានាថា ការហ្វឹកហាត់បែបនេះមិនក្លាយជាឧបសគ្គថ្លៃចំណាយ និងធានាថាធនធានព្រមទាំងទីតាំងសម្រាប់បម្រើដល់ការហ្វឹកហាត់នោះ មានលក្ខណៈគ្រប់គ្រាន់ និងអាចឱ្យបុគ្គលគ្រប់រូបនៅក្នុងគ្រប់តំបន់របស់រដ្ឋ ចូលប្រើប្រាស់បានដោយសមស្រប។ មុនពេលចេញផ្សាយរបាយការណ៍ និងអនុសាសន៍បែបនេះ រដ្ឋមន្ត្រី ឬតំណាងដែលបានចាត់តាំង ត្រូវរៀបចំសវនាការសាធារណៈយ៉ាងហោចណាស់ចំនួន 2 ដង នៅក្នុងតំបន់ខុសៗគ្នារបស់រដ្ឋ ដើម្បីប្រមូលមតិយោបល់ពីសាធារណជន ពាក់ព័ន្ធនឹងការអនុវត្តលក្ខខណ្ឌ តម្រូវនៃការហ្វឹកហាត់បាញ់អាវុធពិតនេះ។ របាយការណ៍ និងអនុសាសន៍ណាមួយ ត្រូវដាក់ជូនប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា ប្រធានគណៈកម្មាធិការចម្រុះទទួលបន្ទុកប្រព័ន្ធតុលាការរបស់រដ្ឋសភា និងព្រឹទ្ធសភា (Senate and House Chairs of the Joint Committee on the Judiciary) និងប្រធានគណៈកម្មាធិការចម្រុះទទួលបន្ទុកសន្តិសុខសាធារណៈរបស់រដ្ឋសភានិងព្រឹទ្ធសភា (Senate and House Chairs of the Joint Committee on Public Safety) ឱ្យបានមុន ឬត្រឹមរយៈពេល 9 ខែ គិតចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន។

មាត្រា 153 អាជ្ញាបណ្ណដែលមានសុពលភាពក្នុងការកាន់កាប់អាវុធ ដែលត្រូវបានចេញឱ្យក្រោមមាត្រា 131 ឬ 131F ក្នុងជំពូក 140 នៃច្បាប់ទូទៅ ប័ណ្ណសម្គាល់អាវុធដែលមានសុពលភាពក្រោមមាត្រា 129B នៃជំពូក 140 ដដែលនោះ ឬអាជ្ញាបណ្ណលក់ដែលមានសុពលភាពក្រោមមាត្រា 122 នៃជំពូកទី 140 ដដែលនោះ ត្រូវរក្សាសុពលភាពរហូតដល់ផុតកំណត់ មានការផ្អាកជាបណ្តោះអាសន្ន ឬមានការដកហូតអាជ្ញាបណ្ណដែលបានលើកឡើងនោះ ហើយត្រូវផ្តល់សិទ្ធិឱ្យអ្នកកាន់កាប់អាចមានសិទ្ធិធ្វើជាម្ចាស់អាវុធនានាដែលត្រូវបានអនុញ្ញាតដោយអាជ្ញាបណ្ណ នៅត្រឹមពេលដែលអាជ្ញាបណ្ណនោះត្រូវបានចេញឱ្យ ឬបន្តសុពលភាពចុងក្រោយបង្អស់។

មាត្រា 154 មិនឱ្យហួសពី 6 ខែ បន្ទាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ត្រូវជូនដំណឹងដល់បុគ្គលទាំងឡាយណាដែលមានអាជ្ញាបណ្ណកាន់កាប់អាវុធ និងបណ្ណសម្គាល់អាវុធដែលមានសុពលភាពនៅថ្ងៃច្បាប់នេះចូលជាធរមាន អំពីលក្ខខណ្ឌនានាក្រោមមាត្រា 121B និង 121C ក្នុងជំពូក 140 នៃច្បាប់ទូទៅ ដូចដែលបានបញ្ចូលដោយមាត្រា 32។

មាត្រា 155 (a) មិនឱ្យហួសពី 6 ខែ បន្ទាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ត្រូវប្រកាសឱ្យប្រើប្រាស់បទប្បញ្ញត្តិនានាដែលតម្រូវដោយមាត្រា 121B ក្នុងជំពូក 140 នៃច្បាប់ទូទៅ ដូចដែលបានបញ្ចូលដោយមាត្រា 32។

(b) មិនឱ្យហួសពី 6 ខែ បន្ទាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ការិយាល័យប្រតិបត្តិសន្តិសុខនិងសុវត្ថិភាពសាធារណៈ ដោយពិគ្រោះយោបល់ជាមួយនាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវប្រកាសឱ្យប្រើប្រាស់បទប្បញ្ញត្តិនានាដែលតម្រូវដោយមាត្រា 121C នៃជំពូក 140 ដដែលនោះ ដូចដែលបានបញ្ចូលដោយមាត្រា 32។

មាត្រា 156 មិនឱ្យហួសពី 1 ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវបង្កើតផ្ទាំងព័ត៌មានអនឡាញ និងបោះពុម្ពផ្សាយទិន្នន័យអាវុធដែលតម្រូវដោយកថាខណ្ឌ (c) នៃមាត្រា 121E ក្នុងជំពូក 140 នៃច្បាប់ទូទៅ ដូចដែលបានបញ្ចូលដោយមាត្រា 32។

មាត្រា 157 នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវបង្កើតប្រព័ន្ធចុះបញ្ជីអាវុធតាមប្រព័ន្ធអេឡិចត្រូនិក ដែលបង្កើតឡើងស្របតាមមាត្រា 121B ក្នុងជំពូក 140 នៃច្បាប់ទូទៅ ដូចដែលបានបញ្ចូលដោយមាត្រា 32 មិនឱ្យហួសពី 1 ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ប៉ុន្តែ អាវុធទាំងអស់ត្រូវតែចុះបញ្ជីឱ្យបានត្រឹមត្រូវតាមច្បាប់នេះ និងមិនឱ្យហួសពី 1 ឆ្នាំ បន្ទាប់ពីប្រព័ន្ធចុះបញ្ជីអាវុធតាមប្រព័ន្ធអេឡិចត្រូនិកដែលបានលើកឡើងខាងលើនេះ ត្រូវបានបញ្ចប់រួចរាល់ និងដាក់ឱ្យប្រើប្រាស់ជាសាធារណៈ។

មាត្រា 158 នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវបង្កើតប្រព័ន្ធចុះបញ្ជីអាវុធតាមប្រព័ន្ធអេឡិចត្រូនិក ដែលបង្កើតឡើងស្របតាមមាត្រា 121C ក្នុងជំពូកទី 140 នៃច្បាប់ទូទៅ ដូចដែលបានបញ្ចូលដោយមាត្រា 32 មិនឱ្យហួសពី 1 ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន ប៉ុន្តែ អាវុធទាំងអស់ត្រូវតែចុះបញ្ជីឱ្យបានត្រឹមត្រូវតាមច្បាប់នេះ និងមិនឱ្យហួសពី 1 ឆ្នាំ បន្ទាប់ពីប្រព័ន្ធស្នើសុំលេខសេរីដែលបានពោល ត្រូវបានបញ្ចប់រួចរាល់ និងដាក់ឱ្យប្រើប្រាស់ជាសាធារណៈ។

មាត្រា 159 មាត្រា 38 និងមាត្រា 75 ត្រូវចូលជាធរមានក្នុងរយៈពេល 18 ខែ បន្ទាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន។

# ការបម្រើការងាររបស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ

ការិយាល័យរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋមានផ្នែកជាច្រើន ដែលផ្តល់សេវាកម្មផ្សេងៗគ្នាដល់ប្រជាពលរដ្ឋនៃរដ្ឋម៉ាសាឈូសិត។ ខាងក្រោមនេះគឺជាបញ្ជីនៃផ្នែកមួយចំនួនដែលអាចជួយអ្នកបាន។

ស្វែងរកព័ត៌មានអំពីផ្នែកទាំងអស់របស់ការិយាល័យរដ្ឋមន្ត្រី គេហទំព័រ **www.sec.state.ma.us.**

**សេវាព័ត៌មានប្រជាពលរដ្ឋ (Citizen Information Service - CIS)** របស់ការិយាល័យរដ្ឋមន្ត្រី មានតួនាទីជាទីភ្នាក់ងារព័ត៌មាន និងបញ្ជូនសំណើសុំជំនួយសំខាន់ៗរបស់រដ្ឋ ដោយផ្តល់ព័ត៌មានអំពីកម្មវិធី និងទីភ្នាក់ងាររដ្ឋនានា។ CIS ក៏ផ្តល់ឯកសារអប់រំជាច្រើនស្តីពីប្រធានបទសំខាន់ៗសម្រាប់ប្រជាពលរដ្ឋរដ្ឋម៉ាសាឈូសិត រួមមាន៖

- រដ្ឋម៉ាសាឈូសិតសូមស្វាគមន៍៖ មគ្គុទ្ទេសក៍ជាក់ស្តែងសម្រាប់ការរស់នៅក្នុងរដ្ឋនេះ
- មគ្គុទ្ទេសក៍ច្បាប់ និងអត្ថប្រយោជន៍សម្រាប់អតីតយុទ្ធជន
- ពន្ធគយលើយានយន្ត
- លំនៅឋានដែលមានសុវត្ថិភាព និងមានអនាម័យសម្រាប់ប្រជាពលរដ្ឋរដ្ឋម៉ាសាឈូសិត
- និងឯកសារជាច្រើនទៀត!

ទូរសព្ទ 617-727-7030 ឬ 1-800-392-6090
អ៊ីមែល៖ cis@sec.state.ma.us

**ផ្នែកសន្តិសុខ** ធ្វើការងារដើម្បីការពារវិនិយោគិនក្នុងរដ្ឋម៉ាសាឈូសិត។

ទូរសព្ទ 617-727-3548 ឬ 1-800-269-5428
អ៊ីមែល៖ securities@sec.state.ma.us

**ផ្នែកបោះឆ្នោត** គ្រប់គ្រងការរៀបចំការបោះឆ្នោតរដ្ឋទាំងអស់ និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោត។

ទូរសព្ទ 617-727-2828 ឬ 1-800-462-VOTE (8683)
អ៊ីមែល៖ elections@sec.state.ma.us

**ផ្នែកឯកសារសាធារណៈ** គ្រប់គ្រងការអនុវត្តច្បាប់ស្តីពីឯកសារសាធារណៈរបស់រដ្ឋ និងជួយអ្នកដែលកំពុងស្វែងរកឯកសារផ្សេងៗ។

ទូរសព្ទ 617-727-2832
អ៊ីមែល៖ pre@sec.state.ma.us

**ផ្នែកគណៈកម្មការនានា** គ្រប់គ្រងការស្បថចូលកាន់តំណែង និងបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារសម្រាប់ប្រើប្រាស់នៅក្រៅប្រទេស។

ទូរសព្ទ 617-727-2836
អ៊ីមែល៖ comm@sec.state.ma.us

**ផ្នែកសាជីវកម្ម** ទទួលខុសត្រូវលើការចុះបញ្ជីអង្គភាពអាជីវកម្មដែលរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញនៅក្នុងរដ្ឋម៉ាសាឈូសិត។

ទូរសព្ទ 617-727-9640
អ៊ីមែល៖ corpinfo@sec.state.ma.us

**បណ្ណសាររដ្ឋម៉ាសាឈូសិត** ប្រមូល រៀបចំកាតាឡុក និងរក្សាទុកឯកសារដែលមានតម្លៃយូរអង្វែងពីប្រវត្តិសាស្ត្ររដ្ឋ និងរដ្ឋាភិបាលសម័យអាណានិគមជិត 400 ឆ្នាំ។

ទូរសព្ទ 617-727-2816
អ៊ីមែល៖ archives@sec.state.ma.us

**សារមន្ទីររដ្ឋម៉ាសាឈូសិត** ធ្វើឱ្យប្រវត្តិសាស្ត្ររដ្ឋម៉ាសាឈូសិតមានភាពរស់រវើកឡើង តាមរយៈការតាំងពិព័រណ៍ និងកម្មវិធីសម្រាប់សិស្សានុសិស្ស។

ទូរសព្ទ 617-727-9268
គេហទំព័រ៖ www.CommonwealthMuseum.org

**ផ្នែកទស្សនាចរណ៍វិមានរដ្ឋ** ផ្តល់ជូនដំណើរទស្សនកិច្ចដោយឥតគិតថ្លៃនៅក្នុងវិមានរដ្ឋម៉ាសាឈូសិតជាប្រវត្តិសាស្ត្រដល់ភ្ញៀវមកពីទូទាំងរដ្ឋម៉ាសាឈូសិត និងពីជុំវិញពិភពលោក។

ទូរសព្ទ 617-727-3676
អ៊ីមែល៖ MAStateHouseTours@sec.state.ma.us

**គណៈកម្មការប្រវត្តិសាស្ត្ររដ្ឋម៉ាសាឈូសិត** មានរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋធ្វើជាប្រធាន ហើយមានភារកិច្ចទទួលខុសត្រូវលើការអភិរក្សទីតាំង និងបេតិកភណ្ឌប្រវត្តិសាស្ត្រនៅក្នុងរដ្ឋម៉ាសាឈូសិត។

ទូរសព្ទ 617-727-8470
អ៊ីមែល៖ mhc@sec.state.ma.us

## ផ្នែកផ្សេងទៀត រួមមាន៖

### ផ្នែកអ្នកបញ្ចុះបញ្ចូល

ទូរសព្ទ 617-727-9122
អ៊ីមែល៖ lob@sec.state.ma.us

### ផ្នែកបោះពុម្ពផ្សាយ និងបទប្បញ្ញត្តិរដ្ឋ

ទូរសព្ទ 617-727-2831
អ៊ីមែល៖ regulations@sec.state.ma.us

# ✓ បញ្ជីត្រួតពិនិត្យអ្នកបោះឆ្នោត

សូមហែកចេញ ហើយកាន់យកទៅកន្លែងបោះឆ្នោត។

**សំណួរនៅលើសន្លឹកឆ្នោត ▶**

សំណួរទី 1 ☐ យល់ព្រម ☐ មិនយល់ព្រម
សំណួរទី 2 ☐ យល់ព្រម ☐ មិនយល់ព្រម
សំណួរទី 3 ☐ យល់ព្រម ☐ មិនយល់ព្រម
សំណួរទី 4 ☐ យល់ព្រម ☐ មិនយល់ព្រម
សំណួរទី 5 ☐ យល់ព្រម ☐ មិនយល់ព្រម
សំណួរទី 6 ☐ យល់ព្រម ☐ មិនយល់ព្រម
សំណួរទី 7 ☐ យល់ព្រម ☐ មិនយល់ព្រម
សំណួរទី 8 ☐ យល់ព្រម ☐ មិនយល់ព្រម
សំណួរទី 9 ☐ យល់ព្រម ☐ មិនយល់ព្រម

**មុខតំណែងនៅលើសន្លឹកឆ្នោត ▶** **មុខតំណែងនៅលើសន្លឹកឆ្នោតឆ្នាំ 2026 លេចឡើងតាមលំដាប់ដូចខាងក្រោម៖**

សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក ____________________

អភិបាលរដ្ឋ និងអភិបាលរងរដ្ឋ ____________________

អគ្គរដ្ឋអាជ្ញា ____________________

លេខាធិការរដ្ឋ ____________________

ហេរញ្ញិក ____________________

សវនករ ____________________

សមាជិកក្រុមប្រឹក្ស ____________________

តំណាងរាស្ត្រសហរដ្ឋអាមេរិក ____________________

សមាជិកព្រឹទ្ធសភាប្រចាំរដ្ឋម៉ាសាឈូសិត ____________________

តំណាងរាស្ត្ររដ្ឋម៉ាសាឈូសិត ____________________

រដ្ឋអាជ្ញាប្រចាំតំបន់ ____________________

ប្រធានការិយាល័យចុះបញ្ជីគ្រួសារនិងមរតក ____________________

ហិរញ្ញិកខោនធី ____________________
*(សម្រាប់ខោនធី Bristol, Norfolk និង Plymouth ប៉ុណ្ណោះ)*

សមាជិកក្រុមប្រឹក្សាភិបាលប្រចាំខោនធី ____________________
*(សម្រាប់ខោនធី Barnstable, Bristol, Dukes, Norfolk និង Plymouth តែប៉ុណ្ណោះ)*
*ឬ ក្រុមប្រឹក្សាភិបាលនៃខោនធី Franklin (សម្រាប់ខោនធី Franklin County តែប៉ុណ្ណោះ)*

មន្ត្រីនគរបាលប្រចាំខោនធី ____________________
*(សម្រាប់ខោនធី Franklin ប៉ុណ្ណោះ)*

**William Francis Galvin**
**រដ្ឋលេខាធិការនៃរដ្ឋម៉ាសាឈូសិត**
One Ashburton Place, Room 1705
Boston, MA 02108

អង្គការមិនស្វែងរកប្រាក់ចំណេញ
ECRWSS
ប្រៃសណីយ៍សហរដ្ឋអាមេរិក
(U.S. Postage)
**បង់ប្រាក់រួច**
រដ្ឋមន្ត្រីកិច្ចការរដ្ឋ
រដ្ឋម៉ាសាឈូសិត

OFFICIAL ELECTION MAIL
Authorized by the U.S. Postal Service ®

**ឯកសារផ្លូវការ**

# *អ្នកបោះឆ្នោតដែលរស់នៅតាមផ្ទះលំនៅឋាន*

**ព័ត៌មានសម្រាប់អ្នកបោះឆ្នោត** ត្រូវបានផ្ញើតាមប្រៃសណីយ៍ទៅកាន់អ្នកបោះឆ្នោតតាមអាសយដ្ឋានលំនៅឋាន ទៅកាន់អ្នកបោះឆ្នោតដែលរស់នៅក្នុងទីតាំងស្នាក់នៅជាក្រុម និងទៅកាន់ទីតាំងសាធារណៈដែលងាយស្រួលប្រើប្រាស់នៅទូទាំងរដ្ឋម៉ាសាឈូសិត។ ច្បាប់ចម្លងបន្ថែមមានចំនួនកំណត់ អាចទទួលបាននៅសាលាក្រុង និងសាលតំបន់មូលដ្ឋាន ព្រមទាំងបណ្ណាល័យមួយចំនួន ឬដោយហៅទូរសព្ទទៅផ្នែកបោះឆ្នោតរបស់រដ្ឋមន្ត្រី Galvin តាមលេខ 617-727-2828 ឬ 1-800-462-VOTE (8683) ឬហៅទៅផ្នែកសេវាព័ត៌មានប្រជាពលរដ្ឋ តាមលេខ 617-727-7030 ឬ 1-800-392-6090។ អ្នកប្រើប្រាស់ TTY អាចទាក់ទង MassRelay តាមលេខ 800-720-3480។ សូមប្រាកដថាបានចូលមើលគេហទំព័ររបស់យើងនៅ៖ **www.sec.state.ma.us** កំណែអត្ថបទជាភាសាអេស្ប៉ាញ ចិន វៀតណាម និងខ្មែរ នៃឯកសារព័ត៌មានសម្រាប់អ្នកបោះឆ្នោត ព្រមទាំងកំណែជាអក្សរធំសម្រាប់អ្នកមានបញ្ហាភ្នែក ក៏អាចរកបានតាមលេខទូរសព្ទដូចគ្នាខាងលើផងដែរ។ កំណែជាសំឡេងក៏មានផ្តល់ជូនពីបណ្ណាល័យ Perkins នៅទីក្រុង Watertown តាមលេខ 1-800-852-3133។

♻ បោះពុម្ពលើក្រដាសអាចកែច្នៃឡើងវិញ